បណ្ណាល័យ LIBRARY
COMMISSION DES MOEURS & COUTUMES

ទស្សនាវដ្តី ផ្សាយដំណើរនិងការសិក្សា នៃគណៈកម្មការស្រាវជ្រាវ ទេសចរណ៍ប្រពៃណី
និងភូមិសាស្ត្រមនុស្សជាតិ

ចំណាត់ការ ផ្នែកគណៈកម្មការស្រាវជ្រាវ ហ្វូងទំនៀមទម្លាប់ ញ៉ុក - ថែម, ប្រធានផ្នែក
ពុទ្ធសាសនបណ្ឌិត្យ

កម្រងអត្ថបទ ផ្នែកដំណាក់កាលសាសនា : ព្រៃវត្តីស្ថិតក្នុងញាណ ស្មារ - ភោយ
ក្រុមដំណើរព្រៃវត្តីចំនិត នៅពុទ្ធសាសនបណ្ឌិត្យ

មាតិកា

ផ្នែកអក្សរសាស្ត្រ ទំព័រ

ហ្វូងទំនៀមទម្លាប់ ញ៉ុក - ថែម
ពាក្យ ជាះពួនដែងប្រែវត្តីសង្ខេបប្រែទេសចំនួន.... ១
ពាក្យជាះពួនដែងភ្លូមិសាស្ត្រសាកល..... ២០
អ្នកនិពន្ធ ញ៉ុក ទេពតិត្ថរឈើម ព្រៃសេម ប្រែវត្តីភ្លេងមហោរី និងមហោរីតាមពាក្យ.... ៣៣
លោក ភិយ - ប៊ុត សម្រាយបញ្ហាដែន ព្រឿង ស៊ីន - យ៉ាត - សេន អ្នកនយោបាយឯក
ជាតិចិន..... ៤៩
ឃុនសុខ - មេធី ភ្លេង - សៀង ឯកសារ សាត្រី ភាគទី ១៤ (តពីលេខ ១២
ឆ្នាំ ១៩៤៣)..... ៤៧

ផ្នែកសាសនា

ព្រះគ្រូបញ្ញាលំទិត ភៅ សិទ្ធ
ព្រឹទ្ធបង្គ្រៀនសាសនាចារ្យ ឃុវ៉ែលយ៉ាតថា (តពីលេខ ១១ ឆ្នាំ ១៩៤៣) ៥៤
លោកអគ្គមហា សេរ៉ី សុវ៉ាត្ថស្វាយ សុភាសិត និងការពោលទិដ្ឋ (តពីលេខ ១២
ពោះសុទិន ជំនាន់ចាស ឆ្នាំ ១៩៤៣)..... ៥១

KAMPUCHEASORIYA

Revue religieuse et littéraire éditée par l'Institut Bouddhique.

Rédacteur en chef de la partie littéraire : Luong Niponmontrey Nhok-Thèm, Pandit à l'Institut Bouddhique.

Rédacteur en chef de la partie religieuse : Vénérable Préah kru Suvaddhañāna So-Hay membre la Commission du Tripitaka

TABLE DES MATIÈRES

Partie littéraire :

		pages
Luong Niponmontrey Nhok-Thém (I.B.)	Préface et histoire sommaire de la Chine	1
—id—	Préface et Géographie Générale . .	29
Oknha Téppitur Chhim-Krasém (I.B.)	Histoire de la musique Khmère dite " Mahori "	33
Monsieur Pay-Buc Chef Comptable (I.B.)	Une épisode de la vie de Sun-Yat-Sen, homme politique Chinois . .	38
Khun Sundaramedhi Nhoung-Sœung (I.B.)	Mille et une nuits facs 14 (suite de nº 12 année 1947	47

Partie religieuse:

Vén. Preah kru Pannalikhit Kao-Sim	Yuvachariyakatha (suite de nº 11 année 1947)	54
Vén. Preah Moha Sao-Liv vat Svay (koh Soutin Kg. Cham)	Suphasit et Daralovad (suite du nº 12 année 1947)	71

20e Année: nº 1 Janvier 1948 — Prix d'abonnement annuel 6$00 .

8-8-67

រឿងប្រវត្តិសាស្ត្រខេមរជាតិ ដែលយើងបានបោះពុម្ពផ្សាយកន្លងមក
សុទ្ធសោះនេះមកទល់ពេលនេះ គឺចាប់តាំងពីឆ្នាំ ១៩៤៨ ដល់ ឆ្នាំ ១៩៦៥ ម្តងៗ
ប៉ុន្តែមានហេតុផលជាច្រើនណាស់ដែរ ដែលធ្វើឲ្យរឿងនេះត្រូវយឺតយូរហួសមក ។ ល ។
បើយើងនឹកឃើញពីផ្លូវដែលរឿងនេះតែងតែបានជួបប្រទះនឹងការលំបាកយ៉ាងខ្លាំងហើយនោះ
ហាក់ដូចជាធ្វើឲ្យចិត្តយើងប្រែប្រួលមិនចង់បោះពុម្ពប្រវត្តិសាស្ត្រនេះ
ទៀតសោះឡើយ ប៉ុន្តែយើងនៅតែមានការចាប់អារម្មណ៍ចង់ឃើញរឿងនេះ
ត្រូវបានបោះពុម្ពផ្សាយជាលើកទីពីរ ដើម្បីឲ្យអ្នកជាម្ចាស់ប្រយោជន៍ជាច្រើន ។ ដោយគ្រាន់តែសង្ឃឹមលើសេចក្តី
ខ្នះខ្នែងដែលមកពីអ្នកជាម្ចាស់ប្រយោជន៍ទាំងនោះ យើងក៏សម្រេចចិត្តយកលុយ
ចេញមកបោះពុម្ពផ្សាយជាលើកទីពីរ ដើម្បីឲ្យអ្នកជាម្ចាស់ប្រយោជន៍ទាំងនោះ
ទទួលបានរឿងនេះ ដែលមិនទាន់បានបោះពុម្ពផ្សាយនោះ ។

ហេតុដូច្នេះ យើងសូមអភ័យទោសជាមុនចំពោះអ្នកអានទាំងឡាយ
ដែលមិនទាន់ទទួលបានរឿងនេះ ដែលយើងបានបោះពុម្ពផ្សាយរួចហើយ
ប្រសិនបើយើងមានលទ្ធភាពនៅឡើយទេ យើងនឹងបោះពុម្ពបន្ថែមទៀត
ដើម្បីឲ្យអ្នកជាម្ចាស់ប្រយោជន៍ទាំងនោះ ទទួលបានរឿងនេះ ។
ម្យ៉ាងវិញទៀត យើងនឹងលើកយកនូវគន្លឹះមួយចំនួនដែលបានកត់ត្រាក្នុងរឿងនេះ
ប្រវត្តិសាស្ត្រនៃជាតិផ្សេងៗ ដែលជាជាតិដែលមានការបោះពុម្ពផ្សាយ
ចំណាយច្រើនសមរម្យ ដូច្នេះការបោះពុម្ពផ្សាយប្រវត្តិសាស្ត្រ
ដែលកត់ត្រាក្នុងរឿងនេះ គឺមានប្រយោជន៍ដល់បងប្អូនរួមជាតិភាគ
ច្រើនមិនខាន ។

ញ៉ាក-ថែម

ប្រវត្តិសាស្ត្រប្រទេសចិនសង្ខេប

ភាគទី ១

វគ្គទី ១

ដើមកំណើតជាតិចិន

ដើមកំណើតជាតិចិនខាងលិចតំបន់ណា ? — ថ្ងៃនេះ អ្នកប្រាជ្ញទាំងឡាយខាងប្រវត្តិសាស្ត្រនៅដដែលថែកត្តាមិនទាន់ដាច់ស្រេច តែដែលពោលត្រូវគ្នាយ៉ាងច្រើនមានៈ ថាពួកចិនចេញមកពីតំបន់ទន្លេកាស្ប៊ែរ ឬសគល់កំណើតចិនខាងលិចនៅភាគតំបន់ទាត់សមុទ្រនេះឯង ប្រហែលមុនពុទ្ធសករាជ ១៨០០ ឆ្នាំ (មុនគ្រិស្តសករាជ ២៣៤៣ ឆ្នាំ) ។ ពួកចិនទាំងនោះលើកគ្រួសារចេញពីតំបន់ដើម ចូលទៅតាំងទៅកាន់តំបន់ភ្នំគង់-គារ៉ា ហើយលើកចេញពីភ្នំគង-គារ៉ា ចូលមកតាំងទៅកាន់ដែនដីចិនសព្វថ្ងៃនេះ ។ តំបន់ដែលចូលមកតាំងនៅដំបូង គឺស្រុកប៉ែចិលីនិងចាន់-ស៊ី តមកទល់ពត្រឹកភាណាខេត្តបេញ្ជាទៅដល់ខេន-ស៊ី, ហ៊ូ-ណាន និងចាន់-ទុង ដែលតាំងទៅខាងលិចនៃខេត្តហ្គាន់ ហូ ហើយលើកឆ្លងខេត្តនេះទៅតាំងនៅចន្លោះខេត្តហ្គាន-ហូ និងហ៊ុក-សេ ដែលជាកន្លែង មានដីដីជាតំណែលសំ ។

ដែនដីដែលចិនចូលទៅតាំងនៅនោះ មិនមែនតែម្នាក់ឯងទេ ដើមពួកចិនត្រូវប្រែតំណាក់ស្មុគស្មាញ ខ្លួនចូលទៅបានយ៉ាងយឺតៗ

ជារយៈវេលា ៦,០០ ឆ្នាំ ទើបតាំងនៅខាងបូរទបបានក្នុងដែនហាន់ ស្ទឹង រួច
មកតាំងនៅកន្លែងដែនហ៊ួ-ណាង រួចតមកទៀត ចិនក៏តអាណាខេត្តបាន
ស្រុកផ្សេងៗ នៅទិសខាងត្បូងទន្លេហ្វាង-ហូ ។ ហើយតមកទៀតជា
ច្រើនសតវត្សរ៍ ដរាបមកដល់ពុទ្ធសករាជ ៣,១០ ឆ្នាំ ទើបចិនលុកលុយ
ទន្លេបានដែនដីខាងត្បូង រំលងទៅថា ប្រទេសចិនសព្វថ្ងៃនេះ ។
(ឯសេចក្តីដែលពោលអាងមកនេះ គ្រាន់តែការស្មានទេ) ។

កន្លះយៈវេលាជាយូរយារអង្វែងនេះ មានមនុស្សសំខាន់ៗ ដែល
មានល្បីឈ្មោះក្នុងពង្សវង្សចិន គឺហ៊ួ-អ៊ី ជាអ្នកតិតបង្កើតអក្សរចិន,
ចិន-ទុង ជាអ្នកតិតធ្វើយានជំនិះមានកង់ទ្បើង, ក៏ង-ខ ជាអ្នកសាង
តម្រាតារាស្ទ្រ ហើយមានព្រះបរមក្សត្រដែនវិន្ធានុភាព ឈ្មោះ
ព្រះអង្គព្រះនាមយ៉ៅ, ស៊ុន, យូ ។

ស្រុកចិនកើតអ្នកប្រាជ្ញសីលធម៌

កន្លះសម័យដែលប្រទេសចិន មានរបៀបគ្រប់គ្រងស្រុកទេស
ទៅតាមរបៀបស្តេចគ្រាញ់គ្រប់គ្រងដែនតតូចៗ ជាច់ដោយឡែកៗ ពីគ្នា
នោះ មានហេតុកេទសំខាន់កើតទ្បើង គឺកើតអ្នកប្រាជ្ញខាងសីលធម៌
មានឈ្មោះថា ខុងជឺ ជាដើម ។

ពាក្យថា ខុងជឺ, ខុងជូ, កុងស៊ូ ឬកុងស៊ូ ជាឈ្មោះអ្នកប្រាជ្ញចិន
ខ្លាក់ ដែលបានរៀបរាប់សីលធម៌ ខ្លះគ្នានប្រដៅប្រថាដូនជាតិចិន អ្នក

ក្រុងជ្រូកនេះជាតំបន់ហៅថា "កុនហ្គុយស៊ីយុស" ។ នេះកើតមុនពុទ្ធបរិនិព្វាន ៨ ឆ្នាំ កំណើតនៅភូមិ ព្រួច ក្នុងខេត្តកាន់-ឌុង ឬសង់-ឌុងថែស់ អាណាព្រែលូ ចាប់ផ្តើមរៀនសូត្រតាំងពីអាយុបាន ១៥ ឆ្នាំ ដល់អាយុ ២៥ ឆ្នាំ ទើបតាំងខ្លួនជាសាស្តាចារ្យ ប្រឹងបង្រៀនមហាជនរហូតដល់អាយុ ៥០ ឆ្នាំ ទើបបានទទួលមុខងារធំនៅក្នុងរាជវាំងហ្គុយស្រុក តមកបានឡើងឋានៈជាទីអគ្គមហាសេនាបតី (ផ្នែកទ្វីន ១) នៃអាណាព្រែលូ, តមករត់គាយខ្លួន លោកដោះខ្លួនចេញពីមុខតំណែងការ ហើយចាប់ផ្តើមសរសេរតម្រាប់តម្រាំនៃដីលើខ្នើយរបស់លោក ហេយអនិច្ចកម្មក្នុងកំណត់អាយុ ៧៩ ឆ្នាំ ។

អំណើរការតមក ត្រកូលខុងដឺអនិច្ចកម្មទៅបាន ១៤០ ឆ្នាំមានអ្នកជ្រូងចិនម្នាក់ទៀតហៅថា "មេង-ស៊ូ" ដែលគួរកត់ថាជាសាវកសំខាន់ ១ របស់ខុងដឺ ។ មេង-ស៊ូ កើតក្នុងពុទ្ធសករាជ ១៧១ ក្នុងអាណាព្រែលូដែរ ។ ឯឪពុកដូចគ្នានឹងមេង-ស៊ូ មានទំនងខុសគ្នានឹងខុងដឺ ចន្ទិច គឺមេង-ស៊ូ ឃុកចិត្តពុកជាកំនឹងវិជ្ជាការដែនដីច្រើនជាងប្រាជ្ញាសាលដមិ មេង-ស៊ូ នេះមានអាយុ ៨ ឆ្នាំ ទើបអនិច្ចកម្ម ។

ក្រៅពីលទ្ធិខុងដឺដែលពោលមកនេះ នៅមានលទ្ធិ ១ ទៀត ដែលចំនេះគាត់ស្គាល់ច្រើនមកដល់ភូមិថ្ងៃនេះ គឺលទ្ធិតៅម៉ាស្ទូ ។ អ្នកជ្រូងដែលបង្កើតលទ្ធិនេះហៅថា "ឡៅ-ស៊ូ" កើតមុនខុងដឺ ៥៧ ឆ្នាំ គឺមុន

ពុទ្ធសករាជ ៦១ ឆ្នាំ ។ លក្ខន្តិនេះជ្រៀតថាមានព្រះជាធំជំនួតនៅលើស្ថានសួគ៌ ត្រូវជ្រើតជ្រើនសន្ធឹងសួង ទើបព្រះជាម្ចាស់ដែលជ្រាបជ្រាបណាមសលក្ខន្តិនេះក្លាយទៅជាគោរពខ្ញុំបម្រើសាសនាទេវ្តា ដែលពួកចិនកាន់សាសនាសព្វថ្ងៃនេះ ។

កន្លងសម័យនោះ ប្រទេសចិនមានខ្លួនជាប្រទេសអាណាចក្រ មានក្សត្រគ្រប់គ្រងជាច់ដោយឡែក។ តាំងតែមកបានរួបរួមបូលគ្នាជាមហាអាណាចក្រតែមួយវិញបាន មានព្រះមហាក្សត្រាធិរាជតែ ១ ព្រះអង្គទ្រង់ព្រះនាមថា វ៉ុង-ទី ក្នុង ព. ស. ២៤៧ ។ ព្រះមហាក្សត្រអង្គនេះទ្រង់គ្រប់គ្រងរាជសម្បត្តិបាន ៦៦ វស្សា ទើបទ្រង់ទិវង្គត ។

សម័យដែលពួកចិនតាំងឡាក់ឋានបានខ្ជាប់ខ្ជួនមានសេចក្តីចំរើនរុងរឿងដូច្នោះហើយ ពួកហួន ឬពួកមុង្គលក៏ចាប់ផ្តើមរុករានទំនើបកន្លែងសម្រាប់តាំងឡាក់ឋានខ្លះដែរ ។ ក្នុងរជ្ជសម័យព្រះបាទ វ៉ុង-ទី នោះ ពួកហួនដែលចិនហៅថា ហាង-នូ ឬ ហៀង-នូ បានចូលមកលុកលុយយកដែនដីខាងសមុទ្រជប៉ុន ។ ព្រះបាទ វ៉ុង-ទី ទ្រង់ធ្វើចម្បាំងទប់ពួកនេះអស់កាលយូរ ទៅទីបំផុតទ្រង់បានតបសាងកំពែងយ៉ាងធំសំបើមសម្រាប់ការពារប្រទេសចិន តាលពីពុទ្ធសករាជ ៧២៨ មានបណ្តោងវែងជាង ៣.៣០០ គីឡូម៉ែត្រ នៅរាត់ជាប់ការសាងយ៉ាងធំសំបើមអស្ចារ្យណាស់ ដែលមានជាប់តរហូតមកដល់សព្វថ្ងៃនេះ ។

វគ្គទី ២

កាលអស់បុណ្យព្រះចៅពញាឯកដុំ - ខ ហើយ ពួកវង្សចិនមិនបានតាំងនៅខ្លាចខ្លួនប៉ុន្មានទេ ដោយហេតុតើតបះបោរបណ្តេញឲ្យចេញក្នុងស្រុក ចើតទុកាសឲ្យពួកហួនស្រុកលុកយកស្រុកចិនកាតខាងដើង តមកមានមេទ័ពចិនតូចតែម្នាក់ឈ្មោះ លៀវ - ប៊ុន រួបរួមស្រុកចិនឡើងវិញបាន ។ តមកទៀត លៀវ - ប៊ុន តាំងខ្លួនជាព្រះចៅពញាឯកជា ជាបឋមក្សត្រ្តៃចេស់ពួកហ័ន ជាពួកវង្សសំខាន់ ដែលគ្រងរាជ្យបានចំនួន ៤ សតវត្សរ៍ គឺតាំងពី ព. ស. ៣៤៤ ដល់ ៣ ស. ៧៦៣ តាំងទីក្រុងនៅ ស៊ូ - ជាំង ក្នុងខែត្រចេន - ស៊ូ ទឹងឡុក - អៀង ក្នុងខែត្រហូ - ណាន ។ តមកទៀត មានព្រះមហាក្សត្រ្តៃយ៍ដែលមានព្រះនាមល្បីល្បាញ ១ អង្គ ព្រះនាមរ៉ូទី មានអាមាត្យពូកែចំណាប់ម្នាក់ឈ្មោះ ឆាង - គៀន រឹបូរសាងាតីបានកាតពន្ធីតណាណាទេតួចនិងហួតដល់អាស៊ូតណ្ណាល ។ ដល់ក្សត្រិយ៍តង្គនេះទៅទៀតនៅ សេបក្តីចំរើនភ្លាំងពួកតំបន់ឆេតិចនៅវិញតាំងរហូត ព. ស. ៤៩៣ ។

លុះមកដល់សម័យព្រះចៅ ស៊ី - អួន - ទី ទ្រង់បានគ្រប់គ្រងប្រទេសចិនអស់រយៈពេល ២៩ ឆ្នាំ (រវាង ព. ស. ៤៧០ - ៤៩៩) ទើបចិនមានកំឡាំងខ្លាំងពូកែឡើងវិញ ។ គ្រានោះ ប្រទេសចិនឡើងទៅលើស៊ី

ឧណ្ណាលៈ សឹងភ្ជាប់មកជាមួយក្នុងព្រះពាជអំណាចរបស់ព្រះរាជាពិពាជ្រៃទេសបិន រហូតមកដល់តួតតិយមន្ត្រី ជាន់អំណាច

រ៉ុង - ម៉ុង ទ្បើងគ្រងរាជ្យ

ដល់មក ព. ស. ៩៩២ មានលោកតាចំនួនពីរនាក់ឈ្មោះរ៉ុង-ម៉ុង ចាកផ្លូវព្រះមហាក្សត្រីយ៍ពាជនេចញពីពាជធានីហើយតាំងខ្លួនជាព្រះពាជាពាពាជទ្បើង ។ ការដែលគេនេះ បណ្តាលឲ្យកើតមានលាបពណ៌ក្នុងស្រុកទ្បើងយ៉ាងសំបើម ។ តមកមានព្រះពាជអង្គមួយអង្គ ព្រះនាមលៀវ-សៀវ ដែលទើបនឹងសាងសួនឆ្នាំ ១ គ្រាជាវេលា ១៥ ឆ្នាំ គ្រប់ចាន់ទ្បើងគ្រងពាជ្យជាព្រះចៅពាពាជាធិពាជទ្រង់ព្រះនាមជាព្រះចៅខ្វាង-វ៉ូ-ឌី ពេលពី ព. ស. ៩១៩ រហូតដល់ ព. ស. ៩០០ ។

លុះព្រះមហាក្សត្រីយ៍ពាជ្យចាន គ្រប់តាន់ទ្បើងវិញចាន ហើយ ទ្រង់ចាប់ផ្តើមប្រមូលគាណាចក្រចិនជាថ្មីទ្បើងវិញ ទ្រង់ទ្បាស់ទីក្រុងពីស្រុកស៊ុ-ជាន់ទៅនៅលោ-យ៉ាង ។ ទ្រង់ចាប់ផ្តើមបង្កើតការចលាចលតាតែចាន សាន្តតាណាទូទៅ ហើយបានតែងតាំងមេគ្រួសារចិនឲ្យតាន់តែរឹងធំទូលាយចេញទៅទៀត ហើយចូនជាពួកហួនលែងជាស្តេចនឹងចិនទៀតទៅ គ្រប់ដែកសាមគ្គីគ្នាជាពីរពួក ប្រកាប់ប្រចាន់គ្នាឯង ជាគុកាសបើកឲ្យចិនពីរនាក់ណាស្តេចហួនដល់ខ្លួនឯ-ស្តង់ ។

គន្លងវ៉ាង ព. ស. ៩៩១ ទៅដល់ ៦៧០ មានព្រះមហាក្សត្រដែលខ្លាំងពូកែ មានវិញ្ញាខុភាព មានមេទ័ពឯក។ មានថ្លៃដែយ៉ាងលឿលាញជាច្រើនណាស់ មានមេទ័ពប៉ុនទៅនឹងតៀវហៀនជាដើម ជាដើមហេតុឲ្យអាណាចក្រចិនវែងធំឧឡារទេព្រោះយ៉ាងសំរបើមអស្ចារ្យ តែតែពួកមហាក្សត្រក្រុងរោម តំបូនបង ស្ថានមេគ្រីនឹងក្រុងចិន ។

សម័យសាមក្កុ

គន្លងវ៉ាង ព. ស. ៧០៩ តមក ព្រះមហាក្សត្រជាវង្សហ៊ានចាប់ផ្តើមរសាំរសាយ មិនរឹងប៉ឹងដូចដើមទៀត ហើយគន្លងវ៉ាង ព. ស. ៧៩៧ មានមនុស្ស ១ ពួកដែលហៅតាមរឿងសាមក្កុថា ចោរជួតសំពត់លឿង តើតរៀងក្នុងរជ្ជសម័យព្រះចុងហៀន-តេ ។ ពួកមេទ័ពដែលទៅបង្ក្រាបចោរបានស្ងប់ហើយ តែឡប់តាំងខ្លួនធ្វើជាធំក្នុងស្រុកចិន មិនគោតខ្លាចព្រះពួកអំណាចក្សត្រក្រុងចិន តែតែស្រុកចិនតាំងមូលចែងខ្លះចេញជា ៣ ក្រុម ដែលហៅថាសាមក្កុ ។ មានមេទ័ពដែលខ្លាំងពូកែឆ្លៀវឆ្លាតម្នាក់ឈ្មោះបូ ឆូ តាំងខ្លួនជាមហាឧបពល ជាអ្នកសម្រេចពួកការផែនដីទៅចូលព្រះចុងហៀន-តេ ។ មានមេទ័ពពូកែម្នាក់ទៀតឈ្មោះស៊ុន-ក្វន តាំងខ្លួនជាធំនាស្រុកចិនភាគខាងកើត ។ មានមេទ័ពម្នាក់ទៀតតាំងខ្លួនឡើងជាក្សត្រទី ៣ ហៅថា ឡៅ ពី។ តាំងខ្លួនជាអ្នក

ត្រង់ត្រង់ស្រុកសៃ-ធួនកុដ ព.ស. ៧៥៧ ។ ម្ចាស់រដ្ឋាភិបាលត្រូវចំនួនចែកចេញជា ៣ ភាគ តាំងឲ្យរាំងសម្រាប់ឆ្នាំទៅវិញទៅមកអស់កាលជាយូរមកដែរ ។ លុះមកដល់គ.ស. ៨០៩ ទើបមានមេទ័ពយ៉ាងក្លាតែម្នាក់ ឈ្មោះ សុមា-ចេន រួបរួមអាណាចក្រចិនឲ្យមូលគ្នាឡើងវិញបានមកដដែល ។ ពេលនោះស៊ុនឡើងត្រង់ពេលសម្រាត្តិ តែមិនអាចតស៊ានសេចក្តីចំរើនដូចកាលក្នុងត្រង់ជាន់ឡើយ ហើយតាំងពីកាលណោះមក អាណាចក្រចិនក៏ចាប់ផ្តើមរៀរកយ ។

វគ្គទី ៣

អំណាចរបស់ពួកហ្លួង

ឯពួកហ្លួងដែលជាប់ខ្លាំងអំណាចក្រុងចិន ត្រឡប់មានវិទ្ធិអំណាចឡើងភ្លៀវភ្លា ប៉ុន្តែលុះលុយយកបានហ្គាងដល់ទីក្រុងចិន ក្នុងត្រង់ស៊ុនក៏ចេញចាកដែនដីកាតខាន់ដើង ទៅតាំងអាណាចក្រនៅដីចិនកាតខាងត្បូងវិញ តាំងពី ព.ស. ៨៤០ ដល់ ព.ស. ៨៦៣ តែមិនសូវមានសេចក្តីចំរើនហើយខ្សោយកំឡាំងអាទុកតដន ។

លុះដល់ពេលត្រង់ត្រូប មានអំណាចកន្លែងស្រុកចិនឡើងវិញ ដើមអាចផ្សាយអំណាចចូលទៅកន្លែងដែនដីចិន ភាគខាងដើងហ្គាងដល់អាស៊ុតណាស ផ្លូវតែមានតម្លៃកន្លែងអាណាចក្រចិនក៏បានស្រួលឡើងវិញ ស្ថានមេត្រីខាងផ្លូវព្រះពុទ្ធសាសនាក៏ត្រឡប់មានឡើង ព្រះមហាក្សត្រែនីធ៌ប្រ-

ជាជនជាតិចិន ក៏ចាប់ផ្តើមគោរពកាន់ព្រះពុទ្ធសាសនា តាំងអំពី
កាលណោះមក ។ ក្នុង ព.ស. ៩២៩ ព្រះចៅសុន-ហៀវ៉ូទី
ទ្រង់ជាន់ឥសាន៍ហោ ព្រះពុទ្ធរូបទៀតជាដំបូងបំផុតក្នុងព្រះរាមរាជវង្ស ។
ក្នុងរជ្ជសម័យ ព្រះចៅជិន-ស៊ីនទី ទ្រង់ជា ទ្រង់បញ្ជូនសមណៈ
ទូតរបស់ចិន ចូលទៅប្រទេសឥណ្ឌា កាលព័ ព.ស. ៩៤២ ។ តាំង
ពីកាលណោះមក ព្រះពុទ្ធសាសនាមានសេចក្តីរុងរឿងក្នុងប្រទេសចិន
យ៉ាងខ្លាំងក្លា ត្រកូលខ្ពង់ខ្ពស់ធំធំនាំគ្នាប្តូរចាប់ពន្ធុវស្ត្រទៅជាច្រើន ។
មានសេចក្តីដំណាលថា ក្នុងរវាង ព.ស. ៩៩០ មានចំនួនវត្តក្នុងស្រុក
ចិនច្រើនជាង ១៣.០០០ វត្ត មានពួកកិកុជាជាតិឥណ្ឌាចូលទៅនៅក្នុង
ស្រុកចិនច្រើនជាង ៣០០០ រូប ។

ឯពាក្យរាជវង្សត្រូវៈ តាំងដើមមកនោះ មិនមែនជាជាតិចិនទេ តែដល់ពាន
ខួលសេចក្តីចំរើនតាមបែបចិនកាន់តែច្រើនឡើងៗ ក៏ក្លាយទៅជាចិន
ទៅ ប៉ុន្តែតាមផ្លូវប្រវត្តិស្រុកខ្មែរ កាលបើក្មេនចំរើនឡើងហើយ
ក៏ត្រូវប៉ះរៀវភៅយៈទៅវិញ ។ លុះដល់មកក្នុង ព.ស. ១០៧៧
ពាក្យរាជវង្សត្រូវៈ ក៏បែងចែកគ្នាជា ៦ ភាគតឺភាគខាងលិច តាំងទីក្រុងនៅ
ស៊ុ-ង៉ាន់ក្នុងខែត្រហេន-ស៊ី ភាគខាងកើតតាំងទីក្រុងនៅឆាង-ហៅ
ក្នុងខែត្រហ៊ូ-ណាន ។

សម័យរាជវង្សស៊ុយ

ពាជវង្សគួប: ដែលចែកខ្មែរចេញជា ២ តាត់ដូច្នោះហើយ ដល់មកគ.ស. ១៦២០ ត្រូវបាន្ទរួបរួមចូលគ្នាឡើងវិញ ដោយពាជវង្សស៊ុយបានតាំងខ្លួនជាឡាក់ហានឡើងកន្ត គ.ស. ១០៦៤ ។ ហេតុគេចំនងនេះគួរចាប់ជាការសំខាន់ ១ ដែលបណ្តាលឲ្យកែតាសេចក្តីចំរើនរុងរឿងឡើងវិញ ដូចសម័យពាជវង្សហាន ។ រវាង គ.ស. ១០៨៩ ដល់ គ.ស. ១១៦០ ចិនបានរួបរួមយកអំណាចថាស់ចេស់ចិនមកវិញបានទាំងអស់ ។

ប៉ុន្តែកន្លងផុតសម័យនៃព្រះបាទយ៉ុង-ទី កន្លងពាជវង្សស៊ុយនេះ មានសេចក្តីចំរើនរុងរឿងកន្លងមកដំបូង។ ដល់ចុងក្រោយត្រូវប៉ាស់ហើយទៅវិញ ហើយព្រះមហាក្សត្រិយ៍តង្គ នេះត្រូវថយចេញពាយពាជសម្បត្តិ ។ កន្លងមកសង្ឃឯង ពួកមេទ័ពនាយកងសឹងមានចំណងចង់ឡើងត្រូវពាជសម្បត្តិ ទៅតែដែលពាជបល្ល័ង្កកំពុងនេះ កន្ត គ.ស. ១១៥៧ ជាឆ្នាំសំខាន់កន្លងបំផុតសំរាប់ស្តេចចិន គឺជាឆ្នាំកំណត់កន្លងរវាងសេចក្តីល្អបានវិលត្រឡប់មកដល់ចិនវិញ ។ ឯពួកមន្ត្រីមកន្លងដែលជាណ្តើមពាជបល្ល័ង្កចាស់ពាជវង្សស៊ុយបានសម្រេច គឺមានពុទ្ធន្តិង កូន ៤ នាក់ គាពុកឈ្មោះលី-យួន កូនឈ្មោះលី-ចេមិន ដែលជាអ្នកផ្តើមតាំងពាជវង្សថាង់ឡើង ។

វគ្គទី ៤

រាជវង្សចាំង - សម័យចៃសុងមហារាជ

តាមដោយពិត ពាជវង្សចាំងនេះ គឺអាតុកគន់កូនដូចពោលមក ហើយ ជាអ្នកតាំងខ្សែន ។ លី - ឃួនជាអាពុកស្ទើរតែមិនចាប់ផ្តើអ្វី ទៀយ ការដែលពាជវង្សចាំងបានតាំងខ្សែនក្តី ការតន្ទឹកតំណាចបន្ទាប់ក្តី ស្រេកចិនចំរើនរុងរឿងដោយគារ្យធម៌ ដ៏ដែលមានសម័យពាជ្ជមស្ថេក្តី សំដីបានសម្រេចដោយស្នាដៃលី - ចេមិនស្ទើរតែពាំនាស់ ដែលជាការចំណែកអស្ចារ្យណាស់ ។

ក្នុងសម័យដែលស្រេកចិនកំពុងកើតចលាចល ក្នុងដែនដីព្រះចាន ឃ្លីង - ន័រនោះ មនុស្សពាំងឡាយចៃមុនទៅតវ៉ៃគ្រែកូលចាំង ដែលជាឧកាសល្អនាំឲ្យវង្សគ្រែកូលចាំងតាំងខ្លួនជាធំឡើងបានក្នុងស្រេកចិន ។ ឯលី - ឃួនជាអាពុក ជាមនុស្សខ្វាចប្រែចិន មិនសូវហ៊ានធ្វើការអ្វីទេ ទើបលី - ចេមិនជាកូន ចាប់ផ្តើការគ្រប់យ៉ាងជាតំណាងតាំងនាមបិតាខ្លួន ។ ជំបូង លី - ចេមិនបានប្តូរមកកំឡាំងទាហាន ហើយបានទៅចងស្ពានមេត្រីនឹងពួកគួតិ រួចនាំបិតាលើកទ័ពបួលទៅវាយបានស្រុកស៊ូ - ង៉ាន ខ័ត្រកុង ក្នុង ព.ស. ១១៦០ ដល់មកក្នុង ព.ស. ១១៩១ លី - ចេមិនប្រកាសតាំងបិតាខ្លួនឡើងជាព្រះចៅពាជាធិពាជក្រុងចិន ពាជវង្សថ្មីតែងតែឡើងដោយស្នាដៃក្មេងកំឡោះអាយុ ២៦ ឆ្នាំ ដែលគួរឲ្យអស្ចារ្យណាស់ ។

ប៉ុន្តែមុននឹងបានត្រង់ត្រង់ខែត្រដែនចំនួនទៅនោះ លោ ចេមិនទើប
បិតា ត្រូវធ្វើការច្បាបច្បាមពួកមេទ័ពនាយកងធំ ដែលកំពុងតាំងខ្លួនជា
ស្តេចក្រុងចិនទៀតសព្វខ្លួន ។ ក្រៅពីនេះ ត្រូវធ្វើការបង្ក្រាបខែត្រ
ដែនដែលរើងទើងទាំងអម្បាលម៉ាន ជាវេលា ១៦ ឆ្នាំ ទើបបានស្ងប់
សាន្តគ្រាណា ។ ឯលោ-ឃួនជាបិតាមានទិស្សយទន់ខ្សោយតាមធម្មតា
បណ្តោយឲ្យព្រះអគ្គមហេសីកំណាច់ក្នុងព្រះបរមរាជវាំងតាមចិត្ត ហើយ
ទ្រង់ក្រាបសូមបាណាតែពួកដំកើងព្រះកិត្តិយសរបស់ទ្រង់ ។ ទើប
លោ-ចេមិនយល់ឃើញថា បើបណ្តោយមុខជាពុជអាណាចក្រចិន
ដែលខ្លួនចំណាស់ទៅជានឹងវិនាសសាបសូន្យទៅវិញមិនខាន ទើបដក
ព្រះបិតាតាំងជាព្រះចៅដែនដីកត្តិយសទៅវិញ ហើយតាំងខ្លួនឯងទៅជា
ព្រះចៅកជាធំកជ ព្រះនាមថា ព្រះបាទថៃ-សុងមហាកជ ទ្រង់គ្រប់
គ្រងកជអាណាចក្រចិន អស់រយៈ ២៣ ឆ្នាំ គឺតាំងពី ព.ស. ១០៧០
ដល់ ព.ស. ១០៩២ ជាព្រះមហាក្សត្រសំខាន់បំផុត ក្នុងពង្សវង្ស
ប្រទេសចិន ។

លោ-ចេមិន ប្បាំងនឹងពួកគ្លួកិ

ឯនេះរបស់កជវង្សថាំងនេះ ក្នុងដំណាក់ដំបូង ។ មានសេចក្តីលំបាកជា
ច្រើន ពួកគ្លួកិដែលតាំងនៅខ្ទប់ខ្លួនក្បែរកំដែនស្រុកចិន រមែងចាំរក
ឱកាសចន្លោះនឹងចំផ្លាវចូលចិន ក្នុងកាលដែលចិនថយខ្សោយកំឡាំង

ហេតុនេះហាន់ដាក់ឆ្នាំ ៣ ស. ១១០៧ តួនតួកំសាន់តើតបួលលុក
លុយខាន់ទៃគ្រែដែនចេន - ស៊ុហើយលើកសំដៅទៅគ្រងស៊ុ - ង៉ាន ។ នៅ
វេលានោះពួកតាហានចំនានចិត្តរញ្ជួយជាច្រើន ដោយពួកសគ្រែបួល
មកដល់ឆាប់ពេក ។ នៅគ្រានេះឯង ផែលលី - ចេមិនសំដែងសេចក្តី
ភ្លាហានមន់អាចយ៉ាន់ចំខ្លែក. គឺនាំតាហាន ៤០០ នាក់គ្រែបួលទៅកន
ចំពេញមទ័ពតាហានតួកិរហូតដល់ខ្លួនមទ័ពតួកិតាំងព័រនាក់ឈ្មោះកៀ - លី
ឌីង់តុ - លី ទិយាយសម្លែងការគ្រាតែរមទ័ពតួកិយល់ព្រម ថយទ័ព
គ្រឡប់ទៅស្រុកវិញ ។ ទើបឃើញថា វីរបុរសនេះបានជួយស្រុងចិន
ឲ្យរួចពីគ្រោះថ្នាក់ មិនបាច់ឲ្យមនុស្សម ១ ដំណេកស្រក់ដល់ដីទេ ។

តមកគ.ស. ១១៦៩ កងទ័ពតួកិដែលមានកៀ - លី ជាប្រមុខ
ក៏លើកបួលមកលុកលុយខាង់កាន - ស៊ូ មានកំឡាំងតាហានសេះដល់
មួយសែន ក៏យទ័ពចំនួនភ្លាមសំដៅមកខ្លួនតរ ស៊ុ - ង៉ាន ។ ទើបលី.
ចេមិនដែលខ្លើងគ្រងពាជ្យជា ព្រះហ្គនថៃ - សុងមហាកជ ស្តេចចេញទៅ
ហួតដល់ចន្លោះពួកតួកិមុនកងទ័ពនៃ អង្គឡេដល់ ហើយទ្រង់មានព្រះ
បន្ទូលទ្លាង់ៗថា "ពួកតួកិធ្វើខ្ញុំសងឹងស្ថាន មត្រីធំណាស់" ។ ឯពួក
តាហានតួកិគ្រាន់តែគ្រវែកឃើញ ព្រះជ្គនថៃ . សុងមហាកជ ក៏ភ័តភ័យ
ប្លុះតឹងដ៏សេះសំដែងសេចក្តីគោរព ទ្រង់បព្រះទ័នាំងមសុត្រាស្តេច

ចូលទៅជួបនឹងកៀ-លោ។ មិនដឹងជាមានហេតុផ្សេងដូចម្តេច ស្រាប់តែលែងគិតធ្វើចំណាំងលើកទ័ពឆ្ពោះទៅស្រុកវិញអស់ទៅ ។

ឯគណៈតំណាងពួកតួកិតីមែកខ្វែកគ្នាជាច្រើនភាគ តំណាងពួកតួកិតីឆ្ពោះទៅជាមិត្តមុន ប៉ុន្តែកៀ-លីដែលជាមេទ័ពសំខាន់របស់ពួកតួកិនៅមិនទាន់អស់ចិត្ត នៅតែបន្តើលើកទ័ពទៅលុកលុយប្រទេសចិនម្តងទៀត ។ ក្នុង ព.ស. ១១៧៣ កៀ-លី លើកទ័ពចូលមកតាំងនៅប្រទល់ដែនខេត្តចាន់-ស៊ី ត្រូវមេទ័ពចិនឈ្មោះ លី-សុីង ផ្សាយកាត់ទ័ពតួកិជាច់បេញ្ជាជាពីរកំណាត់ ហើយមាន ១ ពួកលើកស្ទាត់ផ្សាយពីគ្រោះខ្លួន ។ កៀ-លី ត្រូវទ័ពចិនផ្សាយតាមមិនដឹងខ្លួន ក៏បាក់ទ័ពរត់ខ្ចាត់ខ្ចាយឆ្ងាយទ័ពត្រឡប់ទៅមុខ្លីវិញ ទ័ពចិនវៃឆ្លៀតតាមចាប់កៀ-លីបានខ្លួនបញ្ជូនទៅក្រុង ស៊ូ-ឆាំង ។ តាំងពីគាលណោះមក ខេត្តដែនមុខ្លីភាគខាងកើតនឹងភាគណាមួយជាប់មកជាប់ណុះចិន ដោយមានភាគាមាត្យចិនត្រួតត្រាគ្រប់គ្រង ។

ជំលៀងជិងចិន

កាលបើបានធ្វើបាបធ្វើមពួកតួកិកន្លងដែនមុខ្លីលើកបន្ទាប់ហើយ ព្រះចៅទៃ-សុងមហាក្សត្រ ទ្រង់ចាប់ផ្តើមធ្វើបាបធ្វើមពួកតួកិទំនាស់លិចតទៅទៀត គាប់ជួនជាមានហេតុផ្សេងនឹងកើតទៀតផង គឺកាលពី ព.ស. ១១៨៤ ពួកជាហានតួកិទំនាស់លិច លើកចូលមកប្រទូសកំដៅពួកចិន

នៅចំណុចលំដាប់ ខ្ញុំបានឲ្យលើកទ័ពចេញទៅបង្ក្រាបកងទ័ព្រួនចូលទៅ
រហូតដល់ខេត្តវ៉ៃនក្នុង (ក្រចេះផងដែរ) ។ ទាល់តែកូរ (តែផងណែ) ១ អង្គ
ក្នុងវ៉ៃនតន្ត្រារ៉ាប់រងអំណាចរបស់ពិន សាលពី ព.ស. ១៦៨៥ ។
តាំងពីតាលរណោះមក ផងណែក៏ តាតខ្លាចអំណាចព្រះបាទថៃ-សុង
មហាកដ ហើយខាំគ្មានស្ថានមេត្រីទំនឹងពិន កដូចពិនក៏ឃុនកូលទៅ
កាន់ពួកសំណាក់ប្រទេសផងណែ ។ តាលតដតរ (តាយខ្មៀង) មាន
កូរ (តែផងណែ) ១ អង្គ ព្រះនាមមិជុន:បានតាត់ស្ថានមេត្រីទំនឹងប្រទេស
ពិន ចណ្តាលហេតុឲ្យប្រទេសពិនលើងទ័ពចូលលុកលុយផងណែ រហូត
ដល់ក្រុងផងត្រែះ ចាប់ស្តេចមិជុន: បញ្ជូនទៅក្រុងសុ-ឃាំង តាលឆ្នាំ
ព. ស. ១៦៩១ ។

ក្នុងរជ្ជសម័យព្រះបាទថៃ-សុងនោះ ប្រទេសពិនចំរើនឡើងដោយ
វិត្ថារនុភាពយ៉ាងខ្លាំងបំផុត ។ ព្រះពាធិកដអង្គនេះទ្រង់សរសេរឿង
របស់ទ្រង់ទុក ។ អានៀថា "អ្នកដែលធ្លាប់ ដ្ឋការ (ចុះបញ្ជីជាមអណាចក្រ
តួចធំមកហើយ មានតែពីរពាក់ដេ គឺប៉ុង-ខ្មែរងពដាវ៉ាដ្ឋ ១ ភ្ញូ-ខ្មែ
ក្នុងពដាវ៉ាដ្ឋាំង ១ ប៉ុន្តែកាលដែលយើងចាប់ផ្តើមលើតឡើង យើង
អាចដ្ឋការ (ចុះបញ្ជី) បានច្រើនជាង ៦០ ពាលរដ្ឋ (ដែលមានទ្រង់ ៤
ស្តេចស្ថាន អនុស្សាវ៉ាំងឡាយនៅដែនឆ្ងាយ។ ដាច់ស្រយាលដើរឡើង
គ្នាបួនមកថ្វាយខ្លួនសុំជាខ្ញុំយើង" ។

ព្រះបាទថៃ-សុគមហាកដ្ឋែនដំរីវង្គតទៅកាលពី ព.ស. ១១៩២ កន្លងព្រះជន្មាយុ ៨៩ ព្រះវស្សា គេតម្កល់ព្រះសពដែនខេស្រុកបេន-ស៊ុ មានឧសាន៍រូបក្បត្តែផ្សែងជាចំណុះដែនព្រមទាំងរូបភាពជីវាន ៦ ផែល ដែនធ្លាប់ប្រើក្នុងពិការមង្គ្រាម ។

វគ្គ ទី ៩

រាជវង្សថាំង-សម័យរាជការដែនដីធ្លាក ទៅក្នុងកណ្តាប់ដៃព្រះរាជិនី

កន្លងប្រវត្តិសាស្ត្រមកលោកគែងមានហេតុចំឡែក ១ កើតឡើង ជារឿយៗ គឺថាបើក្នុងពេលផ្សែនដីណា មានព្រះមហាក្សត្រដែលដែន ព្រះបារមីតជានុភាព ខំនឹងធ្វើស្រុកនេះឲ្យបានចំរើន ខំនឹង មានអំណាចដ៏រុងរឿងហើយ កន្លងយេះរលាស់ទាបខ្លាចតមក នាងព្រះ មហាក្សត្រឡើងគ្រងរាជ្យថ្មី ស្រេចតែចំរើនរុងរឿងខំនឹងអំណាចរបស់ ប្រទេស តែឡប់ជាថយទៅយ៉ាងខ្លាំងអំណាចទៅវិញ ដោយកំហុសរបស់ ព្រះមហាក្សត្រីថ្មីក៏មាន ដោយហេតុគេជាខែខ្លៅតក៏មាន ដូចយើង បាននិយាយមកហើយកន្លងប្រវត្តិសាស្ត្ររបស់ក្រុងគេម ទុកជាក្នុងប្រវត្តិ-សាស្ត្ររបស់នានាប្រទេសដែលខំនឹងពោលថាលំដាប់តទៅក៏គង់មានខំនឹង ដូចគ្នាដែរ ។ ឯរឿងក៏រៀបរាប់ពីរជ្យថាំងនេះក៏ដូច្នោះដែរ គឺកាលដែល

អស់ពុណ្យព្រះបាទថៃ - សុគន្ធមហាពជរហ៊ោះ ពជរឆ្នេរនេះគឺជាប់ឆ្នេរមុខវាត
ស្ទួយទ្រូងតាមខៀវរាញ់ នោះក្នុងរវាងវេលា ៦០ ម៉ោ គឺគាំងព័ត្ថុសកពជ
១១៩ ពុ ដល់ពុទ្ធសកពជ ១២៥៣ នោះ ពជការផែនដីធ្លាក់ទៅខៅក្នុង
កណ្តាប់ដៃរបស់ស្តី ដែលជាហេតុនាំឲ្យពជរឆ្នេរថានិលិចលង់រីទាសអស់
ទៅនៅទីបំផុត ។

កាលព្រះបាទថៃ - សុគន្ធទិវង្គតទៅហើយ ពជឧទ្ទេសរបស់ព្រះអង្គក៏
បានត្រួតត្រាតពជរមម្ភត្តជាដំណាតមក ទ្រង់ព្រះនាមថា ព្រះបាទកៅ-
សុន្ទ តែព្រះបាទកៅ - សុន្ទមានត្រាតែមួយព្រះអង្គឯទេ ពុំមានទំនង់ព្រះពជបិតាជារប៊ែន
ប្តូនឯងថាផ្តួយគ្នាក៏សឹងជាបាន ព្រះបាទថៃ - សុគន្ធមហាក្សត្រ ទ្រង់ចាន
លក្ខណាខ្លាំងក្លៅតែតាត់ធន់ ឯព្រះបាទកៅ សុន្ទត្រូវប់ជាមនុស្សខ្ទន់
ខ្សោយមិនតាចធ្វើការអ្វីឲ្យបានសម្រេចដោយព្រះកត្តិឯងទៅរួច ថែមទាំង
ចាណ្តាយព្រះអង្គ ឲ្យលុះក្នុងកណ្តាប់ដៃព្រះនាងវែលជាទីគ្រោសក្រាណ
របស់ទ្រង់ ទាល់តែព្រះនាងនោះធ្វើតម្រិតស់ដល់ប្រទេសចិនជាយ៉ាន
ក្រៃលែងតាលតមក ។

ប៉ុន្តែអំណាចរស្មីនៃព្រះបាទថៃ - សុគន្ធមហាពជ មិនទាន់ផុតរលត់
អស់នៅឡើយ ទើបមានពួកមន្ត្រីជាន់ចាស់ដែលមានសេចក្តីស្មោះស្ម័គ្រ
ឥតព្រះអង្គជាច្រើនរូប ចាត់ចែងរួបរួមអាណាខេត្តកៅ - លីចាំន
ម្ចូល មកចាក់ស្តេចក្នុងស្រុកចិនបានជាន់តស់ (ចំណែកនៅចំលងខាងក្រោត)

ហើយយកបានខេត្តដែន តាយោតាតៃ (បំណែកទឹកដីសាងឆ្នាំលិច) មក
បន្ថែមដីចិនដោយឡែកទៀតផង ជាការចំរើនអាណាចក្រចិនឲ្យកាន់
តែលាយឡៃកែលែង ជាគ្រឿងនឹងប្រដាប់ព្រះកិត្តិយសកិត្តិសក្តិរបស់ព្រះចៅ
កៅ-សុង ដោយទ្រង់មិនបាច់ជួយធ្វើអ្វីឡើយ ។ ប៉ុន្តែតាមរយៈអំពីកាល
នោះមក ស្រុកចិនពាក់ផ្តើមមានកលិយុគរហែរឡើង អស់រយៈពេល ៦០
ឆ្នាំ ដោយមានតួនាទីបញ្ឈប់ដែនជាតួឯកដ៏ទួសនាយកេង (ប្រុស) ជួប
មានរសជាតិសាវម៉ាជាដរាបតរៀង ។

(មានត)

ពាក្យទ្រាវៗ

ភូមិសាស្ត្រសង្ខេបនៃសាកលលោកនិងផែនដីយើងនេះ ដែលខ្ញុំបានស្រង់ប្រែពីភាសាថៃមកជាភាសានេះ ដោយមានបំណងចង់ផ្សាយវិជ្ជានេះដល់ញាតិរួមជាតិ ដែលមិនបានរៀនសូត្រភាសាដទៃ ហើយវិជ្ជាភូមិសាស្ត្រនេះក៏មិនសូវមានបរិបូណ៌ក្នុងភាសាយើងៗ

មុនដំបូង ខ្ញុំសូមលាទាំង ខ្ញុំមិនមានចំណេះវិជ្ជានេះទេ គ្រាន់តែជាអ្នកស្រាវជ្រាវយកចំណុចខ្លះៗ ហើយចងផ្សាយទៅកាន់ញាតិរួមជាតិ ឲ្យបានជ្រាបលំនៃដីរបស់ខ្លួនវិញ ដែលមិនសូវមានបរិបូណ៌ក្នុងភាសាខ្មែរយើងប៉ុណ្ណោះ ។

ខ្ញុំសូមជម្រាបថា ភូមិសាស្ត្រដែលខ្ញុំបានរៀបរៀងឡើងនេះ ជាសេចក្តីស្រង់រៀបរៀងសង្ខេប ប្រើបំដីភាសាងាយៗ ប៉ុន្តែនៅមានពាក្យបច្ចេកសព្ទថ្នាក់ក្រែន ដែលមិនអាចចៀសវាងបាន សម្រាប់ការរៀបរៀងភូមិសាស្ត្រនេះ ។

មួយវិញទៀត ខ្ញុំសូមបញ្ជាក់ថា បំណងដើមរបស់ខ្ញុំអំពីការធ្វើរឿងនេះ គ្រាន់តែជាការស្រាវជ្រាវដំបូង ទោះបីមានភ្លាំងភ្លាត់ខ្លះ ឬមិនសមរម្យយ៉ាំងណា ក៏ទុកជួយជាសាមគ្គីធួស ឬជាគម្លួយ ទុកឲ្យអ្នកធ្វើជាន់ក្រោយតែងតែរៀបចំឲ្យកាន់តែបានល្អទៀត ។ ហេតុដូច្នេះ ខ្ញុំសូមគាត់ទោសអំពីសំណាក់របស់លោក អ្នកអានរឿងនេះទុកជាមុន ក្នុងគ្រានេះផង ។

ឋិតណ្ឌ ធិការ

ក្រមសាស្ត្រសាកលសង្ខេប

ហ្គងនិពន្ធមន្ត្រី ញ៉ុក ថែម

ប្រែ - រៀបរៀង ជាភាសាខ្មែរ

វគ្គទី ១

១ – អ្វីពីពិភពលោក - កន្លងសម័យបុរាណកាលនោះ មនុស្សយើងតែងមានយោបល់យល់ថា ពិភពលោកគឺផែនពសុធា ដែលយើងកស្រែយ៉ាងទៅសព្វថ្ងៃនេះមានសណ្ឋានសំប៉ែត តាំងនៅនឹងថ្កល់ហើយយល់ថា [ពេះអាទិត្យដើរប្រទក្សិណជុំវិញពិភពលោក។ នេះមានសណ្ឋានធំជាងដួងគាទិត្យជារាប់ពាន់ភាគ នឹងមានសេចក្តីយល់តាមក្បែរមើលឃើញថា [ព្រះចន្ទូមានសណ្ឋានធំជាងផ្កាយឯទៀត។ តាំងអស់ ។ លុះអំណើះតាមតៗមក មនុស្សយើងគាន់តែមានសេចក្តីខ្វេះជំនះបំភ្លើនកើនទៀងជាលំដាប ទើបជាប់សេចក្តីពិតបានថា ពិភពលោកយើងនេះជាផ្កាយដួងមួយក្នុងតារាកាសដូចជាផ្កាយតាំងឡាយដែរ ហើយយល់ថា ពិភពលោកយើងវិលប្រទក្សិណជុំវិញដួងគាទិត្យ ។ បណ្តាផ្កាយតាំងឡាយដែលយើងមើល ឃើញដើរតាមសន្ទោលើផ្ទៃមេឃនោះ ផ្កាយដួងខ្លះមានភ្នាក់តូច ដួងខ្លះមានភ្នាក់តំ គឺមានភ្នាក់ធំប្តូចជាងពិភពលោកយើងនេះក៏មាន មានភ្នាក់ធំប្តូចជាងដួងគាទិត្យក៏មាន ។

ឯបណ្តាផ្កាយដែលវិលច្រកក្បែរដួងអាទិត្យជាខ្ពស់នេះ គួរហៅថា ផ្កាយបរិវារបស់ដួងអាទិត្យ តាលើរួមទាំងផ្កាយបរិវារ-ទាំងដួងអាទិត្យ រួមគ្នាទៅ គួរសន្មតហៅថា សុរិយបក្រវាឡ ។

២—អំពីសុរិយបក្រវាឡ: សុរិយបក្រវាឡនេះមាន:

ដួងអាទិត្យ តាំងនៅជាកណ្តាល ឯដួងអាទិត្យនេះជាដុំភ្លើងមួយ យ៉ាងធំសម្បើមមហិមាបញ្ចាំងពន្លឺស្មើនឹងកំដៅទៅសព្វទិសានុទិស ។

ឯដួងផ្កាយទាំងឡាយដូចជាពិភពលោកយើងជាដើមនេះសុទ្ធតែជាផ្កាយមិនមានពន្លឺស្វាយខ្លួនឯងទេ តែទទួលពន្លឺនឹងកំដៅមកពីដួងអាទិត្យទាំងអស់ ។

ប្រសិនបើយើងនឹងសង្កេតឃើញឆាកដួងអាទិត្យនឹងពិភពលោកយើងនេះ នឹងឃើញថាឆាកធំហើរលោកយើងនេះគួចជាងដួងអាទិត្យជាច្រើនណាស់ គឺដួងអាទិត្យមានទំហំធំជាងពិភពលោកយើងដល់ទៅ ១ លានភាគ ។ ដួងអាទិត្យនេះមិនមែនតែណាតែនៅនឹងថ្កល់ក្នុងកណ្តាលអាកាសទេ មានអ្នកប្រាជ្ញតាមសាស្ត្រពិនិត្យឃើញថា ដួងអាទិត្យតែងវិលជុំវិញខ្លួនឯង ការវិលជុំវិញខ្លួនឯងនេះ ក្នុង ១ ជុំដូចវេលា ២៥.ថ្ងៃ ៧ ម៉ោង ៤៩ នាទី ។

๓ – អំពីសណ្ឋានដែលពីភពលោក – មានហេតុផលជាច្រើនបែបការដែលទាំងឱ្យយើងជឿជាក់ច្បាស់ថា ពិភពលោកនេះមានសណ្ឋានមូលលក្ខណៈដែលថា ត្រឹមសន្និដ្ឋាន ថាលោកមានសណ្ឋានមូលនេះគោលដោយសង្ខេបមាន ៥ បែបការ គឺ:

ក) បើយើងឈរនៅមាត់ច្រាំងសមុទ្រ ឬជាមានទូកក្តោងថ្មសំពៅមកកាងយើង មុនដំបូងបង្អស់ដែលយើងបានឃើញគឺបុងសសរក្តោង ខ្លួនគោះបូលមកជិតបន្តិចទៀតទើបមើលឃើញសសរក្តោងនឹងក្តោងហើយរួចទូកជាលំដាប់ ។ ប្រសិនបើពិភពលោកមានសណ្ឋានសំប៉ែតមែន យើងនឹងមើលឃើញរួចទូកតាំងមូលបានដោយងាយជាមិនខាន ។

ខ) ដួងអាទិត្យ, ដួងចន្ទនឹងដួងផ្កាយឯទៀតៗ សឹងមានសណ្ឋានជារង្វង់មូលៗ តាំងអស់ ទើបមានឱ្យគេជឿថាលោកយើងជាផ្កាយមួយដែរក៏តង់មានសណ្ឋានមូលដូចពពួកផ្កាយតាំងនោះដែរ ។

គ) កាលណាមានចន្ទគ្រាស ស្រមោលពិភពលោកយើងនេះចោលស្រមោលទៅចំដួងចន្ទ យើងមើលឃើញស្រមោលពិភពលោកកន្លះណ:នេះមានលក្ខណ:ជារង្វង់មូលដែរ ។

ឃ) ដួងអាទិត្យនេះរះខ្សឹងពីទិសខាងកើតមុន ប្រសិនបើលោកមានទ្រង់ទ្រាយជាផ្ទាំងសំប៉ែតមែន គ្រាន់តែថ្ងៃរះខ្សឹងពីដើនមេឃ

ខាងកើត មនុស្សពាំងឥសភក្នុងលោកនំងមើលឃើញដួងតាទិត្យ ឬពន្លឺ
ស្មើថ្ងៃត្រមុតត្រមែបប្រទេសពាំងអស់មិនខាន ។

ង) កន្លែងយប់ យើងមើលឃើញផ្កាយ ។ នៅទិសខាងជើង
ហាក់ដូចជាជាប់នឹងដើងមេឃ តែបើយើងខំដើរសំដៅទៅរកផ្កាយនេះ
ឆ្ងាយទៅ។ យើងនឹងមើលឃើញផ្កាយនេះកាន់តែអណ្តែតខ្ពស់ឡើង។
ជាលំដាប់ កាលបើយើងធ្លាក់ដំណើរទៅទិសខាងជើងដល់ពាក់ព័ន្ធតែដល់
ទៅកំពូលលោក យើងនឹងមើលឃើញផ្កាយនោះនៅចំពីលើក្បាល
យើងតែម្តង ។

ហេតុពាំង ៥ នេះហើយដែលនាំឲ្យយើងសន្និដ្ឋានថា ពិភពនេះមិន
មែនមានសណ្ឋានសំប៉ែតទេ ពិភពជាមូលតែមិនមែនមូលរលើងស្អាតដូចជា
ប៊ាល ឬគ្រាប់ឃ្លី សណ្ឋានមូលរបស់ពិភពលោកប្រហែលមានចំនងដូច
ផ្ទាចត្រលោកសង្ឃ ដុំខ្លះនិងលើងទេ ។

๒— ទំហំពិភពលោក ចេញចាប់ផ្តើមពីកំពូលលោកខាងលើ
ទៅរកកំពូលលោកខាងត្រើមប្រមាណ ៤០.០៧០ កិឡូម៉ែត្រ ជាស់
ដោយដុំវិញតាមខ្សែរង្វង់ប្រមាណ ៤០.០០៣ កិឡូម៉ែត្រ គិតទំហំ
ពាំងមូលប្រមាណ ៥១០.០៨២.០០ កិឡូម៉ែត្រក្រឡា ។

៥ – អាការៈលំនៃពិភពលោកមាន ២ យ៉ាងគឺ :

ក) វិលជុំវិញខ្លួនឯង ក្នុង ១ ជុំដាវេលា ២៤ ម៉ោង (២៣ ម៉ោង ៥៦ នាទី ៤ វិនាទីជាង) ល្បឿននៃការវិល ក្នុង ១ ម៉ោងជាង ១.០០០ គីឡូម៉ែត្រ ។ នេះហើយជាហេតុឲ្យមានយប់នឹងថ្ងៃ ។

ខ) វិលប្រទក្សិណជុំវិញដួងអាទិត្យក្នុង ១ ឆ្នាំបាន ១ ជុំ (គិតជាថ្ងៃ ៣៦៥ ថ្ងៃ ៦ ម៉ោង) នេះជាហេតុឲ្យមានរដូវក្តៅនឹងរដូវត្រជាក់ ។

យើងនៃធ្លាប់កំណត់ថា ក្នុង ១ ឆ្នាំមានចំនួន ៣៦៥ ថ្ងៃគត់ តែតាមដោយពិត ក្នុង ១ ឆ្នាំមាន ៣៦៥ ថ្ងៃនឹង $\frac{1}{4}$ នៃថ្ងៃទៀតផង គឺលើស $\frac{1}{4}$ នៃថ្ងៃ ។ ចំពោះបើលោកវិលប្រទក្សិណដាវេលា ៤ ឆ្នាំនឹងកើនពេលម៉ោងជាប់គ្នា ១ ថ្ងៃ ទើបមានការបន្ថែមថ្ងៃ ១ ថ្ងៃ ដែលហៅថា អធិកវារៈ ក្នុង ៤ ឆ្នាំបន្ថែមម្តង ។

៦ – អ័ពីរជ្ជិ : វេលាលោកវិលនោះ រមែងវិលទៅតាមជុំវិញស្រុលនៃពិភពលោក មានចំនួនដូចជាក្រែងវិលទៅជុំវិញស្រុលចេស់ៗជួញដូរដែរ ។ មួយវិញទៀតការវិលរបស់លោកនេះមានចំនួនច្រើនសន្ធឹងនឹងការវិលនៃម្ជុលនាឡិកា តែងវិលពីស្តាំទៅឆ្វេងជានិច្ច ។ ក្នុងខណៈដែលលោកវិលប្រទក្សិណជុំវិញដួងអាទិត្យនោះ ស្រុលចេស់លោកមិនបានតាំងទៅត្រង់ៗដូចជាដុំទេ គឺមានការរង្គើឯចញ្ជើងបន្តិច ។

ហក្នុងដែលលោកវិលផ្លឿនេះហើយជាបច្ច័យយ៉ាងសំខាន់ ក្នុងការធ្វើឲ្យថ្ងៃទំនងដូចមានវេយ៉ាងដែរ - ខ្ញុំ - គិត - ច្រើនមិនស្មើគ្នា ទំនងធ្វើឲ្យណាកូមិកនត់ចន់ផ្សេង ។ ក្នុងពិភពលោកមិនឲ្យស្មើគ្នាដែរ ទើបនាំឲ្យមានរដូវខ្យឹង ។

ពាលដែលលោកយាកផ្លឿនកំពូលលោកទៅខាងជើង ថែរទៅរកថ្ងៃនិរាទិត្យ ។ គឺបញ្ជាំងពន្លឺរស្មីផ្លុះទៅសព្វបរិវេណ តំពូលលោកខាងជើងខុសជាលោកមានអាការវែងដុំរាល្វូនជាងគេ តែតាមតំបន់ផ្សេង ។ ទៅចំហៀងលោកខាងជើងតែងខ្លួលតំរងថ្ងៃដូចគ្នាដែរ ចំហៀងលោកខាងត្រើមប្លែកគ្នា នោះបានខ្លួលពន្លឺថ្ងៃផ្លុះចាំងដល់ដែរតែតិចណាស់ ។ ទៅខណៈនេះហើយ ចំហៀងលោកខាងជើងទៅជារដូវក្តៅ ។ លុះតមកដួងពិភពនេះវិលប្រទក្សិណទៅតាមវិថីដុំរាល្វូងដួងអាទិត្យបានយៈពេលកណ្តាលឆ្នាំ ដែលយើងសន្មតថាកន្លះឆ្នាំ ទើបតំពូលលោកខាងជើងវាងចេញមិនសូវត្រែចំថ្ងៃ ឯតំពូលលោកខាងត្បូងត្រឡប់ថែរទៅរកថ្ងៃវិញ ធ្វើឲ្យចំហៀងលោកខាងត្បូងមានពន្លឺថ្ងៃផ្លុះចាំងដល់ច្រើន ទើបធ្វើឲ្យចំហៀងលោកខាងជើងជារដូវរងា ចំហៀងលោកខាងត្បូងជារដូវក្តៅទៅវិញ តែងតែផ្លាស់ប្តូរគ្នាដូចេះដាច់ឆ្នាំ ។

រដូវក្តៅនឹងរដូវរងានេះជារបស់មានប្រចាំនៅគ្រប់ៗតំបន់ក្នុងលោកនៅទៅក្នុងតំបន់ខ្លះរដូវទាំងពីរមានយេះវែលស្មើគ្នាក៏មាន មិនស្មើគ្នា

កំមាន តែមានរយៈវែងខ្លីជាងគេ, ស្រែបតែភូមិប្រទេសនឹងការណ៍ហេតុផ្សេង ។ នៅតំបន់នោះ ។ ។

ព៌- ផ្នែកភូមិភាគផ្សេងៗក្នុងលោក- តាមទឹកសមុទ្រដែលចាំងមកកាន់ផ្ទៃពិភពនេះមិនមែនធ្វើឲ្យផ្ទៃពិភពបានទទួលកំដៅថ្ងៃស្មើ ។ គ្នាគែបតំបន់ទេ តែតំបន់ខ្លះបានទទួលកំដៅថ្ងៃច្រើន តំបន់ខ្លះបានទទួលកំដៅថ្ងៃតិច ហេតុដូចនេះ ពីព្រោះពិភពលោកមានអាកាសរុំព័ទ្ធជុំវិញគ្រែតដូចពោលមកខាងលើនេះ ដាបច្ចុយយ៉ាងស្មើគ្នាធ្វើឲ្យផ្ទៃផែនដីនៅតំបន់ខ្លះក្តៅខ្លាំង តំបន់ខ្លះក្តៅតិច ។ តំបន់ខ្លះត្រជាក់ខ្លាំង តំបន់ខ្លះត្រជាតិច ។ អ្នកប្រាជ្ញភូមិសាស្ត្របានញែកបំបែកផ្ទៃផែនដីនេះជា ៥ ភាគ គឺ:

ក- ភាគក្តៅ- ភាគនេះមានអាណាខ្សែដូចជាប់នៅជុំវិញខ្សែស្រូឡូ (Equateur) ខាងលើនៅចន្លោះនឹងខ្សែ ត្រូពិកដុងតង់សេរ (Tropique du cancer) ខាងក្រោមក្បាលនៅចន្លោះនឹងខ្សែត្រូពិកដុងកាព្រីកន (Tropique du capricorne) ខ្សែទាំងពីរនេះនៅឃ្លាតឆ្ងាយពីខ្សែស្រូឡូស្មើគ្នា ដែលមានប្រវែង ២៣ អង្សា ជាខ្សែនៅកន្លែងខ្ពស់បំផុត នឹងចាប់ផុតកន្លែងត្រជាក់ដែលយើងល្មមមើលឃើញជួនណាតិច្ច នៅចំពីលើកំពូលរបស់យើងបានកន្លះពេលថ្ងៃត្រង់ជាក់ បើឡើងខ្ពស់ឡើងៗលើផ្ទៃផែនដីមកគ្រាមដល់ខ្សែត្រូពិកទាំងពីរ ដែលមានប្រវែង ២៣ អង្សា ជាខ្សែនៅកន្លែងខ្ពស់បំផុត នឹងចាប់ផុតកន្លែងត្រជាក់ដែលយើងល្មមមើលឃើញជួនណាតិច្ច នៅចំពីលើកំពូលរបស់យើងបានកន្លះពេលថ្ងៃត្រង់ជាក់ បើឡើងខ្ពស់ឡើងៗលើផ្ទៃផែនដីមកគ្រាមដល់ខ្សែត្រូពិកទាំងពីរ

ខ្សែក្រាស់ពីរនេះ ទំនងមិនជាឃើញផ្លូវគាងនៅចំពីលើក្បាលរបស់យើង ទេក្នុងរយៈពេលថ្ងៃត្រង់ដាច់ ហេតុនេះហើយបានជាភូមិភាគនៅក្នុងន័យនេះ ខ្សែក្រាស់ពីរនេះមានតំណៅថ្ងៃខ្លាំងក្លាជាងគេបង្អស់ ។

១— ភូមិភាគរងាខាងលើឬខាងជើង ភូមិភាគចំណែកនេះ មានឈ្មោះគាងចំ (Arctique) ដែលនៅឃ្លាតឆ្ងាយពីអំពូលាលោកខាងលើ ២៣ ½ អង្សាគ្រឿងតំណាត់ ក្នុងភូមិភាគនេះ ផ្លូវគាងរះខ្សែនផុតពីដើងមេឃយ៉ាង ច្រើនក្រែ ២៣ ½ អង្សាប៉ុណ្ណោះតែងតែជូរក្តៅ ហេតុនេះពន្លឺដែលចាំងធ្លុះទៅលើផ្ទៃផែនដីចំណែកនេះឃើញមើលឃើញតិច ព្រះគាងរះដើរបែរកៀង ដែលមិនចំពីលើផ្លូវស្រុកយើងនេះទេ ជាហេតុធ្វើឲ្យមានតំណៅថ្ងៃតិចនឹងមានអាកាសត្រជាក់ខ្លាំងណាស់ ។

៣— ភូមិភាគរងាខាងក្រោមឬខាងត្បូង មានអាកាសធាតុពីថ្ងៃដូចជាភូមិភាគរងាខាងលើដែរ ផ្សេងគ្នាតែត្រង់ចំណែកដុំទៀកំពូលលោកខាងត្រមោះមានឈ្មោះគាងចំក (Antarctique) ជាត្រឿងតំណាត់ ។

ឃ— ភូមិភាគមជ្ឈិមរងាខាងលើឬខាងជើង ត្រង់ភូមិភាគចំណែកនេះ គាងផ្លូវគាងរះមិនក្តៅខ្លាំងមិនត្រជាក់ពាក់កណ្តាលទេ. (climets tempérés) តំណាងមិនក្តៅខ្លាំងត្រាកែផ្ទៃមនុស្សឲ្យដុះចម្រើន

ឬរឿងខ្លាំងពាលំនៃរដូវកាមិនកើតទុំនេះ ។ ប៉ុណ្ណោះទេ ឮសូរដែលនៅភពនីមួយៗ ក្នុងភូមិភាគចំណែកនេះ ស្មុគស្មាញមែនទាមទារ ខាងចំណេះចេះដឹងល្អ ខាងសេចក្តីចំរើនជាងពួកមនុស្សនៅភូមិភាគដទៃ ទៀតកន្លះលោក ។

ជ — ភូមិភាគមិនក្តៅមិនរងាខាងក្រោមឬខាងត្បូង — ភូមិភាគចំណែកនេះក៏មានអាកាសស្រួលល្អដូចខាងលើនេះដែរ ហើយពួកមនុស្សនៅភូមិភាគចំណែកនេះ ក៏មានសេចក្តីឱ្យគួរដូចពួកមនុស្សខាងលើដែរ ។

ឈ — ការប្រៀបធៀបពេលមោងៗ — កន្លះណាដែលលោកវិលពីទិសខាងលិចទៅទិសខាងកើតនោះ ពេលមោងកន្លះតំបន់ផ្សេងៗ លើពិភពលោកមែងខុសៗគ្នា គ្រប់ៗ អង្សា កន្លះ ១ អង្សា ប្រមាណ ៤ នាទី ។ តាមទន្លឹងនេះកន្លះ ១៥ អង្សាខុសគ្នាប្រៃលាស ១ មោងដល់ ១៨០ អង្សាខុសគ្នាដល់ ១២ មោង ហេតុនេះទេបានយើញថាវេលាថ្ងៃត្រង់ជាក់នៅស្រុកអ្នកយើងនេះ ប្រទេសនីមួយដែលនៅខាងកើតស្រុកអ្នកធ្លាយជាវេលាថ្ងៃរសៀល ហើយប្រទេសមួយទៀតដែលនៅខាងលិចធ្លាយជាវេលាព្រឹកព្រហាមទៅវិញ ហេតុទាំងនេះព្រោះព្រះអាទិត្យរះឡើងកន្លះតំបន់ផ្សេងៗ មិនស្មើគ្នា ហ្នឹងឯង ។ តាមធម្មតាប្រទេសដែលនៅខាងកើតមែនបានយើញជួងអាទិត្យរះឡើងមុនគេនឹងពេលដែលថ្ងៃលិចទៅមុនប្រទេសនានាដែលនៅទិសខាងលិច ។

៩— អ៊ំពីដួងចន្ទ្រឬព្រះចន្ទ្រ — ដួងចន្ទ្រជាភ្លាយចរាំវរបស់លោក រមែងវិលច្រកក្បាលជុំវិញលោក ១ណា:ដែលលោកគោចរច្រកក្បាលៅតាមដុំវិញដួងអាទិត្យនោះ ដួងចន្ទ្រនៅឃ្លាតឆ្ងាយពីលោកច្រមាណ ៣៨២.១៤៤ គីឡូម៉ែត្រហើយវិលដុំវិញខ្លួនឯងនឹងវិលច្រកក្បាលដុំវិញលោកក្នុងរយៈពេលវែងគ្នា គឺជារយៈ ៤៧ ថ្ងៃ ៧ម៉ោង ៤១ នាទី ពន្លឺដែលផ្សាយចេញពីដួងចន្ទ្រនេះជាពន្លឺដែលបានទទួលមកពីដួងអាទិត្យ ឯទំហំដួងចន្ទ្រគេមានខ្នាតតូចជាងលោកច្រមាណ $\frac{1}{4}$ ភាគ ដួងចន្ទ្រគោចរៅតាមវិថីមានល្បឿនលឿនច្រមាណមួយម៉ោង ៣.៦៦០ គីឡូម៉ែត្រ ។

១០— អ៊ំពីដួងបន្ទ្ង — ដួងអាទិត្យរមែងច្រកដងវែងក្បែរយើងជារង្វង់មូលជានិច្ច តែដួងចន្ទ្រមិនមានសណ្ឋានដូច្នេះជានិច្ចទេ គឺយប់ខ្លះយើងមើលឃើញដួងចន្ទ្រពេញវង់ យប់ខ្លះឃើញតែភាគណ្តាលយប់ខ្លះឃើញដួងចន្ទ្រតែបន្តិចៅក៏មាន ហេតុដែលគេមើលឃើញដួងចន្ទ្រមានសណ្ឋានដូច្នេះ ពីព្រោះដួងចន្ទ្រមិននៅទីឯងតែកន្លែងមួយឡើយ ។

១១— អ៊ំពីសូរ្យគ្រាសនឹងបន្ទ្គ្រាស — ពេលដែលដួងចន្ទ្រវិលច្រកក្បាលដុំវិញលោកហើយ ពិតជាលោកគោចរដើរច្រកក្បាល

ដុំវិញដួងអាទិត្យ ដូចបានពោលមកខាងលើនេះ មានបួនឋានលើរបស់ចាំង
ឈ្មោះ ចួនជាគោចរនៅចំគាគីរបស់ចាំង ៣ នៅកន្លែងជួរជាមួយគ្នាដូចជា
ខ្សែបន្ទាត់ តែដំណើរនេះមិនមែនមានជាន់ច្បាស់ យូរៗ ទើបបួនជាមានម្តង
ជាបច្ចុយឈ្មោះសំខាន់ដែលនាំឲ្យកើតផល ២ ប្រការ គឺកន្លែងណេះនេះស្មើ
ព្រះអាទិត្យចាំងចំដួងចន្ទ្រដ្ឋើឲ្យដួងចន្ទ្រមានស្រមោលមកចំលោក ទើប
ធ្វើឲ្យផែនពិភពចំណែកខ្លះនឹងស្រមោលមួយណេះយើងហៅថា កើតសុរ្យ-
គ្រាស ។ បើបែរជាផ្លាស់កន្លែងគោចរ គឺលោកបើងនៅកណ្តាល ព្រះ
អាទិត្យបញ្ចាំងស្មើមកចំលោកយើង ធ្វើឲ្យលោកយើង ឮ ចំហៀងទៀត
ចុះស្រមោលទៅចំដួងចន្ទ្រ ទើបធ្វើឲ្យដួងចន្ទ្រងងឹតស្រអាប់ ខណៈនេះ
យើងហៅថាកើតចន្ទ្រគ្រាស ។

សុរ្យគ្រាសក្តី ចន្ទ្រគ្រាសក្តី មិនកើតមានឡើងជានិច្ចទេ យូរៗ
ទើបមានម្តង ព្រោះតាមធម្មតាការគោចរបស់ដួងចន្ទ្រមិនសូវបានមកជាប់
ចំខ្នងជាមួយគ្នានឹងលោកនឹងព្រះអាទិត្យទេ ។

វគ្គទី ២

១២ -- អំពីផ្ទៃផែនដីនិងទឹក -- ផ្ទៃផែនដីនឹងទឹកនៃពិភព
លោកមានចំនួនប្រមាណ ៥១០. ០០០. ០០០ គីឡូម៉ែត្រក្រឡា ដែលជា
ផ្ទៃផែនដីប្រមាណ ២៩ ភាគក្នុង ១០០ ភាគ (១៤៧. ០០០. ០០០

គិតជាប្រាក់ (តម្លៃប្រាក់) ដែលមានតម្លៃប្រមាណ ៧៦ ភាគរយ ឬ ១០០ ភាគ (៣៦៣.
០៩១.០០០ គិតជាប្រាក់) ។

ផ្នែកផ្នែនដីនេះនៅសល់ភាគខាងជើងនៃពិភពលោកដែលមាន ២ ភាគ
ក្នុង ៧ ភាគ (ប្រមាណ ១០១.០០០.០០០ គិតជាប្រាក់) ដែល
ក្នុងភាគខាងត្បូងតែម ១ ភាគប៉ុណ្ណោះ (ប្រមាណ ៤៧.០០០.០០០
គិតជាប្រាក់) ។

មានមួយ ១.០ទៀតដែលយើងត្រូវដឹង គឺគឺមានផ្នែកផ្នែនដីនៃពិភព
លោកជាងពាក់កណ្តាល ផ្នែកតាំងនៅទីដែលមានអាកាសល្អត្រូវនឹង
ចំរើនរឹងរឹងរបស់មនុស្សជាតិ ។ ចំណែកខាងទីដែលមានអាកាស
ធ្ងន់ខ្លាំងនោះមិនមែនជាទីនាំឲ្យមានចំរើនខាងនយោបាយ ឬវប្បធម៌
មនុស្សលោកទេ ។

១៣ — អ្នកទ្វីបផ្សេងៗ — ពិភពលោកនេះ ប្រកបដោយ
ផ្នែកផ្នែនដីធំតូច ដែនដីនេះ គេបែងចេញជាភាគៗ ហៅថាទ្វីប និមួយៗ
មាន ៧ ទ្វីប គឺ:

(មានត)

ប្រវត្តិភូមិមហោរីនិងភូមិមហោរីតំណាពាន្យ

ឧបញ្ហាខេត្តកំពង់ចាម ស្រុកស្ទឹងត្រង់ ឃុំចុងឃ្នៀង

មហោរីជាន់ក្រូច

ប្រែបជាន់ជើម

ភូមិ ១ នេះ ដែលហៅថា "មហោរី" ជាភូមិខ្មែរ ១ ឃ្លាំងដែលមានមកតាំងពីបុរាណកាល ដោយខ្មែរបានផ្លាស់ប្តូរឆ្លើតខ្លាំងដោយគំនិតខ្លួនឯងជាដំបូង ក្នុងរយៈដែលខ្មែរចុះមកនៅក្នុងប្រទេសកម្ពុជានេះហើយ មិនមែនជាបានប្រែបមកអំពីប្រទេសណាទាំងស្រុង ឬបានប្រែបមកអំពីប្រទេសឯណាទាំងមួយក៏ទេ គឺកើតឡើង ដោយខ្មែរម្នាក់ឯងសុទ្ធសាទ្បើងនេះសូម្បីសម្តេចព្រះមហាក្សត្រីជាទុក្ខព្រួយ អ្នកតែងប្រវត្តិភូមិផ្សេងៗ របស់ស្រុកតាកែវ ភូមិមហោរីជារបស់ខ្មែរ ហើយស្រុកផ្សេងក៏ប្រែបអំពីខ្មែរទៅលើង ១ ជាន់ទៀត ។ ទន្ទេះបើនិយាយស្រាវជាវរកទៅតទៀតឃើញពិតជាដូច្នេះ ព្រោះនាមប្រទេសចាំងអស់រៀងលើងតែប្រទេសស្រុក ១ ចេញ រាមនិងមិនមានភូមិប្រែបនេះទេ ។

ក៏ភូមិមហោរីនេះក្នុងជាន់ដើមខ្មែរកាន់កូន ១ នៅមានគ្នាប្រមាណ ៤-៥ នាក់ប៉ុណ្ណោះ គឺ:

១ អ្នកប្រែបនាំបានទីតាំងដោយខ្លួនឯង

២ អ្នកកូនខ្មែរ ២ (គឺខ្មែរ)

៣ អ្នកគ្រែះចាប៉ី

៤ អ្នកផ្លុំខ្លុយ

៥ អ្នកដំស្គរជោន

កន្លះសម័យជាខំដើម អ្នកលេងភ្លេងហោរ៉ាំនិងគ្រឿងភ្លេងហោរ៉ាំ
ខាងតែប៉ុណ្ណោះ អ្នកស្រែកនាំគ្នាលេងទទួលសម័យលេងជាការខ្លួន ។

សម័យក្រោយ ៗ មក មានអ្នកតំណែងថ្មីមកគ្រឿងភ្លេងហោរ៉ាំខ្សែនិងខ្យល
ដោយលេងជាប់មក លុះមកដល់សម័យនេះ ភ្លេងហោរ៉ាំដើមមានគ្រឿង
ច្រើន ហើយជាច្រើនថ្នាំង ហៅថា មហោរ៉ាំគ្រឿងពិណពាទ្យ ១ ថ្នាំង
មហោរ៉ាំគ្រឿងខ្សែ ១ ថ្នាំង ដូចមានអធិប្បាយតទៅនេះ

ប្រាំគ្រឿងមហោរ៉ាំគ្រឿងពិណពាទ្យឬមហោរ៉ាំគ្រឿងធំ (រាំធំ)

កន្លះសម័យជាខំដើមដំណាក់ អាចលេងភ្លេងមហោរ៉ាំច្រើនមានតែ
ភ្លេងប្រើ ៦ លេង, លុះសម័យតមក ទើបប្រើសខ្លះ ស្រីខ្លះ លេង
រួមរំដាំជាមួយគ្នា ដោយយកស្រីជាអ្នកច្រៀងនាំបទ ព្រោះស្រីច្រៀង
មានសំឡេងពីពេះផ្អែមល្អជាងប្រុសច្រើនដង ។ សម័យ
ក្រោយនោះមកទៀត ប្រមាណតាំងពីសម័យក្រុងលង្កាដំណាលមក ទើប
កើតមានគ្រឿងមហោរ៉ាំស្រុង (គ្មានប្រុសលាយ) ១ ឈុតទៀត ដោយ
មានពួកអ្នកចាំដែលមានឧត្តមជាន ធំធំមានបន្ទាប់ពីច្រើនផ្តើមបង្ហាត់ពួកស្រី
ខ្សែលេងឡើង ដើម្បីប្រគំបំរើខ្លួន ។

កាប់តាំងតែមានពួកស្រីស្លៀកមាន់ហាវឡើងហើយ ប៉ែរហាលជាមានមនុស្សច្រើនមែន ទើបជាហេតុឲ្យមានអ្នកគិតប្រែកែចន្ទ្រមេត្តិនមហោរាច្រើនឡើងយ៉ាងលំដាប់មក តាមដែលប្រាកដក្នុងវេលានេះមានដល់ទៅ ១២ យ៉ាង គឺ:

១ ច្រកខ្សែ ៣

២ តូ: ទេ

៣ ខ្ចីយ

៤ រោគឯក មាស

៥ រោគឯក

៦ រោគជុង គឺ រោគសំឡើងធំ

៧ រោគតូច គឺ រោគសំឡើងតូច

៨ គង់ធំ

៩ គង់តូច

១០ ស្តារោគ

១១ រមា

១២ ឈឺធ្មេញ (គោះបង្ហាក់) ។

មហោរាពិណាពាទ្យនេះ ច្រើនមានតែប្រុសសោះ ឬក៏មានស្រីណាយផង ១ នាក់ ២ នាក់ប៉ុណ្ណោះ ដៅមានលង់ជាបដល់សព្វថ្ងៃនេះ ។

មហោរីគ្រឿងខ្សែ

(ខ្លះហៅភ្លេងខ្មែរ)

ការដែលមានឈ្មោះថា "មហោរីគ្រឿងខ្សែ" ព្រោះភ្លេងនេះប្រើគ្រឿងខ្សែច្រើនជាងភ្លេងដទៃ ពាក្យសំឡេងសោតក៏ព្រោះដើរតាមណាស់ ហើយសំឡេងស្រាលជាងមហោរីគ្រឿងធំ ឬមហោរីពិណពាទ្យ, សម័យនេះ មហោរីគ្រឿងធំពុំសូវមានលេងណាស់ទេ ច្រើនលេងតែមហោរីគ្រឿងខ្សែ។ នេះហើយជាគ្រឿងលេងរបស់ពួកស្ត្រី ទើបមានឈ្មោះថា "ក្រុមមហោរីស្ត្រី" មហោរីគ្រឿងខ្សែនេះ វង់ធំ មានគ្រឿងភ្លេង ១២ យ៉ាងដែរ:

១	ចែងខ្សែ ៣	គ្រឿងកូត
២	ចែងតួ	"
៣	ចែងដែ	"
៤	ចាប៉ី	គ្រឿងគះ
៥	ឆះរេ	"
៦	ខ្ទុង	គ្រឿងផ្លុំ
៧	រនាតឯក	គ្រឿងវាយ
៨	រនាតឆ្អឹង	"
៩	ឆគីរ៉ាំ	"

១០ ស្គរគោន	៤គ្រឿងខ្លះ
១១ រមនា	"
១២ ឈឹង	៤គ្រឿងគោះបង្ហាក់

រួម៤គ្រឿងក្នុងវា ១២ តែមកតាមសម័យនេះ អ្នកខ្លះគេថែម គាតា-
វេយ៉ុង ៤គ្រឿងក្នុងចាំកាំង ១ មកទៀត ហើយបន្ថយខ្លះទៀត ចេញ
ក៏មាន ។

រឿង ស៊ុន - យ៉ាត់ - សេន

អ្នកនយោបាយឯកជនជាតិចិន ការងារចាប់ឃុំនៅក្រុងឡុនដ្រ

លោក ប៉ាយ - ប៊ក ប្រែពីភាសាបារាំង

សេចក្តីពណ៌នាពីហេតុការណ៍ដែលគេមិនសូវបានដឹង ក្នុងដំណែប្រាត្តិរបស់លោក

ស៊ុន - យ៉ាត់ - សេន លោក George eiler រៀបរៀង

កាលណៈដែលលោក ស៊ុន - យ៉ាត់ សេន មានជីវិតរស់នៅ ខ្សឹមក្តី គ្រាយនៃលោកខ្លួនឯងប្តូរមួយៗហើយក្តី មានពួកកាសែតបានសរសេរអំពីប្រត្តិដ្ឋានរបស់លោក ដែលគេតែងតែយល់ថា លោក ស៊ុន ជាមេបង្កការចលាចលយ៉ាងហ៊ានកាត (Agitateur vulgaire) ប្តូរជាវីរបុរសរបស់ជាតិ (Héros national) ដោយពិនិត្យទៅតាមកាលកំរិយារស់នៅ, តាមការដែលធ្លើ, ក្នុងចំណោមសង្គតិនិន្នាការនៃពួកបក្ខពួកនយោបាយរបស់លោក ឬតាមការយល់ច្បាស់ញញួលនៃបក្ខពួករបស់លោក ។

ក្នុងគតិមានន័យនោះ មានសៀវភៅ ១ បោះពុម្ពចេញផ្សាយក្នុងរាជធានីឆ្នាំ ១៩៦៥ នៅក្រុងណែវយ៉ក ឈ្មោះថា « ស៊ុន - យ៉ាត់ - សេន ទីឧសាធារណរដ្ឋចិន » ។ អ្នកនិពន្ធសៀវភៅនេះឈ្មោះ ប៉ូល - លីណាមើរហ្គ (Paul Linaberger) ដែលជាមិត្តភក្តិរបស់លោក ស៊ុន ហើយក៏ចាប់បានរួមដំណើរជាមួយនឹងលោក ស៊ុន ក្នុងគ្រាដែលធ្លើដំណើរទៅ

ការទៅបរទេសដែរ ដោយសារតែ ។ អ្នកនិពន្ធនេះ បានសរសើរគុណ
អំពីតម្លៃរបស់ចំណាកការបដិវត្តន៍ (Père de la Révolution) លោកធ្លាប់
ទៅរៀនទៅសាលារៀនជាមួយគ្នា រួចតមក លោកបានតាមលោកស៊ីន
ទៅកន្លែងផ្សេងៗយ៉ាងច្រើនថ្ងៃ ។ ដែលលោកបានចំពេញ ។ ប៉ុន្តែ
មានរឿងមួយ ការណ៍ប្រតិបត្តិរបស់មហាបុរស (Grand homme)
នេះ គឺត្រង់រឿងដែលគេយកខ្លួនលោក ស៊ីន - យ៉ាត - សេន ទៅឃុំខ្លួន
ទុកនៅក្រុងឡុងដ្រ ដែលតាមបង្គាប់ស្តេចដូចមានៈនោះ ពួកអ្នកនិពន្ធតុំសូវ
បានសរសេរខុសទេ ។ ឯដំណើររឿងឥស្ប៊ូនីដែរគ្រោះថ្នាក់ (Aventure)
នោះលោកស៊ីន បានសរសេរដោយខ្លួនឯងក្នុងសៀវភៅ ១ ដល់មក
ឥឡូវនេះ គេរកមិនឃើញទេ ។ សៀវភៅនេះ គេបានបោះពុម្ពនៅក្រុង
ប៊ែស្តូល គ. ស. ១៨៨៧ ឈ្មោះថា Kidnapped' in London ។ ក្នុង
សៀវភៅនេះ មានបុរេតិហាសគួរឲ្យពិតពិលរមិលរមិលដែលឆើតឆ្នៃ
ចេតមកតាមរឿង ក្នុងចំនេះជាច្រើនផ្នែក ។

លោកស៊ីនបានសិក្សាវិជ្ជាវេជ្ជសាស្ត្រ នៅមន្ទីរពេទ្យតូចក្នុងភូមិ
សាសនា ជាតិអង់គ្លេស អាមេរិកាំង នៅស្រុកកន្លាំងក្នុង គ. ស. ១៨៨២
ដែលមានលោកឧត្តមវេជ្ជបណ្ឌិតឈ្មោះ (Ker) ជាអធិបតី ។ លោក
បានចំពេញកិច្ចការនេះ ពី គ. ស. ១៨៨៧ ទៅដល់ គ. ស. ១៨៨៦
នៅវិទ្យាល័យវេជ្ជសាស្ត្រ ក្រុងហុងកុង ។ លោកបានប្រឡងជាប់

សញ្ញាប័ត្រ មកប្រមប្រាញ ខានវេជ្ជបាស្ត្រ ទំនិសិល្បសាស្ត្រ ដោ
ក្រុងហុងកុង ។

លោកមានទំណាក់ទងនៅក្រុងម៉ាកាវ (Macao) ដែលមានពួកថ្ម
ដាំជាតិចិនច្រើនជាងគេ ក្នុងចំណោះនោះ ពួកគង្វៀមតែងតែសុខាភិបាល
ជាតិចិន ហើយលោកជាយោកាត់ទាក់ ប៉ុន្តែពួកខ្មែរវិញ
ដាតំណាងប្រទេស ហើយកាលប្រាប់ពាក្យយោគសែលហាមមិនឲ្យធ្លាប់ដួលមុខ
ឯទីតាំង គឺប្តូរលេណាតែគ្មានសញ្ញាប័ត្រជាតិពាក្យយោគសែលហើយ គេ
មិនចូលស្គាល់ថាជាអ្នកវេជ្ជបណ្ឌិតឡើយ ។ ពួកគេនាំបង្កើតទេវស័ក្តិជា
ច្រើនយ៉ាង ពាល់ដែលលោកស៊ុនខ្ចាយចេញតិចតួចនោះទៅនៅស្រុកគង្វៀ
ទៀត ។ ម៉ូរីស ឡេវ៉ាន់ដាវស្គី (Maurice Levandaw Sky) បានផ្សាយតិ-
មានលោកស៊ុន-យ៉ាត់-សេន ក្នុងទស្សនាដ្ឋី ដឺម៉ុងដ៍ (revue des deux
mondes) ។

នៅក្រុងម៉ាកាវ លោកស៊ុន-យ៉ាត់-សេន បានចាប់ផ្តើមធ្វើនយោ-
បាយតាដាវ:ឡើង ដាបឋម ក្នុងឆ្នាំ ១៩២៥ ដោយមាន «បំណងចំណែង
ប្រៃរៀបរាប់ដែលគេបានឃើញជាក់ច្បាស់ ក្នុងកាសែដែលបង្កើត
គណបក្សយុវជនចិន (Jeune Chine) ឡើង» ។

ពេលកស៊ុនបានសរសេរសៀវភៅលោកទុកថា នៅក្រុងម៉ាកាវនោះ
ហើយ ដែលលោកបានសិក្សាខាងវិទ្យានយោបាយជាបឋម ហើយបាន

ផ្តើមធ្វើបដិវត្តន៍ខាងនយោបាយ (mouvement politique) ដែលលោក
គិតរកនាមគណបក្សអ្វី ឲ្យបានសមរំជាងនាម «យុវជនចិន» នោះគ្មាន ។

លោកបានថ្លែងអំពីសេចក្តីឃើញដ៏ថ្លៃថ្លា នៃពួកគណបក្ស
នេះ ទំនងដើម្បីបញ្ចេញមតិឲ្យឃើញជាក់ច្បាស់តាមប្រពៃណី លោក
ក៏បានអធិប្បាយអំពីចរិយាលាមកយ៉ាងវែកលែង នៃផ្លូវកិច្ចការបត្រពត្តិ
និយមចិន ។

ពួកអ្នកនាំកែប្រែបែបចាស់ (Réformateurs) គ្រាយដែលបាន
ថ្វាយលិខិតដល់សម្តេចព្រះចក្រពត្តិ ។ ពុំព្រមទទួលយល់ព្រម ថែម
ទាំងបានជាក់ព្រះពន្ធឲ្យចាប់ខ្លួនដល់ពួកនោះវិញផង ។ ដើមពួកគេ
គិតសម្រេចថាត្រូវប្រែយុទ្ធវិធីវិញ - ឯការខំនឹងនេះដែលគេអាចនឹងធ្វើទៅ
បាន ដោយមានហេតុច្រើនយ៉ាង គឺការគាត់អន់ចិត្តរវាងពួកពិជ័យ
សង្គ្រាមនឹងព្រះមហាក្សាធិរាជ, ការតយុទ្ធរវាងពួកក្រមនគរបាលនឹងពួក
ពាណិជ, អំពើទុច្ចរិតនៃទាហានស្តេចចក្រពត្តិដែលត្រួតត្រាខេត្តក្វាង
(Kouangs) ទាំងពីរ ។

គេបានធ្វើគ្រាងការ ដើម្បីទំនងឲ្យដណ្តើមយកខេត្តកន្តាំង, ចាប់
ពួកមន្ត្រីបង្ខំឲ្យលះបង់សិទ្ធិអំណាចគ្រប់បែប ។ ឯកិច្ចការនេះ ត្រូវបំពេញ
ជា ២ ផ្លូវគឺកងតាលខ្លះមកពីក្រុងស្វាតាវ (Swatow) ១ កងទៀតមកពីមាត់

ខ្ញុំខាងលិច ត្រូវចំមួយគ្នាសម្រេចយុទ្ធវិធី ខែវិច្ឆិកា ឆ្នាំ ១៨៧៧ កន្លងថ្ងៃណាមួយក៏បាន ។

ចើតុងជាយ៉ាងណាក៏ដោយ ក៏គង់តែគេយើញខ្លួនឯងបុព្វហេតុសព្វគ្រប់ ហើយពួកបះបោរទាំងអម្បាលម៉ាន កំពុងជាប់តន់ខ្លាំងខ្លាយស្រាប់ ។ លោកស៊ុន-យ៉ាត់-សេន ជាន់ឮពីនោសកម្មរបស់ត្រីនគ្រា ជាន់អញ្ជើញទៅគ្រងមាគារតាមកប៉ាល់ ហើយនៅទីនោះ ៦៤ ម៉ោង ទើបលោកចេញដំណើរទៅហុងកុងវិញ ។ នៅទីនោះ លោកជាន់ស៊ើបសួរពីលោកព្រឹទ្ធាចារ្យរបស់លោក ហើយជាពិសេសណាមិត្តរបស់លោកផង គឺលោកជេម កន់ឡី (James Cantlie) ហើយលោកជាន់ជួបមាបលោកកន់ឡីនិងគ្រោងថ្នាក់ដែលខ្លួនលោកត្រូវទទួល ។ លោកគ្រូពេទ្យនេះជាន់ខ្ចីឧទ្ធរណ៍ឲ្យតំណាងមេធាវី (Avocat) នៃលោកស៊ុនពុំព្រមធ្វើតាម ហើយជាន់បេញដំណើរទៅដល់កូបេ រួចទៅយ៉ូកូហាម៉ា ហើយលោកផ្លាស់សំលៀតបំពាក់ចិនបេញជាជប៉ុន ឆាត់សក់បេញខុកពុកមាត់ ២ - ៣ ថ្ងៃ ក្រោយមកទើបលោកធ្វើដំណើរទៅហូណូលូលូ (Honolulu) ដល់មកកន្លែងខែឆ្នូរ៉ាំងឆ្នាំ ១៨៩៦ ជាន់ទៅដល់ក្រុងសង់ហ្វ្រង់ស៊ីស្កូ (San Francisco) ហើយកន្លះរាត្រី ៣ ទៀតមកក្រោយទៀត ទើបលោកធ្វើដំណើរទៅដល់ប្រទេសអង់គ្លេស ។

កាលដែលគេចាប់ខ្ញុំ (ស៊ីន - យ៉ាត់ - សេន)

ចាន នៅក្រុងឡុងដ្រ

ថ្ងៃ ១ ខែកក្កដ ឆ្នាំ ១៨៨៦ ខ្ញុំចុះមកដល់ទីក្រុងឡុងដ្រហើយចាន់តាក់អាស្រ័យនៅសណ្ឋាគារ ប៉ាតសេលអូស្ត្រង់(Hôtel Haxel au Strand) ដល់ព្រឹកស្អែក ខ្ញុំចុះទៅដល់គេហដ្ឋានលោកតង់ទ្ធិ លេខ ៤៦ ផ្លូវដេវ៉ង់ស៊ើរ (Devangshir) ដែលចានទទួលខ្ញុំដោយសេចក្តីពាក់ព័ន្ធ ឯលោកតង់ទ្ធីនឹកឃើញ ចានរកជួលបន្ទប់ ១ ឲ្យខ្ញុំនៅលេខ ៨ ក្រោយគ្រិនចាស (Grays - InPlace) នៅសណ្ឋាគារគ្រោយ (Gray) តង់មណ្ឌលហូលចិរ៉ែន (Holbarn) ។

លោកស៊ីន ចានធ្វើតនូចាសដើរមើលទីក្រុងឡុងដ្រដើម្បីទស្សនាសាមន្ទីរ និងបុរាណវត្ថុ ដែលគេចានប្រមូលទុកក្នុងនោះដែលនៅកណ្តាលភូមិភាគ ពិភពលោក (Centre de l'Univers) ។

ដែលនាំឲ្យខ្ញុំដែលឆាជាតិចិនកើតចិត្តរីករាយសប្បាយជាពន្លឹក គឺការតមនាគមន៍ខាងយានជំនិះដូចជាពួករថឡែន, រថក្តឹង, រទេះទូ, រទេះសេះជាន់ចាស់ ចេញចូលមិនចេះដាច់មិនចេះបង់គ្មានឈប់ឈរសោះ ។ ឯពួកក្រុមនគរបាលចានប់ពេញកិច្ច ពិនិត្យត្រួតត្រាយានភាមាន:ដោយហ្មត់ចត់ ។ល។ ។

២-៣ ថ្ងៃតមក ខ្ញុំបានទៅលេងតំណាងខ្លួនដែលលោកនាំខ្ញុំទៅស្នើរ
តែកាលថ្ងៃ ហើយបានត្រឡប់ចូលទៅកន្លែងខ្លួនប្តូរធ្វើការវេនសំរាលលោកផង ។
មានថ្ងៃ ១ ទៅកោះតំពុនខ្លួនមានការហារពីតលោកបានពណ៌នាពី
ស្ថានអគ្គិភ័យខ្លួនចំនួនថែលទៅដែលទីនោះ ហើយនិយាយតំណែងថាឲ្យខ្ញុំចូល
ទៅមើលលេងទីនោះបាន ។ ឯការហារលោកនិយាយថាសង្ឃឹងថា មិន
ត្រូវធ្វើដូច្នោះទេ តុំឲ្យលោកអញ្ជើញទៅដែលស្ថានអគ្គិភ័យខ្លួនចំនួន ត្រែង
គេចាប់លោកយកទៅប្រទេសចិនវិញ ។ ដោយក៏នាំគ្នាសើចឡើងទាំង
អស់គ្នា ដោយមិនបានយល់ដល់តំនិតដ៏ឈ្លាសវៃរបស់ស្ត្រី ដែលយល់
ហេតុផលដល់ទៅចំណុចផុត ។ ថ្ងៃស្អែក ១ ខែតុំ ទៅជួបលោកឧត្តមវេជ្ជ-
បណ្ឌិតម៉ាសុង (Manson) ដែលខ្ញុំធ្លាប់ស្គាល់ទៅហុងកុងជាច្រើនដង
រឿងពេល ។ លោកមានប្រសាសន៍រៀបរាប់ពាក្យតំណែងថា ត្រូវលោក
ទៅឲ្យធ្លាយពីស្ថានអគ្គិភ័យខ្លួនចំនួន ពីតមែនតែគេឲ្យដំណឹងយ៉ាងច្បាស់
លាស់តាំងពីរឿងនេះ ប៉ុន្តែខ្ញុំមិនដែលបានឃើញអគ្គិភ័យខ្លួនចំនួនដល់
ម្តងផង ។

ថ្ងៃអាទិត្យ ពេលព្រឹក ១១ ទៅកូឡូ ម៉ោង ១០ កន្លះ ខ្ញុំបានដើរលេង
តាមផ្លូវ ដ៏វែងសុង ដោយមានសង្ឃឹមថា នឹងទៅព្រះវិហារគ្រិស្តសា-
សនាជាមួយនឹងគ្រូពេទ្យពេទ្យតាំងញាតិសន្តានរបស់លោកផង ។ តែក្នុង ១
រំពេចនោះមានបងម្នាក់ចូលមកជិតខ្ញុំពីខាងក្រោយ ហើយសួរខ្ញុំថាតាសា

អង់គ្លេសថា លោកជាជាតិអីប៉ុន្មានទេ ? - ខ្ញុំក៏ឆ្លើយទៅវិញថា ខ្ញុំជាជាតិចិន ហើយមកពីខែត្រកន្តាំងវែង ។ បើដូច្នេះ យើងជាប្រជាជាតិជាមួយគ្នា ហើយនិយាយភាសាដូចគ្នា ព្រោះខ្ញុំមកពីខែត្រកន្តាំងវែង ។

(យើងត្រូវដឹងថា ភាសាអង់គ្លេសឬភាសាពិតស៊ុនអង់គ្លេស ("Pidgin" anglais) ជាភាសាដែលគេតែងប្រើជាភាសាសាធារណៈខ្លួនៗ បំពោះជនជាតិចិនដូចគ្នា ដែលនៅនិរមជនបទផ្សេង ។ ជារឿយអន្ទើ ឆ្ងាយពួកឈ្មួញមកពីស្ងាខ្លួ ហើយពួកឈ្មួញមកពីស្រុកកន្តាំង នៅឆ្ងាយពីគ្នាប្រមាណ ១៨០ មីល ប្រហែលចង់ដាច់ពីក្រុងឡុងដ៍ទៅលីវែរពូល (Lyverpool) ប៉ុណ្ណោះទេ ប៉ុន្តែពោលភាសាខុសៗពីគ្នា មិនអាចស្តាប់គ្នាបាន ។ ឯរបៀបអក្ខរាវិធីដូចគ្នាតាំងគស់នៅប្រទេសចិនទាំងមូល ។ ហេតុដូច្នេះពួកពាណិជ្ជការស្ងាខ្លួ មានកិច្ចការប្រស័យទំនិងចិនកន្តាំងនៅហុងកុង ត្រូវសរសេរសៅប៉ុត្រតាមអក្ខរាវិធីភាសាចិន ។ ប៉ុន្តែបើចិនកន្តាំងត្រូវការនិយាយទំនិងចិនស្ងាខ្លួ ត្រូវប្រើភាសាអង់គ្លេសទៅវិញ ។ សូមបញ្ជាក់ថា អក្ខរាវិធីរបស់ជប៉ុន ក៏មានលៃបតាមជូចគ្នាទំនិងរបស់ចិនដែរ ។

ដូច្នេះ បើចិនម្នាក់ជំនិយាយប្រស័យទំនិងជាតិជប៉ុនស្តាប់គ្នាមិនបាន គេអាចប្រើសរសេរអក្សរទំនិងក្រដាស ឬ លើដីខ្សាយល់សេចក្តី ស្តាប់គ្នាបាន ។

គេបានទាំងខ្ញុំទៅបន្ទប់ ១ នៅខាងត្រកាមគេហដ្ឋាននោះ ហើយមាន
មនុស្សពីរនាក់មកបង្គំឲ្យខ្ញុំឡើងទៅលើថ្នាក់ទី ១ បូលក្នុងបន្ទប់ដែលគេ
ប្រាប់ឲ្យខ្ញុំឈរចាំនៅទីនោះសិន ។ បច្ចាមិត្តនៅតែមិនឈប់ឈិនខ្ញុំឲ្យ
នៅទីនោះទៀត ក៏ទាំងខ្ញុំឲ្យឡើង ៧កាន់ថ្នាក់ទី ៣ ដែលមានបង្អួចតែ ១
ហើយមានចំរំដែកខ្លាំងផង ។ ខ្ញុំបានឃើញមនុស្សម្នាក់ចូលមកក្នុងទី
នោះ ដាមនុស្សចាស សក់ពុកចង្កាស្កូវស្រស់ហើយ ដេញក៏ចាត្រកអ័ត
ត្រមមកកាន់ខ្ញុំថា :

« ខែអ្នក ! ទីនេះជាប្រទេសចិន, ឥឡូវនេះអ្នកឯងនៅក្នុងប្រទេស
ចិនហើយ » ។

ដល់ដាក់តួបអង្គុយហើយ លោកនោះក៏សួរឈ្មោះខ្ញុំ ។ ក៏ឆ្លើយតប
ទៅវិញថា ខ្ញុំឈ្មោះសុន ។

លោកនោះនិយាយទទឹងខ្ញុំវិញថា អ្នកឈ្មោះ សុន-វេន (Sun Wen)
យើងបានទទួលលិខិតលោកពីបន្ទប់ចិន ប្រទេសអាមេរិកឲ្យដំណឹង
មកខ្ញុំថា អ្នកឯងបានដឹកកុម្មុ៉ាល់ឈ្មោះម៉ាសេស្ទ័រ តាលេបានដល់
ក្រុងឡុងដ៍នេះហើយ ទាន់បង្គាប់ឲ្យខ្ញុំរកចាប់ខ្លួនឲ្យបាន ។

ខ្ញុំក៏តបទៅវិញថា តើលោកចង់និយាយយ៉ាងណា ?

(មានត)

ឃុនសុន្ទរមេធី ញ្ញង - សឿង ប្រែ

(តទៅទំព័រចប់)

ហើយឆ្លងទៅប្រៃខុសខ្លះនឹងនោះ អ្នកខ្លះថាទៅថាឈ្មោះយនាំឲ្យខំនាស់ខ្លួនប្រយោជន៍ទៅវិញ តែមនុស្សពាលអស់ទឹងស្អប់ខ្ញុំមកហើយគេនឹងចោះបង់អកយោលលែងកាច់អាន ។

លោកន្ធរេខ្លិន - អប៊ី ខំប្រឹងឲ្យដំបូន្មានដល់បុត្រសំឡាញ់រហូតដល់លេងបាត់ស្មារតីអស់អាយុសង្ខារគេនឹងពេលនោះឯង, តាលវែលលោកន្ធរេខ្លួលអនិច្ចធម្មៅហើយ គេតំរៀបចំធ្វើបុណ្យបញ្ចុះសពលោកយ៉ាងអធិកអធម តាមសមគួរដល់ស័ក្តិយសរបស់លោក ។

និយាយដល់ត្រង់នេះ ខ្ញុំសែកសាដូគាបខ្លួលព្រះបាទសារ្យាថាបពិត្រព្រះករុណាជាម្ចាស់ជីវិតលើស្លឹង ស្តេចគាល់ហ្នឹមិនធុញគ្រាន់ទំនងខ្ញុំព្រះសណ្តាប់រឿងវែងគគ្គនយាយាំហ្នាំនេះយូរនោះទៀយ ទើបលោកយ៉ាំហ្នាំចាប់សារសំតួរឿងរបស់ខ្លួនតទៅទៀតថាដូច្នេះ

កាលធ្វើបុណ្យបញ្ចុះសពលោកន្ធរេខ្លិន - អប៊ីរួចហើយ អ្នកផងពាំងពួនគ្នាត្អាកត់ឈ្មោះថែមទៀបៀតខ្លួនហាស្ត្រីថា "បេតែខ្លួនហាស្ត្រីនេះកូនចាស់ស្លាប់" ព្រោះអ្នកកំណើតនេះតើតកូនកូនចាស់ស្លាប់ ។ តាមទំនៀមនៅប្រទេសនោះ កាលប៉ាមាតាបិតាខ្លួលអនិច្ចធម្មៅ កូន

ចៅត្រីវឈប់សមាគមចំនួនមួយនៃដោយឥតចេញទៅធ្វើការបានឆាប់ត្រឹម
ផ្ទះសម្បែងទេឬយ៉ា តើសំពុតនៅតែកន្ទុយដូចម្ដេចស្រួតស្រដាត់ដើម្បីកាន់
ខ្លួចំពោះរូបបុគ្គលដែលឬយ៉ាដ៏រឹតចៅនោះឯង ។ ចំណែកខាងចៅខ្មែ-
ឌិនហស្ស័ន មានសេចក្ដីខ្លួចព្រួយយ៉ាងវិលវិលហួសប្រមាណពេក
ព្រោះត្រាត់ឮថាមនុស្សចាកចិត្តសង្ឃាញ់ចេស់ខ្លួន, តាមទំនៀមស្រួល
ដែលគេត្រវឈប់សមាគមកាន់ខ្លួនតែមួយទៀ, ខ្លួនមែនទៅជាកាន់ខ្លួនឈប់
សំពុតក្នុងផ្ទះដល់ទៅពីរទៀ ដោយឥតបង្អាក់ឲ្យអ្នកណាយើញសោះ
ហើយឥតចេញទៅជួយធ្វើការកេងការដែនដីថ្លាយព្រះពាត្រកន្ទបាល់ស្លាប់
ទេឬយ៉ា តែតែអង្គុយយំកើតខ្លួមុខត្រមក្រំក្នុងលំនៅរបស់ខ្លួនតែម្យ៉ាង;
រឿងនេះនៅថណ្ដាលឲ្យព្រះពាត្រកន្ទបាល់ស្លាប់ខ្ញង់ព្រះពៃកេងយ៉ាងខ្លាំង
ព្រោះខ្ញង់ព្រះចិត្តចៅឃើញថាចៅខ្មែឌិនហស្ស័នព្រហើនគាងកាច
ហ៊ានប្រមាទមើលងាយដល់ព្រះចេស្ដា ទើបព្រះអង្គមានព្រះឫទ្ធារឲ្យ
ហៅអគ្គមហាសេនាថ្វាយចូលមកតាល់ជាប្រញាប់; សេនាបតីថ្មីនេះខ្ញង់
ទើបនឹងតាំងក្នុងកាលដែលលោកអគ្គមហាសេនាទូរខ្មែន-អលី ខ្លួល
មរណភាពទៅ តាលអគ្គមហាសេនាថ្មីមកដល់ហើយ ខ្ញង់មានព្រះពាត-
ឫទ្ធារចង្អាប់ឲ្យទៅឯផ្ទះ ទោចយោងអគ្គមហាសេនាចាស់ជាប្រញាប់ហើយ
ឲ្យរឹបយកផ្ទះសម្បែងខ្ទឹងកៀកកៀនស្រចំការចម្ការដំណាំតាំងអស់ត្រមាំង
ចាប់ចៅខ្មែឌិនហស្ស័នជាកូនមកផង ។

គ្រានោះ អគ្គមហាសេនាប្តី កំទួលព្រះពាហុឡើងក្រោមហើយ ចេញអំពីព្រះពាហុកាំងសំដៅទៅផ្ទះខ្មោចអគ្គមហាសេនាចាស់ ជាមួយនឹងព្រះពាហុអាជ្ញាហើយនឹងមេទាហានជាច្រើនរូប ។ មានឪពុកចេះខ្មែរឯនហាស្ត្រីន នៅក្នុងចំណោមមនុស្សទាំងអស់នោះដែរ បានដឹងរឿងនេះហើយ ក៏លបរត់ទៅមុនជាប្រញាប់ ដើម្បីឲ្យដំណឹងដល់ទៅហ្វាយនាយចេះខ្លួន ។ កាលទៅដល់ផ្ទះ បានឃើញចេះខ្មែរឯនហាស្ត្រីនកំពុងអង្គុយក្នុងបន្ទប់ប្រចាំការ ដោយសេចក្តីក្រែមក្រំស្រងូតមុខ ទើបឪពុកនោះចូលទៅគាបសង្កត់ខ្សែរដើង ហើយក៏ដំណឹងទាំងកំពុងហត់ម្ហប់ៗជង់ថា "លោក... លោក, សូមលោកនេះខ្លួនក្នុងពេលឥឡូវនេះឲ្យឆាប់" ។ ចេះខ្មែរឯនហាស្ត្រីន ងើបក្រឡេកឡើងហើយសួរថា «មានរឿងអីបានឪពុងជង់ឲ្យយើងនេះខ្លួន ?» ។ ឪពុកចេះខ្មែរតបថា «សូមលោកកុំបង្អង់ឲ្យយូរពេល, ត្រូវស្រួតត្រយាំងរហ័ស ព្រោះព្រះពាហុខ្លាំងនឹងលោកខ្លាំងណាស់, ខ្លាំងបានបង្គាប់ឲ្យលោកអគ្គមហាសេនាប្តី នាំពួកព្រះពាហុអាជ្ញានឹងមេទាហានជាច្រើនឲ្យមកចាប់យកផ្ទះសម្បែងនឹងខ្លួនឯងសម្លាប់ចាំងអស់ហើយឲ្យចាប់ចាំងខ្លួនលោកជង» ។

ចេះខ្មែរឯនហាស្ត្រីន បានឮសំដីឪពុកចេះខ្មែរប្រាប់ហើយ ក៏ស្ងុតក្តីក្នុងស្មារតីស្រឡាំងកាំង រកនៃះក្រែងទៅក្នុងចិត្តក៏មិនកើត ទើបសួរឪពុកថា:

នោះថា « ហើយដូចោះ មានគេលួចបួលទៅក្នុងផ្ទះ ដើម្បីនឹងប្រមូលយកអីវ៉ាន់ទាំងឡាយទៅ ឬទេ ? ពាស: គឿនយ៉ាងបង្គំថា « ទេលោក, ពុំបាច់គិតគូរអំពីរឿងអីវ៉ាន់នោះ, លោកត្រូវតែបុះអំពីផ្ទះគេបញ្ចេញទៅក្នុងទីណាមួយ ក្នុងគ្រាឥឡូវនេះយ៉ាន់ប្រញាប់ជើបរួចខ្លួន ព្រោះតគ្គមហាសេនាដែលទ្រង់ស្គាល់ពីដន្លាងនោះមុនយ៉ាងនឹងមកដល់ក្នុងពេលឥឡូវហ្នឹងហើយ » ។ ហេតុនេះហើយបានជាគ្រោតអំពីតៅអីក្តាមពាក់ស្បែកដើងយ៉ាងប្រញាប់ប្រញាល់ ចេតគាមេតទ្រូតប្រមុះដើម្បីកុំឲ្យអ្នកផងនឹងមើលស្គាល់ រួចបុះចេញពីផ្ទះគេបញ្ចេញទៅតាមផ្លូវក្រោយនៃទីក្នុងនោះ ឥតឈប់ឈរឡើយ ហើយបានរត់ទៅដល់តំបន់ទីសាធារណៈស្មសាន (ទីសម្រាប់កប់ខ្មោចខ្លះ) ហើយបានរត់ពេលនោះថ្លៃក៏រសៀលជ្រុនជ្រែដែរ ទាល់តែបានទ្រង់ដើរចូលសំដៅទៅកន្លែងដែលខ្លួនបានដាក់ទុកសេះរបស់ខ្លួន ដោយមិនបានឈប់អាស្រ័យដំណេកនៅទីនោះឡើយ ។ ផ្ទះនោះធ្លាប់ជាវត្តមួយ មានស្មណ្ឌានមួយដងចាមណ្ឌប (ជោម) ហើយមានចំនួនសមាមៀ គួរឲ្យពិតពិលទីណាមើល គឺនូវទេដ្ឋិនៈ ផលិ ចានឲ្យគេតសាងខ្លួនតាំងពីខ្លួនទៅរស់ម្ល៉ះ ។ តែលុះដែលបានទ្រង់ដើរចូលទៅនោះមិនបានឃើញផលទីណាផង ស្រាប់តែចំរែនចិនជាតិយូហ្វ (Juif) ម្នាក់ជាអ្នកបង្កើតរក្រាក់ទិនជាមេដំណូកយ៉ាងធំដើរមកប្រាប់មុនគ្នា ព្រោះតេ

លែងត្រឡប់អំពីខាងក្រៅបូលមកគាន់ទីតែនឹងវិញ ។ ជាតិស្ងើចស្ងៀមនេះ
គាលបានស្គាល់ជាអំណាចរបស់ខ្មែរឧដុមហាសន្ធនហើយក៏ឈប់ជាបបួរដោយ
សេចក្តីគួរសម ។

ថៅកែជាតិស្ងើចនោះឈ្មោះ អ៊ុសាអ័ក, លុះគាត់ឮគួរសមរួចហើយ
ទើបសួរទៅបេះខ្មែរឧដុមហាសន្ធនថា "សូមលោកអភ័យទោស, ចុះលោក
អញ្ជើញទៅណាមកណា ទាំងពេលល្ងាចថ្ងៃនេះ ហើយក៏ដូចជាស-
ស្មើតសស្មុកផង តើលោកមានភ័យអាសន្នអ្វីក្រៃលែងណាឬទ្បូចម្តេច? ។
បេះខ្មែរឧដុមហាសន្ធនតបថា "ចាទ, អម្បាញ់មិញនេះ ខ្ញុំកំពុងខ្ជួលគាន
ដំណេកថ្ងៃក្នុងផ្ទះខ្ញុំ, ក៏ពុងតែលក់ ស្រាប់តែយល់សុបិញ្ញាឮខ្មោចឪពុកខ្ញុំ
មកឈរសំឡឹងសំឡក់ខ្ញុំដោយគាគរោកដូចជាខឹងធំខ្ញុំខ្លាំងណាស់, ខ្ញុំ
ក៏ភ្ញាក់ព្រឺតឡើងភ្លាមហើយញ័រខ្លួនកក្រើកសព្វសាច ទើបខ្ញុំក្រោកឡើងដើរ
ចេញមកអំពីផ្ទះសំដៅទៅឯផ្នូរខ្មោចឪពុកខ្ញុំនោះ ដើម្បីសំបួងសង្កែងសូម
ទោសលោក តែក្រែងបួនជាមានខុសត្តឆ្គងដូចម្តេច" ។ ថៅកែអ៊ុសាអ័កមិន
ជាន់ដឹងរឿងដែលខ្មែរឧដុមហាសន្ធនកើតឡើងនៅចេញអំពីទីក្រែងនោះ
ទេ ទើបនិយាយឡើងទៀតថា "លោក, អត្តមហាសេនាបតីតាលោកដែល
ត្រូវគាត់ទៅហ្វាយនាយរបស់ខ្ញុំដែរ គាលនៅសល់ទៅខ្លួយនោះ បានតំណ
ទំនិញផ្លុកក្នុងសំពៅដ៏ច្រើនហើយសំពៅទាំងនោះកំពុងនៅតង់ក្បាលស
សមុទ្រមិនទាន់បានចូលមកដល់ដែលក្រុងកាល់សូក៏ទេនៅខ្លួយ ; ដ

ខំនិញចាំងអស់នោះតើវាបង់លោកពិតប្រាកដព្រោះវាតអំពីមុខ
ហើយ, ឥឡូវនេះខ្ញុំចង់ទិញខំនិញលើកដំបូងចាំងអស់ក្នុងសំពៅ
ចាំងឡាយនោះដែលនឹងបួលមកចតនៅផែក្រុងបាល់សូរ៉ានេះក្នុងថ្ងៃក្រោយ
បើលោកត្រូវការលក់ឲ្យខ្ញុំ១ចន្លឹងបួនប្រាក់មួយពាន់តហាបណាមុនឲ្យហើយ
ស្រេច ព្រោះប្រាក់ខ្ញុំមានជាមែនតែក្នុងថង់ជាមួយនេះស្រាប់" ។ លុះ
និយាយដូច្នេះហើយ ថៅកែអ៊ុសាអ័តក៏ញុះញង់ប្រាក់ឪពុកឲ្យ
តាមតែចិត្តលោភញ្ជើញឲ្យបេក្ខេទ្ធនហាស្សុនបានឃើញពិតប្រាកដ ។

គ្រានោះឯង ពេញបេម៉ាហាណាតបង់បេក្ខេទ្ធនហាស្សុនមែន
ព្រោះខ្លួនកំពុងមានគ្រោះថ្នាក់ហ៊ានក្លាន់ហើយមានតែខ្លួនប៉ុណ្ណោះ ហាក់
ដូចជាមនុស្សគ្មានាថាក់ព្រឺព្រឺរោងពីឯគ្មានទៅហើយ លៅតមានប្អូប
ច្រមុះនឹងថៅកែជាតិស្ទឺហ្គ៍យកប្រាក់មកឲ្យខ្លះ ។ ទើបបេក្ខេទ្ធនហ
ហាស្សុនទឹកមុខស្រស់ដល់អង្គាស្រីយេបង់ថៅកែអ៊ុសាអ័ត ដែលបាន
និយាយសុំទិញខំនិញចាំងនោះ ខុកដូចជាសេចក្តីស្រឡាញ់ប្រាណបង់
ខ្លាំង ។ បេក្ខេទ្ធនហាស្សុន ក៏ខ្ជួលត្រមក្តាមដោយសេចក្តីរីករាយ
យ៉ាងពន្លឹក ។ ថៅកែអ៊ុសាអ័ត សួរបញ្ជាក់ទៀតថា "លោកត្រមលក់
ខំនិញកងដែលនៅចាំងអស់ ដែលនឹងបួលមកចតនៅផែក្រុងបាល់សូរ៉ា
នេះឲ្យខ្ញុំ ដោយគិតជាប្រាក់មួយពាន់តហាបណាមែនឬ?"

ចេត្រែទនិងហស្សរ៉ូន ឆ្លើយថា "ចាទ, ខ្ញុំត្រៀមលក់ឲ្យអ្នកមួយពាន់កហាបណៈ" ។ ឃើតែអ៊ីសាអ័ក ប្រគល់ប្រាក់មួយថង់ឲ្យភ្លាមៗ ហើយសុំឲ្យចេត្រែទនិងហស្សរ៉ូន កាប់ម៉ៃចេត្រែតែងលោះពីមួយពាន់ទង្គិចមកវិញ ប្រគល់ឲ្យគេប៉ុន្មាន, ប៉ុន្តែចេត្រែទនិងហស្សរ៉ូនមិនចាប់កាប់ទេ ព្រោះខុកចិត្តគ្នាស្រាប់ហើយ ។ គាត់នោះ ឃើតែអ៊ីសាអ័កនិយាយសូមឲ្យចេត្រែទនិងហស្សរ៉ូនសរសេរសំបុត្រមួយទុកនៅដៃខ្លួន ដើម្បីជាភស្តុតាងថាបានលក់ដីនិញពាំងនោះឲ្យមែន គឺតជាប្រាក់ចំនួនមួយពាន់កហាបណៈ ហើយក៏ចាញ់ចេត្រែតែងប្រដាប់សរសេរ ដែលនៅជាប់នឹងខ្សែក្រវាត់របស់ខ្លួនមកបើកយកទៅដៃនឹងក្រដាសសម្រាប់សរសេរសំបុត្រ មកហុចឲ្យចេត្រែទនិងហស្សរ៉ូន ។ ចានសរសេរសំបុត្រមានសេចក្តីដាំងខ្លីដូចខាងក្រោមនេះ :

"ខ្ញុំឈ្មោះចេត្រែទនិងហស្សរ៉ូនក្រែងបាល់សូរ៉ា បានលក់ដីនិញលើតដំបូងកងសំពៅចាំងអស់ដែលនឹងចូលមកបតនៅទីដែនេះ ឲ្យឃើតែជាតស្ទីហ្វ៍ឈ្មោះអ៊ីសាអ័ក គឺតជាប្រាក់ចំនួនមួយពាន់កហាបណៈ ដែលខ្ញុំបានទទួលរួចហើយ, ខ្ញុំសូមធ្វើសំបុត្រនេះទុកនៅដៃអ៊ីសាអ័កជាភស្តុតាងស្រាប់" ។

(ចេត្រែទនិងហស្សរ៉ូន ក្រែងបាល់សូរ៉ា)

ចប់ ភាគ ទី ១៤ តែមប៉ុណ្ណោះ ។

សូមអញ្ជើញអស់លោក អ្នកមើលរឿងថ្មីក្នុង ភាគទី ១៥ តទៅទៀត ។

ព្រះគ្រូបញ្ញាលិខិត ភៅ-សឹម

ត្រូវផ្ទៀងសាសាថាលជាន់ខ្ពស់ ត្រូវតុំភ្លេញ រៀបរៀង

(តពីលេខ ១១ ឆ្នាំ ១៩៤៧)

ខ្ញើយថយចោលកូនប្រពន្ធទៅ ភៀសខ្លួនចេញទៅរកទីស្ងាត់ វែកឆ្ងាយ
ឲ្យគេញើសស្រស្រាក់ ដល់ថ្ងាក់គ្មានស៊ីទំរាំឆោត(១) ។

ចំណែកមហាវមិត្តវិញ តែងតែដើមនឹងសម្លាប់ឲ្យដាច់ញ្ញើមជាមិនខាន
ទៅចំណែងតែនឹងលែងប៉ុណ្ណោះទេ សូម្បីតែចរិកគាត់ទាំងរបស់ខ្លួន
ឲ្យឆ្អែតស្កប់ស្កល់ទាល់តែដួលហួសប្រមាណទាល់ចាក់ច្រាស បណ្តាល
ឲ្យកើតទុក្ខវេទនាឆ្ងាយរកស៊ីពុំបានក៏មានខ្លះដែរ ។ តួយ៉ាងព្រះបាទ
បសេនទិរដ្ឋសោយព្រះស្ងោយឲ្យគេចំអិនដោយអង្ករ ១៦ នាឡិជាមួយ
គ្នាទឹមបង ។ ទ្រង់តំពុនស្រែងតក្តីមិនទាន់បានឆ្ងាយតក្តីនៅឡើយ
ក៏យាងទៅជាន់សំណោកព្រះសម្មាសម្ពុទ្ធ មានព្រះការុណ្យបាក
អន្លះអន្លួច សូម្បីតែឆ្កឹយផ្កាក៏ផ្ទួមិនរកែត តន់ប្រុះប្រែរឡើង ។ ព្រះ
សម្មាសម្ពុទ្ធទ្រង់សួរថា : "អហាបពិត្រ ទ្រង់មិនបានផ្ទួសព្រះ
ភាយាទេឬ ទើបយាងមកទីនេះ?" ។

---

(១) គឺរាស់ត្រាត់ច្រាសចាកចោលរបស់ត្រូវយ៉ាង ។

ព្រះកស្សបសម្តេចថ្លែងថា: "បពិត្រព្រះអង្គ ខ្ញុំមានសេចក្តីទុក្ខធំគាំងតែពីព្រឹកដែលខ្ញុំបានបរិភោគអាហារមក" ។ ព្រះសាស្តាត្រាស់ថា: មហាបពិត្រ សេចក្តីទុក្ខធំយ៉ាងនេះ ព្រោះតែខ្ជិលសោយអាហារដែលហួសប្រមាណទេតើ! ទើបត្រាស់ជាគាថាថា:

មិទ្ធី យទា ហោតិ មហាឝ្ឃសោ ច
ឯឡាយិតា សម្ប្បរិវត្តសាយី
មហាវភោវ ឯឝមបុដ្ឋោ
បុនប្បុនំ ឝត្ថុមុបេតិ មន្ទោ ។

សេចក្តីថា: បុគ្គលឯណាជាអ្នកមានសេចក្តីងោកងុយច្រើន ជាអ្នកបរិភោគនូវភោជនមានជម្ងឺច្រើន ជាអ្នកប្រព្រឹត្តដេកលាក់បំពេនៀលដូចជាជ្រូកស្រែអណែលចង់ញ៉ាំមនុស្សយកយកជ្រូកមានពពួកជាដើម ។

បុគ្គលខ្លះទៀតជាមានបញ្ញាខ្លៅ ព្រោះមិនធ្វើព្រះវិនិច្ឆយ៍ គឺអនិច្ច-ទុក្ខ-អនត្តា ទុកក្នុងចិត្ត រមែងកើតទៅកាន់គតិ (កើតខ្វិត) រឿយៗ នឹងមិនរួចពីគតិខ្វិតឡើយ ។

ព្រះជាម្ចាស់សន្និសីទសម្តែងធម៌សោយបន្ទុបអាហារ ដែលចំអិនដោយអង្គ ១៦ ទាំងនោះ ទ្រង់ក៏មានព្រះការុណ្យស្រាលសោយនូវសេចក្តីសុខ មានសេចក្តីស្និទ្ធស្នាលស្រឡាញ់ព្រះសាស្តា ទ្រង់ធ្វើឥសិសមាធ ៧ ថ្ងៃ ថ្វាយកិច្ចសង្ឃកម្មព្រះពុទ្ធសាសនា ។ គួរជាបាតាម

អាសិតជាពិសមាន ៤ យ៉ាង សូមទាញយកមកអាងដូចជាពាក្យកាព្យ
តទៅនេះ

បទកាកគតិ

ពិស ៤ យ៉ាង

អាសិតនេះឯង ឯកប្រាជ្ញសំដែង ជាគ្រឿងតំកាង ថាក្នុង
លោកនេះ មានពិស ៤ យ៉ាង ដូចមាននៅខាង មុនជាំណាត់ ។
មួយរៀនវិជ្ជា មិនខំសិក្សា ឲ្យចេះហ្មត់ចត់ ទំនឹកឮជាពិស
ព្រោះមិនប្រាកដ នាំឲ្យខឿងហត់ លំបាកខ្លួនប្រាណ ។

ពីរ - ការបរិភោគ អាហារគគ៌លោក មិនដឹងប្រមាណ ស៊ីច្រើន
ហាត់ច្រាស រំលាស់លស់ខ្លាន ក្តៅឆាតុមិនឈាន ដុតដូចម្រែកតី ។
ចាត់ជាពិសពុល ព្រោះតែស៊ីផ្សុល នាំកាឡកណ្តៀ ឲ្យមក់គ្រប់ខាន
សន្ធានច្រែសស្រី ព្រោះតែចំណី តប្បរិះគិត ។

បី - រឿងនិទ្ទេស អាត់លក់ពិន័យ ពីអ្នកដំនិត ដំណើរក្តីក្តាំ ខ្លួន
ខុសមិនពិត ជាពិសរុបរឹត ជល់អ្នកក្រីក្រ ។

បួន រឹស្សីក្រមុំ ចំរើនវ័យធំ រូបពង់ស្រស់ល្អ ជាពិសដល់ចិត្ត
ច្រែសស្និទ្ធបន្ត ចាស់ខ្លះទន់ក ផ្តើលតាមគេដែរ ។

នេះហើយ ចំណីអាហារដែលធ្វាញ់ពិសា មិនត្រឹមតែធ្វើមនុស្ស
សត្វ ឲ្យជាប់ចិត្តដោយរសជាតិ, ឲ្យសោយទុក្ខវេទនា ឲ្យអស់ព្រៃ

សម្បត្តិប៉ុណ្ណោះទេ សឹងគាបធ្វើមនុស្សឲ្យអន្ទះអន្ទែងក្នុងសង្សារដូចនេះ ខ្លះដែរ តួយ៉ាងព្រះតិស្សត្ថេរ ចាញ់តែឧបាយរបស់នាងវណ្ណទាសីជាស្ត្រីឆ្នូត ឈ្លបប្រែគេនបបានទឹងបង្ហិនជីវិតលោក ។ ឥឡូវដោយអាសគណ្ហា ដកឃ្លាមិនរួច ទាល់តែនាងនោះធ្វើកាលពុតជាឈឺ ទើបទូលឲ្យចូលទៅកាន់ទីបន្ទប់ ហើយប្រលោមលួងលោមជាយសោនកិច្ចអន្ទះអន្ទែងបានដូចក្នុងគ្រានោះឯង ។

ព្រះដ៏មានជោគ ខ្ញុំប្រកាសសេចក្តីនេះជូនកិក្ខុទាំងឡាយ ឲ្យពិចារណាឲ្យឃើញក្នុងការដែលបរិភោគបណ្តាហារ ហើយខ្ញុំនាំរឿងព្រេងមកពន្យល់ថា :

កាលដែលកន្លងទៅហើយ មានឧយ្យានបាលម្នាក់ឈ្មោះសញ្ជ័យជានាយសួនបុប្ផារព្រះបាទព្រហ្មទត្តក្នុងក្រុងពារាណសី ។ គ្រានោះ មានសត្វល្វាស ១ មកក្នុងឧយ្យានោះ ឃើញនាយឧយ្យានបាលហើយសួរបោលតែម្តង ឯនាយសួនបុប្ផាវិតមានគម្រាមដេញបញ្ជាឲ្យ ។ សត្វល្វាសនោះមកកាន់ឧយ្យានញយៗ ពុំដែលដាច់ ។ ឯនាយឧយ្យានបាលបេះផ្កាទឹងផ្លែឈើយកទៅថ្វាយស្តេចពាល់ ។ ថ្ងៃ ព្រះពាលក្រែងសួរថា : « នែ ! ឧយ្យានបាល ឯងពែកងបានឃើញហេតុអ្វីជាចំឡែកដែរឬ ? » អ្នកក្សាសួនបុប្ផាក្រែបទូលថា : សូមទ្រង់ព្រះមេត្តាជ្រាស គ្មានឃើញហេតុអ្វីជាចំឡែកទេ ឃើញមានតែសត្វល្វាស ១ ក់មកកាន់ឧយ្យានៈនោះ ។

ព្រះពាល[illegible]ត្រាស់ថា : បើចុះឯងនឹងចាប់ឈ្មោកវាបានឬទេ ? នាយឧយ្យានបាលក្រាបទូលថា : សូមទ្រង់ព្រះមេត្តាប្រោស បើបានខំតយុទ្ធបន្តិចទូលបង្គំនឹងតាមចាប់សត្វឈ្មួញនោះ តាំមកកាន់ព្រះពន្ធនាគារសន្តាមបង្គាល់ ។

ស្តេចទ្រង់ព្រះពិចារណាឃើញនាយឧយ្យានបាល ឃើញវៀលាបពុងស្មៅត្រង់ទីដែលសត្វឈ្មួញដើរចូលទៅកាន់ឧយ្យាននោះ ។ សត្វឈ្មួញមកហើយខំតាស៊ុបពុងស្មៅនៃកលាបដោយឧត្តមយ៉ាង ក៏ជាប់ចិត្តដោយរសតណ្ហា មិនទៅកន្លែងណាទៀត ។ នាយឧយ្យានបាលដឹងថាសត្វឈ្មួញជាប់ចិត្តដោយរសឧត្តមហើយ ក៏បង្ហាញខ្លួនឲ្យឃើញញ្ញែ ។ ពាល់តែសត្វឈ្មួញកើតរសចង្កុំវិស្សាសៈ ហាន់ចូលមកស៊ុបស្មៅដែលនាយឧយ្យានបាលកាន់ដំដៃ ។ នាយឧយ្យានបាលក៏ឲ្យចាំចាប់ផ្លូវថ្នល់ដោយតន្ត្រី ហើយកាច់មែកឈើមួកពាយតាមផ្លូវប្លែកនោះ រហូតតាំងពីព្រះពន្ធនាគារមកដល់សួនឧយ្យាន ។ គាត់ក៏ស្ពាយបំពង់ខែកយុទ្ធនឹងស្មា ជីជាប់ស្មៅត្រង់ចង្កឹះ ពេលពាយស្មៅវៀលលាបដោយឧត្តមយ៉ាងត្រង់ទីចំពោះមុខសត្វឈ្មួញ ឯញញួរឈ្មួញឲ្យចូលទៅកាន់ព្រះពន្ធនាគារពាល់តែបាន ។

សត្វឈ្មួញចូលទៅដល់កន្លែងព្រះពន្ធនាគារហើយ នាយគុកបាលសួរទៅចំពោះមុខគាត់ថា ត្រឡប់ទៅឃើញមនុស្សពាន់ឆ្ងាយ ក៏កិតកំយ

ញាប់ញ័រខ្លាចស្លាប់ ប្រឹងស្ទុះចុះស្ទុះឡើងតែងតែងក្នុងព្រៃរកផ្លែឈើនិងសត្វជាន
(ពាល់តែស្លាប់) ។

(ត្រានោះ) ព្រះបាទព្រហ្មទត្តទ្រង់ទតឃើញសត្វឈ្លូសកំពុងញាប់ញ័រទ្រង់ក៏ដឹងតាមទៀយញាសត្វថា: ម្ចឹងថែបនេះជាសត្វអាស្រ័យនៅកន្លែងព្រៃស្ងុំខ្លុំ, ឥឡូវនេះមកគាន់កន្លែងយ៉ាងនេះ ព្រោះតែជាប់ជំពាក់ដោយសេតណ្ហា ម្ចាលអ្នកទាំងឡាយកាលគ្នា សេចក្តីលាមក (អ្វី) ឲ្យវិសេសជាងសេតណ្ហាដែលមានក្នុងលោកនេះ មិនមានសោះឡើយ ។ ឯនាយឧយ្យានជាលបាននាំម្ចឹងឈ្លូស ដែលអាស្រ័យនៅកន្លែងព្រៃស្ងុកឲ្យមកគាន់អំណាចរបស់យើងដោយសេតណ្ហានេះឯង ។ តរឿងនេះសូមតែជាពាក្យពាក្យបង្ហាញគតិដូចតទៅនេះ:

ទឹងអើយទឹកឃ្មុំ ផ្អែមហើយផ្អែមធុំ ក្ងិនឈ្ងុយពិសា បងចិត្តម្ចឹងឈ្លូសដោយសេតណ្ហា គេមេបទុជា ទាបុន្មានខែស្មា ។

ឈ្លូសពុំបានដឹង ទឹកឃ្មុំស្រែវែង ជាញ៉ូនមកស្មា ចូលក្នុងឧយ្យានឲ្យស៊ីបុង្គស្មា ឲ្យឋេកឲ្យនោ ជាល់តែទុកចិត្ត ។

អ្នករក្សាសួន គេបង្ហាញខ្លួន ឲ្យឃើញផ្ងើស្ងួន ១ថ្ងៃ ២ថ្ងៃ ឈ្លូសចូលទៅជិត យកគេធ្វើមិត្ត ចូលចិត្តស៊ីស្មា ។

គេគាន់នឹងដៃ លួងលោមកាលថ្ងៃ ព្រោះតែខ្លួនទៀ គេធ្លាក់ខ្លួនចិនទាំងកកេវ ថ្ងាយស្តេចតក់ទៀ ឯព្រះពរកំណ ។

នេះយកតែខ្លះ មែកឈើរនេះ មកតាយចំទាំង ព័ទ្ធឲ្យជិតស្មុង កុំឲ្យឃើញភាំង នេះដើរចំពាំង ខ្លួនដើរបណ្តាយ ។

ដៃនេះតំពាក ជាប់ស្មៅមិនដាក មើលមកខាងក្រោយ ស្មៅលាបតែងឃ្លុំក្លិនបក់ឲ្យ ស៊ុះដើរតាមក្រោយ ដល់ព្រៃពងភាំង ។

ឯខាងខ្លាវបាល ឃើញត្រែកត្រអាល រុញខ្លាវបិទភាំង ឈ្លូសបួលទៅដល់ កន្លែពងភាំង ឃើញមនុស្សភ័យខ្លាំង ញ៉ាំខ្លួនដល់ស្លាប់ ។

ហៃឃុវដែន ចូរចុះបន្ថែន អាហារដែលឆ្ងាប់ បរិភោគឈ្លួយឆ្ងាញ់ បន្តិយមួយម្តាប់ កុំឲ្យវង្វាប់ ដូចឈ្លូសនោះឡើយ ។

ចប់ ភត្តសោណ្ឌា ពួកអ្នកលេងស៊ីភត្តតែប៉ុណ្ណេះ ។

ចាណាសោណ្ឌា (១)

ទោសធឹកទឹកស្រែរឹង ៦ យ៉ាង

១ - សន្ធិដ្ឋិតា ធនជានិ អ្នកធឹកស្មុក រមែងវិនាសខ្ទេចៗ សម្បត្តិដែលឃើញជាក់ស្តែងដោយខ្លួនឯង

២ - ភាសហាប្បវាឌ្ឍនិ បង្កឲ្យកើតសេចក្តីជម្លោះ មានជម្លោះជាច្រើនជាលំដាប់ជាប់ជាក់ជាដើម

៣ - ភោគានំ អាយតនំ បណ្តាលហេតុឲ្យកើតភោគៈច្រើនមានឥតឹតក្តៃតជាដើម

---

១ ពួកអ្នកលេងធឹកស្រែ ។

៤ - អភិជ្ឈាសញ្ញាជនី ទាំងឲ្យចូលកើតឈ្មោះមិនពិពេះ មានច្រហាមោគាមិតា ឥណីពោលពាក្យដាក់ទៃនឹងបិតាដែលខ្លួនមិនត្រូវពោលតបតាំងនៅឡើយ

៥ - ហិរិកោបិនជនិទ្ទុសនី ការបង្ហាញកេរ្តិ៍ឱ្យសត្វគេយល់ត្រង់ត្រង

៦ - បញ្ញាយ ទុព្ភលិគណៈ ធ្វើឱ្យញាឱ្យមានកម្លាំងតិចជាង តែថា មិនអាចដើម្បីធ្វើមគ្គបញ្ញាឱ្យមានកម្លាំងថយបានទេ ។

ហាក់នឹងថា ! មិនគួរនឹងឆ្ងល់ទេ ! សុភជាគេសង្ឃដែលត្រូវលះបង់ចោលកង់គេសង្ឃឯទៀតដែរ ចុះហេតុអ្វីក៏មនុស្សប្រុសស្រីសេពាសោយទៅហើយក៏ឱ្យមានទោសដែរ ! មិនដូចជាគេសង្ឃឯទៀតដែលគេសេពសោយទៅហើយថាឥតមានទោស ?

គេសង្ឃឯទៀត ដែលគេសេពាសោយទៅឥតមានផ្លូវដឹកនាំចិត្តឱ្យប្រព្រឹត្តធ្វើអំពើអាក្រក់ផ្សេងៗទេ ជាតែងសម្លាប់ធឹងធ្វើកម្លាំងនឹងស្មារតីរបស់មនុស្សឱ្យរឹងប៉ឹងប៉ុណ្ណោះ ។

ឯសុភនេះ ជាគេសង្ឃមានកំឡាំងដ៏ខ្លាំងក្លា កាលណាដែលគេផឹកទៅហើយ ឥណីធ្វើកំឡាំងរបស់មនុស្សឱ្យទន់ខ្សោយ ហើយឥណីធ្វើចិត្តរបស់មនុស្សឱ្យក្លាហាន អាចហ៊ានបំពានធ្វើអំពើបាបផ្សេងៗដោយងាយ។ អំពើបាបណាដែលមិនធ្លាប់ធ្វើ ក៏អាចធ្វើបានដោយកំឡាំងសុភ

ទ្បាវង្វេង ដូចការឮប់គោរពច្រៃតិចគួរគោតរៀងគន្លងត្រកួលចាំងឡាយ
មានមាគាចិតា ទំនិសមណព្រាហ្មណ៍ជាដើម ជាបុគ្គលគួរគោរពគោត
ខ្លាច លុះត្រូវសុភកាលណា សុភធ្លាប់គួរគោះទ្បាប្រែត្រឡប់វង្វេងបាត់
លែងគោរពគោតខ្លាច លែងស្គាល់ទុះបុគ្គលនោះ។ ឧទ្បាយ នេះជា
ទោសសុភដូចបានគោលខាងដើមនោះ ។

ឯទោសទៅបរលោកនោះ មនុស្សដែលផឹកសុភ លុះធំហាយខន្ធ
ទៅកាលណា ផលសុភនាំដំណើរមនុស្សនោះទ្បាទៅធ្លាក់នរកឆ្នាំ
តូច្ចនរក មានទឹកទន់ដែលពុះទៅងាប់ជាទិច្ច ទឹកនោះហូរចូលទៅកន្លែងមាត់
សត្វនរក ហើយពុះកន្លែងនោះ។ ក៏ឆ្លាយរលាយស្ងាប់។ ហើយកើតទ្បាំង
ទៀត ដរាបទាល់តែអស់ពាបកម្ម ទើបទ្បាំងទៅកើតកន្លែងទំណែ។ បាប
កម្មនោះមិនទាន់អស់ ក៏ទ្បាជាលង្ហួនាទៅជាមនុស្សត្តិតិរច្ឆាន រលាក់រលើ
ល្ងីល្ងើផ្សេង។ ដោយទោសផឹកសុភ, ព្រះបរមសាស្តាចារ្យទ្រង់ត្រាស់
ទេសនាទុកដាអនេកបរិយាយ មិនអាចស្រង់យកមកអធិប្បាយទ្បាបាន
សព្វគ្រប់ក្នុងទីនេះឡើយ ។ តអំពីនេះទើងអធិប្បាយតាមអាការរបស់អ្នក
ផឹកស្រា ដែលបានឮឃើញក្នុងកន្លែងជួបជុំបច្ចុប្បន្ននេះ ដើម្បីទ្បាស្គាល់អាការ
របស់សុភផ្លែអ្នកផឹកទ្បាសំដែងបញ្ជូនអាការយ៉ាងណា។ នោះ ដូចត
ទៅនេះ ។

អាការអ្នកជំកសុរា

ជំក ១ ពែងអកែ(ក្រាយ)[1]

- ២ ពែងស្រាយចិះញ៉ែម
- ៣ ពែងសម្រែមមាយ៉ា
- ៤ ពែងគ្រាប្រចាក
- ៥ ពែងអារក្សង់
- ៦ ពែងប្រតំបង[2]
- ៧ ពែងទឹកសំសង់យំគាលិតខ្លួន

កំពង់អាការទំមួយៗ មានសេចក្តីអធិប្បាយតទៅនេះ

ជំក ១ ពែងអកែក្រាយនោះ ត្រូវដឹងថាពន្លាតំសុក រមែងធ្វើអ្នកជំកឲ្យមានសំដីច្រើនតាមែតក្រាយ ចែករំលែកអធិប្បាយស្រស់ស្រាយជាមួយនឹងអ្នកដទៃដែរឯង ឬក៏និយាយបញ្ចិនបញ្ចើងកៀសនាយអាយទៅកែមនុស្សអ្នកដើរទៅមកជុំតខាង ដោយរឿងហេតុណាមួយដែលខ្លួនទឹកឃើញក្នុងពេលនោះ ហើយក៏ទំនាយអកែក្រាយស្រាយទៅតាមដំណើរតែមានលេចចំខ្លះក្រឡឹយ ។ អាការប្រើសំដីចេញទៅនោះ ខ្លះតោលសំដីឥតរឿង ។ កនិរពែងឮសទ្ធឹកហាកដ្ឋដូចជាឈ្លោះប្រកែកគ្នានឹងអ្នកណាមួយ ខ្លះក្រមុំមិនក្តីទេ តែលុះត្រាសុភាពោលសម្ដែងចេញមក

---

១ បុរាណលម៉ាយគាត់ដើមជំកស្រាខ្លាំងពែង ។ ២ ខ្លះថាជំក ៦ ពែងស្រែតុំបង ។

ស្នង់ដូនចុងច្រមុះចង្កេះចង់ឆ្កែងិះ ង្ហឹ អាំះ ហ្អាំះ ។ បែកសំដីច្រើនឥត
ប្រយោជន៍តិចតួចណាស់ដើម ធ្វើឫកពាហាក់ដូចជាគ្មានអ្នក
ណាស្មើដូចបាន ។

ខ ๒ ដែលថា ផឹក ๒ ពែង ស្រាយចិញ្ចើមនោះ ធម្មតាអ្នកផឹកស៊ុត
តែផឹកដល់ ๒ ពែងហើយ តែក្លៀកខ្លួនស្រាយចិញ្ចើមព្រិត ចឹងចំចេត
ដើងធ្វើនិមិត្តកម្មញាក់ចិញ្ចើមដំឡើងក្អែកគ្រលួចដញ្ចប់មាត់ ដើម ឬថា ។
ព្រួសគំនរមាត់ឆ្នេងស្លាំ គាញសក់ក្បាលហុចមុខឲ្យអ្នកផងពាំងពួង តាម
ខំនឹងគាថាមានស្រាយចិញ្ចើមដាំដើមនោះឯង ។

ខ ๓ ដែលថា ផឹក ๓ ពែងសំរាមម្យ៉ាមមាយានោះ អ្នកផឹកស៊ុត
តែផឹកដល់ ๓ ពែងហើយរាមងឹងធ្វើមាយាមារយោគលាក់ពុតត្បុត ភ្លូញ
ក្អែរចេញសាការ ធ្វើហាក់ដូចជាអ្នកមិនឆឹកពិត ធ្វើសញ្ញាជាគ្រឿងសំគាល់
ឲ្យអ្នកដទៃដឹងថា "ខ្ញុំជាមនុស្សអ្នកល្អ ប្រពឹត្តត្រឹមត្រូវអ្នកមានធម៌សាច-
ស៊ីល - ទានមានសីក្តីយសប្រហែលខ្លឹងគេដែរ" ឈ្មោះថាជាមនុស្សចិត
ប៉ាំងតំនិតខ្លួនឲ្យអ្នកណាមួយដឹងថាខ្លួនផឹកស៊ុតឡើយ ។

ខ ๔ ដែលថា ផឹក ๔ ពែងទ្វារប្រចាក់នោះ គួរផ្ទាល់ថា អ្នកផឹកស៊ុត
កាលណាផឹកដល់ ๔ ពែងហើយ រមែងឮញញួញកាយថ្នាសព្វអន្ទើ តឹ
លើកដៃដើងតន្ទឹងឆាក់ដំហុយចូលីប៉ុងឡើង ឥឡូវតញ្ចាត់លោតអង្គេង
ហាក់ឆ្នេងហាក់ស្លាំងាំងាក់ ចាប់ដំបងត្រនង់ណោលណោតគុនត្រគាប់ ស្ទុះ

ទៅប្រាប់ចាប់ចំចាប់កើបចាញ់ដើងដៃអ្នកជាខ្មែលដ៏លាស្លៀត ពុំនោះសោត ស្តុះទៅជាលំគប់គប់បេសំនេះនោះ ប្រែអាការជំម្រើនកិរិយាហាក់ដូចជាយក្ស ឬ មារគាមភ្លាត្រប្រហាក់ដៃលខ្លួនបេះ ។

ទី ៥ ដៃលថា ជឹក ៥ ពែនអារក្សធំនោះ គ្រូវដឹងថា ពួកអ្នកជឹកសុកតែធឹតដល់ ៥ ពែនហើយ រមែងជ្រប់ខ្លួនជាក់មុខសំយុងបុះលុតជង្គង់ចាំង ២ គ្រីក្បាលយកដៃចាំង ២ ច្រត់ប៉ាក់ទៅលើដែនជើលរំជ្រែងជ្រោងខ្លួនដម្រង់មុខបន្ទុនកនុនបុះក្រោម ហាមាត់ស្ទាបម្តងៗ ធ្វើចំនងហាក់ដូចជាគេជាន់អារក្សអង្គុយនបោកពីមុខ ធ្វើក្បាលងឹតងោកខ្លាចំចាំខ្លួលខ្លោចអារក្សមកជាន់យ៉ាងណាក៏ អ្នកជឹកសុកដល់ ៥ ពែនហើយក៏មានគាការយ៉ាងនោះដែរ ។

ទី ៦ ដៃលថា ជឹក ៦ ពែនច្រត់បខនោះ គ្រូវដឹងថា ដល់ថ្នាក់សន្ធឹ ឬ សន្ធឹងខ្លួនដេកនៅលើខ្នែងខ្នង ឃាទឈ្មោះលែងកប់គេអ្នកណា ហើយ តាំងផ្តើមចេញសម្ងួនច្រងរឿងផ្សេងៗឮស្ទើរឮៗ រួចពីច្រងរឿងមកឮស្ទួរច្រត់បខ ដៃស្តាំច្រងមូនខ្លួនកុំ បង្គងក្អែក សុតជូជក ហើយក៏ងាន់តែឮសម្ងួនតិចៗទៅ ស្រាប់តែបញ្ចេញជូរជូរ រួចពីជូរមកឮស្ទួរក្តួចគ្រហែមមួនៗ ដៃស្តាំហាតេកួនៗដល់ខ្លួរសេចក្តីខ្លួចញ័រ ហាក់ដូចជាគេច្រត់បខក្នែងលែងកូនពេលនោះ ។

ទី ๗ ដែលថា ផឹក ៧ តែងនឹងកំសត់យ៉ាងណាគ្មានន័យនោះ គួរជ្រាបថាអ្នកផឹកស្មុកដល់ ៧ តែងហើយ អន្ទិយយំសោកខ្សឹកខ្សួលក្តួលក្តងខ្លួនតួចិត្តអាល័យដល់តែ ព្រោះប្រែក្តីផឹកជ្រលហួសប្រមាណបានក្តីមរណៈប្តូស្មើរជិតនឹងមរណៈ ធ្លាក់ចិត្តគាំងខ្លួនយំស្រណោះអាល័យទៅតាមសម័យរឿងបេះខ្លួនដែលវិតក្កកន្លងទៅនោះ ។

អ្នកផឹកស្មុកតួរគិតឃើងខ្លួនហ៊ោ តែវិនឹកពីនឹងផញ្ជឹងតាមសេចក្តីនៃពាក្យកាព្យដែលតែងសេចក្តីសង្ខេបខ្លះជាបែបរបស់អ្នកផឹក ដូចត ៧ នេះ ។

កាព្យពាក្យ ៧

អ្នកដើយអ្នកផឹកទឹកស្មុក ចេះនឹកមេត្តាគាំងខ្លួន ផឹក ๑ តែង ៧ តែងឯង ត្រូវចំក្បួនខ្លួនយើងគួរអនិច្ចា ។ ចេះនឹកស្រណោះដល់រូបកាយដួលដេកមិនឆ្ងាយពីផបស្រា តែ* ស្រឹងខ្លួនស្រាតក្បែរផ្លូវធ្លា ដេរខាត្មានគ្នាជួយកំដរ ។ កូនស្រាអសោចជ្រុះចេញសាយ ចៃតសារព័ត៌ាយ ๆ ញាញ៉ែរ ញើសចេញសព្វច្បាណាហួសញ្ជរ គួរនឹងរអងមិតិតសង្វេត ។ ចៃអស់អ្នកផឹកចាំទុកឃ្លាដើយ ត្រូវលះឲ្យហើយកុំឯបំពេន កុំផឹកឲ្យជ្រុលដល់ដួលដេក សូខ្យាសេះសូខ្យាឈ្មោះពុះយោកជាតិ ។ ឮប្រាប់លោកបុណ្យពីត្រង់នាយ ប្រដៅសត្វសម្លាប់ប្រើមារយោខ ទំលះ

សុកទសាធ៌ជាតិ កុំឃ្លាតវៀតធ្វើសីលទាន ។ ឲ្យទាន់វ័យខ្លួនកំពុងក្មេង
តែរលេះឲ្យជេងកុំស្រែកឃ្លាន សាធ៌សីលជាទំនៀមស្រាបស្រួចប្រាណ
តាំងពានជាខុនធ្វើដើមផល ។ ធម៌តាំងពីរនេះនាំឲ្យ ថ្កើង គួរកាប់តាស់
ឡើងធ្វើជាថ្នល់ អ្នកប្រាជ្ញតាំងឲ្យយោកពន្យល់ ចាត់ជាឋុសគល់
យានជំនិះ ។ ហៃយុវជនតាំងប្រុងស្រែ គួរតែគប្បីគិតត្រិះរិះ ចូរទំរើ
ខ្លួនពីផឹកនេះ ឲ្យបានរេចពីសន្ដាន ។ ទោះបើតែផឹកស្រាជាប់ស៊ីសាច់
ស្រែវាំងមិនជាប់រៀមិនបាន រលងស្គាល់ប្រពន្ធកូនខ្លួនប្រាណ នាំឲ្យ
រំខានបានក្ដីខ្លុក ។ ដូចជាព្រះបាទពោធិសម័ ព្រះចៅអប្រិយគ្មានឈ្មល់
មុខ កូនស្អប់សាច់ស្ងែលុកក។ មួលកបាត់ខុកធ្វើព្រះស្មោះ ។ ចូរឯង
មើលរឿងព៌ាវស្ដេចនេះ យកទៅត្រិះរិះកុំបីភ្លាយ កុំធ្វើតម្រាប់តាម
បណ្ដាយ ខុកតែខ្ចីទាន់ក្រោយឲ្យអសោច ។ អាស្រ័យមកពីពោសសុក
គ្មានគិតបុត្រាប៉ុនស្រមោច មួលកកាប់បាត់ស្ងាប់ជាន្លោច យកទៅ
កំឡោបធ្វើព្រះស្មោះ ។ រឿងមួយទៀតកូនពោធិសត្វ បិតាស្លាប់
បាត់ខុកទ្រព្យឲ្យ ដល់ ៤០ គោដំពុបណ្ដាយ ឲ្យកូនទាំងក្រោយសៅ
ស្រែល ។ កូននោះចាយទ្រព្យជួលលៃទំលេង ពួកប្រុសស្រីក្មេងមក
ស៊ីឈ្នួល ប្រឹងកំសប្បាយតាមចំនួល ដល់ខ្លួនបាត់មកផឹកស៊ី ។
កើតពោសផឹងស្រាខ្លៃស្រវឹង មិនដឹងថាប់ទ្រព្យបាត់ខ្លួនខ្លី គ្មានអ្វី
បិញ្ចឹមពោះសូន្យជីវី ស្លាប់ខ្លួនកេញតែនៃអូសពោល ។ មានរឿងមួយ

ខៀតកូនឃើងស្លឹង ជាកូនឃើងប្រើឃើងតែតែងថ្មោល ទោសពីចាយទ្រព្យ
ចំណូតគ្រាល ត្រូវញាតិវង្សចោលនេលែងគប់ តើងទោសដឹក
ស្រាស្រែងឹងទោរ ពុនតាងដំនោរចំណោងទ្រព្យ តាលំពែរនាសូនបង់
អកឮ តួកញាតិតេស្អប់តេចាត់ចោល ។ ឯរឿងចាំង ពៃ តាទៅនេះ
ឯងត្រែរត្រីរិះតិតវេញនោល ចំណូនដែលនៅផ្ទះតែ ត្រាល ឆាប់លះ
បង់ចោលហ្នាអាក៏ ។

រឿងស្តេចពារាណសី

ក្រុងពារាណសី មានមហាក្សត្រិយ៍មួយព្រះអង្គ វេលាសោយព្រះ
ស្នោយហើយ ចើគ្មានសុភនិតីសាចទ្រង់ក៏សោយព្រះស្នោយមិនបាន ។
ក៏កន្លងនូវនោះ លុះដល់ថ្ងៃ១ ភ្លោសថពួកអ្នកនតរតេមិនដែលសម្លាប់សត្វ
ឡើយ ។ អ្នកធ្វើព្រះស្នោយស្តេចទិញយកសាច់មកលាក់ទុកកន្លងថ្ងៃ ៧ ដង
នៃបក្ស (ប៉ុន្តែនិងធ្វើថ្វាយ) សត្វឆ្កែចាំងឡាយក៏ទំពាស៊ីសាចនោះអស់
ទៅ ។ អ្នកធ្វើព្រះស្នោយមិនបានសាច់កន្លងថ្ងៃ១ ភ្លោសថ មិនហ៊ានាំកន្ត
យកទៅថ្វាយស្តេច ទើបត្រាចទូលសេចក្តីនោះដល់ព្រះឱរសទៅ ឆ្លើយ
ថា "នែ! អ្នកចាំងឡាយ កូនប្រុសរបស់ខ្ញុំជាទីស្រឡាញ់ពេញព្រះ
ទ័យរបស់ស្តេច ។ ទ្រង់ទតយើញកូននេះហើយទំនងថើបបបោសអង្អែល
ខ្លួនកូនរបស់ទៅឲ្យអង្គុយលើភ្លៅនៃស្តេចពេលណា អ្នកចាំងឡាយយក

កត្តនាំចូលទៅថ្វាយស្តេចកំពុងក្រសាលថ្ងៃឡើងលើដាមួយនឹងកូននេះ
កន្លងពេលនោះបុះ" ។ ពួកអ្នកធ្វើព្រះស្មោចក៏នាំកត្តចូលទៅតាមចំនួន
នោះ ។ លុះនោះ ស្តេចកំពុងស្រាំងស្រាមិនឃើញមានសាច់ក្រយាកន្លងកាលនិតាស់សួរថា: "ឯណាសាច?" ពួកអ្នកធ្វើក្រយាក្រាបទូលថា: "ថ្ងៃនេះជាថ្ងៃទោសថគ្មានសាច់តស់ទេ" ។ ព្រះបរមក្សត្រខ្ញុំជាប់កូននោះមួលកក្រើយជីវិត លើកចោះចោលទៅចំពោះមុខអ្នកធ្វើកត្តហើយខ្ញុំជាថ្លែងថា: "ចូរយកសាច់នេះទៅចំអិនឲ្យនាប់" អ្នកធ្វើកត្តធ្វើតាមព្រះពាក្យតម្រាស់ ។ (ពេលនោះ) សូម្បីតែមានមនុស្សណាមួយហ៊ានយំសៃកក៏គ្មាន ព្រោះខ្លាចស្តេច ។

ព្រះទៅការណ៍ខ្ញុំសោយព្រះស្មោច ទឹងសាច់កូននោះឯងហើយខ្ញុំផ្តួលកំលាន់ទៅ លុះដល់ចប្ងូសម័យខ្ញុំតើនឡើងស្ងាត់សុកទើបមានព្រះពាក្យតម្រាស់ថា: "អ្នកចាំងឡាយចូរយកកូនមកឲ្យអញ" ។ គ្រានោះ ព្រះនាងទេវី កំពុងខ្ញុំព្រះកន្ទៃនន្ទកកន្ទេញក្រាបទូលថា: "បពិត្រព្រះសម្មតិទេព ថ្ងៃម្សិលមិញខ្ញុំសម្លាប់កូនព្រះអង្គឯង ហើយសោយព្រះស្មោចជាមួយនឹងសាច់កូននោះទៅហើយ" ។ ព្រះពាក្យខ្ញុំព្រះសណ្តាប់ហើយ ខ្ញុំព្រះកន្ទៃនសោយសោកនឹងស្តាយព្រះពាក្យបុត្រាទើបខ្ញុំព្រះចិន្តាថា: "សេចក្តីទុក្ខវេទនាអញនេះ ហើយកើត

មកតែអំពីគោសធំកសុក" ខ្ញុំឃើញគោសក្នុងកំរិយាធំនូវសុកដូច្នោះ ហើយក៏ចាប់អាថម៌ដឹមកផ្ទួតព្រះកន្ត្រកហើយខ្ញុំអធិដ្ឋាន (សម្បថ) ថា ចាប់ដើមតាំងពីកាលនេះទៅ អញមិនបានបរិភោគសម្រែចព្រះអរហត្តផលបណ្តោះទេ អញលែងធំកសុកថែបនេះ ដែលជាអំពើធ្វើឲ្យវិនាសផលបន្តិចបន្តួចនោះ ខ្ញុំក៏លែងសេពសោយសុកតាំងពីកាលនោះរហូតទៅ ។

ចប់ រឿងស្តេចពារាណសី ។

រឿងកូនព្រះពោធិសត្វ

សេចក្តីថា ព្រះពោធិសត្វជាព្រះសម្មាសម្ពុទ្ធយើងព្រះអង្គកើតជាសេដ្ឋីក្នុងក្រុងពារាណសី ជាអ្នកមានទ្រព្យកប់ទុកក្នុងផែនដីចំនួន ៤០ កោដិ ព្រះអង្គតែងធ្វើបុណ្យទ្រព្យទានពុំដែលដាច់ លុះដំណើរអំពីនេះទៅ ក៏បានទៅកើតជាព្រះឥន្ទ្រ ។

ឯកូនព្រះបរមពោធិសត្វនោះទៅ តម្កាល់ឯង ចាត់ចែងធ្វើមណ្ឌលប្រមូលពួកមហាជនច្រើនគ្នាមកធំកសុក បានចាត់ការចំណាយកហាបណៈ ១ ពាន់ ឲ្យជល់ពួកអ្នកលេងល្បែងភ្នាល់ច្រែងចាំងនោះ ខ្លួនឯងជាអ្នកលេងស្រែ ធំកសុកស៊ីសាច់ តាល់តែជាប់ចិត្តស្អិតតែនឹងល្បែងមានភ្នាល់ច្រែងជាដើមនោះ ហើយចំណាយទ្រព្យចាំង ៤០ កោដិ ព្រមទាំងគ្រឿងឧបភោគ ទំនិបវិភោគទ្រព្យវិនាស តាល់តែឆ្កាត់ខ្លួនទៅជាមនុស្សក្រក្រមនាថា ស្ទើរតែគ្មានសំពត់ ។ (នៅមានត)

លោកមហា "សៅរ៍-លី"

វត្តសោយ ឃុំម្រៀន ស្រុកគោះសូចិន ខេត្តកំពង់ចាម

(ឥតលេខ ១២ ធ្នូ ឆ្នាំ ៤៧)

វគ្គទី ៣

ពាក្យ ៨

ចូរមើលអាទិត្យបន្ទាលលា គ្មានស្រាកមួយនាទីពាំងថ្ងៃយប់ ចូរមើលតពកសាត់មិនមានឈប់ អ្នកប៉ងសុខសិប្បគួរគិតរំពឹង ។ ចូរមើលដាតិស្មៅចោះក្តៅយ៉ាំងណា នេតាស់ភាត់ម្ចាំងងំលាស់មិនទង់ ចូរមើលអណ្តើកទាំរត្រងសូង អំណាចងារច្រើនទីរលំគ្រៃយគ្រា ។ ចូរមើលរំតេះជញ្ជួនទឹក ស្រោចស៊ីតពន្ធឹងនៅវាលស្រុក ចូរមើលខ្យាដាតិតបាទាំលួនលីលាបានធ្វាយដួចចិត្ត ។ ចូរមើលអន្លង្គត្រសងត្រមគ្នា ទាញស្ទឹកស្តុកសម្បុតស្ងួត ចូរមើលកម្លាំងព្យាមចង្រិត ការរួងពិចិត្របិតជាសុខសាន្ត ។ ចូរមើលពាលចក្ស៊ីវិលបរ ទំមុជត្រវាចាប់មច្ឆាបាន ចូរមើលស្រមោចទំខ្លាំងប្រមាណ ពាក់ពាងធំហួសប្រាណបានដោយច្រយោង ចូរមើលទិសទស្សាយនាយដិតខ្លួន មហាប្តូបបួនច្រាំមណ្ឌលលោក ចូរមើលមហាណ្តាតឆ្នេរត្រៃយគោក ត្រង់ណាកើតគោតមានកស្តនានា ។ ចូរមើលវែនទំរូបដំណាងលោក នគរនគរគៀងមានរូប

ឆជា ចូរមើលឥណ្ឌាចំនួនម្ភូជា ទន់ដ៏ឃកាកនៅនាគ្រែដ៏ណា ចូរមើល
ខ្លួនអ្នកតើពាបម្ដងខ្លះ មានទ្រព្យសម្ដិចសនាយម្ដងសា ចូរមើលរូបអ្នក
ជ្រាក់ប៉ុន្មេចម្ដា មានហត្ថស្រាត្តពាបម្ដងទៅ ។ ចូរមើលគ្រួសារជាតិ
សាសនាអ្នក ដែលអ្នកពីនិពាក់តើជ្រាក់ម្ដេចទៅ ចូរមើលពួជអ្នកតើពាក់
ប្ដូរជ្រៃ សុខម្នាពោមៅប្ដូរនៅមែចណា ។ ចូរមើលជនាមាមីរសកល
មើលគិតពិភាល់សព្វឆកាល ចូរមើលស្រុកគេភ្លើងឃសអារ្យ តើ
ធម្មជាតណាជាមេបមុខ ។ ចូរមើលអ្នកនិរលើលាលើ តើព្រៃ
អំតើអ្វីឲ្យពោសខ្លួ ចូរមើលអ្នកខ្ចៅបានសៅប្ដូសខ្ញ ខ្ញើយហាត់ចំប៉ុក
ប្ដូសុខអាត់ ។

វគ្គទី ៤

ពួកកុំរៀន

កុំរៀនស៊ូច្រែនតាំតើមនិត្រា កុំរៀនតណិតាមិនចេះពិនិត្យ កុំរៀន
តិកង្ខរឿងមិនគួរតិត កុំរៀនជម្រាណាឥតប្រយោជន៍ ។ កុំរៀនអៀន
ខ្លាចផ្ដាមមិនគួរការ កុំរៀនមិនពិចារឲ្យល្អិតល្អោច កុំរៀនស្អប់ការ
អង្គាច់អង្គាច កុំរៀនចេះចុងទ្រព្យគេមិនឲ្យ ។ កុំរៀននៅចំនេរ
ខាតការកម្ម កុំរៀនបណ្ដាក់ចាំថាពេលក្រោយ កុំរៀនច្រែសមើល
ងាយនាំគ្នាយ កុំរៀនមិនឲ្យមានសុមយាចក ។ កុំរៀនផ្ដាសាគូខ
ឆ្ពោះមុខក្រៀវ កុំរៀនម៉ិចមៀរមាយាម៉ិចម៉ក កុំរៀនមាយាថ្លែងឥតម្ចឹក

ម្ចាក់ កុំរៀនឆ្មឹកឆគឹកមាវយោទចោកេ ។ កុំរៀនលិចលាហ្គាលែះលួនហែរហែរ
កុំរៀនបែចម៉ែបែរសន្ធូរសោ កុំរៀនខ្ចិចខ្ចក់ឡឹកឡក់ចាំឡោ កុំរៀន
តែតែគ្រាមាយោញឹកញាក់ ។ កុំរៀនម៉ាត់មៀងសម្លក់កែបូរ កុំរៀន
រអូរផ្ទួរៗដឹកគ្នា ។ កុំរៀនឡូរញ៉ាំក្តិចឈ្លេបត្រែចក កុំរៀនជ្រងសក់ធ្លក់ ដៀង
កិច្ចតល ។ កុំរៀនការគូតក្រែឡិចក្រែឡុច កុំរៀនស្តីចាក់ចុចអុជគាល
ខ្លួល កុំរៀនកាន់ការបៀបបៀមសល់រាំ កុំរៀនមិនធ្លល់មិនខ្លួលស្ទូ
សង ។ កុំរៀនមិនស្តាប់ត្រាប់ទុបាយតេ កុំរៀនប្រមាទមេដេរៀមច្បង
កុំរៀនប្រព្រឹត្តលេងលែ្បងស៊ីសង កុំរៀនធ្វើយធ្ងន់តង់ពាក្យមេបា ។
កុំរៀនដំនើបដំអង់ទ្រមក់ កុំរៀនជក់អាកៀនញៀនតញ្ជ កុំរៀនរំក្រែប
ជីកមេរ៉ាសុព កុំរៀនសាក់ចាប់ជារមិនមាំ ។ កុំរៀនពាណិនាដើមក្តៅ
អ្នកផង់ កុំរៀនត្រាប់ត្រងមាយោទក្រែងាំ កុំរៀនស្តីញាប់ជាប់លាប់
ព្រលាំ កុំរៀនពាំនាំពាក្យស្រែងញុះញង់ ។ កុំរៀនច្រាំភ្លៀលង់ទៅ
ងាល់ស្លាប់ កុំរៀនមិនស្តាប់ត្រាប់ច្បាប់ពុទ្ធអង្គ កុំរៀនរួសកន់ពេតនាំ
ចែកចង់ កុំរៀនថមអង្គនាំខុនពាំ ។ កុំរៀនត្រែត្រែគាធណ្តូងណាង
ឥតនិត កុំរៀនប្រព្រឹត្តស្តីឥតសុំ កុំរៀនគាន់ចិត្តសន្ធើមចែបាំង
កុំរៀនប្រណាំងកាសនាក្អកធំ ។ កុំរៀនវាតជាតិញាតិដៅពង្ស កុំរៀន
ដៀមង្គលពុំទុត្តម កុំរៀនស្អប់គួនតំនួនចង់តុំ កុំរៀនជំទុំគ្នាស្តីកេយ
កយ ។ កុំរៀនឆាប់ទឹងមិនជឹងដើមទន កុំរៀនបួកងំបង់ខាតមិនស្គាយ

កុំរៀនចំអកញញើតាជូនជាមួយ កុំរៀនចរិយាយកកន្ទើរខ្លួនច្រើបច្រំគេ ។ កុំរៀនដៀលពាក្យអាក្រក់ចិសាច កុំរៀនស្តែងខ្លាចកុសលបុព្វញ្ញ កុំរៀនលែងរៀនគាំយើយកេ កុំរៀនធ្វើលេលាប់ឫតលំកលាន ។ កុំរៀនឱនក្រាយយូរទៃមក់ កុំរៀនចាយឈ្លក់ហួសខុនធនធាន កុំរៀនស៊ីច្រៃនផ្តើនតាមចិត្តឃ្លាន កុំរៀនឱនានរឿងអ័ប្យក្រាជ្ញ ។ កុំរៀនបែត្រីរូបវ័ត្ថាយងាយ កុំរៀនឱយាយពាក្យផ្សាសា កុំរៀនលួចលួនបែពន្ធមិត្តភ្លា កុំរៀនលើលាលង់កតិយាម ។ កុំរៀនអានចិត្តព្រហើនកោងភាព កុំរៀនបន្ទាបលន់មាតុត្រាម កុំរៀនអាងេសន្ធានដឹកឈាម កុំរៀនដេកយាមចាំកម្ចាស់ណាង ។ កុំរៀនច្រៀងលេងនឹងក្មេងតូច កុំរៀនរប៉ូចរប៉ិលអួចអាង កុំរៀនចរោចេះចេងក្មេងអាន កុំរៀនណូងណាងវាងាំជ្រាប់ឫត ។ កុំរៀនដុតយតនិស្ស័យទុតាតិ កុំរៀនស្មេហ៍ភាយាតែព្រឹង កុំរៀនស្តប់ខឹងហើយមិនច្រើងនឹក កុំរៀនរឭកហើយមិនភ្លាច្បាណ ។

វគ្គនី ៩

បទកាកគតិ

ម្នាលកូនច្រុស-ស្រី ចិតាស្រែដ៏ ចូរចាំណាច្បា ហាត់ចិត្តរំព័ន ច្រើនត្រាច់ពាចា ដែលប្លូបុត្រា ថាតាំនឹប្តូនាន ។ ស្រុកនេត្រណាស់ ជនច្រើនតែក្រាស់ ផុតកិច្ចពាប់ចាន បុត្រច្រើនគំនិត ពិនិត្យសព្វស្ថាន រក្សាចិត្តច្បាណា ឲ្យប្រាកដ្ឋគួម ។ កិច្ចការកម្មក្តៅ រៀនជុលរៀនដេរ

រឿនចាំកាំជាកំគុំ, រឿនចាំនជានប៉ះ រឿនផ្សះផ្សាបផ្សំ រឿនជ័បរឿនចំ
រឿនត្បាញវៃ ។ រឿនថ្លៃបរឿនថ្លៃ រឿនគ្រែបចាក់ជា ចាក់ដុំនក្រៃឡៃ
រឿនក្រែងចងគ្រែប រឿនជ័បរបៃ រឿនស្រែរឿនថ្នៃ រឿនលៃលិនក្លៃញ ។
រឿនចាក់បងគាត គ្បាញស្បូតសណាត ចាក់ឆ្នូតមើលឃើញ រឿន
អន្ទងធ្នាក់ ឲ្យជាក់ស្តាត់ស្តើញ លួមឈ្នួញមកឃើញ ដណ្តើមគ្នាទិញ ។
រឿនចោះតបាស រឿនកែកស្តុចាស់ ឲ្យថ្មីលេញ រឿនសព្វការ
ស្តី កុំបីលង់មិញ ពាន់ចាស់នៅពេញ រឿនទៅស្តាយសិល្យ ។
រឿនធ្វើបបរ រឿនបុកអង្គរ រឿនលាងចានផ្តិល រឿនរៀបទុកជាក់
ពស្តុពាក់សរិល រឿនធមិកាន់សីល ខ្ជូនអាត្មា ។ រឿនស៊ីរឿនដក
ទិញដូរលក់ ចេកដូងម្ទូស្វា រឿនដាំបណ្តុះ ឈ្មោះឈើផលា ចេះ
ស្ទឹងផ្លែផ្កា លក់ចិញ្ចឹមកូន ។ រឿនចាយសរៃ រឿនកុំដេកថ្ងៃ រឿន
កប់បងប្អូន ជីតូតជីតា ជីលាជីដូន មួយមិត្រចិត្តស្ងួន ខ្ជួនក្តើប្តូរគ្នាក់ ។
រឿនលេខអក្សរ រឿនគ្បាច់មករ រឿនគួរកំសត្វាក់ រឿនខ្វក់រឿនស្អុត
រឿនសិតរឿនសាក់ រឿនជាងមាសច្រាក់ ជាងចាក់ក្រែវឆ្នាំង ។ រឿន
ធ្វើកាំបិត រឿនផែថែបចិត រឿនចិបឲ្យរឹង រឿនធ្វើបបាប់ ពន្លាត
ប្តូដឹង បបរដាក់ប្តូកឹង រឿនជញ្ជឹងរាត ។ រឿនស្តូម្ខាយ រឿនក្បួនខ្មាស
ពាយ រឿនលាក់រឿនលាត រឿនតប៉ះប៉ូន រឿនគុនថង់ត្បាត រឿនធ្វើ
ចំណាត រឿនប្រែប្រែជូរ ។ រឿនស្តើករឿនពាក់ រឿនស្តាប់

ទ្រៀងភាក់ រឿនពាប់អម្បូរ រឿនស្រឡាញ់ជាតិ ញាតិឃ្លាតឆ្ងាយយំយូរ រឿនដួយត្រកូល ជាតិស្រុកអាភ្ន ។ រឿនចាប់តាស់កាត់ រឿនតាពេក្ស័ត្រ រឿនស្តីចរោ រឿនពាជស័ព្ទ ចែនចក្លាប់ធម្មតា រឿនតែងអាឡា លំទំនៃសេចក្តី ។ រឿនឆ្នូរឿនចាខ រឿនមើលអាពាធ ដោះទុក្ខប្រុសស្រី រឿនផ្សុំទុសថ ចំហុតលក្ខាញ្ញាស្ប៊ី រឿនពាស់រែងដំ រឿនក្លែងស់ពន ។ រឿនធ្លើមេទ័ព រឿនកុំខ្លាចងាប់ រឿនបុកក្បាហាន រឿនបើកនាវ រឿនថ្កឹងាន រឿនសន់ថ្នល់ស្ពាន រឿនដាវតំហោរ ។ រឿនធ្លើជាងទង រឿនគ្បាញ់អូមមង. ជាងគាត់គាល់គោរ រឿនធ្លើដើងពាន ផ្តល់ចានតែងថា ជាងអាតមេ្បរ គ្រូថ្នាំហោសត្តង ។ រឿនជាងដេរគាវ ខោជាក់ហោប៉ាវ ធ្លើបាវគាវុង ពួកព្រៃចៀមចំ ជាហ៊ុំគ្រែមុង គាវយឺតសាវុង លុងដងខ្នង។ រឿនធ្លើហ៊ីចសោ អូបធំត្រីសប៉ោ ពាង់ត្រចៀកបួន គុងដុងនាប់ត្រឡាប់ត្រមួន តូបធំឆ្នួន ម្ហូបដួនគៅតី ។ រឿនជាងជាន់ឥដ្ឋ ចាយអដ៏ស្អាត រឿនគ្បាញ់ជាលស្ប៊ី កន្ទាំងំខ្ញីតៅ កន្ទៅត្រកត្រី ឧញ្ជើគ្រូថ្ម លាយលះបថ្នង់ឈ្នាង ។ រឿនចាយអត្ថ: មើលថ្ងៃឡើងស័ក្ត នរលក្ខណ៍រូបកាន់ គេស៊ីប្លុតតែង រឿនថ្នឹងដំនាង មានភ័ព្វសំណាង ប្តូកយ៉ាងណា ។ រឿនហេតុសាស្ត្រ រឿនចាំទ្រៀបស្រាស់ នក្សត្រតាក តតំអាងត្បូ បវ័តចន្ទ្រា ផែនដីលីហា យូរនាប់ប៉ុន្មាន ។ រឿនស្តង់ទឹកដី ស្មានជាតុជាតំដី ឥសង់ភូមិស្ថាន វត្តវិញ្ញា សង់ត្រីហាលាន រឿនទ្រៀបំណោន

សំពាន់ត្រែប៉ូវ ។ រឿនធ្វើនាក់ បើកក្តងផលសា លឿនលយតេកក្តូ
យាំងទូកកាណូត្រែ ឡូវបុត្រសំពៅ ទឹកពាក់ថ្ពាល់ បើកទៅស្នានដល់ ។
រឿនធ្វើសំប៉ាន កប៉ាល់យន្តយន្ត ត្រែវិចត្រសកល អាកាសយាន
ភាពយន្តខ្នុរយៈ ឥឡូវធ្លាប់ឮ អគ្គិសនី ។ រឿនបេម្ងាប់សែ្ន
រំលោភស្ពានថែក ថ្លៃដែរមណ្ឌ ជាតែ្ងកាកែង ជាខ្លួនក្លែងក្តី ធ្វើឆ្ងាំង
ផែកដំ ខ្សែម្ជុលដេរម្សិល ។ ថង់រងែកន្ត្រី ចាវ៉ែខ្សែរ៉ុ ត្រែបូចសំពៅត
បំភ្លៀនសែ្ករជើង ផែនដីនស្ងប់សែ្ងត ជាន់ឈើឈូសឈៀត ធ្វើត
រឿនកុំភាន ។ ធ្វើនាឡិកា សារសោធ្នាក់ត្រា រឿនចែងថ្ងៃគាន រឿន
ថ្ងៃមុនស្មើ រឿនប្រែះជ្រាន រឿនកែ្សប្រាណ ឲ្យជានរុងរឿង ។
រឿនធ្វើកាំភ្លើង រមៀកោះថៅភ្លើង បាក្តងក្រងមឿង រថភែតែបក្រ
ខោបក្រតែប់ត្រឿង រឿនឲ្យតែប់រឿង ពួកយានជំនិះ ។ រឿនធ្វើឋូតូស
តែប់ថែកឈើតូស ឋូដូតថែកកិះ រទេះត្រែបី រថគោលាសេះ សំពាប
ឋញ្ជិះ ត្រួសាកំសាន្ត ។ រឿនភាសាស សន្ទ រឿនអក្សរសោស្ត្រ
ជាតិរៀកែ្សប្រាណ រឿនធ្វើភាពាន ជិត្តមុតហៅហាន រឿនហាត់
សន្ធាន រឿនទិតន្ធរឿង ។ រឿនធ្វើកំសៀវ ផឋសពណ៌ខៀវ ធ្វើលំខ
ស្អាយលឿង ត្រែហាមថែតង ពណ៌ខ្លួងខ្លីត្រែប្រឿង ស្រែតាំងលឿង
លឿងពុំផ្លែមេយ ។ ហង្សប្រាខប្រាផ្នាត់ ត្រួយចែកលំខស្វាត់ លំខពណ៌
ថែក ។ រឿនធ្វើដែកគោល ខ្សែស្ពានដែក កញ្ចាំងចាំងក្តែក ឆ្នុះ

មើលស្រមោល ។ កែវទឹកតូចធំ ដង្កាប់ដង្កឹង ដែកដំដែកគោល ញញួរ ស្វាន ខ្វៃ បង្គៀនដៃហ៊ោល ច្រមុះអុជច្រោល ពួរយោលយឺតយាត ។ រៀនធ្វើកែវស្តង់ ធ្វើច្រែនអេស្ទង់ សាងីទូញពក្ខាត ច្រែងតាតច្រែងជូង ច្រែងលូលាន់ល្អាត ខ្លែងរាំរន់ពាត ច្រែងហ្គុងសាលង្គាត ។ រៀនធ្វើសាច្ចី សូដាកៅស៊ូ ទឹកអប់តូនឯក រៀនគ្រងមាលា បុប្ផាកូនច្បែក រំចៃតែប្លង់ឯក តាប់ក្បែកផនា ។ រៀនគិតផញ្ជឹង គ្រែរំរែពីង បណ្តុះបញ្ជា ក្តៅផ្តាំ សព្វសិល្បសាស្ត្រា មានកង់លោតា កុំបីព្រំលង់ ។ ចើរស្លៀវល្អាន់ ចើរស្ងួតគេដាន់ ចើរស្លឹលវាបង ចើរល្អាសវាផុយ ចើរល្មួយវាស្ងួន ចើរស្ងុំវាជង់ ចើរស្ងួនវាល្ងឹត ។ ចើច្រែតវាល្អ ចើព្រែលវាត្រែ ចើច្រែកវាជិត ចើច្រែនវាស់ ចើប្រែសមិនស្ងែត ចើព្រាងត្រែតែត ចើព្រឹទ្ធសំពះ ។ ចើច្រែឲ្យច្រាប់ ចើច្រាបឲ្យស្តាប់ ចើច្រាប់ឲ្យច្បាស់ ចើរៀតឲ្យត្រាយ ចើច្រាយឲ្យច្រាស់ ចើប្រែនវាល្អះ ចើច្រាស់ឲ្យផុត ។ ចើរចេះឲ្យចែង ចើចាំឲ្យស្តែង ចើចិត្តឲ្យមុត ចើចាប់ឲ្យរាញ ចើរចេញឲ្យផុត ចើចារឲ្យសុទ្ធ ចើចុតឲ្យស្ងែ ។ ចើចាយឲ្យតែត ចើចាន់ឲ្យពិត ចើរចែកវាស្ងួន ចើចន់ឲ្យមួន ចើចួនឲ្យរែន ចើរចារឲ្យស្តែង ចើរែនឲ្យច្បាស់ ។ ចើរៀនឲ្យជាក់ ចើរស្រាវច្បាក់ ចើរកក់វាខ្ជាស់ ចើរៀបឲ្យសម្រ ចើរុំឲ្យត្រាស់ ចើរឹងឲ្យណាស់ ចើរត្រួតឲ្យខ្ជែន ។ ចើរាំងឲ្យជាប់ ចើរស៊ូឲ្យតាប់ ចើរកប់ឲ្យរឿង ចើរកឲ្យបាន ចើរុនឲ្យមឿង

បើាជឲ្យខៀន បើរៀងឲ្យសម ។ បើសីលឲ្យស្អាង បើសៅឲ្យឃ្មាង បើ
សាងឲ្យសម បើសើបឲ្យតួរ បើសួរឲ្យបំ បើសិស្សឲ្យខំ បើសមវាងាប់ ។
បើសំបឲ្យសូត្រ បើសង្ឃឲ្យស្តូត បើសូត្រគេពាប់ បើលែកវាចាំ បើសាំវ
លាប់ បើភ្លេកភ្លាប់ បើសុខសប្បាយ ។ បើបាទឲ្យថែង បើបាច
ឲ្យត្រែង បើថែងឲ្យសាយ បើបោកវាថែក បើបុណ្យខ្ពស់ខ្ពាយ បើបង់
វាស្តាយ បើថែកវាបង់ ។ កាយកុំកាល កុំខ្ទះខ្ទាយខ្ជិល កុំលេងលិចលង់
កុំឆោមឆោតឆៅ កុំជ្រែជ្រុលជ្រង់ កុំសៅតើពង់ កុំលង់លុះលោញ ។
កុំលោភបើសលន់ កុំសោសវាសេន់ កុំស្វាញស្វិតស្វាញ កុំជោរជេលជាតិ
កុំផ្ងាតផ្ងរផ្ងាញ កុំសុះស្ងើតស្ងាញ កុំជាញជាតិជន ។ ចិត្តចោរកុំបង
សូឲ្យស្ងួរកុំសង យប់យូរកុំយន់ បងប៊ីកុំបោះ ពួជពាស់កុំពន្ធ កូតកវាកុំកិន្ត
ជាន់ជាប់កុំជេរ ។ កូនកាចកុំកោត ខ្លួនខ្ចៅកុំខ្ចោត កូនកុំចំនេះ ឥតប្រាថ្នា
កុំអួត ឆ្កែឆ្កួតកុំក្បែរ កូនកុំចោលកន្លែ វេរកប្តូរគ្នា ។ ខនរជាកាយ បើ
ប្រតិបត្តិឲ្យ ក្រែឲ្យសុខ កុំឲ្យគេស៊ប ឲ្យស្ងើចចំផុត ប្តូរកូនលំអុត
ច្រៀបាណាតិ ។ ឯះទ្រព្យសម្បត្តិ បង្គប់ផ្តាត់ ពួជពង្សមុនី ឃើតមក
ចំញឹម ជាប់គាយិន្ទ្រិយ កាយតីជានី ទីមាតុស្នាន ។ ផេះកុំដៀលពួជ
ល្ងង់កុំខ្ចូល ពួជខ្លួចកុំអាន ការណ៍ក្រែកុំត្រាក ពាក្យរោលកុំស្នាន ស្ងើ
ស្មាធីកុំវាង សីលថានកុំស្ងប់ ។ ក្រែកុំធ្លើគ្រាន់ រឿនកុំស្រែកន់ ត្រាន់កុំ
អាលស្តប់ ខ្លាញ់កុំអាលស្តិ ក័ងកុំកាលឡប់ ធំកុំអាលថប់ ងប់កុំឲ្យគាត់ ។

បរិយោសានកថា

សុភាសិតនិទ្ទេសកថា ខ្ញុំបានតណ្ហាជាសន្ធិត បរិបូណ៌ដោយគតិវិចិត្រ ដើម្បីជាសច្ចវេមក ។ សង្ខេបចប់ចុះត្រឹមប៉ុណ្ណេះ ឈប់ស្ទេះពីរេះសូម សច្ចា ប្រែណិធានផ្សាំដោយខេតនា ស្មោះសច្ចាផូរផង់ស្អាត ។ សូមផល ទុកដល់វេមក មានមហាភ្ញ្ជាតាជាដើមអាទិ៍ ឲ្យបានគតដោយសប្បាយ កុំបីឃ្លាតសុខបីវេកាល ។ ឲ្យសុខក្នុងមនុស្សលោក ៦ ទេវលោកជ័យទ្បារ ឲ្យសន្តិសុខយ៉ាងអស្ចារ្យ និដ្ឋិតាចប់ត្រឹមនេះហោង ។

ចប់

RÉGIE DU
COMMISSION DES MŒURS & COUTUMES

កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា ទំនៀមទម្លាប់ប្រពៃណី ចោះពុម្ពផ្សាយ
អំពីពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកអក្សរសាស្ត្រ: ហ្វូងនិពន្ធមន្ត្រី ញ៉ុក-ថែម, បណ្ឌិត នៅ
ពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកដំណឹងសាសនា: ព្រះគ្រូសុវិឡញ្ញាណ សូរ-ហាយ
ព្រមដំពូកព្រះវិន័យ នៅពុទ្ធសាសនបណ្ឌិត្យ

បញ្ជីរឿង

		ទំព័រ
ផ្នែកអក្សរសាស្ត្រ		
ហ្វូងនិពន្ធមន្ត្រី ញ៉ុក-ថែម	ពាក្យបរិយាយដើមនៃរឿងសាមកុក	៨១
អ្នកឧកញ៉ាវិបុលរាជសេនា(ខ្លូ-ពាន)		
ព័ណ៌ងារស្ត្រី	អារម្ភកថានៃរឿងសាមកុក	៩០
អ្នកឧកញ៉ាទេពាទ្វរឈឹម-ក្រែសេម		
ព័ណ៌ងារស្ត្រី	ល្ខោនស្បែក	១០០
ឃុនសុន្ទរមេធី ញូង-សឿង	ឯកសហស្រកត្រី ភាគទី១៧	១១៧
ហ្វូងនិពន្ធមន្ត្រី ញ៉ុក-ថែម	ប្រវត្តិសាស្ត្រប្រទេសចិន (តទៅ).....	១២១
លោក ភ័យ-ប៊ុក សមុហបញ្ជីធំ	រឿង សុន-យ៉ាត-សេន អ្នកឧយោបាយឯក	
	ដ៏ឆិចិន (តទៅ)	១៣២
ផ្នែកសាសនា		
ព្រះវិនយធម្ម ឃួរ-ប៊ុណ្ណា	សង្គហធម៌.....	១៤៤
ព្រះគ្រូបញ្ញាលង្កិត ភៅ-សឹម	ឃុវរវិយោកថា (តទៅ)	១៥៥

ឆ្នាំទី ២១ — លេខ ២ ខែ កុម្ភៈ ឆ្នាំ ១៩៤៨ — ដំឡៃដាវ ១ ឆ្នាំ ៦៨ រៀល ។

KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique.

Rédacteur en chef de la partie littéraire : Luong Nibandhamantrī Nhok-Thèm, Pandit à l'Institut Bouddhique.

Rédacteur en chef de la partie religieuse : Vénérable Brah grū Suvaddhañāna So-Hay membre la Commission du Tripitaka

TABLE DES MATIÈRES

Partie littéraire:

		page
Luong Nibandhamantrī Nhok-Thèm (I.B.)	Introduction à l'histoire de "Sam kok"	81
Oknha Vipularājasenā Nou-Kan Député	Histoire de "Sam kok"	90
Oknha Deb Bidur Chhim - Krasèm Député	Théatre d'Ombres Chinois (Lokhon Sbèk)	100
Khun Sundaramédhi Nhoung - Sœung (I.B.)	Conte "Mille et une nuits" fasc. 15	109
Luong Nibandhamantrī Nhok-Thém (I.B.)	Histoire de Chine (suite)	121
Monsieur Ray - Buc Chef Comptable (I.B.)	Un épisode de la vie du Dr. Sun-Yat-Sen, (suite)	132

Partie religieuse:

Vén. Brah Vinaya-dhamma You-Ponn membre de la Commission du Tripitaka	Sangahadhamma	144
Vén. Brah grū Paññā-likhit Kao - Sim professeur de l'Ecole supérieure de Pali	Yuvācariyākathā (suite)	155

20e Année: n° 2 Février 1948 — Prix d'abonnement 68$00 par an.

ការសិក្សារឿងនៃរឿងសាមកុក

របស់

ហ្លួងធិពន្ធុមន្ត្រី ញ៉ុក-ថែម

រឿងសាមកុកនេះ ជារឿងវីរបុរសទាំង ១ ក្នុងគន្លងប្រវត្តិសាស្ត្រចិន ក្រោយពីកងទ័ពនៃរដ្ឋទាំងបួនសង្គ្រោះពីនាឯកដើមសង្គ្រោះបាន ។ ក្រោយមកពេលដែលរឿងខ្លី គេមិនបានតត់ត្រាជាអក្សរខ្មែរមកតាំងពីដើមទេ គ្រាន់តែជារឿងនិយាយដំណាលតៗគ្នាមក ។ ដល់សម័យតមកគ្រាយទៀត ប្រជាជនជាតិចិននិយមយករឿងសាមកុកនេះទៅតែងល្ខោន ដែលយើងហៅថាល្ខោនហ៊ី ទើបនាំឲ្យរឿងសាមកុកនេះសាយភាយបេញាទៅ មានអ្នកចេះដឹងរឿងកំរនេះកាន់តែច្រើនឡើង ។ ទើបអ្នកប្រាជ្ញចិនប្រមូលចងក្រងតត់ត្រាជាអក្សរខ្មែរតមក ។ ដល់សម័យស្មុគចិនចេះឆ្លាក់ពុម្ពអក្សរហើយ គេបានបោះពុម្ពផ្សាយរឿងសាមកុកនេះជាសៀវភៅឡើង ជាដើមហេតុឲ្យរឿងសាមកុកសាយភាយខ្លួទៅកន្លែងប្រទេសចិន រហូតដល់នានាប្រទេសផង ។

បើយើងពិគ្រោះមើលសេចក្តីថ្លៃរឿងនៃសាមកុកនេះទើបយល់ថាអ្នកនិពន្ធរឿងនេះ មានបំណងបង្ហាញក្រងថ្លៃរឿងឲ្យទៅជាគន្លាសម្រាប់សិក្សាខាងផ្លូវនយោបាយស្រុកទេសផង ខាងផ្លូវកិច្ចការសឹងសង្គ្រាមផង ហើយតែងបានខ្លះហូរហែ គួរឲ្យសរសើរដល់គំនិតទំនើងសេចក្តីព្យា-

ឃាមវេស់ន្តកនិពន្ធរឿងសាមកុតនេះណាស់ ។ ហេតុនេះហើយបានជា
រឿងសាមកុតនេះបានផ្សាយចេញទៅ មិនត្រឹមតែក្នុងស្រុកចិន ហើយ
ដល់នានាប្រទេសផង ។

ចំពោះប្រទេសសៀម គេបានប្រែរឿងសាមកុតចេញពីភាសាចិន
ជាលើកដំបូង កាលពី ព. ស. ២៣៤៩ កន្លងមកយូរដែលមិនទាន់មាន
ពេទ្យសម្រាប់បានព្យាបាលសៀរភៅនៅឡើយ ។ ដល់សម័យពេទ្យ
សម្រាប់បានព្យាបាលសៀរភៅផ្សេងៗបានហើយ គេក៏បានចាត់ការបោះពុម្ព
រឿងសាមកុតនេះផ្សាយជាច្រើនលើកដែរ ។ រឿងសាមកុតដែលគេ
បានចាត់ការបោះពុម្ពលើកគ្រាយមុនសំណុំ ព. ស. ២៤៧០ ប្រហែល
ជាពុម្ពបំបានបោះពុម្ពលើកគ្រាដំនេះហើយ ដែលអ្នកឧកញ៉ាវិបុលកវិសេខា
(កន) តំណាងឯកស្តេ បានប្រែចេញជាភាសាកោសាបចំសព្វគ្រប់ តែ
គ្មានឧកាសនឹងបោះពុម្ពផ្សាយរឿងនេះ តមកជាច្រើនឆ្នាំ ។ គ្រាយ
មកក្រោយនេះបានយកសំណៅប្រែរឿងសាមកុតមកប្រគល់ឲ្យពុទ្ធសាសន-
បណ្ឌិត្យ ដើម្បីឲ្យចាត់ការបោះពុម្ពផ្សាយតាមត្រូវការ ។ យើងសូម
លោលជាតំណាងតាងនាមពុទ្ធសាសនបណ្ឌិត្យ សូមសំដែងអំណរអនុមោ
ទនាចំពោះអ្នកឧកញ៉ាវិបុលកវិសេខា (កន) ហើយសូមសរសើរសេចក្តី
ព្យាយាមដែលបានខំខ្នះខ្នែងយកប្រែរឿងដ៏វែងនេះគ្រាតែចប់សព្វគ្រប់ ។
ប៉ុន្តែក្នុងឧឆាសសព្វថ្ងៃនេះ ពុទ្ធសាសនបណ្ឌិត្យមិនអាចបានចាត់ការបោះពុម្ព

ផ្សាយជាសៀវភៅជាច់ដោយឡែកទៅបាន ទើបនាំយកវរឿងនេះមកបុ
ផ្សាយក្នុងទស្សនាវដ្តី តម្អូជសុរិយានេះជាបណ្តើរៗទៅសិន ។

ឯវរឿងសាមកុននេះ បើសរុបសេចក្តីឲ្យខ្លីតាមអត្ថាធិប្បាយរបស់
ក្រុមព្រះអាំរ៉ុងភាន់តាពអ្នកប្រាជ្ញប្រតិសាស្ត្រជាតិថៃ ដូចមានសេចក្តី
តទៅនេះ ។

" វរឿងសាមកុននេះ ចាប់ផ្តើមមានវរឿងកើតឡើង កន្លងផុតកាល
ព្រះបាទឡែនតេ កាលពី ព. ស. ๗๑๑ (គ្រង់ គ. ស. ๑๕๘) ដែល
ជាឋានហេតុបណ្តាលឲ្យឆ្ងល់ណាចក្រចិនចែកខ្លួនចេញទៅជា ๓ ភាគ
ដែលចិនហៅថា "សាមកុន" ។ ព្រះមហាក្សត្រព្រះអង្គនេះ ឥតសមត្ថ-
ភាព ទ្រង់ដឿស្តាប់ពាក្យខ្លួលញុះញង់របស់ពួក១ន្ធ (ពួកមន្ត្រីប្រុស
ការម្នាក់ក្នុងព្រះរាជសំណាក់) ពួកមន្ត្រីភូមិន្ទក្នុងក្រុង កំគ្មានអ្នកណា
មួយខ្វាំងតួតែ ល្មមជាទីនោរគោតក្រែងបេះដូនខ្លួនទៅ រាជការផែន
ដីក៏ស្ទើរឃ្លើងឃ្លាតជាកផ្លូវសុបរិពយុត្តិធម៌ ពួកចោរកំណាចក៏ឡើង
បានខ្លួនជាយដល់ទ្រង់ចំរើតទៅ ។ ក្សត្រព្រះអង្គនេះ ទ្រង់មានព្រះ
រាជបុត្រ ๒ ព្រះអង្គ ព្រះអង្គច្បងព្រះនាមមាន់ផ្លូវទ្រង់ខ្លួលត្រង់ពាក្យ
ជាតំណព្រះរាជវង្ស តែព្រះនាងហួហៅ ជាព្រះវរជនទីស្តីរាជការផែន
ដីជំនួស ព្រោះព្រះរាជបុត្រនៅកុមារណាស់ ។ ព្រះរាជបុត្រ អនុជ
ព្រះនាម ហាន់ផ្លូហៀប តំណព្រះវរជនី នាងតាំងវៃហា ជាអយ្យិកា

ចិញ្ចឹមតាំងពីនៅជាទារក ហើយទំនុកបម្រុងដល់ឲ្យបានភាពសម្បត្តិ
ទើបនាងតាំងពីរៅជាអនុទេវីគ្នា ។ គ្រោះព្រមបានឡើងគេទុកឯង្គរៅ
នោះ ហូដិនជាបងប្រុសនាងហូហៅ បានធ្វើជាមន្ត្រីធំ ក្នុងព្រះរាជវាំង
ធ្វើការសុខបានឲ្យគេសម្លាប់នាងតាំងពីថៃហាយ ហើយនិងកូនពួកនាងទៀត
ចេញទៀត ប៉ុន្តែ ព្រះនាងហូហៅរាជវាំងការពារពួកនាងទាំង ។ តមក
ហូដិនលួចមានចុតហ្វាយសំងាត់ ជាដល់តាំងគ្នា ចៅហ្វាយស្រុកឈី-ឡុង
ឲ្យលើកទ័ពចូលទៅបង្ក្រាបពួកនាង ។ បានដំណឹង ក៏ធ្វើការលឿន
ឲ្យហូដិនចូលទៅកន់វាំង ព្រោះដៃគ្នាជាប់ហូដិនសម្លាប់ទៅ ។ ខាងពួក
ហូដិនឃុនដឹងទំនាស់ ក៏នាំគ្នាដុតព្រះរាជវាំង ហើយលើគ្នាចូល
លុតលុយកាប់សម្លាប់ពួកនាងជាបណ្តើរបណ្តើរ ។ ក្សត្រនិងភរិយានាងគេចរត់
ទៅស្នាក់នៅខ័ដវៃ ។ ឯតាំងតុកាលបានឧកាសជាប្រយោជន៍ដល់ខ្លួន
ក៏លើកទ័ពចូលក្រុង បង្ក្រាបការឈឺឈរបានហើយ ទើបដកព្រះ
មហាក្សត្រនីនាងហូហៅជាព្រះវរជនន័រចេញចាកពីរាជសម្បត្តិ លើក
ហាន់ដូហៀប ជាព្រះអនុជឡើងគ្រងរាជ្យ ទ្រង់ព្រះនាមព្រះបាទហៀន-
តេ តាំងតុក៏តាំងខ្លួនឯងជា "សៀងតុក" (តំណែងអគ្គមហាសេនាប-
តី) សម្រេចពីការដែរ ។ កាលតាំងតុបានឡើងជាសៀងតុកហើយ
ក៏តាំងប្រព្រឹត្តអំពើទុច្ចរិតផ្សេងៗ ពួកមន្ត្រីនៅក្រុង គ្មានអ្នកណាមួយអាច
កំចាត់តាំងតុចេញ ក៏នាំគ្នារត់ចេញទៅនៅខេត្តក្បែរៗជាច្រើន ។

ក្នុងចំណោមពួកដែលរត់ទៅនោះ មានមន្ត្រីភូកម្ពាក់ឈ្មោះបូធូ ជាន
បបួលចៅហ្វាយស្រុកជាច្រើនស្រុកលើកទ័ពទៅបង្ក្រាបតាំងតុ ប៉ុន្តែ ធ្វើ
ការមិនសម្រេច ព្រោះមិនរួមសាមគ្គីគ្នា ដោយចៅហ្វាយស្រុកអស់នោះ
គិតតែចង់ជាន ប្រយោជន៍ធំអំណាចតែសព្វ ។ ខ្លួន ម្ល៉ោះហើយទៅជា
ខាសខែងច្បាំងតែគ្នាឯង ។

តមមមិនយូរប៉ុន្មាន អង់អ៊ុនជាមន្ត្រីធំទៅលើក្រុងកំគិតធ្វើកលឧបាយ
កំចាត់តាំងតុបេញជាន សម្រេច ដោយយកស្ត្រីរូបឆោមដែតធ្វើជានុយ
ប៉ុន្តែ អង់អ៊ុនមិនអាចចាត់ការស្រុកខេសឲ្យរៀបរយទៅបាន ដែមតាំង
ក្បត្តែចង់កាជ្រកក៏ឥតសមគ្គភាព ទើបជាហេតុឲ្យបក្ខពួកចៅតាំងតុ មាន
លិឈុយគុយគ៏ជាដើម ធ្វើការសងសឹកសម្លាប់អង់អ៊ុនទៅទៀត ចៅយ
បង្គំឲ្យព្រះបាទហៀនតេ តាំងពួកខ្លួនឲ្យធ្វើជាធំក្នុងទឹកក្រុង ។ ទៅទីបំផុត
ពួកនេះគិតកំចាត់ព្រះបាទហៀនតេចេញ ទ្រង់គេចរត់ចាលទីក្រុងទៅ
ទ្រង់បានសេចក្តីលំបាកវេទនាជាអនេក ហើយមានព្រះរាជឱង្ការឲ្យហៅ
ចូរចូលមកជួយទំនុកបំរុងទ្រង់ ក្នុងឧកាសនោះ ។ ពួកចូលើកទ័ពចូលទៅ
បង្ក្រាបពួកក្បត់បានពាបពាយទៅទីក្រុង ហើយបានចូលតំណែងជាសៀង-
កុក សម្រេចរាជការដែនដី តែជណ្តាទ្រង់ក្រៅទៅតែបន្តិចបន្តួចទើបទ្រង់
តាំងព័ទ្ធលតាំងតុលិឈុយ-គុយគ៏មកនោះ ។ ឯពួកមន្ត្រីដែលរត់ចាល
ទ្រង់ទៅកាន់សម័យតាំងតុ ក៏បានត្រឡប់ចូលមកទីក្រុងវិញ ក្នុងពេល

ដែលបច្ចួបបានធ្វើជាសៀងកុតដោយស្ម័គ្រចិត្តបុះបូលទំនិចបច្ចួកមាន ដែលនៅសៀម។ ចាមើលបំណាក់មាន ដែលនៅវៀតខែងក៏នៅមាន ។

ឯបច្ចួនេះ ជាមនុស្សមានសតិបញ្ញាវាងវៃជាមេទ័ពមានសមត្ថភាពជាអ្នកគាចគ្រប់គ្រងបង្គាប់បញ្ជាខែត្រក្រៅទាំង អាចធ្វើឲ្យខ្មែរមានអំណាចមានកំឡាំងតើនចំរើនឡើងជាងកាលជាន់មុននេះ ។ ប៉ុន្តែ បច្ចួច្រើនធ្វើការតាមតែចំនើងចិត្តខ្លួន ពួកនាក់ដែលមិនមែនជាបក្ខពួកបច្ចួច្រើនស្អប់តិតកំចាត់ចេញ តែគ្មាននរណាហ៊ានកំចាត់ចេញទេ ព្រោះពួកសៀកែងស្រឡាញ់បច្ចួដោយភាគច្រើន ។ បច្ចួប្រើអំណាចមុខក្រសួងផ្លូវហួសពេក ជាហេតុឲ្យព្រះបាទហ្វូនតេខ្វែងកំព្រះទ័យយ៉ាងខ្លាំង ដល់ទៅខ្ទេងយកព្រះរហោហិតសារសេរព្រះទន្លាសម្ងាត់ហៅវត្តមកស្វាមីភក្តិឲ្យតិតកំចាត់បច្ចួចេញ ។ ដំណឹងនេះផ្សាយដល់ខែត្រក្រៅ ចណ្តាពួកទាហ៊ានស្មោះដែលមានកំឡាំង មិនមែនជាបក្ខពួកខាងបច្ចួ ក៏យល់ថាបច្ចួជាសត្រូវទំនិចផែនដី ដូចជាតាំងតុដែរ ទើបនាំគ្នាវិនិច្ឆ័យឡើង ។ ឯបច្ចួដែលប្រកាន់សក្តិខ្លួនជាសៀងកុត ក៏យល់ថាត្រូវតែបង្ក្រាបខែត្រក្រៅដែលវិនិច្ឆ័យជាសត្រូវទំនិចផែនដី ទើបជាហេតុឲ្យកើតជាបម្បាំងឡើង ដោយតាំងសង្ឃឹមថាបម្បាំងបង្ក្រាបពួកក្បត់ផែនដី ។ ផលនៃការបម្បាំងគ្នាជាយូរអង្វែងនោះ បែកខាងនិងទំព័ត

ពួនបួងឡាំងបង្ក្រាបខែត្រក្រៅបានជាចំនួនច្រើន បង្ក្រាបមិនបានតែបណ្តាខែត្រដែលនៅក្រោមឧកញ៉ាស៊ុនកួននឹងខ្លៅពីប៉ុណ្ណោះ ។

ស៊ុនកួន ជាម្ចាស់ស្រុកឧត្តាំង ជាខែត្រធំ ។ តាំងនៅទិសខាងកើត ជាអ្នកគ្រប់គ្រងស្រុកទេសបានល្អតាំងនៅក្នុងសីលធម៌ មានមនុស្សនិយមរាប់អានច្រើន ត្រាតែមានកំឡាំងអ្វីនឹងពួកឧទ្ទាំនច្រើន ។ ឯខ្លៅពីនោះ ដំបូងជាមនុស្សអនាថា តែមានត្រកូលខ្ពស់ជាប់សែស្រឡាយក្នុងរាជវង្សហ៊ន ជាអ្នកមានអធ្យាស្រ័យល្អ ហើយតាប់បួនបានមនុស្សពួកតែមានថ្វីដៃមកបួលដូចជាឧទាយ ឧទាយមានច្រើននាក់ ទើបមានកេរ្តិ៍ឈ្មោះល្បីឧទ្ទឹង តមកបានខុងមេងជាទីប្រឹក្សាខាងសឹកសង្គ្រាម បានណែនាំឲ្យបងមិត្តទឹងស៊ុនកួន ត្រួតដៃគ្នាតស៊ូនឹងពួនបួងទើបរក្សាខ្លួនបានសុខ ហើយតាប់បួនបានខែត្រសេដួនតាំងនៅទិសខាងលិចជាប់ឆ្នែកទើបតាំងឡាក់ឋានបានមាំមួន ។ ឯព្រះចក្រពត្តិហ្វូនតេ ជាព្រះមហាក្សត្រៃប្រទេសចិនតែព្រះនាមដូចបួងឧកកតា តែពង្សាវតារចិនទៅកប់ថាជាព្រះមហាក្សត្រៃប្រទេសចិនពាំនមួល ។

លុះពួនមនិច្ចតម្មៅ ពួកីជាកូនពួនបានឧទ្ទិសតំណែងសៀងកុកជាតំណតមកដល់ឧសបិតា រួចបានដកព្រះចក្រពត្តិហ្វូនតេចេញពីតាជ-សម្បត្តិ ហើយប្រកាសតាំងខ្លួនឯងឡើងជាព្រះមហាក្សត្រៃប្រទេសចិនផ្ទាស់ពាជវង្សថ្មីហៅថាពាជវង្សវ៉ុយ គាលពី ៣. ស. ៧៦៣ ។ ចំណែកខាង

ឡៅពី ក៏បានតាំងខ្លួនជាក្សត្រឡើងវិញ ចាត់តាំងកងវរឆ្ងាំងទៅ
ថ្មីទៀតនៅខែត្រវែនសេដ្ឋ ។ ទាំងស៊ុនកួន មិនចង់នៅចំណុះចូកី
ឬឡៅពី ក៏តាំងជាឯកពលខ្លើងនៅខែត្រវែនកន្លាំង ។ តាំងអំពីទាល
ណោះមក ប្រទេសចិនតាំងមួលក៏បែងចែកចេញជាសាមកុង តែបែងចេញ
ជា ៣ អាណាចក្រសឹងមានឥស្សរៈដាច់ដោយឡែកពីគ្នា ។ អាណា-
ខេត្តរបស់ព្រះបាទចូកីហៅថា វុយកុក ។ អាណាខេត្តរបស់ព្រះ
បាទឡៅពី ហៅថា ចុកកុក ។ អាណាខេត្តរបស់ព្រះបាទស៊ុនកួន
ហៅថា ង៉ឺកុង ។ តំណើរកាលតមក កាលអស់បុណ្យព្រះបាទឡៅពី-
ចូកី - ស៊ុនកួនហើយ ក្នុងត្រង់ត្រង់ប្រទេសជាតំណតមក ជាអ្នកឥត
សមត្ថភាពតាំងបីកុក ទើបស៊ីម៉ាចៀវដែលជាអ្នកសម្រេចពលកាវែនវ៉ែ
ងវុយកុក បង្ក្រាបបុកកុកបានមុន រួចតមក ស៊ីម៉ាអៀន បុត្រស៊ីម៉ាចៀវ
ផណ្តើមពលសម្បត្តិវុយកុកបានផ្ទាស់កងវរឆ្ងាំថ្មីហៅថាពលវរឆ្ងាំនិន ហើយ
បង្ក្រាបង៉ឺកុកបាន ១ កុងមៀត ។ ទើបមហាអាណាចក្រចិនត្រឡប់ចូល
រួបរួមគ្នាមួលតែមួយបានឡើងវិញ ចប់រឿងសាមកុងដោយសង្ខេបខ្លី
តែមប៉ុណ្ណោះ" ។

(សង្ខេបរឿងសម័យកងរឿងសាមកុងនេះ ដូចគេសម័យពលវរឆ្ងាំ
ហ៊ានរៀវរោះ ក្នុងរជ្ជកាលព្រះបាទឡៃនេត ២១ ឆ្នាំ ក្នុងសម័យតាំង

កុក ក្នុងរជ្ជកាលព្រះបាទហ្វ្រានគេ ៣០ ឆ្នាំ សម័យសាមកុក ៦០ ឆ្នាំ
ប្រមូលសម័យកាល ក្នុងរឿងសាមកុកនេះជារយៈ ១១១ ឆ្នាំ) ។

ទៅទីបំផុត យើងខ្ញុំមានសេចក្តីសង្ឃឹមថាអស់លោកអ្នកអានរឿង
សាមកុក ដែលជាសេចក្តីប្រែចេញមកពីភាសាវិបុលាជសេនា (កន)
តំណាងឯកស្តេ តង់មានសេចក្តីពេញចិត្តដោយច្រើនមិនខាន ដ្បិតរឿង
នេះមានសេចក្តីផ្តែរឿងជាប់ជាក់ទង់គ្នាហូរហែ គួរឲ្យចង់ស្តែចង់ដឹង ។
ឯអក្ខរាវិរុទ្ធនឹងពាក្យពេចន៍ខ្លះ យើងខ្ញុំបានពិនិត្យតែសម្រួលៗតាម
សម័យនិយម ដែលលោកអ្នកប្រែបានអនុញ្ញាតឲ្យតែបានតាមត្រូវគោរ
ជួបមានសេចក្តីបញ្ជាក់ក្នុងអារម្ភកថាចេញមកលោកស្រាប់ ។

អារម្ភកថា

រីសេចក្តីនៃព្រះពុទ្ធវចនៈនៃព្រះមហាកស្សបត្ថេរ ដែលសោយជាសម្ភត្តិកដ៏មហាប្រទេសចំនោះ អ្នកប្រាជ្ញបុរាណគេបានសង្គ្រោតសង្គ្រាត ហៅជាភាសាចិនក្នុងរឿងនេះថា «សាមកុត» មានចែចែនច្រើនក្នុងក្រុងទេពមហានគរជាភាសាសៀម។ បពិត្រកស្សបត្ថេរបានចាត់ការឲ្យផ្សឹងផ្សាត់តាមប្រភេទប្រទេស ក៏យើញជាក់ច្បាស់ថា ក្នុងសម័យសាមកុតនោះជាដំណាក់កាលពុទ្ធកាល ដែលព្រះពុទ្ធជាអម្ចាស់នៃយើងព្រះអង្គទ្រង់បរិនិព្វាន ចន្ទ្រង់រំលងទៅហើយបាន ៧៦៣ ព្រះវស្សា ទើបមហាប្រទេសចិនទុបត្ថម្ភរឿងសាមកុតនេះឡើង តែតាំងពីពុទ្ធសករាជ ៧៦៣ រហូតដល់ ៨៦៣ ព្រះវស្សា ទើបផុតផែនដីសាមកុតនោះទៅវិញ ឆាយុផែនដីសាមកុតនោះ កាប់បានពេញ ១០ ឆ្នាំដោយគណនា ។

ខ្ញុំមានសេចក្តីប្រាថ្នាចង់ឲ្យបានរឿងនេះ ផ្សាយក្នុងក្រុងតម្កាធិបតីតទៅ ទើបនៅមានចិត្តទុស្សាហ៍ប្រែមកជាភាសាខ្មែរពីដើមដល់ចប់តំរង់ជាសេចក្តី ៧៨ ខ្សែ តែមកតួមចញ្ចូលគ្នាជាសៀវភៅឲ្យតិចទៅវិញ តិ ៥ ខ្សែជាសៀវភៅ ១ ត្រូវជា ១៥ សៀវភៅ រួមចាំងសៀវភៅចុងចប្ងន់ដែលមានរួមគ្នាតែ ៣ ខ្សែ ១ សៀវភៅនោះផង ។

រីឯវែលបានស្ថាបនាជាភាសាខ្មែរកាលប្រើរឿងនេះ តិសំណេះច្រើពាក្យសំដី តាមសម័យបច្ចុប្បន្ន រៀបៗពាក្យពេចន៍ពុំសូវល្អឹត

ល្អន់ស្រួលតំរកដូចលោកបូកណាទេ ព្រោះខ្ញុំចេះភាសាខ្មែរពុំស្ទើនឹងលោកសម័យថាស់ ចំណេះសៀមក៏ពុំមានជាប់ច្បាស់មុតមាំ គ្រាន់តែជ្រុំយកលំនាំឲ្យស្តាប់ចុនប៉ុណ្ណោះ ទោះបីខ្ញុំលើសាលោះខុសពុំត្រូវក្តីក្តី ១ឯណានិមួយ ក៏សូមឲ្យលោក - អ្នកចេះដឹងទាំងឡាយ ជួយតែងតែប្រដៅឲ្យត្រឹមត្រូវឡើងផងចុះ ព្រោះរឿងនេះចំពោះជាបុណ្យសាស្ត្រអាចនឹងញ៉ាំងឲ្យធ្លៀវឆ្លាស ទ្រូវសតិបញ្ញាចេះដេរកសំដីវៃស្ទាល់យល់គំនិតចិត្តមនុស្សល្អនឹងអាក្រក់គ្រប់ប្រការ ហើយនឹងជាទីទាំងគាត្មាឲ្យប្រព្រឹត្តទាំងសត្យានុសីត្យពិតត្រង់ក្នុងវង្វៀតិ បុរសដ៏មានគំនិតមារយាទគួរសិក្សាឲ្យចេះដឹងរឿងនេះ ទុកជារត្តឹងច្រែងដាប់សម្រាប់សតិឆ្ងាជ្យឲ្យបានទើបនឹងចំរើនមានទ្រូវសិរីសុវត្តិវិឌ្ឍនាការដោត្រសេមសុខនិរទុក្ខមហាប្រសើរតទៅ ។

អ្នកឧកញ៉ាវិបុលវាដសេនា កន ភូឈួយសេនាបតី

រុំត្រែត

ភ្នំពេញ, នៅថ្ងៃ ២៧ ខែមើគ្នាំ ១៩៣៣

ត្រូវនឹងថ្ងៃ ១ កើតខែចេត្រឆ្នាំរកានៅជាចត្វាស័ក ព. ស. ២៤៧៦ ។

រឿងសាមកុក

វគ្គទី ១

ដើមឡើយផែនដីនៃមហាណាចក្រចំនួនទាំងមូល ពាក់តាំងពីមុនជាន់សាមកុកឡើងទៅនោះ ក៏ជាសុខរៀងមកយូរណាស់, ក្រោយនោះក៏កើតជាសឹកសង្គ្រាម លុះសង្គ្រាមស្ងប់ក៏ត្រឡប់ជាសុះវិញ ។ ដំណាតអំពីសម័យនោះមកមានព្រះមហាក្សត្រសោយរាជសម្បត្តិក្នុងមហាណាចក្រចំនួនខ្នង់ព្រះនាមព្រះចៅដំរីចូលអង្គ រំលងពីនោះមកមានព្រះមហាក្សត្រសោយរាជសម្បត្តិជាលំដាប់ត ។ មកទៀត ជារៀងព្រះអង្គសឹងជាសុះក្សេមក្សាន្ត គណនាបាន ៨០០ឆ្នាំ មហាណាចក្រចំនួនក្នុងជាន់នោះ មានវែត្តធំ ។ ចំនួន ៧ មណ្ឌល, ឯរាជធានីពីក្រុងដែលស្ថិតនៅ ។ ក្នុងវែត្តដ៏ធំកុកហៃ ។ ព្រះចៅដំរីចូលអង្គយកបានមណ្ឌលទាំង ៧ មកជាចំណុះនៃព្រះអង្គរួមជាអាណាចក្រ ១ ។ ព្រះមហាក្សត្រជាលំដាប់ជាន់ក្រោយនោះខ្នង់ព្រះនាមព្រះចៅដំរីអង្គ ខ្នង់ឆ្លៀសង្គ្រាមបានជ័យទំនឹងហាន់ឆ, ក្រោយនោះហាន់ឆទាំងហាន់កូបូបក្បាំងគ្នាទៀតក៏បានរាជសម្បត្តិទៅហាន់កូបូវិញ, ហើយមានព្រះរាជវង្សជាដំណាតពីស្តេចហាន់កូបូសោយរាជ្យជាលំដាប់តមកទៀត ពាក់បានចំនួន ១២ អង្គក្សត្រ ។ គ្រានោះមានមាហ្មឺនធំម្នាក់ឈ្មោះអង្គម៉ាំងវៃចង្គក្សត់ជណ្តើមយករាជសម្បត្តិបានហើយតាំងខ្លួនជាម្ចាស់ផែនដីសោយរាជ្យបាន ១៨ ឆ្នាំ ។ ក្រោយ

នោះមានព្រះពុទ្ធរស្មីស្តេចហាន់ភ្លូច. ព្រះនាមហាន់កងប្ញីសម្ងាប់កងម៉ាំង
ចេញបាន៤ហើយទៀងសោយរាជសម្បត្តិតមកទៀត ។ លំដាប់ក្សត្រ
សោយរាជ្យតពីស្តេចហាន់កងប្ញីមកមានចំនួន ១៦ អង្គក្សត្រ, ឯស្តេច
ដែលសោយរាជ្យចុងក្រោយនោះគេឆ ព្រះនាមព្រះចៅហាន់តេ, ក្នុងបុរាណរាជ្យ
នេះ ផែនដីស្រុងចិនបែកជា ៣ អាណ្ឌាសាចិនហៅថា "សាមកុក"
ព្រោះមានស្តេចជាម្ចាស់ផែនដី ៣ ព្រះអង្គក្នុងមហាណរាជក្រចិននោះ ។

ក្នុងសម័យនោះព្រះចៅកងជាធំរាជ ហាន់តេ មិនមានព្រះពុទ្ធរស្មីសោះ
បានសុំឈ្មោះខ្មែនតេជាវេជ្ជរាមកចិញ្ចឹមថា ព្រះពុទ្ធរស្មី, ព្រះចៅ
ហាន់តេទិវង្គតទៅ ខ្មែនតេបានសោយរាជ្យមានព្រះពុទ្ធរស្មី៦ ព្រះអង្គ
ព្រះរៀមនាមហាន់ជូតៀន, ព្រះអនុជនាមហាន់ជូហៀប ។ កាលក្នុង
រាជ្យព្រះចៅខ្មែនតេនោះ ស្តេចនេះមិនបានតាំងនៅក្នុងផ្លូវទេសពិធីរាជធម៌
តាមបូរាណរាជប្បវេណី តាំងមិនបានសេពគប់នឹងអ្នកមានតម្រិះជ្រាជ្ញ
សុចរិតទៀងត្រង់នឹងផែនដីទៀយ, គាប់ព្រះទ័យប្រមាទរវើរវាយ
ល្បែងពាល មណ្ឌលឲ្យវេរីកាន់យកតែតាមសំដីមនុស្សអន្ធពាល
អសត្យ ប្រព្រឹត្តទៅតាមអំពើចិត្តទុច្ចរិតលាមក ផែនដីក៏កើតកលិយុគ
វិបរិតទៅវេរីវេរា ។ ខណៈនោះខាងភ្នំកុង[1] ដែលទៅតាល់បំរើ

---

១ ជាពួកមនុស្សប្រុសអង្គ្រែ ជាពួកអ្នកពាជីការខាងក្នុងព្រះពុទ្ធរាជវាំង តាមទំនៀមស្រុក
ចិនសម័យបុរាណ ។

ផ្ទាល់ព្រះអង្គ មានអំណាចញ៉ាំងឱ្យស្តេចឱ្យលុះនៅតាមៗបាយទុច្ចរិតផ្សេងៗ
បាន ។ មានខ័ន្ធមួកស់ឈ្មោះថៅដៀកជាធំលើសខ័ន្ធដទៃ ឃើញព្រះ
ថៅឡេនតាខ្មៅធ្វេសស្មារតីយកព្រះទ័យទុកដាក់ស្រឡាញ់ខ្លួន ក៏តំរេះ
ចិត្តគិតនឹងជកពួកតាំងធ្វើអំពើលាមកផ្សេងៗ, សូមឱ្យតិច្ចរាជការបណ្តា
ដែលមាននៅក្នុងព្រះរាជអាណាចក្រមណ្ឌលតាំងប៉ុន្មាន ក៏ព្រះរាជា
បណ្តោយឱ្យសេរចនៅលើពួកខ័ន្ធតាំងអស់ ព្រោះខ័ន្ធជាអ្នកចាំរួលពិត
គិតតែតម្រូវឱ្យត្រូវតាមអធ្យាស្រ័យនៃខ្លួនដែលមានប្រយោជន៍, គ្រា
នោះ បណ្តាអស់ពួកនាហ៊ានសត្វមុខមន្ត្រីកកួចធំទ្វាជការ អាណាប្រជា
ពស្ត្រីទាសកម្មករតាំងឡាយ ក៏តើតសេចក្តីក្តៅក្រហាយខ្លួនៅតាំងព្រះ
ឆនវ ។

ខណៈនោះមានមន្ត្រីធំៗ ពាក្យនាក់ដែលជាមនុស្សស្មុចរឹតល្អទំនឹងផែនដី
ឈ្មោះតៅប៊ូ១ តាន់តួន១ ចុងឃើញស្តេចវង្វេងក្រេចស្មារតីយកព្រះទ័យ
ទុកដាក់ស្តីគ្រែស្រឡាញ់ពួកខ័ន្ធតាំងឡាយ ក៏គិតរិះរកៗបាយទំនឹងសម្លាប់
ពួកខ័ន្ធតាំងនោះចោលចេញ ។ ឯថៅដៀកខ័ន្ធនោះដឹងខ្លួនក្តាមក៏ញុះញង់
ឱ្យពួកខ័ន្ធតាំងឡាយ រកៗបាយចាប់យកតៅប៊ូនឹង តាន់តួនតាំងពីនោក់
ទៅសម្លាប់ចោល, លុះផ្ទៃសេរចក៏ជួបប្រជុំថ្វាយហើយ ថៅដៀតនឹងខ័ន្ធ
តាំងនោះក៏រឹតតែងូលខ្លាយកំរើបចិត្តឥតខ្លាចអ្វីសោះឡើយ ។

លុះអំណើះពីនោះមក ព្រះចៅឡែនតេ សោយរាជសម្បត្តិបាន ១២ឆ្នាំ ជាទុច្ចរិតក្នុងថ្ងៃ ១៩ កើត ខែផល្គុន ព្រះអង្គទ្រង់បញ្ជូនចាប់លើព្រះទីនាំងកៅអីក្នុងទីធ្លាសាធ (អ៊ុនតុនតៀន), នៅវេលាថ្ងៃត្រង់ជាក់កំបណ្តាលឲ្យឃើញអាកេវង្កាកំឡាំងព្យុះសង្ឃរាជាអស្ចារ្យណាស់ ឃើញមានតស់ ១ ធំសម្បើម សម្បុរខៀវធ្លាក់ចុះមកពីលើអាកាសនៅទីចំពោះព្រះភក្ត្រ ហើយតស់ក៏នេចលូនឡើងព័ទ្ធរុំជើងព្រះកៅអីដែលស្តេចគង់ព្រះអង្គទ្រង់ស្ងួនព្រះទ័យភ័យតក្កមាធ្លាក់ព្រះកាយពីលើព្រះកៅអី ដួលសន្ធប់ចុះលោះបាត់ព្រះស្មារតីពុំដឹងព្រះអង្គសោះ, ពួកនាហ្មឺនទាំងអស់បានឃើញគ្រប់គ្នាក៏ភ័យមិនមានស្មុះស្មៃប្រពាក់ប្រពន្ធ ខ្លះច្រឡំលួចលូតៅលើកគ្រែហ៍ទាំព្រះពជាចូលទៅឱនទំព្រះមន្ទីរខែនក្នុង, ឯតស់នោះក៏អន្តរធានបាត់ទៅវិញមួយរំពេច ។ លំជាប់នោះក៏បង្កើតជាផ្គរន្ទះអសនីបាញ់ខ្ទេចខ្ទីរញ៉ីរតេត្រឹកអស់ពាំងវែនដី ស្មើរតែភ្លុកក្រឡាប់, មេឃក៏ចុះអាប្តូងងឹតបិទសូរ្យសែង ព្រះពិរុណក៏រំលោះជាភ្លៀងធ្លាក់ផង្គ្រាលយៅដោយគ្រាប់ធំលធំ ។ ចំមករលើផ្ទះសម្បែងមហាជនរលំរលើងដួលតរលើគ្នាជាគោលាហលពេញនគរ, ចណ្តាកស្តេចដែលតែផ្តើលភ្លុកតែរាវជ្រួលច្របល់, ក្រុងដល់ថ្ងៃរសៀលទើបស្ងប់ខ្យល់ព្យុះភ្លៀង ។ រំលងពីនោះមក ៤ ឆ្នាំដល់រដូវត្រជាក់ក្នុងខែបុស្យ ស្រុកឡុកអៀនោះជាពជាទីព្រះធរណីក៏តក្រើកអំពើពញាច់ញ៉ីរឯង ទឹកទន្លេឡើងលិចអស់ភូមភាគ

ផ្ទះសម្បែងអ្នកស្រុកដែលនៅស្បែរមាត់កំពង់ រលំរលើងរលំងយ៉ងអណ្តែត
ទៅតាមទឹកចង្កត់អស់, ពេលនោះវៃប្រទេសខ្មែរមានញ៉ាំទៅជាមានឈ្មោល ។

លុះដល់ថ្ងៃ ១ កើតខែពិសាខឆ្នាំនោះកើតបុព្វនិមិត្តជាភ្លើងឆេះឡើង
មានអណ្តាតប្រហែល ២០ ជាម (៤០ ម៉ែត្រ) ចាក់ចោតត្រឡប់អណ្តាត
ទំាងផ្សែង ចូលទៅក្នុងស្ថែងព្រះខ័ន្ធាំង អ៊ុនគុកភ្លើង ។ ដល់មកខែជេស្ឋ
ក៏កើតបុព្វនិមិត្តមួយទៀត ជាពន្លឺរស្មីដ៏រោឹងធ្លាក់ចុះមកពេញព្រះពុទ្ធកំពង់,
ឯកំពង់ស្ទឹងដែលមានទំហំធំរហើយខ្ពស់ជាងគេនោះ ក៏បណ្តាលទៅជាបែក
ធ្លាយពីកំពូលចុះមកយ៉ាងអស្ចារ្យ ។ ព្រះចៅខ្សោតត្រង់ពាល់ក្នុង
ព្រះទ័យពេកណាស់ក៏ត្រាស់សួរទៅពួកនាហ្មឹនសព្វមុខទ្វីតួចធំទាំង-
ឡាយថា «និមិត្តរំបែរតែងចុះតើនឹងល្អឬឆ្គាត់ប្រកាសដូចម្តេច?» ឃើញ
ជានាហ្មឹនធំចេះដឹង ក៏តាំងសរសេរជាសំបុត្រសម្តាត់ក្រាបទូលថា
«ហេតុដែលបណ្តាលឲ្យឃើញអស្ចារ្យដូចេះ មិនមកពីអ្វីទេ គឺមកពីពួក
ខ្ញុំអញ្ជើញប្រតិត្តទុច្ចរិតកន្លងព្រះពុទ្ធប្បវេណីគ្រប់ប្រការនោះឯង ហើយ
ជាបណ្តាលឲ្យកើតនិមិត្តអស្ចារ្យប្លែកដូច្នេះ, ដើម្បីឲ្យព្រះអង្គទ្រង់ឃើញ
ហើយត្រិះរិះតាមតួរដ៏គារ" ។ ព្រះចៅខ្សោតបង់សេចក្តីហើយ ក៏
មានព្រះទ័យបរិភក្តជាខ្លាំង ទ្រង់ដកដង្ហើមធំ តែមិនបានមានព្រះបន្ទូលថា
ដូចម្តេចឡើយ ទើបស្តេចត្រាកចាកអាសនាផ្ទាល់ព្រះគូសាឆ្លងព្រះអង្គថ្មី។
ពេលនោះខ្លួចចៅដៀតខ័ន្ធ ចូលទៅក្រាបថង្គំតាល់ពាក្រាយព្រះទីនាំង

ចាន់ក្រឡុកទៅរយើញលិខិត ដែលស្តេចកំពុងតែដឹងសេចក្តីប្រាស់ជាលិខិតរបស់យើឡុងធ្វើក្រាបបង្គំទូលដូច្នោះ ក៏ឈរមកពាក្រានឱដ៏ឧកញ្ញាវិញថា "យើងត្រូវកេចបាយដូចម្តេចឲ្យបានសេចក្តីសុខនេះ ឆ្លាក់ទៅលើយើឡុងជាយ៉ាងណាហ៊ាស ដើម្បីឱដ៏ឲ្យស្តេចធ្លើចោសយើឡុងនោះចេញចាកអំពីសក្តិយសជាមន្ត្រីឲ្យបាន" ។

ឯពួកខន្ធីដែលជាមេធំ ។ នោះមាន ៩ នាក់ គឺឈ្មោះថៅជឹត ១ តៀវតុង ១, តៀវយ៉ាង ១, ហាងស៊ី ១, ភួនគុយ ១, ហៅឡាំ ១, តៀនសុីត ១, ហេហ៊ុយ ១, កាំម្លេង ១, ដើមន្ត្រីឯណាមិនបានទៅកន្លែងស្តាប់ចង្កាប់នៃពួកខ៉ន្ធីពាំងនោះ ក៏ឲ្យដកហូតជារបេញពីពជការ, អ្នកឯណាទៅកន្លែងបង្គាប់ជញ្ជាំ តំតែងតាំងលើកដំកើងឲ្យឡើងយសសក្តិដោមន្ត្រីតួចតាមចិត្ត ។ ឯថៅជឹតនឹងពួកខន្ធីទាំងនោះ ក៏តាំងឈ្មោះខ្លួនជា "សុីបសៀងសុី" ព្រះថៅឡងតេ ក៏យកព្រះទ័យទុកដាក់ជឿតាមយកតាមពាក្យសំដីនៃឈ្មោះតៀវយ៉ាងខន្ធី, សន្ធតហៅថា "ព្រះបិតាធម៌", ឯជការនឹងព្យាច់ចំលាប់សម្លាប់នៃនដ៏ឥតន្ធវៃប្រទៅ, បណ្តាអាណាប្រជាកស្តេចសកម្មករទាំងឡាយ ក៏មានសេចក្តីក្តៅក្រហាយជាចលាចលកល់តំបន់ តើតបោរកំណាចលួចប្លន់គាប់សម្លាប់គ្នាជារឹតវែនតែកណាស់ ។

ចំពោះខាងស្រុកតង្គីងកុនខ្មោះមានបុរសចិនជួន ៣ នាក់ ឈ្មោះតៀវកុក ១, តៀវប៉ូ ១, តៀវលៀង ១, ឯឈ្មោះតៀវកុកនោះ ជាអ្នក

ដើរវៀរនូនគេថាំលើកំពូលភ្នំ ហើយបានជួបប្រទះនឹងតាចាស់ម្នាក់មុខមាត់គណិសម្បុរដូចជាពាក វែកលឿង ដៃកាន់ឈើច្រត់ តាចាស់នោះ ក៏នាំគ្នាវៀរកុកចូលទៅកន្លែងគុហាលើភ្នំ ហើយឲ្យក្មួនតម្រា ៣ ចប្រាប់ឈ្មោះ "ថៃវែងយ៉ាស៊ុត" ហើយប្រាប់ថា "ចូរអ្នកយកតម្រានេះទៅជួយខំនុតបំរុងមនុស្សពាំងឲ្យបានសេចក្តីសុខសប្បាយចុះ តែម៉ាងនេះអ្នកមានចិត្តមិនខ្វែងគ្រងំគិតប្រទុស្តជយទំងពជាវាវែនដីវេលាណាក៏យកន្លែងនឹងបង្កើតមានដល់ខ្លួនអ្នកវេលានោះ" គ្រៀវកុកក៏លុតជង្គង់គ្រាបសំពះហើយដាបសួរថា "ខ្លួនលោកនេះជាអ្វី?" តាចាស់នោះឆ្លើយប្រាប់ថា "យើងជាខ្មែរគា" ថាហើយក៏អន្តរធានបាត់ទៅ ។

ឯគ្រៀវកុក លុះបានតម្រានេះហើយ ក៏ម្ចាស់លែតឲ្យចាកមកកាន់ទីលំនៅខ្លួនវិញ ទំរៀនទៅខ្លួញតាមតម្រានោះពាំនឹងថ្ងៃពាំនយប់ដកបាល់តែចេះចាំមាត់ស្ទាត់ គាបសូត្រហៅឲ្យលំហៅក្រៀងបានត្រង់ប្រសើរតាំងខ្លួនជា "គូយិន" ប្រែជាភាសាខ្មែរថា អ្នកចេះដឹងយ៉ាងវិសេស" ។

តានោះ នៅស្រុកតន្លឹកគុន ពួកអ្នកស្រុកកើតជម្ងឺជាច្រើន, គ្រៀវកុកបានដឹងហើយចំសរសេរជាលេខយន្តមន្តតាថាតាមតម្រាយកទៅដែកឲ្យពួកអ្នកស្រុក ។ នោះពាំនប្រុសពាំនស្រី ដើម្បីបំបាត់ជម្ងឺយ៉ាងសក្តិ

ស៊ីខ្ចុតធាប់ពូកែណាស់ . មនុស្សម្នាមហាជនក៏ជឿស្រឡាញ់កាប់អាន តៀវកុកចុកជាគ្រូអាចារ្យប្រៀនប្រដៅចំនួនជាងរយនាក់ ។

ចាប់តាំងពីពេលនោះមក តៀវកុកក៏ទំដើរស្វះស្វែងព្យាបាលជេគា-ពាធតាមស្រុកភូមិស្រុកជំនិតមជនបទនានា អ្នកណាបានលេខយន្តមន្ត នាថារបស់តៀវកុក យកទៅក្បាច្ចុកលើជូរះ ក៏បានជាជូរះស្រឡះគស់ ជម្ងឺដាច់ឥតមានភ័យបារម្ភអ្វីឡើយ ។ បណ្តាជនក្នុងស្រុកភូមិជំនឹង ខ្លាយមកកាប់អានមានច្រើនឡើងកាល់ៗថ្ងៃ ។ តៀវកុក លុះកើតមានលាភ-សក្ការៈ ខ្លាំងមនុស្សម្នាមហាជនចុះចូលជាសិស្សគណៈច្រើនហើយ ទើបតាំងសិស្សគណៈចាំងនោះឲ្យធ្វើជាក្លាក់ជារឃុំគ្រប់ៗ អាទ្រូវហៅលជា ១០ ដំបន់តំបន់ធំ ។ គានមនុស្សចំនួន ២ ហ៊ានថ្លៃ ៣នាក់, ឯដំបន់តូច ។ មានមនុស្សចំនួន ៦ ពាន់ ឬ ៧ ពាន់នាក់, មានមេគាន់កាប់ក្បាក្លួនស្រុកតាមលំដាប់ហើយមានទង់ជ័យសម្គាល់បេញច្បាំងគ្រប់ៗ ដំបន់ ។

តៀវកុកតាំងខ្លួនជាបុង៏ខុន (ស្តេចគ្រាញ់) ហើយក៏តែងឲ្យបាយឲ្យវន្ទីពុទ្ធទៅថា ផែនដីនឹងក័ន្តរ៏ប្រែជាបណ្តាចលហើយ ព្រោះមានអ្នកមានបុណ្យមកគ្រងផែនដីជាថ្មី ស្រុកទេសនឹងបានសុខសប្បាយ ហើយឲ្យយកគ្ការលាបពណ៌ស្បែរសៅគក្បូរ ២ ផ្ទាំ ទុកនៅមុខភ្នំងឺតូរផ្ទះថា "ឆ្នាំថូតស្រុកនឹងបានសុខសប្បាយ" ។ (មានត)

មហោស្រព ៣

ភាពស្បែកស្មោន

ការលេងមហោស្រពមួយយ៉ាងដោយប្រើរូបស្បែក ដែលឆ្លាក់ដំរូចតាមរឿង ហៅថា ភាពស្បែកស្មោន សឹងមានលក្ខណៈប្រហែលគ្នានឹងស្មោនមនុស្សធម្មតា ។

រឿងសម្រាប់លេង គេកំណត់លេងតែរឿងដែលទាក់ទាមដោយរឿងព្រះវេស្សន្តរ ព្រះនាគឃុណ្ឌ ដូចយ៉ាងរឿងពាមកេរ្តិ៍ជាដើម ដើម្បីជាកិត្តិយសដល់ព្រះជាម្ចាស់អំបូរនោះ ដូចគ្នានឹងស្មោនខោល រឿងឯទៀតក្រៅអំពីនេះមិនដែលមានចំនៀមទម្លាប់ទេ ពាំងមិនទានលេងជាច្រកតីដូចស្មោនផង មានលេងម្តងមួយកាលចំពោះតែកន្លែងវេលាដែលមានពិធីបុណ្យធំៗ ដូចយ៉ាងបុណ្យចំរើនព្រះជន្ម ខួបបុណ្យថ្វាយព្រះភ្លើងជាដើម ។ ហេតុដែលមិនមានលេងជាច្រកតី មកពីរូបស្មោនដែលសម្រាប់លេងនោះមានតែ១សម្រាប់ដូចយ៉ាងរំនៀមដែលលេងក្នុងកាលឥឡូវនេះ មានតែរូបរឿងរាមកេរ្តិ៍ប៉ុណ្ណោះ ត្រូវការលេង៣យប់ណាក៏យករូបនោះចេញលេងតាល់ដងទៅទឹងប្តូរូបឲ្យប្រែតាមកន្លែងរឿងផ្សេងៗ ពុត

លេង ក៏ចុះសោចាំយកច្រែនណាស់ ពាំនាំគ្នានទំនៀមទម្លាប់លេងដូចគោលហើយផង ហេតុនោះគេទើបលេងតែក្នុងរឿងកម្សត់ដែល ។ គ្រប់ពាក្យដែលលេង តែបើពុកជាមានលេងជាច្រកត្រគ ក៏គង់មិនមានមនុស្សមើលដូចល្មាន ព្រោះកាពសែ្បកនោះមិនសូវមានសេជាតិជាទម្លាមើលដូចល្មាន មិនមានសម្ផស្សចំត្ដសម្ផស្សគែកដូចល្មាន ឆាវដែលមានលេងម្ដង។ នោះច្រែនតែមនុស្សជាន់ពាចនឹងកូនក្មេងឈរមើល ។ ឆាវដែលមានលេងម្ដង។នោះ ដោយអ្នកម្ចាស់បុណ្យជួលជាប់ថ្លៃយកទៅលេងឲ្យក្មេវមើល ទើបមានមនុស្សមើលច្រែន។ ឲ្រសិនបើយកថ្លៃព័ន្ធមើល មើលទៅគង់ជាមិនមានអ្នកមើលប៉ុន្មាននាក់ណាស់ ។

វិធីធ្វើភាពសែ្បក

វិធីដែលនឹងធ្វើភាពសែ្បកនោះ គេយកសែ្បកគោមកគ្រាំទឹកឲ្យទន់ហើយ យកទៅហាលថ្ងៃឲ្យស្ងួត រួចយកដែកមានមុខមុតមកគោសចាំងសងខាង ឲ្យស្ដើងនឹងឲ្រាបស្មើសាច់ ទើបយកទឹកភ្លៅដែលសាយដោយជ្រូងបាតឆ្នាំង ឬ ជ្រូងជាងដូងបុតលាងនឹងទឹនហើយយកមកលាបសែ្បកនោះឲ្យសព្វចាំងសងខាង ប្រមាណមើលភ្លៅល្អហើយ យកទៅហាលថ្ងៃឲ្យស្ងួត កាលស្ងួតហើយគេទាត់ឲ្យរលើបល្អហើយ បើមិនចេះគួរប្រុងឯង គេរកជាងដែលចេះគួរប្រុងល្អ។ មកគួរជាប្រុងផ្សែងៗ តាមរឿងនោះ គួរហើយត្រូតមើលសព្វត្រប់ ឃើញថាមិនគាស់ហើយ ទើបជាប់

ឆ្នាក់ដោយដែនត្រឿងឆ្នាក់សង់មានមុខនង្គ័សណ្ឋានផ្សេង ។ មានពន្លាត
នង្គ័ដែលក្រែចកជាដើម ។ កាលឆ្នាត់ជាន់ច្រែនឆ្នាំនង្គ័ម្តងលេនជាន់ហើយ
នេះទើបដែលត់ ឬ កោសកែឲ្យមានពណ៌ផ្សេង ។ តាមដែលត្រូវការ គឺ
បើត្រូវការពណ៌ស ឲ្យកោសល្បាប់ខ្លៀដែលលាបគោះចេញឲ្យអស់ហើយ
ក៏ទៅជាពណ៌ស បើចង់ឲ្យមានពណ៌ខៀវ ឲ្យយកចុណដុះលាយនឹង
ទឹកផ្លែក្រូចឆ្មា លាបទៅក៏ជាពណ៌ខៀវ, បើចង់ឲ្យមានពណ៌ក្រហម
ឲ្យយកទឹកស្បែងនឹងសាច់ផ្លូវលាយគ្នាលាប ក៏ជាពណ៌ក្រហម, បើចង់
ឲ្យមានពណ៌លឿង ឲ្យយកទឹកស្បែងលាយនឹងទឹកក្រូចឆ្មាលាបដុះ ។
ទៅក៏ជាពណ៌លឿង ។ កាលដែលត់ពណ៌ផ្សេងស្រេចហើយ ទើប
យកឈើបួនចំរៀកមកគាបសង្កត់ខាង ផ្តើជាមេសម្រាប់កាន់ជើតទៅមក
កាល់ ។ រូបនោះទៅ ។

ភាពស្បែកដែលឆ្នាក់ជារូបហើយនោះ មានបញ្ញត្តឈ្មោះហៅ
ផ្សេង ។ គឺភាពដែលជារូបដើរ មិនថាមនុស្សយក្ខ ឬ ស្វា ហៅថា
"ភាពចរ" ទាំងអស់ ។ ភាពដែលជារូបហោះហើរ មិនថា មនុស្ស
ឆក្ខ ឬ ស្វា ហៅថា "ភាពហោះ" ទាំងអស់ ។ ភាពដែលផ្តុំពលរៀប
ពលសម្រាប់ហែស្តេច ឬកើតចេញទៅ មិនថា មនុស្ស យក្ខ ឬ ស្វា
ហៅថា "ភាពរេហ៍ពល" ទាំងអស់ (ពួតនេះសៀមហៅថា "រេន" ។

ក្រែអំពីនេះមានរូបភាពផ្សេង ។ ទៀតជាច្រើន សឹងតុំអាចរៀបរាប់ឲ្យ
សព្វគ្រប់បាន ។

ក៏តែក្នុងរូបអំបាលនោះ មានរូប ៣ ជាសំខាន់ក្នុងរឿងភាពស្បែត
គឺរូបព្រះឥសូរ ១ រូបព្រះនាងយសោធរា ១ រូបព្រះឥសី ១ រូបទាំង ៣ នេះ
ហៅថា "ភាពស្តេច" ឬ "ស្បែងស្តេច" ជាធំជាប្រធានលើរូបទាំងពួង ។
ភាពស្បែងស្តេចនេះកាលនឹងធ្វើឡើងតាងលំបាកបន្តិច គឺរូបព្រះ ២ អង្គ
នោះ គេរើសគេស្បែងតាងតែបាប់ដែលត្រូវខ្នាចព្រាយធ្វើមកធ្វើ រូបឥសី
គេយកស្បែងខ្លាធំ ឬខ្លាឃ្មុំមកធ្វើ បើបានស្បែងដូចនេះមកធ្វើ គេកាន់
ថាជារបស់ពូកែសក្តិសិទ្ធិ ។ រូបទាំង ៣ នេះ កាលនឹងធ្វើអ្នកធ្វើត្រូវ
ស្លៀកសពាក់ស ហើយត្រូវប្រញាប់គួរនឹងជាប់ធ្លាក់ឲ្យហើយក្នុងថ្ងៃនោះ
កុំឲ្យកន្ទុយកត្រៃដៀបាន ។

របស់បូជាគ្រូ

កាលនឹងធ្វើរូបទាំង ៣ នេះ គោងរៀបរៀបរាប់ជាយ៉ាងគ្រប់តាមទំនៀម គឺ
ចាយសីប៉ាក់ធាម ១ គូ ត្រយាបួសគីបាយមហូចចំណីត្រៃមត្រសំដែល
មិនលាយជាយគ្រឿងចំអាបមានត្រសាច់ជាដើម ១ សំពត់នឹងក្បាលជ្រកស្មា ១
ប្រាក់ចិទ្ធខ្មែន ៦ បាទ ។ របស់អម្បាលនេះកាលបូជាគ្រូបូជា
ហើយត្រូវបានទៅអ្នកគួរទ្វាក់ ។ លុះទ្វាក់បូជាហើយ គណាចជា ៣ ពណ្ណ
ផ្សេងគ្នា គឺរូបព្រះឥសូរលាបពណ៌លឿងខ្ចី ឬចិទមាសក៏បាន រូបព្រះ

ពណ៌លាបពណ៌ខៀវ ហើយត្រូវជាក្បាច់រចនាតាមត្រឹងសំលៀកចំពាក់ ឲ្យល្អរិចរិតជាងរូបចាំងពួង ព្រោះរូបចាំង ៣ នេះជារបស់សំខាន់សំពាប់ចាកមកលេងបើកពេលជាដំបូង ។

វិធីធ្វើឆាកឆ្នុះ

ឆាកសំពាប់ឆ្នុះភាពស្បែកនោះធ្វើដោយសំពត់សយ៉ាងស្តើង ហើយសាប់ជាកយ៉ាងមុង គឺយកសំពត់ថែបនោះមកកាត់ជាពីរផ្ទាំងដេរភ្ជាប់គ្នា ចង់ឲ្យក្បូបឬធុតបាំងធ្វើទៅតាមត្រូវការ ធ្វើជាផ្ទៃឆាកត្រង់កណ្តាលដើម្បីទំនងឲ្យឆ្នុះពន្លឺឃើញស្បែកនោះច្បាស់ ជាយជុំវិញគេធ្វើដោយសំពត់ផាខៃយ៉ាងក្រាស់ ដើម្បីទំនងបំបាំងភាពស្បែកនោះ កន្លងវេលាដែលចេញសេង ដូចយ៉ាងល្ងាចចេញអំពីឆាកល្ងាច រមាយ៉ាងតាំង ៤ នោះគេយ៉ាបដោយសំពត់ពណ៌ផ្សែង ។ ឯណាមួយក៏ចាន រួចជាក់ខ្សែជាច្រែនអន្ទេរតាមជាយនោះសំពាប់ចងត្រង់ដូចយ៉ាងឆាកឆ្នុះកុន ឆាកនោះបួនជ្រុងស្មើប្រវែងខាងហ៊ា ៧ ហត្ថក៏មាន ៨ ហត្ថក៏មាន ១១ ហត្ថក៏មានស្រេចហើយទៅត្រូវការ ។

រោងលេងភាពស្បែក

វេលាលេងភាពស្បែកនោះ គេសង់រោងមួយសំពាប់លេងគឺធ្វើជារោងសសរ ៤ ខាងធំក្បូបធ្វើតាមឆាកឆ្នុះដែលពោលហើយ មានផ្ទៃខ្ពស់ឡើងពីដីប្រមាណស្មើក្បាលមនុស្ស ដំបូលប្រក់ស្បឹកឬក្បឿងម្ខាង ដូច

យ៉ាងចង្ក្រា ហើយចិទ្ធាំងដញ្ជាំនឹងតាំង ៣ ជ្រុង ទុកតែខាងមុខឲ្យនៅ
ក់ល សំពត់ចងធាតុនៅបុងសសរតាំង ៤ ជោតទង់ប្រដាប់ឲ្យជាទីល្អ
មើលផង ។

វិធីលេងភាពស្បែក

ភាពស្បែកនេះគេលេងតែវេលាយប់ ព្រោះត្រូវការពន្លឺភ្លើងធ្លុះបែ
រោះស្រែលជិតដល់ពេលទំនឹងលេង គេក៏ដញ្ជូនភាពស្បែកធាតុនៅនឹង
ត្រឹងភ្លើងទៅរៀបជាក់កន្លែងនោះឲ្យហើយស្រែចពីវេលាថ្ងៃ ។ ដល់
វេលាត្រលប់ពួកអ្នកលេងតាំងពុំខ្លាន < គឺអ្នកជើតអ្នកបរចាអ្នកតុតនឹងពួក
ភ្លើងពិណពាទ្យក៏ទៅប្រជុំគ្នានៅពេងនោះដើម្បីលេង ។ណៈនោះម្ចាស់
បុណ្យគេយកខៀន ៣ ដើមនឹងច្រាក់ ៣ ស្មើជារបស់តំណាលឲ្យទៅឲ្យ
ម្ចាស់ភាពស្បែក។ យកខៀន ១ ដើមចែកឲ្យទៅពិណពាទ្យ ពួកពិណ
ពាទ្យទទួលយកខៀននោះមកអុជនៅសំកៅ ហើយនាំគ្នាលេងភ្លេងហោម
ពេង។ នោះតាំងភ្លើងសាធុការឡើងជាដំបូង ហើយភ្លេងច្រៃ,ឬហៅថាត្រៃ
ពេង ៣ បទ ចូលក្នុង លាស្មើ ជា ៦ ភ្លេងផងគ្នា រួចហើយដេពិណពាទ្យ
ក៏ឈប់ អ្នកបរចាទើបយកខៀនអុជបូជានៅភាពស្បែក ស្តេចតាំងពីអង្គ,
ចំណែកឯមនុស្សតាំងពួងក្នុងពួកនោះក៏ហោះឡើងសួគ៌ អ្នកជើតក៏លើក
រួចព្រះឥសូរឡើងជើត ពួកអ្នកភ្លេងក៏លេងភ្លេងជើតតទៅ លំដាប់នោះ
អ្នកបរចាអុជខៀនបូជា ហើយក៏ថយទៅឈរនៅទីរបស់ខ្លួន ហើយលើត

ដៃឃាត់ពិណពាទ្យឲ្យឈប់ អ្នកបរចាក៏លោតបទនំមស្សការព្រះជាម្ចាស់
៣ បទតាមចំនៀម ។

លោតចប់បទទី ១ ហើយពួកពិណពាទ្យក៏លេងភ្លេងដើតទៀត អ្នក
បរចាក៏លើកដៃឃាត់ភ្លេង ហើយលោតបទទី ២ តទៅ លុះចប់ហើយ
អ្នកភ្លេងក៏លេងភ្លេងដើតទៀត អ្នកបរចាក៏លើកដៃឃាត់ភ្លេង ហើយក៏
លោតបទទី ៣ តទៅ ចប់ហើយអ្នកភ្លេងក៏លេងភ្លេងដើតដូចមុន ។

លំដាប់នោះអ្នកក្បាច់ទុនក៏យកបទុន ៣ ដើមមកអុជបង្កិលជុំវិញដើង
បទុន (គឺទីសម្រាប់ដុតបទុន) ៣ ជុំហើយ យកភ្លើងបទុននោះទៅអុជ
អាជម៍បទុន ដែលតម្កល់នោះ ភ្លើងក៏ឆេះឆ្ការលឿង ពួកពិណពាទ្យ
ក៏លេងភ្លេងដើតឡើងព្រមគ្នា ចំណែកឯអ្នកបរចាក៏ចេញមកលត់ទៀន
ដែលបូជាស្បែក ហើយក៏ធ្វើពិធីនមស្សាមសេតសំមន្តអាគមតាមចំនៀម
ដែលគេរៀនសូត្រមក អ្នកដើតក៏យកកាពស្បែកមកគ្នុះម្តងទៀត ប៉ុណ្ណោះ
ឈ្មោះថាចប់ពិធីហ៊ុមភេតើកមុខព្រះហើយ ។

លុះហុមភេតើកមុខស្រេចហើយ លំដាប់នោះគេច្រៀនចាប់លេង
រឿងស្វាច្របាច់គ្នា គេបញ្ចេញរូបស្វាស ១ ស្វាញី ១ លើកដើត
ចេញមកពីខាងក្រៅ ១ ពីខាងស្តាំ ១ មកច្របាច់គ្នាតណ្តាលទី វេលា
នោះពួកភ្លេងក៏លេងភ្លេងដើត តែត្រង់ផ្លុំតែស្រែឡៃ ១ តង ទំនងនោតឈប់
បន្តន់សិន ចំណែកឯស្តាំឆ្មេតែត្រូវយកឲ្យក្មេងឡើងដែលហៅថាដើត

ណាក តែជើតបេញគ្រែ ស្វាចាំង ២ នោះច្រែចាប់គ្នា មួយស្រែចាក់ ហើយក៏លែងគ្នាបេញភៅដោយសព្វខ្លួន រួចត្រឡប់ជើតចូលមកចាប់គ្នាទៀតជាវារៈទី ២ នឹងវារៈទី ៣ ដូចវារៈទី ១ ក្មេងក៏លែងដូចគ្នានឹងវារៈទី ១ ដែរ តែនេះហៅដោយឈ្មោះវា ស្វាច្រែចាប់វារៈទី ១ ស្វាច្រែចាប់វារៈទី ២ ស្វាច្រែចាប់វារៈទី ៣ ក្នុងខណៈវារៈច្រែចាប់គ្នាទី ៣ នោះ គេក៏ជើតរូបស្វាស ចង់ស្វាទៅនឹងជើតរូបឥស៊ីបេញមន ពួកក្មេងក៏លែងក្មេងជើតហើយឈប់ សន្មតថាស្វាសឈ្មះស្វាទៅ ចាប់ចង់ស្វាទៅបាននាំយកមក លុះមកដូចនឹងឥស៊ី ក៏សុំឲ្យលែង ដល់មកត្រង់នេះ អ្នកបាចក៏បេញមកបាចតាមរឿងតែត្រូវធ្វើសំឡេងប៉ែបៗ បែបយ៉ាងអ្នកស្រែកគ្រែដែលនិយាយមិនច្បាស់ លុះបាចចប់រឿងហើយ ក៏ជើតត្រឡប់ភៅវិញ ។

តែជួនកាលគេមិនលេងរឿងស្វាច្រែចាប់គ្នានេះ គេចាប់លេងរឿងនាងមេឲល្ងា ដែលគេខុកជារឿងចាប់ចុាំងាងដើមរឿងដែលមិនលេងនោះ។ តើជើតរូបនាងមេឲល្ងា កមសូរអាជុនបេញមក ពួកក្មេងក៏លែងក្មេងជើតតាមនោះ ។

កាលលេងចប់ចរហោមពេង ទំនរចាំមើតពេងស្រែចដូច្នេះហើយ គេចាប់លេងសាច់រឿងតទៅ តាមប្រែកតីច្រែនលេងរឿងកមក្តីខាង

ដើម ត្រង់ទ្រូង - ខ្សែសង្វាន់ធំព្រះលក្ខណ៍ចង្កាំងគ្នាគ្រែរឿងនាងស្ងួនភនអា ជាដើម ។

ចំណែកឯក្ខែនដែលលេងនោះ គេលេងតាមក្ខែនស្លាធម្មតាដូចមានពោលហើយក្នុងរឿងស្លាធ ។

គ្រឿងភ្លេង

ឯគ្រឿងក្ខែនសម្រាប់លេងភាពស្បែកនេះ គេលេងតែវង់តូចតឹសក្តោ ១ ស្គរធំ ១ នគរ ១ វង់ តង ១ វង់ សាឡៃ ១ ឈឹង ១ ។ គ្រោះភាពស្បែកនេះគេទុកជាតូចជាងស្លាធ ទើបចាត់គ្រឿងក្ខែនឲ្យមានតិចតែល្មមសមគួរ ។

ឃុនសុខួរមេដ ញូង-សឿន រក្សែ

លោកហង់-តឹមសេង ពិនិត្យ

រឿងគួរពេនឌិន-អលី និង បេឡែទេឌិន-ហាស្សូន

(ត)

លុះសារសេរសំបុត្រចប់ហើយ បេឡែទេឌិន-ហាស្សូន ក៏ហុចទៅឲ្យថៅកែគុំសាអ័ន ។ បានទេខួលយកមកខ្ចុតក្នុងប្រអប់ សម្រាប់ដាក់សំបុត្រស្នាមផ្សេង ។ ហើយដំបូលាបេឡែទេឌិន-ហាស្សូន ដើរចេញអំពីទីនោះសំដៅចូលទៅកាន់ទីក្រុងយ៉ាដ្រប្បាប់ប្រញាល់ ព្រោះពេលកាន់តែជិតយប់ហើយ ។ ចំណែកខាងបេឡែទេឌិន-ហាស្សូន ដើរសំដៅទៅកន្លែងរបេឌិន-អលី ជាបិតារបស់ខ្លួន; លុះបានទៅដល់ទីនោះហើយ ទើបលុតជង្គង់សំពះខុនក្បាលពាទៅទីធ្លាដី សំដែងនូវសេចក្តីគោរពយ៉ាងស្មោះអស់ពីគោះ, មានមុខចាំងមួលទេតជោគទៅដោយទឹកត្រេក ហើយក៏តាំងយំខ្សឹកខ្សួលអួលអន់ខន្ធក់ក្រខួញគួញត្រែរអំពីសេចក្តីទុក្ខវេទនារបស់ខ្លួនថាដូច្នេះ "ខុបេឡែទេឌិនកំសត់ ! អ្នកឯងនឹងទៅជាមនុស្សយ៉ាងណាទៅ ? អ្នកឯងនឹងទៅកេតីពីនឹងព័ទាក់ក្នុងទីណាដើម្បីនឹងតាំងកោះស្តេចខុប្ចាត់ដែលឮថាបានអ្នកយ៉ាងនេះ ? ខុអនិច្ចាកម្មអើយ កើតខុក្ខសង្រែងសង្រៃអំពីមរណភាពនៃបិតាសំឡាញ់ មិន

ខាន់ចុងស្រែកស្រែន្តជួរសេរ្យីយដង ស្រាប់តែមានត្រែះថ្នាក់មកជិះ
ជាន់កវែមខ្លែក! ឧរូបអើយរូប! កម្មគ្រាស់អ្វីក៏ខុសតេទាំងម្ល៉ះ!" ។
បេះខ្លែខឹងហស្ស័ន ក្រាបពោលទៅនឹងដំហើយយំសោកយ៉ាងនេះ
អស់ឆាលជាយូរណាស់ ទើបក្រោកឡើងវិញ ហើយជាក់កក្បាលផ្ទួត
ទៅនឹងផ្លូវខ្មោចម្តុក, សេចក្តីខ្លួចសោកខ្វាក់ខ្វល់ខង្គិះតានតឹងកង់ខ្លែង
ក៏រីងរឹតតែខ្លែតតែថមឡើងខ្លែតជាងពីមុន, បេះតែជាតជង្រើមធំយំអណ្តឹត
អណ្តកហួតឆាលតែខ្លាយកំឡាំងបន្តិចម្តងៗ ទើបរំកិលជាកក្បាល
អំពីផ្លូវ ហើយច្រះខ្លួនសន្ធឹងដេកលក់ស្តូកស្តឹងលើកម្រាលវង្គកៀនផ្លូវ
នោះទៅ ។

កង់គ្រាដែលមាណពបេះខ្លែខឹងហស្ស័ន កំពុងលក់សិប់យ៉ាងនេះ
ស្រាប់តែមានចិសាចមួយដែលធ្លាប់ទៅអាស្រ័យក្នុងទីស្នាននោះកង់
ពេលថ្ងៃៗហើយចេញដើរគ្រាច់រង្គាត់កង់ពិភពលោកកង់ពេលយប់ៗតាម
ទំនៀមធម្មតា, ឆាខប្រទះឃើញមាណពកំពុងដេកលក់ក្បែរផ្លូវខ្លួនឯងខុន
អលីដូច្នោះ ក៏ចូលទៅជិតដើម្បីសង្កេតមើលឲ្យជាក់ច្បាស់; ដោយពេល
នោះ មាណពបេះខ្លែខខុនហស្ស័នដេកផ្ងារ ទើបលំអែងដំគ្រងមុខមាត់
ចាំងមួលភ្លឺស្រស់ចំព្រឹង ហាក់ដូចជាថែងចាំងដល់ចក្ខុរបស់ចិសាច ។

សាលចិសាចពិនិត្យសង្កេតមើលជាក់លាក់ហើយ ក៏លោលាន់មាត់
តែម្នាក់ឯងថា "អើហ្ន៎! មាណពនេះបើតាមសង្កេតមើលរូបកង់មុខមាត់

ដែលល្អស្រស់ច្រើនដូច្នេះ មិនមែនជាអ្នកថោកថយទេ តែជាខ្ពស់មួយ
អង្គកន្លងហានសួគ៌ ដែលព្រះចាត់មកឲ្យកើតក្នុងមនុស្សលោកនេះដោយ
ពិត" ។ លុះនិយាយដូច្នេះហើយ ទើបចិសាចនោះហោះរំលងទៅលើ
អាកាស ចាប់ខួចនឹងនាងទេពធីតាម្នាក់ ហើយក៏ដំរាបសួរគ្នាទៅវិញទៅ
មកដោយសេចក្តីគួរសម ។ រួចហើយ ចិសាចនិយាយទៅកាន់នាង
ទេពធីតាថា "សូមនាងចុះទៅជាមួយនឹងខ្ញុំ ទៅរហូតដល់ទីស្នាន
ដែលខ្ញុំភ្ជាប់ទៅអស្ចារ្យនោះ ខ្ញុំនឹងបង្ហាញរបស់មួយដ៏ត្រកាលចំឡែក
អស្ចារ្យ, បើនាងបានឃើញហើយ មុខជានឹងកោតសរសើរដូចខ្ញុំពុំខាន" ។
នាងទេពធីតាក៏យល់ព្រមតាមហើយ ទើបចុះអំពីអាកាសមកចាំងពីនាក់
កន្លែងណា:នោះភ្លាម; កាលបានមកដល់កន្លែងដីរនោះហើយ ចិសាច
ក៏ល្បួលបង្ហាញថា "នាងភ្ជាប់បានឃើញកំណេះណាមួយល្អឆើតជាង
មាណពានេះទៅទៀតដែរឬ ?" ។

នាងទេពធីតា បានសង្កេតពិនិត្យមើលបេះដូងជនហស្ស៍នោយ
ម៉ត់ចត់ហើយ ក៏ជាកមកនិយាយនឹងចិសាចវិញថា "មាណពានេះមាន
រូបល្អស្រស់មែនហើយ, ប៉ុន្តែមានរបស់មួយឆើតត្រកាលជាងនេះទៅ
ទៀតដែលខ្ញុំទើបនឹងឃើញអម្បាញ់មិញនៅឯត្រពាំងតែរំឯណោះ, បើអ្នកបង
ស្តាប់ខ្ញុំនឹងនិយាយរឿងត្រូវប់ឥឡូវនេះ" ។ ចិសាចឆ្លើយទៅវិញថា "ល្អ,
ល្អហើយ សូមនាងនិយាយចុះ" ។ នាងទេពធីតា ត្រូវប់ចិសាចឲ្យ

ច្រៀងស្តាប់ដោយយកចិត្តទុកដាក់មែនទែន ព្រោះនាងចាប់យកវឿននោះ
មកនិយាយតិចម្តាយ ហើយអធិប្បាយយកយោសចក្តីថា "ព្រះពជ-
ច្រនេសអេស៊ុប្តីមានអគ្គមហាសេនាម្នាក់ឈ្មោះ សេមសេនិន ម្ចាស់ម្នេ
ហើយលោកសេនាបតីនេះមានកូនក្រមុំអាយុច្រហែល ២០ ឆ្នាំ ។ នាង
នោះមានរូបឆោមលោមភ័ណ្ឌយ៉ាងឆើតជាស្រីគ្រប់លក្ខណ៍ ដែលមិន
ធ្លាប់ឮមុខណាមួយនិយាយម្ល៉ងសោះ ។ ព្រះពជាច្រនេសអេស៊ុប្តី មាន
ជាបងណែនជាកូនក្រមុំលោកអគ្គមហាសេនា មានរូបល្អណាស់ទីណែ
ស្មើឯណាមកប្រដូចគ្មាន ទើបទ្រង់គ្រាស់ឲ្យហៅអគ្គមហាសេនានោះ
មកហើយទ្រង់មានបន្ទូលថា "អើលោកអគ្គមហាសេនា, ខ្ញុំបានដំណឹង
ថាលោកមានកូនក្រមុំមួយមានអាយុគ្រប់ការហើយ ឥឡូវនេះខ្ញុំចង់សុំ
យកមកធ្វើជាស្រីសុំ, រឿងនេះតើលោកយល់ព្រមឲ្យខ្ញុំឬមិនព្រម? អគ្គ-
មហាសេនាឥតមានចាប់ភ្ញាក់ទាន់ដំណើរកំរនេះពីមុនសោះ ស្រាប់តែ
មកឮព្រះឧទ្ទាវដូច្នោះ ក៏ស្រឡាំងកាំងកាន់តាំងស្មារតី; ប្រសិនបើរូប
អ្នកដទៃស្តីព្រះរាជាវិញនោះ សមបើលោកអគ្គមហាសេនានឹងព្រម
ខ្ជួលដោយសេចក្តីត្រេកអរណាស់ ប៉ុន្តែមកប៉ះលើព្រះពជាដូច្នេះ
លោកមិនបានរំពឹងឃើញយ៉ាងនេះទេ ទើបក្រាបបង្គំទូលថា "បពិត្រព្រះ
គុណាជាម្ចាស់ជីវិតលើក្បាល, សូមទ្រង់ព្រះមេត្តាប្រោស; ខ្ញុំលះបង្គំពុំសម
គួរដល់ព្រះកិត្តិយស ដែលព្រះអង្គទ្រង់មានព្រះពជបំណងចំនួនស្តាន

មេត្រៃចំពោះប្អូនលួចខ្ញុំទេ, រឿងនេះ ខ្លួនលួចខ្ញុំសូមត្រាបត្រៃតាមល្អនឹងខ្លួនឯង
ព្រះចុង សូមអង្វរកុំឲ្យទ្រង់មានព្រះចិត្តាយល់ឃើញថា ខ្លួនលួចខ្ញុំជាមនុស្ស
អាក្រក់ ព្រោះតែទ្រង់ជាស់នឹងព្រះពរអព្យាស័យខ្លាំយ ។ ព្រះអង្គ
ទ្រង់បានត្រាបស្រាប់ហើយថា ខ្លួនលួចខ្ញុំមានកូនប្រុសមួយឈ្មោះ ឧប្បរេ-
ឯន-អលី ដែលបានខ្លួនលួចតំណែងយកមកសក្តិជាអគ្គមហាសេនារបស់ទ្រង់
ដូចជារូបខ្លួនលួចខ្ញុំដូច្នេះដែរ; យើងមានសេចក្តីថាស់ទៃងទ្វៃនឹងគ្នា
ដែលជាហេតុនាំឲ្យកាលឲ្យប្អូននោះត្រង់ចោលស្រុកចាត់ទៅ ហើយតាំងពី
ពេលនោះមក ខ្លួនលួចខ្ញុំមិនដែលបានដឹងដំណឹងដំនួបអ្វីសោះ, ទើបតែកន្លង
រាត្រី ៤ ថ្ងៃមុននេះ ខ្លួនលួចខ្ញុំបានឮដំណឹងថា ប្អូននោះធ្លើមរណៈកាល
ទៅហើយនៅឯត្រកូងចាស់ស្ងាំឯណោះ នៅក្នុងឋានន្តរជាអគ្គមហាសេនា
ខៃព្រះពជាក្នុងត្រកូងនោះឯង ។ ប្អូនខ្លួនលួចខ្ញុំនោះមានកូនប្រុសមួយ
ហើយយើងបានសន្យាគ្នាចាំងពីនោះតាំងពីពេលមុនថា បើមានកូន
យើងនឹងធ្វើដន្ធនឹងគ្នា, ខ្លួនលួចខ្ញុំដឿជាក់ច្បាស់ថាសូមឲ្យកូនធ្លើមរណៈកាល
ទៅយ៉ាងនេះ ក៏គង់មានបំណងចង់ឲ្យខ្លួនលួចខ្ញុំធ្លើអាពាហ៍ពិពាហ៍នោះ
កុំខាន; ព្រោះហេតុនោះ តាមបំណងរបស់ខ្លួនលួចខ្ញុំ គឺចង់បំពេញសេចក្តី
ប្តេជ្ញានោះឲ្យបានពេញលេញកុំឲ្យស្លៀងឃ្លៀងឃ្លាត, ខ្លួនលួចខ្ញុំសូមអង្វរ
ព្រះពជាហថ្ងៃយ សូមទ្រង់មេត្តាត្រាស់ប្រាប់ណើអនុញ្ញាតឲ្យខាន; នៅ

កន្លែងនេះ ក្មួយនាងឯងសព្វមុខមន្ត្រីដែលមានកូនក្រមុំដូចជាខ្លួនឯងនេះ
ក៏មានច្រើនគ្នា ហើយល្មមព្រះអង្គយកមកធ្វើជាស្រីស្នំបាន" ។

ព្រះពជាថ្ងៃទេសគេស៊ុប្ត កាលបានព្រះសណ្តាប់ពាក្យនេះហើយ
ក៏ទ្រង់ព្រះពិរោធយ៉ាងខ្លាំងចំពោះសេមសេខនិនម៉ូហាម្មទ ។

ដោយទ្រង់ខ្ញាល់ខ្លាំងនឹងលោកអគ្គមហាសេនាដែលទ្រង់ឥតរវល់ស្តាប់
ថ្លែងដូច្នេះ ទើបទ្រង់មិនអាចទប់ទល់សេចក្តីក្រោធបាន ហើយក៏មាន
ព្រះឱង្ការត្រង់ទោះបោះបោកតំហកតំហែងថា « អ្នកឯងដែលហៅគេញាប់ចិត្តជំ
មែន ថ្លែងលេងនយើងឥ អ្នកឯងហ៊ានមើលងាយថាមិនសមគួរនឹងបង
ញ្ជាតិពន្ធជាមួយនឹងអ្នកឯងឬ ? អ្នកឯងហ៊ានលើកខ្ពស់លើកដាក់បង្ហាប់ឲ្យ
យើងរកកូនក្រមុំអ្នកឯងទៀតវិញ; រឿងនេះមិនអីទេ, អ្នកឯងចាំមើលចុះ
យើងនឹងឯសឯសឹកឲ្យអ្នកឯងដឹងខ្លួនម្តង; យើងសន្យាថា កូនក្រមុំអ្នកឯង
ឥតបានប្តីដូចនៃក្រៅពីខ្ញុំកំដរយើងដែលជាមនុស្សច្រណែនដូចគេហើយ
មានរូបអាក្រក់ក្រៃណាទៀតអោះនោះឡើយ ។ កាលមានព្រះឱង្ការ
ដូច្នេះហើយ ទ្រង់បណ្តេញអគ្គមហាសេនាឲ្យចេញសេចក្តីឆាប់,
លោកអគ្គមហាសេនាក៏ថយខ្លួនដោយកាន់ចុះ ដោយមានសេចក្តីរាន់គាន
តឹងចិត្តនឹងសេចក្តីតាមសម្លុះជាខ្លាំងបំផុត ។ កន្លងថ្ងៃនោះ ស្តេចទ្រង់
គាស់ប្រើឲ្យហៅតង្វាលសេះម្នាក់របស់ព្រះអង្គឲ្យចូលមកគាល់ ដើម្បី
ទ្រង់ផ្តាំផ្តែឲ្យជាប្តីនាងកូនក្រមុំអគ្គមហាសេនា, ឯបុរសនោះតមកាំងមុខតម

ចាំនៃក្រោយ ហើយរួចកន្លះអាក្រក់ខ្លៅក្រញាសខាងក្រញុញ មុខរ៉ុញ
ច្រមុញដូចខ្លោចលង់ មើលទៅគួរឲ្យខ្លាច, លុះទ្រង់បានតាំងអាជ្ញាដាក់
តំណែងឲ្យអគ្គមហាសេនា សមសេចនិន ម៉ូហាម្មេឲយល់ព្រមរៀបចំធ្វើមង្គល
ការកូនក្រមុំខ្លួនជាមួយនឹងបុរសគមនោះរួចហើយ ទើបទ្រង់ឲ្យទៅធ្វើ
សំបុត្រលក្ខន្តិកសញ្ញាអាពាហ៍ពិពាហ៍ រួចឲ្យសាក្សីជារាប្រចនរួចប្រុះហត្ថ-
លេខាសម្រេចកន្លះចំពោះព្រះក្តីព្រះអង្គ ។ ឥឡូវនេះ អាពាហ៍
ពិពាហ៍ជាអពមង្គលនោះ គេបានរៀបចំរួចហើយ; ពេលដែលខ្ញុំកំពុង
និយាយប្រាប់អ្នកនេះ ពួកជាវៃការបស់នាហ្មើនមុខមន្ត្រី ក្នុងកាជ-
តូលប្រទេសអេស៊ីប្តូបានមកជួបជុំគ្នានៅក្បែរទ្វារបន្ទប់ទីតមួយ គាន់
ខៀនពាល់តែដៃគ្រប់ៗគ្នា រង់ចាំតែបុរសគមង្គតទឹកសំអាតខ្លួនប្រាំណែរួច
នឹងអាលនាំយកទៅឯផ្ទះប្រពន្ធ ដែលបានស្អិតស្អាងភាក់តែងខ្លួនរួចជា
ស្រេច ។ កន្លះពេលដែលខ្ញុំចេញពីក្រុងកៃរ៉ូមកអម្បាញ់មិញនេះពួកស្រី
បានមកជួបជុំគ្នាអស់ហើយ កំពុងរៀបចំនឹងនាំងាងក្រមុំនោះព្រមចាំង
គ្រឿងប្រដាប់សម្រាប់អាពាហ៍ពិពាហ៍ ទៅដាក់កន្លែងបន្ទប់មួយបំរុងនឹងចាំ
ទទួលបុរសគមជាប្តី ។ ខ្ញុំបានឃើញជាក់ណាស់ហើយ, ខ្ញុំហ៊ានសន្យាតាំង
ក្បាលនឹងអ្នកឯងថា គេមិនអាចពិតពិលរំលើលរួបនោមនាងក្រមុំនោះ
ដោយដូចសេចក្តីស្ងើចសរសើរឡើយ ។

ឥឡូវនាងខេមធីតាបញ្ចប់ពាក្យនេះហើយ, ឯសាបក៏ចាប់ទំយាយថា "ពោះម៉ែនាងនិយាយអួតសរសើរយ៉ាងនេះ ក៏ខ្ញុំនៅតែមិនទាន់ជឿស៊ប់ថា នាងនោះមានរូបឆោមល្អឆើតដាងអ្នកតំណែ្លះនេះ" ។ នាងខេមធីតាតបថា "ខ្ញុំមិនត្រូវការជជែកតវ៉ាជាមួយនឹងអ្នកតទៀតទេ, ខ្ញុំប្រាប់អ្នកឲ្យត្រង់ថាអ្នកតំណែ្លះនេះ បើយកទៅផ្ទឹមនឹងនាងក្រមុំព្រហ្មចារីនី ដែលគេចំរើនខុនឲ្យបុរសតមនោះឃើញថាសមគ្នាណាស់; ខ្ញុំគិតឃើញទុបាយមួយ ដែលមានចំនងល្អមឆើងធ្វើបាន ដើម្បីនឹងជំនាស់ផ្ចាញ់ផ្ចាលដល់អង្គកិច្ចមិថេស់ស្តេចប្រទេសអេស៊ុប្ត, ទុបាយនោះគឺឆើងយកអ្នកតំណែ្លះនេះទៅជាគំប្លងជំនួសនាគមគង្វាលសេះនោះឯង" ។ ឯសាបឆ្លើយទទួលព្រមថា "ទុបាយដែលនាងគិតនេះប្រពៃហើយ, ខ្ញុំយល់ព្រមតាមទាំងអស់, ឆើងនឹងរៀបចំភ័ន្តុសេចក្តីសងសឹងរបស់ស្តេចប្រទេសអេស៊ុប្ត ហើយឆើងលួងលោមមុតុកដែលកំពុងកើតទុក្ខឲ្យបានល្អត្រង់ឯង ព្រមទាំងធ្វើកូនក្រមុំនាក់ដែលស្មានថាមុខជានឹងធ្លាក់ខ្នុនដូនជាបថោកពាបនោះឲ្យបានសប្បាយរីករាយឡើងវិញ ។ ខ្ញុំនឹងធ្វើទុបាយនេះឲ្យសម្រេចឥឡូវនេះតុំខាន ហើយខ្ញុំសង្ឃឹមទុកជាក្តីថា នាងក៏គង់មិនបង្អែបង្អន់នឹងឆើងនេះដែរ; ខ្ញុំហ៊ានធានាក៏បានដែរថាអ្នកតំណែ្លះនេះទៅជាក់ឯត្រង់តែនឹងកែវនាងកំពុងដែលតំយ៉ាងនេះ កុំឲ្យក្រាក់ជំនឹងខ្លួនសោះ ហើយតាលបើឆើងធ្វើកំប្លងនោះសម្រេចសព្វគ្រប់ជួបជំណាងហើយ ការ:

ដែលនឹងលើកពាក្យកំខ្សោះនេះទៅដាក់កន្លែងដែលទៀតនោះ ខ្ញុំសូមប្រគល់លើនាង ។

លុះនាងទេពធីតានឹងចិសាច ពិភាក្សាជាមួយគ្នាអំពីកិច្ចដែលបំពុងនឹងធ្វើនោះប្រហែលជា ទើបចិសាចលើកត្រកងបាវទេវទិន-ហាស្សនៃថ្មមួយទៀត ។ កុំឲ្យក្មាក់ហើយក៏ហោះឡើងទៅកាន់អាកាសយ៉ាងរហ័សដែលផុតវិស័យមិនអាចនិយាយបាន, យកទៅដាក់ត្រង់ទ្វារផ្ទះមួយជាតបន្ទប់ខាងដែលបុរសតមដួតពីករួចហើយរៀបនឹងចេញមក, ខានចាំឲ្យពួកបាវព្រាវជាច្រើននាក់ រង់ចាំចុងវិហាចាមជូនដំណើរផង ។

កន្លែងណោះនោះ បេទ្រែទទិន ហាស្សនៃ ក្មាក់ឡើងស្រាប់តែស្រឡាំងកាំងកាន់តាំងស្មារតី ព្រោះឃើញខ្លួនឯងនៅតណ្តាលទីក្រុងដែលខ្លួនឥតស្គាល់សោះ, រៀបនឹងហាមាត់សួរគេថា ហេតុដូចម្តេចក៏មកនៅកន្លែងនេះដូច្នេះ, ប៉ុន្តែចិសាចទះស្មាហើយខ្សឹបប្រាប់ថាកុំមាត់ ។ នៅឲ្យស្ងៀម; តទៅទៀត, ចិសាចបានឲ្យទៀនមួយទៅបេទ្រែទទិន-ហាស្សនៃហើយក៏ប្រាប់ថា "ទៅ, ចូរអ្នកដើរបន្ទុកកន្លែងចំណោមមនុស្សដែលអ្នកឃើញស្ទ្រាបខ្លួនបំពង់នោះ ហើយចូរដើរតាមគេទៅរហូតទាល់តែដល់បន្ទប់មួយ ដែលគេកំពុងរៀបចំធ្វើមង្គលការ ចាំឲ្យអ្នកក៏ត្រូវតែចូលតាមទៅកន្លែងបន្ទប់នោះដែរ ។ ឯប្តីថ្មី អ្នកនឹងគេចស្គាល់ឲ្យបានដោយងាយណាស់ ព្រោះគេមានខ្សែពីគេចាំងអស់, ឯលុះចូលទៅអ្នកត្រូវដើរតែប

ខាងស្តាំក, ហើយត្រូវបើងថង់ប្រាក់ដែលមាននៅជាប់នឹងខ្លួន យក
ប្រាក់ដើរចែងឲ្យពួកអ្នកភ្នែង នឹងពួករបាំប្រុសស្រីទាំងអម្បាលម៉ាន ។
លុះដែលអ្នកបួលទៅដល់ក្នុងបន្ទប់នោះហើយ, អ្នកកុំភ្លេចឲ្យសោះ គឺ
ត្រូវយកប្រាក់ពីក្នុងថង់ហុចឲ្យពួកស្រី ។ ជាអ្នកបំរើផង ដែលអ្នកនឹង
ឃើញនៅកំដរដុំវិញសាមីខ្លួនប្រពន្ធ ឥលូវបើស្រីបំរើទាំងនោះចូលមក
ជិតអ្នក ។ ប៉ុន្តែកាលណាតែគ្រា ដែលអ្នកលូកដៃទៅក្នុងថង់នោះ, អ្នកត្រូវ
ក្រសាយកប្រាក់ឲ្យពេញដៃ ហើយត្រូវសំចៃកុំឲ្យអស់ ។ អ្នកត្រូវ
ធ្វើឲ្យប្រុងផង តាមពាក្យដែលខ្ញុំនិយាយប្រាប់នេះ ដោយការតាំងស្មារតី
ឲ្យរឹងមុឺងមាំត់, កុំភិតភ័យ, កុំតក់ស្លុតឲ្យសោះ រួចហើយបួរអ្នកទៅ
សម្រាកជាមួយនឹងស្រីតញ្ជាដែលនៅសម្រាកក្នុងបន្ទប់នោះឯង ។

អ្នកកំណេះបេត្រែខ្ចិន ឮឧយល់ដាក់ឮស់អំពីឧបាយដែលខ្លួន
ត្រូវធ្វើនោះហើយ ក៏បួលទៅស្បែរទ្វារបន្ទប់ទឹក; កិច្ចជាដំបូង ដែល
បេត្រែខ្ចិនត្រូវធ្វើនោះ ក៏គឺទៅដល់ភ្លាមតាំងសុំអុជទៀនបស់ខ្លួនបន្ត
អំពីចាវម្នាក់ រួចហើយដើរបន្ទំជាមួយនឹងមនុស្សឯទៀត ធ្វើខ្លួនហាក់ដូច
ជាចាវត្រាវបស់មន្ត្រីណាមួយនៅក្នុងតែវដែរ, ដើរជួនដំណើរបុរសគម
ដែលចេញពីបន្ទប់ទឹក ហើយដឹះសេះទៅគាន់ផ្ទះខាងស្រែ ។

បេត្រែខ្ចិន ហាស្ទីន ដើរបន្ទំជាមួយអ្នកភ្នែងនឹងពួករបាំប្រុសស្រី
ដែលដើរនាំមុខបុរសគម ក៏ចាន់លួចយកប្រាក់ម្ភង ។ ពេញចាំងដៃអំពី

ថវិមនវែកឲ្យពួកជាំ ជាំនោះ ។ ដោយហេតុនេះ ហាស្ស៊ីន មានចិត្តខ្ជិលយ៉ាងណាៗ ប្រាកដការសែងលែងដល់អ្នកផង រនេះណាប្រាប់គ្នានហើយមានចិត្តមុះញញឹមស្រស់ស្រាយយ៉ាងនេះ ទើបអ្នកដែលបានខ្ជិលអំណាយចាំងអម្បាលម៉ានោះ នាំគ្នាសំឡឹងមើលគ្រប់ៗគ្នា; កាលបានពិនិត្យសង្កេតមើលហើយ ឃើញថាហេតុនេះនហាស្ស៊ីនមានរូបសម្បត្តិសក្តិសមល្អឆើតជាងមនុស្សជាំពួង, ពួកជាំនោះក៏ចេះតែសំឡឹងមើលហើយមើលទៀតមិនជាក់ក្តែង ។

តមក គេបានទៅដល់ទ្វារផ្ទះលោកអគ្គមហាសេនាសេមសេនឯ ម្ចាស់ហេតុដែលពុំបានគិតស្មានថា កុយមនជល់ដាតបង្កើយក្បែរខ្លួនលោកយ៉ាងនេះសោះ ។ ពួកព្រះពជអាជ្ញា ឪយាត់ជាព្រៀវជាំងឡាយដែលកាន់ទៀនគ្រប់ដៃមិនឲ្យចូលទៅ ដើម្បីកុំឲ្យពន្លឺពួនជ្រួលច្របល់ច្រឡែនពេក ហើយប្រាប់ជាំងហេតុឯ ហាស្ស៊ីនផង, ប៉ុន្តែពួកអ្នកភ្លេងជាំងអស់ ឈប់ដៃតែតាំងថាបើមិនបើកឲ្យហេតុឯ ហាស្ស៊ីនចូលទៅជាមួយផងទេ ពួកគេក៏មិនព្រមចូលទៅដែរ, រួចហើយនិយាយតទៅទៀតថា "អ្នកកំណើនេះមិនមែនជាជាប្រៀវនៅក្នុងស្រុកនេះទេ ត្រូវពិនិត្យមើលឲ្យជាក់ច្បាស់ជាងនេះ គឺជាមនុស្សប្រទេសក្រៅទេតើ គេត្រូវការមើលរៀបបុណ្យសាសាហ៍ពិភពនៅក្នុងក្រុងយើងនេះ" ។ ដល់និយាយដូច្នោះហើយ អ្នកភ្លេងជាំងនោះ ទោះបីពួកព្រះពជអាជ្ញាកាំង

ដូចម្តេចក៏មិនត្រមស្លាប់ នាំគ្នាចាប់ចេរែខេនឌិន - ហាសន្ត បញ្ចូលមកក្នុងក្រមួនហើយឲ្យចូលទៅតាល់តែបាន រួចហូតយកខ្នែងពីដៃចេរែខេនឌិន-ហាសន្ត ហុចទៅឲ្យអ្នកឯទៀតកាន់ដំនួសវិញ ។ លុះចូលទៅដល់កន្លែងបន្ទប់ហើយ គេឲ្យបុរសតមអគ្គិយលើអាសនៈមួយ មានរបៀបរៀបចំយ៉ាងស្អាត តែរូបកូនក្រមុំលោកអគ្គមហាសេនា, ចំណែកខាងចេរែខេនឌិន-ហាសន្ត ពួកអ្នកក្មេងបានរៀបចំដាក់ឲ្យទៅខាងស្តាំបុរសតម។

គេមើលទៅឃើញនាងក្រមុំតាក់តែងខ្លួន ដោយគ្រឿងអលង្ការយ៉ាងមានផង់ផែ, ប៉ុន្តែមើលទៅមុខមាត់មិនស្រស់សោះ ឃើញស្លក់ស្លេកស្លាំង ទំនងដាមានរសជាតិក្តៅត្រជុយយ៉ាងធ្ងន់, រឿងនេះបណ្តាលមកពីអ្វីនោះ គេអាចតាមដេញបានដោយងាយណាស់ ត្រង់ខែវាជិតនាងមើលទៅឃើញប្តីគាត់ក្រក់មុខក្រញុះក្រញៀវ ក្រញេសមិនសមជាគូគួរស្នេហាសោះ ។ ពួកគរិយានៃនាម៉ឺនសព្វមុខមន្ត្រីធំ - តូចតាំងអស់ត្រមតាំងស្រែ។ កន្លែកំឯនឯស្រែ។ ក្នុងក្រឡអគ្គិយអមសឆាងតាមថ្នាក់តាមដាន់ខ្ពស់តាមដោយលំដាប់ហ្មងហែហើយ សុទ្ធតែតែងខ្លួនដោយគ្រឿងអាភរណៈយ៉ាងថ្លៃថ្នូតាំងអស់ គួរឲ្យពិភពិលមើលមើលក្រៃពេក; នាងតាំងអស់នោះកាន់ខ្នែងធំ។ ឆេះភ្លើងក្រោងក្រៃតែបន្តិចដៃ ។

(មានត)

ប្រវត្តិសាស្ត្រសង្ខេបប្រទេសចិន

ហ្គួងទិពង្គមន្ត្រី ញ៉ុក-ថៃម ប្រែរៀបរៀង

អំពីប្រវត្តិសាស្ត្រសាកលសៀម

(តទៅ)

អំពីព្រះរាជិនី រ៉ូ-ហៀរ

កាលព្រះបាទថៃ-សុង មហាក្សត្រមិនទាន់ទិវង្គតនោះ ព្រះបាទ
កៅ-សុងនៅជាមកុដពជកុមារ មានចិត្តប្រាថ្នាចង់ស្តីប្រពៃស្រស់ល្អម្នាក់
ឈ្មោះនាងរ៉ូ-ហៀរ ដែលជាកូនស្ងួនឯងរបស់ព្រះពជបិតា ។ លុះកាលព្រះ
បាទថៃ សុង មហាក្សត្រទិវង្គតនោះ តាមទំនៀមប្រពៃណី នាងស្នំគ្រប់ៗ គ្នា
គោរពសេពគប់ចូលទៅនៅក្នុងទីព្រះបរមសពរបស់ព្រះមហាក្សត្រ ឯព្រះ
នាងរ៉ូ-ហៀក៏ត្រូវគោរពសេពគប់ចូលទៅនៅក្នុងទីនោះដែរ ប៉ុន្តែកាលដែល
មកុដពជកុមារ កៅ-សុង ឡើងគ្រងរាជសម្បត្តិជាព្រះពជាធិពជក្រុងចិន
ហើយ ទ្រង់មានព្រះបន្ទូលឲ្យហៅ ព្រះនាងរ៉ូ-ហៀរចេញពីទីផ្សព្រះ
បរមសពចូលមកនៅក្នុងព្រះពជវាំងវិញ ។ គួរកត់ថាជាគ្រាដំបូងដែល
ព្រះមហាក្សត្រចិនទ្រង់ធ្វើការល្មើសទំនៀមប្រពៃណីហើយជាប្រចួលអាក្រក់ក្នុងពជវង្សថាំង ។ កាលនាងរ៉ូ-ហៀរចេញមកនៅក្នុងវាំងហើយ
នាងក៏ជាក់សក់ចូមហួតដល់សក់នាងដុះវែងល្មមប្រើការបាន គ្រាន់តែ
ចូលមកនៅក្នុងវាំងបាន ២-៣ ថ្ងៃ នាងរ៉ូ-ហៀរក៏ផ្ញើស្រីព្រះស្នំ

សំណាប់តាប់ព្រះទ័យរបស់ព្រះចុងកៅ - សុង ហើយនៅវេលានោះព្រះ
ចុងកៅ - សុងមានព្រះអគ្គមហេសីរួចទៅហើយផង ។ ការដែលនាង
វ៉ូ - ហៀបានជាស្តីព្រះស្នំសំណាប់ដូច្នេះហើយ ព្រះនាងនៅមិនទាន់
អស់ចិត្តចង់បានឡើងតាន់ទីអគ្គមហេសីរបស់ព្រះចុងកៅ - សុង ទើប
ខំគិតរិះរកឧបាយឲ្យព្រះចុងកៅ - សុង ចាស្អែញព្រះអគ្គមហេសីចេញ
ហើយខ្លួនឯងនឹងបានឡើងគង់លើបល្ល័ង្កជំទីដន្ទស ។ នៅទីបំផុតព្រះនាង
គិតបើញឧបាយតែមួយយ៉ាង ដែលជាខុសវិតកម្មយ៉ាងអាក្រក់ក្រៃលែង
គឺព្រះនាងវ៉ូ - ហៀ មានព្រះទុរសមួយនឹងព្រះចុងកៅ - សុងព្រះនាងឯង
ធ្វើឧបាយច្រឆាប់តកូនខ្ចីរបស់ខ្លួនឲ្យស្លាប់ទៅ ហើយភ្លែងក្រាបបង្គំទូល
ព្រះចុងកៅ - សុងថា ព្រះអគ្គមហេសីសម្លាប់កូនរបស់ព្រះនាង ដោយ
ខ្លាចកូនព្រះនាងដណ្តើមបដរាជសម្បត្តិ ។ ព្រះចុងកៅ - សុងក៏ជឿតាម
ដោយឥតពិចារណា ទើបឲ្យដកព្រះអគ្គមហេសីចេញពីតំណែង ហើយ
ទ្រង់ឲ្យតាំងព្រះនាងវ៉ូ - ហៀជាអគ្គមហេសីឡើង ឫហៃលដូចការទៀញ
តំណែងអគ្គមហេសី ដោយជំរិតរបស់កូនក្តីនោះ ។ អំណោះកាល
តមក ព្រះចុងកៅ - សុងទ្រង់នៅមានព្រះទ័យអាឡោះអាល័យអគ្គម-
ហេសីចាស់ ឫមួយទ្រង់ជាបរិសេចក្តីពិតអំពីរឿងសម្លាប់ពដរាជនោះ
តែមិនមានរឿងភ័ស្តុតាងឲ្យច្បាស់លាស់ តាមួយទ្រង់លះបង់ចោលទៅ
រកមហេសីចាស់យ៉ាងស្ងាត់ ។ ព្រះនាងវ៉ូ - ហៀបានដឹងរឿងដូច្នេះ

ក៏មានព្រះពុទ្ធសាសនាប៉ែបផ្សាប់ ឲ្យតាត់ដែតាត់ជើងរបស់មហាសីវិចេញ មុខ
គួរឲ្យអាណាឯអាធ័មពាន់ភេកណាស់ ដោយព្រះពាជាធ័ពជក្រែងចិនមិន
ហ៊ានមានព្រះទុង្ការថាអ្វីមួយព្រះទុស្ឋឡើយ ។ តមកព្រះនាង វ៉ូ-ហៅ
មានព្រះពុទ្ធសេនីធំព្រះបាទកៅ-សុង មួយអង្គ ទើបព្រះនាងឲ្យដក
ទុសរបស់ព្រះអគ្គមហេសីចាស់ចេញពីតំណែងមកពុទ្ធកុមារ ហើយ
ព្រះនាងឲ្យតាំងព្រះពុទ្ធសេរបស់ព្រះនាងក្នុងតំណែងនេះទៅវិញ ។ ក្រៅ
អំពីនេះ ព្រះនាងក្រាបទូលឲ្យព្រះបាទ កៅ-សុង ចែបហាជើវិតពួកមន្ត្រី
ចាស់ ។ ដែលតាំងខ្លួនជាសត្រូវនឹងព្រះនាងអស់ទៅជាចំនួនច្រើន ។

តាំងអំពីពុទ្ធសករាជ ១២០៣ មក កិច្ចការរបស់ស្រុកខេសធ្លាក់
ទៅនៅក្នុងព្រះហស្តព្រះនាងយ៉ាងជាប់ស្រេច តាមដោយពិតនោះ ព្រះ
នាង វ៉ូ-ហៅមិនមែនជាស្ត្រីល្ងង់ខ្លៅខេ ។ អ្នកជ្រាបព្រះវិន័យជាតិ
ចិន បើទុតជាស្អប់ខ្ពើមព្រះនាង វ៉ូ-ហៅនោះយ៉ាងណាក៏ដោយ ក៏នៅ
តែនិយាយអួតថា ព្រះនាងជាស្ត្រីឈ្លាសវៃប៉ុនប្រុសប៉ប់ត្រង់ត្រង់ស្រុក
ខេសបានល្អជាងព្រះពុទ្ធស្វាមីទៅទៀត ព្រោះកិច្ចការដែលសំខាន់ ។
របស់ស្រុកខេស បានប្រព្រឹត្តទៅដោយស្រួលរៀបរយទាំងអស់ អំណាច
ចិនទៅក្រៅប្រទេសក៏តង់ទ្រង់ទៅល្អដដែល ពួកឥហានចិនដែលចេញ
ទៅប្លាំងនឹងពួកមនុស្សព្រៃ ក៏នៅតែប្លាំងតស៊ូឥតបន្ធូរបន្ធយ ទាំងការ
តបតែងខាងក្នុងស្រុកក៏មិនជាទន់ខ្សោយណាស់ណាខេ ប៉ុន្តែសេចក្តី

ក្តៅគ្រហាយខ្លោចផ្សាខ្លួនទៅនៅកន្លែងជាសំណាក់ ពួកក្សត្រកន្លែងជាវង្សថាំង ត្រូវចាប់ខ្លួននាំទៅប្រហារជីវិតអស់ជាច្រើនមិនមែនតិចឡើយ ពួកតរីយោនីដ៏ប្លែកវេសក្សត្រអស់នោះ ត្រូវចាប់មកធ្វើជាទាសីវេសព្រះនាងវូ-ហៀវ ។ ឧកញ៉ាព្រះអគ្គមហាសីក្នើអំពើអាក្រក់ដ៏សាហាវដល់ម្ល៉ោះហើយក៏ដោយ ព្រះចៅទៅ-សុង៏ក៏នៅតែមិនហ៊ានស្តីបន្ទោសថាអ្វីឡើយ ប៉ុន្តែទ្រង់ក្រែមក្រំខ្លោចផ្សាក្នុងព្រះទ័យបន្តិចម្តង ។ ឥតស្រាកឬហួតដល់ក្នុងពុទ្ធសករាជ ១២២៦ ព្រះពជនុសរបស់ព្រះអគ្គវិលកើតនីនអគ្គមហេសីថាស់ ត្រូវព្រះនាងវូ-ហៀវដាក់ថ្នាំចំពុលស្លាប់ទៅ ។ ព្រះចៅទៅ-សុង៏ បានទតឃើញព្រះពជនុសត្រូវថ្នាំចំពុលស្លាប់នៅក្បែរព្រះកន្ត្រកូវឲ្យ ក៏នៅតែមិនហ៊ានមានព្រះពជនុង្វារថាអ្វីមួយព្រះនុស្ឋឡើយ ដល់ព្រះពជនុសត្រូវគេចំពុលស្លាប់ទៅមិនយូរប៉ុន្មាន ព្រះចៅទៅ-សុង៏ក៏ជាន់តែក្រែងព្រះទ័យខ្លាំនឡើង ។ ហើយទំនួតទៅកន្លែងពុទ្ធសករាជ ១២២៦ នោះឯង ហើយទ្រង់ទំនួតទៅយ៉ាងមហាក្សត្រដែលខ្លាចប្រពន្ធចំផុតក្នុងលោក ដែលមិនគួរសោកស្តាយសោះឡើយ ។

ព្រះពជាធិពជតំណាះ ទ្រង់ព្រះនាមថា ព្រះចៅចុង-សុង ជាពជនុសរបស់ព្រះចៅទៅ-សុង៏ ដែលកើតនីនព្រះនាងវូ-ហៀវ បានឡើងគ្រងរាជសម្បត្តិនៃមហាណាចក្រចិនតទៅ ។ ឯមហាក្សត្រព្រះអង្គនេះក៏

មានចំនួនដូចមុនទៀត គឺមានព្រះមហេសីដែលមានចិត្តរំលោភលើសលន់ មានឧបាយក្រឡាប់ផ្តាប់ផ្តាំរត្រឡប់ត្រឡិន ទ្រង់ព្រះនាមថា ព្រះនាង វ៉ៃ-ដ៏ ។ នេះក៏មានបំណងនឹងធ្វើតាមតម្រាប់ព្រះនាងវ៉ូ-ហៀដែរ គឺចាប់ ពាក្យចេកអំណាចការត្រួតត្រាស្រុកខេមរនុកក្នុងព្រះហស្តព្រះនាង ទើបជាហេតុកើតរឿងមិនចុះសម្រុងគ្នានឹងម្ចាយក្មេង គឺព្រះនាងវ៉ូ-ហៀ។ ឃើញថាព្រះចៅខបុង-សុងស្រឡាញ់ប្រពន្ធជាងម្ចាយ ព្រះនាងក៏ដក ព្រះចៅខបុង-សុងចេញពីភជសម្បត្តិ ហើយខ្លួនព្រះនាងឡើងជាព្រះ ភជាពជំនីវេស់ក្រុងចិនយ៉ាងដាច់ស្រេច មិនមានបុគ្គលណាហ៊ានមកកាំងភជអំណាចតទៅទៀត ។ ឯពួកក្សត្រសាលោហិតវេស់ភជវង្សថ្មាំងជារច្រើនអង្គ សឹងមានចិត្តនឹកអៀនខ្មាសនឹងអាត់អន់តោមនស្សជាំងុតដោយហេតុសាច់សាលោហិតវេស់លី-ចេមិន គោងរលំលោយដោយស្នាដៃវេស់ស្តី ដែលកាលពីដើមមកខ្លួនគាងនោះមានសម័ក្តីតែមតែជាស្តីព្រះសំមាត់ប៉ុណ្ណោះ ទើបនាំគ្នាចង្អៀតការចលាចលឡើងតែមែរជាបក-ជ័យ ហើយត្រូវកាត់ក្បាលនាំយកទៅថ្វាយ «សម្តេចព្រះពជាភជិនីនៃក្រុងចិន» ទាំងអស់ ។

សម្តេចព្រះពជាភជិនីនេះ ទ្រង់ធ្វើអកុសលកម្មដ៏សហាវបំផុតក្នុងសម័យវេស់ព្រះអង្គ គឺការកាត់ក្បាលមនុស្សក៏បានកាត់ចេញហើយជាច្រើនច្រើន ដាក់ថ្នាំពុលសម្លាប់មនុស្សក៏បានច្រើនហើយ ឆាត់ដៃជើងដ

មនុស្សក៏ភ្ញាប់ធ្វើហើយ ប្រចាប់ភក្ខនទ្ធីរបស់ខ្លួនសម្ងាប់ក៏ចាន់ធ្វើហើយ
បើដូច្នេះតើនៅមានអំពើអកុសលថែមណាទៀតខ្លះ ដែលព្រះនាងត្រូវ
ធ្វើតទៅទៀត ? - ព្រះនាងគ្មូចាំតនៃប្រទេសអេសុប្តី ភ្ញាប់មានក្តៅ
ឈ្នោះលឿនធ្វើអំពើសាហាវ មកហើយ ក៏នៅតែមិនទាន់ដល់ពាក់
កណ្តាលព្រះនាងវ៉ូ-ហៀវនេះឡើយ ។ ព្រះនាងវ៉ូ-ហៀវ នៅមាន
លក្ខណៈមួយយ៉ាងទៀតនាំឲ្យអសោចក្តៅឈ្នោះជាច្រើនណាស់ដែរ គឺ
ព្រះនាងជាស្ត្រីមានចិត្តរំលោភកាមតណ្ហាកម្រមានស្មើដៃប្រៀបផ្ទឹមបាន
តែមតែគ្មហស្ថជន្ម្ម មិនអាចផ្តាប់ព្រះទ័យព្រះនាងឲ្យបានឆ្អែតស្កប់
ស្កល់ទឹកាមគុណទេ ទើបព្រះនាងឲ្យបេះវេតភិក្ខុកំឡោះមួយរូបឲ្យ
ចេញពីកន្លែងវត្តមកចម្រើព្រះនាង គ្រានោះ មានភិក្ខុកំឡោះរូបស្រស់
មួយរូបព្រះនាងសព្វព្រះទ័យណាស់ ទ្រង់តាំងឲ្យធ្វើជាចៅអធិការកន្លែ
វត្តដែលជាចំផុតកន្លែងក្រុងលោ - យ៉ាង ហើយទ្រង់អនុញ្ញាតឲ្យលោកនេះ
ចេញចូលបានគ្រប់ពេលវេលាតាន់យប់តាន់ថ្ងៃ ។ ការប្រហារជីវិត
មនុស្សក៏កាន់តែមានច្រើនឡើងកាល់ៗថ្ងៃ ហើយការកាត់ក្បាលមនុស្ស
នោះសោកទៀត គោងធ្វើមែនៗមិនមែនធម្មតាទេ ព្រោះត្រូវ
នាំយកក្បាលមនុស្សដែលកាត់ហើយនោះ ទៅថ្វាយឲ្យទ្រង់ទតមើ
ព្រះទ្រង់ផង ។ ព្រះនាងវ៉ូ-ហៀវទ្រង់តែងព្រះអង្គជាមហាក្សត្រ
ហើយទ្រង់ប្រុងនឹងតាំងព្រះកជវង្សជាថ្មី ដោយការប្រគល់ពជសម្បត្តិ

ឲ្យពួកអ្នកឃុំរបស់ព្រះនាង ។ ការធ្វើដូច្នោះជាការជ្រុលពេក ទើប
មានពួកមន្ត្រីដែលសុចរិតស្មោះត្រង់ធឹងពាជវង្សយ៉ាង ដែលត្រូវព្រះពជា-
ន្តុកាពព្រះនាងត្រូវបណ្តាច់ចាល់តែងើបក្បាលមិនរួចនោះ ក៏នាំគ្នាខឹង
ចាស់យ៉ាងវែងបុង្គង សូម្បីពួងស្រុកចំណុះក៏នាំគ្នាឃល់ចាស់ដែរ ។ គ្រា
នោះ មានក្សត្រគួកមួយអង្គកងវែត្រដែនអានន មានកំឡាំងពាហាន
វែងបុង្គងត្រាន់បើ ក្នុងវេលានោះហៅថា មេបូម្ពុ ឃានបញ្ជ្រែកាសថា បើ
អ្នកឯណាគិតបំផ្លាញពាជវង្ស ចាំងហើយ មេបូម្ពុនឹងលើកទ័ពចូលលុក
ស្រុកមួយរំពេច ព្រះនាងវ៉ូ - ហៀយល់ថា ខ្លាំងតើតបណាបលវែកជា
ខ្លាំងទើបគិតគូរបង្កានមេត្រីនឹងមេបូម្ពុ ទើបចាត់ពាជបម្រើឲ្យចូលទៅសុំ
ឥណ្ឌឹងកូនក្រមុំរបស់មេបូម្ពុ យកមកធ្វើឲ្យកូនព្រះនាង ដែលព្រះនាង
បម្រុងនឹងប្រគល់ឲ្យត្រង់ពាជសម្បត្តិជាលំដាប់តទៅ តែមេបូម្ពុមិនល្ងង់
ដល់ទៅខ្ចួលយកនុយរបស់ព្រះនាង ទើបឆ្លើយតបទៅវិញថា ក្រៅ
អំពីសាច់សាលោហិតរបស់ ថៃ - សុង ហើយ មិនមានបុរសឯណាមានស័ក្តិ
ស្មើគ្នានឹងកូនក្រមុំរបស់ខ្ញុំនេះឡើយ ។ ឯលព្រះនាងវ៉ូ - ហៀ ឃានទទួល
ពាក្យតបជាសេចក្តីមើលងាយប្រមាទដល់ព្រះបរមតេជាន្តុកាពដូច្នោះ ក៏
ខឹងក្រៃក្រៃពាលើសលន់តណានាហើយ ទ្រង់បញ្ជ្រែកាសថា បើអ្នក
ឯណាមួយអាចឆក់ក្បាលមេបូម្ពុយកមកថ្វាយឃាន ទឹងទ្រង់ប្រទាន
ទ្រព្យសម្បត្តិឲ្យទៅជាមហាសេដ្ឋី ។ ឯមេបូម្ពុ លលឃានជ្រាបដំណឹង

ដូច្នោះហើយ ក៏លើកទ័ពចូលទៅលុកលុយដែនចិន ចាន់ចំម្ងាញដីរកតាហានចិនជាង ៩ ម៉ឺននាក់ ។

ការមេបូអ៊ូសំដែងវិទ្វេទ្យឃើញស្តេចដូច្នោះ ព្រះនាងវ៉ូ-ហៀវចាប់ដឹងខ្លួនឡើងខ្លះ ទើបព្រមឧលង្វេស្ថានមេត្រីនឹងមេបូអ៊ូជាថ្មី ហើយយកកូនបេះខ្លួនដែលដកចេញពីកដមកឡត្តិ យកខ្លួនទៅឃុំខុននោះត្បាច់ឲ្យឡើងសោយរាជ្យឡើងវិញ តែកិច្ចការរបស់ស្រុងខេសគង់នៅកន្លងណាប់ដៃព្រះនាងតាំងអស់ ឧមកសម័យនេះដន្លាយុរបស់ព្រះនាងជាន់តែដកកាតណាស់ហើយ ទើបចាប់ប្រគល់កិច្ចការសំខាន់ៗខុននៅដៃរបស់មន្ត្រីតួច្រាសច្បាណ ២ នាក់ជាសែ ធាន ដែលតាល់ចម្រើជាតព្រះចាវយុគលរបស់ព្រះនាងតាំង ២ នាក់ជានិច្ច តាំងយប់តាំងថ្ងៃ ។ នាងតាំង ២ នាក់បន្ទូនមានអំណាចធំចំផុត បើនឹងសម្លាប់ព្រះចាវបុង - សុន ហើយតាំងខ្លួនឯងឡើងត្រួតរាជ្យក្នុងពេលណា ក៏សឹងចាន់ដូចចំណង់ ។ នៅគ្រានេះ ពួកក្សត្រិយ៍កន្លងពីរជ្យថាំងនឹងទំនង់ត្រាតទៅទៀតពុំបាន ដល់មកកន្លងយប់មួយ កន្លងពុទ្ធសករាជ ១២៤៩ ពួកក្សត្រិយ៍អស់នោះ ក៏នាំគ្នាចូលរួមតំឡាំងតាហានលើនចូលទៅកន្លងព្រះរាជវាំង បង្ខាំងឲ្យព្រះចាវបុង - សុនត្បាច់ឲ្យជាក់ថាតំណាក់ព្រះនាងវ៉ូ-ហៀវនៅត្រង់ណា ព្រះចាវបុង - សុនត្រូវតែចង្អុលត្បាច់តាមត្រង់ហើយពួកក្សត្រិយ៍ទាំងនោះ ក៏នាំតាហានចូលទៅកាន់តំណាក់ព្រះនាង

វ៉ូ-ហៀវ ។ ខណៈនោះព្រះនាងតើនទៀងកត់ភ័យស្រឡាំងកាំងព្រមទាំងនាងពីរនាក់បងប្អូន ដែលនៅវត្តព្រះចុងយុគលទាំងសងខាង ពួកចាហានចូលដល់ក៏យកឆាវដៅកំដុំបន្ទឹក បង្គាប់ឲ្យចុះហត្ថលេខាលាចេញពីរាជសម្បត្តិ ឯខាងពីរនាក់បងប្អូនក៏ត្រូវពួនចាហានចាប់អូសយកទៅសម្លាប់នៅចំពោះមុខព្រះនាង តែខ្លួនព្រះនាងវ៉ូ-ហៀវនោះ គ្មានទោសណាហ៊ានធ្វើអន្តរាយអ្វីទៀយ ដោយហេតុអ្វីមិនច្បាស់ ។ តែតអំពីនោះមកបាន ២-៣ ថ្ងៃ ព្រះនាងក៏ក្សត្រយ ព្រះជន្មទៅដោយរោគ(ក្តៅក្រហាយ)ព្រះឧរា មានចំនងដូចជាព្រះពេជ្ញាមីរបស់ព្រះនាង ។

តាំងអំពីព្រះនាងវ៉ូ-ហៀវ បានធ្វើជាស្រីព្រះស្វាមីណាប់របស់ព្រះបាទកៅ-សុង ក៏ព្យាយាមប្រមូលយកអំណាចនៃមហាណាចក្រចិនមកទុកក្នុងដៃ ក៏ចាប់មានមនុស្សស្អប់ខ្ពើមនឹងប៉ងគាយាងព្យាបាន តែចំពោះក្រណាស់ឥតមានទេណា ហ៊ានធ្វើអ្វីទៀយ ទាល់តែព្រះនាងស្លាប់ទៅតាមសេចក្តីនឹងឆុងសង្ឃារបស់ព្រះនាង ពួកវាដេលស្អប់ដៅប្រទេចផ្តាសាឲ្យព្រះនាងហិនទាក់ឆ្កាក់តក្តួនគោនឹងចិចាំពេលស្លាប់របស់ព្រះនាងឥស់វេលាយូណាស់ ព្រោះព្រះនាងមានព្រះជន្មាយុដល់ ៨១ ឆ្នាំ ទុកពេលឲ្យព្រះនាងគ្រងរាជសម្បត្តិដល់ ៤៥ ឆ្នាំ ទើបព្រះនាងទិវង្គតទៅ ។

អ្នកគាន់ប្រវត្តិសាស្ត្រចំនួនបានឃើញហើយថា ស្រីមានអំណាចតឹមណា ព្រះបាទកៅ-សុងនៅរកាមអំណាចស្រីតឹមណា ដើងតង់

ឃើញថា មិនមានព្រះមហាក្សត្រែតអង្គណាខ្លាចប្រពន្ធឲ្យដៃក្រៃលែងជាងព្រះចាន់ទេវ-សុនទៅទេ ក្នុមួយមិនមានព្រះពជនីអង្គណាប្រព្រឹត្តអំពើអាក្រក់លាមកដៃក្រៃលែងជាងព្រះនាងវ៉ូ-ហៀរទេ ម៉ើតែគេឃើញត្រឹមប៉ុណ្ណោះមិនទាន់ពេញជាក្រែវទេ ព្រោះក្រែនចិន នៅមានព្រះពជាងពជរបស់មហាណាចក្រចិន ដែលខ្លាចប្រពន្ធរបស់ខ្លួនជាងព្រះចាន់ទេវ-សុន នោះនៅមានទៀត តែព្រះចាន់ចុង-សុន ដែលព្រះនាងវ៉ូ-ហៀរតែងតែកជសម្បត្តិជាតំណែរតមក ហើយព្រះពជនី ដែលគេក្រក់ជាងព្រះនាងវ៉ូ-ហៀរតែងនៅមានទៀត គឺព្រះនាងវ៉ែ-ជី អគ្គមហេសីរបស់ព្រះចាន់ចុង-សុន ដូចមានសេចក្តីសារសំខ្លីជាលំដាប់តទៅ ។

អំពីព្រះចាន់ចុង-សុនឆ្លងព្រះនាងវ៉ែ-ជី

ព្រះចាន់ចុង-សុន កាលទុកបង្គូតអំពីអណាចដ៏ធំធេងរបស់ព្រះពជមាតាហើយ ក៏គ្រប់គ្រងតម្កល់នៅក្រោមអំណាចព្រះនាងវ៉ែ-ជី ជាអគ្គមហេសីទៀត ។ នៅសម័យដែលទ្រង់គ្រងព្រះពជមាតាជនបញ្ជាតពជសម្បត្តិនៅនឹងនៅកន្លែងគ្មានទោះ ព្រះនាងវ៉ែ-ជីក៏តាមស្តេចនៅរួមទុក្ខគោងយាត់ជាមួយផង ហើយតែងប្រលោមលួងលោមព្រះទ័យព្រះចាន់ចុង-សុន ឲ្យលែងតែទន់ឃើញថាព្រះនាងវ៉ែ-ជីជាគំរោះល្អពិត ។ ហើយទ្រង់សព្វព្រះទ័យជាច្រើន ។ ប៉ុន្តែតាស្រឡាញ់ក៏ក្លាយទៅជាខ្លាច លុះព្រះពជមាតាទិវង្គតទៅហើយ ព្រះចាន់ចុង-សុន-

ក៏ច្រៀតល់អំណាចដែនដីឲ្យព្រះអគ្គមហេសី ពួកអាមាត្យមន្ត្រីនាំគ្នាក្រាបទូលឲ្យទ្រង់ឈប់ថា សារធ្វើដូច្នេះ មានតែវិនាសអន្តរាយ ពុំគប្បីពួកអាមាត្យរាជឋបណ្ឌិត ក្រាបទូលឆាន់ដល់សុភាសិតសាស្ត្រពុទ្ធ - ដីយ៉ាងណាៗក៏ដោយ ព្រះបាទបុន - សុនទ្រង់មិនយកព្រះកាណស្តាប់ឡើយ ។ សារដែលពោលថា ព្រះបាទបុន - សុនខ្ជាប់ប្រតន្ធយ៉ាងព្រះបាទកៅ - សុនទៅទៀតនោះ មិនមែនក្លែងពោលឲ្យលើសឡើយ ព្រោះអគ្គមហេសីត្រូវការអ្វី ព្រះរាជាធិរាជក៏ឆាងតែយល់ព្រមតាមចាំងអស់ ដូចជាព្រះអគ្គមហេសីត្រូវការមានប្រាសសហាយ ព្រះបាទបុន - សុន ក៏ទ្រង់យល់ព្រម ។ ព្រះនាងវ៉ៃ - ជី ទទឹមមន្ត្រីកំណេះរួចស្រេចមកដល់ផ្ទះ ឃើញមានសេចក្តីរាមរីករួសរាយជាខ្លាំង ពាល់តែកើតរឿងអពមង្គលទៀងក្នុងព្រះពេលសំណាក់ ព្រះបាទបុន - សុន ក៏មិនទ្រង់អើពើដល់ម្តងឡើយ ។ មានមន្ត្រីធំម្នាក់ចូលមកក្រាបបង្គំទូលឲ្យទ្រង់ចាត់ការលុបបំបាត់រឿងអប្រិយនោះចេញ ហៃរបាមានព្រះពាជនុដ្ឋារឲ្យគាត់ក្បាលអ្នកដែលមកក្រាបទូលនោះវិញមកទៀត ។ ឯពួកអាមាត្យមន្ត្រីដែលត្រូវប្រហារជីវិតដោយរឿងនេះ មានអ្នកខ្លះជ្រាបបានជួយទំនុកបំរុងឲ្យព្រះបាទបុន - សុនជាឈ្នួលគ្រប់ក៏មាន ។

ឯព្រះនាងវ៉ៃ - ជីតែងតែមានសប្បាយរីករាយនឹងតាមគុណ ឃើញប្តីក៏ពាសពាក់ដោយភាពរីករាយឥតស្ងាយដូចដុំក្រួស កិច្ចការស្រួលរៃមិនរលាស់ បរិណ្ណាយឲ្យតើតដល់ចុងសោយ ។ (មានត)

រឿង ស៊ុន - យ៉ាត់ - សេន
អ្នកនយោបាយឯកជាតិចិន កាលជាប់ឃុំនៅក្រុងឡុងត្រឹង
លោក វ៉ាយ - ប៊ុក ប្រែពីភាសាបារាំង

(តទៅ)

លោកនោះនិយាយទាំងខ្ញុំវិញថា » អ្នកឈ្មោះស៊ុន - វេន (Sun-Win) យើងបានទទួលរបូរលេខលោកតាមប្រៃសណីយ៍ ប្រចាំប្រទេសអាមេរិក ឲ្យដំណឹងមកខ្ញុំថា "អ្នកឯងបានឡើងកប៉ាល់ឈ្មោះម៉ាស៊ុស៊ិក (Majistie) ជាលេខមកដល់ទីក្រុងនេះហើយ មានបង្គាប់ឲ្យខ្ញុំរកចាប់ខ្លួនឲ្យបាន" ។

ខ្ញុំក៏តបទៅវិញថា "តើលោកចង់និយាយយ៉ាងណា?" —

កាលពីមុន លោកបានជូនពាក្យទៅកុងស៊ីយ៉ាមេន (Tong-Li-Yamen) នៅក្រុងប៉េកាំង ដើម្បីនឹងសុំកែប្រែបញ្ជាប់ប្រៃពណីរបស់ប្រទេសជាតិ ហើយបង្គំឲ្យបញ្ជូនពាក្យទៅសម្តេចព្រះមហាចក្រពត្តិម៉ុងគូលី ប្រៃហែលជាពាក្យនោះ មានសេចក្តីពីរោះត្រចៀកល្អ បានជាពួកភ្នំងស៊ីយ៉ាំ-មេន ត្រូវការខ្លួនអ្នក ។ ហេតុនេះអ្នកឯងនឹងត្រូវជាប់ឃុំខ្លួននៅទីនេះ ទម្រាំតែព្រះមហាចក្រពត្តិ មានព្រះរាជឧទ្ទាន្តត្រាស់បង្គាប់ឲ្យសម្រេចពីរឿងអ្នកយ៉ាងណា?

តើខ្ញុំឲ្យដំណឹងទៅម៉ាក្តកក្តុំខ្ញុំ ។ «មិនបានទេ» តែអ្នកឯងគប្បីសរសេរទៅកាន់និយ្ជានដែលអ្នកស្គាល់ ឲ្យគេយកអំពាំនាំមកឲ្យអ្នកបាន» ។

គេបានឲ្យប៉ាតង ទឹកភ្នែកនឹងក្រែងសមកខ្ញុំ។ ក៏សុំសរសេរសំបុត្រ
ទៅដល់លោកគ្រែពេទ្យ "ម៉ង់សុង" ជូនដំណឹងពីការដែលគេឃុំខ្លួនខ្ញុំទុក
កន្លែងគ្គកជូតចិន ហើយសូមឲ្យលោកជម្រាបដល់លោកចន៍ខ្ញី
ឲ្យគេយកការពិតមកឲ្យខ្ញុំផង ។ ឯលោកចាស់នេះតមកជួបចន្លិច ទើបខ្ញុំ
ស្គាល់ឈ្មោះ "សៀហេលូដេ (Sir Halliday) ។ នេះពន្យល់ខ្ញុំថា
មិនត្រូវដាក់ថាជាមនុស្សជាប់ទោសទេ ត្រូវថ្លាស់ការនេះចេញទើបខ្ញុំ
សរសេរយ៉ាងនេះថា ខ្ញុំនៅក្នុងឋានជូតចិន សុំឲ្យលោកឲ្យដំណឹងទៅ
លោកចន៍ខ្ញីផង ឲ្យលោកផ្ញើអក្សរមកឲ្យខ្ញុំ" ។ រួចលោកនេះនិយាយ
ឡើងទៀតថា ខ្លួនលោកមិនបង់ឲ្យខ្ញុំសរសេរទៅមិត្តភក្តិខ្ញុំ គ្រាន់តែឲ្យខ្ញុំ
ជាប់ភៅជនិយដ្ឋាន ដែលខ្ញុំស្នាក់អស់ប៉ុណ្ណោះ ។ ខ្ញុំក៏បាន
តបទៅវិញថា ខ្ញុំមិនបានទៅស្នាក់កន្លែងភៅជនិយដ្ឋានទេ មានតែលោក
ចន៍ខ្ញី, ទើបបានជ្រាបទីកន្លែងដែលខ្ញុំទៅ" ។

កន្លែងនោះ មិនជាប់ឆ្ងាយឡើងទួលទេ លោកដែលសួរខ្ញុំនេះ បង់
ដើរនេះយោបាយយ៉ាងល្អិតសុខុម ដើម្បីនឹងដឹងហេតុផ្សេង ។ មាន
ក្រែងសនឹងលិខិតសំបុត្រស្នាម ដើម្បីបង់ដឹងមិត្តភក្តិខ្ញុំដែលជាជាតិចិន ។
លុះខ្ញុំសរសេរចប់ហើយ ក៏ជូនលិខិតនោះទៅលោក ។ លោកបាន
មើលសំបុត្រនោះសព្វគ្រប់ហើយ ក៏ប្រគល់មកឲ្យខ្ញុំវិញថា "នេះល្អ
ហើយ" ខ្ញុំក៏ចញ្ចឹលក្នុងស្រោម រួចជូនទៅលោកនោះវិញទៀត (សៀ.

ហាលីដេ) ម៉ាកានី (SirHalliday Macartney) ដោយខ្ញុំនឹកស្មានថា សំបុត្រ
ខ្ញុំមុនជាបានទៅដល់លោកត្រឹមដំណើរមិនខាន ។

រួចលោកសៀវហាលីដេ ក៏ដើរចេញតាមទ្វារនោះទៅ បិទទ្វារចាក់
សោបន្ទប់ ខ្ញុំក៏ជាប់ឃុំនៅទីនោះ ។

នៅខាងក្រៅ មានអ្នកយាមពីរនាក់ ក្នុងពួកនេះមានជាតិឥណ្ឌាម្នាក់ផង ។
ចួនតាលមានតាហានទីបីមកចាំយាមលក្ខណៈថែមទៀតក៏ខាន ក្នុង២៤ម៉ោង
ដំបូង មានតាហានចិនយាមដើរចេញចូល ហើយនិយាយមកកាន់ខ្ញុំជា
ភាសារបស់ខ្លួន ពួកនេះវាតបានឲ្យពាក្យមានអ្វីមកខ្ញុំទេ ហើយខ្ញុំគាន់តែ
សួរឈ្មោះលោកដែលថាស់ដែលបានធាំខ្ញុំយកមកឃុំទុកនៅទីនេះ ។

ពួកនោះឆ្លើយមកកាន់ខ្ញុំវិញថា គឺលោកសៀវហាលីដេម៉ាកានី
«ម៉ាគាយេន» ដែលគេជាប់ហៅនៅទីនេះថា ព្រះចៅទម្លាស់ «ម៉ា» ។

អស់ពេលជាច្រើនម៉ោង គឺមកដែលខ្ញុំជាប់ឃុំមានតាហានយាមម្នាក់
ចូលមកកន្លែងបន្ទប់ខ្ញុំហើយ ពោលថា លោកសៀវហាលីដេម៉ាកានី បង្គាប់
ឲ្យខ្ញុំត្រូវតែហោះប៉ាគាវអ្នក ។ រួចក៏រើកគាយងកក្បូនសោ ទៅដែ
នឹងចាក់ចិតបន្ទប់ខ្ញុំព្រមទាំងប្រមូលយកត្រជាស់សំបុត្រស្នាម ដែលកត់ត្រា
ពាក្យមានដែលកេបានដោយកត្រមៅ តែគេមិនបានឃើញហោ ប៉ាងកន្លែ
អាវ ដែលមានឆន្ទៈត្រ (ត្រជាស់ទ្បាក់) ពីរបីសន្លឹកនោះឡើយ ។
គេបានសួរខ្ញុំថា លោកត្រូវការចំរើនអាហារអ្វី ? ខ្ញុំឆ្លើយថា ត្រូវការទឹក-

ដោះគោ ។ វាក៏យកទឹកដោះគោមកឲ្យខ្ញុំ ។

មានអ្នកបំរើជាតិអង់គ្លេសពីនោះមកអុជភ្លើងចោសសំអាតកម្រាលឥដ្ឋ ។ ខ្ញុំសុំឲ្យបម្រើម្នាក់ដែលបានបួលទៅកន្លែងចន្លុះខ្ញុំមុនដំបូងឲ្យយកលិខិតមួយ ដែលខ្ញុំបានសរសេរទៅជូនលោកគង់ខ្ចី ។ ដល់បម្រើម្នាក់ទៀតបួលមកវិញ ខ្ញុំក៏សួរពីដំណើរដែលខ្ញុំឲ្យផ្ញើសំបុត្រ ដូចបម្រើមុននេះដែរ ។ ដល់ក្រោយមក ទើបខ្ញុំបានដំណឹងពីសំបុត្រនោះ តែអ្នកជាំងពីរបានប្រាប់ខ្ញុំថា បានផ្ញើទៅដល់អ្នកដែលត្រូវទទួលហើយ ។ ដល់ល្ងាចថ្ងៃអាទិត្យ មានកុមារអង់គ្លេសម្នាក់បួលមកលេងខ្ញុំ ។ គាត់បានដេញដោលសួរឿងអ្វីឡើយ ខ្ញុំបានដេកជាំងសំលៀកបំពាក់ តែឥតបិទភ្នែកជិតឡើយ ។

ថ្ងៃក្រោយមកទៀត គឺថ្ងៃទី ១២ ខែកក្កដា ម្សិល មានពួកបំរើជាតិអង់គ្លេសពីនោក់ បានត្រឡប់បួលមកជុះលោងចន្លុះខ្ញុំ បានយកផ្សែង, ទឹក, ទឹងម្ហូបអាហារមកឲ្យខ្ញុំ ។ មានបម្រើម្នាក់ប្រាប់ខ្ញុំថា បានយកសំបុត្រ ដែលខ្ញុំបានប្រគល់ឲ្យវាជូនដល់ទីកន្លែង ម្នាក់ទៀតឈ្មោះកូល «Cole» តបមកខ្ញុំវិញថា លិខិតប្រហែលជាដល់ទីកន្លែងមិនខាន ។ ថ្ងៃអង្គារ ទី ១៣ ខ្ញុំបានសួរបម្រើដែលក្មេងជំទង់ (មិនមែន ឈ្មោះ Cole) ថា អ្នកឯងបានឃើញលោកគង់ខ្ចី ហើយបានប្រគល់ឲ្យមែនឬទេ ? — វាតបមកវិញថា បានឃើញពិតប្រាកដ — ដោយខ្ញុំមានត្រេកអរជាម្លេះក្នុងចិត្តជាច្រើន ទើបវាស្បថ

ន៍ដ៏ខ្ញុំថា វាបានឃើញលោកតាំងខ្លួន ខ្លួសម្បុត្រនោះហើយលោកពោលពាក្យថា « ល្អហើយ » ។ ប្លែងជាពេលនោះគ្មានត្រកាសសរសេរ ទើបខ្ញុំសរសេរនាំដួងកូនតម្លៃដោយខ្លួនឯង ហើយថ្លែងឲ្យវាយកទៅឲ្យម៉ែគ្នាកក្តីខ្ញុំទៀត ខ្ញុំបានប្រគល់ថ្លែងជាវង្វាន់ឲ្យវាតន្លះស៊ូវ៉ែរ៉ាំង (Demie-Souverain) = 10 Shilling: 12,60) ទៅវាដោយន័យសង្ឃឹមថា វាមុខជាយកចិត្តទុកដាក់កាន់តិចច្រើនរបស់ខ្ញុំ តែខ្ញុំមិនបានទុកចិត្តពិតថ្លែងជាមួយដទេ—រួចតមកទើបខ្ញុំបានដឹងថា វាយការរឿងរ៉ាវរបស់ខ្ញុំទៅដល់មាឃរហៅហ្វាយវាសព្វគ្រប់។

ថ្ងៃទី ៤ ក្រោយដែលខ្ញុំជាប់ឃុំនោះ មានឈ្មោះតាំង (Tang) ម្នាក់បានមកជួបនឹងខ្ញុំ ហើយខ្ញុំក៏ស្គាល់ជាក់ថា ឈ្មោះនេះឯងដែលបានចាប់ខ្ញុំមក ឈ្មោះនេះជាក់ស្តែងគឺយហើយពោលទៅនឹងថា: " ចាលដែលខ្ញុំបានឃើញអ្នកពីថ្ងៃមុនហើយបាននាំអ្នកមកដល់ទីនេះ ខ្ញុំគ្មានតែចំពេញកិច្ចរបស់ខ្ញុំប៉ុណ្ណោះ ឥឡូវខ្ញុំសុំចូលមកចរចាដោយមេត្រី, ប្រសិនបើអ្នកឯងខ្លួនសារភាពថា អ្នកឯងឈ្មោះ "ស៊ុន-វេន" មែន អ្នកឯងពេញជាគិតត្រូវ, ម្តេចក៏អ្នកឯងនៅតែប្រកែក ព្រោះការពិត គេបានដេញឃើញអស់ហើយ ។

ឈ្មោះនេះក៏ពោលបញ្ជោរលោយចំអកផងថា អ្នកឯងមានកិត្តិស័ព្ទល្បីល្បាញនៅប្រទេសចិន, ហេតុការណ៍របស់អ្នក ព្រះមហាបក្តពន្ធនឹងពួកមន្ត្រី "ត្សុង - លី - យ៉ាំមេន Tsong-Li-Yamen" បានជ្រាបអស់

ហើយ ម៉ើអ្នកមុខជានឹងស្ងាប់ យើងត្រូវចាកចេញពីលោកនេះទៅ
គួរទុកឈ្មោះឲ្យគេដំណុះគុណគុណតទៅ ពីព្រោះអ្នកឯងមកនៅទីនេះបាន
សេចក្តីថា អ្នកឯងត្រូវស៊ប់ ស្ងាប់ អ្នកឯងជាបង្ហុះ ?

ខ្ញុំក៏ស្រែកឡើងថា "ជួយម្តង" យើងនៅប្រទេសអង់គ្លេសទេ
តើ មិនមែនប្រទេសចិនទេ អ្នកឯងចង់យកខ្ញុំទៅធ្វើអ្វី បើអ្នកឯងចង់
និរទេសពីទីនេះ ត្រូវអ្នកឯងឲ្យដំណឹងទៅរដ្ឋាភិបាលអង់គ្លេសជាមុន
អំពីរឿងខ្ញុំជាប់ឃុំ ។ ខ្ញុំមិនជឿថា រដ្ឋាភិបាលអង់គ្លេសបោះបង់ខ្ញុំ
ចោលទេ ។

យើងមិនបាននិរទេសអ្នកឯងតាមផ្លូវច្បាប់ទេ តុលាការចាំងអម្បាល-
ម៉ានគេបានចាត់រៀបចំខុនជាស្រេច នាវាគេបាននិយាយព្រមព្រៀងគ្នា
ជាមុនស្រេច អ្នកឯងត្រូវគេបង់ស្ងាបសេកកន្ទែងចុកចាត់ នាំយកអ្នកឯង
ចេញទៅស្ងាត់ឥតកន្លែងណាទេ រួចឲ្យចុះនាវាមានចាហានយាមក្បែរ
ហូតទៅដល់ហ្គាំកុង ហើយឲ្យអ្នកឯងចុះកប៉ាល់តូចមួយនាំអ្នកទៅស្រុក
កន្លាង ដើម្បីសម្រេចតាមទោសប្រហារជីវិតបង់ ។

ខ្ញុំបានឆ្លើយតទៅថា តំនិតអស់នេះមិនមានបញ្ហាសល់ប្រាកដ
ជាឥតហេតុសោះទេ ក្នុងខណៈដែលខ្ញុំដើរឆ្ងាយទៅ ប្រហែល
ជាខ្ញុំមានក័ព្ទសំណាង បានជួបនិយាយគ្នានឹងពួកជនជាតិអង់គ្លេសមិន
មានទេ ។

ចិនតាំងឆ្លើយថា "មិនបានទេ" ។ អ្នកឯងត្រូវតែឃុំខ្លួនខ្លួនលើនាវាយ៉ាងម៉ឺងម៉ាត់ ដាច់អ្នកឯងនៅទីនេះទៅទៀត ព្រោះហេតុដូច្នេះ បានជាអ្នកឯងមិនងាយនឹងរត់រួចឡើយ ។

ខ្ញុំនិយាយតបទៅវិញថា ក្នុងសេនាទាហ៊ានដែលនៅលើនាវានោះ ដោយស្មានទៅថ្ងៃហែលជាមិនមានចិត្តសប្បុរសដូចបច្ចាមិត្តខ្ញុំទេ ហើយថ្ងៃហែលជាមានលោភខ្លះ មានចិត្តអាណិតអាសូរខ្ញុំជួយសង្គ្រោះខ្ញុំឲ្យផុតរួចពីវិនាសកម្មមិនខាន ។

ចិនតាំងឆ្លើយឡើងថា នៅលើនាវានោះសុទ្ធតែជាមិត្តភក្តិលោងសៀហេល្លីដេម៉ាតានី ។ ពួកនេះមុខជាធ្វើតាមបង្គាប់ទៅហ្វាយនាយរបស់ខ្លួន ។ ហើយចិនតាំងនិយាយតទៅទៀតថា, ត្រូវឲ្យខ្ញុំបុះកប៉ាល់មួយដែលដើរតាមផ្លូវនាវៃគរ្ភា ស្តុកក្លេន (ligne de navigation Glen) តែខ្ញុំមិនទាន់បានធ្វើដំណើរចេញទៅនៅសប្តាហ៍ក្រោយនេះទេ (ដើរឥឡូវថ្ងៃ ១៤ ខែកក្កដា) ព្រោះលោកដ្ឋមន្ត្រីមិនបានជួលនាវាតាមតំណាត់នោះ លោកចង់ដឹកនាំទំនិញទៅមុនសិន ហើយលោកគ្រាន់តែចេញថ្ងៃយានជំនិះពួកអ្នកដំណើរប៉ុណ្ណោះ ។

ដល់សប្តាហ៍ក្រោយ ដល់ដឹកទំនិញរួចហើយ ទើបអ្នកឯងត្រូវបុះកប៉ាល់ទៅ ។

ហើយខ្ញុំនិយាយឡើងថា គ្រោងការថែបនេះតិចបានធំធ្វើការឲ្យ
បានផលសម្រេច ។

ទើបចិនតាំងតបមកវិញថា បើយើងភ្ជាបហេតុទាំងនេះ យើងនឹង
សម្លាប់លោកនៅទីនេះក៏បាន ព្រោះទីនេះជាស្រុកចិន ហើយគ្មានអ្នក
ណាមួយអាចតវ៉ានឹងពួកមន្ត្រីហានអគ្គកាជទូតបានទេ ។

ដើម្បីនឹងថ្នមចិត្តខ្ញុំ ចិនតាំងបានលើកឧទាហរណ៍មកប្រៀបថា
មានបុគ្គលស្នេហាជាតិ ៗ ក្មេរ ដែលបានរត់ចេញពីប្រទេសក្មេរ បំណាង
ទឹងទៅប្រទេសជប៉ុន មានពួកញាតិក្នុងស្រុកជាមួយបានណែនាំបុគ្គល
នោះ ឲ្យទៅខាងស្រុកជាមួយ បានណែនាំបុគ្គលនោះឲ្យទៅខាងស្រុក
សាំងវៃ ហើយគេក៏បានចាប់យកទៅប្រហារជីវិតចង់ ទៅជាកូមិបេស
អង់គ្លេស រួចពួកចិនបានផ្ញើសពទៅប្រទេសក្មេរវិញ ដើម្បីឲ្យតុលាការ
សម្រេចទោស ហើយគេបានយកក្បាលនោះទៅតាប់ចិញ្ចៀ រួចគេបាន
ឲ្យភ្ជាប់ដល់អ្នកធ្វើការមុខត្រង់ដំណាប់ប្រទេសនោះ ។

ខ្ញុំឃើញបានថា ពេលនោះ ចិនតាំងមានចិត្តសង្ឃឹមថាបង់ឲ្យភ្លាត
បាលចិន ដំកើងយសសក្តិឲ្យ ដោយយកបានចាប់សម្លាប់ខ្ញុំ ។

ខ្ញុំក៏បានសួរចិនតាំងតទៅទៀតថា ម្តេចក៏អ្នកឯងមានចិត្តគាយាជ
ញ្ជាបានខ្ញុំខ្លាំងម្ល៉ះ ?

ចិនតាំងតបថា ព្រះពន្ធុភ្លាព្រះមហាចក្រពត្តិត្រាស់បង្គាប់ថា

ត្រូវចាប់អ្នកស្លាប់ប្តូរទៅឲ្យគេវិតបាន ។

កន្លងរំយោសាន ខ្ញុំបានពន្យល់ថា ហេតុរឿងក៏ដាក់ក្បែរនេះ ហើយ ដែលនាំឲ្យមានចម្ងាំងដូច្នេះ ហើយការចាប់ខ្ញុំទៅច្រហារជីវិតចង់ទៅនោះ នាំឲ្យមានរឿងក៏លំបាកតទៅខាងមុខជាអនេកច្រើនការ ។

ខ្ញុំថា: រង្វាកិបាលអង់គ្លេសអាចធ្វើទណ្ឌកម្មពួកមន្ត្រីទៅឋានអគ្គភូតចំនួនេះក៏បាន – ហើយអ្នកឯងជាតលាវដទៅកន្លែងស្រុកជាមួយនឹងខ្ញុំ ។ អាចប្រាប់ឲ្យបក្ខពួកខ្ញុំនៅវៃត្រកាន់ខ្លួន ធ្វើការសងសឹកអ្នកទទឹងញាតិសាលោហិតរបស់អ្នកទៀតក៏បាន ។

ចន្លាំងក៏ច្រៀបសំដីពន្យល់ខ្ញុំថា ដែលខ្លួនកង្វេ តែធ្វើតែតាមបង្គាប់ឋានអគ្គភូតហើយដែលមកស្លុចចំពោះក៏ស្ថាបនស់អ្នក តែដោយសេចក្តីមេត្រីតែប៉ុណ្ណោះ ។

* *
*

ការជជែកជាមួយនឹងទាហានយាមជើម្បីប្រើនយោបាយដោះខ្លួនខ្ញុំឲ្យរួចរស់ជីវិត

ដល់ម៉ោង ๑๑ យប់ ចន្លាំងបានត្រឡប់មកតាន់បន្ទប់ខ្ញុំ ហើយបានសួរឿងក៏ថ្មីមុនទៅនោះទៀត ខ្ញុំក៏បានឆ្លើយថា អ្នកឯងលួមធ្វើជាកល្យាណមិត្តរបស់ខ្ញុំបានហើយ ចុះអ្នកអាចជួយសង្គ្រោះខ្ញុំបានឬទេ? ចន

តាំងឆ្លើយថា ហេតុដូច្នេះបានជាខ្ញុំមកជួបនឹងលោកនៅទីនេះទៀត ខ្ញុំគិតរកឧបាយដើម្បីឲ្យលោកចេញចាកទីនេះឲ្យបានឆាប់ - ប៉ុន្តែការនេះត្រូវបង្អង់បង្អិចសិន ក្នុងពេលនេះ ខ្ញុំបានឲ្យជាងសោធ្វើកូនសោពីរ ១ សម្រាប់បន្ទប់លោក ១ ទៀតសម្រាប់ទ្វារចូល ។

បិនតាំងគួរតែប្រើឧបាយបែបនេះ ពីព្រោះបម្រើបេស៍លោតរដ្ឋមន្ត្រីដែលលោកទុកចិត្តណាស់នោះមានកូនសោពីរដាក់ជាប់នឹងខ្លួនជានិច្ច ។

ដោយខ្ញុំអធិប្បាយពីកិច្ចការដែលខ្ញុំប្រឹងនឹងរត់ចេញពីទីនេះ កន្លងកាលខាងមុខ ។ បិនតាំងឆ្លើយថា ពេលនេះ លោកគិតការនេះមិនសម្រេចទេ ប៉ុន្តែបើដល់ថ្ងៃសុក្រខាងមុខនេះ ពេលម៉ោងពីរព្រឹកប្រហែលជាបានការ មុនចិនតាំងនឹងចាកចេញពីឡៃ បិនតាំងប្រាប់ខ្ញុំថា ត្រូវលោកប្រុងប្រៀបឲ្យស្រេចដល់ថ្ងៃសុក្រនោះលោកទំនងជាបានរួមខ្លួនមិនខាន — ដល់ចិនតាំងចេញផុតទៅ ខ្ញុំក៏បានសរសេរលិខិត ១ ទៅលោកគង់ថ្វី ឲ្យបម្រើម្នាក់យកទៅជូន —

ស្អែកព្រឹកថ្ងៃព្រហស្បតិ ១៩ ខែតុលា ខ្ញុំបានប្រគល់លិខិតនោះឲ្យបម្រើម្នាក់នៅទីនោះ តែដល់ថ្ងៃរសៀលតាមពាក្យចិនតាំងថា ពួកបម្រើបានឲ្យលិខិតនោះដល់ពួកពាសការមុខក្រសួង ហានអគ្គពាសខ្លួនទៅហើយ ។ បិនតាំងថា ដោយកិច្ចការលោមកដែលលោកបានធ្វើតាំងអម្បាលម៉ាន លោកធ្វើឲ្យខូចការដែលខ្ញុំបានធ្វើមធ្លើ ដើម្បីឲ្យ

លោកវាត់ចេញពីទីនេះ ហើយសៀហាល្វដេមាំរកានី ចាន់បង្ខោសខ្ញុំវាត់ខ្លួន ដោយខ្ញុំបានចំភ្លឺកិច្ចការឲ្យលោកដែលគេប្រឹងនឹងធ្វើចំពោះលោក។ ដល់ចប់ការសន្ទនា ខ្ញុំក៏សួរទៅចិនតាំងវិញទៀតថា ចុះខ្ញុំមានសង្ឃឹមថានឹងបានរស់រួចជីវិតឬទេ ?

ចិនតាំងតបមកវិញថា ក្នុងពេលនេះ លោកមានសង្ឃឹមច្រើនប៉ុន្តែលោកត្រូវប្រតិបត្តិតាមខ្ញុំបន្តិចទៀតទៅ កុំឲ្យឃ្លៀងឃ្លាតឡើយ ។

ចិនតាំងប្រាប់ខ្ញុំឲ្យសរសេរពាក្យមួយទៅជូនលោករដ្ឋមន្ត្រីជាអគ្គពាធ្លូត សូមឲ្យលោងប្រោសប្រណីទោសនោះ ។ ខ្ញុំក៏យល់ព្រមធ្វើតាមហើយ ខ្ញុំក៏សូមបាត់កាទីកភ្នៅនឹងក្រដាស ។ ចិនតាំងបានបង្គាប់ទៅឈ្មោះគូលដែលជាបម្រើជាតិអង់គ្លេស ឲ្យយកប្រជាប់សរសេរមកឲ្យខ្ញុំសរគ្រប់ ។ ខ្ញុំបានប្រាប់ទីកភ្នៅចិន ដោយខ្ញុំយល់ថា នឹងសរសេរជាភាសាអង់គ្លេសទៅរដ្ឋមន្ត្រីខ្ញុំមិនសមគួរ ។ តែចិនតាំងប្រាប់ខ្ញុំថាសរសេរជាភាសាអង់គ្លេសប្រសើរជាង ពីព្រោះលោងរដ្ឋមន្ត្រីមានតែឈ្មោះទេនៅទីនេះ កិច្ចសរសេរគួរតែស្រួចទៅលើលោកម៉ាកានីតាំងអស់ ។ រួចខ្ញុំសួរទៅចិនតាំងទៀតថាត្រូវឲ្យខ្ញុំសរសេរដូចម្តេចខ្លះ ។ ចិនតាំងថា :

" ត្រូវលោកបងសេងថា លោកមិនបានបួលទៅសមាគម ជាមួយនឹងពួកក្រុមសម្ងាត់ទៅទៀតឡើងទេ តែខ្លួនលោកត្រូវពួកមន្ត្រីតាំងនោះ

ក្នុងនោះចប់ផ្តាច់ ហើយលោកបានបួលមកកេហាឧកាសនៅក្នុងឡុងដ្រែនេះ ដើម្បីឲ្យគេកសេចក្តីយុត្តិធម៌ ក្នុងរឿងនេះ" ។

ខ្ញុំក៏បានសរសេរតាមភាក្យ ដែលចិនតាំងបានប្រាប់មក ពាក្យនោះវែងប្លែកខ្ញុំដាក់បួលក្នុងរត្រោមដើរទៅជូនលោកសៀហល្លីដេម៉ាកាន់ទី ។ ខ្ញុំក៏ហុចសំបុត្រនោះទៅចិនតាំង ។ ក៏យកចេញពីមន្ទីរខ្ញុំទៅ លែងឃើញវាលែងត្រឡប់មកវិញទៀតឡើយ ។

ដល់ខ្ញុំត្រឹះរះវែងធ្វាយទៅទើបឃើញថា គាវែលខ្ញុំធ្វើដូច្នោះ ដាសេចក្តីល្អដ៏ល្ងីឥតខ្ចោក ។ ដ្បិតខ្ញុំឲ្យគាវែលថា ខ្ញុំបានមួលមនដោយចិត្តឯង ដើម្បីតវ៉ាពីរឿងរបស់ខ្លួន ។

ខ្ញុំបានឮហោយវ្រកមនហើយថា ចិនតាំងឲ្យដំណឹងខ្ញុំថា លិខិតតាំងអម្បាលម៉ានរបស់ខ្ញុំត្រូវចំរើតាំងនោះ បានយកទៅឲ្យចុងមិត្តរបស់ខ្ញុំតាំងឥស់ ឥតមានសំបុត្រណាមួយទៅដល់លោកកន់ខ្លីដាងលម្អាណមិត្តរបស់ខ្ញុំទេ ។

ខ្ញុំក៏ព្យាយាមរបោះសំបុត្រទៅតាមបង្អួច ឲ្យតវ៉ាត្រចេញទៅក្រៅបន្ទះដាសំណាងល្អ មានសំបុត្រសោតធ្លាក់ទៅលើដំបូលផ្ទះអ្នកជិតខាង ។ ដោយខ្ញុំចង់ឲ្យសំបុត្រចរបស់ខ្ញុំធ្លាក់ទៅទីធ្លា ។ ខ្ញុំក៏ចង្អុលបង្ហាញសេនរុំជាមួយក្រយាសរហែតវែងចោលទៅតាលតែអស់ប្រាក់សេន ខ្ញុំក៏យកប្រាក់ស្មើនរុំក្រយាសចោលទៅជូចមុនទៀត តែសំណាងមិនល្អ មានសំបុត្រ ១

សង្គហធម៌

របស់ព្រះវិន័យធម្ម យ្យុរ – ប៉ុណ្ណា

នៅវត្តខ្ចុណ្ណាលោម

ជាក្រុមដំនុំព្រះត្រៃបិដកក្នុងពុទ្ធសាសនបណ្ឌិត្យ ក្រុងភ្នំពេញ

ឯមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

វេលានេះ អាត្មាភាពទើសំដែងអំពីសង្គហធម៌ ដែលជាធម៌សម្រាប់សង្គ្រោះដល់គ្នាទើងគ្នា; សូមតស់សោតអ្នកទាំងឡាយចាំស្តាប់ដូចសំដែងតទៅនេះ:

កិច្ចប្តូរបាយដែលសម្រាប់សង្គ្រោះ ឬស្រោចស្រង់គ្នាទើងគ្នាឲ្យបានមូលមិត្រហៅថា សង្គហៈ ។ សង្គហៈនេះចែកចេញជា ៤ យ៉ាងគឺ:

១ – ទានៈ ការចែកវិលតឲ្យ

២ – បេយ្យវជ្ជៈ ការពោលពាក្យពីរោះ គួរឲ្យចាប់ចិត្ត

៣ – អត្ថចរិយា ការប្រព្រឹត្តិឲ្យជាប្រយោជន៍ដល់គ្នាទើងគ្នា

៤ – សមានត្តតា ភាពជាអ្នកតាំងខ្លួនឲ្យស្មើៗចំពោះបុគ្គលជនគ្នា ។

សង្គហធម៌ទាំង ៤ យ៉ាងនេះ តែងប្រមូលជនទាំងឡាយឲ្យមូលមិត្រគ្នាក្នុងសកលលោក ។ ម៉ើសង្គហធម៌នេះមិនមានហើយ សាមគ្គីភាពក្រមព្រៀងមូលមិត្រគ្នា ក៏នឹងធ្លុះធ្លាយបែកបាក់ទៅពុំខាន ។

ព្រះពុទ្ធជាម្ចាស់ទ្រង់សរសើរសេដ្ឋកិច្ចនេះ ថាជាកិច្ចយ៉ាងប្រសើរបំផុតក្នុងលោក ។

ឯការសង្គ្រោះនេះ ជាឋានៈរបស់បុគ្គលអ្នកស្ថិតនៅក្នុងទីជាបុព្វការី ដូចជាមាតាបិតាមានការៈទាន់សង្គ្រោះបុត្រធីតា; អាចារ្យមានការៈទាន់សង្គ្រោះសិស្ស; ចៅហ្វាយនាយមានការៈទាន់សង្គ្រោះទាសកម្មករ, ឥស្សរជនមានព្រះពជាជាដើម មានការៈទាន់សង្គ្រោះដល់ប្រជាពលស្តុ ។

ជនដែលបានធ្វើសេចក្តីសង្គ្រោះចំពោះបុណ្ណាមួយហើយ ជននោះឈ្មោះថាជាបុព្វការី, ជនជាបុព្វការីនោះក៏គួរទទួលយកតបវិញដែលនេះត្រូវធ្វើមកវិញ ។ សូម្បីតែជនអ្នកគួចមិនគិតប្រយោជន៍ផ្ទាល់ខ្លួន ហើយមានចិត្តមេត្តាសង្គ្រោះដល់ញាតិឯទៀត ។ កិត្តិយសមានអ្នកដទៃគោរពរាប់អានជួយលើកដំកើងឲ្យខ្ពស់ក្រាន់ទីជាជំបាន ។ ព្រោះហេតុនោះបានជាព្រះពុទ្ធជាម្ចាស់ ទ្រង់មានបំណងនឹងនាំសត្វឲ្យបានសម្រេចគុណសម្បត្តិគឺការតាំងខ្លួនត្រូវក្នុងធម៌ ទើបទ្រង់សំដែងនូវសង្គហៈបាយនេះទុកជាផ្លូវដួចន័យដែលបានពោលមកខាងដើម រួមបូលជាយសង្ខេបជា ៤ គឺ: ទាន:, បេយ្យវជ្ជ:, អត្ថចរិយា, សមានត្តតា ដូចេ្នះ ។

ទី ๑ - ទាន: ការឲ្យនោះ បែងចេញជា ๒ យ៉ាង គឺឲ្យសំដៅចំពោះបុគ្គលម្នាក់ៗ ហៅថាឥសាធារណទាន ๑, ឲ្យជាសាធារណៈដល់មិនសំដៅចំពោះបុគ្គលម្នាក់ៗ ហៅថា សាធារណទាន ๑ ។ ដូច

ជាមាតាបិតាឲ្យគាហារ គ្រឿងប្រដាប់ស្លៀកពាក់ដល់បុត្រធីតាក្នុងវេលាដែលនៅកំឡុះក្រមុំ ឬឲ្យទ្រព្យសម្បត្តិធ្វើជាដើមទុន ឲ្យទិញផ្ទះសម្បែង ក្នុងកាលដែលបុត្រធីតាចំរើនវ័យហើយ; ចៅហ្វាយនាយឲ្យភោគសម្បត្តិដល់ពាសកម្មករ ញាតិមិត្តចែកចាយគ្រឿងប្រើប្រាស់ទ្រព្យកោជនាហារដល់គ្នីគ្នា ។ បុត្រធីតាដែលមានផ្ទះសម្បែងហើយបានដួនគោជនាហារ គ្រឿងស្លៀកពាក់ដល់មាតាបិតាដែលចាស់ជរា; ពាសកម្មករធ្វើការងារ ឬដួនវេចស់ដល់ចៅហ្វាយនាយជាហេតុសំដែងសេចក្តីចង់មេត្រីភៅរកចៅហ្វាយនាយ; យ៉ាងនេះហៅថា អសាធារណៈទាន គឺបូជាឬតបគុណចំពោះបុថុជ្ជនម្នាក់ឯង ។

អស្សវជន ឬ អ្នកមានទ្រព្យសម្បត្តិ ជាអ្នកមានចិត្តផ្សាយមេត្តាអាណិតអាសូរប្រណីដល់មហាជន ហើយលះចង់សេចក្តីកំណាញ់ចរិយ្យាគឲ្យដួលគេទៀលថ្កល់ ដឹងរៃពន ធ្វើស្ពាន ដើម្បីជាផ្លូវគមនាគមន៍ទៅមកបានស្រួល, សង់សាលា ជាដើមឈើ ជីកស្រះដើម្បីជាទីសំណាក់អាស្រ័យដល់មនុស្សអាគន្តុកៈ តាំងចង្កើត ឬទុនតបម្រុងធ្វើផ្ទះពេទ្យជាទីព្យាបាលរោគសត្វយ៉ាង, តាំងចង្កើត ឬទុនតបម្រុងសាលាចត្រែនដាក់ឲ្យចំណេះវិជ្ជាដល់កុមារកុមារី ។ យ៉ាងនេះហៅថាឲ្យឬសគ្រឹះជាសាធារណៈមិនចំពោះបុថុជ្ជន ។ ពានមានសភាពយ៉ាងនេះអាចឲ្យសេចក្តីសុខដ៏ធំធួលឆ្ងាយ ជាង់ឲ្យចំពោះបុថុជ្ជនម្នាក់ឯង គ្រោះ

ពន្លឺកមេត្តាចិត្តផ្សាយទៅកាន់លោកទាំងមូល ។ ទានៈការឲ្យឬសង្គ្រោះដោយផ្សាយមេត្តាចិត្តយ៉ាងនេះ ចាត់ជាបារមី ១ ហៅថា ទានបារមី ។ ទានបារមីនេះព្រះពុទ្ធជាម្ចាស់ទ្រង់បានបំពេញបានសន្សំមកច្រើនជាតិឥតគណនាឡើយ, លុះព្រះអង្គបានត្រាស់ហើយទ្រង់សំដែងទូរសង្គហទាននេះ ថាជាកន្លែងឬដំណើរនៃសេចក្តីសុខក្នុងលោកនេះ និងលោកខាងមុខ; នេះជាសង្គហទី ១ ។

ទី ២ បេយ្យវជ្ជៈ បើគ្រាន់តែឲ្យប៉ុណ្ណោះ ប៉ុន្តែមិនបានពោលពាក្យពិកោះគួរឲ្យចាប់ចិត្តផងនេះ, តែដែលឲ្យនោះ បើទុកជាច្រើនយ៉ាងណាក៏ដោយចុះ ក៏ច្បាស់ជាហាក់ដូចជាតិច, បើពោលពាក្យពិកោះគួរឲ្យស្រណោះចាប់ចិត្ត, ទោះដែលឲ្យនោះ សូម្បីតិចតួចសោះ ក៏ច្បាស់ជាហាក់ដូចជាច្រើន, ព្រោះធ្វើឲ្យកើតសេចក្តីស្រឡាញ់ពេញចិត្ត ធ្វើអ្នកដែលមានទុច្ចរិតឲ្យជាទីពេញចិត្តបាន ។ ព្រោះហេតុនោះបានជាព្រះសម្ពុទ្ធជាម្ចាស់ទ្រង់ចាត់បេយ្យវជ្ជៈ ជាសង្គហទី ២ ។

បេយ្យវជ្ជៈ ប្រែថាពាក្យដែលពិកោះគួរពេញចិត្ត គួរចាប់ចិត្ត ចែកចេញជា ២ យ៉ាងគឺ: បិយវាចា បានខាងក្រោយពីកោះខាងដើម ធ្វើអ្នកនិយាយឲ្យជាទីស្រឡាញ់ចង់ស្តាប់ ១, អត្ថសញ្ជិតា វាចាក្រោយពីបិយវាចា ប្រយោជន៍ ១ ។

ប៉ិយភាសិត អាចនឹងពាក្យចំពូកមនុស្សក្នុងលោកទៀតស្រឡាញ់ពាក្យគ្នាបាន, ដូចជាមាតាចំពោះ បុត្រធីតាដោយពាក្យនៃផ្នែមដូចហៅថា កូន ឋ នាង ដូច្នេះជាដើម ពាក្យនេះគួរទៀតចំពូកដល់បុត្រធីតាតន់ពេក ធ្វើឲ្យកើតសេចក្តីស្រឡាញ់ ។ បុត្រធីតាដែលចេះនិយាយពាក្យពីកេះគួរទៀតចំពូក, មាតាបិតាក៏ស្រឡាញ់ពេញចិត្ត ។ ជនជាវស្សវដែលឈ្មោះសក្តិតាមចំណងសន្ធានពោលពាក្យរាក់ទាក់ច្រៀស័យ រួសពេញដល់អ្នកភូចខ្លួនៅគ្រប់ជាន់ គ្រប់ថ្នាក់, រមែងធ្វើខ្លួនឲ្យជាទីស្រឡាញ់គោរពចិត្តបេស់មនុស្សទាំងឡាយ ចេះនិយាយជីតនាំអ្នកភូចឲ្យមានតំនិតធ្វើតិច្ចការដោយសេចក្តីប្រឹងប្រែង ហើយឲ្យជាសុចរិតបានផង ។ ឯាចនេះកូនខ្មែរនេះឯង បើពុកជាមនុស្សខ្មោះពីដើមមកភ្ជាប់ពាក្យនៃខ្លួនតំនិតគ្នា ដល់ទៅមើលមុខគ្នាមិនត្រង់ក៏ដោយ សាលបើបានឮសំដីពីកេះញាយៗក៏អាចនឹងស្រាយតំហឹងនោះបាន ។ ដូចពាក្យបុព្វណ្ណលោកពោលថា "សំដីជាឯក លេខជាពោ" សំដីនេះលើនពុកជាមួយ ចំណេះវិជ្ជាពុកជាពីរ ។ អ្នកដែលមានចំណេះយ៉ាងណាក៏ដោយចុះ, ប៉ុន្តែបើពោលវាចាមិនជាទីគាប់ចិត្តជាវាចាតំកេះតំរើយមិនពេញចិត្តអ្នកស្តាប់ អ្នកមានចំណេះខ្មោះ ក៏ទៅជាឥតមានតម្លៃបន្តិចតួចទៅវិញ ។ ជនអ្នកឧត្តុង្គចំណេះវិជ្ជាសោះទេ, ប៉ុន្តែបើមានវាចាពិកេះ ចេះទុនលំពោនសុភាពចរិយាល្អគួរឲ្យពេញចិត្ត, តង់មានអ្នកជំនែនតួចំពេះតួជួយសង្គ្រោះ តែបូជា ឬឲ្យកុំ

នេះនោះពុំខាន ។ ចាំងនេះកំណើតមកពីកេរ ។ ប៉ុន្តែមនុស្សម្នាក់ៗមិនត្រូវធ្វើខ្លួនឲ្យឥតចំណេះវិជ្ជាទេ, ត្រូវតែខំប្រឹងរៀនសូត្រជាដរាប ។

អត្តសញ្ញាតា ភាពថា ភាពប្រកបដោយប្រយោជន៍ ។ ជនអ្នកស្រឡាញ់សេចក្តីសុខ-ចំរើន និយាយតែសំដីណាដែលប្រកបដោយប្រយោជន៍ ជាសំដីមានតម្លៃឲ្យអ្នកស្តាប់ចូលចិត្តចង់ស្តាប់, ហើយអ្នកស្តាប់នោះ យកទៅធ្វើតាម ប្រតិបត្តិតាមទៅ ក៏រមែងកើតផលកើតប្រយោជន៍ ។ សំដីយ៉ាងនេះ ចាត់ជាសំដីបានការ ជាសំដីអ្នកប្រាជ្ញ ។

ព្រះចេមសាស្តា ទ្រង់ទេសនាដឹកនាំវេនេយ្យសត្វ ឲ្យយើញដោយបញ្ញាថា យ៉ាងនេះជាធម៌ យ៉ាងនេះមិនមែនជាធម៌, ទ្រង់ពន្យល់ឲ្យលះអកុសលចេញ ហើយឲ្យសមាទានយកកុសលធម៌វិញ ឲ្យគាបបានឲ្យកែកាយកវាចាធម៌នោះ ។ ទ្រង់បណ្តុះសេចក្តីពប់គានវបសំមហាជនតាំងត្រហស្តាំងបព្វជិតឲ្យមានកំឡាំងតាំងនៅអស់កាលដ៏យូរអង្វែង ។ ព្រះពុទ្ធសាសនាដែលនឹងអាចតាំងនៅបានរហូតមកដល់សព្វថ្ងៃនេះ ក៏គ្រស័យ ព្រះពុទ្ធវាចា ជាសច្ចវាចា ជាអត្តសញ្ញាតា ភាពថា, ភាពពិត, ភាពមានប្រយោជន៍ ។ ភាពមានប្រយោជន៍នេះ ជាសំដីគាត់ថ្លៃពុំបាន ។ ការពោលតាក្យពីកេរយ៉ាងនេះ ចាត់ជាសង្គហតី ២ ។

ទី ๓ - អត្ថចរិយា ការយល ប្រព្រឹត្តជាប្រយោជន៍ដល់គ្នានឹងគ្នា នោះ គឺ បើប្រសិនជាឲ្យ ឬនិយាយពាក្យពីរោះ ជាគុណចាប់ចិត្តបុគ្គលមេត្រីខុកបានយ៉ាងស្ងួតក៏ពិត, ប៉ុន្តែបើជាមនុស្សចេះតែមើលចំណាំគ្នាទៅវិញទៅមក មិនប្រព្រឹត្តប្រយោជន៍ដល់គ្នានឹងគ្នា គឺថាមិនហុចប្រយោជន៍ឲ្យ មិនជ្រាប់ៗចាយឲ្យកើតប្រយោជន៍ឲ្យ គ្រាន់តែឲ្យចេស់ប្រើប្រាស់ ខឹងនិយាយតាមការសម្លុតប៉ុណ្ណោះ ការជិតស្និទ្ធនោះក៏ខឹងសាបរលាបទៅវិញបានដោយងាយ ។ ព្រោះហេតុនោះ អត្ថចរិយាការប្រព្រឹត្តជាប្រយោជន៍ដល់គ្នានឹងគ្នានេះ ក៏ជាគុណយ៉ាងសំខាន់គប្បីតយោងគ្នានឹងគ្នាឲ្យទៅកាន់សេចក្តីសុខ - ចំរើនតរៀងទៅបាន ។

ឯការយើតយោងឲ្យប្រយោជន៍ដល់គ្នានឹងគ្នានោះ ដូចជាមាតាបិតាខ្វល់ខ្វាយធ្វើប្រយោជន៍ឲ្យបុត្រធីតា គឺទំនុកបម្រុងឲ្យមានសុខសប្បាយ ចំណេះវិជ្ជា ផ្តល់ឲ្យបុត្រធីតាតាមជាន់តាមថ្នាក់; ចំណែកបុត្រធីតាវិញក៏ជួយខ្វល់ខ្វាយក្នុងកិច្ចការរបស់មាតាបិតា គឺថាត្រូវចិញ្ចឹមគាត់ដោយការគោរពគុណ ។ ឥស្សរជនជួយធុរៈដល់អ្នកជិតស្រុកត្រូវការពឹងពាក់ព្យាបាលទំនុកបម្រុងឲ្យមានក្តៅឈ្លោះឃុបឃិតក្តី ប្លាកដក្នុងទីប្រជុំជន, រមែងជាទីនិយមកាន់តាមរបស់អ្នកពឹងពាក់, អ្នកជិតពឹងពាក់សោតទៀតក៏ត្រូវធ្វើកិច្ចការរបស់លោកឲ្យសម្រេចតាមចំនង់ជិតលោកជុំនួចដែរ ធ្វើឲ្យលោកជឿជាក់ទឹកចិត្តបាន ឲ្យលោកស្រឡាញ់រឹតតែខ្លាំងឡើង ។

មិត្រសំឡាញ់ ក៏ត្រូវជួយទ្រូលំទ្រាយកិច្ចធុរៈគ្នាទៅវិញទៅមក ដោយ
តម្លាំងយយទ្រូះ ដោយកំឡាំងវាយទ្រូះ កំឡាំងគំនិតទ្រូះ កំឡាំងទ្រព្យទ្រូះ
ឲ្យសមតាមទំនង៏ពុទ្ធភាសិតថា អត្តម្ថំ ជាតម្ថំ សុខា សហាយា
មិត្រសំឡាញ់ពាំងឲ្យាយ កាលបើធុរៈកើតឡើង, វៃមង៏ជួយនាំឲ្យបាន
សេចក្តីសុខ ទើបមានមេត្រីចិត្តរាប់រកគ្នាយ៉ាង៏ស្និទ្ធ ។ សូម្បីញាតិក៏ជួប
គ្នា ត្រូវតែជួយធុរៈគ្នាតាមលំដាប់ញាតិ, មិនចាំបាច់ញាតិសាច់សាលោ-
ហិតជិតគ្នាទេ ឲ្យតែរួមជាតិជាមួយគ្នា ក៏ត្រូវតែជួយផ្តល់ប្រយោជន៍ឲ្យ
តាមសមគួរ យ៉ាង៏នេះទើបរាប់រកគ្នាទៅពេលមុខបានស្រួលល្អ ។ ឯការ
ជឹកនាំកូន៏ផ្លូវមិនខ្វៃតសោត ក៏ត្រូវបង្ហូលគ្នាឲ្យបរិភោគធនធានធ្វើកុសល
ដើម្បីនឹង៏ញ៉ាំង៏ឪគ្នាឲ្យស្រុះស្រួលនិងតកូ៏តាបុណ្យខោះ ឲ្យចេះស្និទ្ធ
ស្នាលគ្នាតទៅ ។ ដូចជនអ្នកមានសីលជាមិល្ហ អាចជឹកនាំអ្នកឥតសទ្ធា
ឲ្យមានសទ្ធា ឥតសីល ឲ្យមានសីល តំណោ ញ៉ាំសូភ៌ញ៉ា ឲ្យមានចិត្ត
ទូលាយបរិច្ចាគទ្រព្យធ្វើបុណ្យ អ្នកល្ងង៏ខ្លៅឲ្យមានប្រាជ្ញា ។ យ៉ាង៏នេះ
ឈ្មោះថាប្រព្រឹត្តប្រយោជន៍ដល់គ្នានឹង៏គ្នា កាលបាជាសង្គហ ទី ៣ ។

ទី ៤ - សមានត្តតា ភាវជាអ្នកតាំង៏ខ្លួនឲ្យស្មោះស្មើរៀតេ
បុគ្គលដង៏គ្នាតាមសមគួរនោះ, តបុគ្គលសូម្បីគ្រាន់តែឲ្យ ឬនិយាយពាក្យ
ពិកោះត្រមាំង៏ជួយទ្រូលំភ្លាយធ្វើប្រយោជន៍ ឬណែនាំប្រាប់ប្រយោជន៍
ដល់គ្នានឹង៏គ្នាតែប៉ុណ្ណោះ, តែបើមិនចេះរៀបចំខ្លួនប្រាណឲ្យសមតាម

អត្តភាព តែមិនស្គាល់ធំ-តូច-ខ្ពស់-ទាប ជាអ្នកប្រកាន់មានៈ ក្នុងភាន
មើលងាយគេ ធ្វើឫកពាក្រអឺតក្រអោងយ៉ាងនេះទេ, សេចក្តីពាក់ព័ន្ធគ្នា
តំនឹងសាបរលាបទៅវិញ ។ លុះតែគាស្រ័យខ្លួសេចក្តីស្មោះស្ម័ គាំង
ខ្លួនឲ្យសមតាមអត្តភាពផង, ទើបសេចក្តីពាក់ព័ន្ធនោះនឹងមានកម្លាំងអាច
ភាំងនៅបានយូរអង្វែងទៅបាន ។

ជនអ្នកមានវ័យតិច សូម្បីវិសេសជាងដោយឈសសត្តិ ដោយ
អំណាច ដោយកោតសម្បុ ដោយបារមីប៉ុនណា, ក៏ត្រូវតាំងខ្លួនឲ្យសម
តាមថ្លៃបភាព ឈសសក្តិជាដើមប៉ុណ្ណោះ, គឺត្រូវតែតំនាក់តាក់តួរដល់
ជនអ្នកមានវ័យចំរើនជាងខ្លួន, ពីដើមមកធ្លាប់ពាក់ព័ន្ធយ៉ាងណា ខាង
ក្រោយមកក៏ត្រូវពាក់ព័ន្ធយ៉ាងនោះ ។ ជនទាំងឡាយ ដែលបានឧបត្ថម
សេចក្តីគោរពសោតវិកន្ធយ៉ាងនេះហើយ, ក៏រមែងស្រឡាញ់ពេញចិត្ត
សំដែងអាការពាក់ព័ន្ធតទៅវិញ ។

ពួកញាតិដែលមានវ័យស្មើៗគ្នាទៀតសោត ក៏ត្រូវសំដែងសេចក្តី
ពាក់ព័ន្ធគ្នាដោយពេញចិត្តចំពោះញាតិផងគ្នា, ពោះនិយាយស្តីក្តី ធ្វើការ
ងារអ្វីក្តី ដេក-ដើរ-ឈរ-អង្គុយក្តី ក៏ត្រូវប្រតិកូល ត្រូវធ្វើ ត្រូវនិយាយ
ស្តីឲ្យសមតាមអត្តភាពរបស់ខ្លួន ។ ញាតិដែលជាអ្នកធំមានមេត្តាពាក់ព័ន្ធ
ញាតិដែលជាអ្នកតូច ស៊ូរស្នាលគ្នាទៅវិញទៅមកជួយគ្នាទៅវិញទៅមក
ដើម្បីតាំងវង្សត្រកូលរបស់ខ្លួនឲ្យចំរើន; សេចក្តីសាមគ្គីនៃញាតិនេះ,

រមែងញ៉ាំងសេចក្តីសុខឲ្យកើតមានខ្លួនឯងសព្វគ្រប់; ដូចមានពុទ្ធភាសិតថា ធីរោ ច សុខមសំវាសោ ញាតីនំ សមាគមោ អត្ថកាមជ្ជវដែលមានមនុស្សរួមគ្នានៅរួមជាមួយហើយ, រមែងញ៉ាំងសុខឲ្យកើតដូចជាការជួបជុំ នឹងសេចក្តីត្រេកត្រអែងនៃពួកញាតិដូច្នោះដែរ ។

មួយទៀតជនដែលអាស្រ័យនៅក្នុងគណៈដូចជាភិក្ខុសង្ឃ ដែលអាស្រ័យនៅជាមួយគ្នាបាន ក៏ដោយអំណាចមានធម៌ស្មើគ្នា ។ បើមិនដូច្នោះទេ ក៏មិនឈប់ធំនឹងក្សាសាមគ្គីឲ្យគង់នៅបានឡើយ ។ ព្រោះហេតុនោះ បានជាលោកដែលជាប្រធាននៃគណៈត្រូវប៉ិនប្រសើរដើម្បីឲ្យមនុស្សទាំងឡាយក្នុងគណៈ និយមធ្វើតាមសណ្តាប់ធ្នាប់របស់គណៈ កំចាត់បង់នូវមនុស្សដែលល្មើសចេញ ហើយរក្សាសាមគ្គីរបស់គណៈឲ្យតាំងនៅមាំមួនឡើង ។

សមានត្តតានេះ ប៉ើធ្វើឲ្យសម្រេចនូវមោក្ខផលរបស់បុគ្គលឯគណៈ: ហើយ រមែងឃើញយោងបុគ្គលនឹងគណៈនោះ ឲ្យតាំងនៅក្នុងសាមគ្គីធម៌ យ៉ាងជិតស្និទ្ធបាន - នេះចាត់ជាសង្គហទី ៤ ។

សង្គហធម៌ទាំង ៤ ចប់តែប៉ុណ្ណេះ ។

ឯលើបើចប់ធម៌ទេសនាហើយ សូមផ្សាយចំណែកកុសល ដល់អស់លោក - អ្នកទាំងឡាយ ដែលបិតនៅក្នុងគម្ពីរជួតាំងមួល សូមឲ្យបានសេចក្តីសុខ - ចំរើនតរៀងទៅ ។

ទុក្ខប្បត្តា ច ឆន្ទុក្ខា ភយប្បត្តា ច ឆំ ភ្ពយា
សោកប្បត្តា ច ឆំ សេ្នកា ហោន្តុ សព្វេបិ ចាណិនោ ។

សត្វសត្វទាំងឡាយដែលដល់នូវសេចក្តីទុក្ខ ក៏ឲ្យបាត់ទុក្ខទៅ, ដែលដល់នូវភ័យ ក៏ឲ្យបាត់ភ័យទៅ, ដែលដល់នូវសេចក្តីសោក ក៏ឲ្យបាត់សោកទៅ (ដោយអំណាចធម្មទេសនានេះ) ។

សំដែងអំពីសង្គហធម៌ ៤ យ៉ាងចប់តែប៉ុណ្ណេះ ។

ព្រះគ្រូបញ្ញាលិទ្ធ កៅ-សឹម

គ្រូបង្រៀនសាលាបាលីជាន់ខ្ពស់ ក្រុងភ្នំពេញ រៀបរៀង

(ត)

ព្រះឥន្ទ្រជ្រាបហេតុនោះក៏បានចុះមកឲ្យឆ្នាំង ១ ដែលសម្រាប់ប្រសិទ្ធិជាទីឲ្យសម្រេចប្រយោជន៍គ្រប់យ៉ាង ហើយប្រាប់ថា "នែកូន! ឯងបួរក្បាឆ្នាំងនេះទុក កុំឲ្យបែកធ្លាយ! កាលបើឆ្នាំងនេះ មិនបានបែកធ្លាយទេ ឯងនឹងសម្បូរហូរហៀរទៅដោយទ្រព្យមិនខាន ចូរឯងកុំប្រមាទឲ្យសោះ" ហើយក៏គ្រឲ្យចំទៅកាន់ទីលំនៅរបស់ខ្លួនវិញ ។ ចាប់ដើមតាំងពីថ្ងៃនោះមកកូននោះបេះតែផឹកស្រាស្រែរឹងមិនដឹងខ្លួន ហើយស្ទុះទៅចាប់ឆ្នាំងនោះលើកបោះត្រវែងទៅលើអាកាស ស្ទុះទៅឱនទួលទុកភ្លាត់ចំណាប់ចាប់មិនជាប់ បែកធ្លាក់ចុះទៅលើផែនដីបែកខ្ទេចខ្ទី ។ កូននោះធ្លាក់ទៅជាមនុស្សទ័ពាល់ក្រ ស្ងួតកំណាត់សំពត់ម្តងខ្មែត កាន់អម្បែងដើរសុំទានគេស៊ី ទៅដេកស្លាប់នៅតែស្ទះសំយាបផ្ទះអ្នកដទៃ (គេថាខ្មោចបាត់ផ្តែក៏ចបួលគ្នាអូសចោលទៅ) ។

ចប់រឿងកូនព្រះពោធិសត្វ ។

រឿងកូយអនាថបិណ្ឌិកសេដ្ឋី

សេចក្តីថា: កូយរបស់អនាថបិណ្ឌិកសេដ្ឋី បំផ្លាញប្រាក់ ៤០ កោដិជារបស់ដែលនាគាបិតាខ្ចីឲ្យ។ វិនាសដោយហេតុតែផឹកសុរា ហើយទៅកាន់សំណាក់សេដ្ឋី ឲ្យមួយពាន់តហាបណៈមកបង្គាប់ថា: "ឯងចូរយកគ្រឿងនេះទៅធ្វើដំណូចចុះ" ។ កូយនោះយកគ្រឿងនោះទៅទិញស្រាផឹកអស់ហើយ ទៅឯនាំសំណាក់សេដ្ឋីម្តងទៀត សេដ្ឋីបានឲ្យ ៥០០ តហាបណៈមកទៀត ក៏យកទៅទិញស្រាផឹកតាលំតែអស់ សេដ្ឋីបានឲ្យសំពត់សាដកមានសាច់ក្រាស់ ២ ដួងមកទៀត ក៏យកទៅឲ្យវិនាសអស់ទៀត ទើបសេដ្ឋីប្រែមនុស្សឲ្យចាប់កូយនោះពាក់ព្រាត់ច្រានចេញទៅក្រៅផ្ទះ ។

ឯកូយនោះឥតមានអ្នកណាជាទីពឹងសំណាក់តែស្រីយ៉ ក៏ទៅដេកស្លាប់ក្បែរសំយ៉ាចផ្ទះអ្នកដទៃ មនុស្សចាំងភ្លើយនាំគ្នាពាក្យអួសខ្មោចនោះយកទៅចោលទាំងក្រែស្មុកទៅ ។

ហេតុនេះហើយ អ្នកឆ្លាតស្រាវជ្រាវពិចារណាតាមរឿងដែលគណនាមកជាទំនាន់តតិ មិនត្រូវយកតម្រាប់តាមទៅអនាគតឡើយ ។

ចប់ចាន់សោណ្ឌាតែប៉ុណ្ណេះ ។

ទោសកើតអំពីអង្គុយឬឈរមាន ៦ យ៉ាង [1]

មនុស្សយើងត្រូវស្គាល់ប្រមាណក្នុងកាលដែលបួលទៅតាន់សំណាក់លោកអ្នកធំដោយមានកិច្ចណាមួយ តម្រូវឲ្យស្គាងទោសដែលកើតអំពីអង្គុយ ឬឈរខុសខ្នង នាំឲ្យជាទំនាស់អប្យាស្រ័យរបស់អ្នកធំ គំទុំក្នុងចិត្តនាំឲ្យខូចភាគប្រយោជន៍ខានបាន ដូចមានមាតិកាបង្ហាញសម្រាប់ឲ្យគោរពខ្នងឲ្យបានល្អតទៅនេះ ។

១ - អង្គុយឬឈរឆ្ងាយពេក (អតិទូរ)

២ - អង្គុយឬឈរជិតពេក (អច្ចាសន្ន)

៣ - អង្គុយឬឈរខាងលើខ្យល់ (ឧបរិវាត)

៤ - អង្គុយឬឈរខ្ពស់ជាងពេក (ឧន្នតបច្ឆាទេស)

៥ - អង្គុយឬឈរចំមុខពេក (អតិសម្មុខ)

៦ - អង្គុយឬឈរចំខាងក្រោយពេក (អតិបច្ឆា) ។

ចំ ១ ដែលថាអង្គុយឬឈរឆ្ងាយពេកនោះ គួរជ្រាបថា: កាលបើត្រូវការអ្នកធំសួរ ឬខ្លួននិយាយជំរាបជូនរឿងអ្វីៗ គោងតែប្រើសំដីសម្ងួនសួរនឹងធ្វើយឆ្ងន់ឆៅវិញទៅមកឲ្យលាន់ឮខ្ទាំង ទើបដឹងការណ៍នោះ។ ឬាសំ ។

---

[1] បច្ចេសមន្ត... ត្រង់វើរញ្ជោកណ្តូរណ្តែតា ។

ទី ២ ដែលថា អង្គុយឬឈរដើរតេក ជាហេតុនាំឲ្យអប្បាយសដល់លោកអ្នកធំ ព្រោះខ្លួនបុណ្យតូចស័ក្តិតាបសាចអំណាចមិនអាចលើកអត្តភាពរបស់ខ្លួនឲ្យស្មើ ហាក់ដូចជាស្មៀស្មាំលដំណាលគ្នាឬតា ទើងអ្នកធំនោះ។ ពុំនោះសោត បណ្តាលនាំឲ្យស្អុះស្អាប់កើតសេចក្តីធុញថ្នាន់ ទើងធ្វើការអ្វីមួយមិនកើត ។

ទី ៣ ដែលថាអង្គុយឬឈរតើលើខ្យល់នោះ ត្រូវដឹងថា: កូនខ្លួនយើងដែលចង់ផ្សាយចំហាយចេញទៅ នាំឲ្យជាសត្រូវបៀតបៀនដល់លោកអ្នកធំ មិនឲ្យរីកយសឬផ្សាយចំតុដោយសារកូននោះ។ ។

ទី ៤ ដែលថាអង្គុយឬឈរខ្ពស់ជាងអ្នកធំនោះ ត្រូវដឹងថា: ធម្មតាមនុស្សយើងតែងសំដែងឬតា ច្រកចង្អេរដោយធម៌អស្ចារ្យ: ប្រើអាការពុំស្ងប់គោរពគោតខ្លាច ចង់ដំណើងឬតា ដើម្បីស្មើនឹងអ្នកធំ ។

ទី ៥ ដែលថាអង្គុយឬឈរចំមុខពេតនោះ គួរជ្រាបថា: អ្នកធំឬខ្លួនអ្នកគួបត្រូវការមើលមុខ គោងតែសំដែងចំមុខពេត ហាក់ដូចជានាំឲ្យកើតហេតុសេចក្តីរើងគ្នីងគៀរញៀមត ។

ទី ៦ ដែលថាអង្គុយឬឈរចេញពីខាងក្រោយពេតនោះ គួរដឹងថា: អ្នកធំរលាត្រូវការនិយាយ ឬចង់ឃើញមុខ គោងតែងាកមកចៃរៀមទើបឃើញមុខស្គាល់តាការតែរំយោសឬត្រូវ ជាហេតុនាំឲ្យមានសេចក្តីលំបាកដល់លោកអ្នកធំ ។

ក៏កង់ចក្ខុដ៏តន់ឃមរបស់អ្នកបួសវិញនោះ គួរស្គាល់ឋាន ២ យ៉ាង

១- អង្គោថាន ឋានខាងក្នុង

២- ពាហិរដ្ឋាន ឋានខាងក្រៅ

ឯឋានខាងក្នុងនោះ គឺទៅកន់រាគ្គមានន័យ ដោក - ដើរ - ឈរ - អង្គុយ ត្រូវឲ្យមានសម្បជញ្ញៈ ការដឹងខ្លួនស្គាល់ប្រមាណកន្លងវាយាបថទាំង ៤ នោះដែរ គួយ៉ាង កិក្ខុ-សាមណេរដែលបួលទៅកាន់ស៊ុំណាក់ព្រះគុរូបជ្ឈាយាចារ្យរបស់ខ្លួនជាដើមកន្លងគាល់ អង្គុយស្តាប់ធម៌ទេសនា ត្រូវប្រើវាយាបថ ឲ្យរម្យទម្យរៀបរយកុំឲ្យបង្ហិះបង្ហើរស៊ាស់ចង្កុយរំនើតក្រវែបខ្លួនកាយឲ្យមានសភាពបសារទៅតាមទំនួល មិនត្រូវអង្គុយហោងហោង បញ្ឈរក្បាលជង្គង់ ច្រត់ដៃលើចង្កាច្រត់រៀងចរាចរខ្លួនចំរេតផ្លែក ឬក៏ចាក់ដៃម្ខាងផ្អប់ទឹកខ្នងជ្រោងខ្លួនធ្វើខ្លួនហាក់ដូចជាគ្រុធំ ១ ដែរ ពុំនោះសោតនិយាយគាអ៊ូមួយ ឆ្កាដៃវាសបុះវាសទ្បើង ធ្វើខ្លួនហាក់ដូចជាចេះក្រហែលនឹងគ្រូបជ្ឈាយាចារ្យនោះដែរ, នេះហើយជាឆាការរបស់មនុស្សព្រៃហ៊ានគេងឆាប ធ្វើខ្លួនឲ្យមានអំណាចខ្ពស់ដូចជាអ្នកធំ គួរនិយមចុះកន់ទោសដូចបុរាណគោលមកហើយនោះ ។

ឯឋានខាងក្រៅនោះ គឺខាងក្រៅអំពីទីវត្ត សាលបើកិក្ខុ-សាមណេរខ្លួនមិនគួរយក - ទាយិកា ដោយមានកិច្ចធុរៈបុណ្យទានជាដើមទៅទីផ្ទះគេឬទីណាមួយ ដែលបញ្ជូនទៅជួតអំពីទីរបាររបស់

វត្តខោះ គោងរៀបចំដំរីយោធពលឲ្យមានរបៀបរៀបរយទៅតាមលំដាប់
វស្សាចាស់ខ្ចី ហើយសឹមដើរចេញទៅ កុំដកថាវ៉ៃ ឆាន់ស្លា គោល
ចរចាគ្នាយ៉ាងឯកសង្វៃ ដើន្ទដើរទៅនោះឡើយ ត្រូវដើរទៅជាជួរ ។
ជាទីភ្ញាំងសំរេសិលឲ្យកើតសេចក្តីជ្រះថ្លាដល់ជនទាំងពួង ។

លុះដល់ទៅផ្ទះតាយាតគេនិមន្តឡើងឆាន់អាសនៈ តាយ៉ាមលាមើល
ទ្រូងស្តាំសិន កុំឲ្យប្រសាន់ពេក ឲ្យសមគួរដល់ឋានៈ[1] ត្រូវពិចារ-
ណាបំពោះអាសនៈ: មានតាន្លូ ព្រំ ចៀមជាដើមនោះផង ។ ដែល
នឹងពិចារណាអាសនៈនោះ គោងពិចារណាដល់ត្រឹងចរិក្ខារប្រើប្រាស់
ដូចផ្តិលទឹក នៃវត្ត ដើងតាងដាក់ស្លាបាវ៉ៃ ក្បាក់ដាក់ចាន់តែ តន្ទោ
ស្លាឆ័ត្រដែលគេរៀបចូរដាក់ឆត្តទឹកនោះ ហើយសឹមដាក់បង្គុយលុតជង្គង់ចុះជា
មុនតាមទំនួល ចង្អាមមុខសម្រួលចុះបន្តិច តែកុំក្រេបកន្ត្រោតដែល
អង្គុយនោះឲ្យសោះ ត្រូវមានសតិសម្បជញ្ញៈឲ្យខ្ជាប់ ទើបបាននឹងោ
ថាបព្វជិតនិយម ។ ព្រោះមានបព្វជិតខ្លះច្រើនពុំសូវប្រយ័ត្នខ្លួនស្គាល់
ប្រមាណ កន្ត្រោតដែលឡើងកាន់អាសនៈ: នៅផ្ទះតាយាត . តាយ៉ាម
ឥតមានគំនិតគិតពិចារណាសោះឡើយ ពត្រាំងពត្រែត សស្ទើត
សស្ទក់ ត្រែនត្រែនបន្ទន់ឆ្អេរប្រើខ្មាយ ហាក់ដូចជាខ្លាចតាយ៉ាតម្ចាស់
តាមណាស់ ឬក៏សំដែងឆាតារហាក់ដូចជាគោរពតាយ៉ាមជាម្ចាស់តាន

(មានត)

១ ត្រូវសំឡឹងមើល ១ ជ្រុងទីមជាងគេ ។

RÉGIE DU DÉPÔT LÉGAL

អក្សរសិល្ប៍ខ្មែរ

COMMISSION DES MŒURS & COUTUMES

រស្មីភាវ្ជឹ ផ្សាយដំណឹងខាងសាសនា ទំនៀមប្បញ្ញត្តិ ប្រពៃណី

អំពីពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកអក្សរសិល្ប៍: ហ្លួងធំពន្ធមន្ត្រី ញ៉ុក-ថែម, បណ្ឌិត ស៊ៅ ពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកដំណឹងសាសនា: ព្រះគ្រូសុវិឡញ្ញាណ ស្ង-ហាយ ក្រុមជំនុំព្រះត្រៃបិដក នៅពុទ្ធសាសនបណ្ឌិត្យ

បញ្ជីរឿង

ផ្នែកអក្សរសិល្ប៍		ទំព័រ
អ្នកនាងកញ្ជ្រៀទេពតិទ្ធរឈឺម-ក្រសែម		
តំណាងអក្សរ	ល្ខោនខោល	១៦១
អ្នកនាងកញ្ជ្រៀរៀបរាជវង្សសេនា(ខ្នែ-ពាន)		
តំណាងអក្សរ	រឿងសាមកុក (តមក)	១៧១
ហ្លួងធំពន្ធមន្ត្រី ញ៉ុក-ថែម		
នៅពុទ្ធសាសនបណ្ឌិត្យ	ប្រវត្តិសាស្ត្រសង្ខេបប្រទេសចិន (តមក)...	១៩៩
" "	ភូមិសាស្ត្រសភាពលសង្ខេប (តមក).....	១៩៩
យុទ្ធសុន្ទរមេធី ញូង-សឿង		
នៅពុទ្ធសាសនបណ្ឌិត្យ	ឯកសារហ្លួងត្រី ភាគទី១៩	២០៩
លោក ភ័យ-ប៊ុក សមុហាឯញ្ញំ		
នៅពុទ្ធសាសនបណ្ឌិត្យ	រឿង ស៊ុន-យ៉ាត-សេន (តមក)	២១៩
ផ្នែកសាសនា		
សមុហាពោធិញ្ញាណ ខ្ញុង-ស៊ឿន	អំពីការសង្គ្រោះបាតប្រែគល់មុខការព្រះសង្ឃ-	
	យក វត្តទណ្ឌាលាង	២១៧
ព្រះគ្រូបញ្ញាសិទ្ធិ ភៅ-សិម	យុវចនៈយោគាចារ្យ (តមក)	២៣២

ភ្នំពេញ ២១ — លេខ ៣ ខែ មីនា ឆ្នាំ ១៩៦៨ — ដងខ្សែ ១ ឆ្នាំ ៦៩ រៀល ។

KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique.

Rédacteur en chef de la partie littéraire : Luong Nibandhamantri Nhok-Thèm, Pandit à l'Institut Bouddhique.

Rédacteur en chef de la partie religieuse : Vénérable Brah grū Suvaddhaññāna So-Hay membre de la Commission du Tripitaka

TABLE DES MATIÈRES

Partie littéraire :

		page
Oknha Déb Bidur Chhim - Krasém Député	Danse masquée (Lokhaun khaul)...	161
Oknha Vipularājasenā (Karn) Député	Histoire de Sam kok (suite).....	171
Luong Nibandhamantri Nhok-Thém (I.B.)	Histoire de Chine (suite)	189
—id—	Géographie générale (suite).....	198
Khun Sundaramedhi Nhoung - Sœung (I.B.)	Mille et une nuits fasc. 15 (suite)	208
Monsieur Ray - Buc Chef Comptable (I.B.)	Un épisode de la vie du Dr. Sun-Yat-Sen, (suite).....	219

Partie religieuse:

Vén. Samuha Bodhiññāna Duong-Dœun Vat d'Unalom P. Penh	Cérémonie de passation de Service du Chef de secte Mahānikāy à Vat d'Unalom Phnom-Penh	225
Vén. Brah grū Paññālikhit Kao - Sim professeur de Pali à l'Ecole supérieure de Pali	Yuvacariyakatha (suite)	232

*កញ្ចាំខេពតិខ្លួ [ក្រសេម គន្ធបណ្ឌិត រៀបរៀង]

អធិប្បាយរឿងល្ខោនខោល

ល្ខោនខោលនេះ ក៏កប់រួមនៅក្នុងចំពូកល្ខោនដែរ តែមាន បំណងដោយឡែកផ្សេងអំពីល្ខោន គឺល្ខោននោះគេលេងរឿងផ្សេង ។ មិនមានកំណត់ ចំណែកឯល្ខោនខោលនោះ គេកំណត់លេងចំពោះតែ រឿងដែលទាក់ទាមដោយរឿងព្រះជាម្ចាស់ គឺព្រះឥសូរ ព្រះនាយណ៍ ដែលជាព្រះកន្ធសេយ្យសាស្ត្រ គឺលេងរឿងអវតារ (ចៃដន្យ) របស់ព្រះ ជាម្ចាស់ ដូចយ៉ាងរឿងកមក្តៅ (កមាយណៈ) សឹងជាព្រឹត្តិរបស់ព្រះជា ម្ចាស់នោះ ដើម្បីប្រកាសកិត្តិគុណសេចក្តីទាំងពួងកែនឹងភ្លាមនរបស់ព្រះ ជាម្ចាស់ នឹងអ្នកដែលព្រះជាម្ចាស់ចុនចៃដន្យមកកើត ដូចយ៉ាងព្រះកម, តាមកន្លងមកថា លេងរឿងដូច្នេះដោយហេតុឲ្យកើតមគ្គុលស្តួចដល់ អ្នកលេង នឹងជាទីប្រោសប្រណីរបស់ព្រះជាម្ចាស់ ទើបគេនិយមលេងមកដល់ឥឡូវនេះ តែមនុស្សក្នុងសម័យនេះមិនសូវជាមានអ្នកយល់ ដូចសោលមចខាងលើនេះទេ គេយល់ត្រឹមតែថាជា ល្ខោនស្រុក ។ យ៉ាងណាមិញលេងជាគ្រឿងសប្បាយរីករាយ ហើយក៏លេងតាមកាល តាមសម័យដែលគួរលេង តាមប្រក្រតីមានលេងតែក្នុងព្រះរាជពិធីធំៗ របស់ស្តេចដែនដី អ្នកក្រៅមិនដែលឃើញមានលេងទេ ។

រឿងអវិទូរនោះ មានជល់៧ ១០ រឿង, ៩ រឿងខាងដើមជារឿងដែលមានរួចមកហើយ នៅ១ រឿងខាងចុងចំជុតថា ខ្ញុំមានមកកន្លងអតីតកាល ក្នុង ១០ រឿងនោះពាក់រឿងកមកេរ្តិ៍ឮលមួយថាជារឿងព្រះអវិទូរ រឿងនេះកន្លែប្រទេសកម្ពុជាមានតេចេះដឹងដោយច្រើន រឿងឯទៀតជារបស់កំចិកំចាំង មិនសូវមានអ្នកណាចេះដឹង ហេតុនោះ តែកាលណាត្រូវលេងល្បែងទោល គេក៏លេងតែរឿងកមកេរ្តិ៍នោះឯង ក្នុងរឿងនោះមានតាំងមនុស្ស តាំងយក្ខ តាំងស្វា ៣ សាសន៍ផងគ្នា, ពួកអ្នកលេងអំបាលនោះក៏តោងហាត់ក្បាច់លេងផ្សេងគ្នា តាមភាពរបស់អ្នកតាំង ៣ សាសន៍នោះ គឺអ្នកដែលត្រូវធ្វើជាមនុស្ស (រួមតាំងទេវតាផង) ក៏ហាត់តាមលំនាំក្បាច់កំក្នុងបរិច្ឆេទទី ២ ដែលគោលមកហើយ អ្នកដែលត្រូវធ្វើជាយក្ខនិងស្វា ក៏ហាត់ក្បាច់តាមភាពយក្ខនិងស្វាផ្សេងទៅទៀត ក្បាច់តំបែបនេះ មិនដែលច្រទេះឃើញក្បួខ្នាតដើមដែលជាឫសគល់នោះទេ ជាមានដូចម្តេចខ្លះ ប៉ុន្មានបែប ប៉ុន្មានយ៉ាង មិនច្បាស់ផ្ញើឲ្យហាងតំណែងតាស្រែយសិក្សាត ។ មកដល់សព្វថ្ងៃនេះ តែតាមដែលរួបរួមកន្លងមកនេះ ឃើញក្បាច់យក្ខមាន . . ប៉ាង ក្បាច់ស្វាមាន . . . យ៉ាង ដូចមានតទៅនេះ ។

ក្បាច់ស្មោនខោល ក្បាច់យក្ខ

ក្បាច់ទសកំណ្ឌបេញស្តីរាជការទី ១

របៀបបង្គុយ - ទសកំណ្ឌខ្នង់ត្រឿងពាក់ផ្សេពេញយស អង្គុយលុត ជង្គង់លើព្រះរែង ដៃចាំងពីកាន់អាវុធរូបនាគបុងដើម មុខខ្នង់ដើមស្មើនឡើងបន្តិច ជាកិរិយាសំដែងអាទុកភាតដ៏ឃោរឃៅ ។

ក្បាច់ទសកំណ្ឌបេញស្តីរាជការទី ២

របៀបបង្គុយ - ទសកំណ្ឌខ្នង់ត្រឿងដូចមុន អង្គុយបញ្ឈរជង្គង់ខាងស្តាំ ខ្នែត្រចៀងទៅខាងធ្វេងបន្តិច ដៃស្តាំកាន់អាវុធរូបនាគ ជាក់ដៃគងលើជង្គង់ស្តាំ ឲ្យពុងដៃនឹងជង្គង់ស្មើគ្នា, ជាកិរិយាសំបើម ។

ក្បាច់ទសកំណ្ឌបេញស្តីរាជការទី ៣

របៀបបង្គុយ - អង្គុយតាមអរិយាបថដូចទី ២ ប៉ុន្តែកែរផ្លឹងក្បាលទៅខាងស្តាំបន្តិច ដៃកាន់អាវុធជាក់គងលើជង្គង់ស្តាំ ត្រង់ពាក់ចណ្តាលកំភួនដៃ ។

ក្បាច់យក្ខ ទី ១

របៀបរាំ - ឈរជ្រុះជើងធ្វេងទៅមុខយ៉ាងពេញជំហាន បង្ហើបមេជើងឲ្យតាំងឡើងលើ ដៃធ្វេងលើកពេញទៅមុខ - ចេដៃចំបត់មកចុងបាតដៃ, ដៃស្តាំដាក់ទៅស្តាំ កាន់អាវុធបញ្ឈរគេលំឡើងលើ ។

ក្បាច់យកចុ ទី ២

របៀបធ្វើ — ឈរបង់ជំនែងក្បែរកន្ត្រង់ចេញចាំងសងខាង ចំអើតខ្លួនចេញទៅស្តាំខ្លះ ទៅឆ្វេងខ្លះ ដៃស្តាំកាន់អាវុធពាក់កណ្តាលលើកងាខ្សែន, ដៃឆ្វេងដាក់ចុះក្រែមបំពត់ខ្នងដៃបួលកន្ត [ ]មួចង្កុលដៃចង្កុលចំមករកភ្លៅឆ្វេងរបស់ខ្លួន ។

ក្បាច់យកចុ ទី ៣

របៀបធ្វើ — ដូចគ្នានឹងបែបទី ២ ក្រៃតែដៃឆ្វេងផ្ងារចាកដៃចេញ ឲ្យ[ ]មួចដៃចុះក្រែម ។

ក្បាច់យកចុ ទី ៤

របៀបធ្វើ - ឈរបង់ជំនែងពេញទំ ជន្តន់ចាំងពីរវាតចេញទៅខាងចាំងសងខាង, ជនខ្លួនតាំងត្រង់, ដៃឆ្វេងលើកខ្នងសំហុចទៅឆ្វេង ផ្ងារចាកដៃ ឲ្យ[ ]មួចដៃចាំង ៤ សំយុងចុះក្រែម មេដៃចំពត់ខ្ទង់ចាកដៃ, ដៃឆ្វេងឈរអាវុធត្រង់ពាក់កណ្តាលយកមកផ្ងារទៅពោះ ។

ក្បាច់យកចុ ទី ៥

របៀបធ្វើ - ឈរបង់ជំនែងពេញទំ ជន្តន់ចាំងពីរវាតចេញទៅឆ្វេងទៅស្តាំ ជនខ្លួនទៅមែតមុខចាំងស្តាំបន្តិច មុខមើលឆ្វៀងទៅឆ្វេង, ដៃ

ធ្វេនលើតខ្ពស់ ហុចទៅធ្វេន ដួចក្បាច់ទី ៤, ដៃស្តាំកាន់អាវុធត្រង់ពាក់
តណ្តាលឲ្យខាងឆ្វេងលើ ហើយលាតត្រង់ចេញទៅស្តាំ ។

ក្បាច់យកុទី ៦

របៀបកំ - ឈរចង្អឹងដួចក្បាច់ទី ៥ តែបញ្ចប់ដង្កត់ធ្វេនឲ្យញោច
ទៅខាងធ្វេនបន្តិច, ដៃធ្វេនលើតពាទៅធ្វេន តែឲ្យខ្ចោមដៃតមកក្រោយ,
ដៃស្តាំកាន់អាវុធត្រង់ពាក់តណ្តាល ឲ្យតល់ចុះក្រោម លើតយារទៅ
ស្តាំ ។ មុខទើយលែបក្រឡេងមើលផ្លាយ ។

ឧសភាណ្ឌចូលឧទ្យាន

របៀបតែងខ្លួន - តែងពេញយសដួចមុន តែគ្មានកាន់អាវុធ ទៅជា
កាន់ផ្តិតក្រជាសដំនួស ទីនប្រជាប់ដោយផ្កាក្រនៈនាដៃស្តាំ តែបៀន
ស្តាំបន្តិតមាសំយោគជាយទាំងពីរទៅក្រោយ សំដែងកិរិយោសប្បាយ
រីតរាយ ។

ឧសភាណ្ឌកំ

ក្បាច់ផងជាយ ទី ១

របៀបកំ - តែងខ្លួនដួចភាលចូលឧទ្យាន តែគ្មានកាន់ផ្តិត, ដំបូងចេញ
មក ដៃពាំងពីរដ្ឋឹមបង្កើះ ។

ឧសភាឈ្នាំ

ក្បាច់ជាជាយទី ២

របៀបធ្វើ- ឈូងជាជំហរយក្ស តែឈរបង់ដំណែង តែបន្ទោរដង្គង់ខាងឆ្វេងបន្តិច ដៃឆ្វេងដាច់ម្រាមពីរ ដាក់ប្រទល់គ្នានឹងដៃស្តាំ ពីខាងមុខដៃស្តាំនោរត្បៀតផ្ងួតផង ។

ឧសភាឈ្នាំ

ក្បាច់ជាជាយទី ៣

របៀបធ្វើ- ឈូរដោរបាដើងស្តាំ ដើរឆ្វេងលើកខ្ពស់, ដៃខាងពីរលើកហុចត្រង់ទៅមុខ នឹងដាច់ម្រាមពីរទាំងសងខាង តែដៃស្តាំនោរត្បៀតផ្ងួតផង ។

ឧសភាឈ្នាំ

ក្បាច់ជាជាយទី ៤

របៀបធ្វើ- ឈូរដោយដើងស្តាំ បន្ទុំនង្គង់ទៅមុខបន្តិច, ដើងឆ្វេងលើកខ្ពស់ សំយុងចុងដើងចុះក្រោម ដៃឆ្វេងត្រង់ចេញទៅឆ្វេង ដាច់ម្រាមពីរខ្សែនលើ ម្រាមឯទៀតលាក្រញាងចេញ, ដៃស្តាំចោះទៅក្រោយឲ្យចុងដៃសណ្តាក់ចុះខាងបន្តិច ដាច់ម្រាមពីរ នឹងត្បៀតផ្ងួតផង ។

ឧសភាណ្ឌកំ

ក្បាច់ជជាយទី ៥

របៀបកំ - ឈរឈោងដើងធ្វេងទៅមុខ, ជង្គង់ខ្លួនបក្កោរទៅមុខរកៀង ធ្វេងបន្តិច ដៃធ្វេងធ្វើក្រពុំងចេញទៅមុខ ដៃស្តាំចោះទៅក្រោយ ត្បៀតដូចបក្សារឡើង ចាំងរំសាយដូចឲ្យលាចេញផង (១) ។

ក្បាច់ក្ងេងស្រស

របៀបកំ - ឈរបន្ទន់ជង្គង់ចេញទៅខាង បុងដើងចាំងពីរកែបំបែរចេញទៅខាង។ ដៃចាំងពីរលើកវៀងចេញទៅ ហើយបំពត់បុងដៃមកពេញខ្លួន, មុខទ្រេតធើយបន្តិច ក្នុងរណៈនេះ ខ្នែងដើងចាំងពីរដែង ។ (រលោនោះក្ងេងនីងរៀបបទលេងឲ្យស្រស) ។

ឧសភាណ្ឌសោភ

- របៀបនរិយាបថ - អង្គុយបត់ជង្គង់ធ្វេងជាក់កាច បញ្ឆេជង្គង់ស្តាំ ដៃស្តាំជាក់តងលើជង្គង់ស្តាំ ហើយចាប់កាន់ដៃធ្វេង បន្ទន់ក្បាលទៅខាងស្តាំធ្វើរលៀង សំដែងកិរិយាខុក្ខសោភ ។ អាវុធជាក់ខាងខ្លួន ។

មេក្បាច់ធំ រមស់ក្បាច់យកក្ខមានតែប៉ុណ្ណេះ រលោកំគោងកំពៅជាលំនាំផ្សេង។ ដើម្បីភ្ជាប់តទៅក្បាច់ ១ ទៅក្បាច់ ១ ត្រង់កន្ទែងខ្លះកំយាត

---

១ ឲ្យតាមលក្ខានទៅវើ មិនដាស់កាន់ប៉ុណ្ណាន គោះបីភានតាន់កំបាន មិនមានកំបាន ខស់កាន់ទៅត្រង់ក្បាច់កំ ។

ក្បាច់កំរបស់មនុស្សនោះទៅកំផង ត្រង់ខន្ធែនដែលសំខាន់ៗទើប
បញ្ចេញក្បាច់យកតែពេញចិ ។

* * *

អធិប្បាយក្បាច់ស្វា

អ្នកដែលត្រូវធ្វើជាស្វា គេតែងខ្លួនចំនងជាស្វាធំឯកាកម្មុខរូបស្វា
ជាស្វាសឬស្វាទៀ គោធ៍ស្មៀតពាក់តណិតាមនោះ បើជាស្តេចស្វា
គោធ៍មានពាក់សង្វាផង ។

ក្បាច់ស្វាទី ១

របៀបធំ - ឈរបង់ចំខែងពេញចិ បន្ទុំដង្គងំធ្យេញទៅខាងមុខ
បន្តិច ខ្លួនចំអើតចេញទៅមុខធ្វើងស្តាំ ដៃស្តាំពាន់អាវុធខ្លី តាំងត្រីសូល
ឬដំបងខ្លី ឲ្យបុងចុះក្រោម ។

ក្បាច់ស្វា ទី ២

របៀបធំ — របៀបដំហរដូចទី ១ ប្តូរតែដៃធ្វេងលើកលាតចេញ
ទៅមុខ ហើយចំបង់ដៃចូលមកនឹងដើមទ្រូងវិញ ដៃស្តាំកាន់អាវុធជាប់
ពីមុខត្រង់រវាងនោះ ចំបង់ដៃចុះក្រោម ឲ្យបុងអាវុធឡើងលើ តែឲ្យ
នៅពីក្រៅដៃ ។

ក្បាច់ស្វាទី ៣

របៀបធ្វើ — តំរិយោជំហរដូចមុន ប្តូរតែដៃធ្វេងត្រែតចុះត្រែងរកដី តាក់ចណ្តាលក្បៀ ដៃស្តាំកាន់អាវុធលើកងាកឡើង ឲ្យចុងអាវុធចុះស្របតាមដៃ ។

ក្បាច់ស្វាទី ៤

របៀបធ្វើ - តំរិយោជំហរដូចមុន ប្តូរតែដៃធ្វេងជាក់ផ្ងារចេញទៅមុខ តែឲ្យចុងដៃតាចុះ ដៃស្តាំលើតងាឡើង ឲ្យចុងអាវុធឡើងលើ ។

ក្បាច់ស្វាទី ៥

របៀបធ្វើ - តំរិយោជំហរដូចមុន ប្តូរតែដៃធ្វេងលើកខ្ពស់ចេញទៅមុខ ត្រមាមដៃធ្វើបែបជាមាត់ស្វាហា ។

ក្បាច់ស្វាទី ៦

របៀបធ្វើ - តំរិយោជំហរនឹងលើតដៃដូចមុន ប្តូរតែតដៃធ្វេងចាត់ចូលហើយដាច់ត្រមាមពីរ ។

ក្បាច់ដើត

របៀបធ្វើ — ក្បាច់នេះដូចគ្នានឹងក្បាច់ទី ៥ ប្តូរតែក្បាច់នេះដៃធ្វេងជាត់ត្រែងស្មើចេញទៅមុខ ។

ក្បាច់មើលចំហៀង

របៀបធ្វើ — ឈរវិញចដើនចេញ បញ្ចាំជង្គង់ចេញទៅឆ្វេងទៅស្តាំ ខ្ជូនអើត មើលទៅចំហៀងខាងឆ្វេង, ដៃឆ្វេងធ្វើជួចក្បាច់ដី ៥, ដៃស្តាំឈរនាវុធជាក់ពីមុខក្បាល ឲ្យពុងចេញទៅក្រៅ ។

ក្បាច់ស្វាលង់ទ្រនេស

របៀបធ្វើ – ដើរចេទ្ធំជង្គង់ ដៃឆ្វេងជាក់លើជង្គង់ឆ្វេង ដៃស្តាំយួរខ្សែន ខ្ជូនផ្តៀង បត់ចស្លៀក ជាក់រយោអស់កំឡាំងល្អិតល្អៃ ។

ក្បាច់គម្រាម

របៀបធ្វើ – ដើងឆ្វេងចោះទៅមុខ បញ្ជាដង្គង់ខ្សែន ដើងស្តាំសណ្តូតត្រង់ទៅក្រោយ ដៃទាំងពីរជាក់គ្រាបលើជង្គង់ឆ្វេង ខ្ជូនអើតទៅលើជង្គង់ឆ្វេងនោះ។

ក្បាច់ធក់

របៀបធ្វើ — អង្គុយចំគោត ដៃឆ្វេងយួរជាក់ពីមុខ ដៃស្តាំលូកទៅខាងស្តាំខ្ជូន, មួលខ្ជូនជាកមើលទៅឆ្វេងត្រឿនខាងក្រោយ ។

ក្បាច់លប

របៀបធ្វើ — ដើងឆ្វេងចោះទៅមុខ បញ្ជាដង្គង់ដើងសណ្តូតទៅក្រោយ ដៃមុខត្រឿនទៅឆ្វេង ដៃទាំងពីរយួរជាក់ពីមុខ ជាអាការស្មាតែនភ្ជាប់ធ្វើជួច្នោះ ។ ចប់ក្បាច់ល្ខោនទៅស ។

វគ្គទី ១

អ្នកឧកញ៉ាវិបុលរាជសេនា (ស្នូរ-កន)

ប្រែពីរឿនសាមកុក ភាសាសៀម

(ត្រកូល)

គ្រានោះ ស្រុកឆេងដាវ១ អីដាវ១, ឈៀដាវ១, កេងដាវ១, ឃាំង-ដាវ១, តុនដាវ១, គីដាវ១, គ្រប់ក្រុងឲ្យ, ពួកអ្នកស្រុកចាំង ៨ តំបន់នេះ ក៏មានសារសេរយក ឈ្មោះគឿកកុកជាទីសក្ការបូជាគ្រប់ៗឆ្នាំ, ទើប គឿកកុកប្រើឈ្មោះមាំអួនយីឲ្យយកមាសប្រាក់ទៅជូនហង់ស៊ុនទ្ធីដែលជា តំណាន់ទៃគ្រនៃខ្លួន, ហើយឲ្យមាំអួនយីនិយាយដាក់បជាអាចិត្តជាមួយហង់ស៊ុនទ្ធីថា "គឿកកុកជូនបេះនេះមក សុំឲ្យហង់ស៊ុនទ្ធីជួយធ្វើការជាកលសឹកកងទ័ពក្រុង" រួចហើយ គឿកកុកក៏ប្រជុំបងប្អូនប្រុសទាំងពីរនាក់ពន្យល់សេចក្តីថា "បើនឹងគិតការអ្វីៗ ត្រូវឲ្យយកចិត្តបណ្តាក់ស្តាជាប្រមាណ ដ្បិតឥឡូវនេះបណ្តាអ្នកស្រុកចាំង ៨ មណ្ឌល ក៏កប់អាន ស្រឡាញ់នៅក្នុងទុក្ខស្តាប់បង្គាប់យើងអស់ហើយ បើបានការព្រម ព្រៀងដូច្នេះ គប្បីយើងត្រូវតែគិតយកដែនដី, ប្រសិនបើយើងមិនអើ តើកងវេលានេះទេ ក៏នឹងមានសេចក្តីស្តាយនៅថ្ងៃក្រោយ" ។ ប្អូនប្រុស ទាំងពីរនាក់ក៏យល់ព្រមផង ទើបគឿកកុកឲ្យបញ្ជូនបញ្ជាលទៅ ព្រម

ដោយគ្រឿងសស្ត្រាវុធគ្រឿងប្រើប្រាំការ ដល់កំណាត់ចេញច្បាំងវេលាណាទើបបានចាត់ការដោយស្រួល ។

គឿវកុកប្រើសិស្សម្នាក់ឈ្មោះតន់ដីឲ្យឈ្នះសំបុត្រសម្ងាត់ឲ្យទៅជូនហង់ស៊ីវ៉ន្នី, ឯតន់ដីវិមិនបានយកសំបុត្រនោះទៅជូនផ្ទាល់ហេង់ស៊ីវ៉ន្នីក៏យកទៅជូននាហ្មឺនឯទៀត ឲ្យថ្វាយព្រះចៅឡេនតៃវិញ ព្រះចៅឡេនតៃជាបសេបក្តី ទើបគ្រាស់ប្រើឲ្យហោជិនជានាហ្មឺនធំលើតតន់ទីតទៅចាប់មាំអួនយើដែលជាអ្នកនាំបណ្តាការទៅជូនហង់ស៊ីវ៉ន្នីនោះសម្លាប់ចោលទៅ ហើយចាប់ចាំងហង់ស៊ីវ៉ន្នីជាក់គុកខុកទៀត ។ លុះគឿវកុកដឹងដំណឹងដូច្នោះ ក៏ចាត់ការគ្រឿមសេនាពាហនទុកព្រម, ហើយតាំងខ្លួនជាសៀនកុងបុងគុន (ប្រែថា ស្តេចសួគ៌), តាំងដៀវប៉ាប្អូនបង្អាប់ជាគេកុងបុងគុន (ប្រែថា ស្តេចផែនដី), តាំងគ្រឿវលៀង ជាប្អូនទៅ ជាយិនគុងបុងគុន (ប្រែថាស្តេចមនុស្ស), ហើយគឿវកុក ក៏ស្រែកប្រកាសប្រាប់សេនាពាហនទាំងបណ្តាកស្តេចតាំងពួងថា ជាការផែនដីនៃព្រះចៅឡេនតៃ ខ្ញុំដឹងនាសសាបសូន្យអស់ហើយ។ មានអ្នកមានបុណ្យមកសោយរាជសម្បត្តិជាថ្មីទៀត អ្នកតាំងអស់គ្នាចូរធ្វើតាមពាក្យទៅតាំនាយចុះទើបបានសេបក្តីសុខសប្បាយដោយមួលមិត្តគ្នា ។ បណ្តាកស្តេចតាំងពួងឮហើយ ក៏មានសេចក្តីត្រេកអរយ៉ាងដូច្រៃលែង, គឿវកុកឲ្យយកសំពត់ពណ៌លឿង ជូតក្បាលតាំងអស់គ្នាជាសំគាល់ប្រមាណជាសែសិបឬហា-

សិបម៉ឺនតាក់ ដែលជាពួកគង់របស់តៀកកុក, ហើយតៀកកុកនឹងសេនាធិបតីទាំងនោះ ក៏ព្រមចិត្តគ្នាធ្វើជាចោរ ឧន្នឹងកងអ្នកឯណាតទល់នោះគ្មាន ក៏តែងមានកំឡាំងច្រើនឡើង ។

ហោជិនឃើញហេតុដូច្នោះ ក៏នាំយកសេចក្តីនោះទៅក្រាបបង្គំទូលព្រះចៅខ្សែនគេ ។ ជាបហើយ ទើបគ្រាស់ឲ្យយកព្រះពជ្រាវប្រាប់ទៅគ្រប់ទៃត្រាំងអស់ថា "បើអ្នកឯណាមានថ្លៃដៃខ្លាំងតូចកែចាប់ពួកចោរជួតក្បាលលឿងបាន ឧន្នឹងឲ្យបំណាច់ភ្នំនាំធ្វើជានាម៉ឺនមានយសសក្តិតាមថ្នាក់តុណានុរូប" ទើបគ្រាស់ប្រើបុរីឲ្យនំជៀតោហានឯក ១, ខ្សែជិន ១, ហាំហ៊ីសុង ១, ដូហ៊ី ១, ឲ្យលើកពលចេញទៅជា ៣ ចែក ដើម្បីតាមចាប់ខ្លួនតៀកកុកឲ្យបាន ។ ឯតៀកកុកក៏លើកតាហានទៅតំឡុំនៅបុនដែនស្រុក អិរដើរ; ខ្សែអៀនចៅបក្សាយស្រុកអិរដើរនោះ ជាពួកអ្នកស្រុកកាំនមៃជាប់លោហិតតវ៉ែ្ស ខឹងហានកូប ជាចៅឡាំងបុនហាន់, គាលបើដឹងដំណឹងថា "ពួកចោរជួតក្បាលលឿង លើកគ្នាមកវាយបុនដែនស្រុកអិរដើរដូច្នោះ ក៏ឲ្យហៅចៅចេងជាតាយតាហានមកពីគ្រោះប្រឹក្សា, ចៅចែងថា "ពួកចោរមានកំឡាំងក្លាហានណាស់តាហានស្រុកយើងតិច គួរឲ្យមានសំបុត្រទៅបញ្ជុះបញ្ចូលពួកអ្នកស្រុក ដែលនៅបុនដែនសិន បើអ្នកឯណាថ្លាំងតូចកែមានថ្លៃដៃចាប់ពួកចោរចាំងនោះបាននឹងខ្លួនស្មើសេចក្តីតាប់ប្រសើរនោះដល់ព្រះចៅខ្សែនគេ" ។ ខ្សែអៀនក៏

ឃល់ត្រម ទើបឲ្យធ្វើជាសំបុត្រចញ្ចុះចញ្ចូល យកទៅបំពេញនៅមុខ
ច្រកត្រង់ស្រុកត្រង់វែកត្រង់ជាន់អស់ ។

នៅស្រុកខុនគួន មានបុរសម្នាក់ឈ្មោះខ្ញុំ)ត៉ា កាលត៉ាកុមារឈ្មោះ
ហៀនតាក ជាអ្នកមិនសូវសង្វាតរៀនសំបុត្រស្នាមអ្វីនឹងគេ តែជាអ្នក
មានគម្រិះថ្លាឆ្លាវច្រើន ចិត្តក៏ល្អ សូម្បីមានសេចក្តីត្រូវការយ៉ាងណាក៏
មិនគាចនរណាដឹងបាន ព្រោះគ្មានភេការបញ្ចេញទៅខាងក្រៅ ឲ្យគេ
ដឹងច្បាស់ដោយសោះ, មានកិរិយាសុភាពរាបសា មានចក្ខុភ្លឺរកច្រើន មាន
សន្តានចិត្តជាអ្នកខ្ជិលយ ចាំនរូបកនិសោតកំណត់ដំបងនិងជាងមនុស្សច្រើនពួន,
ច្រកចរដោយឈ្លក់ណារូបធំខ្ពស់ស្រឡះប្រមាណជា ៥ ចាតឬយ តែចៀង
សន្ធឹងយាវដល់ស្មា ដៃវែងសំយុងចុះគ្រាមយាវដល់ក្បាលជង្គង់ មុខ
សក្បូសដូចពណិថ្មកែវ ចមួរមាត់ក្រហមដូចជាតិហិង្គុល ក្អែកចាំងគួរមើ
ជាកទៅខាង មើលឃើញត្រចៀកខ្លួនឯង ។

ខ្ញុំ)តីនោះជាបុត្រខ្ញុំ)ហេង។ជាពូជព្រះវង្សព្រះថៅហាន់កេង:ត
លុះខ្ញុំ)ហេងជាបិតាអនិច្ចកម្មទៅ ខ្ញុំ)តីក៏នៅតំណែតតីរនាក់នឹង
ខាងា, ខ្ញុំ)តីជាមនុស្សមានសេចក្តីកតញ្ញូ បេះថែរក្សាមាតាមិនឲ្យមាន
ហ្មង តែជាអ្នកឧត្តរិព្យសម្បត្តិ តស្សាញតែកន្ទុលលត់ចំញ្ញឹមដរាល ។ ខ
លំនៅដែលខ្ញុំ)តីនៅនោះឈ្មោះភូមិ:ខ្ញុំ)សង៌ឈុន នៅជិតស្រុកខុន.

ភ្លួន, ផ្ទះដែលខ្ញុំតាំងនៅៗ ជិតរំដើមមន។ នោះមានកំពស់ប្រមាណជា ៨ ឫមក្ងាយ មានមែកត្រសុំសាខាជួបគ្នា ។

គ្រាមួយមានត្រីម្នាក់ដើរមកឃើញកូមិផ្ទះខ្ញុំតាំងដើមមនត្រង់ធំ តម្រាខ្លួន ក៏ចំនាយថា "កូមិនេះមានអ្នកមានបុណ្យនៅ, រៀលនោះខ្ញុំតាំងនៅតូបនៅឡើយ ពេលដែលខ្ញុំតាំងលេងជាមួយនឹងក្មេងតូចៗជួបគ្នាតែងស្រដីជា "បើអញបានធ្វើស្តេច អញនឹងយកដើមមននេះធ្វើជាសួតបួតែប៉ុន" ខ្ញុំតាំងអួតគឺជាអាបានឮខ្ញុំតាំងនិយាយដូច្នេះក៏សំគាល់ខ្ញុំតាំងថា "តួយអញនេះថ្ងៃមែលជាមានបុណ្យធ្លាក់ដល់មែន" ចាប់តាំងពីពេលនោះមក ខ្ញុំតាំងអួតគឺជាមានចិត្តបំរុងឲ្យមានស្រឡាញ់ដល់ខ្ញុំតាំងជារឿយៗ ។ លុះកុមារខ្ញុំតាំងអាយុបាន ១៥ឆ្នាំ មាតាឲ្យទៅនៅរៀនអក្សរនឹងត្រីម្នាក់ឈ្មោះតេហៀន, ខ្ញុំតាំងមានសំឡាញ់ឆ្នាក់ឈ្មោះខ្ញុំតាំងទិត១, ឧឆ្ងស៊ុនចាន ១, នៅរៀនអក្សរជាមួយគ្នាដរាបដល់តែងដល់អាយុ ២៥ឆ្នាំ ។

ខណៈនោះ ខ្ញុំតាំងដើរចេញទៅបានឃើញសំបុត្រដែលគេបិទនៅក្បាលទ្វារស្រុកក៏ឈរមើល។ ហើយដងដងថ្ងៃមធំ, ពេលនោះមានមនុស្សម្នាក់ឈរពីក្រៃយខ្ញុំតាំង ពោលថា "យី! អ្នកឯងនេះជាតិជាប្រុសត្រង់ឆ្ងាំង, ម៉េចក៏មិនជួយឯកអាសាដែនដី? ហេតុអ្វីហ៊ានក៏មកឈរដងដងធំដូច្នេះវិញ" ខ្ញុំតាំងពីបែរមុខទៅឃើញមនុស្សនោះឈរពីក្រៃយ

រូបកន្ទឹធំដំបង កំពស់ ៥ ហត្ថ ក្បាលដូចក្បាលខ្លា ភ្នែកក្រែលោតធំៗ ឆ្អឹមរឹតធំ សំឡេងឮដូចផ្គរ គំរើយដូចរន្ទេះផ្ទាយ ។ ខ្មៅ)ពីរយើញចំឡែកដូច្នោះ ក៏សួរថា "អ្នកឯងឈ្មោះអ្វី?" មនុស្សខ្មោះឆ្លើយថា "យើងឈ្មោះតៀហ៊ុយ អេកតិក នៅស្រុកបុងគុន, យើងមានទ្រព្យសម្បត្តិនឹងរៃចំការជាច្រើន មានចាំងកងលក់សុកនឹងសាច់ឱ្យតផងដែរ យើងតាប់ចិត្តនឹងរតគប់នឹងមិត្រភក្តិណាដែលមានសតិបញ្ញាច្រើន, ដល់ឥឡូវនេះ យើងបានមកឃើញអ្នកឈរមើលសំបុត្រហើយដកដង្ហើមធំ នាំឱ្យយើងពិការល់ក្នុងចិត្តពេកណាស់ ទើបយើងសួរអ្នកចង់ដឹងសេចក្តី ។ ខ្មៅ)ឆ្លើយថា "យើងជាភូតព្រៃវែង្រព្រៃរៅហាន់តេងតេឈ្មោះខ្មៅ)ពីបានឮដំណឹងថា មានពួកចោរដួតក្បាលលឿងមកធ្វើឱ្យអន្តរាយដែនដី ទើបយើងចង់ជួយយកការដែនដី ដេញចៅកំពប់ពួកការចោរចាំងនោះ តែនឹងលុះចៅមិនរួចដោយកំឡាំងតិចទ្រព្យសម្បត្តិក៏ស្ពប់ស្តើង យើងតិតចៅមិនសម្រេច ទើបឈរដងដង្ហើមធំដូច្នេះ" ។ តៀវហ៊ុយឆ្លើយថា "ទ្រព្យសម្បត្តិយើងឯណោះមានត្រៃប់ត្រាន់ល្មមហើយ, ដូច្នេះយើងតិតនាំគ្នាចៅបញ្ចុះបញ្ចូលពួកអ្នកស្រុកដែលមានថ្លៃដៃពូកែ ។ ឱ្យលើកគ្នាចៅជួយព័ទ្ធចាប់ពួកចោរកំណាចចាំងនោះ, តើអ្នកយល់ថាដូចម្តេច?" ខ្មៅ)ពីឆ្លើយថា "គំនិតដែលអ្នកតិតនេះត្រូវពិតមែនហើយ តាប់ចិត្តយើងពេក

ណាស់ ដោយតំនិតនេះត្រូវនឹងតំនិតយើង· រួចក៏ជជែកលាបពូលទៅក្នុង
គៀមសុកចិញសុកផឹកជាមួយគ្នា ។

ខណៈនោះ មានមនុស្សម្នាក់ចូលកន្លែងជាតំណែងសម្រាប់ជជែកមកឈប់
នៅមុខគៀមលក់សុក ហើយស្រែកហៅអ្នកលក់សុកថា "ចូរអ្នកយកសុកមកលក់ឲ្យយើងនាប់។ យើងនឹងនាំគ្នាផឹកចូលទៅជួយយកតាសាផែនដី" ខ្លាចតែជាកទៅយើញមនុស្សនោះរូបកាយធំដុំចង់ កំពស់ ៦ ហត្ថពុក-ចង្កាប្រវែង ១ ហត្ថក្បាយ មុខក្រហមដូចផ្លែពព្រាទុំ ចប្លុមាត់ក្រហមដូចជាតិហិង្គុល ចិញ្ចើមដូចកូនខ្នាង (សត្វខ្នាង) ភ្នែកវែងដូចភ្នែកសត្វក្រពើ តិរច្ឆានុស្សភ្លែតតែមនុស្សធម្មតា, ខ្លាចតែយើញដូច្នោះក៏ចប្លុលឲ្យចូលទៅផឹកសុកជាមួយគ្នាហើយសួរថា "អ្នកឈ្មោះអ្វី?" មនុស្សនោះឆ្លើយថា "យើងឈ្មោះកូនអ្វី ខ្លះហៅថាហ៊ុនតៀង, នៅស្រុកហត្ថរតនៈលឿង នៅស្រុកនោះមានមនុស្សម្នាក់មានឫទ្ធិឫសម្បត្តិច្រើន ប៉ុន្តែកាលណាសំតែងតែកំហែងមនុស្សទាំងភូមិឲ្យតេរោតខ្លាចខ្លួន, យើងយើញហេតុការក្រក់ដូច្នេះក៏សម្លាប់វាចោលទៅ, យើងរត់មកនៅស្រុកនេះស្រុកនោះជាច្រើនដងទំហើយ ឥឡូវយើងទើបនឹងបួលមកដល់ស្រុកនេះបានឮជំណឹងថា មានគេចិញប្រគាសបញ្ចុះបញ្ចូលពួកអ្នកស្រុកឲ្យទៅជួយយកតាសាផែនដីចាប់ពួកចោរផ្លូតក្បាលលឿន, ហេតុនេះបានជាយើងមកដើម្បីជួយយកតាសាធ្វើដារនេះ ។

ខ្ញុំ)ពីតបថា "មែនហើយ! យើងចាំងពីនាក់នេះក៏កំពុងតែក្រិះគិតដូចអ្នកដែរ បើយើងចាំង ៣ នាក់មានគំនិតគិតត្រូវគ្នាដូច្នេះឈ្មោះថាជាការប្រពៃពេកណាស់», ក្មួនអ៊ូបានឮដូច្នោះ ក៏មានសេចក្តីពេញចិត្តឥតខ្នើស, គៀវហ៊ុយឆ្លើយថា "យើងចាំង ៣ នាក់មានគំនិតគិតត្រូវគ្នាដូច្នេះ ខ្ញុំសូមអញ្ជើញអ្នកចាំងពីរទៅផ្ទះខ្ញុំ, នៅក្រោយផ្ទះខ្ញុំមានសួនច្បារជាទីសប្បាយណាស់ ហើយជាកន្លែងស្ងាត់ផង ចាំងផ្កាយថ្ងៃក្តៅ ក៏មានម៉ែកនៅទីនោះជាច្រើន យើងនឹងបានចេះបួងាព្រះខួរខ្ពស់ ហើយនឹងបានឲ្យសច្ចប្រណិធានដល់គ្នាឲ្យជាចិត្ត ១ ថ្លើម ១ ជាមួយគ្នា នឹងបានគិតគូរការងឹតៗ ។ ខ្ញុំ)ពីនឹងក្មួនអ៊ូ បានឮដូច្នោះមានសេចក្តីត្រេកអរណាស់ ទើបបបួលគ្នា ដើរតម្រង់ទៅកាន់ផ្ទះគៀវហ៊ុយ ។

ព្រឹងឡើងគៀវហ៊ុយក៏រៀបចាត់ចែងយកសេះសនឹងក្របីភ្ជួរឲ្យជួបខ្នែង មានចាំងត្រឹងពូកាអាម៉ាសផ្សែងៗ នាំយកទៅជាមួយផង, លុះទៅដល់ទីសួនច្បារគ្រោយផ្ទះ ក៏អុជខ្នែងធូបធ្វើសក្ការបូងាព្រះខួរខ្ពស់ គាំងសច្ចប្រណិធានថា ×"យើងខ្ញុំឈ្មោះខ្ញុំ)ពី, ក្មួនអ៊ូ, គៀវហ៊ុយ ចាំង ៣ នាក់នេះ នៅស្រុកទេសផ្សេងៗ ពីគ្នា រៀលាថ្ងៃនេះបានមកឥប្រែសពគ្នា, យើងនឹងបានគាំងចិត្តឲ្យសត្យសញ្ញាដោយសច្ចប្រណិធានសច្ចថសច្ចានសុំយកគ្នាធ្វើជាបងប្អូនហាក់ដូចជាបងប្អូនរួមឧទរជាមួយគ្នាជាចិត្តដ៏រឹត ១ សុំឲ្យមានសេចក្តីខ្នែងត្រង់ដល់គ្នានឹងគ្នាគ្រា

តែគេសុំជីវិតរៀងខ្លួន ដើម្បីទីនឹងបានជួយទំនុកចំរុងដល់ផនដីឲ្យបានសេចក្តីសុខតទៅ, បើមានភ័យអន្តរាយដោយប្រការឯណាមួយត្រូវឲ្យជួយយកអាសាដល់គ្នាទីនឹងគ្នា សូមឲ្យមានបារមីឫទ្ធិសក្តិសិទ្ធិក្នុងសច្ចាមក្តីមិនលះបង់ចោលគ្នាឡើយ តើត្រូវតែជួយការពារគ្នាដោយបាលតែស្មើគ្នាទាំង ๓ នាក់, រីសេចក្តីសច្ចាដែលយើងខ្ញុំទាំង ๓ នាក់បានតាំងសច្ចាប្រណិធាននេះ យើងខ្ញុំសូមទទួលសំពោះមុខទេព្តា សូមឲ្យទេព្តាជួយធ្វើជាសាក្សីពេជ្រញាណ បើតទៅយើងខ្ញុំទាំង ๓ នាក់ពុំរៀងត្រង់ទីនឹងគ្នា សូមឲ្យទេព្តាបំផ្លាញជីវិតឲ្យឃើញពិតប្រាកដជាន់កែកនាលោកិយ ។

លុះធ្វើសច្ចាប្រណិធានរួចហើយ គេក៏សន្មតហៅឡៅ)ពីជាបងច្បង, កូនអ៊ូជាប្អូនបន្ទាប់, តៀវហ៊ុយជាប្អូនតូច ។ វេលានោះពួកអ្នកស្រុកដែលភ្ញាក់ពួកៃ ពួកណាបានដឹង ក៏នាំគ្នាទៅចុះបួលនឹងពួកនេះបានប្រមាណជា ๓๐ នាក់ ។

ថ្ងៃមួយឡៅ)ពី, កូនអ៊ូ, តៀវហ៊ុយបានឲ្យរៀបតុលៀងភោជនាហារចាត់ការរៀបចំត្រឿងសស្រាវុធទុកជាស្រេច នៅខ្វះតែសេះជំនិះប៉ុណ្ណោះដែលមិនទាន់មាន ។

គ្រាយពេលនោះបន្តិចមកស្រាប់តែមានបុរសម្នាក់មកប្រាប់ឡៅ)ពីថា "ឥឡូវនេះមានឈ្មួញពីនាក់នាំសេះដោយជើនបួលមកលក់ក្នុងស្រុកនេះ ឡៅ)ពីឮដូច្នោះក៏ស្តុះម៉ីមានបេញ្ញាទៅទូលឈ្មួញសេះទាំងពីរនាក់

នោះនាំចូលមក ឯឈ្មួញសេះពាំងតារនោះ ម្ចាស់ឈ្មោះតៀវស៊ុនផង, ម្ចាស់
ខៀតឈ្មោះខ្លា)សុង, ឈ្មួញពាំងពីរនាក់នេះបានឱយយួបគ្នាប់ខ្លា ពី
ថា " យើងខ្ញុំពាំងពីនេះក់រកស៊ីជួញសេះបានសុខជាយូរឆ្នាំមកហើយ
ទើបតែមកដល់ឆ្នាំនេះ នាំសេះទៅលក់ច្រកនែងនឹងពួកចោរ នៅកណ្តាល
ផ្លូវទៅមិនរួច, ទើបយើងខ្ញុំនាំគ្នាត្រឡប់ចូលមកស្រុកនេះវិញ" ។ ខ្លា)ពី
ស្តាប់ហើយក៏ហៅឈ្មួញពាំងពីនោះឡើងទៅលើផ្ទះ ហើយបង្គាប់
ឲ្យរៀបចំកោជនាហារ បរិភោគពាំងអស់គ្នា រួចទើបខ្លា)តាំងផ្តើមនិយាយ
ឡើងថា យើងគិតនាំគ្នាទៅចាប់ពួកចោរកំណាច ដែលរាត់ធ្វើឲ្យបណ្តាជន
ដល់ដែនដី ។ តៀវស៊ុនផងនឹងខ្លា)សុងស្តាប់ហើយឆ្លើយថា "លោកមាន
ប្រសាសន៍នេះត្រូវនឹងចំណង់របស់យើងខ្ញុំពេកណាស់ ដូច្នេះយើងខ្ញុំពាំង
ពីរនាក់សូមជូនសេះ ៥០, ប្រាក់ ៥០០ ជំនួសនឹងដែក ១០០ ហាបដល់
លោក ដើម្បីជាកំលាំងធ្វើការនេះតទៅ, ចាហើយក៏ជូនបង់ពាំងនោះទៅ
ឲ្យខ្លា)ពីៗបានទទួលហើយ មានសេចក្តីត្រេកអរគុណដល់ឈ្មួញពាំង
ពីរនាក់ជាអនេក, រួចទើបឲ្យកេងាំងមកដំធ្វើជាត្រប៉ះ ៦ ស ម្រាប់កាន់ខ្លួនឯង,
ដំធ្វើជាដាវ ១ ច្រវាន ១១ ហត្ថ ទម្ងន់ ៨២ នាឡិ ឲ្យកូនអ្នកាន់ ដំធ្វើជា
លំពែង ១ ច្រវែង ១០ ហត្ថ ទម្ងន់ ៨៥ នាឡិ ឲ្យតៀវហ៊ុយកាន់ ហើយ
ខ្លួនឲ្យធ្វើគ្រឿងក្រោះពាក់ ខ្លួនអាន ស្រះស ម្រាប់បញ្ជាំងគ្រប់គ្នាពាំង

ចាប់តាំងពីពេលនោះមក អ្នកចាំង ៣ នាក់ក៏បញ្ជុះបញ្ចូលពួកអ្នកស្រុកវៃលមានប្លែវៃបានចំនួន ៥០០នាក់នាំចូលទៅគេចៅចេង។ ក៏នាំចូលទៅគេចៅហ្វាយស្រុកខ្មែរអៀន អ្នកចាំង ៣ នាក់តំណាងចៅហ្វាយស្រុកវៃហើយ ទើបនិយាយថ្កោលទោសឈ្មោះទំនៀមទំលាប់ចៅហ្វាយស្រុកខ្មែរអៀន ។ ពួកខ្មែរតែងសេចក្តីមេត្រីគប់តាមចំពោះខ្មែរជាភ្ញាំង, ទើបទទួលខ្មែរជាទុកជាកូនប្អូន ។

លុះនៅមកបានប៉ែនថ្ងៃ មានបំរើរាន់សំពុតមួលមកប្តឹងថា "ពួកចោរជួតក្បាលលឿង មានការហានឯកឈ្មោះតៀអ្នេងដឹ បានលើកពលបំទួនរាប៉ុនមុឺននាក់ ទន្ទ្រានចូលមកដល់ក្នុងដែនស្រុកខ្ញុំនេះហើយ" ចៅហ្វាយស្រុកខ្មែរអៀនឮដូច្នោះ ក៏ចាត់ចៅបង្គីឲ្យហៅខ្មែរពី, គួនអ៊ូ, តៀហ៊ីរមកប្រឹក្សាថា "អ្នកចាំង ៣ នាក់! ចូរអ្នកនាំគ្នាលើកពលដ៏ច្រើនចំនួន ៥០០ នាក់ ទៅតីទប់តូកអាចោរទាំងនោះឲ្យបាន" អ្នកចាំង ៣ នាក់ឮដូច្នោះមានចិត្តត្រេកអរណាស់ ត្រមទទួលជួយយកការដែនដីទើបលើកពលវ័តចាំង ៥០០ ចេញទៅដល់ទៅគាន់ភ្លឺ។ ហ្វាងអានរមិលមើលទៅក៏ឃើញពួកចោរដើរដេរដាស លើកគ្នាចូលមកជាច្រើន ឯពួកចោរទាំងនោះមិនបង្ហើសក់ទេ សុទ្ធតែសំយាតសក់ ហើយជួតក្បាលសំពត់ពណ៌លឿងទាំងអស់គ្នា ខ្មែរតាឃើញដូច្នោះ ក៏ឲ្យរៀបចំជាបន្ទាយតាយចំដែនស្រាសបន្ទា ធ្វើជាកំដែនរ៉ាំទុំវិញ ហើយបានសេះចេញ ៧ឈរមុខ

ចំពោះ ឲ្យកូនអ្នកជិះសេះតមខាងស្តាំ ឲ្យគៀវហ៊ុយជិះសេះតមខាងក្រោយ ខ្លាឃ្លាំងក៏លើកតសែខ្សែនចង្កុលមុខគាចោរហើយដេរថា "នែអាពួកក្បត់" ។ មេចំពាគៀវអ្នកជា ឮខ្លាឃ្លាំងពាដេរដូច្នោះខឹងណាស់ ទើបប្រែចាកោនឯកម្ខាងឈ្មោះគេនមៅឲ្យខ្សែនជិះសេះចេញទៅតយុទ្ធនាកណ្តាលរណ្តៅ គៀវហ៊ុយកាន់លំពែងប្រវែង ១០ ហត្ថ បរសេះចូលទៅប្រយុទ្ធនឹងគេនមៅភ្លាម ពេលនោះគៀវហ៊ុយកំភ្លេងលំពែង ចាក់ត្រូវចំពាក់កណ្តាលដើមទ្រូងគេនមៅធ្លាក់ពីលើខ្នងសេះស្លាប់ក្នុងខណៈនោះឯង ។

*** គៀវអ្នកជាទីទាំងណាស់ ស្តុះកាន់ជាវាខ្សែនសេះបរសំដៅគៀវហ៊ុយកូនអ្នកឃើញដូច្នោះ ក៏ស្តុះខ្សែនសេះបរទៅពាក់ព័ន្ធមុខគៀវហ៊ុយចាំខ្លួនឯង គៀវអ្នកជាឃើញរូបកូនអ្នក ក៏សុតស្មារតីភ័យរលេះរលាំង កូនអ្នកឃើញបានគាកើយកជាវាកាប់ត្រូវខ្លួនគៀវអ្នកជាដាច់ជាពីរកំណាត់ ពួកចោរចាំងខ្លាឃ្លាំងក៏បែកខ្ចាត់ខ្ចាយគេចេញទៅតស់ ខ្លាឃ្លាំងក៏បរសេះចូលដេញប្រកាប់ចាប់ពួកគាចោរបានជាឈ្លើយច្រើនណាស់ លុះមានជ័យជំនះហើយក៏លើកតសែវិលត្រឡប់មកស្រុកខ្លួនវិញ ។

ឯខ្លាឃ្លាំងអៀនលុះដឹងតណាតិមាន ក៏ចេញទៅទទួលខ្លាឃ្លាំងតាជស់ខ្លាស្រុងចៅយនាំត្រឡប់ចូលមក ខ្លាឃ្លាំងអៀនក៏ឲ្យបំណាច់ឆ្អាន់ជស់ពួកគាហានតាមសមគួរ លុះព្រឹកឡើង មានចំរើសេះកាន់សំបុត្រសំបះកេងចៅហ្វាយស្រុងគេនជាវ មកជស់ចៅហ្វាយស្រុងខ្លួនថា ឥឡូវនេះពួក

ចោរជួតកាលលឿន លើកទ័ពមកព័ទ្ធស្រុកឆេងជាវ ច្រើនណាស់ សុំឲ្យ
ចៅហ្វាយស្រុកទុនគួនលើកទ័ពទៅជួយ ខ្ញុំអៀនជាងជួយតែឲ្យឆេង
ខ្ញុំពីមកប្រឹក្សា ខ្ញុំពីថាខ្ញុំចុះទទឹងជួន ២ នាក់សុំយកអាសាទៅ
ទៅជួយស្រុកឆេងជាវឲ្យអស់ពីចិត្ត ។ ខ្ញុំអៀនបានស្តាប់ក៏ចាប់ចិត្តគ្រែត
តាណាស់រលេះរលាំងតាន់ឲ្យចៅចេងឃុំនាំពលចាហាន ៥.០០០ លើក
ចេញទៅជាមួយនឹងខ្ញុំពីកួនអ៊ូ តៀវហ៊ុយ ខ្ញុំពីនឹងចៅចេងលើក
ចាហានទៅដល់ស្រុកឆេងជាវ ពួកចោរឃើញទន់ទ័ពលើកគ្រប់មក
ហេមក៏ចេ ។

ខ្ញុំពីចៅចេងមានពលចាហានតិច ក៏កថាយគេចមកហើយ
ប្រឹក្សាគ្នានឹងកួនអ៊ូ តៀវហ៊ុយថា ពលចាហានយើងតិចជាងពួកតាចោរ
យើងត្រូវគិតជាកល់សឹក ទើបមានជ័យជំនះវិញ ថាហើយខ្ញុំពីឲ្យកួនអ៊ូ
ឃុំនាំពលចាហាន ១ ពាន់ ទៅបង្កប់នៅតំបន់ភ្នំខាងស្តាំផ្លូវ ឲ្យតៀវហ៊ុយ
ឃុំនាំពលចាហាន ១ ពាន់ទៅបង្កប់នៅខាងឆ្វេងផ្លូវ កំណត់ថា បើបានឮ
សំឡេងឃ្មោះវេលាណា ឲ្យលើកចាហានក៏ចូរចេញមកទាំង
សងខាង កួនអ៊ូ តៀវហ៊ុយទទួលបង្គាប់ខ្ញុំពីហើយក៏លើកចាហាន
ចេញទៅ លុះព្រឹកឡើងខ្ញុំពីនឹងចៅចេង ក៏លើកចាហានទៅភាមផ្លូវ
ដៃលកួនអ៊ូ តៀវហ៊ុយបង្កប់ពលនៅនោះ ។

ឯពួកចោរកំលោភលុកពន្ធគ្នាដេញតាមខ្លាចមិនទាន់ ក៏ចាកចេញទៅ ប្រយុទ្ធហ៊ានយកជយលាភមកដល់ច្រកភ្នំដែលបង្គំថាហានខាងលិច ហើយឲ្យរវាងហ្មេះជាសញ្ញាឡើង ក្លួនគ្នា តៀរហ៊ុយ ដែលបង្គំថាហានខាងលិចនោះ ក៏ចេញមកវិញ ហើយ ក៏ចេញមកដល់ច្រកភ្នំដែលបង្គំថាហានខាងកើតនោះ ក៏ឲ្យរវាងហ្មេះជាសញ្ញាឡើង ក្លួនគ្នា តៀរហ៊ុយ ដែលបង្គំថាហានខាងកើតនោះ ក៏ចេញមកវិញ ហើយ ក៏ចេញមកដល់ច្រកភ្នំដែលបង្គំថាហានខាងជើងនោះ ក៏ឲ្យរវាងហ្មេះជាសញ្ញាឡើង ក្លួនគ្នា តៀរហ៊ុយ ដែលបង្គំថាហានខាងជើងនោះ ក៏ចេញមកវិញ ហើយ ក៏ចេញមកដល់ច្រកភ្នំដែលបង្គំថាហានខាងត្បូងនោះ ក៏ឲ្យរវាងហ្មេះជាសញ្ញាឡើង ក្លួនគ្នា តៀរហ៊ុយ ដែលបង្គំថាហានខាងត្បូងនោះ ក៏ចេញមកវិញ ហើយ ក៏ចេញមកដល់ច្រកភ្នំដែលបង្គំថាហានខាងលិចនោះ ក៏

ខ្លាំ)ពី ៥០០ នាក់ ឯលោកចង់លើកទាហានដែលមានចិត្តទៅស្រុកកុនតួនវិញ
ឯណោះនោះខ្លាំ)ពី តួនដូច្នេះ តែហ៊ុយកាំលើកទាហានទៅដល់ស្រុកកុនកុង
ហើយបបួលគ្នាប្លន់ស្រែចំការលោកិត ទើបយកទាហានវែលខ្លួនបានតែ
ប្រាំពីរនឹងពួកចោរគាល់តែមុខនោះមកពណ៌នាឲ្យលោកិតស្តាប់ លោកិត
ពេញចិត្តណាស់ក៏និយាយថា អ្នកទាំង ៣ នាក់ចូរទៅធ្វើការជាមួយ
នឹងយើងចុះ ។

ខាងតែក្រុកមានពួកចោរជាពលទាហានចំនួន ១៥ ម៉ឺន ខាងឯ
លោកិតមានពលទាហានចំនួន ៥ ម៉ឺន ទ័ព លោកិតនឹងតែក្រុកតាំង
បន្ទាយជិតរួសរល់គ្នា ជានតតាំងប្រកាំងគ្នាមិនទាន់ចាញ់ឈ្នះនៅឡើយ
លោកិតនិយាយទៅនឹងខ្លាំ)ថា តែប៉ែនឯងតែរៀងជាអ្នកតែក្រុកនោះ
ឃុំទាំពួកចោរទៅប្រាំនឹងចាស់ហ្ម៊ុងនឹងជួហ៊ុំនៅស្រុកអេនឆ្នា យើង
នឹងបំបែកទាហានឲ្យអ្នក ១០០០ រួមជាមួយនឹងទាហានចេស់អ្នកៗបួរលើក
ទៅជួយចាស់ហ្ម៊ុងនឹងជួហ៊ុំនៅស្រុកអេនឆ្នេះចុះ ហើយឲ្យអ្នកជួយស៊ើប
យកដំណឹងពីកងតែក្រោមឲ្យដឹងផង ខ្លាំ)ពីទទួលតាក្យលោកិត
ហើយក៏លើកទាហានស្រុកតួនទាំងយប់ . ថ្ងៃជួនទៅស្រុកអេនឆ្នេះ ។

ឯចាស់ហ្ម៊ុងនឹងជួហ៊ុំកំពុងបរសួលបួលប្រាំនឹងទ័ពនោះនៅមិនទាន់
ចាញ់ឈ្នះអស់ពេល.ហើយ តែប៉ែតែរៀងឲ្យទាហានថយទៅកាន់ទី
កន្លែង ហើយឲ្យយកចំបើងធ្វើជាវាំងឡំទុកនឹងបន្ទាយ ខាងឯចាស់ហ្ម៊ុងនឹង

ដូហ៊ុបានដឹងទើបប្រាប់ក្បាត្តាថា ឥឡូវនេះពួកចោរយកចំបើង៧ចង្កឹះឆ្លងដំរកដ៏ចម្ងាយ យើងនឹងតាមយកភ្លើងដុតចម្ងាយពួកចោរឲ្យបាន តាមហើយឲ្យឯកស្មៅទៅតរលាក់ទុកកែវចម្ងាយជារបៀន លុះពេលកណ្តាលអធ្រាត្រយប់ស្ងាត់ប្រហែលយាម ២ ក៏បង្កើតឲ្យលាប្ញុះជាខ្លាំងបោកបក់ត្បូងខ្យប់ ពួកឥហានដែលចញ្ជូនទៅលាក់ចង្កុយល់បានការ ក៏នាំគ្នាយកភ្លើងឈួលដុតស្មៅនោះនេះទៀត ភ្លើងក៏នេះកលជាលអស់ទាំងដំបង្ហាយចោរ ឥទ្ធិភ្លើងក៏ភ្លឺសន្ធោសន្ធៅបីដូចពេលថ្ងៃ ពួកចោរសឹងតែកិតកើយជាចលាចលច្របូកច្របល់ក្នុងចម្ងាយ សឹងតែស្ទុះតេ៎ត្រាត់ត្រាយចោលគ្រឿងប្រដាប់សម្រាប់សឹកតតែ៎ក្រោះបំពាក់ទន់ងាយនេះ ភ្លើងក៏នេះទៀតម៉ត់ឥតមានសេសសល់ ពួកចោរតេ៎ចេញពីចម្ងាយ ហាន់ហ៊ូសុងនឹងដូហ៊ុក៏តាំងកុយរៀបពួកពលឲ្យចូលដេញចាក់កាប់សម្លាប់ពួកចោរត្រូវបួសពិការមរណៈស្លាប់ទឹងត្រាកប់ពុំបាន លុះត្រឹកឡើងតៀវប៉ូតៀវលៀងទូរេស់ពួកចោរភាំងឡាយ ដែលនៅសល់នោះសឹងតែដោះតេ៎ឲ្យរួចជីវិតតែរៀងខ្លួន លុះតេ៎ទៅជួបទឹងកងទ័ពមួយកងសុទ្ធតែកាន់ទង់ក្រហមឥតឥហានកងមុខចេញស្លាក់កាត់ពួកចោរទុកមិនឲ្យទៅមុខបាន ឯមេទ័ពនោះឈ្មោះថូឆួ កំពស់ប្រហែល ៩ ហត្ថកែកតួចពុកមាត់រែង ជាបុត្រថូកួ ។ (ប្រវត្តិថូឆួ) រីឯថូឆួនោះ កាលនៅពីក្មេងរមែងចូលចិត្តដើរលេងនឹត្រកេបបោញ៉ាសត្វ តែនចូលចិត្តស្តាប់ចម្រៀងរាំកុរ្យតន្ត្រី

មានសតិបញ្ញាវង្វៀវហ៊ាស ឈ្មោះបួតឹកត្រែវជាមា កាលបានឃើញ
បួធួជាអ្នកលេងមិនធ្វើការកេស៊ុកមានចិត្តស្អប់ខ្ពាំងណាស់ ទើបដើរទៅ
ប្រាប់ខ្នងនឹងប្រាប់រឿងព័ទ្ធបួកូជាបងដឹង បួធួដឹងថាបួតឹកជាមាស្អប់ខ្លួន
គាំរឿងទៅប្រាប់ចិត្ត ក៏ច្រែះបាយធ្វើជាខ្យល់ចាប់ដួល មកឃើញដូច្នោះ
ក៏ស្រែកប្រាប់បួកូថា បួធួខ្យល់ចាប់ដួលទៅហើយ បួកូភ័យណាស់ស្ទុះ
ចេញទៅមើល បួធួក៏គ្រាកឡើងលេងដូចប្រក្រតី បួកូក៏សួរថា មា
ឯងទៅប្រាប់អញកម្សាញ់មិញថា ឯងខ្យល់ចាប់ ឥឡូវបាត់ហើយឬ?
បួធួធ្វើយថា ខ្ញុំគាំងពីដើមរៀងមកមិនដែលមានឈឺអ្វីសោះឡើយ ហេតុ
ដែលមានគាត់ស្អប់ខ្ញុំបានណាស់ ទើបយកសេចក្តីមិនពិតមកដាក់បង់គា
ដោយក្លែងក្លាយទេ គាំងពីថ្ងៃនេះតទៅបួកូក៏ជឿពាក្យបួធួ ទោះមានោះ
ទីឥនាំយកហេតុអ្វីទៅនិយាយប្រាប់ក៏បួកូលែងជឿពាក្យសំដីបួធួសោះ ឯ
បួធួក៏គាន់តែកំរើបឥតគោតខ្ចាចនរណា ប្រព្រឹត្តអំពើអាក្រក់ផ្សេង។ ដាច់
មុន ពួកភឿនដែលលេងជាមួយគ្នាក៏លើកបញ្ឆោសេរសើបួធួថា ដែនដី
សម័យនេះកើតរាំងវេលាខ្លាំងណាស់ គ្មាននរណាមួយមានសតិ
បញ្ញាក្លៀវក្លាហ៊ានប្រាប់ប្រាមការពារបង្ហាញមិត្តឲ្យកាចសោះ យើង
គាំងឮយយល់ឃើញថា ខ្លួនលោងមានសតិបញ្ញា ព្រើនដឹងតិតការ
ប្រាប់ប្រាមពួកគាំណាច ក៏អាចនឹងធ្វើឲ្យដែនដីប្រែបដោយសេចក្តីសុខ

ឯក្នុងស្រុកឡាំបង្អន់នោះ មានមនុស្សម្នាក់ឈ្មោះ ហ្គូ ដើរមានក្រចាប្រជាជនណាស់ តែដំណឹងយ៉ាយឲ្យអ្នកចាំនឹងក្លួនបានដឹងថាផែនដីក្រឡាជាជាន់ទី៣ នោះទើបនៅសល់ឲ្យហើយ ដែលនឹងក្រោកក្រោមពួកបច្ចាមិត្រភាជសត្រូវឲ្យកបាបបាន ឃើញមានតែក្លួនម្នាក់ ។ ឯស្រុកលិឡាំនោះ មានត្រួម្នាក់ឈ្មោះ ទៅធៀវ ចេះមើលសក្ខណៈមនុស្ស លុះក្លួនដឹង ហើយក៏ស្វែងទៅរកទៅធៀវ បានជួបហើយសួរទៅធៀវថា ខ្លួនខ្ញុំបានដឹងអំណើះតៈមុខ តើនឹងបានជាមនុស្សល្អ ឬអាក្រក់ប្រការដូចម្តេច ? ទៅធៀវនៅតែស្ងៀម ក្លួនក៏សួរថែមទៅទៀត ទៅធៀវឆ្លើយថា ខ្លួនអ្នកជាមនុស្សមានសតិបញ្ញាក្រៃន តទៅមុខនឹងការពារផែនដីបាន ប៉ុន្តែមិនបានប្រកបដោយសត្យសុចរិតនឹងផែនដី តើជាសត្រូវនឹងភាជសម្បត្តិ ។ ក្លួនក៏សើចដោយសេចក្តីពេញចិត្ត លុះក្លួនបានអាយុ ៦០ ឆ្នាំ ក៏ចូលទៅធ្វើភាជាជាងហានក្នុងស្រុកឡុកគៀងជាដំណាក់ក្លួនឲ្យយកឈើចំនួន ៩០ តំណាត់ទៅដោតទុកត្រង់ភ្លូវអាំង ៤ ទិស ហាមមិនឲ្យមនុស្សដើរកណ្តាលយប់ បើនរណាដើរទៅមកទុសវិលា ឲ្យកាប់ចោកខ្លួនទៅធ្វើទោស លុះតណ្តាលយប់ក្នុងថ្ងៃមួយ ក្លួនដើរទៅត្រួតក្រវែលប្រទេនមនុស្សអ្នកជាមាក្លួនថ្មី ដើរមកទុសវិលា ក្លួនឲ្យកាប់ខ្លួនទៅវាយ ១៩ ខ្លាជ ។

(មានត)

ប្រវត្តិសាស្ត្រសង្ខេបប្រទេសចិន

ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថៃម

ប្រែរៀបរៀងអំពីប្រវត្តិសាស្ត្រយោគល

(ត្រួត)

គ.ស.ពុទ្ធសករាជ ១២៦៩ ក្សត្រគ្រួតថៃលឈ្មោះមេប្ងូម៉ូក៏លើកទ័ពចូលមកលុកលុយស្រុកខានស៊ូ ព្រះនាងមិនចាត់ការតទល់ទេ បណ្តោយឲ្យភ្លាំងធ្វើលេងបានតាមសប្បាយចិត្ត ។ គ.ស.ពុទ្ធសករាជ ១២៩១ មានព្រះអគ្គមហេសីមួយអគ្គកុលជាឈ្មោះថាង ប្រសូតបានសម្តេចប្រុសសហាយរបស់ព្រះនាងវ៉ែ-ដិបង់ ៧ ទើបនាំឲ្យកើតហេតុធំរឿង ព្រោះតែរាជឧសេរបស់ព្រះចាទបុង-សុង ដែលជាមកពីជាតិកំណើតអ្នកស្រុកមាន ត្រូវចាត់ជាជាតិមនុស្សហោតកាចនេះ ព្រះចាទបុង-សុង មានព្រះទ័យឲ្យចាប់ព្រះរាជឧសេរបស់ព្រះអគ្គមហេសីទាំងប្រហារជីវិតនៅចំពោះមុខអាមាត្យក្នុងទ្រង់ទាំងពួង ព្រោះហេតុតែមានចិត្តក្តាហានហ៊ានសម្លាប់ប្រសូតសហាយរបស់ព្រះអគ្គមហេសីៗ ទុកជាព្រះភ្នែកបុង-សុង លុះក្នុងអំណាចធ្វើតាមចំណង់ចិត្តរបស់ព្រះនាងផុតម្ល៉ះហើយក៏ដោយក៏នៅតែមិនដាច់នាងចិត្តរបស់ព្រះនាងវ៉ែដដែល ដល់មកគ.ស.ពុទ្ធសករាជ ១២៩៣ ព្រះនាងវ៉ែដ ជាន់ថ្នាំបំពុលព្រះរាជស្វាមីភាល់តែទិន្នន័យ ដែលជាអំពើកម្ចិតក្រៃលែងដាងព្រះនាងវ៉ូ-ហៀរៅខ្លួន ។

មកដល់ត្រង់នេះ ពួកអាមាត្យមន្ត្រីចិនតង់ទឹកស្តាយព្រះនាង វ៉ូ-ហៅ
ព្រោះតាមដោយពិតនោះ ព្រះនាង វ៉ូ-ហៅ នោះពុកជាឆបសាហាវយ៉ាង
ណា នៅមានសតិបញ្ញាចុងក្រសប់ខាងការគ្រប់គ្រងស្រុកទេស មិន
បណ្តោយឲ្យខ្ជាក់ចូលមកញាំញីស្រុកចិនបានតាមចំនើងចិត្ត ។ ប៉ុពុកជា
ព្រះនាង វ៉ូ - ហៅ បានចំផ្ទាញជីវិតមនុស្សជាច្រើនលើសលែងចំពោះមនុស្ស
ដែលជាសត្រូវនឹង ព្រះនាងមិនបានសម្លាប់មនុស្សដែលមានបុណ្យគុណ
នឹងខ្លួនដូចជាព្រះរាជស្វាមីទេ ។ តាមចំនុចនេះទើបឃើញថា ព្រះ
នាង ង៉ែ - ជឺ ជាស្ត្រីអាក្រក់ក្រៃលែងជាងព្រះនាង វ៉ូ - ហៅ ទៅទៀត ។

កាលព្រះនាង ង៉ែ - ជឺ បានផ្តាច់ផ្តិលព្រះជន្មព្រះរាជស្វាមីហើយ
ក៏ចាត់ការយ៉ាមមិនឲ្យអ្នកឯណាដឹងរឿងនេះ ប៉ុន្តែរឿងនេះចេះមិនដឹង
បានចែកខ្ចាយសាយភេញទៅហើយ ពួកមន្ត្រីចាស់ៗ ក៏នាំគ្នាចូលគាល
បាលលឿន ។ ឯព្រះនាង ង៉ែ - ជឺ មិនមានបញ្ញាឈ្លាសវៃប្រហែលនឹង
ព្រះនាង វ៉ូ - ហៅទេ មិនអាចបំបិទបាំងទុច្ចរិតកម្មនោះបានផង មិនអាច
រម្ងាប់ឃរបាលបានក្នុងស្រុកបានផង ។ ឃើលនោះមានក្បត្តិសែស-
ឡាយកាន់ថ្ងៃចាំងមួយអន្លង់ទន់ព្រះនាម មិង - កុង ត្រូវជាជនគ្លាបបង់
ព្រះបាទ ពុង - សុង កាលបានដឹងដំណឹងអាតម្ងល់នោះ ក៏លើក
ទាហានចូលទៅក្នុងព្រះរាជវាំង ហើយបានប្រហារជីវិតព្រះនាង ង៉ែ - ជឺ

ដោយសៅខ្លួ ប្រទេសកម្ពុជាធំតាំង ជុយ - សុន ជាចំណាប់ស្ងួនជាមហា-
ក្សត្រត្រង់ពុជសម្បត្តិក្រុងចិន កាលពីពុទ្ធសករាជ ១២៧៣ នោះឯង ។

នៅកន្លែងនោះ កិច្ចការខាងកន្លែងស្រុកកំពុងលាលែរើរកជាភ្ញាំង
ប្រទេសរាជផ្សេង ។ ក៏នាំគ្នាវិលទៅតាំងជាឥស្សរៈឡើង ភ្ញាំងសក្រវ
ខាងក្រៅដែនក៏លើកម៉ពួលមកមើលស្រុកចិន ឯកំពាំងម៉ពួចិនកំពុង
ខ្សោយមិនអាចការពារស្រុកទេសបាន ។ ដល់ពេលវេលាហើយដែល
ក្រុងចិនត្រូវតែកសាងស្រុកទេសឡើងជាថ្មីវិញដូចកាលសម័យថៃ - សុន
មហាពង្ស ព្រះបាទ ជុយ - សុន ទ្រង់ជ្រាបច្បាស់ថា ព្រះអង្គឯងមិន
មែនជាមនុស្សភ្ញាំងតូចតែទេ លុះទ្រង់គ្រងរាជសម្បត្តិបាន ២ ឆ្នាំ ក៏សុំប្រ-
គល់រាជសម្បត្តិឲ្យទៅរាជវង្សសេ គឺ មិង - កុំង ដែលមានខ្សែលោហិតជាប់
មកពីថៃ - សុន មហាពង្សជាចំណួនច្រើន ហើយព្រះមហាក្សត្រអង្គនេះឯង
ដែលទ្រង់ជួសជុលក្រុងចិនឡើងជាថ្មីបាន ។

អំពីព្រះបាទមិង - ភ្ញាំងទ័ងព្រះនាងយ៉ុង - ហ្សៃ

ព្រះបាទមិង - កុំង ព្រះអង្គមានព្រះនាមមួយទៀតហៅថា ហៅង - សុន ។
ស្តេចមានព្រះរៀមទីន ព្រះអនុជ ៤ ព្រះអង្គ ក្សត្រ ២ ព្រះអង្គជាព្រះរៀម
២ ព្រះអង្គទៀតជាព្រះអនុជ ។ ព្រះបាទហៅង - សុន ទ្រង់មានព្រះ
រាជហឫទ័យស្រឡាញ់ក្សត្រតាំង ៤ ព្រះអង្គណាស់ ដែលទ្រង់ជ្រាបសោយ
រាជសម្បត្តិជួបប្រទះហើយ ក៏គិតរំលឹកព្រះរៀមទីន ព្រះអនុជតាំង ៤ ព្រះអង្គ

ឲ្យខ្ញុំមកតាំង នាជាមួយជាមិត្ត ថែមទាំងក្សត្រមួយព្រះអង្គទៀតផង ដែលត្រូវជាក្មួយជីដូនមួយរបស់ខ្ញុំ ។ ឯក្សត្រអង្គនេះត្រូវជាព្រះពុទ្ធគ្រាព្រះបាទពុទ្ធ - សុង ។ ខ្ញុំសោយក្រយោស្ងោយ ក៏សោយជុំនៅតុមួយទាំងអស់គ្នា ខ្ញុំធ្វើការងារអ្វីក៏ធ្វើជាមួយគ្នា, ព្រះអង្គកាប់គានក្សត្រទាំង ៥ ព្រះអង្គនេះ ដោយសេចក្តីមេត្រីស្រឡាញ់ស្និទ្ធស្នាលអស់ពីព្រះទ័យ ។

មានថ្ងៃមួយ នោះ ព្រះអង្គម្ចាស់លី - យើដែលជាព្រះអនុជរៀបរៀបសំព្រះអង្គ ខ្ញុំព្រះបិណ្ឌ ព្រះរាជាខ្ញុំថែរក្សា ព្រ អនុជដោយព្រះអង្គឯង ។ មានគេលមួយនោះព្រះអង្គស្តេចខ្ញុំដាំព្រះទេសថព្រះរាជទានព្រះអនុជ ក៏ខ្ញុំទទេរៀងតភ្លើង ។ ឆាបឆេះព្រះមស្ថូ ពួកមាត់ព្រះអង្គបន្តិចៗ ពួកមហាតឡឹកឃើញដូច្នោះ ក៏មានសេចក្តីភិតភ័យតក្កមាជាច្រើន, តែព្រះបាទហៀន - សុង មានព្រះបន្ទូលត្រាស់ថា "មិនអីទេពុំមាត់របស់យើង បើវាឆេះក៏ឆេះទៅចុះ ឲ្យតែព្រះអនុជរបស់យើងបានថា" ដោយហេតុដែលព្រះអង្គមានព្រះរាជហឫទ័យល្អដូច្នេះហើយ បានជាព្រះវិមលនីព្រះអនុជរបស់ព្រះអង្គ រឹតតែមានសេចក្តីស្នេហាស្រឡាញ់ខ្ញុំឡើង ហើយនាំឲ្យក្សត្រទាំងនេះមានព្រះរាជហឫទ័យសុខចិត្តទៀតត្រង់ដល់ព្រះអង្គជាច្រើនថែមទៀតផង ។

តាមដោយពិតនោះ ព្រះបាទមីន - កុំឲមានព្រះលក្ខណៈ ល្អខ្វះ
តាត្រង់ខ្វះ តែគួរពង់ថាជាព្រះមហាក្សត្រមានសតិបញ្ញាប៉ុនប្រុសម៉ម្លួយ
អង្គបាន ។ អ្នកប្រាជ្ញប្រែវត្តិសាស្ត្រថាកំឲបួលបិត្តនាំយកព្រះបាទមិន-
កុំឲ ទៅប្រៀបនឹងស្តេចល្ងីល្ងើ ១៤ របស់មហាព្រះទេសបាកំឲសៃស ។
ព្រះបាទមិន - កុំឲទ្រង់ធ្វើសង្គ្រាមកម្ចាត់ផ្នែរបស់ព្រះអង្គជាវេលាយូរ
ជាន់ដំបូង ។ មានជ័យជំនះ តែតមកក្រោយត្រូវចាញ់ជាបាតជ័យទៅវិញ
ចំណែកកិច្ចការខាងក្នុងស្រុកក្រុងនោះ ជាន់ដំបូងមានសេចក្តីរុងរឿងល្អ
ណាស់ ពាល់តែអ្នកប្រាជ្ញប្រែវត្តិសាស្ត្រពោលថា អ្នកណាមិនបានកើត
ខាងក្បាលព្រះបាទមិន - កុំឲ អ្នកនោះតង់មិនដែលស្គាល់សេបក្តីវីរកាយ
ក្បែរក្បាលក្នុងជីវិតនៅក្រុងចិនដូចម្តេចទេ ដោយហេតុនេះឯងបានជា
អ្នកប្រាជ្ញប្រែបង្រៀបព្រះបាទមិន - កុំឲទំនងស្តេចល្ងីល្ងើ ១៤ តែក្រុងបាកំឲ
សៃស ដែលជាសម័យមានពាសំណាងយ៉ាងធំសំបើមអស្ចារ្យ ជាទី
សម្គាល់ព្រះពរជ្ញាទ័យនៃព្រះមហាក្សត្រ តែតមកចុងក្រោយមានតារ
ខ្លះខ្លាយសប្បាយជ្រុលពេក មានចំនង់ដូចគាលក្រុងកេមអស់ខ្លើអំណាច
ឬដូចគាលំបាកំឲសៃសកើតបដិវត្តន៍ឡើងជូរបោះដែរ ។

ក្នុងរជ្ជសម័យនៃព្រះបាទ មិន - កុំឲ នេះឯងដែលប្រទេសចិនមាន
កើតអ្នកប្រាជ្ញ ឧត្តមវិនិតន្ធជាច្រើនប្រជាប់កិត្តិយសរបស់ទ្រង់ជាចំនួន
ច្រើន ទ្រង់តាំងព្រះអង្គជាអ្នកចំនុតបំរុងកវិនិតន្ធទាំងឡាយខ្លួនឯង ។ ក្នុង

ឆ្នាំពុទ្ធសករាជ ១៦៦៦ ខ្ញុំចាត់តាំងព្រះរាជបណ្ណាល័យយ៉ាងធំឡើង
ហើយតមមកក្នុងឆ្នាំពុទ្ធសករាជ ១៦៦៨ ខ្ញុំចាត់តាំងរាជបណ្ឌិតសភា
ឡើង ។ ព្រះអង្គឯងក៏ជាអ្នកប្រាជ្ញ, ជាមេដឹង, ជាកវី ទើប
ខ្ញុំជ្រាបដំណៀងនៃដំណាអស់នេះយ៉ាងច្បាស់លាស់ ។ មានកវីឯក ៤ នាក់
ឈ្មោះលី-តៃប៉ែ ១ ឈ្មោះខូ-ហ្វូ ១ ដែលខ្ញុំកាប់អានជាមិត្តដ៏ប្រសើរ
របស់ខ្ញុំ ក្រៅអំពីនេះ ព្រះអង្គមានព្រះអគ្គមហេសីជាទីសព្វព្រះ
រាជហឫទ័យមួយអង្គ ព្រះនាម ព្រះនាងហ៊ុន-ឈៀ ជាស្ត្រីដែលយកចិត្តទុក
ជាក់ជួយចំខុកបំរុងពួកអ្នកប្រាជ្ញរាជបណ្ឌិតរាជយស្ស ឯខ្លួនព្រះនាងជា
គ្រូគន្ធិយ៉ាងឯក ទើបឃើញថា ពាក្យសំណាក់ចិនកន្លងផ្សុសម័យរបស់
ព្រះបាទមិង-កុង ថ្កុំថ្កើងរុងរឿងជាបំផុត ។ ក្រុងស៊ុងក៏មានកំណាយទៅ
ជាស្ថានសួគ៌របស់ចិនដូចគ្នានៃគន្ធ លី-តៃប៉ែនិងខូ-ហ្វូ គោលពាណិនា
សរសើរសភាពជាទីក្សេមក្សាន្តសប្បាយដ៏ក្រៃលែង ក្នុងសេចក្តីមួយអន្លើ
នោះ ខូ-ហ្វូពោលថា :

" ក្នុងសួនច្បារនៃក្រុងស៊ុ-ជាន នោះ មានខន់ដ៏យមហាកជរបស់
ព្រះរាជាធិរាជ ចោតបក់លោសន់ជាយទៅមកជាន់ខ្ចី ហើយធម្មជាតិតាំង-
ឡាយក៏ល្អស្រស់ជះជាសាទៅរោយពណ៌ផ្សេងៗ ទៅក្នុងសួនច្បារនេះ
ឯតជាទីកើតនៃសេចក្តីស្នេហារបស់ក្រមុំគំនេរ ដែលនាំគ្នាទៅតាម
ស្តួចចោមរោមជាកជរវែង ។ ស្រីក្រមុំៗ រូបឆោមល្អស្រស់មាន

ចំនួនពាល់មិនអស់ ដែលគាន់តែទៅឲ្យដើរតាមហែព្រះកឋិនាន ក្នុងខណៈ
ដែលស្តេចចេញទៅប្រពាត ។ នៅក្បែរគោនព្រះអគ្គមាន់ដែនីធ្វើដោយ
ស្វាបក្អែកបោតបក់ប្លាយជាន់ខ្ពស់ ទាំងមើលឃើញលំអដ៏រុងរឿង ព្រះ
ស្ទឹងជាព្រះកឋិនាសោតទៀត ក៏មានមណ្ឌបតូចមួយបិទបាំងដោយ
ព្រះសន្ទឹយាដែលប្រដាប់តាក់តែងដោយគ្រឿងទៃមុខ ទំនើបគ្រប់ជារូបសត្វ
ដែលកេបាន់ដោយកម្រណាស់ ។ កាលបើស្តេចចេញទៅប្រពាតតាម
ជើងទឹក ស្តេចតែងទ្រង់គង់នាក់ព្រះទីនាំងដែលមានសសរក្តោងធ្វើដោយ
ភ្លុកដំរី ហើយសន្ទឹកក្តោងធ្វើដោយសំពត់ព្រសូត្រយ៉ាងល្អ កាល
ប្រកបដង្ហែទៅនឹងពលិទ័ពដ៏ច្រើនកុះករក្នុងទន្លេសាបហើយ ទ្រង់គាយ
នាក់ព្រះទីនាំងមានសណ្តានដូចសត្វស្វាបយ៉ាងល្អវិសេសមួយហែបហែល
កន្លងពីរ ។ ។

ព្រះនាងយ៉ុង . ហៃមិនមែនតែមតែងាស្តីមានរូបឆោមល្អប៉ុណ្ណោះទេ
ព្រះនាងនៅមានចំណេះបេះដឹង ទំនើសេចក្តីធ្វើគ្នាតាន់ត្រឹងប្រដាប់
ដោយឧត្តមវិមលទៀតផង ។ អ្នកថ្លៃប្រវត្តិសាស្ត្រចូលចិត្តប្រៀប
ធៀបព្រះនាងយ៉ុង . ហៃនឹងម៉ាដាម ប៉ុមប៉ាឌួរបេស់ថាក់ងសែស ព្រោះ
ហេតុព្រះនាងយ៉ុង . ហៃក្តាប់កាន់បេះដូងរបស់ព្រះបាទមិន . ក៏ងមតទុកក្នុង
ដៃបាន មានចំនងដូចម៉ាដាមប៉ុមប៉ាឌួរក្តាប់បេះដូងព្រះបាទលូអី ១៥
ទុកក្នុងដៃបានដូច្នោះដែរ ។ ប្រសិនបើព្រះបាទមិន . ក៏ងស្តេចគង់កន្លែងក្រុង

ស្ដី - ង៉ាន់ហើយ ខ្ញុំមិនដែលឃ្លាតឆ្ងាយពីព្រះនាងយ៉ុន - ហ្វាឡើយ ។ កន្លងវេលាតែមួយនោះ ជាវេលាក្រីថ្ងៃមេឃស្រឡះភ្លឺត្រចះត្រចង់ដោយពន្លឺព្រះចន្ទ្រា ព្រះបាទមិន - ង៉ុនស្ដេចប្រថាប់ជាមួយនឹងព្រះនាងយ៉ុនហ្វា ហាក់ដូចជាខ្ញុំសប្បាយរីករាយក្នុងព្រះពន្លឺព្រះចន្ទ្រ ដែលមានព្រះបន្ទូលឲ្យហៅខ្ញុំនេះ - តែម៉ៅគាល់ ហើយខ្ញុំប្រាប់ក្រាបថ្វាយបង្គំទូលថ្លៃ - តែម៉ៃ ៣ សន្ធឹក ។ លី - តែម៉ៃក៏តែងជាកាព្យ ៣ បទថ្វាយក្នុងវេលានោះ ឯកាព្យហ្នោះមាន ៣ បទនោះនេះនិយមកចាប់អានជាយ៉ាងឯកន្លងតួតអក្សរសោស្ដេចនេះហួតមកដល់សព្វថ្ងៃនេះ ។

« ទ្រង់ទតពពកអណ្ដែតលើអាកាស
ព្រះរាជាទ្រង់មានព្រះបំណង
ហាក់ដូចព្រះនាងយាងមកសាសង
ខ្លួនស្គងបែរកាយនៃបអែបព្រះអង្គ ។
ស្ដេចទ្រង់ទតសួនប្បារង្គាគានា
ព្រះទ័យរីករាយប្លែកត្រយង់
ហាក់ដូចបានឃើញភក្ត្រាស្គុបញ្ជង់
រូបកាយស្រស់ផ្ទរផង់មានរស្មី ។

ក្នុងភពត្រីនេះមុងរឿងជាបំផុត
បមមកុដទតបន្ទូធាយល្អពីសី
ដ្ឋាងដងធ្វើយក្តីនក្រអូបហ្វាយបក្រី
ទាំងស្រស់ស្រីគង់ធ្វើមទន្ទឹមអើយ" ។

តាព្យឃ្លាងចាំង ៣ បទវេស់លី - តៃប៉ែ នេះ ជាសេចក្តីពីរោះចាប់ចិត្តវេស់ចិន្តកវីចិន សមជាទំព្រៀងសិប្បាណវេស់ព្រះកុទមិន - កុំនន្ទិនព្រះខាង យ៉ីន - ហ្វៃ ពិតមែន ។ តែបើវែជាមិនពីរោះចាប់ចិត្តវេស់អ្នកអានប្រតិសាស្ត្រនេះ កុំបីបន្ទោសដល់អៅលី - តៃប៉ែឡើយ សូមឲ្យបន្ទោសតែត្រឹមប្លែកប្រែនេះបានហើយ ព្រោះមិនស្ទាប់ចិនប្រែសព្ទខាងវេបៀបតែងតាព្យឃ្លាង ។

ទំពប៉ិនឈ្នះមេប្លូអ៊ូ

តាបេលាបលរំកែបានតើតឡើងតាំងពីបុងកជ្យព្រះបាទ កៅ - សុនន្ទោះ តែត្រូវបង់ជាស្ងប់រៀបយេវៀរញាបាន ។ ការត្រង់ណោះ ឆ្នាសាសើរព្រះខាង វ៉ូ - ហៀ តំកូងឆ្នាំពុទ្ធសករាជ ១២៣៩ នោះ ព្រះពជិនីមានចិត្តបើងរំងុះព្រះអង្គនេះ បានចាត់បញ្ជូនកងទ័ពចិនទៅវណ្តើមដែនដីផ្សេង។ ខាងកប - តារួមចាំងស្រុកកុលជា នឹងខាងតារមាំពីពួកទីបេត់បានមកទៀត

(មានត)

ហ្គង់ឥណ្ឌូមន្ត្រី ញ៉ាក-ថៃម ប្រៃ រៀបរៀង

(តមក)

១. ទ្វីបអាស៊ី	មានចំហុំដី	៤៥.០០០.០០	គីឡូម៉ែត្រក្រឡា
២. ទ្វីបអាហ្វ្រិក	"	៣០.០០០.០០០	"
៣. ទ្វីបអាមេរិចខាងជើង	"	២២ ០០០.០០០	"
៤. ទ្វីបអាមេរិចខាងត្បូង	"	១៨.៦០០.០០០	"
៥. ទ្វីបអង្គុប	"	១០.០០០.០០០	"
៦. ទ្វីបអូស្ត្រាលី	"	៧ ៧៧០.០០០	"
៧. ទ្វីបអាឆនិក	"	១២.៩៥០.០០០	"
ឯទីឯទៀតៗ	"	៦៨០.០០០	"

១៤.— ផ្ទៃដីនៃទ្វីបផ្សេងៗ.— បណ្តាទ្វីបទាំងនេះ ទ្វីបណាមានទីជិតលួស, ជ្រាបច, ដីខ្ពស់, ដីទំនាប តែមណាខោះ ចំពោះទ្វីបអង្គុបមានជ្រាបធំប្រែជាងគាក់កណ្តាលរបស់ទីជាងទ្វីបចាំងមួយ ឯទីជ្រាបធំរបស់ទ្វីបអង្គុបនៅកណ្តាលទ្វីប ពាក់ព័ន្ធអំពីទិសខាងជើងប្រែទេសចុះកាំងសែស នឹងប្រែទេសអាល្ប៊ីម៉ាញហ្គូនទៅទល់ភ្នំអ៊ូរ៉ាល់ ដែលជាទីបែងចែកព្រំប្រទល់ដែនទ្វីបអង្គុបនឹងទ្វីបអាស៊ី ហើយជ្រាបធំនេះជាទីជាមានជាតិល្អ ប្រឌបចាំងមានជាតូដែលធំធំធ្ងន់ថ្នាក់ចំនួនប្រែជាង ហើយប្រ-

ជាដនដែលគាស្រ័យនៅទាំងដំបន់មុសនេះ មានចំនួនច្រើនណែនណាន់ គាន់តាប់ម្ខួយនៅក្នុងលោកនេះ ។

ខ្ពស់ដែលមានទីដ៏ខ្ពស់ (ជាង ១.៨០០ ម៉ែត្រ) ដោយគាតច្រើន នៅខ្ពូបអាស៊ីចំណែកទីដ៏ខ្ពស់នេះ គឺតាំងពីអាស៊ីមីខ្យីលោតចេញទៅទិសខាងកើត ភាគច្រើនគឺប្រទេសអាំង, អាស៊ុតណាល, បរិវេណភ្នំហិមាល. ឈានចូលទៅដល់ផ្នែកដែនប្រទេសទីបេត៍ ដែលជាប្រទេសតាំងនៅលើកំពូលបំផុតក្នុងលោក (៣.៦០០—៥.២២០ ម៉ែត្រ) ដែលដែនដីនៃខ្ពូបអាស៊ុយនេះ ឬជាទីកាបខ្ពស់មានចំនួនច្រើនជាងពាក់កណ្តាលនៃតួខ្ពូបទាំងមូល ទីដីទំនាបមានតិច ព្រោះហេតុដែកបធំនៅតាតខាងជើងនៃខ្ពូបនេះជាទីខ្ពស់ ច្រើនតែខ្ពស់ជាង ១៨០០ ម៉ែត្រ ដែកបខាងជើងនឹងដីខ្លួលនៅកណ្តាលខ្ពូបទាំង ២ អានេះមានចំនួនមនុស្សស្តើង។ ឯចំនួនមនុស្សច្រើនតែកុះករនៅតាមទីដីទំនាប គឺដីទំនាបតាមដងទន្លេតង្គ្រាក្នុងប្រទេសឥណ្ឌា នឹងដីទំនាបតាមដងទន្លេផ្សេងៗនៅចំណែងប្រទេសចិនទិសខាងកើត ប្រសិនបើរួមច្រើជាដនទាំង.២ ប្រទេសនេះរួមគ្នា នឹងមានចំនួនដល់៧ ៧០០ លាននាក់ គឺត្រូវជា ៣ ភាគក្នុង ៤ ភាតនៃប្រជាជនក្នុងខ្ពូបទាំងមូល ។

បើគិតរួបធួបគ្នានឹងឃើញថា ខ្ពូបគាហ៊ូកមានដីខ្លួលច្រើនជាងខ្ពូបឯទៀតៗ ដីខ្លួលមានប្រមាណ ៤ ក្នុង ៩ ភាគនៃតួខ្ពូបទាំងមូល

ឯទំនាបប្តូដែលបស្ចើមានចំនួនតិច ។ ឯទូបអូស្ត្រាលីក៏មានដីខ្សួលច្រើនជាងពាក់កណ្តាលដែរ ឯទូបអាមេរិកខាងជើងនិងខាងត្បូងមានដីខ្ពស់ប្រហែលៗគ្នា តែទូបអាមេរិកខាងជើងមានទំដីទំនាបតិចជាង ព្រោះដែលបផ្ទាំងធំនៃទូបអាមេរិកខាងជើងរាងតាណាជានឹងអាមេរិក មានកំពស់ជាង ១៨០ ម៉ែត្រ ឡើងទៅស្ទើរតែពាក់អស់ ។

១៥ – អំពីមហាសមុទ្រ – បានពោលហើយថា លើផ្ទៃពិភពលោកយើងនេះ មានចំនួនទឹកដល់ទៅ ៣៦៣.០០០.០០០ គីឡូម៉ែត្រក្រឡា អ្នកប្រាជ្ញភូមិសាស្ត្របានមែងចែកទឹកដ៏ធំសំបើមនេះបេញជា ៥ ភាគគឺ:

ឈ្មោះមហាសមុទ្រ	គិតជាគីឡូម៉ែត្រក្រឡា	ជំរៅគិតជាម៉ែត្រ
១. ប៉ាស៊ីហ្វិក	១៦៧.០០០.០០០	៤៤៥០
២. អត្លង់ទិក	៩០.៦០០.០០០	៤៤១០
៣. ឥណ្ឌៀ	៦៤.៧០០.០០០	៦៨៨៩
៤. អាក់ទិក	១៤.០០០.០០០	៣៩៦០
៥. អង់តាក់ទិក	១១.០០០.០០០	–

១៦ – អំពីទឹកសមុទ្រ – ហេតុដែលទឹកសមុទ្រមានរសជាតិប្រៃដើតមកអំពីជាតិអំបិលចំពួកផ្សេងៗ ឯសមុទ្រណាដែលមានទឹកក្តៅជាងចំហាយមានចំនួនតិច ហើយបានទទួលទឹកសាបដែលហៀរហូរ

ចូលមកអំពីជ្រោះជ្រលង ស៊ីជម្រៅទៅជាច់ខ្លួនច្រើន សមុទ្រនោះមានជាតិអំបិលតិច ទើបធ្វើឲ្យទឹកសមុទ្រនេះមានរសជាតិមិនសូវប្លែក ។ ឯសមុទ្រណាដែលមានផ្លូវទឹកសាបហូរចូលតិច ហើយត្រូវកំដៅថ្ងៃខ្លាំងទឹកសមុទ្រក៏ស្ងួតទៅជាចំហាយច្រើន សមុទ្រនេះមានជាតិអំបិលច្រើនជួបជាសមុទ្រក្តៅប្លែកខ្លាំងសេស ដ៏ស៊ីជម្រៅ មានរសជាតិប្លែកបំផុតក្នុងលោកដោយហេតុមិនបានទទួលទឹកសាបពីផ្លូវទឹកតាមដងទន្លេណាមួយឡើយ ។

១៣.— អំពីហេតុរុំជ្លួលនៃមហាសមុទ្រ - ហេតុរុំជ្លួលនៃមហាសមុទ្រនេះមាន ៣ ប្រការគឺ ១.រលក ២.ខ្សែទឹក ៣.ទឹកឡើងទឹកចុះ (ជោរនាប) ។

រលក កើតឡើងដោយខ្យល់ដែលបក់ជាន់ទឹកឲ្យរេញ្ជួយលេចតួបប្តូរធំស្រែចហើយតែកំឡាំងរបស់ខ្យល់ ។

ខ្សែទឹក ហេតុដែលកើតខ្សែទឹក ដោយហេតុថ្ងៃទឹកកន្លងភាគក្តៅនៃតំបន់ណាមួយបានទទួលកំដៅថ្ងៃខ្លាំងក្លាជាងថ្ងៃទឹកកន្លងភាគឯទៀត ។ ដូចជាទៅភាគអាត្រជាក់ជាដើម ឈរលើទឹកក្តៅក៏មានអាការៈជាំងខ្លួនវាឡើង ទើបធ្វើឲ្យថ្ងៃទឹកចំណែកនេះខ្ពស់ឡើងជាងទឹកកន្លងភាគអាត្រជាក់ ទឹកត្រជាក់ហើយមានកាយវណ្ណជាងទឹកក្តៅ ទើបធ្វើឲ្យទឹកកន្លងភាគក្តៅហៀរហូរលិចទៅលើផ្លូវទឹកតាមប្លែលោកទាំងពីរដែលមានតំបន់ទឹកខាងជាង ទើបធ្វើឲ្យតែងតែខ្សែទឹកលើទឹកឡើង ។ ឯទឹកសមុទ្រកន្លងភាគត្រ-

ជាក់រង្គាវដែលមានទម្ងន់ណែនតាន់ក្រែន នោះជាហេតុធ្វើឲ្យទឹកនេះហូរ ជ្រែកចូលទៅក្នុងទឹកខាងកាត់ក្តៅដែលស្រាលជាង ទើបជាហេតុឲ្យកើត ខ្សែទឹកខាងក្រោមទឹងឡើង តែដំណើរបែបនៃខ្សែទឹកនោះ មិនហូរត្រង់ ទៅទិសខាងជើងនឹងខាងត្បូងត្រង់ៗ តាមដែលយើងយល់ដូចប្លែកទេ ព្រោះមានហេតុដទៃទៀត ជាគ្រឿងប្រែកចទើបជាហេតុឲ្យខ្សែទឹកផ្លាស់ផ្លូវដើរ ទៅមែន ។ ពីគ្នា គឺ :

១. — ផ្លូវខ្សល់ប្រចាំ អ្នកច្បាស់ក្នុងកូមិសាស្ត្រជាច្រើននាក់គោលថា ខ្សល់ប្រចាំផ្លូវ ជាហេតុយ៉ាងសំខាន់ដែលធ្វើឲ្យខ្សែទឹកហូរទៅតាមផ្លូវណាណានិមួយបាន ក្នុងកាតដែលមានខ្សល់បក់ទៅទិសខាងលិចឆ្ងៀងខាងជើង ឬទិសខាងលិចឆ្ងៀងខាងត្បូង រមែងមានហូត ១ ឆ្នាំពេញ យើងនិងមើលឃើញខ្សែទឹងដែលហូរចេញពីកាតក្តៅ សំដៅទៅទិសខាងលិចតែមួយផ្លូវ ដូចខ្សែទឹងនៅខ្សែសូន្យខាងជើងនិងនិងខ្សែសូន្យខាងត្បូងជាដើម ។ នៅតំបន់ដែលមានខ្សល់ប្រចាំបក់ទៅទិសខាងកើតតែមួយផ្លូវ ដូចខ្សែទឹកអន់តាទឹងនិងខ្សែទឹកកុកេស៊ីកេជាដើម ។

២– ការរើលជុំវិញខ្លួនឯងនៃពិភពលោក — . ការរើលជុំវិញ ខ្លួនឯងនៃពិភពនេះរមែងធ្វើឲ្យវត្ថុផ្សេងៗ មានអាការៈញ្ជួយទៅតាមផ្លូវ ពិភពដូចខ្សល់ទឹងនិងខ្សែទឹកជាដើមផ្លាស់ប្រែផ្លូវទៅបាន នៅតាមខាងជើង

ខ្សែសូន្យនឹងចែករវៀងផ្លូវទៅខាងស្តាំ ហើយកាងខាងក្បែរសូន្យនឹងចែករវៀងទៅខាងឆ្វេង ។

៣ – អំពីទីតាំងផែនដី – ប្រសិនបើមិនមានផែនដីតាំងនៅតាមបរិវេណខ្សែសូន្យទេ ខ្សែទឹកក៏នឹងហូរទៅជុំវិញលោកសំដៅទៅទិសខាងលិចហួតទៅ ប៉ុន្តែការបើមានផែនដីមកខ្ទប់ទឹក ផ្លូវដើរបស់មុខទឹក ក៏ត្រូវតែចែរវៀសចែងទៅតាមទិសខាងជើងខ្លះទៅទិសខាងក្បែរខ្លះ ហើយជាដើមហេតុធ្វើឲ្យទឹកក្តៅ ដែលហូរចេញពីកាងក្តៅបង្កើលោកហៀរហូរបួលទៅកាន់ទីដែលត្រជាក់ជាង មានចំណែកទឹកខ្លះដែលហូរទៅប៉ះដំបូងនឹងពីមុខនេះចែរជាហូរវិលត្រឡប់មកទិសខាងដើមវិញវៀតក៏មាន ។

– ១៨ អំណាចរបស់ខ្សែទឹកដែលទាក់ទាមនឹងអាកាស

ទឹកទន្លេក្តៅដែលចេញពីកាងក្តៅជួយធ្វើឲ្យទន្លេកូមិទៅចែងខាងកំពូល (ប៊ូល) លោកសុះខ្ពស់ឡើង ឯទឹកត្រជាក់ចេញអំពីតំបន់ជាជួយបន្ថយទន្លេកូមិក្នុងតំបន់ផ្សេង ។ នៅចំណែងខ្សែសូន្យ ។ ដែលពោលមកនេះមានគំរូតាងមើលឃើញច្បាស់ នៅចំណែងខាងមហាសមុទ្រអត្តឡង់ទិចខាងជើងនោះ មានខ្សែទឹកនឹងខ្សាច់ទិសខាងកើតឆ្ងៃងខាងត្បូងខាងជំណើរទៅជាមួយគ្នា ជួយធ្វើឲ្យកំពង់កប៉ាល់ប្រទេសណារ៉ែសតទឹកកកហួតតេញ ១ ឆ្នាំ ។ ឯកំពង់កប៉ាល់ក្នុងសមុទ្រដែលនៅក្រោមប្រទេសណារ៉ែសចុះមកដល់ ៨០០ គីឡូម៉ែត្រឡើងទៅ ដូចជានៅក្នុងសមុទ្រ

ប៉ាក់ទឹក ទឹងសមុទ្រខ្មៅជាដើម គ្រឿប់ជាមានទឹកចូលកណ្តាលក្នុងកន្លែងដូច
រាជាហេតុធ្វើឲ្យកប៉ាល់ដំណើរនាមើរតាមកំពង់អស់នេះ គោងឈប់
ផ្អាកជាច្រើនថ្ងៃ ។ ខាងក្បែរអាមេរិកក៏មានតំរៀបបន្ទះដែរ តែខ្សែទឹក
គ្រាជាក់អាកទឹកហូរចុះមកខាងក្រោម (ខាងត្បូង) ទឹកហូរកាត់ច្រាំង
សមុទ្រទិសខាងកើតរបស់ប្រទេសកាណាដាទឹងមហាដ្ឋានអាមេរិក ធ្វើឲ្យ
ច្រាំងសមុទ្រឡើងត្រជាក់របស់ប្រទេសកាណាដា ដែលតាំងនៅក្នុងខ្លួនខ្សែ
ជាមួយទឹងប្រទេសអង់គ្លេស គ្រឿប់ជាមានទឹកកកចាប់នៅបានយូរដល់
៩ ថ្ងៃ ហើយធ្វើឲ្យស្រែកណែរយំកដែលតាំងនៅក្នុងខ្លួនខ្សែលើគ្រឹម ៤០
អង្សា មានអាកាសគ្រជាក់ខ្លាំងក្នុងរដូវរងារប្រហែលទឹងភាគខាងជើងផុត
នៃប្រទេសណារ៉ែសដែលតាំងនៅខ្សែខ្លួនលើដល់ ៧១ អង្សា ។

ខ្សែទឹកតែងប្រែតល់ទណ្ឌកូមឲ្យខ្យល់ហើយខ្យល់ចក់យកកំដៅ ឬ
គ្រជាក់ទៅប្រែតល់ឲ្យផែនដីមួយជាន់ទៀត ។

១៩ — អំពីខ្សែទឹកក្នុងសមុទ្រ — ខ្សែទឹកក្នុងសមុទ្រនោះ
មិនចាក់ចំនួនដូចខ្សែទឹកក្នុងមហាសមុទ្រទេ ឯខ្សែទឹកក្នុងសមុទ្រកើតពី
ហេតុសំខាន់ ២ ប្រការ គឺទឹកសមុទ្រគ្រែកំដៅថ្ងៃដុតឲ្យក្តៅជាចំហាយ
ឡើងទៅប្រការ ១ ហេតុដែលទន្លេជ្រោះជ្រលងដងស្ទឹងបង្ហូរទឹកសាប
មកចូលសមុទ្រប្រការ ១ តែប្រសិនបើបរិមាណទឹកសាបមានចំនួនច្រើន
ជាងបរិមាណទឹកសមុទ្រដែលក្តៅជាចំហាយ។ ទឹងកើតទៅជាខ្សែ

ទឹកហូរបួលទៅមហាសមុទ្រ ដូចយ៉ាងកន្លះសមុទ្រខ្មៅ, សមុទ្រប៊ែលហ្ក, ឈូងសមុទ្រហ៊ែសស្យុនធំឈូងសមុទ្រសៀមជាដើម ។ ប្រសិនបើចំនួនទឹកសមុទ្រដែលក្តៅឆាប់ចាយទៅច្រើនជាងទឹកដែលហូរមកពីផ្លូវទឹកផ្សេង ។ ក៏ធ្វើឲ្យកើតជាខ្សែទឹកមហាសមុទ្រហូរបួលមកកន្លះសមុទ្រនោះ ។ វិញ ដូចជាខ្សែទឹកកន្លះសមុទ្រមេឌីតេរ៉ាណេធំសមុទ្រក្រហមជាដើម ។

២០ - អំពីទឹកជោរឆាប.— នៅតាមជាយសមុទ្រធំជាច្រើនតែងមានស្ទឹងចាំងបួលដែលទៅជិតសមុទ្រ តែងមានទឹកចុះ ។ ឡើង ។ ជាទិច្ចដែលហៅថាទឹកជោរឆាប គឺតាលម៉ោទឹកចុះខាបជាលំដាប់ដំបូងហើយក៏ជោរដែនឡើងវិញជារៀលច្រមាណ ៦ ម៉ោង ១៣ នាទី តាអំពីនេះទៅទឹកក៏នាំចហូរចុះទៅវិញដូចដើម ជារៀល ៦ ម៉ោង ១៣ នាទីដែរ តែងតែដូច្នេះរាល់ ។ ថ្ងៃ ក្នុងរៀល ២៤ ម៉ោង ៥១ នាទី ធំងមានទឹកឡើង ២ ដងទឹកនាប ២ ដងជាដរាប ។

ហេតុដែលមានទឹកឡើងចុះនេះ កើតមកអំពីអំណាចរបស់ដួងចន្ទ ។ យើងដឹងច្បាស់ហើយថា វត្ថុផ្សេង ។ មែងមានភាគារស្រូបទាញយឺតឆោងគ្នាទៅវិញទៅមក មានចំនងដូចជាលោកនិងដួងចន្ទដួងអាទិត្យ សឹងមានភាគារស្រូបទាញយឺតយោងគ្នា អំណាចយឺតយោងនៃដួងចន្ទនិងដួងអាទិត្យនេះហើយ ជាបច្ច័យយ៉ាងសំខាន់ក្នុងការធ្វើឲ្យមានទឹកជោរនាបនៅលោកយើងនេះ ។ ភាគណានៃពិភពលោកជាកន្លែងទៅចំដួងចន្ទ

ភាគនេះនឹងមានចំការជោរជន់ឡើងច្រើនជាងភាគជាច្រើនទៀត ឯភាគផ្សេងដ៏
មួយចំហៀងទៀត ដែលនៅចំនឹងភាគដែលនៅជិតជួរជ្រលក់មានចំក
ជោរជន់ឡើងដែរ តែ ២ ភាគទៀតនោះនឹងមានចំកស្រកទៅវិញ ។

តាមធម្មតា ការរំលែងជួរជ្រលកនេះ ធ្វើឲ្យចំកសម្រួលគ្រប់ ។
កំពស់ជោរនោច ២ ជង្រុក ១ ថ្ងៃគឺ ជារ ២ ជង នាច ២ ជង លុះក្រុងថ្ងៃ
ត ។ មកចំកជោរនោចនឹងយឺតជាងថ្ងៃដំបូង ។ ប្រមាណ ៥១ នាទី ដូចជា
ថ្ងៃនេះចំកជោរឡើងវេលាមោង ៤ ២ ថ្ងៃត្រង់ លុះដល់ថ្ងៃស្អែក ចំកឡើង
កន្លងវេលាមោង ១២ និង ៥១ នាទី ដោយអំណាចការនោចរបស់
ជួរជ្រលក់ ឃ្លាតចេញពីដំណែងដើមចន្លោះ ។ ទៅជានិច្ចកាលថ្ងៃ ទើបធ្វើឲ្យ
ចំកជោរនោចមានដំណើរយឺតជាងថ្ងៃមុន ។ ប្រមាណ ៥១ នាទីកន្លះថ្ងៃ ។

ឯជួរគាទិត្យក៏មានចំណែកជួយធ្វើឲ្យកើតចំកជោរនោច ជាន ។ ដែរ
តែកំឡាំងជួរគាទិត្យដែលយឺតយោងលោកមានកំឡាំងខ្លាំងជាង
ជួរជ្រលក់ច្រើនប្រមាណ ២ ក្រុង ៥ ភាគ ព្រោះជួរគាទិត្យនៅឃ្លាតឆ្ងាយ
ពីលោកយើងជាងជួរជ្រលក់ ៤០០ ភាគ ។

អ៊ីពីទីកប្រែធ្លាប់ — ឈរណាជួរគាទិត្យជួរជ្រលក់ទាំងពីរយ៉ាងខ្លាំង
ជាមួយគ្នានឹងរលាក ទើបជួរគាទិត្យនឹងជួរជ្រលក់រួមកំឡាំងគ្នាជាពីរស្រួប
យកលោកនេះ ទើបធ្វើឲ្យចំកជោរជន់ឡើងច្រើនខុសប្រក្រតី (ត្រង់ចន្លោះថ្ងៃ
១៨-១៩ កេរ ឬ ១៩ កើតឬក្រោយនេះ ១ ថ្ងៃ ២ ថ្ងៃ) ចំកច្រើននេះមាន

កន្លះ ១ ទៀ ២ ដង មានន័យ: ឃ្លាតគ្នា ១៥ ថ្ងៃ នៃថា ខែដូនតាគិត្យនៅជាកាច់ ថ្ងៃនឹងដួងចន្ទ្រ ដូចជាកន្លះពេល ៧.៨ ខាងខ្វៃតឬខាងរនោច តំណាងយីតយោងរបស់ដួងចន្ទ្រនឹងដួងអាទិត្យទៅជាប្រែដែនគ្នាមិនស្របគ្នាទេ ទើបធ្វើឲ្យខែកន្លះនៃបន្តិចបន្តួចប៉ុណ្ណោះ ចំពោះនេះកន្លះ ១ ទៀមាន ២ ដងវិញ។

ឯតំណាងយីតយោងរបស់ដួងចន្ទ្រដែលមានមកលើផ្ទៃពិភពនេះ ប្រែជាល ៥ ភាគ តំណាងដួងអាទិត្យ ២ ភាគ កាលដែលមានរឹតជាវេន ខ្លីវែងទៀន ដួងចន្ទ្រនឹងដួងអាទិត្យរួមតំណាងគ្នាយីតយោងនឹងកន្លះទើបត្រូវជាតំណាងយីតយោង: ៥ + ២ គឺ ៧ រីឯដែលមានចំពោះកន្លះតិចតំណាងយីតយោងទើបត្រូវជា: ៥ — ២ គឺ ៣ ក៏តែចំពោះកន្លះថ្ងៃចំពោះប្រែជាបើធៀបនឹងថ្ងៃចំពោះតិច ទើបត្រូវជា: ៧ - ២ ។

វគ្គទី ៣ ដំណាយពីខ្យល់អាកាស

២១ — បរិយាកាស. — គឺអាកាសដែលហ៊ុំរុំផ្ទៃផែនដីនេះ អាកាសនេះមានជាតុចំហាយផ្សេងៗ បើរួមរួមៗប្រមាណ ១០០ ភាគនឹងមានជាតុចំហាយមានប្រមាណដូច្នេះ គឺនីត្រូសែន ៧៧, ១២ ទក្សីសែន ២០, ៦៦ ចំហាយទឹក ១,៤ អាកុង ០, ៧៤ ទក្សីតការបូន ០, ០៣, ទឹងជាតុចំហាយហ៊ីត្រូសែន ត្រចកុង ឌីអុង ទឹងហ៊ាលីម ម្យ៉ាងចន្លះៗទៀត ។ កន្លះបរិវេណជុំតៗថ្ងៃលោកដោយជុំវិញនេះ (មានន័យ)

ភាគទី ១៥

ឃុនសុន្ទរមេធ ញ្ជង-សើរឿង ប្រៃ
លោក ហង់-គិមសេង ពិនិត្យ

(តមក)

ត្រាវដែលបានឃើញថេរខ្មែរដុនហាស្ត្រនចូលទៅដល់ភ្នាម ស្ត្រីទាំងឡាយក៏ផ្តើលឈូសរោមមើលគ្រប់គ្នា ហើយសើចសរសើរកល់មាត់អំពីលក្ខណៈសក្តិសមឥតខ្ចោះរបស់កំឡោះនោះ; កាលថេរខ្មែរដុនហាស្ត្រនអង្គុយហើយ ឥតមានស្ត្រីណាមួយអង្គុយស្ងៀមត្រង់តន្លែងខ្លួនបានទេ នាំគ្នាក្រោកឈូសរោគចូលទៅជិតពិនិត្យមើលឲ្យច្បាស់លាស់។ ដល់វេលាថយទៅកាន់កន្លែងរបស់ខ្លួនវិញ ស្រីទាំងឡាយនោះមានសេចក្តីអន្ទះអន្ទែងព្រួចចិត្តគ្រប់ៗគ្នា ។

ថេរខ្មែរដុន ហាស្ត្រន នឹងបុរសតម ខុសប្លែកពីគ្នាឆ្ងាយណាស់ ព្រោះបុរសតមនោះមានរូបអាក្រក់ ក្រែណានឹងអាក្រក់ មើលទៅគួរឲ្យខ្ពើមរអើម នាំបណ្តាលឲ្យបណ្តាជនក្នុងទីសន្និបាតនោះខ្សឹបខ្សៀវគ្នាអ្វី។ ពួកស្រីៗអត់ត្រាមិនបាននាំគ្នានិយាយតវ៉ាឡើងថា "ត្រូវតែឲ្យកូនក្រមុំយើងមកអួតអំនួតំឡោះរូបស្រស់នេះវិញទើបសម, មិនត្រូវឲ្យទៅបុរសតម

តំរក់នោះទេ" ។ ស្រីចាំងឮយមិននៅស្ងៀមស្ងាត់តែប៉ុណ្ណោះទៀត
ហើយដល់ទៅគោះរួសបន្ទោសដៀលន្ទះដល់ស្តេចទៀតផងថាមិនសមចើ
ឃាត់អាជ្ញាបង្ខិតបង្ខំឲ្យគេមនុស្សអស់កម្លាំងមកបម្រើមួយនឹងស្រី
ដាមង្គលតែម្តងណ៍ផ្លេះលោះ ។ មិនតែប៉ុណ្ណោះសោតស្រីចាំង
នោះ ទាំងបន្ទុះបង្អាប់ដេរប្រទេចផ្តាសាតំណាតកំហែងប្តូរសេតមឲ្យស្លុត
កាន់តាំងស្មាតើ, ស្រួសស្តីឮមាត់ណាន់ទៀតហ៊ានតែងឲ្យប់សឮសាយតេញ
តាំងផ្ទះ តាល់តែគ្មានដែលតំពូងលេងតទីទោះ ឈប់បន្តង់អស់មួយ
ស្រុកៈ លុះស្តេចមាត់ការពែតរោចហើយ ទើបពួកអ្នកភូមិចាប់លេង
តទៅទៀត, ចំណែកស្រីៗ ដែលចំរើនទឹងសំអិតសំអាងតែងខ្លួនឲ្យកូន
គ្រប់កំដរតួលទៅដូចនាង ។

គ្រប់ ១ ខណៈដែលផ្ទាស់ប្តូរសំលៀកបំពាក់, ឆ័ត្រនោះក្រែកពី
កន្លែងខ្លួន ឃាតចាំងពួកស្រីសាមចំការវិហាមអមទៅផង ដើរកាត់មុខ
ប្តូរសេតម ដោយវត្តពិតពិលរមិលមើលបន្ទិចសោះ ហួសទៅឈរខាង
មុខរបេទ្វេខ្លួន ហាស្ត្រីន ដើម្បីបង្ហាញឲ្យគេមើលគ្រឿងតែងខ្លួនថ្មីៗ ។
ខណៈនោះ បេះទ្វេខ្លួន ហាស្ត្រីន ធ្វើតាមៗបាយដែលបិសាចបាន
តឲ្យល់ហើយ ទើបលួតយកថ្នាំតំពក្តងថង់តេញៗដៃ ហុចដែកឲ្យស្រីៗ
ដែលវិហាមអមកំដរគ្នាស្រែកថ្នូរតែមចាំងបុចសាចឲ្យពួកអ្នកភូមិទំងពួក
ច្បាំងផង មើលទៅគួរឲ្យសេចក្តីរីករាយណាស់ អ្នកចាំងមស់ នោះដណ្តើម

រើសច្បាក់ជ្រលក្រមល់ពពាក់ពពួនប្រដៀតរុញច្រានគ្នាទៅវិញទៅមក, ចុងសំដែងសេចក្តីដឹងគុណជាអនេកហើយឲ្យសញ្ញាថា, គេចាំងអស់គ្នាពេញចិត្តឲ្យខាងតែម៉ុំមកបេះខ្លែងដែន ហស្សន៍វិញ, មិនត្រូវឲ្យទៅប៉ុនសមនេះទេ; ពួកស្រីៗដែលកំដរស្រែករកំចាន់ជាឆ្នើយស្ទុះស្រែបគ្នាជូរចាវដែរ ហើយឥតរលែរើពើនឹងប៉ុនសមសោះ ។

កាលបើពិធីផ្លាស់ប្តូរសំលៀកបំពាក់ជារួចរាល់ហើយ ពួកអ្នកភ្លេងក៏ឈប់លេងហើយចាន់ឲ្យសញ្ញាដល់បេះខ្លែងដែន ហស្សន៍ថាឲ្យទៅកន្លែងបន្ទប់នោះបុះ រួចគេនាំគ្នាថយចេញអស់ទៅ ។ ចន្លោះមក ស្រែចាំងឡាយចាន់ឲ្យសញ្ញាជូនគ្នាហើយចេញទៅដែរ, ចំណែកខាងកវីយោជាសាមីខ្លួនបួលទៅកន្លែងបន្ទប់តូបស្រាច់ផ្សំដំណេកមានស្រីៗជាច្រើនបួលតាមទៅជាមួយផង ដើម្បីជួយដោះសំលៀកបំពាក់ក្នុងបន្ទប់ធំនៅសល់តែបុរសគម, បេះខ្លែងដែន ហស្សន៍ចាំជាវិញ្ញាណីរៈបីនាក់ ។ បុរសគមកើតសេចក្តីក្តៅក្រហាយខ្លាំង ដោយឃើញបេះខ្លែងដែនហស្សន៍ក្រាញទៅក្នុងបន្ទប់ មិនព្រមចេញទៅជូរចាវនាំឲ្យមន្ទិលសង្ស័យ ទើបសំឡឹងសំឡក់ហើយចរណ្តាញថា "នែអ្នកនេះ, អ្នកឯងនៅចាំអី? ម្តេចក៏មិនចេញទៅក្រៅដូចអ្នកឯទៀត? បៀសចេញឆាប់ៗទៅ" ។ បេះខ្លែងដែន ហស្សន៍ គ្មានអំណាចក្តីខ្លាំងទៅក្នុងបន្ទប់នោះក៏ចេញទៅចាំងទ្រមទ្រាមសល់ក្នុងតំនិត, ប៉ុន្តែចេញទៅមិនបានចាំង

ផ្ទុកហួសតាំណែនខ្លួនក្បែរនេះ ស្រាប់តែបិសោចនាំគ្នាមេតាអប្បរមេន
ឈរកាំងស្កាត់មុខហើយបិសាចសួរថា "អ្នកចេញទៅឯណាវិញ? មិន
ត្រូវចេញទៅណាទេ, ទៅតទីនេះហើយ, ឯងតមអោនមិនបានទៅតទី
បន្តប់ទេ, កាលមុនជាន់ធីមានរឿងហេតុចេញទៅក្រៅតិចតួចហ្នឹងហើយ, អ្នក
ត្រូវតែហួលទៅវិញហើយចូលទៅក្នុងវល់តងីបន្តប់ប្រពន្ធ កុំបីកោត
ញញើតឡើយ កាលបើចូលទៅជួបស្វាត់តែពីរនាក់ហើយ អ្នកត្រូវ
និយាយថ្កាប់ខាងថាខ្លួនអ្នកហ្នឹងឯងហើយជាប្តីពិតថ្កាកៗ; — ឋាតែ
កងាវែលទ្រង់ផ្តាំប្តូរសេតមឲ្យជាប្តីបេះនាងនោះ តែនាំតែជាកិច្ចចំតន្ត
លេងតំសាន្តព្រះទ័យប៉ុណ្ណោះ មិនមែនឲ្យធ្វើជាប្តីពិតថ្កាកៗទេ; រួច
ហើយថ្កាប់ខាងទៀតថា តាតមអោះ ឥឡូវនេះអ្នកឯងបានឲ្យតេរៀបចំនំ
ៗ យកទៅឲ្យក់ស៊ីតងីកនីសេងណោះដើម្បីកុំឲ្យកំតន់ចិត្តពេក ។
អ្នកត្រូវទំនេរទេបានផ្សងៗទៀត និយាយលួងនាងយ៉ាងម៉េចឲ្យតែខាង
បានផ្សាំជាក់ថ្កាកៗ; កាលបើបានធ្វើតាមយ៉ាងនេះហើយ, តា
អោះមិនមែនជាត្រលំថ្កាកអ្វីទេ នាងមុនជាន់ធីបានតែកាយជាយយល់
ឃើញថា តាវែលនាងតាន់ប្រថ្នាអោះនាំឲ្យបានសប្បាយទៅវិញទេ
តែ ។ អ្នកកុំភ័យឲ្យសោះ មិនអីទេ. តងីពេលអោះខ្ញុំនឹងជាក់តាស្តែ
បង្គាប់កុំឲ្យតាតមចូលទៅបាន ហើយកុំឲ្យក់ចូលទៅតេរឿនរ៉ុកតួនអ្នក

ដែលកំពុងនៅជាមួយប្រពន្ធក្មេកគ្រែ ព្រោះនាងនោះពិតជាប្រពន្ធអ្នក ហើយ មិនមែនរបស់អាតមរេ" ។

គ្រាដែលបិសាចបានឮយ៉ាងនេះ ក៏ឡើងកំហឹងជាខ្លាំង ហាស្ទ្រីនកុំឲ្យកិតភ័យ មិនបានពន្យល់ទេបាយតែមួយម៉ាត់ ប៉ុស្តែតម ក៏ប្រញាប់តអំពីចន្លុះធំ ។ បិសាចបួលទៅបួលហើយ ដល់ណែនខ្លួនដាច់ខ្លាំង ស្រែកដាំរៗ តម្រាមចន្លោះបុរសតមៗ ឃើញដូច្នោះ ក៏ទះដៃស្រែកដេញបន្លើល, ប៉ុន្តែឆ្នាមិនរត់ ចេះជាដំឡើងក្រពកក្រញាង ចេកក្អែកៗមក្រឡេតសំឡឹងសំឡក់បុរសតមស្ទើរតែនឹងស៊ីសាច់ ។ ស្រែកតម្រាមខ្លាំងឡើងៗហើយពន្លឺកខ្លួនឲ្យធំចង្កិចម្តងៗ ពាល់តែប៉ុនកូនលា ។ បុរសតមភ័យខ្លាំងណាស់ រៀបនឹងហាមាត់ស្រែកហៅឲ្យគេជួយ, ប៉ុន្តែគេស្រែកពុំរួច គ្រាន់តែឈរញោមាត់ច្រហាដោយសេចក្តីភ័យតក្តមាស្ទើរស្លុតស្រឡាំងកាំងតាំងស្មារតី; ដើម្បីធ្វើឲ្យកែតភ័យខ្លាំងឡើងទៀត បិសាចតាំងត្រឡប់ខ្លួនក្លាមទៅជាក្រមុំយ៉ាងធំសម្បើម ហើយស្រែកចំ-ភ័យថា "អាតមចោលមេ្លឹត! អញវែងសម្លាប់ឥឡូវហ្មឹងហើយ!" ។ ឮពាក្យដូច្នោះហើយ បុរសតមដួលខ្លាកទៅលើគ្នារ យកអាវទ្រូងត្រួតបា្លស ដើម្បីកុំឲ្យមើលឃើញក្រមុំនោះ, ទំត្រដរធ្វើយតាំងញញ៉ាញញ៉ែរថា "បពិត្រលោកជាស្តេចមហិទ្ធា, បុះលោកសួរខ្ញុំថាមពីរឿងអី?" ។ បិសាចតបភ្លាមថា "គ្រោះធំហើយអាឯង! អាឯងត្រូវមើនចិត្តធំហ៊ានមក

រឿងការខ្លួនជាមួយនឹងលោកស្រីយើង ! ” ប៉ុស្តេតមាំងអង្វរថា “ ខ
លោកម្ចាស់ថ្លៃនើយ, តាម តាលោកមេត្តាគាត់ទោសឲ្យខាន : ប្រសិនបើខ្ញុំ
ធ្លាប់ជាមនុស្សដាមទោសធ្ងន់កំមិនមែន គ្រោះការព្រោះចិត្តធំទេ តែ
ដោយសេចក្តីល្ងង់ខ្លៅពិតៗ ខ្ញុំធ្លាមិនដឹងជាស្រីនេះមានគ្រូបីជាតួ
ស្នេហាទេ; បើខ្ញុំធ្លាខុសធ្ងន់ដូចម្តេច សូមលោកបង្គាប់តាមសេចក្តី
ពេញចិត្តចុះ, ខ្ញុំធ្លាខន់ធំរងទូលថ្វាយបង្គំតាមតាំងអស់ ” ។ ប៉ាសាបន្ទូល
ទៅនឹងថា “ ត្រាសម្ចាស់! បើគាងធំរចេញពីទីនេះទៅ ឬបើមិនទៅឲ្យ
ស្រួលមហូតដល់ថ្ងៃរះទេ, ពុំនោះសោតបើគាងធំរហើយមានតំនាំយយោងភាក្យ
ស្តីតែមួយម៉ាត់ អញនឹងវាំចំបែកក្បាល ។ ល្អើយចុះ អញអនុញ្ញាតឲ្យ
គាងធំរចេញទៅពីផ្ទះនេះ, ប៉ុន្តែត្រូវចេញឲ្យរហ័សកុំជាក់ក្រែយឲ្យសោះ
ប្រសិនបើគាងធំរហ៊ានតែអើតក្បាលមកវិញ អញនឹងផ្តាច់ដំរែគាងធំរឲ្យ
អតបន្តិង” ។ លុះនិយាយដូច្នេះហើយ បាសាបក៏ប្រែកេទៅជាមនុស្ស
ចាប់ដើងចុះសេតមយ្យរឡើង សំបុង៉ក្បាលចុះគ្រែមហាកំដូចជានឹងអ្នក
ផ្ទប់នឹងជញ្ជាំង ហើយនិយាយទៅមកខ្លួនឯងថា “ បើគាងធំរទៅមិនស្រួម
ទៅឲ្យលំនឹងថ្ងៃរះទេ, ដូចអញបានថាវិលមកវិញ, អញនឹងចាប់ដើង
ត្រកាត់ចោតចំបែកក្បាលនឹងជញ្ជាំងនេះពុំខាន ។

ចំណែកខាងបេក្ខែខំនិនហាស្សុន, កាលបើបិសាចនីនាងខេត-
អប្សរនិយាយចាក់ដើងដូច្នេះហើយ, ក៏ចូលទៅរកអង្គុខេដ៏
ចាំស្តាប់ដើងការរបស់ខ្លួន; មួយស្រែចក់ ទើបដួងចាស់ម្នាក់ ទាំងពួ
មកបញ្ជាលកន៏ចន្ទប់នោះហើយ ខ្លួនគាត់មិនបានចូលទៅផងទេ ឈរតែម
ក្បែរមោកទ្វារ ឥតបានពិនិត្យមើលថាគឺជាបុរសឥតម ឬក៏បុរសឯទៀតឡើយ
គ្រាន់តែនិយាយឲ្យដួងទាំងពីរស្តាប់ថា គ្រូទេវតាបានធ្វើតាមប្រាថ្នាណាស្តាម
ការយោគតាមសេចក្តីប្រាថ្នាចុះ ហើយគាត់ចង់ទ្វារលែងឲ្យចេញចូល ។

នាងជាតិរបាមានសេចក្តីឆ្ងឿនឆ្ងល់ណាស់ ព្រោះមិនឃើញ
បុរសឥតម ចែរជាឃើញឯបេក្ខែខំនិន ហាស្សុនទៅវិញ ដែលជាបុរស
ប្រកបដោយគុណសម្បត្តិយ៉ាងឯកកន៏លោក ទើបនាងសួរថា "នែអ្នក
ប្រុសសំឡាញ់, ម្តេចក៏អ្នកមកទៅកន៏ចន្ទប់នេះតាមកំណត់មោង, ហេតុ
ដូច្នេះ អ្នកត្រូវជាគូកនស្វាមីខ្ញុំឬ?" បេក្ខែខំនិន ហាស្សុន តបថា
មិនមែនទេនាង, ខ្លួនខ្ញុំនេះ មានហ៊ានៈផ្សឹងពីតាគម អប្រិយទោះទេ ។
នាងនិយាយទៀតថា "សូមអ្នកប្រយ័ត្នកុំនិយាយកាត់ពីស្វាមីខ្ញុំ ។
បេក្ខែខំនិន ហាស្សុន តបថា នែនាង, ក៏ជាប្តីរបស់នាងមែន! នាង
មានគំនិតយល់ដូច្នេះ យូរយារាល់ហើយឬ? មិនមែនទេ នាងកុំកាន់
ច្រឡំ, ធម្មតាជាតិស្រីត្រូវលក្ខណ៍ច្បាប់ហាលធុននាងមិនត្រូវទៅរួម
រស់នាជាមួយនឹងមនុស្សអប្រិយធុនថោក ដែលអ្នកផងគេស្អប់ខ្ពើមដូច្នេះ

ដោយការជាប់ឃុំ ខ្ញុំឮតាមពាក្យចចាមអាម ក្រសួងនោះមិនអាចនឹងផ្តើមឲ្យមានរឿងនយោបាយដុះដុលឡើងដោយគ្មានភ័ស្តុតាងសោះ ដើម្បីនឹងឲ្យមានសំអាងគេបាននិយាយរាវែលបានដើរតាមផ្លូវសមុទ្រ ក្លែន (ligne de navigation Glen) ហើយគេបានដឹងច្បាស់ថាមានកប៉ាល់មួយមានគេជួលពុត ព្រោះហេតុដូច្នេះ រដ្ឋាភិបាលមានភ័ស្តុតាងនាំឲ្យយល់ច្បាស់ថា សេចក្តីឯការ (rapport) លោកគ្រូពេទ្យនេះពិតហើយគេអាចសំគាល់ថា ជាឯបមកិច្ចក្នុងការឯញ្ជូនខ្ញុំទៅប្រទេសចិន

វិញ គាំងពីនោះមក រឿងនេះធ្លាក់ទៅលើរដ្ឋាភិបាលសម្រេចសេចក្តី
ខ្លួនឯងតែម្តង ។

ពេលការមួយក្រសួងបានចាត់ឲ្យមានចារបុរស (détective) ម្នាក់
ដើម្បីទំនងយ៉ាំមើលជុំវិញគេហដ្ឋានអគ្គភេជន្ធបតីខ្លួនឯង ហើយបានបង្គាប់ទៅ
ក្រុមតម្រួតនគរបាលនៅជិតខាងឲ្យជួយខ្នះខ្នែងក្នុងការនេះ ។

ថ្ងៃព្រហស្បតិ៍ ២៦ ខែធ្នូ ពេលរសៀលមានអ្នកផ្សាយតំណាង
ទាងទាសែត ក្លូប (Globe) បានមកជួបលោកកង់ឌ្វីនៅគេហដ្ឋាន ហើយ
ក៏បានសួរលោកពីរឿងដែលគេចាប់ឃុំឃាំងមនុស្សម្នាក់ នៅស្ថានអគ្គភេជ-
ន្ធបតីខ្លួន ។ លោកគ្រូពេទ្យតបវិញថា លោកបានជួបតែមានរឿងនេះ
នៅការសែត "ថៃម៍" ពីថ្ងៃ ១៨ ខែធ្នូ ហើយបានបន្ថែមសេចក្តីប្តឹង
ការសែតនេះពីថ្ងៃបន្ទុ ១៩ លោកក៏ត្រូវឲ្យការសែត "ថៃម៍" ប្តឹងផ្សាយជាបន្ថែម
តែលោកកង់ឌ្វីបានពោលទៅកាន់អ្នកផ្សាយការសែត "ក្លូប" ថា: សូម
លោកមើលសេចក្តីដែលលោកបានសរសេររឿងនេះ ហើយទុំទីដំណែ
តើជាពិតឬទេ ? លោកបានស្តាប់សេចក្តីពណ៌នាក៏ឃើញថាជាការណ៍ពិត
លោកអនុញ្ញាតឲ្យប្តឹង តែហាមកុំឲ្យដាក់ឈ្មោះលោក ។

ដល់ការសែត "ក្លូប" ផ្សាយរឿងនេះច្រើនហួសជាពីរដង ក្រោយ
មកមានពួកការសែតពីនោះខ្លះ តែការសែតសង់ត្រាល់នៃវ៉ស (Central

Neus) ទិនដេលីមេល៍ (Daily Mail) បានចូលមកជួបទិនលោកកន់ខ្ញុំក៏បានតណិនារឿងជាទុកលសព្វគ្រប់ ។

មនុស្សពាំនពីរនាក់បងប្អូនគេសេចក្តីពិត បានចូលទៅសួរទាន់មន្ទីរអគ្គកជក្ខុតចិន សូមជួបទិនឈ្មោះ ស៊ុន ។ អ្នកពាំនពីរស្រែសាប់តែចេះនិងចិនតាំង។ បានបដិសេធថាមិនស្គាល់ឈ្មោះស៊ុន ។ មានខ្លះបានយកយកការកាសែត "ក្លូប" ទៅបង្ហាញចិនតាំង។ ក៏សើចហើយពោលថា រឿងនេះគេក្លែតក្លាហកទេ តែបណ្តាធិការកាសែត "សង្គ្រាលនៃវៃ" គប ថាកុំឯងកុហក បើពុំលែងឈ្មោះ ស៊ុនទេ ស្ថានអគ្គកជក្ខុតមុខជាមានមនុស្សពាំនពាន់ចូលមកតវ៉ារឿងនេះមិនខាន ពាក្យពាំនប៉ុន្មានឥតមានត្រូបិត្តចិនតាំងឲ្យតក់ស្លុតរន្ធត់ម្ល៉ឺងឡើយ ឈ្មោះនេះតែតែកុហកថែមទៀត ។

គេបានរកលោកសៀរហល្ស៊ដេម៉ាការនិនៅ តាជនិយដ្ឋានម៉ដល់ឯដ៍ហើយគេបានសន្ទនាជាមួយនឹងលោក ។ ពាក្យត្រួយលោកសៀរហល្ស៊ដេម៉ាការនិបានចុះផ្សាយកាសែតថាដូច្នេះ

ការសន្ទនាជាមួយនឹងលោកសៀរហល្ស៊ដេម៉ាការនិ

"លោកសៀរហល្ស៊ដេ មន្ត្រីប្រឹក្សាស្ថានអគ្គកជក្ខុតចិន ពីម្សិលមិញ ទៅនឹងបាត្រនូវរសៀល, បានអញ្ជើញទៅកាន់ក្រសួងការបរទេសក្នុងការសន្ទនាជាមួយនឹងពួកតំណាងកាសែត លោកសៀរហល្ស៊ដេថា- ខ្ញុំមិនអាចដាំបាលោកអ្នកអំពីកិនការស្ងាកស្ងាមរបស់ពាមនុស្ស ដែល

ជាប់ឃុំឃាំងនោះ ត្រៀតតែមានការសែតទេ គេបានតបមកវិញថា ក្រសួង
នានាច្រើនបានបង្គាប់ទៅលោកឡត សាលីសប៊ូរ៉ (Lord Salisbury)
ឲ្យបង្គាប់ស្ថានអគ្គរាជទូតចិនឲ្យដោះលែងអ្នកដែលជាប់ឃុំឃាំងជាតិចិនជា
ច្រើនប៉ុន្មាន ។ សៀហេល៉ូដេមិនដឹងជានិយាយយ៉ាងណាក៏ធ្វើយទៅវិញ
ថា បុគ្គលនោះត្រូវដោះលែង តែកិច្ចការដែលធ្វើ ត្រូវស្ថានអគ្គរាជទូត
នេះមានសិទ្ធិសម្រេចបានតាមសេចក្តីយល់ឃើញ” ។

កន្លងមកសង្គមដែលសន្ធូនជាតំរង់ពីរដងនឹងអ្នកតំណាងការសែត លោក
សៀហេល៉ូដេមាំការនិយាយថា “ស៊ុន-យ៉ាត់-សេន មិនមែនឈ្មោះ
មនុស្សដែលជាប់ឃុំឃាំងទេ យើងបានយកការសង្កត់គ្រប់ ហើយយើង
បានឃើញឈ្មោះនេះច្រើនតែច្រើនដងដែរ តាំងពីគាត់បានមកដល់ច្រើនសប្តាហ៍
ក្តីតែរាត់បានមកដោយចិត្តឯងឯស្ថានអគ្គរាជទូតចិន តែមិនមានអ្នកណា
បង្ខំ ឲ្យគាត់មកទីនេះទេ តែជាការធម្មតាចំពោះជាតិចិនដែលនៅម្នាក់ឯង
ក្នុងក្រុងឡុងដ្រ ច្រើនមកសួរដំណឹងសង្កត់ទៅទីនេះ ឬជាដែលលើង
ទឹងពួកពលរដ្ឋដែលនៅស្រុកជាមួយយើង មានហេតុល្មមឲ្យសង្ស័យ
ឈ្មោះនេះបាន ដែលស្ថានថាគ្មានអ្នកណាស្គាល់ខ្លួនបង់មកយកការពី
ក្រុមពួកយើងនៅទីនេះ កាលដែលឈ្មោះនេះចូលមកដល់ស្ថានអគ្គរាជ-
ទូតគ្មានអ្នកណាស្គាល់ទេ ហើយឈ្មោះនេះបានសន្ធូនជាមួយនឹងមនុស្ស
ម្នាក់នៅទីនេះ គេក៏នាំមកបង្ហាញខ្ញុំ យើងបានឱយគ្នាទៅវិញទៅមក

ហើយមានពាក្យខ្លះដែលនាំឲ្យខ្ញុំមានសង្ស័យថា ប្រហែលជាមនុស្សដែលគេប្រាប់ ឲ្យយើងត្រួតត្រាមើល សេចក្តីសង្ស័យនោះទៅជាពិត ឈ្មោះនេះត្រូវគេចាប់ថ្ងៃក្រោយ ដល់គាត់ត្រឡប់មកពីនេះម្តងទៀត សព្វថ្ងៃគាត់នៅជាប់ឃុំដោយមានបង្គាប់ពីរដ្ឋាភិបាលចិន សំ-ដែងច្បាប់រវាងប្រទេស (droit international) លោកសៀរហាល្វីដេជាៈ "មនុស្សនោះមិនមែនជាតិអង់គ្លេសទេ គឺជាតិចិន ហើយមានតែរដ្ឋមន្ត្រីចិនមានសមត្ថភាពខាងផ្លូវតុលាការ បើជាតិចិនណាមានដល់រឿងនេះ បើមានគេចាប់ខ្លួន ឬមានសង្ស័យពីប្រព្រឹត្តបទអ្វី យើងហាមផ្តាច់មិនឲ្យពួកអ្នកបរទេសចូលមកតវ៉ាពីរឿងឃុំឃាំងនេះឡើយ បើឈ្មោះនេះនៅក្រៅមន្ទីរនេះ យើងនឹងចាប់ខ្លួនបានលុះត្រាតែមានអនុញ្ញាតពីក្រសួងប្រឹក្សាន្ត (Britannique) ពីព្រោះនៅក្នុងក្រមិក្សាន្តប្រឹក្សាន្ត (អង់គ្លេស) -"

លោកសៀរហាល្វីដេ, ដោយមានមនុស្សខ្លះសួរទៀត, ក៏ឆ្លើយតបមកវិញថា: បុគ្គលនេះមិនមែនយើងទុកដូចជាមនុស្សជាប់គុកទេ គឺយើងបានថែរក្សាដូចមនុស្សធម្មតា លោងសៀរហាល្វីដេមិនយកចិត្តទុកដាក់បង់ស្តាប់ពត៌មានក្នុងកាសែត "អំពីរឿងដែលពួកខាងស្ថានអគ្គរាជទូតចិនបានធ្វើការណែនាំចំពោះទៅលើមនុស្សដែលឃុំឃាំងនោះ លោកបានពោលតទៅទៀតថា មន្ទីរអគ្គរាជទូតចិនបានទទួលលិខិតមួយពីហ្វូរញ្ញាអ៊ុហ៊ូសអំពីរឿងនេះហើយ ។

(មានត)

ប្រវត្តិសាស្ត្រប្រទេសចិន

ហ្គួង មិញ្ញ ទ្ធ ន្តិ ញ៉ុក - ថែម ប្រែរៀបរៀង

អំពីប្រវត្តិសាស្ត្រសាកល

(តមក)

ហើយដ្ឋានកំពេចកន្លែងតួកគួកមួយភ្លួងទាន់ដែនអាល ដែលត្បាយាម តាំងវាតអំណាចឡើងកន្លែងតំបន់នោះ ប៉ុន្តែមានពួកតួកមួយពួកទៀត មានប្រមុខឈ្មោះមេបូអ៊ូដូចគោលរួចហើយត្រឡប់ជាសត្រូវជំទាស់ក្បាសា - ហាវនីធ ប្រទេសចិន ក្នុងឆ្នាំពុទ្ធសកាជ ១២៣៩ នឹងក្នុងឆ្នាំពុទ្ធសកាជ ១២៤៩ មេបូអ៊ូលើកទ័ពលុកលុយបួលមកតាំងនៅកន្លែងខេត្តចាន - ស៊ូនីង ប៉ែងលី ហើយបានលើកទៅវាយទ័ពចិនបែកម្ខាងកន្លែងខេត្តកួន - ហួង ទើបលុកទន្ទ្រានបួលមកដល់ខេត្តកាន - ស៊ូ ។

នេះហើយគឺសាពហេតុកេតដែលមានទៅកន្លែងណា: ដែលព្រះជាម្ចាស់ - ភ្នំងឡើងត្រង់ពេលសម្បត្តិ ប្រសាសនាជាយដំបូងរបស់ព្រះអង្គ ក៏តឿបម្បាំងនឹងមេបូអ៊ូឲ្យដាច់ស្រេច ។ ក្នុងឆ្នាំពុទ្ធសកាជ ១២៥៩ ពួកកងទ័ពចិនមានជ័យជំនះហើយបានកាត់យកក្បាលរបស់មេបូអ៊ូ ទៅថ្វាយដល់ព្រះជាម្ចាស់ - ភ្នំងផង ។ មេតែលៀមជាពុត្រប្រុសរបស់មេបូអ៊ូ ក៏ព្រមទៅក្រោមចំណុះក្រុងចិនដោយស្មោះត្រង់តមក ។ ក្នុងឆ្នាំពុទ្ធសកាជ ១២៥៩ ពួកតួកខាងអតេនក៏ត្រូវជ្រាបជ្រាមឲ្យទៅក្រោមអំណាចចិន

យ៉ាងពិតប្រាកដ ការដែលចិនបានប្រាប់ប្រាមសម្តែចវៀបានន័យថាឲ្យមានភ័យដល់ប្រទេសខ្មែរ ហើយក្នុងវេលានេះ ពួកអាវុធនឹងពួកសាសនាឥស្លាមបានវាយចូលប្រទេសឥណ្ឌា បានបួលមកតាំងនៅខាងត្រង់ក្រសៀន ទើបពួកនីថេតបែរវៀរមកកំឡាំងគ្នានឹងអាវុធសម្រាប់ច្បាំងតស៊ូនឹងក្រុងចិន ពុតជាខំធ្វើដូច្នេះ ក៏នៅតែបរាជ័យក្រុងចិន ទើបអំណាចចិននៅខ្ពស់ស្ដុងដដែលទាំងកើតក៏ត្រឡប់មានឡើងវិញម្តងទៀត ។

កាលបើបានប្រាប់ប្រាមខ្លីស្ដុងនៅទីសាងកើតបានហើយ ប្រសាសនោបាយចេស់ព្រះបាទ មិន-ភ្លុង ក៏មានទំនងដូចជាក្បត្តិចិនមុន ។ នេះដែរ គឺជាកមកផ្សាយអំណាចកងដែនដីតណ្ឌាលទ្វីបអាស៊ី ជិតបួលមកប្រទេសឥណ្ឌា ក្នុងវេលានេះពួកឥស្លាមកំពុងលុកលុយខ្លួនយកដែនដីឥណ្ឌា ហើយពួកក្បត្តិឥណ្ឌាមិនមាននរណាពឹងប៉ុនខ្លាំងពូកែលើមទឹងតស៊ូបាន ហេតុនេះ អាណាចក្រតូចៗនៅតំបន់នោះមានសង្ឃឹមតែពឹងបុណ្យប្រសិទ្ធជាវង្សចាំងប៉ុណ្ណោះ ។ មួយវិញទៀត ដែនដីជាច្រើនអន្លើក្នុងអាស៊ីតណ្ឌាលធ្លាប់នៅក្នុងអំណាចចិន សូម្បីក្នុងពេលដែលពួកឥស្លាមលុកលុយចូលមកនេះ ចិនក៏នៅមានអំណាចត្រួតត្រាស្ទុះទេសអស់នោះជាច្រើនអន្លើ ដោយហេតុនេះហើយបានជាចិនមិនព្រមឲ្យជាតិឥស្លាមចូលមកមានអំណាចក្នុងដែនដីចំណែកនេះ ទើបចាប់ធ្វើសង្គ្រាម

ទឹងជាតិឥស្សរមយ៉ាងខ្លាំង តែពួកឥស្សរមមានកំឡាំងរឹងប៉ឹងដោយអំណាចមានចិត្តជឿជាក់ក្នុងព្រះមាហាម៉ុច ហានបង្ខាំងតស៊ូបង្ហាញកងទ័ពចិនក្នុងតំបន់អស់នោះចាក់បែកអស់ទៅ ក្នុងរវាងពុទ្ធសករាជ ១៦៩៤ អំណាចចិនក៏ជុតរបូតអស់ទៅនៅក្នុងអាស៊ុកណ្ណាល ។

ការដែលចិនអស់អំណាចក្នុងអាស៊ុកណ្ណាលនេះ ជាប្រាក់ដំបូងដែលនាំឲ្យព្រះពាជវង្សថាំង ដល់ខ្សែសេចក្តីវិនាសសាបសូន្យក្នុងកាលជាលំដាប់តទៅ ។

វគ្គទី ៦

អវសានវៃព្រះរាជវង្សថាំង

តាមធម្មតា គ្រប់ប្រទេស គ្រប់យ៉ាង គ្រប់ក្រការ តែមានសេចក្តីចំរើនដល់ខ្ពស់ចំផុតហើយ តែងតែមានសេចក្តីទ្រុឌទ្រោមសាបសូន្យទៅវិញ ពាជវង្សថាំងក៏មានចំនងដូចគ្នាដែរ ប៉ុន្តែពាជវង្សនេះបានធ្វើសេចក្តីចំរើនរុងរឿងដល់ប្រទេសចិនយ៉ាងធំវៃក្រៃលែង ទឹងបានឲ្យអំណាចនឹងការប្រៈធម៌ដល់ប្រទេសជាតិចិនយ៉ាងខ្ពង់ខ្ពស់ ទើបគួរតែថ្លែងរឿងកំរើតពីហេតុនៃសេចក្តីសាបសូន្យរបស់ពាជវង្សនេះដោយតិស្តារតាមសមគួរ ។

ក្នុងឆ្នាំពុទ្ធសករាជ ១៦៩៤ ជាឆ្នាំដែលអំណាចចិននៅអាស៊ុកណ្ណាលជុតរបូតអស់ទៅ ក្រែងចិនកំតើតឧស្សាហ៍លើកពលមកវាយតប់ឡើង ។ ក្នុង

ដែនចម្ការកៅអាងត្បូងនោះ ពួកគឺ-ឆៃ ជាតិភូកៅអាងស្រុកលៀវ-តុង ចាប់ផ្តើមលុកចូលមកខាងឈូងសមុទ្រចេ៉ដំលី ហើយបានកាន់កាប់ទេសកងទ័ពចិនមួយកន្លះ ។ ចំណែកយ៉ុន-ណាន ពួកណាន-ចៅ គឺជាតិថៃ តាំងនៅកងដែនតាលី ក៏បានបណ្តេញកងទ័ពចិនមួយកងដែលតាំងនៅក្នុងតំបន់នោះ ទៅបាត់ចេញពីទេសដែនបៃស់ខ្លួនទៅ ក្រៅពីបានចាត់បញ្ជូនកងទ័ពធំៗទៅធ្វើបតិបតិ្តការ តែកងទ័ពណាន-ចៅ បានរក្សាទ័ពចិនបែងខ្លះខ្លីនៅមាត់ទន្លេសាចតាលី ក្នុងឆ្នាំពុទ្ធសករាជ ១៤៨៦ នោះឯង ដែនដីខាងយ៉ុន-ណាន ក៏ផុតបាត់អំពីអំណាចចិនទៅ ។

បើទុកជាកាជវៀរថាងបានក្តៅឲ្យចិនមានយសសក្តិខ្ពង់ខ្ពស់ឡើងយ៉ាងណាក៏ដោយ ប៉ុន្តែ ក្រៅជាជនចិនទៅតែមានចិត្តរាងគុញគ្រាន់ធំធាតុកេនបៃស់ក្រុងចិន រហូតរហែលជារយៈ ១៩០ ឆ្នាំនោះ ព្រោះក្នុងកំឡុះៗជាតិចិន ត្រូវចាត់បញ្ជូនទៅទ័ពខ្លួចមង់ជីវិតក្នុងតំនខ្សាច់ទៅក្នុងសមុទ្រខ្សាច់ ក្ងូ-ចេ, ក្នុងតំនទៀកកកទៅដែនអ័ស-ឆៃ ទៅលើទីលូលួសដ៏ត្រជាក់ស្រែតនៃដែនដីទីបេត, ទៅក្នុងព្រៃភ្នំក្រំឆ្ងាយដ៏លំបាកវេទនានៃដែនយ៉ុន-ណាន ដោយហេតុមានចម្បាំងសង្គ្រាមមិនមានស្រាកស្រាន់ឲ្យបន្ទុយចំនួនកស្ទួតអស់ទៅជាច្រើនកាល់ៗ ឆ្នាំ ។ តាំងឲ្យមានសេចក្តីរួញរាជដល់ពួកដែលនៅក្នុងស្រុក ដោយបាត់បង់ជីវិតកូនចៅបៃស់ខ្លួនទៅកាល់ៗ ឆ្នាំ ។ ចំណែកវីស័ទាន់បៃស់ចិន គឺ លី-ឆៃ ប៉ ទិន-ប៊ូ-ក្វូ បានតែងសៀវ-

ទៅពណ៌នាអំពីសេចក្តីលំបាកវេទនាបស់ពួកជាហាន ខ្ញុំនិងអំពីផលអាក្រក់នៃចម្បាំង តាមដោយពិតនោះ ខ្ញុំនឹងជាកំហុសរបស់ក្សត្រ ឬរបស់អ្នកណាមិនបានចាំងអស់ ព្រោះបើមានសឹកសត្រូវលុកលុយចូលមកក្នុងស្រុកទេសហើយ មនុស្សក្នុងស្រុកត្រូវតែចាប់អាវុធច្បាំងតស៊ូប៉ុន្តែ ក្នុងសម័យកាលវង្វាន់នេះ ចិនមានសឹកសត្រូវរំលើនទៀងៗ ហើយកាលណាឆ្នាំគោងមានចម្បាំងមិនស្រាក ។ ក្នុងគ្រាព្រះបាទថៃ-សុងមហាកាជ ចិនឈ្នះចម្បាំងស្ទើរតែមិនបានចាប់ចេញទៅច្បាំង ឬច្បាំងមិនបានប្រែកំឡាំងពាហាន ទើបធ្វើឲ្យជីវិតជាតិចិនមិនខូចបង់ទៅច្រើនទៀយ ប៉ុន្តែមនុស្សថៃ-សុងនោះគេបានដោយងាយស្រួលណាស់ ក្នុងរយៈពេលមួយឆ្នាំទើបគេមនុស្សថៃបានម្ភាក់ ។ តាលៅថៃជាជនចិនគោងបង់ខាតសាច់ឈាមជាច្រើនដូច្នេះ ពួកជាហានក៏ចះបោរទៅជាក្បត់ទៀង ជាហេតុនាំឲ្យកាជវង្វាន់វិនាសសាចសូន្យទៅទៅទីបំផុត ។

មានមេទ័ពចិនម្នាក់ឈ្មោះ ង៉ាំង-លោងាន ឃានឲ្យលួងដំណែងពីព្រះបាទមិង-កុំង ជាអ្នកបញ្ជាការទ័ពក្នុងទេត្តបេជិលីបានតាំងខ្លួនជាមេក្បត់ទៀងនឹងព្រះពជាធិពជឃានលើកទ័ពចូលមកឲ្យនឹងឃានស្រុតលោយ៉ុង ក្នុងពុទ្ធសករាជ ១៦៤៨ ហើយតមមួយឆ្នាំទៀតយឃានស្រុកស៊ី-ង៉ាំង ដែលជាទីក្រុងធំធ្វើឲ្យកាជសំណាក់បស់ព្រះបាទមិង-កុំងគោង

ផ្ទាស់ទៅតាំងនៅឯស្រុកសេ-ដួន ។ តែមប៉ុណ្ណោះមិនទាន់អស់គ្រោះនៅឡើយ ពួកក្បត់ធ្វើតបង្គាប់ឲ្យព្រះឃុនមិង-កុំងប្រហារជីវិតព្រះនាងយ៉ុង-ហៃ ដែលជាអគ្គមហេសីសំណប់ស្នេងិងជីវិតរបស់ព្រះអង្គ ដោយពួកក្បត់ចោទថា ព្រះនាងជាដើមហេតុនាំឲ្យកើតចលាចលរវើរវាយក្នុងរាជធានីច្រើនខែ ធ្វើឲ្យជនស្លាប់ណាក់យ៉ាងសន្ធឹកសន្ធម្ភហ៊ឺហាចាយវាយព្រះពន្ធឲ្យខ្ទេចខ្ទាយហួសពេក តែតែសព្រោយមួយមុខមិនទឹកដល់សុទ្ធតុន្តរបស់បណ្តាពួកស្តេច ។ ចំណែកខាងព្រះឃុនមិង-កុំងជាអ្នករងគ្រោះមិនអាចចាត់ការដូចម្តេចបាន គោងជាណ្តោយឲ្យពេជ្ឈឃាតនាំព្រះអគ្គមហេសីទៅប្រហារជីវិតតាមចង្កាប់របស់ពួកក្បត់ ។ ព្រះនាងយ៉ុង-ហៃដំបូងអ្នកជាផ្ទៃប្រតិសាស្ត្រនាំទៅប្រៀបធៀបទន្ទឹងមាំជាមប៉ុមប៉ាន់ដូរបស់ចាក់ទីសេស តែមកដល់ឆាន់បុងជីវិតគោងប្រៀបធៀបទន្ទឹងព្រះនាងមាំរីអង់តួនេតបានសចាក់ទីសេសដោយឡែកថែមទៀតផង ។

មនដល់ចំណែតនេះ យើងបែរទៅទំនៀលើកដល់សេចក្តីដែលពោលមកហើយក្នុងវគ្គទី ៧ នោះកំទន្ទឹងចូលចិត្តឲ្យសួរថា អ្វីជាហេតុឲ្យពួកជនរងថ្ងាំងរសាំរសាយរៀវភៃ? អ្វីជាហេតុឲ្យប្រជាពលស្តេចនៃដែលស្រឡាញ់ពេញចិត្តទន្ទឹងពួកជនរងនេះបែរចិត្តគ្រឡប់ជាក្បត់ហើយបះបោរចលាចលឡើង? ការពិត ការដែលនាំមានគោងទៅច្បាំងទន្ទឹងខ្លាំងសត្រូវកាល់ៗឆ្នាំ ២ដងជីវិតក្នុងមួយឆ្នាំៗ ជាចំនួនច្រើនគោះ មិនមែនជាកំហុសរបស់ព្រះមហា-

ក្សត្រឡើយ ព្រោះមិនមែនតែតឹមពាក្យថាំង ឬពាក្យណាទេ ប៉ើ
មានសឹកសត្រូវចូលមកលុកលុយដល់ស្រុកទេសហើយត្រូវតែលើកទ័ព
ចេញទៅតតាំង ហើយប្រជាជនត្រូវតែលះបង់ជីវិតសាច់ឈាមជួយ
ស្រុកកំណើតរបស់ខ្លួន ។ ដោយគោរពប្រជាពលស្តាប់ចំនក់យល់រឿងនេះ
ច្បាស់ដែរ ប៉ុន្តែបើមានតែតឹមសង្គ្រាមមួយមុខមិនជាការអ្វីទេ មិនគាំទ្រ
ស្រុកចំនកើតបណាចលវិលកន្ទើរឡើយ ប៉ុន្តែកំហុសនេះភ្ជាក់ទៅលើព្រះ
មហាក្សត្រចំនក្នុងសម័យនោះ គឺថាព្រះបាទមិន-កុំនត្រង់កសាងបាសាទ
ពាក់កណ្តាលយ៉ាងសំបើមរុងរឿងថ្កុំថ្កា បាយវាយឆ្នះឆ្ងាយ ត្រង់តែកាយសម្បាយ
ដូចព្រួយអ្វីក្នុងខណៈដែលស្រុកទេសកំពុងមានសង្គ្រាម ។ ឯភាពនៃ
សង្គ្រាមតាសពេញដោយសេចក្តីលំបាកគោកយ៉ាកវេទនាបង់ពួក
ភាហាន ទឹងភាពនៃសេចក្តីថ្កុំថ្កើងរុងរឿងរបស់ពាក្យសំណាក់ ភាពពាំងព័ត
នេះបើមកមានប្រាកដឡើងក្នុងខណៈជាមួយគ្នា ប្រជាជនតែងតែកើត
សេចក្តីក្តៅក្រហាយទំនុកទោមនស្សឡើងជាធម្មតា ព្រោះខាងណោះ
ពួកភាហានគោងយកជីវិតទៅប្តូរជួយស្រុកទេសរបស់ខ្លួន ចំណែកខាង
ណោះ តឹងពាក្យសំណាក់តិតតែសម្បាយកែកយកក្សេមក្សាន្ត ។ ប្រសិន
បើព្រះបាទ មិន-កុំន ទ្រង់ប្រតិបត្តិពាក្យកុង ក្នុងខណៈនោះឲ្យតឹមត្រូវ
ទឹងកាលសម័យបច្ចុប្បន្នសម្បាយកែកយកក្នុងពាក្យសំណាក់ ជាបណ្តោះ

ឆាសន្ទសិន ចាំឲ្យហើយសឹងសង្ឃឹមសិនសឹមសប្បាយតាមសព្វព្រះទ័យ
ប៉ុះ ធ្វើដូច្នេះពួកខាហានតង់តែមិនចេះចោរៅជាក្បត់ឡើងទេ ។

ចំណែកឯព្រះចាខមិង-កុំង តាំងពីខួបចង់ជាតែព្រះអគ្គមហេសីៅ
ព្រះអង្គមានតែសេចក្តីក្រៀមក្រំជំហៀព្រះទ្រូងជាខ្លាំងលើសលន់ តមកមិន
ឃ្លាប៉ុន្មានក៏ស្តេចលាចាកពិភពសម្បត្តិទ្រង់ប្រគល់មកុងជាឲ្យៅស៊ូ-សុង
ជាព្រះរាជនុសេ ចំណែកព្រះអង្គស្តេចៅរកទីវិវេក ទ្រង់សង្កេត
ទ្រង់ព្យាយាមធ្វើឲ្យភ្លេចភ្លាំងសេចក្តីខ្លាំងសោករៀមក្រំពាំងអម្បាល
ណោះចេញ ។

ខូ-ហ្គូ ជាចិន្តកវីឯករបស់ចិន មានចិត្តស្មោះត្រង់ស្មោះម៉ាកក្តីនឹងព្រះ
ចាខមិង-កុំង ចានតាមស្តេចៅផង ។ នៅវេលាដែលព្រះចាខមិង-កុំង
តង់កង់ទីវិវេកនោះ ខូ-ហ្គូចានតែងតាណិនាសេចក្តីមួយអន្ទើយថា :

"អនិច្ចា ! ទ្វារចាំងមួយពាន់នៃព្រះពន្លាំងចានចែងដែតណែនហើយ
ត្រង់ស៊ី-ង៉ានក៏ពាសពេញៅដោយល្អង់ធូលី ដែលហុយឡើងដោយ
ដើងសេះរថសំពួកតាតារ ពួកមន្ត្រីៅកង់ស្រះនឹងជុះនើចឡើងមកឲ្យអ្នក
ណាមើល ពួកស្រីព្រះស្នំធ្លាប់ៅជាមកេមព្រះពាធាពិពាធ ចុះឥឡូវនេះ
ចាត់មុខៅណាទស់ៅ ព្រះនាងយ៉ុង-ហ្គូមិនទ្រង់ញញឹមព្រះឧស្ឋឲ្យ
ចានឃើញព្រះទន្តដ៏សស្អាតដូចកាលមុនទៀតហើយ" ។

(មានត)

វគ្គទី ១

អ្នកឧកញ៉ាវិបុលរាជសេនា (ស្អូរ កង) ប្លែ

(គម្ពីរ)

ឯបច្ចួនោះ ធ្លើកជាតាមុីងម៉ាត់តែងមានអំណាចឡើងកាលថ្ងៃ មនុស្ស
ទាំងពួងសឹងកោតក្រែងរាងខ្លាចជាច្រើនណាស់ ព្រះចៅឡែនតែងដឹ
ជាបស្គាល់ក៏តាំងឲ្យឡើងយសជា "ឧុនវិរៈឡែង" ។ លុះពួកចោរ
ជួតក្បាលលឿងកំរើបចលាចលពេញក្នុងស្រុកអេងជួន ព្រះចៅឡែនតែ
ទ្រង់តាំងឲ្យបច្ចួឡើងវិជាតុរង្គ ឲ្យឃុំតាមាន ៨០០០ លើកទៅ
ជួយស្រុកអេងជួន លុះទៅដល់ហើយក៏ប្រទះនឹងតៀវហ្គោ តៀវលឿង
ទ័ពពួកចោរដែលសល់ពីស្វាប់ការលែកបន្ទាយតំរៅនោះ បច្ចួក៏លើក
ពលស្ទាក់តាត់មុខពុក ហើយខ្ចប់សម្លាប់ពួកចោរអស់ប្រហែលមួយម៉ឺន
ប្លាយ តាហានបច្ចួចាប់បានសេះទឹងត្រឹងសស្រួលជាច្រើនណាស់
តែខ្លួនតៀវហ្គោ តៀវលឿងគេចតំរូចទៅ ។

ឯបច្ចួបួលទៅកុហាងហ៊ូសុនទឹងជូហ៊ូ ហើយដំណាលតាំកិច្ចពួកជតា
តាំងពួង ទើបបច្ចួសុំយកតាហានទៅតាមតៀវហ្គោ តៀវលឿងទៀត ឥង
ខ្លាតាំងខ្លួនអ៊ូតៀវហ៊ុយ លើកពលមកដល់ស្រុកអេងជួនបានពួសំឡែងគេ

តគាំងបង្ក់ងគ្នា ឃើញមានពន្លឺភ្លើងភ្លឺស្វាងណាស់ ក៏លេះរលាំងដេញ
ភាហានឲ្យស្រួតបួលទៅជួយ លុះមកបួលទៅដល់ពួកចោរក៏បែកបាក់ខ្ចាត់
ខ្ចាយទៅ ខ្លាំពីក៏នាំគ្នាមកអូតៀរហ៊ុយ បួលទៅរកហង៊ីសុង៉ទ័ងដូហ៊ុ
ជួបគ្នាហើយក៏និយាយថា លោតិតឲ្យខ្ញុំបានមកជួយធ្វើការហាក ។
ហង៊ីសុង៉ទ័ងដូហ៊ុនឆ្លើយថា ខ្ញុំអរគុណណាស់ប្អូនិយាយថា ឥឡូវនេះ
តៀវភ្លោតៀវលៀងទ័ងពួកចោរបែកអស់ហើយ ខ្ញុំឃើញថា តៀវភ្លោ
តៀវលៀងទ័ងរត់ទៅរកតៀវតុកជាបង៉ទៅស្រុកបុង៉តុង៉ បើដូច្នេះបួរអ្នក
លើកទាហានស្រួតរួតតាមស្កាត់ស្កាត់ចាប់ឲ្យបានខ្លួនចុះ ។ ខ្លាំពីតួនអ៊ូ
តៀវហ៊ុយ ក៏លាគ្រង្គប់លើកទាហានតាមទៅ លុះដល់ពាក់កណ្តាលផ្លូវ
ឧទ្ទលជួបច្រៃទ័ងព្រះកជបម្រើ ឃុំមនុស្សពោសក្តន៉ទ្រង់ដាក់លើរទេះ
បរមកគ្រាលែកតាមមើលទៅស្គាល់ ឃើញពួកស់ដាលោតិតទៅក្តន៉ទ្រង់
នោះ ខ្លាំពីស្តុតចិត្តហោតចុះពីលើខ្នង់សេះស្ទុះបួលទៅសួរលោតិតថា
ហេតុម្តេចអ្នកទើបមកគ្រាពោសថ្ងូរចេះ លោតិតឆ្លើយថាខ្ញុំបានត័ទ្ធទ្រោម
តៀវតុកឧុតឲ្យទៅក្តន៉ជម្នាយ ទៀបទ័ងជាប់ខ្លួនបានហើយ តៀវតុក
ដ៏ខ្លួនបេះតែប្រុនប្រយ័ត្ន ខ្ញុំទ័ងគ្នាជាប់ឲ្យនាប់ជាប់ពុំបាន ព្រះបៅ
ខ្លួនតែច្រើនបានជ្រាប ទើបគ្រាស់ប្រើដូហ៊ុតគ្រួមកាំងចេញមកស៊ើប
ការពួកការ ដូហ៊ុងក្រាបថ្វាយទ័ងបង៉បានសំណូកច្រៃរតេសតិខ្ញុំ បានប្តឹង
ដំណថា កន៉កន៉ទ័ងនេះ កំពុង៉ជាប់ស្បៀងភាហារណាស់ ខ្ញុំគ្មានរបស់អ្វី

តួរសមជួនជាជំនួនទេ ដូហុងទឹងនឹងខ្ញុំត្រឡប់ទៅភ្នែងពិតទួលព្រះទៅ
ខ្សែនគេថា ខ្ញុំមិនយកចិត្តទុកដាក់ធ្វើការសឹកសង្ឃឹម ហេតុនោះបាន
ជាយឺតយូរពុំសម្រេចការ ព្រះទៅខ្សែនតែទ្រង់ជ្រាបការនោះ ទើបត្រាស់
ប្រើតាំងតុះឲ្យចេញមកជាមេទ័ពជំនួសខ្ញុំ ហើយត្រាស់ឲ្យចាប់ខ្ញុំធ្វើទោស
ជាក់ខ្នងនាំទៅស្រុកក្រែង ។ តៀវហ៊ុយបានឮដូច្នោះក៏ទឹកចិត្តណាស់
កន្ត្រាក់យកជាវលើកខ្សែងទឹង សម្ងាប់កូឃុំដណ្តើមដោះយកលោទិតចេញ
ពីខ្លួន ខ្សែពាយើញអាការដូច្នោះក៏សុះទៅពាងពាថា កុំអាមេធ្វើលើព្រះ
ពុទ្ធអាជ្ញាសិទ្ធិទឹងធ្វើតាមអំពើបិត្តពុំបានទេ ។ គួនអ៊ូឆ្លើយថាអំបាលលោទិត
ហើយគង់មានសេចក្តីខុសដូច្នេះ ក្រៅពីនេះនរណាទឹងអាចធ្វើជាមេទ័ព
តទៅទៀតបាន យើញាជាទឹងនាំគ្នាកេរពីពីងពាក់អស្រ័យគ្នានឡើយ
សូម្បី ធ្វើការមានគុណតាប់ជាប់ណាប់យាំងណា ក៏គង់ត្រឡប់ខុសទៅបាន
ដូចលោទិតជាគួយាំង ដើដូច្នេះយើងត្រូវត្រឡប់ទៅស្រុកទុនគួនវិញជា
ជាង ។ ខ្សែពាស្តាប់យើញ្រ្តូវ ក៏លើតទាហានត្រឡប់ទៅស្រុកទុនគួន
លុះលើកទៅបានពីរបីថ្ងៃ ដល់ពាកតណ្តាលផ្លូវ ឮសំឡេងវៃសតហោ
កញ្ជ្រៀវាងរកាយក្តុំ ខ្សែពាតីក៏នាំគួនអ៊ូ តៀវហ៊ុយបរសេះឡើងទៅមើល
ពីលើកំពូលក្តុំកែឡេកទៅយើញទ័ពហ្លួងវៃបក យើញទ័ពចោរជួតក្បាល
លឿងលើកដេញសង្កុញមក ខ្សែពាយើញទង់ជ័យ ស្គាល់ថាទ័ពតៀវកុក
លើកដេញទ័ពតាំងតុះ ទើបខ្សែពា គួនអ៊ូ តៀវបាយ ត្រឡប់ញាក់សេះ

ចុះទៅជួយខាងខ័ពហ្លួង ខ័ពតៀវកុកក៏គ្រឡប់ចាក់វែកខ្លាក់ខ្លាយតែតាម
ផ្លូវទៅប្រមាណ ៥០០ ។ ឯតាំងតុះក៏លើកពលចូលបន្ទាយ ហើយឲ្យ
រកឡា)ពី គួនអ៊ូ តៀវហ៊ុយ ទៅសួរថា អ្នកឯងជាមន្ត្រីដំណែងអ្វី ? ឡា)ពី
ឆ្លើយថា ខ្ញុំចុះមិនបានជាមន្ត្រីមានដំណែងអ្វីទេ តាំងតុះបានស្តាប់ដូច្នោះ
ក៏ឆ្លើតរំយោលថែបមើលងាយមិនមានសេចក្តីគួរសមកប់អាន ឡា)ពី គួនអ៊ូ
តៀវហ៊ុយក៏លាគ្រឡប់ទៅវិញ តៀវហ៊ុយក៏និយាយថា យើងបងប្អូន ៣
នាក់ជួយយកអាយុដ៏វែងឲ្យរួចពីសេចក្តីស្លាប់គ្រានេះ ក៏មិនស្គាល់គុណ
យើងសោះគ្រឡប់ធ្វើបុកពាមើលងាយយើងវិញ គួរតែសម្លាប់ចោញទើប
អស់សេចក្តីក្តៅចិត្ត ថាហើយក៏គន្ធាក់ដាវសុះរលៅទៅទីសម្លាប់តាំងតុះ
ឡា)ពី គួនអ៊ូរាក់ឃាត់ថា កុំធ្វើគេដាច្រកជំរើ ។ តៀវហ៊ុយតប
ថា បើមិនសម្លាប់ចោញ គ្រាតែអ៊ូយើងនឹងចង់ទៅធ្វើការជាមួយនឹង
ពួកទីមានសេចក្តីមើលងាយប្រមាទយើងច្រើនទៅទៀត ព្រោះវាមាន
អាជ្ញាសិទ្ធិ បងទាំងពីរទើបចង់ទៅក៏ទៅចុះ ខ្ញុំសូមលាទៅតែឯងឯងវិញ
ហើយ ។ ឡា)ពីគួនអ៊ូឆ្លើយថា យើងជាបងអ្នកទាំង ៣ នាក់ ពោះ
យ៉ាងម្តេចក៏គ្រូវតែស្លាប់រស់ជាមួយគ្នា ដែលទើបតែព្រាត់ព្រាកាត្តានោះ
មិនគួរទេ ទើបទៅណាគ្រូវទៅជាមួយគ្នា តៀវហ៊ុយ តបថា បើដូច្នោះ
គ្រូវចាំឲ្យរសាយសេចក្តីខឹង ថាហើយឡា)ពី គួនអ៊ូ តៀវហ៊ុយ ក៏លើក
ពលតាហានគ្រឡប់ទៅកេដូហ៊ូ ឯស្រុកមេដួនឲ្យតាហានស្រុកដើរទាំង

ចេញទាំងវិថី ដល់ហើយក៏នាំគ្នាចូលទៅកដូហ្គី ហើយពណិនាតីឈរ
ពន្លាទៅទាំងតួនីឲ្យដូហ្គីស្តាប់សព្ទសេចក្តី ។ ដូហ្គីក៏ពេញចិត្តអាណិត
ស្រឡាញ់ពាក់អានឡៅពី តួន អ៊ូ តៀវហ៊ុយ ពន់ពេកណាស់ សន្ធត
ទុកជាពួកកងជាមួយគ្នា ដូហ្គី និយាយថា តាំងតុះនោះ ស្រុកកំណើត
នៅក្នុងក្រុងឡាយលិមយោ ជានាហ្នឹងឈ្មោះហាងតុងថាយស៊ីវ ឯតាំង-
តុះនោះមិនជាអ្នកស្គាល់ការជួញស្រាល មិនស្គាល់មនុស្សល្អឫអាក្រក់
ទេឬយ បើជាអ្នកទៅនៅជាមួយផង កំនឹងកផលប្រយោជន៍មិនមាន
ទេឬយ ។

ឯទំព័រចូរ ដែលទៅតាមតៀវថុំ តៀវលៀងនោះលុះមិនជួបច្រកទេ
ហើយ ក៏លើតត្រឡប់មកកេហាងហ៊ីសុងទៅស្រុកអេងជួន ចូលរួប
រួមធ្វើការជាមួយនឹងហាងហ៊ីសុង។ នឹងចូរ លុះដឹងដំណឹងថា តៀវ-
លៀងទៅស្រុកធូហាងដូច្នោះ ក៏លើកតាហានទៅចាំជំនឹងតៀវលៀង
ឯតៀវប៉ូទៅតាំងបន្ទាយនៅដំបន់ក្រាយភ្នំ ។ មានពួកចោរជោចរឹកប្រ-
មាណ ៨ ម៉ឺន ៩ ម៉ឺន ។

ដូហ្គីលុះដឹងដំណឹងថា តៀវថុំទៅ ។ ទើនោះ ក៏ចាត់ឲ្យឡៅពី
តួនអ៊ូ តៀវហ៊ុយជាទ័ពមុខ តួដូហ្គីជាទ័ពហួន លើនរលេតាហានទៅ
តតាំងចាំជំនឹងតៀវប៉ូ ខាងតៀវប៉ូ ចាត់ប្រើកូរសេង ឃុំទាំពួកចោរចេញ
មកតយុទ្ធនឹងកងទ័ពមុខ នោះឡៅពីប្រើតៀវហ៊ុយឲ្យចេញទៅតទល់នឹង

ក្តួសេង ប្រយុទ្ធគ្នាមិនបានបាន ៣ ភ្លេង គៀវហ៊ុយចាក់ទំងាលំពែងត្រូវ
ក្តួសេងធ្លាក់ពីលើសេះស្លាប់ ពួកចោរចាំងឡាយក៏បែកខ្ចាត់ខ្ចាយអស់
ទៅ ។ ខ្លាពីរជញ្ជាហាន ឲ្យចូលជយកាប់ចាក់ពួកចោរជាច្រើនណាស់
គៀវប៊ូតាល់តំនិតគិតកែច្រកវង់ទៅណាមិនរួច ក៏សេកមន្តគាថា ហើយ
ឲ្យមេយងដឹងចំពោះមល្លាលព្រះសុរិយា បណ្តាលជាអស្ចារ្យផ្កូរផ្កាយ
ធ្លាក់ខ្លួរខ្លារ ធ្លាក់ភ្លៀងខ្យល់ព្យុះបោកបក់គ្រប់ទិសានុទិស មានតាំង
មនុស្សដុះសេះគាន់គ្រឿងអាវុធអណ្តែតចុះមកពីលើអាកាសដោះដាស
ប្រឈឺ ពលហានទាំងខ្លាពីរយើញដូច្នោះក៏ស្ទុះវាត់ជ្រលែកចល់តែវ
ណាស់ ខ្លាពីរក៏ឲ្យថយទ័ពត្រឡប់មកហើយប្រឹក្សាទំងជូហ៊ុ ក៏និយាយ
ថា អាគេទេអស្ចារ្យដូច្នេះ គឺនេធ្លើដោយវិជ្ជាការមន្តអាគមទេ យើងត្រូវ
ឲ្យពាហានខាំយកវចស់ស្មោកគ្រោក ទៅដើរទៅលាក់ចង្កឹបចុកលើកំពូលភ្នំ
បើគេធ្លើដូច្នេះទៀតឲ្យពាហានជាច្រើនបានចាប់វចស់ស្មោកគ្រោកនោះចុះមក
មន្តអាគមនោះក៏ទំងាសាបរលាបទៅឯង ។ ខ្លាពីរក៏ប្រែគួនអ៊ូ គៀវហ៊ុយ
ឲ្យឃុំនាំពលយោធាម្ភាក់ ៣ ពាន់ ឆកវចស់ស្មោកគ្រោកទៅដើរទៅចុក
លើកំពូលភ្នំតាំងសងខាង ត្រងំចំពាំដែលបង្កឹបពាហានតយុទ្ធគ្នានោះ លុះ
ព្រឹកទៅគៀវប៊ូលើកពួកចោរចេញមក ខ្លាពីរក៏លើកពលពាហាន
ចេញទៅតទល់ច្បាំងគ្នា នោះគៀវប៊ូតាំងតែសេកមន្តគាថាធ្លើឲ្យមេយ
ងដឹត កើតផ្កូរផ្កាយភ្លុះខ្យល់ខ្លាំងមនុស្សដុះសេះគាន់អាវុធដូចកាលជាន់មុន

ខ្ញុំពីយើញដូច្នោះក៏ធ្វើជាកថយទៅតមកខាងក្រោយ តៀវប៉ូក៏ដេញជិត
ប្រកិតតាមមកដល់ទីប្រហាប់ប្រកក្តាំងសងខាង ។ គួនអ៊ូ តៀវហ៊ុយក៏
ឲ្យគាហានចាប់សាចអស្ចារ្យលាមកកក់ធ្លាំនឹងឈាមជ្រួកឈាមឆ្អែតលើ
កំពូលភ្នំទៅត្រពួកហោរ រីឯមនុស្សដើរសេះគាន់តែអាចរួចពីគាកាស ក៏
ក្លាយទៅជាក្រអាសនឹងដុំស្មៅតាំងអស់ មេឃដែលងងឹតនឹងភ្លៀងឲ្យល់
ផ្គរខ្លុះក៏ស្រឡះភ្លឺស្វាងដូចធម្មតា ។ តៀវប៉ូឃើញដល់តល់កំចាំងផងខ្លួន
ក៏ថយទ័ពត្រឡប់ទៅខាងក្រោយ ដូហ៊ុខ្ញុំពីក៏លើកពលតាហានតាមប្រកិតដ៏តដោយ
តាមប្រកិតដ៏តដោយទៅទាល់តែដល់ប្រកប្រហាកក្នុង គួនអ៊ូតៀវហ៊ុយ
ដែលនៅពីលើក៏ចាលចុះមកខ្ទប់ប្រសព្វគ្នាតាំងសងខាង តាបាតៀវប៉ូឲ្យ
នៅជាកណ្តាល មិនដឹងនឹងវិនាសទៅខាងណាក៏បែកខ្ចាត់ខ្ចាយអស់ទៅ
ខ្ញុំពីលើកពលតាហានតាមទៅទៀត ក្រឡេកទៅឃើញអក្សរឈ្មោះ
តៀវប៉ូ ឯតៀវប៉ូនោះតេ់ចូលទៅកន្លែងព្រៃ ខ្ញុំពីលើកធ្នូបាញ់ទៅត្រូវស្មា
ធ្វេង ព្រួញក៏ជាប់ស្មាទៅ តៀវប៉ូច្រិងតេ់ស្រួតទៅដល់ស្រុកយ៉ាងសាហ
ចូលកងកំពែងបានហើយក៏ខ្ទប់ចិទ្វារស្រុកទុក ។ ដូហ៊ុខ្ញុំពីដេញ
តាហានតាមទៅក៏កាយទ័ពព័ទ្ធដុំព្រៃស្រុកនោះ ហើយចាត់តាហានឲ្យ
ចេញទៅស៊ើបស្តាប់ដំណឹង ហាងហ៊ីសុនដែលទៅចាំឆ្នាំងនឹងតៀវលៀង
ទទួលសេះចំរើនាំសំបុត្រមកថ្វាយដូហ៊ុខ្ញុំពីថា ឥឡូវនេះហាងហ៊ីសុង
លើកពលទៅចាំឆ្នាំងនឹងតៀវកុតទ ។ ស្តាប់មុនទៅហើយ ឯតៀវលៀងប្អូន

តៀវកុក ក៏លើកពលចេញច្បាំងនឹងហង់ហ៊ូសុង។ ច្បាំងនឹងតៀវលៀង ។ ថែកទ័ពដល់ ៧ ដង គ្រាក្រោយហង់ហ៊ូសុងកាប់តៀវលៀងស្លាប់ក្នុងស្រុកឆ្ងាយនឹងហើយ បណ្តាបក្ខពួកបរបស់តៀវលៀងតាំងប៉ុន្មានសឹងមកចុះចូលនៅជាច្រើន ហង់ហ៊ូសុងបានឃុំខាំយកបក្ខពួកបរបស់តៀវកុក នឹងសពតៀវកុកចូលទៅថ្វាយព្រះចៅខ្មែរគេ។ ខ្ញុំព្រះករុណាខ្ញុំមានឲ្យហង់ហ៊ូសុងឡើងទីជាឧកញ៉ាគុនតឹជាឥស្សរសម្រាប់រក្សាព្រះអង្គឲ្យគ្រងស្រុកបុិយជាវហើយហង់ហ៊ូសុងគ្រាចចង្អុលទូលព្រះចៅខ្មែរគេថា លោកិតមានសេចក្តីតាប់គួរក្នុងការធ្វើសង្គ្រាម នឹងឋានមានសេចក្តីកំហុសដូចជួយហ្នឹងគ្រាចចង្អុលទូលដូច្នោះកំរេ ព្រះចៅខ្មែរគេខ្ញុំជាបដូច្នោះ ក៏គ្រាស់ឲ្យដោះលោកិតចេញពីទោសចោរហើយឲ្យគង់ទីដូចដើម ។ ឯចម្ងួនោះមានសេចក្តីតាប់ប្រសើរក្នុងពាក្យការខ្ញុំរៀបរាប់ប្រាប់ទៀតឈរស្រុកចេញ ។

ដូហ៊ុ ខ្មែរ)តើដែលខ្លាមព័ទ្ធស្រុកយៀងសារនោះដឹងថា បណ្តាគាហានខ្វិកដការគ្មូចធំ សឹងមានសេចក្តីតាប់ប្រសើរក្នុងពាក្យការចាត់ឲ្យទៅឈរវៃគ្រប់ណាដារច្រើនតំបន់ដូច្នោះ ក៏ខំស្រូតរូតដេញគាហានឲ្យចូលវាយតំណាយស្រុកយៀងសារ ជិតនឹងបានការហើយ ខ្ទួលច្បាំងចេងគាយគាហានចារតែកតូរគ្នានឹងពួកចោរតាំងពួន លុះបរស្លាប់តៀវប៉ូជានាយចៅហ្វាយស្លាប់ហើយ កាត់យកក្បាលនាំទៅជូនដូហ៊ុ ខ្មែរ)ពីមានតែក្រៅស្រុក ហើយសុំខ្លួនចុះចូលធ្វើពាក្យការជាមួយគ្នាទៅ ដូហ៊ុមានចិត្ត

អំណោរណាស់ ក៏តែងសំបុត្រតាយដំណើរតើរធ្វើកជការមានគុណបំណាច់ ទាំងប្អូនចកចូលទៅក្រាបបង្គំទូលថ្វាយព្រះចៅមឡេនតែគ្រប់ប្រការ ។

មានឈ្មោះតៀវហង ហាន់តុង ស៊ុនតុង ជាសេនាតៀវកុក លុះតៀវកុកស្លាប់ហើយ ក៏បញ្ចុះបញ្ចូលពួកចោរបានច្រើនហ្នឹង លើកទៅបំផ្ទន់ដងណ្តើមយកទ្រព្យរបស់អស់បណ្តាអ្នកស្រុក ហើយដុតបំផ្លាញផ្ទះសម្បែងជាច្រើន សេះប៉ារើក៏នាំសំបុត្រចកចូលទៅក្រាបបង្គំទូលថ្វាយព្រះចៅឡេនតេ។ ទ្រង់ត្រាស់ឲ្យមានសារត្រាទៅដល់ជួហ៊ូ ឲ្យជួហ៊ូ ចាត់ទាហានដែលមានថ្វីដៃខ្លាំងពូកែលើកទៅបង្ក្រាបពួកចោរទាំងនោះឲ្យបាន ។ ជួហ៊ូបានទទួលព្រះដម្រាស់ហើយក៏ចាត់សេនាទាហានលើកទៅឡោមព័ទ្ធស្រុកអួនសៀវជ្រុងខាងកើត ឡោ)តិ តួនអ៊ូ តៀវហ៊ុយឡោមព័ទ្ធជ្រុងខាងលិចខណៈនោះ តៀវហង ចាត់ឲ្យ ហាន់តុង ឃុំទាំពលទាហានចេញទៅតទល់ខាងទ័ពឡោ)តិ ជួហ៊ូឃុំទាំពលទាហានឯក២០០០ចូលទប់ប្រសព្វតិម្ខាងឯពួកចោរតទល់លើសកំណាំងគ្រាំពុំបាន ក៏ថយទ័ពត្រឡប់ក្រុងកំផែងស្រុកវិញ ឡោ)តិទីនឹងសេនាទាហានទាំងពួង កំលើតតាមចូលទៅវាយទំលាយទល់ដល់កំផែង ក៏ឡោមព័ទ្ធទុក ពួងចោរទៅក្នុងកំផែងស្រុកអត់ជាប់សឿងអាហារខ្លាំងណាស់ ទើបហាន់តុងប្រើទាហានចេញមកកេជួហ៊ូសុំចំណុះបុះបួលជួហ៊ុ។ ដ៏ន ត្រមទទួល ឡោ)តិក៏និយាយថា កាលត្រាផែនដីព្រះចៅហាន់កូបួ ទឹងបានពាជសម្បត្តិនោះ ព័ត្រោះមានមនុស្សមេធ

ស៊ុំចំណុះចុះចូលជារឿន ហេតុម្តេចទើបលោកមិនព្រមខ្ជូលគេជាចំណុះ
ដូច្នោះ ។ ដូហ្ន៎តបថា សាលគ្រាព្រះថៅហាន់កូចូនោះស្រុកខេសមិនបាន
ចែកគ័ តើគប់រូនចំរះជារឿនណា សង្កាន់ជាព្រះថៅហាន់កូចូខ្ជូល
មនុស្សចំណុះចុះចូលរឿន គ្រានេះមានកើតចលាចលតែត្រឹមពួកចោរ
ដួតក្បាលលឿងមួយពួកទេ បើនិងខ្ជូលពួកចោរជាចំណុះចុះចូលទៅ
មនុស្សគាំងពួនិងយកគន្លាប់តាមន្លាថាឆ្កើឧសហើយ បើមានអ្នកមក
បង្ក្រាបសឹមលះបង់ពុតអាក្រក់ គន់មិនត្រូវទៅជាមនុស្សល្អបាន ឃ្លាវ
ទៅនិងឆ្កែតែវិញបានទៀត ។ ឮពាក្យស្តាប់សព្វគ្រប់ ក៏ខ្ជូលថា
ប្រសាសន៍នោះគួរហើយតែថាការដែលឆ្លើងមកឡោមព័ន្ធស្រុកទុកដុំ
ទាំង ៤ ទិសឲ្យទៅដូច្នេះ ពួកវាក៏ខាល់ចញមិនរួចសោះ សូម្បីពួកនោះ
ក៏សិនតែជាជាតិតាហានឧបមាដូចជាសុនខដែលខាល់ព្រក ឃាលណា
ឡើយវានឹងខ្លាំងសឹមឲ្យតាហានយើងចាប់បង់ដោយងាយ តន់ទឹងតាំង
ប្រាំងតាក់តែវិនាសមួយ ។ តាហានយើងក៏គិតនិយាយបង់ខ្លះជាធម្មតា
មានឧបមាដូចយកពុំសែនទៅដួរយកអំបិល បើដូច្នេះសូមឲ្យបន្ទួយតាហាន
ដ្រែងទាន់តើតចេញពុះ ដើម្បីតុកដូឲ្យពួកវាតេចេញទៅ សឹមតាមចាប់
យកដោយដំរែបាស្លាយើញបានដោយងាយ ។ ដូហ្ន៎ស្តាប់ទៅយើញត្រូវ
ក៏ឲ្យបន្ទួយតាហានដ្រែងទាន់តើតចេញអស់ហើយមកព្រួតទំលាយតែទាន់
ទិសទាំង ៣ ។

(មានត)

ភាគទី ១៥

ឃុនសុន្ធរមេធី ញ្ជង-ស្ងើង ប្រែ

លោក ហង់-គិមសេង ពិនិត្យ

(តមក)

"តស់លោក អ្នកចាំងឡាយ, សូមមេត្តាជ្រាបខ្ញុំផង, ហេតុដូចម្តេចក៏ខ្ញុំមកនៅត្រង់កន្លែងនេះ?" ។ មនុស្សម្នាក់និយាយជំនួសគេឡើងថា "នែអ្នកកំឡោះ, គេទើបនឹងបើកទ្វារក្រុងនេះភ្លាម នាំគ្នាចេញមកស្រាប់តែឃើញអ្នកឯងដេកស្តូកស្តឹងនៅមុខ, តួកយើងក៏នាំគ្នាឈប់សង្កេតមើលព្រោះមានសេចក្តីងឿងឆ្ងល់ដែរ; យើងសុំសួរអ្នកឯងវិញ: ចុះយប់មិញ អ្នកដេកនៅកន្លែងនេះឬ? ម្យ៉ាងទៀត អ្នកដើរចេញពីក្រុងអ្នកឯងនៅស្បែរទ្វារណាមួយនៃក្រុងជាម៉ាស់នេះឲ្យ?" ។ ចេត្រទេវិនឆ្លើយថា "អ៊ីនៅស្បែរទ្វារណាមួយនៃក្រុងជាម៉ាស់! អ្នកនិយាយយ៉ាងនេះ តើចំអកឲ្យកឲ្យឱ្យខ្ញុំតែម្តង, កាលពីយប់មិញនេះ ខ្ញុំដេកនៅឯក្រុងកែវទេតើ" ។ និមិត្តតែបានឮពាក្យនេះហើយ ជនពួកខ្លះមានសេចក្តីអាណិតអាសូរ នាំគ្នានិយាយថា "ទុស្សាយពេកតួឲ្យអាណិតណាស់ហ្ន៎! មនុស្សកំពុងពេញកំឡោះរូបស្រស់ស្អាតជាតវៃបែបនេះ មិនសមប៉ប៉ែមឲ្យសតិល្ងីល្ងើដូច្នេះសោះ" ថាហើយក៏ដើរហួសទៅ ។

គ្រានោះ មានគ្រឹហ្ថាចារ្យម្នាក់និយាយឡើងថា "នែចៅគ, ម្តេចក៏អ្នកមិនគិតពិចារណាមើល: បើព្រឹកនេះអ្នកទៅក្រុងជាមាំស៍, រួចល្ងាចម្សិលមិញថាទៅឯក្រុងកែវវិញម្តេចកើត? រឿងនេះមិនចំនង់សោះព្រោះក្រុងទាំងពីរនេះទៅឆ្ងាយពីគ្នាណាស់" ។ ចេរៀខនិនតបថា "ឆ្ងាយខ្លាំងមែន ដំណើរនេះពិតប្រាកដហើយ, ខ្ញុំសូមដំកបថែមទៀតថា ម្សិលមិញខ្ញុំទៅឯក្រុងចាល់សូរ៉ាំមួយថ្ងៃក៏ល្ងាច" ។ និយាយពាក្យនេះស្ទើរតែមិនទាន់ផុតមាត់ផង គេនាំគ្នាសើចតិះដៀលឡើងហ៊ោឱ្យគេស្រែកគ្រប់គ្នាថា "មនុស្សឆ្កួត! មើលមនុស្សឆ្កួតវ៉ុយ!" ។ មានម្នាក់ទៀតចាប់និយាយថា "នែអ្នកប្រុស, អ្នកឯងពិតជាវង្វេងខ្លួនសតិហើយ, ម្តេចក៏មិនគិតពិចារណាមើលដល់ពាក្យដែលខ្លួននិយាយ, ដែលមានដៃរឹបមនុស្សតែម្នាក់ ពេលថ្ងៃទៅឯក្រុងចាល់សូរ៉ា, ពេលយប់ទៅក្រុងកែវ ហើយព្រឹកឡើងស្រាប់តែមកទៅឯក្រុងជាមាំស៍ឯណោះវិញ? អ្នកឯងចេះហេលជាមិនទាន់រលឹកដឹងខ្លួនស្រួលបួលទេដឹង, បើអ្នកតម្រង់ជាសំស្មារតីវិលវល់ខ្លួនឱ្យច្បាស់លាស់ឡើងមើល" ។ ចេរៀខនិនហាសួនឆ្លើយថា "ទេ, ខ្ញុំមិនដឹងជារំលឹកជាស់ស្មារតីប៉ាន់មេចទៅទៀតទេ, បើមនុស្សភ្ញាក់ស្មារតីចេះយ៉ាងនេះទៅហើយ មានទៅដេកលក់ការណា. រឿងនេះគឺពិតប្រាកដដូច្នេះឯង, ម្សិលមិញខ្ញុំបានទាំងរៀបចំធ្វើមង្គលការខ្លួនឯងទៅឯក្រុងកែវឯណោះផង" ។ ពួកអ្នកដែល

ចំណូលខាងស្តាប អាលបើឮពាក្យនេះហើយ ក៏ចេះតែតាំងគ្នាស្តាបខ្លាំងឡើងជាងមុនទៅទៀត, មនុស្សជាដៃលនោះនិយាយតទៅថា "ចូរអ្នកពិចារណាគិតរឿងនេះឲ្យមិនចាស់ ព្រោះអ្នកឯងប្រហែលជាយល់សប្តិទេយ៉ាងម៉េលហើយការស្រមើស្រមៃនោះទៅជិតជាប់កន្លងគំនិតទៅទៀត ឬបានជាចេះតែនិយាយដូច្នេះ" ។ មាណពក៏ឆ្លើយទៅវិញថា "ខ្ញុំដឹងច្បាស់ណាស់ដំណើរដែលខ្ញុំនិយាយទៅពាំងអម្បាលម៉ានឥតស្រមើស្រមៃប្លុកគាន់ប្រឡំទេ, អ្នកថាមកចុះហ៎! ទំរឹងថាខ្ញុំនឹកស្រមើស្រមៃទៅដល់ក្រុងតែរំដូចម្តេចកើត, ខ្ញុំចាំជាក់ច្បាស់ណាស់ថា ខ្ញុំបានទៅកន្លងក្រុងនោះហើយគេបានចាំងនាំប្រាប់ខ្ញុំមកឲ្យឈរនៅចំពោះមុខខ្ញុំដល់ទៅ ៧ លើក តើពាល់តែលើកដែលខាងផ្លាស់សំលៀកចំពាក់ថ្មី?, ហើយដល់ទៅទីបំផុត ខ្ញុំបានឃើញគាងមអប្រែយដែលគេយកមកឧបកិច្ចបញ្ជោតបំរុងឲ្យធ្វើជាប្តីខាងនោះផង, បើយ៉ាងនេះតើ ទំរឹងថាខ្ញុំស្រមៃស្រមើស្រមៃស្រមៃដូចម្តេចកើត? សូមអ្នកមេត្តាជ្រាបខ្ញុំទៀត ចុះអាខ្ញុំ, ឥតក្បាលខ្ញុំត្រមាំងថយជាក់ជ្រាក់ដែលខ្ញុំមានទៅឯក្រុងកែវនោះ តើបានទៅឯណាអស់ទៅ" ។

ចេះទ្រង់ឱមហស្ត្រីន ពុកណាជានិយាយបញ្ឆាក់ហើយបញ្ឆាក់ទៀតតាមសេចក្តីពិតមែនយ៉ាងនេះ ក៏ជនចាំងឡុកយដែលស្តាប់សេចក្តីនោះទៅតែសើចដដែល គឺគេពុំជឿដោយជាច់ខាត" ។ រឿងនេះនាំឲ្យ

ចេះត្រែខ្ញុំនិងហាស្ន៍ន រីឯខ្ញុរវង្វើងកាន់ស្មារតី សូម្បីតែខ្ញុំនឯងក៏គេ
ពិចារណារឿងខ្ញុំនតុំយល់រកកល់តែនឹងមនុស្សសង្ស័យ ខ្ញុំនឯងថែមទៀត
ថាអញ្ចឹងមិនមែនអញ ? ។

លុះបាននិយាយបញ្ជាក់ គាំ ភាវៀត្រមកដោយប្រកាន់មាំថារឿង
ដែលខ្ញុំននិយាយ គាំងអស្ចារ្យម៉ាន ជារឿងពិតឥតក្លែងក្លាយយ៉ាងនេះ
ហើយ ទើបមាណពត្រាក់ឡើងដើរចូលទៅក្នុងក្រុង, ចំណែកអ្នក
គាំងអស់នោះក៏ដើរចោមរោមហើយស្រែកបណ្តើរថា "មនុស្សឆ្កួត!
មនុស្សឆ្កួត!" ។ កាលបាននឮសូរសំឡេងដូច្នេះ អ្នកខ្លះអើតមើល
តាមបង្អួច, អ្នកខ្លះឈរមើលទៀបមាត់ទ្វារ ហើយមានជនខ្លះទៀតរត់
មកចូលក្នុងពាំណាមមនុស្សដែលដើរតាមចត្រែខ្ញុំនហាស្ន៍ន ហើយ
ស្រែកតាមគ្នាថា «មនុស្សឆ្កួត» ដោយឥតដឹងដំណើរដើមទង្វើ
ទៀយ ។ មាណព កំពុងតែតប់ប្រមល់តឹងខ្ញុំនយ៉ាងនេះ ឱះតែដើរ
ទៅ ក៏បានដល់មុខផ្ទះខាងទិយភាណិង (អ្នកលក់គ្រឿងបង្អែម) ម្ចាស់
ដែលចេះតែភ្ញាក់ផ្អើលចំហ ទើបចូលទៅក្នុងផ្ទះនោះដើម្បីគេចវេះអំពើបណ្តាជន
ដែលតាមចោមមើលច្រើនពេក ។

ភាណិងនោះ កាលពីដើមធ្លាប់ជាមេនៃពួកអាប៉ម្នាក់ស្តេចស៊ីផឹក
ប្រមែប្រមៅ តែងតែស្គាត់ហូនផឹកជាមួយពួកឈ្មួញនានាមានឈ្មួញ
រះនេះជាដើម, សូម្បីដើងអ្នកលេងដែលចេះតន្ត្រីនេះមកតាំងផ្ទះសម្បែងរកស៊ីលក់

ជួរនំចំណីទៅក្រុងជាម៉ាស់ គាត់គិតនិតការហោចគ្រាមក្រុមិនដែលឲ្យពុក
ទោសដល់អ្នកណាមួយយ៉ាងនេះហើយ ក៏តង់អ្នកជង់នៅតែខ្លាចគាត់យ៉ា
ងកាច ព្រោះឮថាប់ចាក់សម្លាប់តមកហើយ; ហេតុនោះ គាត់គ្រាន់តែចោល
ក្អែកចំក្អាមចណ្តាជនដែលចោមរោមតាមមើលមេត្រែខ្លួន តាំងអម្បាល
ម៉ានតាំងគ្រាកគេចរឿះក្រៀសអាត្មាចាត់អស់លើង ។ កាលគេទៅ
ចាត់ស្លាត់អស់ហើយ, ពាណិជតាំងសួរប្រុសដំទង់អំពីដំណើរដើមទង
គ្រប់សព្វហើយសួរថា អ្នកឯងជាអ្វី, ខ្ញុំណានាំអ្នកឯងមកគាន់ក្រុង
ជាម៉ាស់នេះ ។ មេត្រែខ្លួនហស្សិន ឥតលាក់អ្វីទេ បានសារសព្វ
តាមហ្មូរហែអំពីកំណើតរបស់ខ្លួន, មណោភាពនៃឥន្ទសេនាបតីជាបិតា,
ដើម្បីហេតុដែលចេញមកពីក្រុងបាល់សូរ៉ា, រឿងដែលដេកឥយប់មុនលើ
ផ្ទះខ្ញុំចនឹកហើយដល់ភ្ញាក់ឡើង ស្រាប់តែឃើញខ្លួនឯងនៅឯក្រុងកែវ
ព្រមទាំងបានរៀបចំការប្រពន្ធនៅរីឯងផង; ក្នុងទីបំផុតគាត់ថ្លែងម្ចាស់
ខ្លួនកំគោងតែងឿងឆ្ងល់ណាស់ ដោយឃើញខ្លួនឯងមកនៅឯក្រុងជាម៉ាស់
ឯណេះវិញព្រឺឆើយ តើមិនយល់រឿងចំឡែកអស្ចារ្យទាំងនោះសោះ ។

ពាណិជក៏និយាយថា "រឿងអ្នកឯងចំឡែកពេកណាស់; ប៉ុន្តែបើអ្នក
យល់ព្រមធ្វើតាមពាក្យខ្ញុំ, អ្នកកុំនិយាយរឿងទាំងអស់របស់ខ្លួនដែលខ្លាច
ទឹងសារសំពួកប្លាប់ខ្ញុំអម្បាញ់មិញនេះ ប្រាប់អ្នកជំទេរឲ្យគេដឹងឮតទៅ
ទៀត, អ្នកត្រូវស្ងើចាំអត់ធ្មត់សិនទៅ បន្តិចទៀតគង់មានឱកាសនឹង

គ្រាប្រណីដួយដោះអ្នកឲ្យរួចអំពីគ្រោះថ្នាក់ដែលអ្នកកំពុងតែទទួលនេះទុក្ខសព្វថ្ងៃនេះពុំខាន; អ្នកត្រូវតែទៅជាមួយនឹងខ្ញុំដកបដល់ពេលនោះ; ម្យ៉ាងទៀតខ្ញុំគ្មានកូនទេ, បើអ្នកយល់ព្រម ខ្ញុំយកអ្នកធ្វើជាកូនភ្លាម, កាលបើអ្នកបានធ្វើជាកូនពិតមែនខ្ញុំហើយ អ្នកនឹងដើរកាត់ទីក្រុងនេះបានតាមចិត្តហើយអតមានឧរណានឹងហ៊ានប្រមាថមើលងាយឡើយ ។

ទោះបីការទទួលខុសជាកូនចិញ្ចឹមគេនេះមិនសមដល់កត្តិយសកូនអគ្គមហាសេនាក៏ពិតមែន ប៉ុន្តែបែរជាខ្លែខ្ចីនិន អាចយល់ព្រមទទួលបានតាមចំណង់របស់អ្នកលក់នំ ដោយពិចារណាឃើញថាគេជាមនុស្សវិសេសលក្ខមធ្វើខ្លួនជ្រាណាបាន ដើម្បីនឹងលៀងដំរែតទៅ ។ ពាណិជឲ្យមាណពស្ទៀតពាក់ ភាវាស្អាតបាត យកសាក្សីជាច្រើនគ្នា ហើយបួលទៅបង្គំលោកចៅក្រមថាខ្លួនបានយកបេះខ្លែនិនធ្វើជាកូន, រួចហើយបេះខ្លែនិន ក៏បានទៅរួមសុខរួមទុក្ខជាមួយនឹងពាណិជ, គេហៅឈ្មោះដំដែលថាហាស្ស៊ែន។, តមកបានចាប់ផ្តើមរៀនធ្វើនំ ។

កន្លងណៈដែលរឿងនោះកំពុងតែតវ៉ាតវ៉ានៅក្រុងដាម៉ាស់ឯណោះ, ធីតាលោកសេមសេនិន ម្ចាស់ហ្វូង ភ្ញាក់ឡើងស្រាប់តែឥតឃើញបេះខ្លែនិនទៅក្បែរខ្លួនឯងសោះ ទឹកស្មានថាប្រហែលជាប្តីលួចគ្រែតឡើងមុនចេញទៅក្រៅមិនឲ្យនាងដឹង ដោយខ្លាចរំខានដល់ការនិទ្រារបស់នាង ហើយចន្លិបខ្លែតឥងនឹងត្រឡប់ចូលមកវិញពុំខាន, ដោយ

ស្នានដូច្នេះ ទើបនាងនៅរង់ចាំមើលដំណើរថ្ងៃនឹងរៀលត្រឡប់វិញ, គ្រានោះលោកអគ្គមហាសេនាជាឯកា មានសេចក្តីអាម៉ាសមុខខ្លាំងណាស់ដោយព្រោះជាប្រុសអសុប្តិ ទ្រង់ប្រើអំណាចយ៉ាងដាច់ខាតដូច្នេះ, លោតមនោះទ្រាបទូលថ្វាយស្រី ប្រុងនឹងចូលទៅយំសោតរៀបជាមួយនឹងនាងអំពីព្រឹងសំណាងអាក្រក់, លោកបានហៅចំឈ្មោះនាងដើម្បីឲ្យបើកទ្វារ ។ ពីតាឮហើយក៏ក្រោតឡើងស្ទុះទៅបើកទ្វារ, បានចាប់ដៃបីតាយកមកថើបហើយពោលតំណាក់ជាយការសំដែងនឹតមុខញញឹមញញែមស្រស់ស្រាយ ; លោកអគ្គមហាសេនា ស្នានថាកូនស្រីមុខជាកើតទុក្ខកម្ទេចក្រៀមក្រំយំខ្សឹកខ្សួលជូបលោកដែរ ហើយចែរជាយើញនាងញញឹមពព្រាយដូច្នោះទៅវិញ ទើបលោតងឿងឆ្ងល់ណាស់ ។ លោកនិយាយគំរាមគំរែយទាំងខឹងសម្បារថា "នែមេធើតម្ន! ហ៊ានឯងសំដែងអាការបែបនេះចំពោះមុខអញឬ? ហ៊ានទើបរៀបការជាមួយនឹងអាមនុស្សគំរាមញ្ជះគេហើយក្លាម លោតែធ្វើតមុខស្រស់ស្រាយមកពេលអញកើត អាការបែបនេះសមណាស់ឬ? ត្រង់អញឯណោះ ស្ទើរតែនឹងប្រែក្លាយដើមទ្រូងស្លាប់ ហ៊ានឯងមិនតិត, កូននេះបានចំជាតូចថោតមែន!! ។

ឥតាឃើញថ្ងៃតាស្តីបន្ទោសដៀលត្មះសេចក្តីតែកាយវាចាស់ខ្លួនដូច្នោះក៏ដាច់ចិត្តថា "លោកម្តាយ, សូមមេត្តាអត់ទោស, លោកពុំគួរនឹងស្តីបន្ទោស

ខ្ញុំតាំងខ្លួនខ្ញែនខ្ញុសចំនងដូច្នេះសោះ ខ្ញុំមិនមែនរៀបការទ្វេនជាមួយ
នឹងគាតមកប្រៀបដែលខ្ញុំស្អប់ខ្ពើមជាងសេចក្តីស្លាប់នោះទេ; អ្នកតាំងអស់
គ្នា បានធ្វើឲ្យគាតមកអៀនខ្មាសជាច្រើន ពាល់តែជញ្ជាំរៅពុំបាន រត់
ទៅពួនបាត់ទៅ ហើយខ្លួតកន្លែងឲ្យកំណេរបូតស្រស់ម្ចាត់ ដែលត្រូវ
ជាស្វាមីខ្ញុំពិតប្រាកដ" ។ លោកសមរសខ្លួនម្តងទៀត ធ្វើយតាត
ទ្បើនលាន់រហ៊ីសថា "ម៉េរ៉ើ, បុរេនឯងនិងចាយឈឿនក្លាយជាប់
តញ្ជាដូចម្តេចហ្នឹង? យ៉ាន់ណាមិញ, នឹងតែមិញនេះគាតមិនបានដេតជាមួយ
នឹងឯងទេឬ?" ។ គាន់ពាជក្លាមថា «ទេ លោតឪពុក, ខ្ញុំមិនបាន
ខ្លួលតានដំណេតជាមួយនឹងបុរសដទៃក្រៅពីកំណេរនោះទេ, ស្វាមីខ្ញុំ
នោះមានក្អែតខ្លួលាយហើយមានរាងចំក្តើម ឡូស្រស់ ។ ក្រែន់តែ
បានឮពាក្យនេះហើយ, លោតឥត្តមហាសេនាធិតីប្រកាតទ្បើនមួយ
វ៉ែពចរៀសតតំហកឲ្យក្មួនថា «មេចាលមេរ្យាត ហានិចតាំងធ្វើឲ្យតញ
រៀងគាន់តំមិតពីរ ក្រែតែសំដីហានិឬ?» ។ ធីតាតបញ្ជាថា ចាសទេ
លោតឪពុក ខ្ញុំដែលចំគាន់ស្មារតីខ្ញុំឲ្យរិលវល់ ព្រោះលោតមិនជឿសំ-
ដីខ្ញុំសោះ» ។ លោតឥត្តមហាសេនានិយាយទ្បើនថា ពិតជាមិនមែន
គាតមឬ?» : ធីតានិយាយដោយ សេចក្តីគាន់ខ្មាញ់សើរតែនឹងលោត
ឪសទ្បើមលើឪពុកថា «លោតឪពុកមលែងនឹតឈ្មោះគាតមនោះទៅ ខ្ញុំ
មិនត្រូវគាតឬឈ្មោះរ៉ាទេ ខ្មោចគាតមកប្រៀយចោលមេរ្យាត លោតឪពុក

ម្តេចក៏ទៅតែងកណ្ឌោះមកនិយាយឲ្យខ្ញុំឮទៀត ? ខ្ញុំសូមដំណាងជំនួសម្តងទៀតថា ខ្ញុំឥតបានទទួលទានដំណែកជាមួយគេទេ, តែជាមួយនឹងស្វាមីវិញស្រស់ប្រឹមប្រិយដូចខ្ញុំបានដំណាងមកម្សាញ់មិញនេះ ហើយឥឡូវនេះគាត់មិនមែនទៅឆ្ងាយពីវិនេះប៉ុន្មានទេ" ។

លោកសេមសេខនិន ម៉ូហាម្មទ ចេញទៅក្រៅភ្លាម, ប៉ុន្តែមិនបានយើញកំណែរបស់ចស់នោះទេ, ស្រាប់តែភ្ញាក់ព្រឺតរោយដូចប្រែខុសអាតមទៅវិញ, យើញក្បាលជាំកុះក្រាម ជើងឡើងលើត្រង់កន្ទុងដែលបិសាចបានជាក់វាយ"ដណាតាំងពីចាប់; លោកក៏សួរដោយសេចក្តីងឿងឆ្ងល់ថា "ចុះហេតុយ៉ាងម៉េចហ្នឹង ? នរណាធ្វើកម្មអកុសលយ៉ាងនេះ ?" ។ អាតម ស្គាល់ជាក់ថាលោកអគ្គមហាសេនា ទើបឆ្លើយថា "យើអើ! លោកនេះហើយឬដែលបានរៀបចំឲ្យខ្ញុំធ្វើមគ្គលការជាមួយនឹងស្រីចេស៎ាគ្រប់ គឺជាសហាយនៃបិសាចបង្កៃ ? ខ្ញុំនឹងលែងចាញ់បន្លោតលោកទៀតហើយ, លោកចាប់ខ្ញុំមិនបានទៀតទេ ប្រាប់ឲ្យដឹង" ។

លោកសេមសេខនិនម៉ូហាម្មទ កាលបានឮអាតមនិយាយដូច្នោះឥតស្មានថាជានិយាយចំអកឲ្យគេវិញលេងផ្តេសផ្តាស ទើបលោកតបថា "ចូរត្រឡប់ត្រឡប់ក្បាលឡើងលើ ហើយឈរឲ្យត្រង់ស្រួលបួលទៅ កុំលេងយកក្បាលធ្វើជើងៗធ្វើក្បាលដូច្នេះមិនគំនង់ទេ" ។ អាតមធ្វើយភ្លាមថា "ខេលោត, បើថ្ងៃមិនទាន់រះទេ ខ្ញុំនឹងទៅតែធ្វើដូច្នេះឯង, (មានត)

ប្រវត្តិពង្សាវតារជាតិ

តំណែងក្តៅណាងនុប្បទាន និង កម្មវិធីលោមបងកំចុះ

ព្រះសពសម្តេចព្រះមហាសុមេធាធិបតីសង្ឃនាយកគណៈមហានិកាយ

ព្រះគ្រូគោធរង្សីចរិយាព្រឹទ្ធ ភដ-កិត្តិ រៀបរៀង

បឋមឧសភៈ វស្សៈឆ្នាំ ១

កុមារហ៊ុន ជាបុត្រលោកដំទប់លេខ ១ នាមហ៊ុក មាតានាមវែន ជាតិខ្មែរ ស្រុកកំណើតនៅភូមិកំពង់ពោធិ៍ដំណាក់មាន់ ឃុំត្រពែងរាង ស្រុកដង្កែបច្ចេសកម្ពុជា សម័យនោះកើតរឹបរឹតក័ន្តខ្លែច ជាន់ពាមកំហែងហេតុនោះមាតាបិតារបស់លោកក៏ហ្វាតចាកខ័ណ្ឌខ្លែងមកនៅភូមិចាក់អង្ករស្រុកកំពង់សៀម ខែត្រកំពង់ចាម ហើយប្រសូតបុត្រឈ្មោះកុមារហ៊ុន នាវេលាមធ្យឹមយោមអធ្រាត្រតែគឺស្ងាត់ ថ្ងៃអាទិត្យ ៨ កើតខែឫស្សា ឆ្នាំកុរ ឯកស័ក ទស្សវត្សរ៍ជាប្រក់តាំងពីវ័យ គ.ស ១៨៦៩ គ្រាយមក មាតាបិតាខ្មែរកុមារហ៊ុនមកនៅឃុំលេខ ១ ស្រុកយ៉ងកំពេញ ខេត្តកំពង់ចាម ជាសម្ងាអាជីវៈ ដោយដល់ស្រុកខ្មែរសាន្តគ្រាណាស់ទើបបានត្រឡប់ទៅនៅស្រុកកំណើតវិញ រួចក៏នាំកុមារហ៊ុនឲ្យទៅនៅវត្តសាំងសាម៉ី ដើម្បីឲ្យសិក្សាអក្សរសាស្ត្រខ្មែរ អំពីសំណាក់

លោតត្រែព្រះមុនីវង្ស ចៅអធិការវត្តសាំដសាមី នាមត្រាំ ក្នុងជន្មាយុ ๑๐ ឆ្នាំ សម័យនក្តីក្តីមានជ័យ ក្នុងវែនដីព្រះបរម ៣ជ្ជ ។

ឧត្តរយនសកៈ រយៈ ទី ๒

កុមារប្រាក់-ហ៊ុន សូត្រវៀនបឋមវិជ្ជាទេវគោសា ចេះដឹងមើលឮ ស្តាប់ស្តាប់ពើត ចេះចាំទន់ស្តឹកភ្នែត ចេះតែងសេចក្តី ចេះលេខភ្លុតភ្លែវ ជាក្មេងមានចិត្ត បិតាទៅក្នុងសប្បុរិសកូមិ ប្រពន្ធបាយកតញ្ញូ កតវេទី ចេះដឹងគោរពប្រណិបត្តន៍មាតាបិតាដោយប្រពៃ លុះដល់អាយុ ๑๒ ឆ្នាំ ក៏លាមាតាបិតាមកបព្វជ្ជាជាសាមណេរដោយសទ្ធា ក្នុងសំណាក់ព្រះបព្វជ្ជាចារ្យ នាមត្រាំ ក្នុងឆ្នាំជនស័ក ត្រីស័ក្ករាជ ๑๘๗๒ សាមណេរប្រាក់-ហ៊ុនបួសឡើង មិនដែលល្មើសចាស់ខុសនឹងព្រះបញ្ញត្តិក្នុងសាមណេរកូមិសោះឡើយ ។ ជាអ្នកសង្រ្គមសមគួរតាមសាមណេរវិន័យ ហើយប្រតិបត្តិដោយល្អប្រពៃមានៈសេចក្តីព្យាយាមទុស្សាហ៍រៀនសូត្រធម្មវិន័យ ហើយប្រតិបត្តិដោយល្អក្នុងព្រះពុទ្ធសាសនា ជាតិវេស្សាជាន់ព្រៃញព្រះន័យនៃព្រះទេបជ្ជាយ៍ កំលាចាតសិក្ខាបទមកជាឃាកាស ជាទេរៀមចំណេះវិជ្ជាការហត្ថកម្មសិប្បវិយការតែជាងមាសជាផ្លូវសម្ងាអាជីវៈ ជាន់ទេបជ្ជាន់ចំរើមាតាបិតាដោយគោរព ដោយសេចក្តីជ្រះថ្លាស្មោះត្រង់ចំពោះគុណជាន់ចំបំផុត ។

តតិយឧសភាវយៈធិ ๓

ជាប្រាក់-ហ៊ុន អាយុ ๒๑ ឆ្នាំ មានចិត្តខ្សឹយណាយក្នុងកេរ
ឃាត់សង្ខារថ្កុំកេរចម្ងាត តែត្រាថ្នាន់តថស្នងសងគុណមាតាបិតា
ខើបលោលោងអុងដ៏មានគុណចេញផ្លាសុបសម្បទា ក្នុងព័ទ្ធសីមាវត្ត
សាំងសាមី ខែត្រតែវែង ។

ព្រះមគ្គញ្ញាណ នាម ឆួយ ជាព្រះឧបជ្ឈាយ៍
ព្រះចន្ទសារោ នាម ព្រំ ជាកម្មវាចាចារ្យ
ព្រះឥន្ទគ្គោ នាម សុខ ជាអនុសាវនាចារ្យ

ព្រមព្រៀងដោយឯណាសង្ឃ ๒๑ អង្គ ជាសង្ឃឯកន្តក្នុង ឲ្យឧបសម្បទា
ដល់កុលបុត្រប្រាក់-ហ៊ុន សំរេចដោយចន្ទកម្មវាចាក្នុងថ្ងៃព្រហស្បត៍
ខែអាសាឍ ឆ្នាំមមែចត្វាស័ក ព.ស. ๒๔๒๓ គ្រិស្តសករាជ ๑๘๘๓
ព្រះឧបជ្ឈាយ៍ឲ្យនាមឧបជ្ឈាត្តិកក្នុងការៈដាច់ចន្ទកេរ ។ ចាប់ដើមពីបាន
ឧបសម្បទាថ្ងៃណាមក កុលបុត្រប្រាក់-ហ៊ុន ជាអ្នកគ្រែកអង្គេនធម្មវិន័យ
ប៉ិយ្ហានវៀនសូត្រ ហូតដល់ចេះចាំកុលបុត្រមាតំខេ ចេះចាំ
ការណាវាចាលើយ៉ាន់ស្អាតជំនាញ ចេះខេសនាសាស្ត្រាយសព្វគ្រប់
គម្ពីរ ចេះចម្រៃបសរភេញ : រមៀចបុណ្ណ ។ បានចំរើនការនៅ
តថបញ្ជូតកម្មដ្ឋាន ដែលបានរៀនតមកពីសំណាក់ព្រះឧបជ្ឈាយ៍ចារ្យ
ក្នុងរវាងនៅភូមិ ៥ រសៀ បានខន្ធសីមាជាឧបសម្បទាចារ្យ ទី ๒ នៅត្រូ

ស្តេចត្រង់ ជាអ្នកសែនរកមោក្ខធម៌ប្រែព្រឹត្តជាន់ធុតង្គវត្តក្នុងទីរហោស្ថាន
នាព្រៃឃុនមេណាំអណ្តូត ខែត្រព្រៃវែង លុះដល់វស្សាទី ៨ ក្នុងឆ្នាំ
ឆលាងឯកស័ក ព.ស. ២៤៧១ គ្រិស្តសករាជ ១៨៩១ ត្រូវស្តេចត្រ
ប្រាក់-ហ៊ុន បានលាព្រះឧបជ្ឈាយាចារ្យមកសិក្សាព្រះបរិយត្តិឥន្ទ្រារុះ ។

ទី ១ អំពីសំណាក់លោកគ្រូព្រះបុប្ផាត់រតនវង្សនាមទិម ទៅ
អធិការវត្តកោះចិន ស្រុកពញាឮ ខែត្រកណ្តាល បាន ១ ព្រះវស្សា
លុះដល់ព្រះបុប្ផាត់រតនវង្សានកំពូទិមទ្ធ ទៅប្រទេសសៀម ទើបត្រូ
ស្តេចត្រង់-ហ៊ុន ទិមទ្ធមរតនដំទៅវត្តសាកវ័នតេជោក្រុងកំពង់ពេញ បាន
សិក្សាព្រះវិន័យពីសំណាក់ព្រះធម្មាចារ្យទាំង ៧ រូបនេះ គឺ :

ទី ២ ព្រះតេជព្រះគុណ ព្រះធម្មលិខិត ព្រះនាមស៊ីវ

ទី ៣ ព្រះតេជព្រះនុណទកញ៉ាសុធម្មមេធាចារ្យ នាម ខ្ម

ទី ៤ លោកគ្រូព្រះមហា កូវ

ទី ៥ ព្រះឆាចារ្យ ឆែវ

ទី ៦ ព្រះអាចារ្យ នន

ទី ៧ ព្រះតេជព្រះគុណទុតញ៉ាសុធម្មមេធាចារ្យ នាម អ៊ុំន

បេះដើមសម្តួរសំដែងធម៌ចាន ទំនប់ផ្លាត់បង្រៀនតេកែត ត្រូវខំខ្ពស់ក្នុង
ចិត្តចានខ្លះ ដោយកំឡាំងព្យាយាមប្រតិបត្តិតាមដោយសមត្ថភាពដល់ប្រាថ្ម
នៃខ្លួនដែលបេះដើម ។

จตุตฺถสกฺก: วย: ฉ ๒

ลោកគ្រូអាចារ្យប្រាក់-ហ៊ុន អាយុ ๓๑ ឆ្នាំវស្សា ๑๑ ចូលខ្សែនសមណសក្តិឧបាសនា ជាចូលរួមរាត់រោសជម្មកដ៏ថ្លៃ ។ ខែអាសាធ ឆ្នាំម្សាញ់ចត្វាស័ក ព. ស. ๒๖๓๙ គ្រិស្តសករាជ ๑๘๙๓ ដល់អាយុ ๓๖ ឆ្នាំ វស្សា ๑๔ ព. ស. ๒๖๓๘ គ្រិស្តសករាជ ๑๘๙๖ ចូលខ្សែនជាចូលរួមរាត់ធម្មចក្រ ចូលចំពេញកិច្ចការសាសនា តាមដំណើរមុខក្រសួងជាគ្រឹមគ្រែវស្ងុខចំរើនល្អ លុះដល់អាយុ ๓๖ ឆ្នាំ វស្សា ๑๖ សម្តេចព្រះមហាសង្ឃរាជា ព្រះនាមខៀង ក្នុងព្រះកោដ្ឋ ទ្រង់ព្រះតម្រិះយល់ឃើញថាព្រះចូលរួមរាត់ធម្មចក្រ (ហ៊ុន) មានសុវិជ្ជាវត្តចរិយាសម្បត្តិបរិបូរណ៌ដោយគុណធម៌ប្រព្រឹត្តល្អក្នុងធម្មវិន័យ គួរតម្លើងឡើងជាព្រះពាជាគណៈចូល ទើបទ្រង់ថ្វាយព្រះតាស៊ុំព្រះពាជានុញ្ញាតព្រះចូលសម្តេចព្រះនរោត្តមសុវណ្ណគោដ្ឋ ទ្រង់ប្រោសព្រះពាជានុញ្ញាតតាំងព្រះចូលរួមរាត់ធម្មចក្រ ជាព្រះសុធម្មត្ថេរពោធាគណៈសម្រាប់ត្រួកដ៏ថ្លៃ ។ ខែអាសាធ ឆ្នាំវក ព. ស. ๒๔๔๐ គ្រិស្តសករាជ ๑๘๙๙ ។

បញ្ចមสกฺก: วย: ฉ ๔

ក្នុងជន្មាយុ ๔๙ ឆ្នាំ វស្សា ๔๙ ក្នុងរដ្ឋដ៏ព្រះករុណាព្រះបរមរាជានុសោដ្ឋ សម្តេចព្រះមហាសង្ឃរាជាទ័ងព្រះបរមរាជានុសោដ្ឋ ទ្រង់ប្រោសព្រះពាជាតាំងព្រះសុធម្មត្ថេរ ហ៊ុន ជាចៅអធិការវត្តសាកម៉ែរាជា

ឃុំលេខ ๓ ក្រុងភ្នំពេញ ក្នុងថ្ងៃ ๖ ឆ្នាំកុរឯស័ក ព.ស. ๒๔๙๒ គិតសក្ករាជ ๑๙๑๐ ព្រះសុធម្មត្ថេរ ហ៊ុន បានទទួលនាទីជាចៅអធិការវត្តនេះថ្មីណាមុនពីយក ព្រះទ័យទុកដាក់កិច្ចការ:គារសាសនា ព្យាយាមរក្សាសង្ឃឲ្យបានសេចក្តីសុខ ចំរើន បានចំទុកបំរុងកិច្ចសាមណេរដែលនៅក្រោមទុកដោយកិច្ចសាកណីយធម៌ ๖ ប្រការ គឺ:

๑ - មានឈឺយកមកប្រគេនដោយមេត្តា

๒ - មានបើកមកប្រគេនដោយមេត្តា

๓ - មានមនោកម្មប្រកបដោយមេត្តា

๔ - រំលែងចែករលាកដែលបានមកដោយធម៌

๕ - មានសីលចរិយុទ្ធជាទីស្រឡាញ់

๖ - មានចិត្តយល់ត្រូវតាមផ្លូវព្រះពុទ្ធសាសនា

បានកសាងចាក់ជើមពេញទីតាមមនោរឲ្យពេញស្មើល្អ ធ្វើកំពែងវត្តព័ទ្ធជុំវិញដោយឥដ្ឋនឹងបេតុងការម៉ែ សាងបង្ហិនព្រះជាមាសជំបិតក្នុងទីព្រះវិហារពេង១ ចោសជាន់ សាងព្រះវិហារពេង១ ចោសបច្ចុប្បន្ន១ បើយកសាងព្រះពុទ្ធរូបធំព្រះកែន ๓ ម៉ែត្រ ទុកជាគោលចារឹកក្នុងព្រះវិហារវត្តសាកវែង សម្រាប់ជាទីធ្វើសក្ការៈគោរពបូជានៃពុទ្ធបរិស័ទ្យជាសាធារណៈទូទៅ សាងកុដិ ๑ ខ្នង សាងសាលាសម្រាប់ធ្វើជម្ងាន ๑ ខ្នង តាមិសាន ๒ ខ្នង កសាងព្រះស្តូបចេតិយក្នុងវត្តនេះ ๑ ក្នុងវត្តសាង.

សាមគ្គី ជំរុញព្រះពុទ្ធរូបចម្លុះធាតុមាតាបិតា ចាន់ថែទាំរក្សាស្អិតស្អាន ព្រះពោធិព្រឹក្សបើដើមកន្លងទីវត្តនេះ ចាន់កសាងគម្ពីរព្រះត្រៃបិដកស្ទឹតរឹតចំនួន ៦៤ គម្ពីរ សាងព្រះពុទ្ធរូបសិតដោយលោហធាតុ ៤ ព្រះអង្គ ទំហំកែន ៧ តឹកស្មើអង្គ ។

ជដ្ឋមឧសភៈ ឆ្នាំ ឆ ៦

ព្រះសុធម្មត្ថេរ ចាន់សិក្សាចំពេញព្រះវិជ្ជាធ្លុះអំពីសំណាក់ព្រះធម្មាចារ្យចាំង ៩ ព្រះអង្គ គឺ៖

១- ព្រះគេជ ព្រះគុណ ព្រះមគ្គញ្ញាណាទ ចជ្ជាយាចារ្យ

២- ព្រះគេជ ព្រះគុណ ឧកញ៉ាអាពាធិបតី នាម ជ្រាក់

៣- លោកគ្រូអាស់ត្រៃ ពក ណ្ហឿង នាម ម៉ុំ

៤- លោកគ្រូអាស់ក្តីកណ្តាល នាម ព្រំ

៥- ព្រះអាចារ្យ ចាំន់

៦- ព្រះអាចារ្យ ខាស

៧- ឧកញ៉ាពជលម្បត្តិ នាម ផ្លុំត

៨- ព្រះគុណ ខ្ចាស់ថ្នៃវ

៩- ព្រះធម្មាចារ្យ នាម ជុក ខេត្តចាត់ដំបង

สัตตมฉสกกะ: วยะ: ฉ ๗

ដល់ជន្មាយុ ๖๙ ឆ្នាំ វស្សា ๖๘ ថ្ងៃ ។ ឆ្នាំជូតបញ្ចស័ក ព.ស. ๒๔๗๖ គ្រិស្តសករាជ ๑๙๓๐ ក្នុងរជ្ជដ៏ព្រះបរមខត្តិយកោដ្ឋបាន ឡើងជាព្រះពុទ្ធោយោសាទាឫ ជាគណៈសម្រាប់ពោ ឫានប្រជុំពុទ្ធ-បរិសទ្យធ្វើបុណ្យបញ្ចុះខណ្ឌសីមាវត្តសាកម៉ែតដោយ ។ ល្អាវិក ក្នុង គ្រិស្តសករាជ ๑๙๓๒ ។

អដ្ឋមឆសកកៈ: វយៈ ឆ ๘

ក្នុងជន្មាយុ ๗๑ ឆ្នាំ វស្សា ๗๑ ថ្ងៃ ។ ឆ្នាំថោះអដ្ឋស័ក ព.ស. ๒๔๗๘ គ្រិស្តសករាជ ๑๙๓๓ ព្រះករុណាបរមខត្តិយកោដ្ឋ ទ្រង់ ជ្រោសព្រះពជ្ជនតាំងជាព្រះពោធិវង្ស ជាគណៈសម្រាប់ឯកទ្វេទ្វង់ តែន៍ ទីឆ្ងាជាអធិបតីព្រះពជ្ជពិធីតាណយក្ស លុះដល់ជន្មាយុ ๗๕ ឆ្នាំ វស្សា ๗๕ ឫានឡើងស្តេចជាសង្ឃនាយកគណមហានិកាយ ព្រះពជ្ជ-ក្រិត្យលេខ ๖ ចុះថ្ងៃ ๑ ខែហ្វ្រីយេរ ឆ្នាំ ๑๙๓๙ ។ លុះដល់ជន្មាយុ ๗๗ ឆ្នាំ វស្សា ๗๗ ឡើងតេញតាជាព្រះសង្ឃនាយក ព្រះពជក្រិត្យ លេខ ๖๖ ចុះថ្ងៃ ๑๗ ដេសេមប្រ៊ ឆ្នាំ ๑๙๔๐ ព្រះជន្មាយុ ๗๘ ឆ្នាំ វស្សា ๗๘ ឫានទទួលគ្រឿងមហិស្សរិយយស តាជាវៃសេនាក្រុងតម្ពូជា ព្រះពជក្រិត្យលេខ ๒๐ ចុះថ្ងៃ ๒๘ ខែកក្កដ ឆ្នាំ ๑๙๔๑ ព្រះជន្មាយុ ๗๙ ឆ្នាំ វស្សា ๗๙ ឫានទទួលគ្រឿងមហិស្សរិយយសជាខ្នុំស្តេចជាតិ

ឥសរ៉ៃខ្ញុំក្រែងជាកំនើសែស តាមប្រែគាសដេះក្រែត ចុះថ្ងៃ ១៦ ម៉ាឃ ឆ្នាំ ១៨៦២ ព្រះសង្ឃនាយកគណមហានិកាយ ជានធ្វើកឋិនទាននឹងឆាកចង្ក្រុលចំនួន ១៥ វត្ត ដើម្បីទុំសាជលជូនដល់លោកអ្នកដ៏មានគុណមានមាគាមិគាជាដើម ជានចំពេញកិច្ចការសាសនាក្នុងមុខក្រសួងដោយផ្លូវសុចរិតយុត្តិធម៌ក្រែកចះដោយសេចក្តីសុខសាមគ្គីចំរើនល្អ មានគុណចំណាប់ក្នុងក្រែងកម្ពុជាធិបតី លោកអធិបតីនៃពាក្យប្រែតំណូរក៏ជានសុំត្រឿងមហិស្សរិយយសតួមខ្លួនសំពីមហានគរណាពាក្យចាលប្រែនេនទុកជាសំគាល់គុណចំណាប់ស្រាប់ ។

ឆ្នាំមធ្យសក: ទយ: ដី ៩

ព្រះជន្មាយុ ៩០ វស្សា ៦០ ជានឡើងសមណសក្តិជាន់ខ្ពស់ ជាទីសម្តេចព្រះពោធិវង្សសង្ឃនាយកគណមហានិកាយ នៅថ្ងៃសុក្រ ៣ កើតខែពិសាខ ឆ្នាំមមីចត្វាស័ក ព. ស. ២៤០៥ ត្រូវនឹងថ្ងៃ ១៧ ខែអាវ្រិល ឆ្នាំ ១៨៦២ ។

កន្ទឹជន្មាយុ ៨១ វស្សា ៦១ ជានឡើងសមណសក្តិជាន់ខ្ពស់បំផុតជាទីសម្តេចព្រះមហាសុមេធាធិបតីសង្ឃនាយកគណមហានិកាយ នៅថ្ងៃសុក្រ ១ កេចខែមេសាឆ្នាំមមែចញ្ចាស័ក ព. ស. ២៤៨៦ ត្រូវនឹងថ្ងៃ ១៥ ខែឧសភាច្រើ ឆ្នាំ ១៨៤៣ ។

ក្នុងឆ្នាំឃុំ ៨៩ សែស្ស ៦៩ សម្តេចបានទទួលត្រឿងមហាស្បៃយ-
ោសនភ្លុមជាន់ខ្ពស់ ជាទំនាក់ក្រុងធ្លាក់ពីសេស តាមដីកាលេខ
៤៣០-៤៤៨ ចុះថ្ងៃ ១៦ ខែឃ្លាំងវិយោ ឆ្នាំ ១៩៤៨ ពីក្រុងបារីស ។

អំពីស្នាព្រះហស្តជាក្បៀដំណែលរបស់សម្តេចពៅចំផុត

១- សម្តេចបានតសាងព្រះផ្នួងថ្មីនាដ៏ដ្ឋលដែលជាកន្ទែងទោស-
ជាតារដ្ឋានចាស់ ទុកជាគោលចាក់ឫសគល់ពីនេះតទៅ បម្រុងនឹង
ប្រតិស្ឋានព្រះសារីរិកធាតុ, ព្រះពុទ្ធបដិមា, ព្រះត្រៃបិដក, គម្ពីរក្បួន
ច្បាប់ពុទ្ធសាសនា, អក្សរណ្ណ ផ្សេងៗ, សម្រាប់សិក្សាគន្ថធុរៈនឹង
វិបស្សនាធុរៈ ។

២- សម្តេចបានបុះព្រះនាមតនុញ្ញាតឲ្យព្រះគ្រូពោធិវង្សបវរយោគ្រូព្ន
ពជ . កឹង ជាអ្នកជំណួសការតសង្ឃ ចាត់ការសាងសាលាចាលរង
នឹងបត្តុទ្ទេសទៅដូចមានរៀបរាប់ក្នុងលិខិតព្រមពីសម្តេចលេខ ៤០៧-៤០៩
ចុះថ្ងៃ ២១-២៣ ខែឃ្លាំង នឹងលេខ ៤២៨ ចុះថ្ងៃ ២ ស៊ូរយេត ឆ្នាំ
១៩៤៧ ស្រាប់ ។

អំពីបណ្តាំសម្តេច

១- បានដល់គោលសក្តណោះពីរបស់សម្តេចនាង ១៧ ដែលម
ពជារោះតុម្ពផ្សាយរុះហើយក្នុងភូមិជសុរិយា ឆ្នាំ ខី ១៧ លេខ ១
ខែឃ្លាំងវិយោ ឆ្នាំ ១៩៤៩ ជាផ្លូវការស្រាប់ ។

๒ - មគ្គបួនដល់ចួនត្រៃប់ ទំនុកសាធសត្វតែងខ្លួនឯង ជាធម៌ខុន
ឲ្យតាន រៀនឲ្យចាន់ស្ទាត់ជាលោត ។ ចៀសចាកអកុសល ក្តីអំពល់
ពីទុក្ខសោក រួចពន់តែងស្មោកគ្រោក តួរឲ្យរកព្រះអរហំ ។ តួអ-អំ
ជាគ្រួយ ចណ្តូលមួយមានសច្ចំ ទន្ទឹដើមធម្ម៌ កតញ្ញូតំជាតល់តាប់ ។

๓ - ព្រះនាមថញ្ចកន្ធ លក្ខណញ្ញាណតាន់ឲ្យខ្ជាប់ តួរិះតួរ
រៀនត្រាប់ តែងំណាតាប់តាន់ក្បាំ ។ ឫគ្គលឫគ្គលា មានចរញ្ញោ
ឫញ្ញាឫឫស់ តួរទំរកទំកស្រែះ ងឹតជម្រះសោកអសោច ។ រួចពន់យើងឹ
សត្វថ្លៃ តិតតាល័យទុបតែខ្ចោច អសុកសោកអសោច ឥតញ្ញោច
ញាញើតឡើយ ។ តួរិះរកវាំង រកព្រះអរហំរៀនឲ្យហើយ កុំស្ងៀម
ស្ងាត់តន្តើយ រៀនឲ្យហើយព្រះអរហំ ។ តាលណានឹងំលាង តល់រួច
ពន់ដោយវាលកំង ៗ ហើយជាន់ព្រះអរហំ តាំងតំជាំងរួបកយា ។
ឥតណាជាន់ធម៌ព្រះ ជឿជាតំឫឫស់តាន់ក្បាំ ស្មើជាន់យានតែគ្រា
តាំមាតាបិតាជាន ។ តេជះតែវមុនិ ព្រះជិនស្រែទង់ក្រែ ឫជាណ
តាំសត្វចួលនិព្វាន សត្វខ្លះមានឯក្រៃយក្រៃស់ ។ ព្រោះចោកុ
មោហៈធំ មកសួចុំពុំស្រែឡះ ឥតណាចង់ឲ្យជ្រះ តួរទំស្តាប់ព្រះធម៌ថ្លៃ ។
កុំទំលេចទំពា សេពាសុរាថ្នាំពិសពុល ដូចតែកម្ចាត់ពុំយល់ ដើរ
ជ្រែជ្រួលថ្នាក់រណ្តៅ ។ តាំលាតាលេខ្ចាំង ជាន់ធម៌ហើយចោលទៅ
ឥតឫជាថ្ងៃក្រៃជាខ្លៅ ព្រោះកម្លៅពុំឲ្យឫណ្យ ។

๘— សច្ចំពាក្យពិត រួចរស់ជាតិ ជាសុខក្សេមក្សាន្ត ជាច្រើន ជាតិប តិចរៃនជាគ្នាន ពុំដែលហួសហ៊ាន ពោលពាក្យមុសា ។ សច្ចំពាក្យត្រង់ សូវស្មោះមិនចង់ រៀបរៃស្រដៀ ទ្រេចន់សត្យា ឲ្យជាគប្រយ សច្ចំក្លៀកក្រែ ក្រអួតតែចំបាន ។ សច្ចំខ្ពស់ សីលខេះ ជាចំ លើសសីលនានា ពីរយេងម្តែច្បាំ- ពីសើលសីលា សច្ចំជាបាមេសីលចាំងឡាយ ។ សច្ចំប្រាជ្ញ រកអស់បុណ្យគ្នាន ប្រៀបផ្ទឹមពុំបាន ឯសីលសច្ចំ ជាក្រែកខ្ញុង បិទបាំងបាបផង ប្រសើរខ្ពស់ ។

៩— ទន្តីប្រាជ្ញ ប្រសើរលើសជាន ជាក្រែកខ្ញុង ជាមេអស់ផល អស់កុសលផង កម្រចិត្តចង បានសីលទន្តី ។

๑๐— អត្ថញ្ញូ នូវអ្នកណា ដឹងគុណតេជ្ញ ឃ្លាតនឹកមិនជាប់ ភ្ញាក់ក្តេចស្មារតើ បែបបទបាលី ធម្មមួលា ។ ជាដើមគល់ឫស ព្រះធម៌ទាំងអស់ កល់ចត្តុក- សិតិសហាស្ស- ធម្មក្ខន្ធា នវលោកុត្តរ ប្រាំបីម៉ឺនបួនពាន់ ។ នវលោកុត្តរ ប្រជានបវរ ព្រះធម្មក្ខន្ធ កើតពីដឹងគុណ តួរនេនឹតតាន់ ប្រជានប្បញ្ញា នវិជ្ជតិ ។ រកអស់បុណ្យគ្នាន ឧត្តមអ្នកមាន កតញ្ញូតា ដឹងគុណ-តបផ្ទែស លន់លើសនានា ប្រជានប្បញ្ញា ប្រជានប្បុណ្យផង ។ កតញ្ញូតា នេះជាខ្ញុងធម៌បីតខ្ញុង ផ្លូវព្រះនិព្វាន ។

๒ - មគ្គបួនផលបួនត្រៃប៉ិដក ទំនុសាសនសព្វកែនខ្លួនខ្លាន ជាធម៌ខុនឲ្យតាន រៀនឲ្យបានស្ទាត់ចប់សោត ។ ចៀសចាកអកុសល ក្តីអំពល់ពីទុក្ខសោក រួចពន់តែងស្មោកគ្រោក តួរឲ្យរកព្រះអរហំ ។ តួអ-អំជាត្រួយ ចាស្លាលមួយមានសច្ចំ ទន្ទឹងដើមធម៌ កតញ្ញូតំជាតល់តាប់ ។

๓ - ព្រះខាមបញ្ចកន្ធ លក្ខណញ្ញាណគាន់ឱ្យខ្ជាប់ តួរិះតួរវៀនត្រាប់ តែងំណាតាប់គាន់ក្បាំ ។ បុគ្គលបុគ្គលា មានបញ្ញោបញ្ញាចប្លាស់ តួរចំរកចំកែស្រះ ងំតែជម្រះសោកអសោច ។ រួចពន់យើនសព្វថ្ងៃ តិតតាល័យនុបតែខ្លោច អសុកសោកអសោច ឥតញ្ញោបញ្ញាញើតឡើយ ។ តួរិះរកអំង រកព្រះអរហំរៀនឲ្យហើយ កុំស្ងៀមស្ងាត់តន្តើយ រៀនឲ្យហើយព្រះអរហំ ។ កាលណាខំរំលាង ពស់រួបកន់ដោយកាលកំង ទៅហើយបានព្រះអរហំ តាំងតាំងរួបកយា ។ អ្នកណាបានដល់ព្រះ ជឿជាក់ប្លាស់គាន់ក្បាំ ស្មើបានយានតែគ្រាន់តាមតាំកាបាន ។ តេជះតែវាមុន ព្រះដំនូលែងខ្លះក្រែបាសក្រាណ តាំសក្តូបួលនិព្វាន សក្តូខ្លះមានឯក្រៃយក្រៃស់ ។ ព្រោះចោកុមោហាធំ មកបួងពុំពុំស្រែឡះ អ្នកណាបង់ឲ្យដែះ តួរខំស្តាប់ព្រះធម៌ថ្លៃ ។ កុំខំលេងតំពា សេពាសុភាថ្នាំពិសពុល ដូចតែគេភ្លាត់ពុំយល់ ដើរដួលភ្លាត់រេណ្តៅ ។ តាលោតាលេងំង ចាន់ធម្មំហើយចោលទៅអ្នកច្រើបាជ្រៃជាខ្មៅ ព្រោះតម្លៅពុំជឿបុណ្យ ។

๘— សច្ចំពាក្យពិត ប្រៀបដូចជាសុទ្ធក្សេមក្សាន្ត ជាច្រើនជាតិប តិចរៃអង្គាន ពុំដែលហួសហ៊ានពោលពាក្យមុសា ។ សច្ចំពាក្យត្រង់ សូរស្មោះមិនបង់ រៀបរៃសេដ្ឋ ឲ្យបង់សត្យា ឲ្យជាគម្រប់ សច្ចំក្រៃក្រែក ក្រែអ្នកតែងបាន ។ សច្ចំខ្ពស់ សីលនេះជាធំ លើសសីលនានា ព័រយេងម្តែច្បាំ- ពីសើៈសីលា សច្ចំជាជាមេសីលចាំងឡាយ ។ សច្ចំប្រជាន ក្រែអស់បុណ្យគ្មាន ប្រៀបផ្ទឹមពុំបាន ឯសីលសច្ចំ ជាក្រែកទ្វន បំពេញបានជាបវរ ប្រសើរខ្ពស់ ។

๙— ទន្តីប្រជាន ប្រសើរលើសជាន ជាក្រែកទ្វន ជាមេអស់ផល អស់កុសលផង កម្ចាត់ចង ជាន់សីលទន្តី ។

๑๐— កតញ្ញូតា ខ្លួនអ្នកណា ដឹងគុណគេខ្លី ឃ្លាតនឹកមិនជាប់ភ្លាំងក្លេចស្មារតី ប្រៀបបាទបុគ្គលិ ធម្មមួលា ។ ជាដើមគល់ឫសព្រះធម៌ទាំងអស់ កន្លងតូច- សិតិសហាស្រ- ធម្មក្នុងខ្លួន ខាងលោកុត្តរ ប្រាំបីម៉ឺនបួនពាន់ ។ ខាងលោកុត្តរ ប្រជានបាវ ព្រះធម្មក្នុង កើតពីដឹងគុណ តួរគេនឹងតែងាន់ ប្រជានបុញ្ញ ខាងផ្តៃ ។ ក្រែអស់បុណ្យគ្មាន ឯមែអ្នកមាន កតញ្ញូតា ដឹងគុណ-តបផ្ទួស លន់លើសនានា ប្រជានបុញ្ញា ប្រជានបុណ្យផង ។ កតញ្ញូតា នេះជាខ្នងធម៌បីតន្ទង ផ្លូវព្រះនិព្វាន ។

๓ — សុភា សង្ឃស្ស សាមគ្គី ការព្រមព្រៀងគ្នា នៃគណៈសង្ឃ ជាហេតុនាំមក នូវសេចក្តីសុខ ។

អំពីអាយុហេបរំយោសាធកាល

សម្តេចចាប់ប្រឈួនធ្ងន់តាំងតែថ្ងៃ ១ ។ ១១ ខ្នាំកុនពូស័ក ព.ស. ๒๔๙๑ ត្រូវនឹងថ្ងៃ ៩ វិច្ឆិកា ឆ្នាំ ๑๙๔๗ ។

๑ - ការបរិបូណ៌ដោយសទ្ធា គឺជំនឿចំពោះតែវត្ថុដែលគួរជឿ មានជឿថា ធ្វើអាក្រក់បានអាក្រក់ ធ្វើល្អបានល្អ ទើបការជឿគុណព្រះតថាគតឬជាដើម, យ៉ាងនេះហៅថាសទ្ធាសម្បទា ។

๒ - ការបរិបូណ៌ដោយការរក្សាកាយ វាចា ចិត្តឲ្យបរិសុទ្ធ មិនឃើញសប្បុរស មិនចៀសចៀនសត្វដទៃ មិនឆក់ជណ្តើមយកទ្រព្យសម្បត្តិអ្នកដទៃ ដែលគេមិនបានឲ្យដោយកាយ វាចា ចិត្ត មិនលួចកូនប្រពន្ធគេ មិនទិយាយពាក្យកុហកបោកប្រាស់យកទ្រព្យគេ មិនត្រេកអរនូវទឹកស្រែឯ គំនាចរៀបឫកពាក្យ ស្តួចឲ្យអ្នកដទៃស្រឡាញ់ចូលចិត្ត បង់គោរពបូជា យ៉ាងនេះ ហៅថា សីលសម្បទា ។

๓ - ការបរិបូណ៌ដោយការគោរពនិតនាសួរចំពោះអ្នកចំសក់ខុតិត ហើយលះបង់ទ្រព្យសម្បត្តិចែកចាយឲ្យគាត់ទានតាមបាន ដើរសម្រេចនឹងការបូជាគុណមានមាតាបិតាជាដើម យ៉ាងនេះ ហៅថា ចាគសម្បទា ។

๔ - ការចម្រើនបួណ៌ដោយការសិក្សារៀនសូត្រ ឬស្តាប់ពាក្យប្រៀនប្រដៅ ដើម្បីឲ្យកើតប្រាជ្ញាចេះពិចារណាស្គាល់គុណទោស ស្គាល់ខុសត្រូវ ស្គាល់ល្អអាក្រក់ ស្គាល់ហេតុផល ស្គាល់សេចក្តីវិនាសទំនឹងចំរើនឬពិចារណាសង្ឃឹងឲ្យឃើញថា ធម្មជាតគ្រប់យ៉ាង ជារបស់មិនទៀងជាដើម, យ៉ាងនេះ ហៅថា បញ្ញាសម្បទា ។

សម្បទា ៤ យ៉ាងនេះ ហៅថា សម្បុកយ៉ាកប្រយោជន៍ជាប្រយោជន៍ដែលយើងត្រូវសន្សំខុសទៅថាលោក ឬក៏ទៅអនាគត ។

ប្រយោជន៍ទាំងពីរប្រការដូចក្នុងពោលមកនេះ បើជនណាបានធ្វើបានសន្សំហើយ ជនោះឈ្មោះថាបានតាំងខ្លួនបានដោយប្រពៃរមែងរីលទៅតាន់សេចក្តីសុខ-ចំរើនតាមប្រាថ្នា ពាក់ថាជាមង្គលមួយយ៉ាងប្រសើរ ហៅថាបុព្វជម្មិ ។

ទី ៤ - បុព្វេកតបុញ្ញតា ភាពជាអ្នកបានធ្វើសេចក្តីល្អខុនមុនពីកន្លងកាលមុន ។ សេចក្តីថា ជនជាតិនីមួយៗ ដែលមានភោគសម្បត្តិ យសសក្តិ រូបពន្លឹងសណ្ឋានខ្ពង់ខ្ពាយល្អ ឬថ្កុំថ្កើងយ៉ាងណា ក៏សុទ្ធតែមកអំពីកិច្ចសំណាងវាស្នា បានមកបំរើសន្សំខុនមកពីកន្លងកាលមុន ដើម្បីយើងធ្វើយ៉ាងណា ប្រព្រឹត្តយ៉ាងណា សិក្សាយ៉ាងណា ទោះបីតិចក្រែនក្តី ដល់ទំនឹងត្រឡប់ឲ្យផលវិញ ក៏រមែងពាញចង្អិលឲ្យតាមគំរូដើមមិនខុសហេតុខុសផលឡើយ ។ សូមតាញុតាហារណ៍ឲ្យឃើញហេតុ

ដល់តែងថ្ងៃបច្ចុប្បន្ននេះថា ព្រះពុទ្ធជាម្ចាស់ក្តី ព្រះឯកគ្គពុទ្ធក្តី អគ្គសាវ័កក្តី ឬក៏ព្រះអរហន្តអង្គឯទៀតៗក្តី ដែលទំនឹងបានត្រាស់ជាព្រះពុទ្ធ ជាព្រះអរហន្ត លះកាត់តំលេសចូលទៅកាន់ព្រះនិព្វាន ហើយមានឈ្មោះថាជាអ្នកឆ្លងផុតយ៉ាងឯកក្នុងលោកនោះ ក៏គង់ស្ថិតមានអំពីបុណ្យកុសលដែលបានតសាងសន្សំទុកមកពីមុន ។ បើពុំនោះ ដូចយ៉ាងឥស្សរជនមានព្រះពរជា ទំនឹងពួកអស់លោកឧកញ៉ាទេសាភិបាលមន្ត្រីធំតូចត្រូវដាំណែនដែលទំនឹងបានទៀនទៅកាន់តំណែងជាច្រើនសន្ធឹក តណ្ហាលុភៈបានយ៉ាងនេះ ក៏គង់ស្ថិតមានអំពីបានសិក្សារៀនសូត្រពីខាងដើម តាមដាន់តាមថ្នាក់ ទើបអាចទំនឹងទៀនទៅកាន់តំណែងនោះៗបាន, មិនមែនបេះតែទៅកាន់ថ្នាក់នោះឯងៗបានឡើយ ។ អ្នកមានសម្បត្តិ អ្នកខ្សត់ខ្សោយសម្បត្តិក៏ដូចគ្នា, លុះតែទំប្រឹងតែប្រឹងធ្វើខុសពីខាងដើម, ទើបសម្រេចផលប្រយោជន៍ទៅបាន ។ ដូចជាតំបូលផ្ទះគ្នាក្នុងបច្ចុប្បន្ននេះ គេជួយធ្វើយើង យើងត្រូវជួយធ្វើគេវិញ, គេឲ្យយើង យើងក៏ត្រូវឲ្យគេវិញ ។ សមដូចព្រះគាថាមួយឥន្ទ្រងថា ចូរជាគោលករគេ ចូរដំ វត្តុរគោ ចរដំខ្ចីនំ ឬតលមកចូរជាគេ រមែងបានការចូរជាមកវិញ អ្នកតំនាក់តាក់ត្បូរគេ រមែងបានត្បូរគាតំនាក់តាក់ត្បូរមកវិញ ។

សេចក្តីដែលបានសំដែងមកប៉ុណ្ណេះនេះ ដើម្បីទ័ងចាញ់ឲ្យឃើញថា សេចក្តីល្អដែលយើងបានធ្វើទុកមកពីកន្លងកាលមុនយ៉ាងណា ដល់មកខាងក្រោយ ក៏មែងឲ្យផលយ៉ាងនោះដែរ ។ ព្រោះហេតុនោះបានជាព្រះពុទ្ធជាម្ចាស់ទ្រង់សំដែងថា ភាពជាអ្នកធ្វើសេចក្តីល្អទុកមកពីកន្លងកាលមុននោះ ចាត់ថាជាចក្កមួយ រមែងវិលទៅកាន់សេចក្តីសុខ-ចំរើនក្នុងលោក ពេលថាជាចក្កធម៌ ៤ ។

ហេតុនេះ សូមអស់លោក-អ្នកចាំងឡាយពួតដៃគ្នាជាកំឡាំងតាំងសេចក្តីព្យាយាមឲ្យរឹងប៉ឹងប្រឹងប្រែតបត្តិតាមចក្កធម៌ទាំង ៤ យ៉ាងនេះ ទើបចក្កធម៌អាចវិលទៅកាន់សេចក្តីចំរើនឲ្យមានពេលទាន់សម័យ តើថាញ៉ាំងព្រះពុទ្ធសាសនាទំនឹងប្រទេសជាតិ មានតួមិនបានសំយើងឲ្យលឿនទៅមុខ កុំបណ្តោយតាមព្រងើយសំណាងស្រុកទេសនោះឡើយ, ចេះយើងមិនប្រឹងទេ ព្រះពុទ្ធសាសនាទំនឹងប្រទេសជាតិក៏ទំនឹងសាបសូន្យទៅពុំខាន ។

សំដែងអំពីចក្កធម៌ ៤ យ៉ាង ចប់នៃប៉ុណ្ណេះ ។

ទីបំផុតធម្មទេសនានេះ សូមផ្សាយកុសលបុញ្ញាភិសជ្ឈអស់លោក-អ្នកចាំងឡាយទៅកន្លងមកពុំបានដឹងមួល ឲ្យបានសេចក្តីសុខ-ចំរើនគ្រប់ប្រការ ។

ตุฏฺฐาธิ អាឧកាវេន ឧបដ្ឋា ចេ ឧបដ្ឋិ

ភោគា ចេវន្តរាយា ច វិនស្សន្តុ អសេសតោ

ដោយអានុភាពនៃព្រះរតនត្រ័យមានពុទ្ធរតនជាដើម បើទុក្ខ
ទិដ្ឋភោគ ទិដ្ឋអន្តរាយចាំងឮយ កើតមានហើយក៏សូមឲ្យវិនាសឈ្មុតរៅ
កុំបីនៅមានសេសសល់ឡើយ (ដោយធម្មទេសនានេះ) ។

ចប់ ចក្កធម៌

គ្រួសជំនុំជំរៅបុរាណម្លាប់
COMMISSION DES MŒURS & COUTUMES

កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា ទំនៀមអក្សរសាស្ត្រ ព្រះពុទ្ធដ្ឋិ្ឋ ឯ
អំពីពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកអក្សរសាស្ត្រ: ហ្លួងធំពន្ធមន្ត្រី ញ៉ុក - ថែម, បណ្ឌិត នៅ
ពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកដំណឹងសាសនា: ព្រះទេពសង្ឃ សួរ : ហ្ស.ឈ
ក្រុមដំនុំព្រះវៃតែបឹងក នៅពុទ្ធសាសនបណ្ឌិត្យ

ផ្នែកអក្សរសាស្ត្រ	មាតិកា	ទំព័រ
ក្រុមដំនុំទំនៀមទម្លាប់ខ្មែរ	សេចក្តីដួនដំណឹង អំពីការផ្សាយភ្ជាប់ដំណឹងអ្នក ប្រឡងជាប់	៤០១
— ក —	សេចក្តីដួនដំណឹងអំពីការប្រឡងទំនៀមទម្លាប់ខ្មែរ	៤០៣
លោក ជាប់ - សាក់	រឿងទាក់ទិនវៃព្រ (ភ្ជាប់លេខ ១)	៤០៩
លោក ភ័យ-ប៊ុក សមុហបណ្ឌិត	សុភាសិតជាភ្លេងសែស (ត.មក)	៤១៣
ហ្លួងធំពន្ធមន្ត្រី ញ៉ុក - ថែម	ប្រវត្តិសាស្ត្រសង្ខេបប្រទេសចិន (ត.មក).....	៤១៥
ឃុនសុន្ទរមេធី ញ៉ង - សើរ៉ង	ឯកសហស្រីភាគទី ១៩ (ត.មក)	៤២៧
អ្នកឧកញ៉ាវិបុលរាជសេនា ខ្ញុ-ពន	រឿងសាមកុក (ត.មច្ច)	៤៤០
ផ្នែកសាសនា		
លោកគ្រូព្រះសង្ឃរាជវិភទ្ធញ្ញាណ សោម - ឃួន ក្រុមដំនុំព្រះវៃតែបឹងក	មធុរភាសិត (ត.មក)	៤៤៧
លោកគ្រូព្រះទេពមុនី ឃួ-ប៊ុណ្ណា ក្រុមដំនុំព្រះវៃតែបឹងក	បរិយាយ សាមគ្គី	៤៤៤
ហ្លួងធំពន្ធមន្ត្រី ញ៉ុក - ថែម	ពន្ធអាស៊ីទ្វីប	៤៦៨
លោកអគ្គបណ្ឌិត ខ្ញុ-ណាត	ការប្រកាសបោះពាំងរៀបចំការសាសនា.....	៤៧៣

KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique.

Rédacteur en chef de la partie littéraire : Luong Nibandhamantri Nhok-Thèm, Pandit à l'Institut Bouddhique.

Rédacteur en chef de la partie religieuse : Vénérable Brah Déb satthā So-Hay membre de la Commission du Tripitaka

TABLE DES MATIÈRES

Partie littéraire :

		page
Commission des Mœurs et coutumes	Proclamation des résultats du concours littéraire organisé par la commission	401
—id—	Organisation du nouveau concours	403
Monsieur Thach Sak Monsieur Ray - Buc	La capture du Sanglier (1er prix)	409
Chef Comptable (I. B.) Luong Nibandhamantri Nhok-Thèm (I. B.)	Proverbes français (suite)	413
Khun Sundaramedhi Nhoung - Sœung (I. B.)	Histoire de Chine (suite)	419
Neak Okna Vipularājasenā Nou-Kan Député	"Mille et une nuits" facs 15 (suite)	427
	Histoire de Sam kok (suite)	440

Partie religieuse :

Vén. Som - Loch ancien membre de la commission du Tripitaka	Madhuraphāsit (suite)	447
Vén. You-Ponn membre de la commission du Tripitaka	Bāriyay Sāmaggi	454
Luong Nibandhamantri Nhok-Thèm (I. B.)	Lumière de l'Asie (vie du Bouddha)	468
Monsieur Ream-Chhoon Yokbat (Ministère des cultes)	Nomination de Chau Adhikar	473

សេចក្តីជូនដំណឹងអំពីការឲ្យផ្អាន់
ដល់អ្នកប្រឡងចំណៀមធម្មាប់ខ្មែរ
ដែលចានជាប់លេខ

កាលពីថ្ងៃ ២៩ ខែសេបតុមប្រ ឆ្នាំ ១៩៤៧ ដល់ថ្ងៃ ៣១ ខែមីនា ឆ្នាំ ១៩៤៨ រវាង ៦ ខែ ក្រុមជំនុំចំណៀមធម្មាប់ស្រុកខ្មែរ នៅក្រសួងពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ បានប្រកាសការប្រឡងចំណៀមធម្មាប់ ២ រឿងគឺ

១ — រឿងព្រៃនចាក់ទន្លេដោយការក្បួតស្រូវ

២ — រឿងព្រៃនចាក់ទន្លេដោយការចាញ់-ជាក់សត្វ

ក្នុងរវាង ៦ ខែនេះ មានបេក្ខជន បានតែងរឿងផ្ញើទៅប្រឡងជាច្រើនៗ ក្រុមជំនុំបានជួបជុំគ្នាពិនិត្យរឿងទាំងនោះ បានឲ្យរឿង ៦ ជាប់លេខ ទើបបានជូនផ្អាន់ដល់បេក្ខជន ៦ នាក់ ដូចតទៅនាមរឿងនិងនាមបេក្ខជនតទៅនេះ:

ផ្អាន់ការចាញ់ និងការជាក់សត្វ:

១ — រឿងជាក់ជ្រូកព្រៃ របស់លោក ជាប់-សាក់ អ្នកបង្ហាត់សិស្សនៅសាលារៀនគេអាតន្លុំ ផ្ទះលេខ ៤៦ ផ្លូវប៉ូលបែរ ភ្នំពេញ ជាប់លេខ ១ បានផ្អាន់ ៩០ រៀល ។

២ — រឿងហ្វូងចាក របស់លោក មាស-ហាំ-ចាឡាក់ស្រុកស្រែតក់ពង់ស្វាយ កំពង់ធំ ជាប់លេខ ២ បានផ្អាន់ ៣០ រៀល ។

៧ — រឿងការសំអុតបាញ់លេងកម្សាន្ត របស់លោក កិក្ខុ ឈឹម - សារ៉ាត ឆ្នាំវត្ត ខណ្ឌ ចោម ក្នុងភូមិ ជាប់លេខ ៣ ចាប់ផ្តើមឆ្នាំ ១៩ រៀល ។

៨ — រឿងការចាក់ជ័រ របស់លោក ឌុ . ម៉ិត ធ្វើការនៅស្ថានីយ៍ រថភ្លើង ស្ថានីយ៍ខេត្តឆ្នាំថ្មី ខែត្រពោធិ៍សាត់ ជាប់លេខ ៣ ចាប់ផ្តើមឆ្នាំ ១៩ រៀល ។

ក្រុមឆ្នាំនការប្តឹងស្រែ

៣ — រឿងរបៀបធ្វើស្រែ របស់លោក កិក្ខុ រ័ត្ន - ជុតិ ឆ្នាំវត្ត ខណ្ឌ ចោម ក្នុងភូមិ ជាប់លេខ ៣ ចាប់ផ្តើមឆ្នាំ ១៩ រៀល ។

៣ — រឿងការប្តឹងស្រែ របស់លោក សោម - សុខ ហៅ ចាន់ - សុខ ស្នងឃុំ នៅឃុំកំពង់ត្រាច ស្រុកគោសហែក ខែត្រ ស្វាយរៀង ជាប់លេខ ៣ ចាប់ផ្តើមឆ្នាំ ១៩ រៀល ។

អ្នកតែងរឿងការចាញ់ឥឆ្នាំការចាក់សត្វ ចាប់ជាប់លេខ ៤ នាក់ គឺ ជាប់លេខ ១ មួយនាក់ លេខ ៦ មួយនាក់ រួលេខ ៣ ពីរនាក់ ។ អ្នក តែងរឿងការប្តឹងស្រែ ចាប់ជាប់លេខតែ ២ នាក់ ហើយសុទ្ធតែលេខ ៣ ទាំងអស់ ដោយហេតុអ្នកតែងរឿងការប្តឹងស្រែ តែងខ្លះច្រែនអន្ទឹ មិនសព្វគ្រប់តាមនោលដែលសួរ ។

ក្រុមដំនុំចំនៀមចម្ការស្រុកខ្មែរ

នៅក្រសួងពុទ្ធសាសនបណ្ឌិត្យ ក្រុងភ្នំពេញ

សេចក្តីផ្តួចដំណាំង

អំពីការប្រឡងទំនៀមទម្លាប់ខ្មែរ

នៅមន្ទីរពុទ្ធសាសនបណ្ឌិត្យ ក្រុងភ្នំពេញ បានបង្កើតក្រុម ១ ហៅថា "ក្រុមដំនុំទំនៀមទម្លាប់ស្រុកខ្មែរ" ក្រុមដំនុំនេះ ធ្វើការប្រមូលកត់ត្រាពុតនៅអារ្យធម៌ - ទំនៀមទម្លាប់របស់ខ្មែរពាំងសម័យបុរាណ និងសម័យបច្ចុប្បន្ន ឲ្យដឹងថាខ្មែរសម័យបុរាណនិងសម័យបច្ចុប្បន្ន មានអារ្យធម៌ដូចម្តេចខ្លះ ការទំនៀមទម្លាប់ដូចម្តេចខ្លះ ។ ប្រមូលហើយរៀបរៀងចោះពុម្ពផ្សាយ ដើម្បីញ៉ាំងប្រជាជនជាតិខ្មែរឲ្យដឹងប្រវត្តិសាស្ត្រនិងអារ្យធម៌ - ទំនៀមទម្លាប់នៃជាតិរបស់ខ្លួន និងដើម្បីញ៉ាំងនានាប្រទេសក្នុងលោកឲ្យដឹងថាខ្មែរពាំងសម័យបុរាណនិងសម័យបច្ចុប្បន្ន ជាជាតិមួយមានអារ្យធម៌ - ទំនៀមទម្លាប់ពាំងផ្លូវលោកផ្លូវធម៌ល្អប្រពៃ តាំងពីសម័យអង្គរដែលជាសម័យមាសរបស់ខ្មែរ រហូតមកដល់សព្វថ្ងៃនេះ ។

កិច្ចការរបស់ក្រុមដំនុំនេះ និងបានជាគោលចារិកដ៏ធំមហិមាក្នុងការសិក្សាប្រវត្តិសាស្ត្រនិងអារ្យធម៌ - ទំនៀមទម្លាប់ខ្មែរ ជាកិច្ចការរក្សាប្រទេសជាតិ សាសនារបស់ខ្មែរឲ្យតាំងខ្ជាន់នៅបាន និងបានជម្រើនតទៅខាងមុខ ។

ឥឡូវ ក្រុមដំនុំនេះ ត្រូវការប្រមូលរឿង ២ គឺ:

១ - រឿងរបរកសុំដេរ ។

២ - រឿងល្បែងផ្សេងៗ

ដើមជួនដំណឹងដល់អស់លោកអ្នកបេះដឹងខ្លះថា ពាំងកម្ពុជាវដ្ត ពាំងមូល សូមឲ្យសរសេរតែងរឿងពាំងនេះ ផ្ញើទៅប្រឡងឯមន្ទីរពុទ្ធសាសនបណ្ឌិត្យ ក្រុងភ្នំពេញ ។ កាលអស់លោកអ្នកតែងផ្ញើទៅដល់ហើយ ក្រុមវិនិច្ឆ័យនឹងប្រជុំគ្នាពិនិត្យមើល បើឃើញថាសេចក្តីតែងរបស់លោក-អ្នកណា ល្អជាងគេ នឹងឲ្យលេខហើយនឹងជូនរង្វាន់ ។ ឯលេខនឹងរង្វាន់នោះចែកជា ៣ ថ្នាក់ គឺថ្នាក់លេខ ១ ជូន ៦០ រៀល លេខ ២ ជូន ៤៥ រៀល លេខ ៣ ជូន ៣០ រៀល ។ រង្វាន់នោះបើលោកអ្នកប្រឡងជាប់លេខណាចង់យកជាប្រាក់ក៏បាន ជាសៀវភៅចោះពុម្ពរបស់ពុទ្ធសាសនបណ្ឌិត្យក៏បាន ។ ដើម្បីឲ្យការនេះបានស្រួលហើយធាប់ សូមលោកអ្នកប្រឡងគ្រប់គ្នា សរសេរសេចក្តីបញ្ជាក់បន្ថែមនៅទាងចុងរឿងដែលផ្ញើទៅប្រឡងនោះៗ តាំងពីដំបូងថា "ត្រូវការជាប្រាក់ឬសៀវភៅ" បង្អាក់ទុកឲ្យហើយ ក្រែងលោបានជាប់ ។

កន្លះលោកអ្នកប្រឡងម្នាក់ៗ ចង់តែងពាំង ២ រឿង គឺពាំងរឿងបរពាំងរឿងល្បែងក៏បាន តែ ១ រឿងក៏បាន ។ បើចង់តែងពាំង ២ រឿង ត្រូវសរសេររឿងនីមួយៗលើក្រដាសដាច់ដោយឡែកពីគ្នា បើលោកអ្នកប្រឡងណាម្នាក់តែងបាន ២ រឿង ហើយជារឿងល្អជាងគេពាំង ២ នោះអាចបានជាប់លេខពាំង ២ រឿង ចាន់រង្វាន់ជា ២ ផ្នែក គួរនាដូច

លោកអ្នកណាម្នាក់តែងរឿងបេះរកស៊ីបានជាប់លេខ ១ រឿងល្បែងក៏ជាប់លេខ ១ ដូចគ្នា នោះនឹងត្រូវបានរង្វាន់ថ្នាក់លេខ ១ ពីរដង បើប្រសិនជារឿងបេះរកស៊ីជាប់លេខ ១ រឿងល្បែងជាប់លេខ ២ ឬ ៣ នោះនឹងត្រូវបានរង្វាន់ថ្នាក់លេខ ១ ម្ដង លេខ ២ ឬ ៣ ម្ដង ដូច្នេះជាដើម ។

ឯការរៀបរៀងសេចក្ដី កុំបាច់គិតពីរបៀបពាក្យពេចន៍ អក្សរខុសត្រូវអ្វីក៏ល្អទៅរួយ គិតតែពីរៀបកប់ឲ្យសំភូគ្រប់កិច្ចការកន្លះបេះរកស៊ី ឬល្បែងនោះ ។ ប៉ុណ្ណោះ ។ បើអ្នកប្រឡងចង់សរសេរជាអក្សរចាក់ឆ្លាក់ចុះ តែត្រូវសរសេរឈ្មោះបេះ - ល្បែង - មនុស្ស - ប្រជាប់ធ្លើរបេះ ឬល្បែងនោះ ។ ទឹងពាក្យថ្លែក ។ ខ្លះជាអក្សរខ្មែរ ។

រឿងដែលប្រឡងចាំងអម្បាលម៉ាន ត្រូវឲ្យបានទៅដល់ក្រុមជំនុំទំនៀមទម្លាប់នៅក្រសួងពុទ្ធសាសនបណ្ឌិត្យ មុនថ្ងៃ ៣១ ខែធ្នូ (ជេសមប្រ៊ី) ឆ្នាំ ១៩៤៨, គឺ ថ្ងៃ សុក្រ ១ កើតខែបុស្ស ព.ស. ២៤៩១ ។

រឿងដែលប្រឡងនោះ បើតែងរួចហើយត្រូវយកទៅជូនមេឃុំឬចៅហ្វាយស្រុក - ខែត្រ ដែលនៅជិតនោះ ឲ្យថ្មើទៅពុទ្ធសាសនបណ្ឌិត្យ ក្នុងពេញ តាមផ្លូវពេជការកំចាន លោកអ្នកប្រឡងយកទៅឲ្យពុទ្ធសាសនបណ្ឌិត្យផ្ទាល់ខ្លួនក៏ចាន ។

សេចក្តីពន្យល់អំពីគោលនៃការតែងរឿងប្រឌិត

១- រឿងបុរាណ ២ រឿងល្បែង

ក) សូមតែងចំពោះតែរឿងបុរាណ ឬល្បែងជនជាតិខ្មែរ ដូចបុរាណស្រុកពោធិ៍ចំការ តំបន់ជាដើម ក្រៅពីនេះតាមតែបុរាណក៏ត្រូវការចាំងអស់ (រឿងលែងតែការពាក់ព័ន្ធ) ។ល។ ដូចល្បែងឈូងឆ្នាក់ លោតអន្ទាក់ លាក់កន្សែង ចាប់កូនខ្ទេង ហ៊ឹង កូនគោល ចាយ៉ុំជាដើម ក្រៅពីនេះតាមតែល្បែងណាក៏ត្រូវការចាំងអស់ (រឿងលែងតែ បៀ-ឆួ) ។

ខ) លោកអ្នកច្នៃឡងចង់តែងតែបុរាណ តែបុរាណល្បែង ឬតិចមុខក៏បាន ។ កាលបើតែងអំពីបុរាណឬល្បែងណា ត្រូវប្រាប់ឲ្យដាក់ថាបុរាណឬល្បែងនោះមាននៅស្រុកនោះ លោកអ្នកតែងធ្លាប់ធ្វើធ្លាប់លេងផ្ទាល់ខ្លួន ឬគ្រាន់តែឃើញគេធ្វើគេលេងឬក៏ដឹងតាមកន្លែងណា ជារបស់ខ្លួនឬរបស់អ្នកណា នៅឯណា ។

គ) លោកអ្នកប្រឡងត្រូវការតែងរឿងបុរាណឬល្បែងណា ។ សូមរៀបរាប់អំពីគ្រឿងប្រដាប់បុរាណឬល្បែងនោះ។ ឲ្យសព្វគ្រប់ដូចបុរាស្រុកត្រូវរៀបរាប់អំពីខន្លឹល-នោស-ជាដើម ។ល។ បុរាណសាខគ្រូត្រូវរៀបរាប់អំពីសំណាញ់-អួន-មង-អញ្ចូង ជាដើម ។ល។ បុរាដំបូលត្រូវ

រៀបរាប់អំពីរហាត់នឹងកីជាដើម ។ល។ ល្បែងឈូងគេយកអ្វីមកធ្វើឈូងជាដើម ។ល។ ចាយទុំគេយកអ្វីមកលេងជាដើម ។ល។ គ្រឿងប្រដាប់អស់នោះ មានច្រើនគ្រប់យ៉ាងដូចម្តេចខ្លះ ត្រូវតាំងរៀបរាប់អំពីកិច្ចការកន្លងរបៀបល្បែងនោះៗផង តាំងពីពេលផ្តើមធ្វើផ្តើមលេង រហូតដល់ធ្វើដល់លេងរួចស្រេច ។

ឃ) របៀបល្បែងណា មានមនុស្សអ្នកធ្វើ ឬអ្នកលេងប៉ុន្មាននាក់ របៀបល្បែងណាគេតែងធ្វើឬលេង វេលាណាខែណាឬមិនកំណត់វេលាគេលេងក្នុងបុណ្យ ឬមង្គលអ្វីលេងថ្ងៃឬយប់ ឬចំនួនតាំងថ្ងៃតាំងយប់ សូមចរិយាយឲ្យសព្វគ្រប់ ។

ង) នៅស្រុកណា មានរបៀបល្បែងអ្វីខ្លះ ដែលប្លែកឬធំជាងស្រុកឯទៀតៗ ។

ច) បើប្រសិនជាលោកអ្នកចម្លង អាចដឹងរឿងច្រើនជាក់ទង់ដោយរបៀបល្បែងណា សូមសរសេរតែងរឿងនោះដាក់ទៅផង តែសូមចាប់ដើមកំណើតរឿងនោះថា ចាន់ដឹងពីអ្នកណា នៅទីណា គេដំណាលចាប់ ពីសាស្ត្រាណាឬសៀវភៅណារបស់អ្នកណា នៅទីណា បើសៀវភៅចោះពុម្ព ឬសាស្ត្រាស្ទឹកតែ ត្រូវចាប់ឈ្មោះ ចាប់ទំព័រ ចាប់អង្គ្លា បើមិនដឹងរឿងច្រើនទេ សូមតែងតែរឿងរបៀបល្បែងចុះ ។

ក) បើរបស់លៀងណាមានគ្រែណាម ឬពិធីដូចម្តេច លៀងណាចាត់ចែងដោយសាសនាណា កំសួរមបរិយាយផង ។

ក្រុមដំនុំទំនៀមទម្លាប់ស្រុកខ្មែរ

នៅក្រសួងពុទ្ធសាសនបណ្ឌិត្យ

ក្រុងភ្នំពេញ

រឿងដាក់ផ្លែកន្ទៃ

សូមជូនមកក្រុមជំនុំទំនៀមទម្លាប់ខ្មែរ

ដើម្បីនឹងសូមបញ្ជាក់អំពីរឿងប្រៃដេញផ្លែកន្ទៃតាមរបៀបបុរាណ រឿងនេះ ខ្ញុំបានបានឮឈ្មោះ គីម-សេក អាយុ ១៩ ឆ្នាំ ធ្វើការនៅសាលារៀនគេអាតន្ទ្រូ លេខ ៤២ ផ្លូវប៉ូលចែរ ភ្នំពេញ បាននិយាយរឿងនេះប្រាប់ខ្ញុំបាទនៅថ្ងៃចន្ទ ២៦ មករា គ.ស. ១៩៤៨ វេលាម៉ោង ១១ ទំង ៣០បាទ រឿងនោះដូចតទៅនេះ:

តាមរបៀបអ្នកស្រុក នៅស្រុកខ្ញែងបៀង ឃុំធ្លៀកណាប ភូមិព្រៃខទំង ខេត្តបាត់ដំបង (មាត់ផ្លែក) គេតែងតែទៅចាក់ផ្លែកន្ទៃនៅដើងកំពាលកន្ទ្រស្រុកខាងលើនេះ ប៉ុន្តែគេទៅដេញតាមរដូវ គឺរដូវរំហើយ ខែអស្សុជ កត្តិក ផល្គុន ហើយនឹងចេត្រ អ្នកស្រុកដែលនៅស្រុកនោះ តែជិតដល់រដូវទៅដេញសត្វហើយ អ្នកដែលគេតែងទៅប្រដេញនោះ គេប្រដង្រៀបគ្រឿងប្រដាប់សម្រាប់ទៅចាក់ ប្រដាប់នោះគេហៅថាបង្គាត់ ឯបង្គាត់នោះមានសណ្ឋានដូចជាមងដែលសម្រាប់ជាក់ត្រី ប៉ុន្តែតូចជាងធំៗ ជាងក្រឡាមងធម្មតា ហើយក្រឡានោះធ្វើអំពីខ្សែដក់ដូនតូចៗ ដូចជាខ្សែដែលគេដេរក្តាន់តូច ហើយមានមេពីរទំហំប៉ុនមេដៃ បង្គាត់នោះមានបណ្តែង ១០ ប្ល ១២ ម, បណ្តោយ ឯទំងប្រហែលជា ៣ ប្ល ៤ ម, ។

របៀបកាយបង្គាត់នោះ គឺ គេយកមេបង្គាត់ដាក់ខាងលើបង្គោលតូចប៉ុនកដៃ
ក្មេង ឯបង្គោលនោះគេដោតបន្តុំសើ ៦ លើដី អាចនឹងរលំមកខាងមុខបាន
ដោយងាយ កាលណាតែមានសត្វអ្វីចូលទៅប៉ះបង្គាត់នោះ, មេបង្គាត់
ខាងក្រោមគេដាក់ឲ្យប៉ះនឹងដី ហើយត្រណមបង្គាត់នោះ គឺគេហាមមិន
ឲ្យអ្នកឯណាដើរកន្ទឹងលើឡើយ ។

លុះដល់ដូវដេញចៅចេញសត្វនោះ មេប្រមូលគ្នាអ្នកដែលនៅជិត
ខាងនោះចំនួនជា ៥០ ឬ ៦០ នាក់ អ្នកឯណាចង់ចៅក៏ចៅបានដែរ មិន
ចំពោះតែអ្នកមានបង្គាត់ទេដែលចៅបាននោះ អ្នកដែលគ្មានបង្គាត់ក៏ចៅ
បានដែរ គេចៅម្តងៗ មានបង្គាត់ចំនួនជា ៥ ឬ ៦ ។

មុននឹងចេញចៅនោះ គេប្រដាប់ប្រដាគ្រឿងសក្ការបូជា គឺ ជ្រាយស៊ី
ជ្រាំថ្នាក់ ១ គូ ស្លាធំដៃ ១ គូ ទៀន ៥ ធួប ៥ មាន់ស្វាយ ១ សំពាម
យកចៅថ្វាយបង់បត់ដែលនៅច្រកឡើងចៅភ្នំពាល លុះបានគ្រប់ប្រ-
ដាប់ប្រដាហើយ ក៏នាំគ្នាចេញចៅ អ្នកដែលចៅតាំងអំបាលម៉ាន សុទ្ធ
សឹងមានអាវុធសំពាប់ការពារអាត្មា អ្នកខ្លះមានកាំបិតស្នៀត អ្នកខ្លះជាវ
លំពែង អ្នកខ្លះស្មូស អ្នកខ្លះទៀតកាំបិតផ្តាក់តូចៗ ។

លុះនាំគ្នាចៅដល់ដើមពោធិ៍នៅច្រកឡើងចៅភ្នំពាល ក៏យក
គ្រឿងសក្ការៈតាំងនោះចៅបូជា បង់បត់ដែលនៅច្រកភ្នំក្រោមដើមពោធិ៍
នោះ បង់បត់នោះនាមតាត់ឈ្មោះហោយតង់ កាលដើមឡើយ កំណើត

យាយតង់នេះ នៅស្រុកយួនកូសាំងស៊ីនឯនោះទេ ប៉ុន្តែដោយសារមានជាតិចាំងម្នាក់ ចានទៅព្យាចាទលើលំនៅរបស់គាត់នោះ គាត់ក៏ត្រឡប់មកនៅៗ ដើងក្តុំពពាលនេះ ចានជាគេដឹងថាគាត់មកនៅៗ ដើងក្តុំពពាលនេះ ពីព្រោះកាលដែលមកដល់ស្រុកនោះភ្លាមក៏ទៅចូលនឹងរួបស្រីម្នាក់ចាស់មានឈ្មោះពុំច្បាស់ ចូលមកក្នុងនិយាយរឿងក៏រៀបចាប់គេងនឹកលក់គ្នា ។

លុះគេដឹងថាគាត់មកនៅៗទីនោះ គេក៏បបួលគ្នាទៅសង់អាស្រមឲ្យគាត់នៅក្រៃដើមពោធិ៍ដែលនៅច្រកក្តុំពពាលនោះ អ្នកណាដែលត្រូវការឡើងទៅលើភ្នំនោះ ត្រូវតែយកគ្រឿងសក្ការៈផ្សេងៗទៅថ្វាយបើពុំនោះទេមុខជាប្រទះនឹងគ្រោះថ្នាក់មិនខាន គឺដួចប្រទះនឹងសត្វសាហាវមិនខានទេ ។

លុះអ្នកដែលទៅចាក់ជ្រកវៃនោះ រៀបថ្វាយរួចស្រេចហើយក៏ទាំងគ្នាដើរឡើងទៅលើភ្នំ ។

លុះកាលដែលអ្នកអស់នោះដើរទៅឆ្ងាយពីអាស្រមនោះកំពែកគ្នាជាពីរពួក មួយចួតឲ្យនៅចាំដើមផ្លូវ មួយពួកទៀតឲ្យដើរយកបង្កាត់ទៅពយចម្ងាយពីដើមផ្លូវទៅប្រហែលជាមួយគីឡូម៉ែត្រ បង្កាត់នោះគេពុយឃ្លាតពីគ្នាពីមួយទៅមួយចុកចន្លោះកណ្តាលប្រហែលជាគ្រាំឬគ្រាំមួយម៉ែត្រ នៅតាមចន្លោះបង្កាត់នោះគេឲ្យមនុស្សយាមពីរប៉ុន្មាននាក់ ។

លុះកាយបង្ហាត់រួចស្រេចហើយ កំចាត់គ្នាឲ្យមកជ្រាប់អ្នកដែលនៅចាំដើមផ្លូវបានដឹង លុះបានដឹងហើយក៏កាយគ្នាចម្ងាយពីមួយទៅដង្ហែគ្នា នាំគ្នាស្រែកហ៊ោកញ្ជ្រៀវ រាយត្រៃផ្សឲ្យជ្រកដែលលាក់ខ្លួនក្នុងព្រៃនោះផ្តើល រត់ចូលទៅកន្លែងបង្ហាត់ដែលកាយនៅខាងមុខ ។

លុះដេញទៅដល់ជិតបង្ហាត់នោះភាលណា ក៏នាំគ្នាស្រែកតែតែងខ្លាំងឡើង ។ ម្ល៉ោះហើយសត្វដែលរត់ទៅនោះលុះដោយអំណាចសន្ធាប់របស់គេ ក៏បេះតែរត់តែតែងខ្លាំងឡើងដើម្បីឲ្យរួចខ្លួន លុះចុងលរត់ទៅស្រាប់តែចូលទៅក្នុងបង្ហាត់នោះ ។ ក៏មូរវាំជាប់ដុំវិញខ្លួនរកតែទៅខាងណាក៏ពុំរួច ។ ចំណែកអ្នកដែលនៅយាមបង្ហាត់នោះ កាលបើឃើញជ្រកជាប់ដូច្នោះហើយ ក៏រត់ទៅចាក់កាប់សម្លាប់ឥតត្រាប្រណីដល់តិចឡើយ ។

ចំណែកអ្នកដែលជាម្ចាស់បង្ហាត់ត្រូវបានក្បាលដើងហើយនឹងកន្ទុយ ចំណែកអ្នកដែលមិនមែនម្ចាស់បង្ហាត់ត្រូវបានស៊ាប់ តាមចំនួនសត្វដែលគាត់បាន ទៅតាក់ម្ភង ។ ដូនកាលបាន ៧ ឬ ៨ ។

បានជាអ្នកស្រែកតែតែងទៅប្រដេញនៅរដូវរំហើយ ដូចគោលមកខាងដើមនោះ ពីព្រោះនៅរដូវនោះស្រែទុំ ជ្រកតែងចុះមកបរិភោគស្រូវស្រែដែលនៅជិតដើងកំពតពាលនោះ ។

លោក រ៉ាយ-ប៊ុក ប្រែ លោក ញ៉ុក-ថែម ពិធីត្រៃ

(តមក)

31°— Le travail est un trésor.

៣១ .— ការងារជាឃ្លាំងប្រាក់ .

"ធ្វើការបានប្រាក់ ធ្វើការបានសក្តិ ធ្វើការបានយស ធ្វើការបានទ្រព្យ បានវិជ្ជាស្មោះ ចំរើនឥតថ្លៃ ដោយសារការងារ" ។

32 .— Il faut battre le fer quand il est chaud .

៣២ .— ត្រូវដំដែក តែងពេលដែលកំពុងក្តៅ ។

"ធ្វើស្រែមានមនុស្សឆ្លាត ទំស្រែកប្រែឆាប់ចិត្តចង់ សាងជាតិដោយស្មោះត្រង់ ទំចង់ស្រីមានក្តៅចិត្ត" ។

33.— Ce qui vient de la flûte s'en va par le tambour.

៣៣ .— បេះដែលបានមកជាប៉ី ដល់ចេញទៅវិញជាស្គរ ។

"ទ្រព្យដែលកេងបាន ដោយទន្ទ្រានលំអាន មិនស្ងួតឡើយ ដល់ខ្លាត់ប៉ាត់ទៅ ចាកលំនៅឯ្វី ឆ្ងាយឆ្ងាយស្រីដី ល្បីពេញទាំងស្រុក" ។

34°— Les absents sont toujours torts.

៣៤ .— អ្នកមិននៅបេះតែខុស ។

"អ្នកមានពាសប្រែនអាងអ្នកស្ងប់ទៅ ត្រង់ខុសត្រូវរៀងខ្លួនមើលមិនយល់ បុរាណបណ្ឌិតពិនិត្យតិតាមយោបល់ កុសលអកុសលត្រូវពិចារណា" ។

35°— On est toujours heureux le soir quand on a bien rempli la journée.

๓๕.- កាលបើគេបានបំពេញអំពើល្អ ក្នុងវេលាថ្ងៃ ដល់ពេលល្ងាច គេនឹងបានសេរ្ចក្សាយចិត្តជានិច្ច ។

"ពេលថ្ងៃធ្វើល្អ ប្រព្រឹត្តធម៌ស សុចរិតជានិច្ច ដល់ពេលល្ងាច គឺតរើញតែតិច្ច ការល្អច្រើនតិច សប្បាយចិត្តគាប់" ។

36° — A force de forger, on devient forgeron.

๓๖.— ជនខំដំដែក គេនឹងទៅជាជាងដំដែក-

"ខំរៀនទើបចេះ ខំធ្វើទើបធេ្លះ ខំធ្វើបានផល ឥតអំពល់ទុក្ខ ខំដើរទើបដល់ ខំគិតទើបយល់ ដោយផលព្យាយាម" ។

37.— Il faut manger pour vivre et non vivre pour manger.

๓๗.- ត្រូវស៊ីឲ្យគ្រាន់តែរស់ មិនមែនរស់គ្រាន់តែស៊ី ។

"ត្រូវដឹងប្រមាណ អាហារដែលបាន បរិភោគតាល់ថ្ងៃ ពោះមានតិបច្រើន ពោះគឺតសំចៃ គ្រប់គ្រាន់សព្វថ្ងៃ ទើបបានសុខសាន្ត" ។

38.— Aide-toi le ciel t'aidera.

๓๘.- ចូរអ្នកជួយខ្លួនអ្នក ទើបខេ្ពាជួយអ្នក ។

"ខ្លួនឯងឯង ទើបបានក្តីសុខ អ្នកផងយល់ម្តុខ មុកចិត្តជួយថែម" ។

36.— Chercher une aiguille dans une boîte de foin.

๓๙.- រកម្ជុលមួយដ្រែកក្នុងតំនរចំបើង ។

"ការធ្វើហួសវិស័យ ជាបច្ច័យវិនាសច្បាស់ ព្យាយាមអស្ចារ្យមាន មិនសមេ្រចប្រយោជន៍ខ្លួយ ។

40.— Faire l'âne pour avoir du son.

๔๐. ធ្វើលាបង់យកកន្ទក់ ។

"ធ្វើឆ្កួតដើម្បីស្គាប់កិច្ចការ ធ្វើកម្រើដើម្បីត្រៃថរសជាតិ ព្យាយាម
មុតមាំកុំបីឃ្លាត ច្រឹងស្មៀតសង្កៀតតង់ឈើញាកល" ។

41.— Bouche d'un démon, cœur d'un ange.

๔๑.- មាត់ជាយក្ស ចិត្តជាទេព្តា ។

"មាត់អាក្រក់ចិត្តច្រើនសោកាំណា ចិត្តថ្លើមសាន់ព៉ាន់ច្រើនមាត់ល្អ
ឯវែបភាពមារយោទខ្មៅស តម្រែយល់ពិតបណ្ឌិតដឹង" ។

42.— Entre l'arbre et l'écorce, il ne faut pas mettre le doigt.

๔๒.- កុំជាក់ម្រាមដៃ កន្លះខ្នារដើមនឹងសំបក ។

"ការណ្ហោះពាស់គ្នា ញាតិផៅមិត្តភ្ងា យើងអ្នកជិតខែ មិនត្រូវ
ជ្រៀតជ្រែក ជាផែកចំកំយ ឲ្យខ្លាំងមានជ័យ កើតពាស់គ្នាខ្លាំង" ។

43.— Couper l'arbre pour avoir le fruit.

๔๓.- កាប់ដើមយកផ្លែ ។

"សម្លាប់មេមាន់យកពងមាស ចិត្តលោភពេញពាសជាសតសុជា
ខ្លួនក្រីក្លួចបាបភាពដូចថា ក្រាញ់ជ្រុលហួសនឹងហ៊ានច្បាណ" ។

44.— Tout est vide et vanité sur ce monde.

๔๔.— របស់ទាំងអស់ជារបស់សោះសូន្យ នឹងជារបស់លក្ខន
បញ្ឆោតនៅកង់លោកនេះ ។

"លោកនេះសោះសូន្យ តើតស្ងាប់ពពួន ច្រែនជាអនេក កេងស្ងាប់មុនចាស់ ឃើញឮស្ងាន់ធំក្អែក គ្រប់ជាន់គ្រប់ផ្ទៃក សាបសូន្យអស្ចារ" ។

45.— On aperçoit la paille dans l'œil de son voisin et non la poutre qui est le sien.

៤៥.— គ្រមើលឃើញតែសម្រាមនៅនឹងក្អែកអ្នកជិតខែ តែគមើលមិនឃើញធ្នឹមជាប់នៅនឹងក្អែកបេះខ្លួន ។

"ពាក្យចាស់ពាក្យពីព្រៃធំ ពោះខ្លួនឯងមើលមិនឃើញ ពោះគេតូចសោតសើ រមិលឃើញប៉ុនភ្នំ" ។

46.— Fais bien et laisse le dire.

៤៦.— ចូរធ្វើតែល្អទៅចុះហើយបើកឲ្យគេថាទៅចុះ ។

"ប្រែព្រឹត្តសុចរិត កុសលក្រមក្រិត្យ ទុត្តមថ្លៃថ្លា អ្នកជិតខែពោលតាមចិត្តគេថា ធ្វើល្អទេវតា ឲ្យពរជោគជ័យ" ។

47.— Pour chercher un ami, il faut goûter beaucoup de sel avec lui.

៤៧.— ស្វែងរកមិត្តសម្លាញ់ណាមួយ ត្រូវភ្លក់អំបិលជាមួយគ្នាជាច្រែនដង ។

"កល្យាណមិត្ត ស្មោះស្មើគំនិត រកបានកម្រ លុះតែសេពគប់ទើបយល់ឮស សុចរិតអាក្រក់ល្អ ដោយរមៀរការ" ។

48— On vient à bout à qui sait attendre.

៤៨.— អ្នកដែលរង់ចាំគេទឹងបានសម្រេចដូចបំណង ។

"ខ្ជិអត់ធន់ ចម្រើនគុណជួន សម្រេចប្រាថ្នា ចង់បានតាន់ចិត្ត តាមគំនិតចិន្តា មិនបានផលា ត្រូវការប៉ុនប៉ង" ។

49— Nul n'est content de son sort.

៤៩ — គ្មានអ្នកណាមួយពេញចិត្តនឹងជោគវាសនារបស់ខ្លួន ។

"និស្ស័យមនុស្សលោក មានច្រើនគរគោក ក្នុងកពសង្សារ មិនថាមានក្រ គាប់ចិត្តវាសនា អាត្រកំល្អយ៉ាងណា តុំសូវមានឡើយ" ។

50— Qui désire tout n'a rien.

៥០- អ្នកដែលប្រាថ្នាតាំងអស់ មិនបានអ្វីសោះ ។

"មនុស្សលោកលន់ មិនឆ្អែតមិនឆ្អន់ បានច្រើនយ៉ាងណា នៅតែខាតខ្វះ កន្ទុះចិន្តា បរបើងលាកា វែងបាត់ធន់ទៅ" ។

51— Qui borne ses désirs est toujours assez riche

៥១ - អ្នកណាសន្តោស អ្នកនោះមានសម្បត្តិ គ្រប់គ្រាន់ជានិច្ច

"តណ្ហាជាមេខ្វះ បេះតែកន្ទុះ មិនដែលគ្រប់គ្រាន់ អ្នកមានសន្តោស ចិត្តលុះជាក់ស្បាន់ ក្រែដេញមិនទាន់ ជាន់តែឆ្ងាល់ថ្ងៃ" ។

52— Deux avis valent mieux qu'un.

៥២ - សេចក្តីយល់ពីរដងមានដំឡៃជាងសេចក្តីយល់ឃើញម្តង

"គិតរួចសឹមធ្វើ បណ្តិតសរសើរ មិនសូវមានក្តាត់ បើយោបល់ពីរ កាន់តែខៀងចាត់ មូលគ្នាពីរអាត់ ច្រកដជាក់ស្បាន់" ។

53— Autant de têtes autant d'avis.

៥៣ - ក្បាលកំប្រែន មតិកំប្រែន ។

"មនុស្សមានប្រែនបែប កលកិច្ចប្រែនលែប ខាយខុសៗគ្នា
លទ្ធដោយខ្លួន មតិប្រាជ្ញ ប្រៃលើងជូរខារ តាមតែយល់ចុះ" ។

54— Tout effet à une cause.

៥៤— ផលទាំងអស់កើតមកពីហេតុ ។

"មានភ្លើងមានផ្សែង មានល្អីតភ្លឺចែង ស្ទឹកឈើកំរើក ដ្បិតមាន
ឫស្សល់បក់ មច្ចជាតិរើក ហែបហែលកខ្វើក ល្អក់ទឹកពុំជា" ។

55 — Quand le lit est bien préparé il faut qu'on se couche.

៥៥ — កាលណាគ្រែដេកមករៀបចំបានស្រួលហើយគេត្រូវ
តែដេក ។

"ធ្វើការមិនប្រមាទ ទំនឹងភ្នាក់ឲ្យបានផល សង្គ្រាមក្នុងសាកល
ប្រាជ្ញាផលគឺកំរៃ"

56 — Qui va lentement va loin.

៥៦ — អ្នកដែលដើរទៅសន្សឹម ៗ ទៅបានឆ្ងាយ ។

"អ្នកដែលដើរទៅមួយ ៗ ឥតទុក្ខព្រួយខ្វាយខ្វាក់ចំណាប់ ធ្វើការ
ងារតាមសណ្តាប់ មិនប្រញាប់ក្រែងភ្លាត់ស្មៃ" ។

57 — A beau mentir qui vient de loin.

៥៧ — អ្នកដែលមកពីឆ្ងាយ កូតកវបានតាមចិត្ត ។

(មានត)

ហ្គួងដងឆ្នូមត្រូ ញ៉ក-ថៃម ប្រែរៀបរៀង

(តមក)

វគ្គទី ៣

ភាពរង្សុង

អំពីការចលាចលមុនតាំងរាជវង្សស៊ុង

ប្រសិនបើលោក-អ្នកចាន់មានពត៌្មានគារចិន តាំងពីដើមរហូតមក ដល់គ្រឹមណោះ ទំនងយើញច្បាស់ថា សេចក្តីប្រែប្រួលដ៏មថា ចិនពុកជាក្រុងកេមរបស់ទ្វីបអាស៊ីនោះ ជាសេចក្តីប្រែប្រួលដ៏សមរំបំផុត ។ ហេតុគេទផ្សង។ ដែលមានក្នុងប្រវត្តិសាស្ត្រចិនក្តី ហេតុនៃសេចក្តីចំរើន ទំនងសេចក្តីសាចសូន្យរបស់ក្សត្រចិន តាមដែលគោលមកហើយក្តី សឹងមានលក្ខណៈត្រូវគ្នាទំនងក្រុងកេមជាច្រើន ។ ហេតុគេទបស់ក្រុងកេមតមកខាងចុង មានសម័យដែលកើតចលាចលរវើកវើរដោយសារគាហាន ដូចមានក្នុងពត៌្មានគារកេមថា សម័យគ្រានោះជាសម័យដែលពួកគាហានបង្កសេចក្តីវិនាសសាចសូន្យ សម័យបែបនេះ ក៏មានក្នុងប្រវត្តិសាស្ត្របស់ចិនដែរ គឺគ្រាដែល ជួ-វេន ចាន់ផ្តួលរំលំព្រះមហាក្សត្រកាជវង្សចាំង អង្គុះ កាយបង្គំស់ កាលឆ្នាំពុទ្ធសករាជ ១៤០ ហើយ

តាំងខ្លួនឯងឡើងជាព្រះរាជាធំរាជក្រុងចិន តាំងទីក្រុងនៅស្រុកវៀ-ហ្វង ឯពួកមេទ័ពឯទៀត ។ ដែលមានកំឡាំងខាហានក៏នាំគ្នាយកតម្រាប់តាមទើបប្រកាសខ្លួនជាឥស្សរៈដោយឡែក។ ឡើង នៅខេត្តដែនដែលខ្លួនតាំងកងខាហាននោះ ,។ បណ្តាពួកដែលតាំងខ្លួនជាឥស្សរៈឡើងនោះមានម្នាក់ដែលខ្លាំងពូកែហើយជាសត្រូវដ៏សំខាន់បំផុតនឹង ដួ-វៃន ឈ្មោះ លី-កេយ៉ង ជាជាតិតួកគិតាំងខ្លួនជាក្សត្រគ្រងរាជសម្បត្តិនៅខេត្តចាន់-ស៊ី។ ក្នុងឆ្នាំពុទ្ធសករាជ ១៤៦៧ ព្រះរាជបុត្រប្រុសរបស់ក្សត្រថ្មីនេះ ឈ្មោះ លី-ជុនហ៊ុយ ក៏យកស្រុកវៀ-ហ្វងបាន ដណ្តើមយកករាជបល្ល័ង្កចិនពីព្រះរាជាធំរាជដួ-វៃនមកបាន ហើយតាំងរាជវង្សថ្មីឡើង ហៅថា ហៀវ-ចាំង តាំងស្រុកលោ-យ៉ាង ជាទីក្រុង គ្រងរាជ្យបាន ១៣ ឆ្នាំ ទើបមានជាតិតួកម្នាក់ទៀតឈ្មោះ ចេ-តិងចាំង មកក៏យយកស្រុកលោ-យ៉ាងបានទៀតទៀត ហើយតាំងរាជវង្សឡើងថ្មីទៀត ហៅថា វង្សអៀវ-ជិន តាំងទីក្រុងនៅស្រុកវៀ-ហ្វង ។ វង្សអៀវ-ជិនគ្រងរាជ្យបានត្រឹម ១០ ឆ្នាំ ក៏ត្រូវពួកតឺ-តៃ មកក៏យដណ្តើមយករាជបល្ល័ង្កទៀតទៀត តមកទៀត ១១ ឆ្នាំ ទើបមានឥស្សរៈជាតិតួកម្នាក់ឈ្មោះ ហៅថាលៀវ-ជី មកក៏យយកស្រុកវៀ-ហ្វងទៀតបាន ហើយតាំងរាជវង្សក្សត្រថ្មីឡើង ហៅថា វង្សហៀវ-ហ៊ន គ្រប់គ្រងរាជសម្បត្តិបានតែត្រឹម ៤ ឆ្នាំ ក៏មានតួកម្នាក់ទៀតមកក៏យបែកដណ្តើមយករាជបល្ល័ង្ក

ទៅបាន ហើយតាំងរង្សីក្សត្រថ្មីឡើង ហៅថា រង្សីហៀវ-ចៀវ គ្រងរាជសម្បត្តិបាន ១០ ឆ្នាំ គឺ តាំងពីពុទ្ធសករាជ ១៤៤៤ ដល់ពុទ្ធសករាជ ១៤០៣ ។

ការចម្បាំងដណ្តើមរាជសម្បត្តិ ផ្តួលរំលំរាជរង្សីចាស់ តាំងរាជរង្សីថ្មី ហើយផ្តួលរំលំគ្នាគ ។ ទៅទៀត ហើយតាំងឡើងថ្មីទៀត មិនមានរាជ្យណាមានដំហរវែងសោះឡើយ នេះហើយធ្វើឲ្យយើងមើលឃើញសភាពវរីតរបស់ក្រុងចិនយ៉ាងសំបើមក្រៃលែង ជាងសម័យមុនតាំងរាជរង្សីថាំងទៅទៀត ។

ការដែលស្រុកចិនតើតចលាចលវរីតឡើងនោះ បើកឱកាសឲ្យប្រជាជនមួយពួក ហៅថា គី-តៃ មានសេចក្តីរុងរឿងមានអំណាចឡើងជាឯកកង្វិបគាស៊ី បុងបូញប្រទេស ពួកគី - តៃ នេះតាំងភូមិប្រទេស កន្លែងមញ្ជូរគោគខាងត្បូងនៅជែនដីដែលហៅថា លៀវតុង ។ ក្សត្រៀរបស់ជនពួកនេះ ហៅថា យេលូគាប៉ាតិ ដែលបានគ្រប់គ្រងប្រជាជនពួកនេះនៅកន្លែងរវាងពុទ្ធសករាជ ១៤៩០ ដល់ពុទ្ធសករាជ-១៤៧០ ហើយបានដណ្តើមយកខេត្តជែនខាងឈូងសមុទ្រប៉ែជិលី ទៅអំពីចិន អ្នកទទួលគ្រប់គ្រងជាដំណតមកហៅថា យេលូតេកួង គ្រប់គ្រងពួកគី - តៃ នៅកន្លែងរវាងពុទ្ធសករាជ ១៤៧០ ដល់ ១៤៨០ ហើយបានជួយឲ្យឈ្មោះ ចេ - គិងចាំង បានគ្រងរាជសម្បត្តិក្រុងចិនម្តង កាល

ពីពុទ្ធសករាជ ១៤៧៤ ហើយក្រុងចំនបានតាំងពីជាវង្ស ស្រៀវ - ជិន ទ្បើងដូចពោលពីខាងដើមរួចមកហើយ ឯក្រុងចំនបានលើកដែនដីខាងជើងខេត្តប៉ៃលិនទំងាន - ស៊ី ដែលជាទីក្រុងបុក - គិង ឬប៉ៃកាំងឲ្យទៅយេលូ - តេមួង ។ ក្នុងឆ្នាំពុទ្ធសករាជ ១៤៨១ យេលូ - តេមួង បានផ្ទាស់ទីក្រុងទៅតាំងនៅឯ ប៉ៃ - កាំង ហើយក្រុង ប៉ៃ - កាំង ក៏ចាប់ផ្តើមមានរឿងកាវសំខាន់ ទំងជាទីក្រុងសំខាន់តាំងពីកាលណោះមក ។ កាលដែលពួក គី - តៃ តាំងនៅខ្ទាប់ខ្ទួនក្នុងក្រុងប៉ៃ - កាំងហើយ ក៏ចាប់ផ្តើមឡុំងលុកលុយដែនដីចំនភាគខាងជើង ហើយតមកក៏ផ្តួលរំលំពជាវង្ស ប៉ៃ - តីចាំងទៅ ហើយចូលគ្រប់គ្រងក្រុងវៃ - ហ្វូងដោយខ្លួនឯង នៅគ្រប់គ្រងជាវេលា ១១ ឆ្នាំ ទើបមានពួកលៀវ - ដ៏ មកកាយជណ្តើមយកក្រុងវៃ - ហ្វូងទៅបានទៀត ដូចពោលរួចមកហើយនោះ ។

ការចលាចលវៃកែលពួក គី - តៃ បានធ្វើឲ្យដល់ប្រទេសចំនក្នុងគ្រានេះ កាច់ថាជាការចលាចលយ៉ាងធំរំកែលែង នាំឲ្យស្រុកចំនក្នុងវេលានោះ បែកខ្ញែកចេញទៅជាច្រើនអាណាចក្រ ។ ក្នុងសម័យកាលវង្សហៀវ - ចៀវ ដែលបានគ្រប់គ្រងពជរមម្បត្តិនៅក្រុងវៃ - ហ្វូងនោះ ក៏មានអាណាចក្រឯទៀត ។ តាំងជាឥសរៈទ្បើងដល់ទៅ ៧ អាណាចក្រ គឺ

១ — ពួកហួនកាតខាងដើង គ្រប់គ្រងខេត្តវៃនចាន-ស៊ី តាំងទីក្រុងនៅស្រុកតៃ ប្លេន តាំងជាឥស្សរៈហ្វានកងរវាងពុទ្ធសកាជ ១៤៩៥ ដល់ ១៥៦១ ។

២ — ពួកថាំងគ្រប់គ្រងខេត្តកៀង-ស៊ូ ង៉ាំនហួយ ទំងកៀង-ស៊ី តាំងក្រុងនៅស្រុកណាន-គិង តាំងពីរវាងពុទ្ធសកាជ ១៤៨០ ដល់ ១៥១៨ ។

៣ . ពួកណាន-គិងគ្រប់គ្រងខេត្តហួ-ប៉ែ តាំងពីកងរវាងពុទ្ធសកាជ ១៤៥០ ដល់ ១៥០៦ ។

៤ — ពួកជូគ្រប់គ្រងខេត្តហួ-ណាន តាំងពីកងរវាងពុទ្ធសកាជ ១៤៣៩ ដល់ ១៥០៦ ។

៥ — ពួកវ៉ូ-យេះ គ្រប់គ្រងខេត្តដាំកៀង តាំងពីកងរវាងពុទ្ធសកាជ ១៤៣៧ ដល់ ១៥២១ ។

៦ — ពួកហួន ទិសខាងត្បូង គ្រប់គ្រងខេត្តក្វាងទុងទំងក្វាង-ស៊ី មានស្រុកកាំង-តាំងជាទីក្រុង តាំងពីកងរវាងពុទ្ធសកាជ ១៤៥០ ដល់ ១៥១៤ ។

៧ — ពួកក្សត្រកាជវង្សចាស់ ហ្វានគ្រប់គ្រងខេត្តសេ-ឆួនទំងខេត្តកៀវ-កៀវ មានស្រុកជិង-ឌូ ជាទីក្រុង តាំងពីពុទ្ធសកាជ ១៤៣៤ ដល់ ១៥០៨ ។

វេលាគ្រាណា ព្រះពាជាធិពាជអង្គដែលគ្រប់គ្រងពាជសម្បត្តិនៅក្រុងវៀ - ហ្វង ទ្រង់ទំរឹងពាយោមរួបរួមអាណាចក្រអស់នោះមកបញ្ចូលជាមួយគ្នា ពួកអាណាចក្រអស់នោះតែងយល់ថាស់ធំទំធឹងជាងពាបហើយពួកគី - តៃ ចាំកេនុកាសកំហែងគំរាមអាណាចក្រកណ្តាលជានិច្ច ទើបគី - តៃនៅវេលានោះ ក៏ក្លាយទៅជាពួកមនុស្សស៊ីឈ្នួល ជួលប្តូនឬជួលបង្កាន ស្រែចតែខាងណាជួលក៏ទទួលស៊ីឈ្នួលចាំងអស់ ។

តាំងរាជវង្សស៊ុង

លុះមកដល់ឆ្នាំពុទ្ធសកពាជ ១៩០៣ ក្សត្រអង្គក្រោយបំផុតរបស់រាជវង្សហៀវ - ចៀវ ដែលគ្រងស្រុកវៀ - ហ្វងនោះទិវង្គតទៅ ពួកមាហាន ទើបប្រកាសតាំងមេទ័ពរបស់ខ្លួនឈ្មោះចៅកួងយិនឡើងជាក្សត្រ ទ្រង់ព្រះនាមថា ព្រះបាទ ថៃ - ជឺ ឡើងគ្រងពាជសម្បត្តិ តាំងពាជវង្សថ្មីហៅថា រាជវង្សស៊ុង ឬសង ដែលជាពាជវង្សធំរបស់ចិនមួយរាជវង្សទៀត ។

ព្រះបាទ ថៃ - ជឺ គ្រងពាជសម្បត្តិនៅក្នុងរវាងពុទ្ធសកពាជ ១៩០៣ ដល់ ១៩១៩ ជាវេលា ១៧ ឆ្នាំ ហើយតាំងពីពេលឡើងគ្រងពាជបល្ល័ង្ក ទ្រង់មានបំណងជំទៀងចាត់ ៦ ប្រការគឺរួបរួមអាណាចក្រឡើងជាថ្មីឲ្យបាន ហើយបណ្តេញពួកគី - តៃ ដែលចូលមកប្រែតវដ្តែក បង្កការចលាចលដល់ប្រទេសចិនជានិច្ចនោះ ឲ្យចេញពីអាណាចក្រចិនទៅ ។

ព្រះបាទ ថៃ-ដ៏ ព្រះមហាក្សត្រអង្គថ្មីនេះ ខ្ញុំមានព្រះទ័ស្សាហៈខ្លះខ្ញែងក្នុងហាន មានព្រះទ័យក្សេមក្សាន្តខ្លួលាយខ្ញុំជាមេទ័ពជាទ័គោរពបូជារបស់ពុហាន ហើយខ្ញុំជាព្រះរាជាធិកជ អាចជ្រាបជ្រាមពួកក្សត់ ធ្វើឲ្យការចលាចលខាងក្នុងប្រទេសស្ងប់រម្ងាប់ទៅបាន តែតែខ្ញុំមិនមានការសិក្សាយ៉ាងវិសេសមកទេ ប៉ុន្តែខ្ញុំសព្វព្រះទ័យនឹងខំខ្នុកបំរុងការសិក្សា សិល្បវិជ្ជា តាំងពេងរៀនរួចរួមតម្រាប់តម្រាវបស់ចិនមានតម្រាខុង-ជីជាដើម ។ កាលការចលាចលស្ងប់រម្ងាប់ទៅហើយ ពួជវង្សរបស់ ថៃ-ដ៏ ក៏ចំរើនរុងរឿងឡើងមួយរំពេច ។ អស់កាលវែលារាងមួយរយឆ្នាំ មុនថៃ-ដ៏ បានត្រងពួជសម្បត្តិ បណ្ណាកស្តួលទៅសឹងមានសេចក្តីស្រួលស្រែងញាប់ញ័រ ទ្វាចអំណាចពាហានចូលមកប្លន់ជាទីបំផុតដោយមិនបានដឹងពេលវេលាជាមុនឡើយ ។ ព្រះបាទ ថៃ-ដ៏ ខ្ញុំនឹងរកឧបាយកែអន្តរាយនេះបាន ដោយខ្ញុំព្យាយាមរកបំណាច់ផ្លាន់ ឲ្យពួកពាហានបានល្មមគ្រប់គ្រាន់មិនចាប់ឲ្យពួកពាហានដើរប្លន់អ្នកស្រុកទៀតៗ ព្រះបាទ ថៃ-ដ៏ មិនដែលប្រើឧបាយប្រឌុសពាយអ្នកណាឡើយ ។ នៅវេលាគ្រាមួយមានពួកក្សត្រជារាជិនអង្គ ធ្វើទុស្សត្រវាសព្រះបាទ ថៃ ដ៏ ខ្ញុំចាត់សុភប្រទានឲ្យក្សត្រអ្នកទោសមួយអង្គសោយ ។ ក្សត្រអ្នកទោសអង្គនោះ ស្នាមថាជាថ្នាំបំពុល (ព្រោះកងពួជសំណាក់ចិនវេលាធ្លាក់ទោសសម្លាប់មនុស្ស ច្រើនប្រើវិធីនេះជានិច្ច) ទើបពុត

ជង្គង់សូមជីវិត ព្រះបាទថៃ - ដី ទ្រង់ញញឹមហើយទ្រង់សោយសុពត្ថ
ពេនះដោយព្រះអង្គឯងទៅ ។

កាលព្រះបាទថៃ - ដី ទើបឡើងគ្រងរាជសម្បត្តិថ្មីៗនោះ ព្រះអង្គ
ទ្រង់ព្យាយាមរួបរួមខេត្តដែនផ្សេងៗ ដែលបែកខ្ញែកពីគ្នានោះមកបញ្ចូល
ក្នុងអាណាចក្ររបស់ព្រះអង្គក្នុងពុទ្ធសករាជ ១៩០៦ ទ្រង់ជ័យខេត្តហ្លួ - ប៉ែ
ន៉ឹងហ្លួ - ណាន ពុទ្ធសករាជ ១៩០៨ ជ័យខេត្តសេ - ធួន ពុទ្ធសករាជ
១៩១៤ ជ័យស្រុកកាំង - តាំង ពុទ្ធសករាជ ១៩១៨ ជ័យស្រុកណាំ -
កាំង ។ តែពួកសត្រូវដែលចាប់ចាមមិនទាន់សម្រេច គឺពួកហួន
នៅទិសខាងជើង ដែលពួកគឺ - តៃជាអ្នកឧបត្ថម្ភ ហើយចាំកេតុការ
ធ្វើការចលាចលរំលើកដល់ប្រទេសចិនជានិច្ច ។ ឯព្រះបាទថៃ - ដី ទ្រង់
ចំរើនទៅក្នុងពុទ្ធសករាជ ១៩១៩ នៅវេលាដែលស្តេចយាងទៅធ្វើ
បម្រាំងនឹងពួកហួនទិសខាងជើងនោះឯង ។

ព្រះបាទថៃ - ចុង, ជាព្រះអនុជរបស់ព្រះបាទថៃ - ដី ឡើងគ្រងរាជ-
សម្បត្តិជាដំណតមកក្នុងរវាង ពុទ្ធសករាជ១៩១៩ដល់ពុទ្ធសករាជ១៩៤០
ទ្រង់ចំរើនរាជកិច្ចតាមស្នាមលំអានព្រះរាជ្ជា ទាំងក្នុងស្រុកទ្រង់ចំនុក
បម្រុងការសិក្សារៀនសូត្រប្របួមតម្រាប់តម្រា ពាល់តែព្រះរាជបណ្តា-
ល័យហ្លួង មានសៀវភៅចំរើនឡើងដល់ ៨ ហ្មឺនក្បាល ហើយតម្រាប់
តម្រារបស់ខ្លួនដឹកជញ្ជូលលើកដំកើងយ៉ាងខ្ពង់ខ្ពស់ ក្នុងសម័យនេះ ។

ឃុនសុន្ទរមេធី ញ្ជង-សឿង ប្រែ

(តមក)

ខ្ញុំនឹងប្រែតឡប់ឲ្យទុសខុសនេះពុំបានទេឬយ៉ា, រឿងនេះ ចាំខ្ញុំជំរាបលោកឲ្យបានជ្រាប កាលពីល្ងាចមិញខ្ញុំមកផ្ទះនេះ ស្រាប់តែឃើញធ្នាក់ភ្លៅមួយយប់មាវ ១ នៅមុខខ្ញុំ ហើយគាន់តែរត់ចង្កៀបម្តង ១ ចាស់តែម្តុំនក្រមាំដាំដែលវាន់ឃាយជាក់កំហិតឲ្យខ្ញុំទាំងអម្បាលម៉ាន ខ្ញុំឥតៈក្តុចសោះ, ហេតុនេះ សូមលោកអញ្ជើញទៅចុះ ខុកខ្ញុំឲ្យខ្មៅតែងកន្ទែងដែលនេះបានហើយ" ។ លោកអគ្គមហាសេនាមិនថយចេញទៅតាមសំដីអាតមទេ កំតែឡប់ជាចាប់ជើងវាប្រែតែខ្លាស់ដាក់ឲ្យឈាស្លេលទៅវិញ; តាន់តែជើងជាប់ដល់ដីក្តាម អាខោះឥតដាន់ត្រាយចន្ទិចសោះ, បាតជើងសព្រាតកំឡាំងមានទាំងអម្បាលម៉ានយកតមកប្រែទាំងអស់ ឥតសំចៃយ, រត់ទៅចូលកាំងត្រាចខ្លួលព្រះកជាអេសុំប្តី តាមដំណើរសត្វត្រៃប់, ឆាលចើបានជ្រាបរឿងចិសាចរត្តីបាចក់ជូរុះ ព្រះអង្គក៏គោងងឿងធ្លុលជាខ្លាំងបំផុត ។

លោកសេមសេខនិន ម្ចាស់ហ្មេខ តឡប់ចូលទៅកន្លងចន្ទប់កូនស្រីវិញ ធ្លុលហើយហៅសែនមហាធ្លុលលើសជាងពីមុនទៅទៀត អំពីរឿងដែលលោងចន់ដឹង ។ លោកបានសួរក្តុនទៀតថា "នែមេកញ្ជោតល្ងី

ស្លើ! ហង្សគាចតឲ្យលន់តួរឿងកំប៉ិកកំប៉ុងសាមក់ាំនេះឲ្យអញបានយល់ ធ្វាយខ្លួយជាងនេះទៀតបានឬទេ?" ។ ជីតា: ទេលោកឪពុក, ខ្ញុំនឹងជាបលោកឪពុកឲ្យហួសអំពីរឿងដែលខ្ញុំបានដឹកបប្រពៃហើយ នោះពុំបានទេ ព្រោះខ្ញុំដឹងតែត្រឹមប៉ុណ្ណោះ ប៉ុន្តែ នេះត្រឹងសំលៀក បំពាក់ប្តីខ្ញុំដែលគាត់ដោះដាក់លើកៅអី, សំលៀកបំពាក់នេះប្រហែលជានឹងគាចបំភ្លឺសេចក្តីឲ្យលោកឪពុកបានយល់ខ្លះពុំខាន; ថាហើយនាង ត័យកឆ្នែតដៃ ដែលខ្លួនមកបង្ហាញឪពុក។ ខ្លួលពិនិត្យមើលសព្វគ្រប់រួច ហើយ លោកនិយាយថា "ឆ្នែតនេះប្រសិនបើមិនមែនជារបស់ចំនើមមក ពីស្រែកមួសុ្សលេខ, អញយល់ថាជាឆ្នែតសម្រាប់មន្តិធ" ។ កាល លោកចាប់បង្ខិលពិនិត្យមើលសព្វគ្រប់ទៅ ប្រទះឃើញជួបជារបស់អ្វី មួយតេរដោក់បញ្ចូលក្នុងបង្អោះស្រទាប់ស៊ីតត់ដែលគ្រួតគ្នា, លោកក៏ ឲ្យ តយកឯកន្ត្រៃមកឲ្យដើម្បីនឹងគាត់មើល, លុះកាតថ្នរួចហើយ បាន ឃើញក្រដាសផ្ទាត់ តជាសៀវភៅដែលខ្លួរេខិន-អលី បានឲ្យមក ថេរេខ្លួនក្នុងពេលរៀបស្ងាប់ ហើយថេរេខ្លួនក៏យតមកដេរដាក់ បង្គប់លាក់ពុកក្នុងបង្អោះស្រទាប់ឆ្នែតនេះ ដើម្បីរក្សាពុកឲ្យបានវិតថរ។ សេមសេខិន ម៉ូហាម្មេ លុះបានចេតសៀវភៅនោះមើលហើយទើប បានស្គាល់អក្សរខ្លួរេខិន-អលី ជាប្អូន ហើយលោកក៏អានចំណងដើង សៀវភៅនោះថា "សម្រាប់កូនខ្ញុំ ឈ្មោះថេរេខ្លួនហាស្សន" ។

លោកកំពុងតែត្រិះរិះដូច្នោះ ស្រាប់តែកូនស្រីយកថង់ថ្នាក់ដែលខៅក្នុង
អាវមកហុចឲ្យលោកទៀត លោកបើកមើលខៅ ឃើញមានហាបណៈ
ខៅពេញជួចបាននិយាយរួចមកហើយ, តោះបើបេក្ខជនជាស្ម័ន
មានចិត្តសទ្ធាជ្រះថ្លាកហាបណៈ ចែកចាយឲ្យគេជាច្រើនក៏ពិតមែន ប៉ុន្តែ
ថង់នោះនៅតែមានធនហាបណៈពេញដដែល ដោយអំណាចឫទ្ធិរបស់
ចិសាចនីនាងខេពជតា ។ លោកបានមើលពាក្យដែលសរសេរលើស្លាក
ថង់ថ្នាក់នោះឃើញមានសេចក្តីថា: "ថ្នាក់មួយពាន់កហាបណៈ: បេស់
ជាតិស្ទីហ្គ៍ឈ្មោះអ៊ុសាអ័ក" ហើយបានឃើញពាក្យដែលអ៊ុសាអ័កបាន
សរសេរមុនទីដែកគ្នាពីបេក្ខជនជាស្ម័ន មានសេចក្តីដូចខាងក្រោម
នេះ "បានប្រគល់ឲ្យបេក្ខជនជាស្ម័ន ដើម្បីជាជម្រើសនិញលើកដំបូង
ក្នុងសំពៅចាំងអស់បេស់លោកទូរេជនអល ជាបិតាដែលបេក្ខជនជា
ស្ម័ន បានលក់ឲ្យ កាលណាសំពៅនិញចាំងនោះទីបចូលមកបតនៅ
ទីនេះ" ។ លោកមើលសេចក្តីនេះមិនចាន់ចាំងចប់ផង ស្រាប់តែ
ស្រែកខ្លោយហ៊ោខ្ទើងហើយសន្ធប់ផ្តាត់មាត់ឈឺងសូន្យទៅ ។

មួយស្រែបក់ លោកសេមសេជនជ ម៉ូហាម្មេ បានដឹងខ្លួនខ្ទើងវិញ
ដោយសារកូនស្រីទីងំស្រីបំរើនាំគ្នាមកជួយឈូស ។ លោកបាននិយាយ
ទៅកាន់ដីកាថា "កូនស្រីមាសខ្ចីពុកអើយ, កូនមិនត្រូវសង្ស័យខេអំពីរឿង
ដែលខ្ចីពុកសន្ធប់ផ្តាត់មាត់ផ្តាត់តនេះ; ដើមចមដូច្នោះ កូនឯងសឹងតែ

ដើម្បីពុំកើត ; ប្តីដែលបានដេកជាមួយគ្នាពីយប់មិញនេះត្រូវជាបងប្អូនដ៏ជូនមួយ គឺជាកូនទូរទេវ៉ិន អលី ។ ច្រាក់មួយទាន់តហាបណៈ នៅក្នុងថង់នេះធ្វើឲ្យអញនឹកលឹកដល់រឿងដែលអញបានបង្កបង្កើតជាមួយនឹងប្អូនសំឡាញ់នោះ គឺជារឿងបណ្ណាការនៃអាពាហ៍ពិពាហ៍ដែលវាបានរៀបចំឲ្យកូនឯង, យើងសូមថ្វាយសេចក្តីអរព្រះគុណយ៉ាងវិសេសចំពោះព្រះជាម្ចាស់, រឿងដ៏ចំឡែកនេះឯងហើយដែលសំដែងឲ្យឃើញនូវឫទ្ធិអំណាចរបស់ព្រះអង្គ!" ។ លោកអគ្គមហាសេនា មើលសំបុត្រប្អូនលោកតទៅទៀត ហើយយកសំបុត្រនោះមកថើបជាច្រើនលើកច្រើនគ្រា ទង្គិះទ្បាំក្បាលសម្រក់ទឹកភ្នែកស្តើរសែញកបែកទក ទើបលោកមានវាចាថា "ធ្វើដូចម្តេចហ្ន៎ ទើនឲ្យខ្ញុំបានបួបប្អូនទូរទេវ៉ិនចំពោះមុខនៅថ្ងៃនេះ ហើយខ្ញុំនឹងនិយាយលួងលោមផ្សះផ្សាជាមួយនឹងវា!" ។

លោកមើលសៀវភៅនោះត្រង់ទំព័រម្ខាងទៀត ឃើញកំណត់ថ្ងៃ - ខែដែលប្អូនទៅដល់ក្រុងចាល់សូរ៉ា, ថ្ងៃខែរៀបអាពាហ៍ពិពាហ៍ត្រមាំងថ្ងៃ - ខែ - ឆ្នាំកំណើតរបស់បេត្រូទូនិនហាស្ស៊ែន; លុះបានពិនិត្យគៀបគ្នាមើលទៅ ក៏បានឃើញថាត្រូវគ្នាទើងថ្ងៃ - ខែ - ឆ្នាំនៃអាពាហ៍ពិពាហ៍របស់ប្អូន, ស្របគ្នាទើងឆ្នាំកំណើតនៃឪពុកលោកនៅក្រុងកែវដែរ, ទើបលោកមានសេចក្តីគោតស្បថស្បែងណាស់ចំពោះរឿងនេះ ព្រោះហាក់ដូចជាបានឲ្យដំណឹងគ្នាទៅវិញទៅមក, ក្នុងទីបំផុតលោកពិចារណា

ឃើញថាកុយបង្កើត ចានមកជាកូនប្រសាលោក។ ក៏សំដែងសេចក្តីវិត
កយសប្បាយយ៉ាងក្រៃលែង ។ លោកុសេនាបតីកាន់សៀវភៅទឹងស្វាក
ថង់ប្រាក់យកទៅគ្រាបបង្គំទូលព្រះរាជា, ទ្រង់ចានព្រះរាជានុញ្ញាតលើក
ទោសចោលកំពោះរឿងដែលកន្ធរទៅហើយ ។ លុះចានជ្រាបការណ៍
សព្វគ្រប់ ព្រះអង្គទ្រង់សព្វព្រះរាជហឫទ័យគ្រាស់ឲ្យរាជបណ្ឌិតសរសេរ
រឿងនោះចាំងអស់ ដើម្បីទុកឲ្យមានជាតំណាប់តទៅក្នុងអនាគតកាល ។

គ្រានោះ លោកសេមសេខុិន ម៉ូហាម្មេទ មិនយល់សោះអំពីរឿង
ដែលកូនប្រសាលោកប៉ាត់ខ្លួនទៅនេះ, ប៉ុន្តែ លោកនៅតែសង្ឃឹមភាល់។
ពេលថាមុខជាទឹងចានឃើញមកដល់វិញក្នុងថ្ងៃណាមួយពុំខាន ទើប
លោកគ្រាន់តែចាំមើលផ្លូវ ដើម្បីទឹងទុបក្រសោចថ្នាក់ថ្នមកូនប្រសា ។
លុះគ្រាចាំដោយឥតប្រយោជន៍យ៉ាងនេះអស់មួយសប្តាហ៍, លោកក៏ចាត់
មំរើឲ្យដើរស៊ើបសួរកេតាសពេញទាំងក្រុងកែវ, ប៉ុន្តែ ឥតចានដំណឹង
ចន្តិចចន្តួចសោះ, លោកមានសេចក្តីតប់ប្រមល់ព្រួយក្រៃណាំខានចិត្ត
ជាទីបំផុត មិនដឹងជាធ្វើដូចម្តេចទឹងចានដឹងរឿងនោះ ។ លោកអត់
ក្រាំពុំចានទើបលាន់មាត់ថា "ឧហ្ម៎! រឿងនេះចានចំជាបំរែកមែន
រឿងបែបនេះ ឥតមាននរណាធ្លាប់ចានដឹងចានឮម្តងសោះ!" ។

ដោយពិចារណារករឿងដែលទឹងកើតមាននៅក្នុងអនាគតពុំឃើញ
ច្បាស់ដូចម្តេចណា ទើបលោកអគ្គមហាសេនាចាប់សរសេរកត់ត្រាទុក

អំពីរបៀបផ្ទះសម្បែងរបស់លោក ក្នុងពេលនោះគឺដូចម្តេចខ្លះ គឺដំណើរ
រៀបអាពាហ៍ពិពាហ៍ដែលកន្លងហួសទៅហើយ មានបែបផែនយ៉ាងណា
បន្ទប់ធំទំនើបបន្ទប់តូចសម្រាប់កូនស្រី តាក់តែងដោយគ្រឿងលំអដូចម្តេច
សំលៀកបំពាក់ទំនើបថ្មីប្លែកបែបបែរខ្លះជាក់ស្តែងណា លោកបាន
កត់ត្រាទុកពាំងអស់ រួចហើយលោកយកឈ្នួត ព្រមទាំងថង់ប្លែកទំនើប
សំលៀកបំពាក់ដែលទៅកន្លងមកវេចរុំខ្ចប់ស្រួលបួល ហើយយកទៅចាក់សោទុកក្នុងហិបវិញ ។

កន្លងវែងយូរថ្ងៃបន្តិចមក ធីតាលោកសេមសេខនិន ប៊ូហាម្មេ ដឹងថាខ្លួនមានផ្ទៃពោះ; លុះទ្រង់គភ៌គ្រប់ ៩ ខែហើយនាងក៏ប្រសូតកូនប្រុសមួយ ។ គេបានឱតាំងកែមេដោះម្នាក់ព្រមទាំងខ្ញុំកំដរប្រុសស្រីជាច្រើន សម្រាប់ថែទាំផ្គត់ផ្គង់ថាកៃ តាមសមគួរដល់ហាន:ជាអ្នកមានត្រកូលខ្ពង់ខ្ពស់: ជីតាបានឲ្យឈ្មោះថា អាយិប ។

កាលអាយិបកុមារ មានវ័យវិឌ្ឍនាការចំរើនធំឡើងបានអាយុប្រហែល ៧ ឆ្នាំ លោកសេនាបតីសេមសេខនិនម៉ូហាម្មេ មិនបង្ហាត់បង្រៀននៅផ្ទះទេ បានយកទៅឲ្យចូលសាលារៀនផ្ញើទុកជាក់ទំនិតម្នាក់ដែលមានកិត្តិយសដ៏ខ្ពង់ខ្ពស់ ហើយឲ្យបាតើនាក់សម្រាប់ជូនទៅសាលាទំនាំមកផ្ទះវិញរាល់ៗថ្ងៃ ។ អាយិបតែងលេងជាមួយនឹងពួកសិស្សជាគួរគន្លងាំងពុយតាមធម្មតា សិស្សទាំងអស់នោះសុទ្ធតែមានហាន:ខ្លាចប

ទើបត្រូវធ្វើសេចក្តីគោរពកោតខ្លែងអាយ៉ងបន្តិចៗគ្នា; ហើយពុកអាយ៉ងហាក់ដូចជាគ្រូដែលអាចបង្ហាប់បញ្ជាកិច្ចការទ្រង់ដំពូកបាន ។ កាលបើសិស្សតាំងឮយ៉ងមានសេចក្តីកោតខ្លាចយ៉ាងនេះ អាយ៉ងក៏ឡើងដៃកើតមានវង្គ្គឹងគ្រហើនក្រអឺតក្រអោងកោងកាចឥតខ្លាចនរណាសោះ តែងធ្វើទុក្ខបុកម្នេញឲ្យគេក្តៅក្រហាយជានិច្ច គឺវាត្រួតត្រាបំបាក់គេតាំងអស់ហើយប្រសិនបើមាននរណាមួយហ៊ានដាក់ខ្លួនតវ៉ាទល់នឹងបំណងរបស់វា ដេរប្រទេចផ្តាសាដោយប្រការផ្សេងៗ ហើយចួនកាលចានដល់ទៅវាយដំចំគាក់គេទៀតផង ។ ដល់ទៅក្នុងទីបំផុត សិស្សតាំងអស់អត់ទ្រាំពុំបាន នាំគ្នាចូលទៅដាក់បណ្តឹងគ្រូបង្រៀនអំពីដំណើរអាយ៉ងត្រហើនកោងកាចពេក ។ មុនដំបូងអាចារ្យទន្ទិយាយសម្រុះសម្រួលលួងលោមសិស្សតាំងនោះឲ្យទំអត់ធ្មត់ទៅ , ប៉ុន្តែលុះឃើញអាយ៉ងវាតែតែឡើងដៃធ្វើបាបគេខ្លាំងឡើងៗ តាំងខ្លួនអាចារ្យឯងក៏អត់ទ្រាំពុំបាន មានសេចក្តីលំបាកតឹងចិត្តណាស់ទើបអំពាវនាវដូច្នោះ ទើបនិយាយទៅសិស្សតាំងឮយ៉ងថា: "ខ្មែអ្នកតាំងអស់គ្នា! យើងឃើញច្បាស់ជាកដថាអាយ៉ងជាកុមារត្រហើនណាស់, យើងនឹងជាប់ៗជាយមួយដើម្បីនឹងធ្វើវាឲ្យអាម៉ាសមុខ ហើយឲ្យវាលែងធ្វើបាបអ្នកតាំងអស់គ្នាតាមសេចក្តីស្មានរបស់យើងថា តាលបើអ្នកតាំងឮយ៉ងធ្វើតាមៗជាយ៉ងនោះទៅ វាមុខជានឹងលែងមករៀនក្នុងសាលានេះបានទៀតហើយ ។

ថ្ងៃស្អែក, ដល់ពេលដែលទឹងត្រូវប្រជុំគ្នាលេងតាមធម្មតា អ្នកទាំងអស់គ្នាត្រូវឈរពោមព័ទ្ធអាយប ហើយឲ្យនរណាម្នាក់ចាប់ទិយាឃឡើងដោយសំឡេងយ៉ាងឮតេញ៉ចំហាងថា :

"ឥឡូវនេះ ពួកយើងត្រូវប្រជុំគ្នាលេង, ប៉ុន្តែត្រូវមានខ្សន្យាគឺអ្នកដែលចង់លេងជាមួយទឹងយើង គប្បីត្រូវចាប់ឈ្មោះខ្លួនទឹង ឈ្មោះផ្កាយឲ្យបានដង្កៀរៀបៀវមក ទើបយើងបើកឲ្យចូលលេងជាមួយផង, បើអ្នកណាមិនត្រូវចាប់ឈ្មោះដូចបាននិយាយហើយនោះទេ យើងមិនត្រូវឲ្យអ្នកនោះលេងជាមួយឡើយ" ។

សិស្សទាំងឡាយ លុះបានឮសូលៗប្រាប់អំពីសំណាក់គ្រូយ៉ាងនេះហើយ ក៏នាំគ្នាលៀវទៅកាន់លំនៅរៀងៗខ្លួនដោយសេចក្តីរីករាយ ។

ស្អែកឡើង គ្រាដែលចួបជុំគ្នាអស់ហើយ សិស្សទាំងនោះតាំងផ្តើមធ្វើកិច្ចដែលគ្រូបានឲ្យលំរួចហើយ គឺឈរចោមរោមព័ទ្ធអាយបហើយ សិស្សម្នាក់ចាប់ប្រកាសឡើងថា "មកវិញ យើងនាំគ្នាលេងល្បែងមួយ ប៉ុន្តែបើអ្នកណាមិនចាប់ឈ្មោះខ្លួនទឹងឈ្មោះម្លាយផ្កាយ យើងមិនត្រូវឲ្យអ្នកនោះលេងចូលឡើយ' ។ គេធ្វើយយល់ព្រមទាំងអស់គ្នាទាំងអាយបក៏យល់ព្រមដែរ ។ ខណៈនោះសិស្សដែលក៏ចាប់សួរឈ្មោះគួរនទាំងអស់តាមលំដាប់ហួរហែ គេបានធ្វើយត្រឹមត្រូវតាមសេចក្តីសន្យាទាំងដើម ចំណែកទាងអាយប កាលគេសួរដល់ឈ្មោះខ្លួន

ហើយ ក៏ឆ្លើយថា "ខ្ញុំឈ្មោះអាយិប ម្តាយខ្ញុំឈ្មោះ ដាមដីប៊ូតេ (នារ៉ោមយ៉ង់) ឧត្តុកឈ្មោះ សេមសេខិន ម៉ូហាម្មេខ មានងារស័ក្តិជា អគ្គសេនាបតីនៃព្រះពាជា" ។

និមិត្តតែពួកពាក្យនេះភ្លាម កុមារទាំងឡាយស្រែកឡើងថា "នែអាយិប អ្នកនិយាយអ្វីដូច្នេះ? មិនមែនឈ្មោះឧត្តុកអ្នកឯងទេ គឺជាឈ្មោះដីតាអ្នកទេតើ" ។ អាយិបឆ្លើយវិញដោយច្រឡោតខឹងថា "ខ្ញុំ! ទេពួកបំភាន់អ្នកទាំងអស់គ្នាហើយ ពួកអ្នកហ៊ាននិយាយថាលោកសេមសេខិន ម៉ូហាម្មេខមិនមែនជាឧត្តុកយើង!" ។ សិស្សទាំងឡាយឆ្លើយត្រមទាំងអស់សំណើចផងថា "មិនមែនទេ ខុសស្រឡះហើយ លោកសេមសេខិន ម៉ូហាម្មេខត្រូវជាដីតារបស់អ្នកទេតើ ហេតុនេះអ្នកទំងចូលលេងជាមួយពួកយើងពុំបានឡើយ ពួកយើងក៏ប្រយ័ត្នខ្លួនមិនចូលទៅជិតអ្នកដែរ ថាដូច្នោះហើយ គេនាំគ្នាដកយ្លោះយកចេញឆ្ងាយពីអាយិប ចំអកចំអន់លេងហើយសើចហាន់ៗតែគ្នាគេ អាយិបមានសេចក្តីអាម៉ាស់អុ្វ កើតទុក្ខគោមនស្សក្តៅក្រហាយឈឺចិត្តខ្លាំងណាស់ ព្រោះការចំអកឡកឡឺយមើលងាយរបស់សិស្សទាំងឡាយ រកធ្វើអ្វីគេពុំកើត ក៏តាំងយំតែម្នាក់ឯង ។

អាចារ្យ បានស្តាប់ដឹងព្រឿងនោះដាក់ប្រាកដចំពោះខ្លួន ទើបនិយាយនឹងអាយិបថា "នែអាយិប អ្នកមិនគាប់ដឹងជាលោកសេម-

សេខ៉ិន ម៉ូហាម្មេទ មិនមែនជាឪពុកអ្នកទេឬ? លោកត្រូវជាដីតាអ្នក
គឺជាឪពុកនាងនារីតោមយង់ម្តាយអ្នកទេតើ ចាំងយើងកំដូចអ្នកដែរ
មិនបានស្គាល់ឈ្មោះឪពុករបស់អ្នកទេ, យើងដឹងរឿងតែប៉ុណ្ណោះថា:
ព្រះពាជាខ្ញុំបានផ្សំផ្សុំរៀបចំធ្វើអាពាហ៍ពិពាហ៍ម្តាយអ្នកជាមួយនឹងបុរស
តមម្នាក់ជាគង្វាលសេះរបស់ព្រះអង្គ ប៉ុន្តែមានបិសាចមួយមកដេកជា
មួយនឹងនាងវិញ; រឿងនេះឯងហើយដែលនាំបណ្តាលឲ្យអ្នកប្រកាន់
មានះតឹងតែងកាចយោរយៅធ្វើបាបគូកនចាំងឡាយ ដកចមកដល់ពេល
នេះ ។

អាយិបកុមារ ត្រូវគេចំអកដៀមជាមឲ្យដូច្នេះហើយទំពាយចិត្ត
ណាស់ ចេញពីសាលាយ៉ាងប្រញាប់ត្រឡប់ទៅផ្ទះយំបណ្តើរដើរ ។
ទៅដល់ក្នុង ចូលទៅកន្លែងបន្ទប់ម្តាយ។ ឃើញកូនយំតើតទុក្ខមុខត្រៀម
តែដូច្នោះ ក៏ខ្ញុំកខ្វួលអួលអន់សម្រក់ទឹកភ្នែក ហើយសួរតេដំណើរ
ដើមទង់យ៉ាងរួសរាន់ ។ អាយិប ធ្វើយេចាំងយំអណ្តឹតអណ្តកព្រោះ
តឹងណែនដើមទ្រូងដោយសេចក្តីឈឺចិត្ត ចាប់ផ្តើមរៀបរាប់អំពីហេតុការ-
ម៉ាស់មុខ ព្រោះតែមានគេមើលងាយដូចជាបានឱ្យហើយខាងដើម ។
រួចហើយអាយិបសួរម្តាយថា "អ្នកម្តាយ! សូមអ្នកប្រាប់ខ្ញុំឲ្យត្រង់កុំលាក់
ប៉ុនណាដែលត្រូវជាឪពុកខ្ញុំ។" ។ នាងនារីតោមយង់តបវិញថា
"កូនប្រុសពន្លក! ឪពុកអ្នកគឺលោកសេមសេខ៉ិន ម៉ូហាម្មេទហ្នឹងឯង

ហើយដែលតែងនុចត្រៃសោចប័ថ្មមអ្នកពល់ៗថ្ងៃ" ។ អាយ៉ប "អ្នកម្តាយ អ្នកជ្រាបខ្ញុំមិនត្រង់ មិនមែនខុពុកខ្ញុំទេ ជាខុពុកអ្នកម្តាយទេតើ ចំណែកខាងខ្ញុំ ជាកូនអ្នកណាវិញ?" ។ ម្តាយបានឮសំដីកូនដូច្នេះ នឹកឃើញដល់ពេលកន្លែដែលតាំងតែចាប់រៀបមង្គលការហើយមក កំពៅមេម៉ាយអស់កាលដ៏យូរ មិនដឹងជាប្តីនាងនោះត្រាត់ជ្រាសចាត់ទៅឯណា នឹកស្រេងស្រេងស្រោចអាណោច អធ័មយំខ្សឹកខ្សួលអួលអន់សម្រែកនឹកក្អែកដោយសេចក្តីសោកស្តាយអាល័យប្តីសំឡាញ់ ដែលជ្រាសនិរាសឃ្លាតចាត់ទៅកេមុខចាតពុំឃើញ និងហាមាត់ជ្រាបកូនដូចម្តេចខ្លែតក៏មិនរួច ។

កន្លះណ: ដែលនារីនោមយ៉ងកំពុងសោកជាកន្លួនទៅក្បែរអាយ៉ប លោកសេមសេនឹង ម៉ូហាម្មេ កំប្លែទៅចាន់ហើយសួរកេហេតុសេចក្តីទុក្ខព្រួយនៃអ្នកទាំងពីរ ។ នារីបានសារសំតូដំរាបបិតា អំពីរឿងអាយ៉ប តាមហ្មូរហែស់តូគ្រប់ ។ ដំណើរនេះនាំបណ្តាលឲ្យលោកអគ្គមហាសេនាកើតសេចក្តីកុកកួលអួលដើមទ្រូងមិនបាត់ពុំបាន កំតាំងសោកសង្រេងសង្រែជាមួយគ្នា ដោយពិចារណាឃើញថាអ្នកទាំងពួងនិយាយបង្ខូចកេរ្តិ៍ឈ្មោះកូនស្រីលោក លោកកំនឹកសង្វែគស្រយុតចិត្តណាស់ចំពោះរឿងនោះឯង ។ លុះគិតឃើញដូច្នោះហើយទើបលោកប្លែទៅកាន់ព្រះបរមរាជវាំង ក្រាបថ្វាយបង្គំច្រណែនខ្លែបព្រះបាទានៃព្រះករុណា

ជាម្ចាស់ដីវិត ខ្ញុំសូមព្រះពរជាខ្ញុំញាតធ្វើដំណើរទៅកាន់ខេត្តខ័ណ្ឌនៃ
បច្ចិមប្រទេស ហើយទៅកាន់ក្រុងឆ្ងាល់សូពជាដើមជង ដើម្បីស្វែងរកបេក្ខខិនហស្ត្រនៃក្សត្រយោកឲ្យឃើញ ដ្បិតអ្នកក្រុងទាំងមូលយល់គ្រប់គ្នាថា បើសាចមួយបានដេកវួមសង្វាសជាមួយនឹងនារីដោមយង់កូនស្រីលោក នាំឲ្យលោកនឹកដោមនស្ត្រូតូចចិត្តជាខ្លាំងបំផុត ។ ព្រះពជាកំមានព្រះហឫទ័យអាណិតលោកអគ្គមហាសេនា បានទ្រង់ព្រះពជាខ្ញុំញាតប្រើសប្រទានតាមបំណង ហើយបានបេញសុកអក្សរសាសន៍ឲ្យព្រះហស្តលេខាប្រថាប់ព្រះរាជ្ញាកព្រះពជទានចំពោះអគ្គមហាសេនា សេចក្តីកង់សុកអក្សរសាសន៍នោះគឺថ្វាយដំណឹង - ឲ្យដំណឹងដល់ព្រះពជានឹងនាហ្នឹនសព្វមុខមន្ត្រីក្នុងតំបន់នានា ដែលបេក្ខខិនហស្ត្រនៃបានចូលទៅនៅអស្រ័យ ដើម្បីឲ្យយល់ព្រមអនុញ្ញាតបើកឲ្យលោកអគ្គមហាសេនាធំ ឆកទៅដោយស្រួលបួល កុំបីចាប់ទោសអូសដំណើរដូចម្តេចឡើយ ។

លោកសេមុសេខិនម៉ូហាម្មេដ រកនឹកពាក្យថ្លែងអំណរព្រះគុណចំពោះព្រះពជាពុំឃើញ គ្រាន់តែគ្រាបប្រណម្យចំពោះព្រះកត្តិដ៏ជាតំបៅពីដេងប៉ុណ្ណោះ ប៉ុន្តែទឹកភ្នែកដែលហូរហៀរចាកនេត្រាលោកមកនោះគឺសំដែងសេចក្តីដឹងព្រះគុណដ៏លើសលុបដ៏ខ្ជួសពាក្យសំដីរបស់លោក ។ រួចហើយ លោកថ្វាយបង្គំព្រះពជាលាត្រឡប់ទៅផ្ទះវិញ

ដល់ហើយក៏រៀបចំគ្រឿងប្រដាប់ប្រដាបំរុងដំណើរទៅដោយរួសរាន់ ។ ការប្រុងប្រៀបឲ្យរៀបចំអីវ៉ាន់ទាំងនោះ រួចកល់សព្វគ្រប់ក្នុងរវាង ៤ ថ្ងៃ លោកក៏ចេញទៅមួយអន្លើដោយទាន់ពារ៉ាគោមយន៍ នឹងអាយ៉ងចៅរបស់លោក ។ ជនទាំងនោះគ្រាច់ទៅអស់ ១៩ ថ្ងៃ តតឈប់សម្រាកនៅកន្លែងណាមួយឡើយ លុះដល់ថ្ងៃគំរប់ ២០ ទ្បានដល់ទៅកន្លែងវាលស្មៅមួយដ៏ស្អាតនៅឆ្ងាយបន្តិចអំពីភ្នំក្រែងជាម៉ាស់ ទើបឈប់ចោះដម្រាំក្បែរមាត់ព្រែកមួយដែលហូរកាត់ទីក្រុង ហើយមានទំហំមាត់ច្រាំងជុំវិញស្អាតធ្វើគួរឲ្យពិតពិលរមិលមើល ។

លោកសេមសេនឱនមូហាម្មេទ្បានគិតសម្រេចថា លោកនឹងនៅសម្រាកក្នុងទីនោះចំនួន ២ ថ្ងៃសិនដល់ថ្ងៃទី ៣ សឹមធ្វើដំណើរតទៅទៀត ។ ពេលនោះលោកបើកអំណាចដល់ពួកមនុស្សដែលទៅតាមលោក ឲ្យចូលទៅក្នុងក្រែងជាម៉ាស ដើម្បីស៊ើបដំណឹងក្រែងបួនជាបេក្ខែតឱនហស្សានៅទីនោះ; ដោយទ្បានអំណាចច្បាប់ដូច្នេះ អ្នកខ្លះក៏ដើរលេងតំសាន្តសប្បាយមើលទីក្រុងដែលខ្លួនធ្លាប់ឮគេនិយាយថា ជាទីក្រុងស្តុកស្តម្ភពេញថ្កើង ។

(មានត)

អ្នកឧកញ៉ាវិបុលរាជសេនា (ឆ្នូ - កង)

(តមក)

ទាំង ៣ នាក់ដែលធ្វើខុសកងកងពលបញ្ជូនចូលទៅ ។ ណៈនោះខ្ញុំពីរ
ទៅដល់កណ្តាលផ្លូវ ឃើញតិត្តិសព្ទថា ចៅហ្វាយស្រុកតេង-ជីវ ចេញ
សំបុត្រឲ្យស៊ើបចាប់ខ្លួន បើទឹងស្រុតទៅឲ្យដល់ស្រុកខ្លួនគួនត្រែងមិន
ទាន់ ខ្ញុំពីដឹងថា ខ្ញុំកេងដែលជាចៅហ្វាយស្រុកតៃដីវជាសែងា
មួយគ្នាទើបគិតថា បើដូច្នោះយើងត្រូវចូលទៅអស្រ័យនៅទឹងខ្ញុំកេង
នៅសិនចុះទើបផុតភ័យ គិតហើយក៏នាំកូនអ៊ូតៀវហ៊ុយទឹងបក្ខពួកចូល
ទៅកេខ្ញុំកេងនៅស្រុកតៃដីវ ដល់ហើយក៏ពណិនាប្រាប់សេចក្តីនៃ
រឿងខ្លួនឲ្យខ្ញុំកេងស្តាប់ ខ្ញុំកេងដឹងកងសំបុត្រចៅហ្វាយស្រុកតេង
ដីវ ត្រូវគ្នាទឹងពាក្យ ខ្ញុំពីប្រាប់ដូច្នោះ ក៏ទឹកអាណិតខ្ញុំពីពន់ពេក
ព្រោះជាសែងាមួយគ្នាហើយជាពូជព្រះវង្សផង ទើបខ្ញុំកេងបំពួនខ្លួន
ខ្ញុំពីកូនអ៊ូតៀវហ៊ុយឲ្យនៅកងផ្ទះ ។

និយាយពីខ្ញុំ ១០ នាក់នោះ ព្រះចៅឡេនតេទង់ត្រាស់ប្រាណ
ណាស់ ទឹងស្រែដឹងិយាយកិច្ចការអ្វីក៏សំរេចដូចចិត្ត ទើបតៀវកុងតៀវ
យឿង ១ខ្ញុំពាំង ២ នាក់ ឲ្យបម្រើទៅនិយាយការដល់មន្ត្រីនាយទាហាន
ដែលចុះទៅកម្រាបពួកអាចោរដួតក្បាលលឿងនោះថា បើអ្នកឯណា

មានទ្រព្យរបស់ជាមាសប្រាក់ ហើយយកទៅជូននាយចៅហ្វាយយើង នោះនាយចៅហ្វាយយើង នឹងជួយក្រាបបង្គំទូលឲ្យបានឡើងឋានសក្តិតាមគុណបំណាច់ បើអ្នកឯណាមិនបានគិតគួរសមនឹងនាយចៅហ្វាយយើងទេ នឹងទូលបង្គំសឲ្យថ្កំរយសស័ក្តិខានធ្វើមន្ត្រីខ្ញុំរាជការតទៅ ។ ខណៈនោះហង់ហ៊ីកូនឹងដូហ៊ីជានាយទាហានធំ បានស្តាប់សំដីបំរើពោលដូច្នោះ ក៏ទាស់អធ្យាស្រ័យណាស់មិនទទួលធ្វើតាមពាក្យពន្យល់សោះ ។ តៀវគុង តៀវយៀងក៏រៀងទូលញុះញង់ព្រះចៅឡេនតេឲ្យដកហូតងារហង់ហ៊ីកូនឹងដូហ៊ីចេញចាកតំណែងរាជការ ព្រះចៅឡេនតេក៏ទ្រង់ធ្វើតាមហើយតាំងតៀវគុង តៀវយៀងឲ្យឡើងធំជាមន្ត្រីធំតាំងអស់ ។ រំលោះនោះរាជការផែនដីក៏ប្រែត្រឡប់ផ្លេសផ្លាសជាខ្លាំងណាស់ អស់អាណាប្រជានុកស្តីទាសករតាំងឡាយ ក៏តេតក្តៅក្រហាយខ្លួនចំពោះព្រះរាជធានី ។

ឈ្មោះកូសេងពួកចោរដួតក្បាលលឿន រត់ទៅនៅស្រុកតៀងសាបញ្ជុះបញ្ចូលបបួលពួកអ្នកស្រុក ដើរលួចប្លន់ដណ្តើមទ្រព្យ កាប់សម្លាប់អាណាប្រជានុកស្តីតាំងពួនជារច្រើនតំបន់ គ្មានអ្នកឯណានឹងរិះគិតសង្កត់សង្កិនឲ្យកបាបសោះឡើយ ឈ្មោះតៀវតៃ តៀវស៊ុនទៅស្រុកយីយ៉ុង ក៏តាំងបញ្ជុះបញ្ចូលពួកប័ក្ខជនបានជារច្រើនហើយ គិតក្បត់ តៀវតៃនោះតាំងខ្លួនធ្វើជាស្តេច - តៀវស៊ុនជាសេមាបតីធំធ្វើការ

អាត្រកំពៅផ្សេងៗ ពួកចៅហ្វាយស្រែកទាំងពួងដំណាណ៍ កំធ្វើសំបុត្រ
បកប្តឹងជូលទៅស្រុកក្រុងជារាច្រើនគ្រា ១ខ្ទី ១០ នាក់បិទសេចក្តីនោះខុក
មិនបានត្រាបបង្គំទូលព្រះចៅឡនតេត្រង់ជ្រាបសោះ ។

មានកាលមួយថ្ងៃ ព្រះចៅឡនតេស្តេចចេញទៅប្រពាតសួនចម្ការ
ត្រង់សោយសុភជ័យនៅទីនោះ ឯ១ខ្ទី ១០ នាក់កំអង្គុយផឹកនៅមុខព្រះ
ទីនាំង ។ ខណៈនោះ ឡៅ)គោជាកំលៀងស្តេច ដឹងថាពួកចោរកំរើប
ក្បត់ឡើងទៀត ព្រះចៅឡនតេ មិនបានត្រង់ជ្រាបឡៅ)គោមានចិត្ត
ចារម្ភណាស់កំតាមស្តេចទៅកន្លងសួន ព្រះចៅឡនតេទតឃើញកំត្រាស់
សួរថា ឡៅ)គោធ្វើទឹកមុខបែបមានភ័យក្តួលមកមានការអ្វី។ ឡៅ)គោ
ក្រាបបង្គំទូលថា ព្រះអង្គមិនត្រង់ជ្រាបឬទេ ? ឥឡូវនេះ ត្រួបខេត្តខ័ណ្ឌ
ទាំងពួង កើតចលាចលទៀតហើយ ស្រែកគន់អន្ទក់យជាច្រើនកដ ហេតុ
ម្តេច ព្រះអង្គមកគន់សោយសុភសប្បាយដូច្នេះ ។ ព្រះចៅឡនតេ
ត្រង់ត្រាស់ថា ខេត្តខ័ណ្ឌទាំងពួងកើតចលាចល យើងប្រើសេនាទាហាន
ទៅបង្ក្រាបកបាបអស់ហើយ ហេតុអ្វីក៏មកនិយាយដូច្នេះ ។ ឡៅ)គោ
ក្រាបបង្គំទូលថា ខេត្តខ័ណ្ឌទាំងពួងដែលកើតចលាចលគ្រានេះ ពីព្រោះ
ខ្ទី ១០ នាក់និយាយការពេជការទាំងពួង មិនប្រកបដោយផ្លូវយុត្តិធម៌
សោះ ទូលព្រះបង្គំជាខ្ញុំដឹងសេចក្តីច្បាស់ លុះទីដ៏ស្ងៀមមិន
ត្រាបទូល ក៏ហាក់ដូចមិនមានផ្លូវកតញ្ញូដល់ព្រះអង្គ រៀលានោះខ្ទី ១០

នាគបានពោលឡើងថា ក្រាបបង្គំទូលជូនថ្នាក់ ក័ន្ធយណាស់ លុះចូលទៅដល់
មុខព្រះទីនាំង ធ្វើទុក្ខយ៉ាងដោះមួក ហើយទ្រែកយំទូលថា ទូលព្រះ
បង្គំជាខ្ញុំនាំងឡាយ ដែលបានធ្វើជាខ្ញុំគ្រាដល្អងធូលីព្រះបាទសព្វថ្ងៃនេះ
សឹងតាំងចិត្តជាសុខរៃតែ ខំធ្វើកជការរក្សាផែនដីដោយខ្នើងត្រង់ណាស់
តែថា អស់ពួកនាហ្មឺនធំៗ នឹងឡើងតាយើញថា ព្រះអង្គទ្រង់ត្រាស
ប្រាណកំពានចិត្តឥច្ចាស្អប់ទូលព្រះបង្គំជាខ្ញុំនាំងឡាយ ទើបគិតទុក្ខ
រកឫរឿងឡើងមកក្រាបបង្គំទូលបន្ទុស បើដូច្នេះ នឹងធ្វើកជការតទៅគង់
មិនបានរួចអាយុដរៃតឡើយ ទូលព្រះបង្គំជាខ្ញុំនាំងឡាយសូមក្រាបថ្វាយ
បង្គំលាលែងធ្វើកជការ ចេញទៅធ្វើស្រែចម្ការចិញ្ចឹមជីវិតចុះ ឯទ្រព្យ
របស់នាំងប៉ុន្មានសូមលើកថ្វាយព្រះអង្គ សូមឲ្យទ្រង់ចែករំលែកឲ្យពួក
សេនាគហានដែលធ្វើកជការ ។

ព្រះចៅឡេនតេបានទ្រង់ព្រះសណ្តាប់ពួកខន្ធពិតទូលដូច្នោះក៏ទ្រង់
ព្រះពិរោធក្រោធនឹងឡើងតាខ្ញាំងណាស់ត្រាស់ថា ខ្ញុំនឯងគ្រាន់តែជាខី
ពីលឿងប៉ុណ្ណោះ សូមម្បីកុងទីពាំរនៅផ្ទះសម្បែងរបស់ឯង ក៏គង់មានបាវ
ព្រាវល្មមប្រើប្រាស់ជាធម្មតា ខ្ញុំនអញជាក្សត្រៈសាយភជសម្បត្តិជា
ម្ចាស់ផែនដី ក៏គប្បីឲ្យមានមនុស្សប្រើប្រាស់នៅខ្លះ ហេតុអ្វី ឯងមក
ឫសាឲ្យអញឈឺចិត្តដូច្នេះ ដែលឯងសំដែងខ្ញុំនជាកតញ្ញូនោះ អញមិន
ឃើញផងសោះ ត្រាស់ហើយទ្រង់បុង្គាប់ពេជ្ឈហោដខាងគ្រូនឲ្យចាប់ខ្ញុំន

ខ្ញុំគោរៀនសម្ងាប់ ពេជ្ឈឃាដក៏ចូលចាប់ខ្លួនខ្ញុំគោចេញទៅ ខ្ញុំ
គោស្រែកចំពោះព្រះកត្តិថា ដែលខ្ញុំធ្វើគ្រាស់បង្គាប់ឲ្យសម្ងាប់ខ្លួលព្រះ
បង្គំជាខ្ញុំនោះមិនបានស្គាយដឹងតែខ្ញុំ ខ្លួលព្រះបង្គំជាខ្ញុំស្គាយតែពាជសម្បត្តិ
ព្រះចៅហាន់កូប្ប ដែលសាងសន្សំមកអំពីដើមបាន ៤០០ ជ្ញាយឆ្នាំហើយ
ស្រុកទេសមិនដែលកើតចលាចលសោះ គ្រានេះមុខជានឹងអន្តរាយសាប
សូន្យជ្រាកជ ពេជ្ឈឃាដក៏ដឹកនាំខ្ញុំគោចេញទៅដល់ទីកន្លែងពិឃាដ
លើកជាវឡើងនឹងកាប់ ខ្លួលតាន់តាំយើញស្លុះមកស្រែកឃាត់ថា កុំ
អាលសម្ងាប់ចាំ ខ្ញុំចូលទៅខ្លួលស្តេចព្រះចៅឡែនគេឲ្យយើញចោសុខ
ត្រៃសិន តាន់តាំក៏ចូលទៅក្រាបបង្គំគាល់ដល់ទីសួនផ្កា ហើយខ្លួលសួរថា
ខ្ញុំគោធ្វើខុសពីអ្វីបានជាព្រះអង្គទ្រង់ឲ្យនាំទៅសម្ងាប់ ព្រះចៅឡែនតេ
បានទ្រង់ព្រះសណ្តាប់តាន់តាំខ្លួលសួរដូច្នោះ ទើបគ្រាស់ថា ខ្ញុំគោជា
មនុស្សចិត្តហ៊ាសពុំមានសេចក្តីគិតយកសេចក្តីមិនពិតមកនិយាយញុះញង់
ខ្មាក់ចោសមកលើខន្ធី ១០ នាក់ដែលមានយសសក្តិជាធំ ហើយស្តីទ្រ
គោះឲ្យយើងខ្ញុំត ។ តាន់តាំខ្លួលថា បណ្តានាហ៊ានតូចធំនូវអស់គាណា-
ចជាន្ទុកស្តេតប់ខ្មែតខ្លាំណាំងអស់ សុទ្ធតែមានសេចក្តីក្តៅក្រហាយ
ជាច្រែនណាស់មានចិត្តស្អប់ចង់ស៊ីសាច់ពួកខន្ធី ១០ នាក់ ឲ្យអស់ទៅ
ហេតុម្តេចព្រះអង្គទ្រង់ក៏អានស្រឡាញ់ពួកខន្ធីនោះខ្លាំងម្ល៉ះ ពួកខន្ធីនេះ
នឹងមានគុណបំណាច់យ៉ាងណា ឬានជាព្រះអង្គតាំងឲ្យធ្វើជាមន្ត្រីធំ

ទូលព្រះបង្គំជាខ្ញុំយើញមិនសមគួរសោះ ។ ១ ទៀត ហង់ស៊ី
ខន្ធី កំប្រែចិត្តក្បត់ ប្រើកលល្បិចយកបួលទំនងពួកចោរដួតក្បាលលឿង
មានអ្នកឯទៀត ចូលមកក្រាបទូលព្រះអង្គ ព្រះអង្គមិនចង់ដំរេកឲ្យ
យើញរៀបត្រង់ ព្រះអង្គក្រែងធ្លើជានៅស្ងៀមដែលព្រះអង្គធ្លើដូច្នេះ
ទំនងចង់ឲ្យរាជសម្បត្តិអន្តរាយឬអ្វី ?

ព្រះចៅឡេនតេត្រាស់តបថា មានអ្នកមកក្រាបទូលថា ហង់ស៊ី
ជាក្បត់នោះមិនមែនសោះ ឯខន្ធីទាំង ១០ អ្នកនេះយើងបានទំនុកបំរុង
អស់ពីចិត្តជាច្រើនដ បើហង់ស៊ីជាក្បត់គង់មាន ៩ នាក់នៅត្រង់ល្អប្រយ៉ាង
ហោចណាស់គង់មានម្នាក់ឬ ២ នាក់នៅត្រង់ល្អទំនងយើង គង់ទំនងនាំ
ពត៌មានឲ្យយើងដឹង ។

គាន់តាំយើញថា ព្រះចៅឡេនតេស្រឡាញ់កប់អាទំខន្ធី ១០ នាក់
លើសលុប ទំនងច្បាព្ទទូលទាំហេតុឲ្យវែងទៅទៀតក៏មិនជាប្រយោជន៍
ជាក់ច្បាស់ គាន់តាំឯណាស់យកក្បាលបោកទំនងត្រែគំនាល់ ដែល
ស្ពៃចគង់នោះទាល់តែបែកក្បាលហូរឈាម ព្រះចៅឡេនតេត្រង់ព្រះ
ក្រែងខ្លាំងណាស់ ត្រាស់ឲ្យគេជ្រយាដខាងឆ្វេងចាប់យកខ្លួន គាន់តាំ
ទំនងឡោះគោ ដែលនាំទៅសម្លាប់នោះយកទៅជាក់គុកពុកទាំង ២ នាក់
វិញ លុះវេលាយប់ខន្ធី ១០ នាក់តតគ្នាហើយហៅភូយុំមកបង្គាប់ថា

បើដល់ពេលគាត់កណ្តាលអធ្រាត្រ ឲ្យលបសម្ងាប់តាន់តាំនឹងខ្លោ)គេចេញចុះ កូឃុំក៏ទៅធ្វើតាមទន្ទឹមភ្លាម ។

ហើយទន្ទឹម ១០ នាក់ក៏តែងជាសំបុត្រព្រះរាជតម្រាស់ទៅដល់ស៊ុនកៀនថា គ្រាស់ឲ្យស៊ុនកៀនទៅឈរស្រុកគៀងសា ហើយឲ្យបង្ក្រាបគួសេង ដែលជាពួកចោរសេះចេញឲ្យកបចាប ស៊ុនកៀនដឹងក្នុងសំបុត្រព្រះរាជតម្រាស់ហើយ ក៏លើកពលទៅបង្ក្រាបពួកចោរ លុះបានកបចាបហើយ ក៏បកសំបុត្រចូលទៅក្រាបទូលព្រះចៅឡេនតេ។ ទ្រង់ជ្រាបទើបទ្រង់ព្រះតំរិះថា ស៊ុនកៀនមានសេចក្តីគាប់ប្រសើរក្នុងរាជការស្រុកកាំងហែជាខ្លាំងណាស់ ទើបឲ្យតែងព្រះរាជតម្រាស់បង្គាប់ស៊ុនកៀនឲ្យទៅឈរស្រុកកាំងហែ ឲ្យខ្លោ)ធីជាទីចៅហ្វាយស្រុកអ៊ុយដីវឲ្យលើកទាហានទៅវាយតៀវគីតៀវស៊ុនដែលតាំងខ្លួនជាស្តេចយើយ៉ុង ។

ឯខ្លោ)កេងដឹងក្នុងព្រះរាជតម្រាស់ថា ខ្លោ)ធីត្រូវទៅចាំធនឹងតៀវគី តៀវអ៊ុនដូច្នោះក៏សរសេរសំបុត្រឲ្យខ្លោ)ពីកាន់ទៅកខ្លោ)ធីក្នុងសំបុត្រមានថា ខ្លោ)កេងខ្លោ)ពីនឹងខ្លោ)ធីជាសែងាមួយគ្នាសុំឲ្យខ្លោ)ពីធ្វើការសឹកជាមួយផង ខ្លោ)ធីដឹងក្នុងសំបុត្រដូច្នោះក៏មានសេចក្តីត្រេកអរណាស់ ។

(មានត)

លោកគ្រូព្រះវិភទ្ធញ្ញាណ សោម-ទ្បុប រៀបរៀង

(ត)

ព្រះសារីបុត្តត្រិះរិះពិចារណាថា លោកនេះ ចានមកបួសហើយក៏នៅតែរងទុក្ខវេទនាដោយអត់អាហារដដែល មើដូច្នោះ ចាំដល់ថ្ងៃព្រឹកស្អែក សឹមអាត្មាអញទើនាំលោកនេះទៅបិណ្ឌបាតលម្អិល ក្រែងដួនជាមានគេដ្រះថ្លាដោយសារអាត្មាអញ គេនឹងនាំគ្នាយកចង្ហាន់មកជាក់ចាត់ខ្លះ លុះព្រឹកស្អែកឡើង ព្រះសារីបុត្តក៏បញ្ជូលលោកនោះថា នែសោសក្រតិស្សៈ មកទៅបិណ្ឌបាតជាមួយនឹងខ្ញុំ ។ ឯសោសក្រតិស្សៈក៏ចានទៅជាមួយ លុះចូលទៅដល់ស្រុកភូមិ ពួកអ្នកស្រុកនោះចានឃើញព្រះសារីបុត្តក៏មានសទ្ធាដ្រះថ្លា នាំគ្នាយកចង្ហាន់មកប្រគេនឹងជាក់ចាត់ លុះក្រឡេកឃើញសោសក្រតិស្សៈនៅពីខាងក្រោយ ក៏ចាត់ដ្រះថ្លានាំគ្នាយកចង្ហាន់ត្រឡប់ចូលទៅក្នុងផ្ទះវិញ ។ ព្រះសារីបុត្តឃើញដូច្នោះក៏គិតពិចារណាថា តុកម្មវេសលោកនេះខេតើ ដែលនាំមិនឲ្យគេដ្រះថ្លា ទើបមានវាចាច្រាប់ថា នែសោសក្រតិស្សៈ ចូរលោកទៅនៅចាំខ្ញុំឯសាលាក្រៅភូមិសិនចុះ ខ្ញុំនឹងចូរទៅបិណ្ឌបាតតែម្នាក់ឯងវិញ បើចានចង្ហាន់សឹមខ្ញុំឲ្យគេនាំយកទៅប្រគេនធាន ។ លោកនេះ ក៏ព្រមទៅចាំលើសាលានោះ ។ លុះព្រះសារីបុត្តចូលទៅក្នុងស្រុកនោះម្តងទៀត

ជនចាំងនោះក៏ដែរថ្ងាំគ្នាយកបង្ហាន់មកជាក់ចុត្រ ហើយនិមន្តឲ្យឆាន់
កងំខ្ចីនោះ មុននឹងឆាន់លោកក៏បានប្រាប់ថា អ្នករាល់គ្នាមើលចាត់ចែង
បង្ហាន់យកទៅឲ្យលោកកូនសិស្សអាគន្តុកាន់ផង លោកនៅចាំឯសាលា
ត្រៃឯណោះ ។ ទើបឧបាសកម្នាក់ទទួលថា កុំព្រួយព្រះគុណលោក
ម្ចាស់ និមន្តលោកម្ចាស់ឆាន់តាមសប្បាយចុះ ខ្ញុំព្រះករុណាធឹងជានាំ
បង្ហាន់យកទៅប្រគេនលោកនោះ ហើយក៏នាំបង្ហាន់យកទៅបម្រុងនឹង
ប្រគេនលោកនោះដោយពិត ប៉ុន្តែ ផលអកុសលកម្មរបស់កិក្ខុនោះមក
បិទបាំងគំនិតត្រឡប់ជាដឹកនាំឲ្យចិត្តអ្នកនោះឲ្យនាំចូលទៅកន្លែងដដែ
វិញ ហើយបរិភោគអាហារចំណីនោះអស់លើង ហើយត្រឡប់មកផ្ទះ
វិញ ។ ឯព្រះសារីបុត្រក៏ឥតបានសួរឿងនោះឡើយ លុះឆ្លងផុតកិច្ចរួច
ហើយ ក៏លាអ្នកស្រុកទៅវិញ ទៅដល់សាលាក៏សួរកិក្ខុនោះថា លោក
បានឃើញគេនាំយកបង្ហាន់មកឲ្យដែរឬទេ ។ កិក្ខុនោះទូលតបថា
មិនឃើញទេ ។ ព្រះសារីបុត្រក៏គិតថា នុកម្មរបស់លោកនេះធ្ងន់ណាស់
តើ ទើបនាំលោកនោះទៅថ្វាយព្រះពាព្រះបាទពិម្ពិសារ តាមរឿងនោះ
ដោយសព្វគ្រប់ ។ ព្រះបរមក្សត្រក៏មានព្រះទ័យអាណិតដែរពេក ទើប
ទ្រង់ឲ្យពួកជាបុរសចាត់ចែងកេសដ្ឋៈចំនួន ១ ជាត្រ លើកមកប្រគេន
ព្រះសារីបុត្រ។ ទទួលចាប់មាត់ជាត្រម្ខាង ឲ្យកិក្ខុនោះចាប់មាត់ម្ខាង
ហើយប្រាប់ថា ចូរលោកឆាន់កេសដ្ឋៈនេះចុះ តែត្រូវប្រែងប្រយ័ត្នកុំឲ្យ

កំពង់ឡើយ ។ កិកុនោះក៏ចាន់ឆ្អែតស្កប់ស្កល់ ។ រៀងនោះ
បើព្រះសារីបុត្រមិនជួយចាប់មាត់ជាតិម្ហាងផង មុខជានឹងកំពង់មិនខាន
ព្រោះតម្ងាំងតម្អាបរៀកិកុនោះខ្លាំងពេកណាស់ ។ មុខគួរឲ្យអាស្ចារ
អាណិតកិកុនោះក្រៃពេក ចាប់ដើមតាំងពីបួសមកកាលណា មិនដែល
ចាន់អាហារអ្វីឆ្ងាន់ឆ្អែតម្ពងសោះ ទើបវែតចាន់ឆ្អែតម្ពងកន្លងពេលនោះ
ឯង លុះឆ្ងាន់រួចហើយ ព្រះសារីបុត្រក៏ថ្វាយព្រះពរលាព្រះរាជទាំកិកុ
នោះត្រឡប់ទៅវត្តវិញ ។ គ្រាក្រោយមកកិកុនោះមានចិត្តសង្វេគខ្លាំង
ក៏ខំប្រឹងការនាជមិ គ្រាតែចាន់សម្រេចអរហត្តផល ហើយចូល
និព្វានកន្លងវៀងនោះឯង ។

នេះហៅថា ភ័យអ្វីមិនស្មើភ័យខ្លាចបាប ។

ត្រង់ចុងថា លាភអ្វីមិនស្មើលាភគឺពោគបៀតបៀនប្រាណ ។
សេចក្តីអធិប្បាយថា លាភ គឺការចាន់ទ្រព្យសម្បត្តិចាន់យស
សក្តិជាដំ តែលាភទាំងនេះមិនហៅថាលាភទុត្តមប្រសើរទេ ការដែល
មិនមានពោគបៀតបៀនកាយ ទើបហៅថា លាភទុត្តមប្រសើរ សមដូច
ពុទ្ធភាសិតថា អារោគ្យា បរមា លាភា ការមិនមានពោគចាត់ជា
បរមលាភ , គឺបុគ្គលណាមួយដែលកើតមកកន្លងលោកនេះ មិនសូវមាន
ពោគអាពាធច្បាធិសេចក្តីឈឺចាប់កន្លងកាយ ច្រើនប្រកបដោយសេចក្តី

សុខសប្បាយយ៉ាងនេះ ទើបហៅថា បុគ្គលមានលាភធំក្តី បើអ្នកដែលមានទ្រព្យសម្បត្តិ មានយសស័ក្តិធំហើយ ប៉ុន្តែបន្តិចឈឺនេះ បន្តិចឈឺនោះឥតបានសេចក្តីសុខសព្វវេលាសោះ យ៉ាងនេះហៅថាបុគ្គលគ្មានលាភវិញ មួយយ៉ាងទៀត បុគ្គលដែលកើតមកទ័លក្រគ្មានយសស័ក្តិនេះ ប៉ុន្តែច្រើនប្រកបដោយកម្លាំងភ្លាំង មានព្រលឹងព្រលះជាតំណក់ទ្រលុកទ្រលន់ស្រួលបួលតាំងមិនសូវមានដម្លីដំកាត់អ្វីមកបៀតបៀនយ៉ាងនេះក៏ហៅថា បុគ្គលមានលាភធំដែរ ។ នេះហើយហៅថា លាភអ្វីមិនស្មើលាភឥតរោគបៀតបៀនប្រាណ ។

ត្រង់បទថា ទានអ្វីមិនស្មើទានធម៌ទេសនា នោះសេចក្តីអធិប្បាយថា ទាននោះលោកចែកដោយសង្ខេបមាន ២ យ៉ាង គឺ : អាមិសទាន ๑ ធម្មទាន ๑ ។ អាមិសទានបានខាងការឲ្យបច្ច័យ ๔ មានចីវរប្បច្ច័យជាដើម បច្ច័យណាមួយគឺឲ្យដល់បព្វជិតឬដល់គ្រហស្ថ ឬដល់សត្វតិរច្ឆានហៅថាអាមិសទាន ពុំនោះសោតបូជាក្តីផ្កាជាដើមដល់ព្រះរត្នត្រ័យក៏រួបរួមហៅថា អាមិសទានទាំងអស់ ឬហៅថា អាមិសបូជាវិញក៏បាន ។

ឯធម្មទាន ការឲ្យធម៌គឺសំដែងធម៌ឲ្យគេស្តាប់ បូបង្ហាត់បង្ហាញថ្លែងត្រង់ទាំងអដ្ឋកថា ឲ្យគេបានចេះដឹងស្គាល់ការណ៍ខុសត្រូវបុណ្យបាបគុណទោសតាមផ្លូវព្រះពុទ្ធវចនៈបុបបូលគេស្តាប់ធម៌នេះហៅថាធម្មទាន ។

បណ្តាទានទាំងពីរនេះ ធម្មទានជាកំពូលនៃទានទាំងអស់ប្រសើរជាងទានទាំងពួង ។ ព្រោះហេតុអ្វីបានជាលោកលើកធម្មទានប្រសើរជាងអាមិសទាន ព្រោះហេតុថាធម្មទានជាមគ្គប្បាយសម្រាប់បង្ហូរទៅអាមិសទាន ឥថាបុគ្គលដែលចេះដឹងលែងតែចាត់ចែងធ្វើអាមិសទានបានក៏ព្រោះតែបានឮបានស្តាប់ធម៌គឺបច្ចប់ដែលច្បាប់ពន្យល់ផលប្រយោជន៍ដូចច្បាប់ពន្យល់ថា ជនណាធ្វើបុណ្យយ៉ាងនេះ នឹងបានផលយ៉ាងនោះៗ បុគ្គលបានស្តាប់បានឮដូច្នោះហើយ ទើបបានចាត់ចែងធ្វើបុណ្យមានឲ្យទានផ្សេងៗជាដើមទៅបាន ។ ព្រោះហេតុនោះ បានជាលោកលើកធម្មទាននេះថាជាទានប្រសើរជាងអាមិសទានទាំងអស់ សមដូចព្រះពុទ្ធដីកាថា :

សព្វទានំ ធម្មទានំ ជិនាតិ
សព្វរតឺ ធម្មរតិ ជិនាតិ
សព្វរសំ ធម្មរសោ ជិនាតិ
តណ្ហាក្ខយោ សព្វទុក្ខំ ជិនាតិ ។

ធម្មទានឈ្នះទានទាំងអស់ ការត្រេកអរនឹងធម៌ឈ្នះការត្រេកអរទាំងអស់ រសធ្លាញ់ពីសាវចរសធម៌ ឈ្នះរសធ្លាញ់ពីសាទាំងអស់ ការអស់ទៅនៃតណ្ហា ទើបឈ្នះទុក្ខទាំងអស់បាន ។ នេះហៅថា **ទានអ្វីមិនស្មើទានធម៌ទេសនា** ។

ត្រង់បទថា បញ្ញាអ្វីមិនស្មើបញ្ញាអ្នកបានព្រះអរហត្ត នោះ
មានសេចក្តីអធិប្បាយថា បុថុជ្ជនខ្វះកង់លោកនេះមានបញ្ញាចេះដឹងសិល្ប-
សាស្ត្រផ្សេងៗ ចាំងផ្លូវលោកផ្លូវធម៌ឃើញចំណាប់ចំនួនច្រើនជាងជដល់ក្អែក
ជនចាំងពួង ពិតមែនណាសំដែរ ប៉ុន្តែបញ្ញារបស់បុថុជ្ជននេះ ចានតែ
សំដែងឫទ្ធិអំណាចខាងក្រៅឲ្យគេខ្លាចឲ្យគេកោតឲ្យគេសរសើរថា គ្រាន់
បើប៉ុណ្ណោះទេ នឹងយកបញ្ញាបែបនោះមកកាប់ឆ្កាកំលេសតណ្ហាក្នុង
សន្តានរបស់ខ្លួនពុំបាន មានតែបញ្ញាអ្នកបានព្រះអរហត្ត ទើបអាច
កាត់ផ្តាច់កំលេសតណ្ហាបាន ព្រះសព្វញ្ញុពុទ្ធគំរើនត្រាស់សរសើរ
បញ្ញានេះ ជាអ្នកគប្រកាសថា អ្នកមានខ្លួនឫសម្បត្តិកប់សែនលានកោដិ
ក៏មិនស្មើនឹងអ្នកមានបញ្ញាឡើយ បញ្ញានេះវិសេសចំផុតក្នុងលោក
ព្រោះហេតុនោះអម្បាលពោធិសត្វចាំងឡាយ កាលបើបានតសាងកុសល
ណាមួយ ។ ហើយក៏រមែងជ្រាបច្បាស់ចំពោះត្រង់បញ្ញាមួយប៉ុណ្ណោះឯង ដូច
កាលព្រះអគ្គទៅជាព្រះបាទវេស្សន្តរបរមពោធិសត្វទៅឡើយ ត្រង់លើក
ជាលើតណ្ហាជាបុត្រសង្ឃឲ្យជាទានតាជូជក លើកព្រះនាងមទ្រីជា
អគ្គមហេសីឲ្យជាទានឥន្ទ្រព្រាហ្មណ៍ ឥតមានស្តាយស្រណោះអាឡោះ
អាល័យឡើយ ។ ព្រះបរមពោធិសត្វត្រង់មានព្រះពាជសទ្ធា ហ៊ាន
ព្រះពាជទានរបស់សំឡាញ់យ៉ាងនេះ ក៏ត្រង់មិនត្រូវគោះនឹងសម្បត្តិអ្វី
ដទៃឡើយ ត្រង់ត្រូវគោរពជ្រាបប្តូរយកតែបញ្ញាមួយមុខប៉ុណ្ណោះឯង

ដោយគ្រន់ព្រះតម្រិះយល់ឃើញថា បើបញ្ញាកើតឡើងហើយ អាច
នឹងដេញសេចក្តីល្ងង់ខ្លៅ ដ៏តក្កដ្ឋសន្ដានបាន ប្រៀបដូចតន្ទីប្រទីប
ជាដើម តែភ្លឺឡើងក្នុងវេលាណាហើយ ក៏អាចដេញងងឹតឲ្យឃ្លាត
ខ្លាត់ខ្លាយចេញទៅឆ្ងាយបាន នេះឈ្មោះថា បញ្ញាមិនស្មើបញ្ញាអ្នក
បានអរហត្ត ។

គ្រន់បទថា អត្ថអ្វីមិនស្មើអត្ថបរមត្ថព្រះអភិធម្ម នោះមានសេចក្តី
អធិប្បាយថា អត្ថឯទៀត។ មានច្រើន តែមិនស្មើនឹងអត្ថបរមត្ថព្រះអភិធម្ម
ទាំង ៤ គឺ ចិត្ត ១ ចេតសិក ១ រូប ១ និព្វាន ១ នោះឡើយ ព្រោះអត្ថ
ទាំង ៤ នេះជាសុខុមភាព ល្អិតជ្រាលជ្រៅពេកណាស់ ហួសវិស័យ
បុថុជ្ជននឹងចាក់ធ្លុះបាន មានតែអង្គព្រះសព្វញ្ញុពុទ្ធទើបត្រាស់ដឹងបាន
ដោយច្បាស់ល្អាស់ មិនមានសល់ចន្លោះ មិនមានភាន់ច្រឡំ ។ លុះ
ព្រះអង្គត្រន់ត្រាស់ជ្រាបច្បាស់នូវអត្ថនេះហើយ ទើបត្រន់សំដែង
ទុកមក ក៏មានអ្នកដែលបេះដឹងតាមព្រះអង្គផងនោះ ដោយកម្រពេក
ណាស់ តិចគ្នាពេកណាស់ មានជនខ្លះតិតមិនធ្លុះមិនភ្ញាយ ដរាបដល់
តែលង់ស្មារតីទៅជាមនុស្សឆ្កួតក៏មាន ។ ដោយហេតុនោះបានជាលោក
គោលថា អត្ថអ្វីមិនស្មើអត្ថបរមត្ថព្រះអភិធម្ម ។

បរិយាយសាមគ្គី

របស់ព្រះទេពមុនី យ្សូ ប៊ុណ្ណា

ក្រុមដំទុំព្រះវិន័យបិដកនៅពុទ្ធសាសនបណ្ឌិត្យ

ឥមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស
សូមនមស្សការចំពោះព្រះរតនត្រ័យ (ដោយសេចក្តីគោរព) ។

ពេលនេះ អាត្មាភាពសូមដកស្រង់យកពុទ្ធភាសិតថា "សុខា សង្ឃស្ស សាមគ្គី" នេះ មកសំដែង ដើម្បីជាសវនាការដល់អស់លោក - អ្នកជាពុទ្ធបរិស័ទចាំងឡាយដូចតទៅនេះ :

ពាក្យថា "សុខា សង្ឃស្ស សាមគ្គី" បែរថា "សេចក្តីព្រមព្រៀងគ្នានៃពួកសង្ឃឬគណៈ នាំមកនូវសេចក្តីសុខ" ។

សង្ឃ សំពូ កន្ធ ធី នេះ សំដៅយកពួកក្រុម គ្រួសារ សំឡូម ឬ ប្រទេសមួយៗ ហៅថាសង្ឃ: ។ ការព្រមព្រៀងគ្នា មូលមិត្ត ជិតស្និទ្ធ រួបរួមគ្នា ស្រុះស្រួលគ្នា ស្រុះចិត្តគ្នា ស្មើដៃគ្នា កន្ធការធ្វើកិច្ចអ្វីៗ ហៅថា សាមគ្គី ។ រួមសេចក្តីថា "ការព្រមព្រៀងគ្នា ក្នុងក្រុមធីមួយៗ នាំមកនូវសេចក្តីសុខ" ។

ការព្រមព្រៀងគ្នាក្នុងក្រុម ឬគណៈធីមួយៗ នេះជាសាធារណៈទូ-ទៅចាំងត្រហស្ថ - បព្វជិត ចាំងតតិលោក - តតិធម៌, តតិចាំងពីរនេះ

បើមិនមានសាមគ្គីធម៌នៅអាស្រ័យផងទេ កិច្ចការអ្វីមួយដែលត្រូវធ្វើ ត្រូវនិយាយ ត្រូវគិត ក៏មិនបានសម្រេចប្រយោជន៍ប៉ុន្មានឡើយ ។

ការព្រមព្រៀងចូលមិត្តគ្នានេះ ជាគុណសម្បត្តិមួយយ៉ាងវិសេសក្នុងលោក សូម្បីព្រះពុទ្ធជាម្ចាស់ ក៏ទ្រង់សំដែងអំពីសាមគ្គីនេះទុកជាពាក្យបញ្ជាមួយ សម្រាប់អ្នកកាន់ព្រះពុទ្ធសាសនាដែរ ។

អស់លោក ! អ្នកសម្បុរសចាំងឡាយ ពេលនេះជាពេលគួរដល់យើងត្រូវកសាងប្រទេសជាតិឲ្យមានពន្លឺស្មើ កិត្តិយសខ្ពស់ត្រឡងត្រឡាយ ដោយការបណ្តុះសាមគ្គី ខាងការរៀនចំណេះវិជ្ជា ទំនាក់ទំនងរកទ្រព្យសម្បត្តិឲ្យកាន់តែមានកំឡាំងខ្លាំងឡើងហើយ បណ្តាជនជាតិចាំងឡាយក្នុងពិភពលោកនេះ ឥតមានរូបណាមួយ ចង់នៅក្រោមបង្គាប់នៃសេចក្តីលំបាកខ្លៅក្តៅក្រហាយ ថោកទាបទេ អ្នកប្រទេសណាដែលធ្លាក់ខ្លួនទៅជាមនុស្សល្ងង់ខ្លៅក្តៅក្រហាយ ថោកទាបហើយ អ្នកប្រទេសនោះ តែងរើខ្លួនគេឲ្យរួចពីកណ្តាប់ដៃនៃសេចក្តីលំបាកខ្លៅក្តៅក្រហាយ ថោកទាបជាដរាប ។

មុនដំបូងយើងត្រូវរួបរួមគ្នារក្សាជាតិ ទំនុកបម្រុងជាតិ គោរពជាតិ លើកដំកើងជាតិ ស្រឡាញ់ជាតិជាមុន កុំឲ្យបែករបែរធ្វើសាមគ្គីជាតិ កុំប្រកាន់បក្សពួកថា ពួកនេះ ពួកនោះទៀតឡើយ ត្រូវឲ្យទំនុកឃើញថាជាតិមួយម៉ាត់ ដែលជាប់សាច់សាលោហិតសែស្រឡាយជាមួយគ្នា

តែម្យ៉ាង៑ បើយើងនៅតែប្រកាន់បក្សពួកថា ពួកនេះ ពួកនោះ ឲ្យបែក
ប្រេះធ្លាស៊ាំសាមគ្គីជាតិខ្លួចហើយ ធ្វើម្តេចឡើយទើបឈានដើរទៅ
កាន់អារ្យធម៌ជាន់ខ្ពស់បាន ។

ហេតុនេះ យើងជាខ្មែរជាតិ ដែលជាជាតិគ្រប់មានល្បីឈ្មោះកង
ពង្សវតារលោកពីដើមទំនឹងគេដែរ ត្រូវរួបរួមគ្នាបណ្តុះសាមគ្គីធម៌នេះឲ្យ
កើតមានឡើង ទាន់ពេលសម័យដែលបើកឱកាសឲ្យ ។

សាមគ្គីនេះបែកចេញជា ៣ យ៉ាង គឺ:

១ កាយសាមគ្គី ព្រមព្រៀងដោយកាយ

២ — វចីសាមគ្គី ព្រមព្រៀងដោយវាចា

៣ — មនោសាមគ្គី ព្រមព្រៀងដោយចិត្ត ។

១ កាយសាមគ្គី ព្រមព្រៀងដោយកាយនោះ គឺ:
គ្រប់ប្រទេសទាំងអស់ក្នុងលោក ដែលនឹងត្រូវស្មុះឡើងចាកភាពថោក
ទាបបាននោះ មិនមែនត្រូវការស័យកំឡាំងរបស់ឯកជនម្នាក់ៗ ទេ ។
ដែលពិតនោះ គឺត្រូវអាស័យកំឡាំងរបស់ជនរួមជាតិទាំងមូល ស្មុះ
ស្រួលចិត្តគំនិតគ្នា មិនប្រឆាំងប្រណាំងប្រជែងឥតអាតជណ្តើមយកមុខ
មាត់តែម្នាក់ឯង ឲ្យទាល់តែបែកជ្រាយប្រេះធ្លាស៊ាំសាមគ្គីខ្លួចទេ, ឯការ
បែកសាមគ្គីនេះ ជាទោសមួយយ៉ាងធំបំផុតក្នុងលោក សូម្បីអ្នកកាន់

ព្រះពុទ្ធសាសនាក៏ដូចគ្នា ។ ដូចមានរឿងដំណាលក្នុងគម្ពីរពុទ្ធសាសនា ថា សម័យនោះ ពួកភិក្ខុនៅក្នុងក្រុងកោសម្ពី គាន់តែមានហេតុបន្តិចបន្តួចប៉ុណ្ណោះសោះ ក៏បណ្តាលនាំឲ្យវិវាទប្រកួតប្រកាន់គ្នា ទាល់តែបែកសាមគ្គីលែងមើលមុខគ្នាត្រង់ ពួកស្តេចមន្ត្រីនំងៗយក ឧបាសក ឧបាសិកា មកនិយាយអង្វរលោមលោមឲ្យស្រុះស្រួលគ្នាយ៉ាងណាក៏មិនព្រមស្តាប់ ទាល់តែគេលែងដែរថា លែងប្រគេនចង្ហាន់ដាក់បាត្រគ្រប់ដប់ទាំងអស់ ព្រះពុទ្ធជាម្ចាស់ទ្រង់ឃាត់ហាមខ្លួត ក៏មិនព្រមស្តាប់នៅតែចេះសម្លុះវិនយកឈ្នះម្ខាងៗ ទាល់តែទ្រង់យាងចេញពីទីនោះ ទៅគង់ក្នុងព្រៃបុលិលេយ្យៈអស់ចំនួន ៣ ខែ ។ ភិក្ខុទាំងនោះក៏មិនបានសម្រេចមគ្គផលអ្វីឡើយ ។

មួយទៀត ដូចពួកស្តេចលិច្ឆវីក្នុងដែនវជ្ជី ជាស្តេចមានបុត្រ មានអនុភាពច្រើន ព្រមព្រៀងគ្នារក្សាអបរិហានិយធម៌ ៧ ប្រការមិនខ្វះមួយ ពេលមួយព្រះបាទអជាតសត្តុ មានព្រះបំណងនឹងទៅច្បាំងដណ្តើមយកដែននោះ តែដោយអំណាចពួកវជ្ជីក្សត្រទាំងនោះ មានសាមគ្គីធម៌ប្រតិបត្តិអបរិហានិយធម៌ទាំងមួន ព្រះបាទអជាតសត្តុក៏មិនអាចនឹងទៅដុះជាន់ញាំញីបង្ក្រាបដណ្តើមយកបានឡើយ ។ លុះដល់មកពេលខាងក្រោយ ពួកវជ្ជីក្សត្រប្រែបែកសាមគ្គីលែងចុះចូលគ្នា មិនយូរប៉ុន្មាន ទើប

ព្រះបាទអជាតសត្តុ លើកទ័ពទៅច្បាំងដណ្តើមយកដែនគោះមកធ្វើជាចំណុះព្រះអង្គបាន ។

រឿងនេះមិនមកអំពីអ្វី គឺមកតែអំពីការបែកសាមគ្គីទាំងឲ្យវិនាសអន្តរាយប្រទេសជាតិ គោតសម្បីតែ ឋិតិអាណាចអាទុកាតបេសន្តរ ទៅជាខ្វះកញ្ចេះគេ ព្រោះតែសេចក្តីបែកសាមគ្គី ។

ហេតុនេះ សូមអស់លោក-អ្នកស្រីមជាតិជាំងក្បាយ ត្រូវតួតដៃគ្នារក្សាសាមគ្គីជាមិនឲ្យម៉ឺងម៉ាត់ កុំប្រកួតប្រជែងដណ្តើមយកចក្ខុពួកឡើយ, តួរតែគោរពឈរឡើងឲ្យត្រង់ខ្លួន កុំឱនលំទម្លុះទម្លាន់ ប្លែកខ្លាំងឲ្យត្រង់ដៃ ទំនងរៀនចំណេះវិជ្ជាឲ្យបានត្រង់គ្នាឡើង ដើម្បីមានធ្វើប្រទេសជាតិ សាសនា ព្រះមហាក្សត្រឲ្យមានតំលៃ កុំឲ្យប្រទេសបានឈ្មោះបើងពោលថ្លៃត្រាយ អ្នកណាទៅស្រុកណា ភូមិណា ស្ថិតមណ្ឌលត្រូវបង្ហូរ គ្នាវៃអង្គាសប្លុកតាសតាមតំបន់ច្រើនតសាធមន្តុរពេទ្យសម្រាប់ព្យាបាលរោគ ទំនងសាលាបង្រៀនអក្សរសាស្ត្រវេស់ជាតិ សម្រាប់បណ្តុះចំណេះវិជ្ជាដល់កុមារកុមារីក្នុងស្រុកក្នុងភូមិវេស់យើង ឲ្យបានត្រង់គ្រាន់ឡើង ព្រោះចំណេះវិជ្ជាអក្សរហាស្ត្រនេះ ជាថ្នមប្រទាក់ជីវិតរបស់ប្រទេស ឯឋិតិអាណាច អាទុកាត យសស័ក្តិ គោតសម្បីតែ ទំនងកើតឡើងនោះ អាស្រ័យមកពីចំណេះវិជ្ជាអក្សរសាស្ត្រវេស់ជាតិជាំងអស់សម្រាប់រក្សាក្តៅឈ្មោះខ្មុក, ដូចជាអំបិលជាជាតិប្រៃ អំបិលតាបរក្សា

ជាតិរបស់ខ្លួនពុក បើពុកជាគេយកទៅជាក់ទៅចង់ក្នុងវត្តអ្វីមួយ មាន
ជូរផ្អែមជាដើម អំបិលក៏នៅតែក្បាជាតិរបស់ខ្លួនឲ្យនៅជារៃជដែល
យ៉ាងណាមិញ វិជ្ជាអក្សរសាស្ត្រចម៌ស់ជាតិ បើរលត់លោយចោយ
ប្រទេសជាតិ សាសនា ព្រះមហាក្សត្រ ឫទ្ធិអំណាច អាឧកាព កោត-
សម្បុរ កំត្រូវយើងរក្សាពុកកុំឲ្យបាត់សេជាតិដូច្នោះដែរ ។

មួយទៀត ចំពោះដែលនិងកសាងប្រទេស ការពារប្រទេស
យើតយោងប្រទេសនោះ ប្រជាជនអ្នករួមជាតិ ត្រូវដើរតាមរបៀបនេះគឺ:

ក ត្រូវគោរពជាតិ, ស្រឡាញ់ជាតិ, លើកដំកើងជាតិ, កុំក្បត់
ជាតិ ។

ខ - ត្រូវគោរពសាសនា, ស្រឡាញ់សាសនា, លើកដំកើង
សាសនា, កុំក្បត់សាសនា ។

គ - ត្រូវគោរពព្រះមហាក្សត្រ, ស្រឡាញ់ព្រះមហាក្សត្រ, លើក
ដំកើងព្រះមហាក្សត្រ, កុំក្បត់, កុំប្រមាថ, កុំមើលងាយព្រះមហាក្សត្រ ។

ឃ - យុវជន (កុមារកុមារី) ត្រូវបួលខ្លួនទៅសាលាសិក្សាប្រគល់
ខ្លួនជាសិស្ស, ទើបត្រូវតាំងចិត្តរៀនឲ្យពូកែចំណេះវិជ្ជា ទំនឹកវិយា
ភ្លូវផ្សេង។ ។

ង ត្រូវគោរពស្តាប់បួលទៅបង្រៀនសិស្សក្នុងសាលា ត្រូវយក
ចិត្តទុកជាក់បំពេញកិច្ចរបស់សាលាឲ្យត្រឹមត្រូវ ឥយកចិត្តទុកជាក់

ចង្រៃនសិស្សឲ្យម៉ឺងម៉ាត់ កុំប្រកាន់មានះឫកខ្ពស់ឱ្យសិស្សលែងស្រឡាញ់អក្សរសោស្តែរចេស់ជាតិខ្លួន ។

ច បុរសស្លូតក្នុងគ្រួសារ ត្រូវយកចិត្តទុកដាក់ព្យាយាមចំពោះកិច្ចការសម្រាប់គ្រួសារប្រចាំគ្រកូលឲ្យពេញលេញកុំឲ្យធ្វេសប្រហែសខ្លួនពេក ។

ឆ ឡៃប៉ុន្តែល (បុរសស្លូតទាស់ ។) ត្រូវសង្កាតទំប្រឹងប្រឹយ៉ាតក្រែងប្រជៀងយកដៃនឲ្យបានល្អត្រឹមត្រូវតាមសាស្ត្រ កុំបណ្តោយឲ្យខូចឫកពា ខឹងស័ស្តមិដែលយើងគួរអប់រំសន្សំទុក ។

ជ - ពាហានត្រូវប្រពឹត្តវិន័យ ប្រចាំបន្ទាយ ប្រចាំកង ប្រចាំជាតិ ទាំងត្រូវអង្គាចអ្វាហានតស៊ូខឹងស្រួចក្នុងពេលដែលប្រទេសត្រូវការពើខ្លួនយើងឲ្យជាអ្នកខ្ជិលការៈការពារ ។

ឈ អ្នកនិពន្ធ ត្រូវសរសេរសៀវភៅស្រមក់តំនិតដែងរឿងគំរោងផ្សេង។ មានរឿងព្រះពុទ្ធសាសនា ខឹងរឿងប្រវត្តិសាស្ត្រជាដើម ឲ្យបានសម្បូណ៌ត្រប់ត្រាន់ឡើង ។

ញ រដ្ឋបាល ត្រូវជួយទប្តូរមុំទុកចម្រុងក្រុង ទេរ្ឋាធលប្រយោជន៍ ខឹងសេចក្តីសុខ។ ចំរើនឋេរក្រុង ឲ្យបានពេញលេញតាមលក្ខន្តិៈការត្រប់ត្រងដែនដី កុំឲ្យដែនដីឋេរខ្ចោលនៅថ្ងៃក្រោយ ។

ជ ក្រសួងប្រជា ត្រូវប្រកបការអោយជីព តាមថ្នាក់ខ្លួនជាសាមញ្ញ
កណ្តាលខ្ពស់តាមទម្លាប់ស្នា ហើយចង់ពន្ធជារដ្ឋកាតាម
ច្បាប់ចរណៃរបស់ប្រទេស ។

ឋ គណៈសង្ឃក្នុងពុទ្ធសាសនា ត្រូវចាត់ការទំនុកបម្រុងតាមចាំង
ខ្លួលការ: ប្រកាសសាសនាតាមការចេះដឹង ដើម្បីនឹងជួយយឺតយោង
ប្រទេសឲ្យបានថ្កុំថ្កើងរៀងរាល ។

ណ អ្នកជាំ ត្រូវចាត់ការលេងល្បែងឲ្យបានពាន់សម័យ កុំរលៀ
តែអ្នកអើយ ខានអើយ នឹងការលេងរឿងដណ្តើមចលុំច្ចគាអង្គុយសោយ
រាជ្យក្នុងមួយយប់ៗ បួនដប់ជង ដដែលៗពេក ត្រូវចាត់ការលេងរៀ
ជាថ្នូរដើមនាំជាតិឲ្យខ្សើងកាន់អារ្យប្រទេសបានជង កុំរលៀតែឥស្សិប្រុស
ទឹងដប់មនុស្សស្លាប់ឲ្យសៅខ្សើងវិញ នាំឲ្យអ្នកមើល អួនស្តាប់ក័ន្ត
តំនិត ។

ចុងយប្រគ្រាងការដែលបានពោលមកខាងលើនេះ ជាថ្នូរដើមនាំ
ប្រទេសឲ្យដើរទៅកាន់អារ្យធម៌បានតាមបំណង ដោយកំឡាងកាយ
ឃ្មាងនេះ ហៅថាកាយសាមគ្គី ។

ខ - វចីសាមគ្គី ការព្រមព្រៀងគ្នាដោយវាចានោះគឺមនុស្សក្នុង
លោកចាំងមូលនេះមានប្រចែនជាតិប្រចែនសាសន៍ បើកចំតាមចំនួនកំរើញ
ថាប្រចែនណាស់ ដូចជាជាតិខ្មែរ ចិន យួន សៀម លាវជាដើម ជាតិ

ចាំងអស់នេះ សុទ្ធតែមានសំដីភាសាផ្សេង ៗ គ្នា ដែលមកប្រែភាសាបេស់ជាតិមិនឲ្យប្រែឡើយ ប្រែកាន់ជាតិ ប្រែកាន់ភាសាតែរៀងខ្លួន លើងភាសាបេស់ខ្លួនថាជាភាសាឯកកល់ ៗ ប្រៀបដែរ សូម្បីជាតិណា ៗ ដែលកាន់ព្រះពុទ្ធសាសនាជួបគ្នា ក៏ព្រះពុទ្ធជាម្ចាស់ទ្រង់អនុញ្ញាតឲ្យរៀនសូត្រអានបាលីតាមសំឡេងអក្សរបេស់ជាតិកល់ ៗ ជាតិដែរ ព្រោះទ្រង់ពិចារណាឃើញថាជាការងាយស្រួលសិក្សា អាចឲ្យសម្រេចប្រយោជន៍បាន ។

ដោយហេតុនេះ បានជាអ្នកកាន់ព្រះពុទ្ធសាសនាកល់ប្រទេសសព្វថ្ងៃនេះ គេប្រកាន់វិធីអានបាលីឆ្ងាស្រួរផ្សេងស្លៀងពីគ្នាខ្លះដោយអន្ទះ ៗ តម្រូវទៅតាមអក្ខរក្រមបេស់ខ្លួន ព្រោះគេកាន់ជំនុំគ្មានឧត្តរកុលុត្តរនិងយមិឯត គម្ពីរចុលវគ្គ[1] ។

ជាតិណាតែគេស្រឡាញ់ជាតិភូមិបេស់គេហើយ គេក៏ស្រឡាញ់សំដីភាសា ទំនៀមអក្សរសោស្តរបេស់គេដែរ គេយល់ថាសំដីភាសាបេស់គេតែមតែល្អ ពិរោះ នាប់ចិត្ត បើទុកជាគេបង្ខំប្រឹក្សាពីកិច្ចការពេជការ ក៏គេនិយមប្រើភាសាបេស់ជាតិជាដាច់, ប៉ុន្តែភាសាឯទៀត ៗ ក៏គ្រូតែរៀនឲ្យចេះនឹងមានសោះក៏ពុំបាន ។ សូមបញ្ជាក់ឧទាហរណ៍ដូចខ្ញុំបានឲ្យឃើញថា ជួបជាសត្វសេត, សារិក, ថ្នាក់សត្វមន្តជាដើម គេតាប់

---

១ វិនយបិដកចុលវគ្គភាគ ១១ បញ្ហ ២៩០ ទំព័រ ២៣០ ដល់ ២៣១ ។

យកមកចំញឹមតាំងពីក្មេង ហើយគេបង្រៀនឲ្យទន់ភ្លន់ដោយភាសាមនុស្ស សត្វអស់នោះវាចេះទន់ភ្លន់ខ្លះដែរ, តែបើពុកជាដូច្នោះ ក៏វានៅតែមិនលះបង់សំឡេងតាស្លុះ សំក ។ ឧទាហរណ៍មកប្រាប់ណ្ហះនេះឲ្យឃើញថា សូម្បីសត្វតិរច្ឆានដែលកើតមកនៅតាំស្រុកខ្មែរមនុស្សយូរនៃយូរឆ្នាំក៏ដោយក៏វានៅតែស្រឡាញ់ថាតំភាសាវាជដែល ។

យើងជាជាតិមនុស្សខ្ពស់ជាងសត្វតិរច្ឆាន បើមិនទន់ភ្លន់ប្រើភាសាសំដីរបស់ជាតិឲ្យត្រឹមត្រូវ មិនស្រឡាញ់ភាសារបស់ជាតិទេ ឈ្មោះថាមនុស្សអន់ជាងសត្វតិរច្ឆានទៅទៀត ។

ហេតុនេះ យើងត្រូវស្រឡាញ់ភាសាសំដីរបស់ជាតិឲ្យជាជាងភាសាឯទៀត, ហើយត្រូវនោលតែពាក្យពិត ពាក្យល្អ ពិភេះគាប់ចិត្តនោលទៅហើយកើតផលប្រយោជន៍ ដែលអ្នកផងស្រឡាញ់ពេញចិត្ត, កុំនោលពាក្យគាត្រអកដែរច្រៃខេចផ្តាសា ចាក់ដោត រុកកួន ញុះញង់នាំអុជអាល បង្កាច់ បង្ខិច សង្កត់សង្កិន ញ៉ាំញី នាំឲ្យកើតក្តៅក្រហាយឲ្យបែកសាមគ្គី ឲ្យខូចផលប្រយោជន៍ជាតិ សាសនា ទឹងព្រះមហាក្សត្រឲ្យសោះ, បើយើងមិនកាន់ មិនប្រឹងប្រែតឹកតាមបែបនេះទេ សេចក្តីវិនាសអន្តរាយ ក៏មុខជាទំនើតទាន់ប្រាកដ សេចក្តីចំរើនទំនឹងមិនមានឡើយ ។

ការព្រមព្រៀងគ្នាដោយការពោលពាក្យសំដីយ៉ាងនេះ ហៅថា វចីសាមគ្គី ។

๓ - មនោសាមគ្គី ព្រមព្រៀងគ្នាក្នុងចិត្តនោះ គឺ : មនុស្ស យើងបុរសស្ត្រីដែលកើតមកក្នុងពិភពលោកនេះ មានចិត្តគំនិតអធ្យាស្រ័យខុសៗគ្នា ខ្លះចិត្តល្អ ខ្លះចិត្តអាក្រក់ រវើរវាយ តែការអ្វីៗ ឬធ្វើការអ្វីៗ ក៏មិនស្មើគ្នា ច្រើនតែចាស់ខុសឃ្លាតឆ្ងាយគ្នា មិនស្របគ្នាគំនិតយ៉ាងនេះ រមែងមានជាធម្មតាបស់មនុស្សគ្រប់ជាតិ ។ អ្នកជ្រាជ្រាំងឆ្លាត បានសង្កេតយើញថា ក្នុងក្រុម គណៈ សង្គម ឬប្រទេសនីមួយៗ បើមានចិត្តគំនិតអធ្យាស្រ័យមិនព្រមព្រៀង មិនស្មើគ្នាបែបនេះហើយ ក្រុម គណៈ សង្គម ឬប្រទេសនោះ មិនមានតម្លៃ មិនមានប្រយោជន៍ មិនលឿនទៅមុខក្តីសុខ - ចំរើនបានទេ ច្រើនតែដល់នូវសេចក្តីវិនាស ឬសេចក្តីអាប់ឱន ។

ប្រទេសនីមួយៗ លុះតែអស្រ័យនូវសេចក្តីព្រមព្រៀងគ្នាដោយចិត្ត គឺមានចិត្តគំនិតអធ្យាស្រ័យត្រូវគ្នា ស្របគ្នា មិនឃ្លាតឆ្ងាយគំនិតគ្នា ទោះបីធ្វើកិច្ចការ ឬតតែអ្វី មិនលំបាកធ្វើ ឬតតែមានកំឡាំង, មិនមានពុតត្បុតអាក្រក់ មិនក្បត់ចិត្តគ្នាឯង មិនមានគំនុំគុំគួនអាឃាតព្យាបាទគ្នាឯង ប្រាប់សេចក្តីកំបាំងដល់គ្នាឯង មិនលាក់សេចក្តីកំបាំងដល់គ្នាឯង ឲ្យគ្នាឯងបានសេចក្តីសុខ - ចំរើន មិនឲ្យគ្នាឯងដល់នូវសេចក្តីវិនាស ។

បើមានគំនិតអញ្ជើញស្រីយកព្រមៈព្រៀងគ្នា ដោយចិត្តបែបនេះហើយ ប្រទេសជាតិក្រុមគណៈ សង្គម សាសនា ទើបស្ទុះទៀងទៅកាន់សេចក្តីចំរើនយ៉ាងឆាប់ហ៊ោសព្វំនាន, ហ៊ានេះ ហៅថា មនោសាមគ្គី ។

ការព្រមព្រៀង មូលមិត្តស្រុះស្រួលគ្នា ដូចបានពោលមកខាងលើនេះ ពាក់ព័ន្ធជាគុណសម្បត្តិ ប្តូជាកំឡាំងមួយយ៉ាងវិសេសក្នុងលោក មានអានិសង្សអោបពាញអ្នកប្រតិបត្តិនោះ ឲ្យដើរលឿនទៅកាន់សេចក្តីចំរើនគ្រាន់តាលសម័យនិយម សត្រូវក៏ពុំហានបៀតបៀនឡើយ ។

សំនៃធ៌ើចំរើយសាមគ្គី ចប់តែប៉ុណ្ណេះ ។

តាលបើចប់ធម្មទេសនាហើយ សូមផ្សាយចំណែកកុសលបុញ្ញកុសលដល់អស់លោក អ្នកជាពុទ្ធបរិស័ទទាំងឡាយ ទៅកុងតម្ពុជរដ្ឋទាំងមូលឲ្យបានសេចក្តីសុខ - ចំរើនត្រប់ប្រការតរៀងទៅ ។

ឧក្កដេកកយា វេរា សោ តា សត្តុបទ្ទវា
អវេរោ តា អន្តរាយា ចិរំ សុខ្ខី ច នេ ជាសា

សេចក្តីក្តុក ខ្ទើងកេត ខ្ទើងកំយ ខ្ទើងពៀរទាំងឡាយក្តី សេចក្តីសោមនឹងសត្រូវ ខ្ទើងបង្កែពទាំងឡាយក្តី អន្តរាយទាំងឡាយដ៏ច្រើនក្តី សូមឲ្យវិនាសបាត់ទៅដោយឆាតេជៈ (នៃធម្មទេសនានេះ) ។

បរិយោសានគ្គំ ចប់

ពាក្យបោរឮ

រឿងពន្ធីគាស៊ូថ្វាយនេះ មានសេចក្តីប្រែជាច្រើនជាតិច្រើនភាសា នៅទ្វីបអឺរ៉ុបនិងទ្វីបអាស៊ុ ហួតដល់ទៅទ្វីបអាមេរិក ដូចមានបរិយាយអំពីរឿងនេះនៅក្នុងគាម្ពីរថា បើសិនអ្នកប្រែជាភាសាបាក់ឯសែសស្រាប់ ។ ឯសេចក្តីប្រែជាខ្មែរភាសានេះ យើងបានអាស្រ័យសេចក្តីប្រែជាភាសាបាក់ឯនិងសេចក្តីប្រែជាភាសាថៃ សម្រួលភាក្យតេចន៍ឲ្យបានជាយយល់ជាយស្តាប់ ដើម្បីជាគ្រឿងប្រដាប់សតិបញ្ញារបស់ពុទ្ធសាសនិកជនជាតិយើង ។

គ្រាន់ឈ្មោះរឿងក្នុងសៀវភៅជាភាសាបាក់ឯសែស ហៅថា "ឡាលុយម៉ាញ ដឺឡាស៊ី" (La Lumière de l'Asis) ឈ្មោះសៀវភៅបើសំរឿងជាដែលនេះ ជាភាសាថៃ ហៅថា "ប្រទីបនៃទ្វីបអាស៊ី" ។ ឯឈ្មោះរឿងក្នុងសៀវភៅជាខ្មែរភាសាយើងនេះ ហៅថា "ពន្ធីគាស៊ូទ្វីប" ។ ដោយសារសេចក្តីក្នុងផ្លែរឿងរបស់សៀវភៅនេះ មានសេចក្តីពិពេះពិសារដោយអត្ថសេទិនិងភាក្យតេចន៍ បានជាត្រូវគេប្រែតៗគ្នាចេញទៅជាច្រើនភាសា ហើយក្នុងភាសានិមួយៗ គេបានបោះពុម្ពផ្សាយចេញជាច្រើនលើនច្រើនគ្រា ដូរតែតាមសេចក្តីត្រូវការរបស់ប្រជាជនក្នុងប្រទេសនោះៗ ។ ឯសេចក្តីប្រែជាខ្មែរភាសាយើងនេះ យើងមិនគាបជាន៉ាក់ប៉ាវ៉ែថា មានសេចក្តីពិពេះពិសារជាងឬប្លែកលើនសេចក្តី

ប្រែជាភាសានានាប្រទេសនោះទេ ប៉ុន្តែយើងយល់ថាពួកអាស៊ីខ្ញុំបាទនេះ
ថ្លែងពីប្រវត្តិ ព្រះធម្មចរិយា ទំនឹងព្រះបញ្ញត្តិជាដើម របស់ព្រះសម្ពា-
សម្ពុទ្ធជាអម្ចាស់ប៉ែកខាងមហាយាន ដែលមានសេចក្តីដើមជាភាសា
សំស្ក្រឹត សឹងមានសេចក្តីថ្លែងរឿងស្រដៀងគ្នាខ្លះ ខុសគ្នាខ្លះដោយអន្លើ ។
ទំនឹងពុទ្ធប្រវត្តិប៉ែកខាងហីនយានរបស់យើង ។

ហេតុដូច្នេះ ទើបគួរតែពុទ្ធសាសនិកជនជាតិយើង ដែលគោរព
លទ្ធិថេរវាទប្តូហីនយាន គប្បីសិក្សាពុទ្ធប្រវត្តិ ទំនឹងគោលធម៌អាថ៌សាន់ៗ
ព្រមទាំងរឿងកំប៉ែលផង ។ ប៉ែកខាងមហាយានឲ្យបានច្បាស់លាស់ខ្លះ
ជាគ្រឿងប្រដាប់សតិបញ្ញារបស់យើង ។ នៅទីបំផុត យើងអាចយល់
ឃើញដឿជាក់ថា គ្រាន់តែអាម្នាក់ថា របស់អ្នកប្រែជាភាសាបាលីឯណោះ
ឬភាសាអាំងគ្លេស ក៏ល្មមជាគ្រឿងបញ្ជាក់ខ្ញុំនៃព្រះពុទ្ធសាសនា
សឲ្យឃើញច្បាស់ថា គុណធម៌របស់ព្រះពុទ្ធសាសនាជ្ញានសាយភាយ
ចេញៗ ស្មើរតែសត្វពិភពផែនដី ។ មនុស្សលោកសំដែងសេចក្តី
គោរពចំពោះព្រះពុទ្ធសាសនា មានចំនួនដល់ៗ ។ ក្នុងភាគ ៣ គួរ
ឲ្យអស្ចារ្យដល់អាទុភាពនៃព្រះពុទ្ធសាសនាពន់ពេកណាស់ ។

ហ្វូងមិត្តទ្ធម្មន្តិ ញ៉ុក - ថែម

ថណ្ឌិត នៅពុទ្ធសាសនបណ្ឌិត្យ

ឥវ៉ាន់ហូ

កថាមុខរបស់អ្នកប្រែ

(ពីភាសាអង់គ្លេស ជាភាសាជាតិសៃ)

ការសរសេរដែលមានសេចក្តីដោយសង្ខេបនេះ មានក់ចិត្តជាប់ចិត្ត, ពោលអំពីរឿងកំរើតអស្ចារ្យ, ថ្លែងអំពីលទ្ធិដ៏វិសេសរបស់ព្រះពុទ្ធ រឿងនេះបានខ្ចាយសាយចេញទៅក្នុងចំណោមប្រទេសអង់គ្លោសក្សុន (Anglo saxons) ហើយមានកត់សរសៃរៀងជាច្រើនដែលអ្នកចាប់ចាន់សរសេរឡើងអំពីរឿងដដែលនេះ; នៅក្នុងឡុង (ប្រទេសអង់គ្លេស) គេបានបោះពុម្ពផ្សាយមកហើយជាង ៩០ លើក នៅប្រទេសសហរដ្ឋអាមេរិក គេបានបោះពុម្ពជាង ១០០ លើកមកហើយ; មួយវិញទៀត គេបានប្រែចេញជាភាសាអ៊ីរុបទាំងអស់ភាសា ទាំងបូកាប្រទេស ជាច្រើនភាសា, នៅប្រទេសឥណ្ឌា គេបានប្រែជាច្រើនបទសក្សាជាង ។

យើងបានយល់ឃើញថា គួរតែចាត់ផ្សាយរឿងដ៏មានខ្លឹមសារនេះដែលជាស្នាដៃរបស់ការីជាន់ឯកម្នាក់ នៃប្រទេសអង់គ្លេស ក្នុងសម័យបច្ចុប្បន្ននេះ ឲ្យបានដឹងឮកាល់គ្នាឡើង ក្នុងប្រទេសចក្រីសៃសនេះ។ ដើម្បីសេចក្តីរុងរឿងដល់សៀរកៅ «ឥវ៉ាន់ហូ» នេះ ដែលជារឿងថ្លែងអំពីយោធាដ៏ខ្លាំងក្លាស់ របស់ប្រទេសទំនាងលិច ពីព្រោះ

ម៉ោតាមការសន្មតដ៏ទៀងទាត់របស់លោក ស៊ីវ្រៃយ៉ូង នោះយល់ឃើញថា "រឿងរស់ដែលពួកមហាបុរសកំពុងនាំគ្នាសិក្សាក្នុងសម័យបច្ចុប្បន្ននេះ ពួកមុនីពុទ្ធសាសនាបានបង្ហាត់បង្រៀន តាំងអំពី ๒๓ សតវត្សមកហើយ" ។

ការពិចារណាឲ្យឃើញទុក្ខ នឹងការតស៊ូរបស់ពិភពលោក បញ្ជាក់នៃការប្រែប្រួល បច្ចុប្បន្នការ ដំណើរគេ។ គ្មានមនុស្សម៉ាស់ឈរ, ការផ្លាស់ប្តូរមួយគ្នានៃលោក អាការជាប់ដំពាក់ពាក់ពន្ធយ៉ាងជាតស្ទុះនៃសត្វលោក ការប្រែប្រួលជាភាពផ្សេង។ មិនប្រែតែរ ការបន្តុះអំពើគេក្រក់ឲ្យតិចចុះ។ ដោយការចន្លែមចំណេះចេះដឹងឲ្យចំរើនកើនឡើង ការបំពេញប្រយោជន៍អ្នកដទៃនឹងការសាមគ្គីចម្រុងគ្នា ដ៏ថ្លៃថ្លាងនេះ សឹងត្រូវត្រង់តាមផ្លូវវិទ្យាសាស្ត្រ នឹងប្រាជ្ញវិទ្យាទំនើបថ្មី នេះហើយដែលជាសេចក្តីពិតដ៏ខ្ពង់ខ្ពស់ ដែលព្រះពុទ្ធជាម្ចាស់ទ្រង់ត្រាស់ទេសនាទុកមក ។

កាលទ្រង់ជួបជាបញ្ហាដ៏ជាក់ច្បាស់ ដោយទ្រង់ទតឃើញទុក្ខសោកនឹងការវេទនារបស់សត្វសត្វដែលមានជីវិតជាំងពួង ទើបទ្រង់តាំងព្រះទ័យជាចំស្រេចថា នឹងស្វែងរកមូលហេតុនឹងថ្នាំសំរាប់បំបាត់ភេតនេះ ។ ហេតុដូច្នេះហើយ បានជាព្រះអង្គទ្រង់លះបង់សេចក្តីសុខសម្រាន្តដែលទ្រង់បានសោយ ស្តេចចេញទៅតែងតែមួយព្រះអង្គឯង

ហ្នឹងធ្វើយ៉ាងចាកការភ្លើតភ្លើនពីកាយ ទំដាក់តតណ្ហាដែលធ្វើឲ្យព្រះចំយ
ខ្វក់ខ្វល់ ហើយខ្ញុំដំបូនចំខ្លួនព្រះហ្ឫទ័យឲ្យធ្ងន់ផុតចាកតំមិតចាស់ចាំង
អម្បាលម៉ាន ដោយខ្ញុំដំកល់ព្រះហ្ឫទ័យក្នុងថ្នាសមាធិភាវនា ។

មុនដំបូង ព្រះអង្គខ្ញុំបានជ្រាបច្បាស់ថា ព្រះអង្គមិនអាចរកឲ្យ
ឃើញផលសំរេចនៃប្រស្នានេះទេ ទោះបីទៅស្ថានសួគ៌ក្តី ទោះបី
នៅស្ថានមនុស្សលោកដែលឥតបិតរថេរនេះក្តី ប៉ុន្តែនៅមានការពិតតែ
អ្នួយ ដែលយើងចេះដឹងយល់បានភ្លាម គឺសេចក្តីពិតដែលនៅកន្លែង
បើងនេះ ហើយជាថ្នាក់ដំបូង ដែលត្រូវអស្រ័យការពិចារណា, កិច្ច
ការនឹងសេចក្តីប្រព្រឹត្តិរបស់យើង ហើយខ្ញុំបានពិនិត្យពិចារណាវិធី
ប្រតិបត្តិ ខ្ញុំក៏បានជួបប្រទះនឹងហេតុផលដែលគ្មានអ្នកណា កែទៀ
ខ្វៃតបាន ទាំងខ្ញុំឯងពាត់ជានិច្ចនិរន្តរ៍ ដែលព្រះអង្គខ្ញុំបម្រុងបញ្ចូល
ទៅកន្លែមហាបញ្ញាត្តិរបស់តម្ន ។

ព្រះអង្គខ្ញុំយល់ឃើញថា កម្មរបស់យើងតែទំពាំរតូវខ្លួនឯង
តម្ន្នោះបេះតែបង្កើតឡើងតៗ គ្មានជាលំដាប់ទៅ ចំរើនទ្វាំងតូវឡើង
ដោយការខម្លាច ពាក់ពន្ធខ្ញុំនៅកន្លែងខ្លួនយើង តែប្រែសន្តានចិត្ត
របស់យើង, លក្ខណៈរបស់យើង មិនឲ្យដឹងខ្លួន ទោះបីកាយ
ក៏តូវតែប្រែដែរ ដោយហេតុនេះ កម្មល្អតែងឲ្យផលល្អដល់យើង
តម្ន្នាតែកំតែងធ្វើឲ្យយើងបានខុកខ្ញោសៈ ហើយរសៅសោកតូវតែក

តើយើងត្រូវតែបានខួលភ្នាក់ ឬ ផលនៃការងារបស់យើងដោយខ្លួនឯង
មួយវិញទៀត ព្រះអង្គទ្រង់យល់ឃើញថាផលនៃសេចក្តីប្រព្រឹត្តពាន់នេះ
តែងតែកើតចំពីរបាក ជាមានគ្រោះថ្នាក់ដល់ខ្លួន តាមចំណែង
នៃខ្សែឡុកឡាយពាន់ឡាយរកទីបំផុតគ្មានតើជាកូនបៅរបស់យើងបណ្តុះ
បណ្តាលឲ្យបានផងចំរើនឡើង ឬបានខួលទុក្ខវេទនាវៀរពេញសាច
សួនឲ្យៅ, សួមឲ្យខ្លួនយើងសោតទៀត ដែលបានសប្បាយ ឬ ទុក្ខសោក
ក៏សុទ្ធតែជាផលដែលជាមត៌តរបស់ខ្លួនឯង អំពីអតីតកាល ។

នៅក្នុងរង្វង់ការពិចិត្យពិចារណារបស់ព្រះអង្គ ព្រះពុទ្ធជាម្ចាស់
ទ្រង់យល់ថា លោកនេះជាទីស្មាក់នៅណោះអាស្រ័យរបស់សត្វលោកកកើត
ឡើងជារូបកាយផ្សេង ។ ពាន់ពាន់លាន ចង់ភ្ជាប់ជាមួយគ្នាន័ង "កន់"
នៃការរំលែកប្រែប្រួលៅ ដោយកម្លាំងច្រើនរៃនៃរបស់ខ្លួនឯង ។

ៅទីបំផុត យើងកាល់គ្នា នៅក្នុងកំរិតជាប់ស្រេច, រួបរួមនៅក្នុង
ជោគជតាមួយជាមួយគ្នា ឥតឥស្សរភាព ចង់ចាប់គ្នាយ៉ាងម៉ឺងម៉ាត់
យើងត្រូវរួបរួមកិច្ចការជាមួយគ្នា ដោយឥតរេតនាឬមានរេតនាក៏ដោយ
តែដែលនាំឲ្យយើងបានខួលសេចក្តីសុខរបស់ខ្លួនឯងបានខ្លោះ លុះតែ
យើងជួយអ្នកឯទៀតឲ្យបានសេចក្តីសុខផង ដរាបដល់បានសម្រេចសេចក្តី

សុទ្ធជាខ្ពង់ខ្ពស់ផុត គឺព្រះនិព្វាណៈ[1] ត្រមាំងដឹងឲ្យដើរតាមដំណើរបស់យើង ដោយការមិនទទឹកនាដល់ច្រាំងភ្លាល់ខ្លួន, គឺការមេត្តាប្រណីនឹងការឆ្លើតាន ។ បើគោលដោយផ្លូវដូចគ្នានោះ សេចក្តីទុក្ខជាហេតុបង្កើតអរិយសច្ចៈ ដែលជាគួរស្ងប់ចិត្តយើងឲ្យឈប់ខ្សាច់ត្រូវ, នាំឲ្យយើងមានមច្ចរិយៈ, ល្មោភខ្លៃឮសម្បត្តិដែលមិនប៉ិនថេរ ហើយនាំឲ្យដើរខុសចាក "ផ្លូវខ្ញែងត្រង់" ។ ដូច្នេះ ទើបយើញឮឮស់ថាមានតែវិជ្ជានឹងការមេត្រី, បារមីធម៌នឹងសីលធម៌ទេ "ដែលជាគ្រឿងកំចាត់រំលាយបញ្ហានៃសេចក្តីទុក្ខ លើកលែងការគេស្ងួតនឹងការព្រួយលំបាក ត្រមាំងញ៉ាំងបារមីធម៌សុទ្ធភ្លាល់ខ្លួន នឹងសម្រាប់លោកឲ្យកើតឡើងបានផង ។ (មានត)

• យើងយល់សមតាមលោក អ៊ិត វិន អារណុលត៍ (M. Edvin Arnold) ក្នុងសេចក្តីដែលថា ព្រះនិព្វានោះមិនមែនជាធម្មជាតិរលត់សូន្យឈឹងទេ ទាំងមិនមែនជាសភាពទ្រទ្រង់នៅជាប់ស្រាប់ យើងមិនត្រូវការរកបន្ថែលសាច្បីងទៀត ក្រៅពីព្រះពុទ្ធាទេថា ៖ កាលបើបានដួយខ្លួនឯងរួចហើយ ត្រូវដួយអ្នកដទៃទៀតផង, កាលខ្លួនបានឆ្លងដល់ត្រើយឯណាហើយ ត្រូវដួយចម្លងអ្នកដទៃឲ្យបានឆ្លងដល់ត្រើយនោះផង, ចូរគោះទុក្ខខ្លួនដើម្បីគោះទុក្ខរបស់គេផង, កាលខ្លួនបានលះដល់ព្រះនិព្វានជាប់ស្រេចហើយ, ត្រូវដួយអ្នកដទៃឲ្យបានលះដល់ព្រះនិព្វាននោះផង; និព្វាន គឺធម្មជាតិដែលមានទៅគ្មានទីបំផុត ហើយទៀងទាត់ជានិច្ច ។ តាមដោយពិតនោះ មានអ្នកបេះត្រុះរើនឹប្រែសើរអ្នក ជានថ្លែងតំនែងយោបល់នឹប្រែសើរទុកថា "ការរស់នៅរួមជាមួយនឹងអ្នកដទៃ ជាដីវិតដ៏ខ្ពង់ខ្ពស់ ប៉ុន្តែកាលណាមើលឃើនឆ្លងត្រើទេតរបស់យើង ដោយក្តីសើរភាពហើយ យើងមុខជាលែងដួបប្រទះនឹងពិប្រែលំនួយទៀត ហើយទ្វារនៃសភាវៈគ្មានទីបំផុត (និព្វាន) ក៏នឹងបើកចំហសម្រាប់យើង" ។ Y. Gaura's Revue de Reine 1er Décembre 1892

អំពីការតាំងថ្មៅអធិការថ្មី

ចាប់តាំងពីខែមករា ឆ្នាំ ១៩៤៧ - ៤៨

សញ្ញាប័ត្រលេខ ១ ចុះថ្ងៃពុធ ២ កេីត ខែ បុស្ស ឆ្នាំច អដ្ឋស័ក តាំង លោកគ្រូអាន - មៅ នាមធាងា ធម្មសុវណ្ណ កេីតឆ្នាំមមី អាយុ ៥៦ វស្សា ៣១ ជាចៅអធិការវត្តឥន្ទវិលាភម ឃុំអំពិល ស្រុកកំពង់សៀម ខែត្រកំពង់ចាម ។

សញ្ញាប័ត្រលេខ ២ ចុះថ្ងៃព្រហស្បតិ៍ ១០ កេីត ខែបុស្ស ឆ្នាំច អដ្ឋស័ក តាំងលោកគ្រូ អ៊ុម - យ៉ នាមធាងា ខិប្បបញ្ញោ កេីតឆ្នាំជូត អាយុ ៣៥ វស្សា ១៦ ជាចៅអធិការ វត្តសុវណ្ណសនាភម ឃុំតាំងក្រសាំង ស្រុកទឹកផុះ កំពង់ឆ្នាំង ។

សញ្ញាប័ត្រលេខ ៣ តាំងលោកគ្រូ ខាង ខុត នាមធាងា បទ្ធសិរិ កេីតឆ្នាំ ១៩០៩ អាយុ ៣៩ វស្សា ១៤ ជាចៅអធិការ វត្តវៃជ្រ ឃុំចំណែត ស្រុកស្វាយទាប ខែត្រកណ្តាល ។

សញ្ញាប័ត្រលេខ ៤ ចុះថ្ងៃ អង្គារ ១៥ កេីត ខែ បុស្ស ឆ្នាំច អដ្ឋស័ក តាំងព្រះញាណកោសល នាមធាងា ជោតិប្បញ្ញោ កេីតឆ្នាំថោះ ឆាយុ ៥៥ វស្សា ៣៤ ជាចៅអធិការវត្តចម្ប៉ា ឃុំក្បាលកោះ ស្រុកកៀនស្វាយ ខែត្រកណ្តាល ។

សញ្ញាប័ត្រលេខ ១ ចុះថ្ងៃ ២៨ មករា ៤៧ តាំងលោកកិត្តិ តន់-
ម៉ាន់នាមធាយ ជម្មការមោ កើតឆ្នាំជូត អាយុ ៥៨ វស្សា ១៩ ជាចៅ
អធិការ វត្តសុត្តាកម ឃុំតគារ ស្រុកកៀមស្វាយ ខេត្តកណ្តាល (ចែក
ទាំងគណៈជម្មយុត្តិ) ។

សញ្ញាប័ត្រលេខ ២ ចុះថ្ងៃ ៣០ មករា ៤៧ តាំងលោកកិត្តិ អ៊ុក-ទ
នាមធាយ ទត្តមោ កើតឆ្នាំកុរ អាយុ ៤៨ វស្សា ២៨ ជាចៅអធិការ
វត្តសន្ទុង ឃុំសន្ទុង ស្រុកព្រៃឆ ខេត្តតាកែវ (ចែកទាំងគណៈជម្មយុត្តិ) ។

សញ្ញាប័ត្រលេខ ៦ ចុះថ្ងៃព្រហស្បតិ៍ ៨ កេច ខែមាឃ ឆ្នាំច អដ្ឋ-
ស័ក តាំងលោកកិត្តិ តាត-តិច នាមធាយ ជម្មបញ្ញា អាយុ ៣៩ វស្សា
១៩ ជាចៅអធិការវត្តគោះអណ្តែត ឃុំម្លាក់ ស្រុកភ្នំពេញ ខេត្តកណ្តាល ។

សញ្ញាប័ត្រលេខ ១១ ចុះថ្ងៃចន្ទ ៥ កើត ខែផល្គុន ឆ្នាំចអដ្ឋស័ក តាំង
លោកកិត្តិ ជា-ខួន នាមធាយ ធម្មវត្តានិវ៌ អាយុ ៦២ វស្សា ៤១ ជាចៅ-
អធិការ វត្តក្លោកមាសលើ ឃុំព្រៃត្រែ ស្រុកកំពង់លែង កំពង់ឆ្នាំង ។

សញ្ញាប័ត្រលេខ ១២ ចុះថ្ងៃ អង្គារ ៤ កេចខែផល្គុន ឆ្នាំចអដ្ឋស័ក
តាំងលោកកិត្តិ សាន់-ស៊ុន នាមធាយ ព្រហ្មជោត កើតឆ្នាំរោ អាយុ
៤៧ វស្សា ២៦ ជា ចៅអធិការវត្តក្លាន ឃុំតាស្នួត ស្រុកចាគាន ខេត្ត
ព្រៃវែង ។

សញ្ញាប័ត្រលេខ ១៣ ចុះថ្ងៃអង្គារ ៩ កេីតខែផល្គុន ឆ្នាំចសំឭ
តាំងលោកគ្រូ អ៊ុម - ផុន នាមឆាយា វិជ្ជង្គជោត កេីតឆ្នាំរកា អាយុ ៦៩
វស្សា ៩ ជាចៅអធិការ វត្តឈូកស ឃុំព្រៃស្រែ ស្រុកទន្លេបាទី ខែត្រ
កំពង់ស្ពឺ ។

សញ្ញាប័ត្រលេខ ១៤ ចុះថ្ងៃអង្គារ ៣ កេីតខែពិសាខ ឆ្នាំកុនឭស័ក
តាំងលោកគ្រូ សម - ហាម នាមឆាយា បន្ទុបុប្ផា កេីតឆ្នាំមមែ អាយុ ៤១
វស្សា ១៧ ជាចៅអធិការ វត្តព្រះម្លូ ឃុំព្រះម្លូ ស្រុកបាកាន ខែត្រ
ពោធិ៍សាត់ ។

សញ្ញាប័ត្រលេខ ១៥ ចុះថ្ងៃអង្គារ ៣ កេីតខែពិសាខ ឆ្នាំកុនឭស័ក
តាំងលោកគ្រូ ស៊ូ - ចន្ទ នាមឆាយា ឥន្ទលិខិត កេីតឆ្នាំជូត អាយុ ៤៨
វស្សា ២៧ ជាចៅអធិការ វត្តថ្មៃ ឃុំព្រះម្លូ ស្រុកបាកាន ខែត្រ
ពោធិ៍សាត់ ។

សញ្ញាប័ត្រលេខ ១៦ ចុះថ្ងៃអង្គារ ៣ កេីតខែពិសាខ ឆ្នាំកុនឭ-
ស័ក តាំងលោកគ្រូ អ៊ុម - អៀម នាមឆាយា សុវណ្ណភ្នែរ កេីតឆ្នាំកុរ
អាយុ ៣៦ វស្សា ១៦ ជាចៅអធិការ វត្តនន្ទមង្គលារាម ស្រុកបាកាន
ខែត្រពោធិ៍សាត់ ។

សញ្ញាប័ត្រលេខ ១៨ ចុះថ្ងៃអង្គារ ៣ កេីតខែពិសាខ ឆ្នាំកុនឭ
ស័ក តាំងលោកគ្រូ អ្នក - ប៊ុត នាមឆាយា ឥន្ទសុវណ្ណ កេីតឆ្នាំកេង

អាយុ ៣៤ វស្សា ១០ ជាចៅអធិការវត្តឧលលៀប ស្រុកចាកាន ខេត្ត
តោងធំសាត់ ។

សញ្ញាប័ត្រលេខ ១៩ ចុះថ្ងៃចន្ទ ២ កើតខែពិសាខ ឆ្នាំកុនទព្វស័ក
តាំងលោកគ្រូ ទុម - លាង នាមធាយ ឥន្ទ្រសុវណ្ណ អាយុ ៥០ វស្សា ៣០
ជាចៅអធិការវត្តអង្គស្មុក ឃុំនគរឡាក ស្រុកកំពង់ត្រាញ ខេត្តតណ្ដាល ។

សញ្ញាប័ត្រលេខ ២០ ចុះថ្ងៃចន្ទ ២ កើតខែពិសាខ ឆ្នាំកុនទព្វស័ក
តាំងលោកគ្រូ អឹង - សុខ នាមធាយ មុនីជោតោ កើតឆ្នាំច អាយុ ៤០
វស្សា ១៧ ជាចៅអធិការវត្តគ្លោត ឃុំលំហាច ស្រុកកំពង់ត្រាញ ខេត្ត
តណ្ដាល ។

សញ្ញាប័ត្រលេខ ២១ ចុះថ្ងៃចន្ទ ២ កើត ខែពិសាខ ឆ្នាំកុនទព្វស័ក
តាំងលោកគ្រូ ស៊ុង - ប៉ុច នាមធាយ ឥន្ទ្រគ្គោ កើតឆ្នាំមមែ អាយុ ៤០
វស្សា ២០ ជាចៅអធិការ វត្តឈូកឧណ្ហំ ឃុំឧលលៀប ស្រុកកំពង់ត្រាញ
ខេត្តតណ្ដាល ។

សញ្ញាប័ត្រលេខ ២២ ចុះថ្ងៃព្រះហស្បតិ៍ ៥ កើតខែពិសាខ ឆ្នាំកុរ
ឧព្វស័ក តាំងលោកគ្រូ ខេត - សៃ នាមធាយ ឥន្ទ្រគេសរ កើតឆ្នាំរោង
អាយុ ៥៥ វស្សា ៣២ ជាចៅអធិការវត្តអង្គរោង ឃុំមហាឫស្សី ស្រុក
គងពិសី ខេត្តកំពង់ស្ពឺ ។

សញ្ញាប័ត្រលេខ ២៦ ចុះថ្ងៃព្រហស្បតិ៍ ៥ កើតខែពិសាខ ឆ្នាំកុរនព្វស័ក តាំងលោកគ្រូ សោម កេត នាមនាយា ធម្មធេសរ កើតឆ្នាំមមែ អាយុ ៥២ វស្សា ៣២ ជាចៅអធិការ វត្តមង្គលមានជ័យ ឃុំពោធិ៍ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ។

សញ្ញាប័ត្រលេខ ២៤ ចុះថ្ងៃព្រហស្បតិ៍ ៥ កើតខែពិសាខ ឆ្នាំកុរនព្វស័ក តាំងលោកគ្រូ សុខ - សុខន នាមនាយា សុវណ្ណគេរ កើតឆ្នាំវក អាយុ ៤១ វស្សា ១៦ ជាចៅអធិការ វត្តឧលខន្ធាប់ ឃុំស្វាយពោ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ។

សញ្ញាប័ត្រលេខ ២៥ ចុះថ្ងៃព្រហស្បតិ៍ ៥ កើតខែពិសាខ ឆ្នាំកុរនព្វស័ក តាំងលោកគ្រូ សួស - អុប នាមនាយា ឥន្ទបញ្ញា កើតឆ្នាំកុរ អាយុ ៤៨ វស្សា ២៨ ជាចៅអធិការវត្តអង្គលំខង ឃុំស្ទុងត្រែ ស្រុកគងពិសី កំពង់ស្ពឺ ។

សញ្ញាប័ត្រលេខ ២៦ ចុះថ្ងៃព្រហស្បតិ៍ ៥ កើតខែពិសាខ ឆ្នាំកុរនព្វស័ក តាំងលោកគ្រូ ប៉ប់ សុខ នាមនាយា សុវណ្ណគេរ កើតឆ្នាំមមែ អាយុ ៦៥ ឆ្នាំ វស្សា ៤៦ ជាចៅអធិការវត្តចរសែត ឃុំចរសែត ស្រុកគងពិសី កំពង់ស្ពឺ ។

សញ្ញាប័ត្រលេខ ២៧ ចុះថ្ងៃព្រហស្បតិ៍ ៥ កើតខែពិសាខ ឆ្នាំកុរនព្វស័ក តាំងលោកគ្រូ ខែន - ជា នាមនាយា ធម្មជោតគេរ កើតឆ្នាំជូត

អាយុ ៥៨ ឆ្នាំ វស្សា ៣៨ ជាចៅអធិការវត្តរួលត្រាច ឃុំមង្គលសេល ស្រុកគងពីសី កំពង់ស្ពឺ ។

សញ្ញាប័ត្រលេខ ២៨ ចុះថ្ងៃព្រហស្បតិ៍ ៥ កើតខែពិសាខ ឆ្នាំកុរ ឧព្វស័ក តាំងលោកគ្រូ ម៉ុក - ហូ នាមធម្មា ឧបនន្ទោ អាយុ ៥៥ ឆ្នាំ វស្សា ២៨ ជាចៅអធិការវត្តដីកដ្រែ ឃុំទឹកល្អក់ ស្រុកគងពីសី កំពង់ស្ពឺ ។

សញ្ញាប័ត្រលេខ ២៩ ចុះថ្ងៃព្រហស្បតិ៍ ៥ កើតខែពិសាខ ឆ្នាំកុរ ឧព្វស័ក តាំងលោកគ្រូ អ៊ូ - ម៉ាង នាមធម្មា សុវណ្ណសរ កើតឆ្នាំកោ អាយុ ២៥ ឆ្នាំ វស្សា ៥ ជាចៅអធិការវត្តព្រះវៃ ឃុំស្វាយចចិម ស្រុកគងពីសី កំពង់ស្ពឺ ។

សញ្ញាប័ត្រលេខ ៣០ ចុះថ្ងៃព្រហស្បតិ៍ ៥ កើតខែពិសាខ ឆ្នាំកុរ ឧព្វស័ក តាំងលោកគ្រូ សួស - អឹម នាមធម្មា ឥន្ទ្រោ កើតឆ្នាំមមី អាយុ ៦៥ ឆ្នាំ វស្សា ៤ ជាចៅអធិការវត្តអង្គអណ្តែត ឃុំពោធិ៍អន្លង ស្រុកគងពីសី កំពង់ស្ពឺ ។

សញ្ញាប័ត្រលេខ ៣១ ចុះថ្ងៃព្រហស្បតិ៍ ៥ កើតខែពិសាខ ឆ្នាំកុរ ឧព្វស័ក តាំងលោកគ្រូ សោម - គោះ នាមធម្មា សុវណ្ណជោតគ្គោ កើតឆ្នាំកេង អាយុ ៦៧ ឆ្នាំ វស្សា ៤៦ ជាចៅអធិការវត្តត្រែងធំ ឃុំពោធិ៍អន្លង ស្រុកគងពីសី កំពង់ស្ពឺ ។

សញ្ញាប័ត្រលេខ ៣២ ចុះថ្ងៃព្រហស្បត៍ ៥ កើតខែពិសាខ ឆ្នាំកុរ ឯកស័ក តាំងលោកគ្រូ សួស-ចាច នាមឆាយា ឧទ្ទុត្តរ កើតឆ្នាំជេស អាយុ ៦៧ ឆ្នាំ វស្សា ៤៦ ជាចៅអធិការវត្តអង្គពពេល ឃុំពោធិ៍អន្លង់ស្រែកតង្គពិសី កំពង់ស្ពឺ ។

សញ្ញាប័ត្រលេខ ៣៣ ចុះថ្ងៃព្រហស្បត៍ ៥ កើតខែពិសាខ ឆ្នាំកុរ ឯកស័ក តាំងលោកគ្រូ ថែន-ជួរ នាមឆាយា ជម្មបញ្ញា កើតឆ្នាំជេស អាយុ ៤២ ឆ្នាំ វស្សា ១៩ ជាចៅអធិការ វត្តអង្គមានជ័យ ឃុំវាលស្រែកតង្គពិសី កំពង់ស្ពឺ ។

សញ្ញាប័ត្រលេខ ៣៤ ចុះថ្ងៃព្រហស្បត៍ ៥ កើតខែពិសាខ ឆ្នាំកុរ ឯកស័ក តាំងលោកគ្រូ ឯក-ឡាង នាមឆាយា ឯកត្តរ កើតឆ្នាំកុរ អាយុ ៤៧ វស្សា ២៧ ជាចៅអធិការ វត្តព្រៃកាន់ ឃុំវាលស្រែកតង្គពិសី កំពង់ស្ពឺ ។

សញ្ញាប័ត្រលេខ ៣៥ ចុះថ្ងៃព្រហស្បត៍ ៥ កើតខែពិសាខ ឆ្នាំឆ្លូវ អដ្ឋស័ក តាំងកិត្តិ ថែន : ញាណ នាមឆាយា មង្គលកេសរ កើតឆ្នាំកុរ អាយុ ៦៤ វស្សា ៤ ជាចៅអធិការវត្តថ្លៃជ្រហ្ម ឃុំវាលស្រែកតង្គពិសី កំពង់ស្ពឺ ។

សញ្ញាប័ត្រលេខ ៣៦ ចុះថ្ងៃព្រហស្បត៍ ៥ កើតខែពិសាខ ឆ្នាំកុរ ឯកស័ក តាំងលោកគ្រូ តង់-សុខ នាមឆាយា សុទ្ធរត្តរ កើតឆ្នាំរោ

អាយុ ៤៨ ឆ្នាំ វស្សា ២៦ ជាចៅអធិការវត្តសែនខៀវ ឃុំស្រែង ស្រុក
គងពីស៊ កំពង់ស្ពឺ ។

សញ្ញាប័ត្រលេខ ៣៧ ចុះថ្ងៃព្រហស្បតិ៍ ៥ កើតខែពិសាខ ឆ្នាំកុរ
ឧព្វស័ក តាំងលោកគ្រូ ឯក លឹម នាមធម្មយោ អច្ឆន្ទត្ថេរ កើតឆ្នាំមមែ
អាយុ ៥១ ឆ្នាំ វស្សា ៣១ ជាចៅអធិការវត្តតាកេម ឃុំស្រែង ស្រុកគង
ពីស៊ កំពង់ស្ពឺ ។

សញ្ញាប័ត្រលេខ ៣៨ ចុះថ្ងៃព្រហស្បតិ៍ ៥ កើតខែពិសាខ ឆ្នាំកុរ
ឧព្វស័ក តាំងលោកគ្រូ សោម-ចិន នាមធម្មយោ សុវណ្ណត្ថេរ កើតឆ្នាំ
ថោះ អាយុ ៤៣ ឆ្នាំ វស្សា ២៣ ជាចៅអធិការវត្តអង្គស្វា ឃុំស្រែង
ស្រុកគងពីស៊ កំពង់ស្ពឺ ។

សញ្ញាប័ត្រលេខ ៣៩ ចុះថ្ងៃព្រហស្បតិ៍ ៥ កើតខែពិសាខ ឆ្នាំកុរ
ឧព្វស័ក តាំងលោកគ្រូ កែវ-ស៊ុម នាមធម្មយោ សុវណ្ណត្ថេរ កើតឆ្នាំជ
អាយុ ៣៩ ឆ្នាំ វស្សា ១៣ ជាចៅអធិការវត្តកាតភ្លុក ឃុំផុង ស្រុក
គងពីស៊ កំពង់ស្ពឺ ។

សញ្ញាប័ត្រលេខ ៤០ ចុះថ្ងៃព្រហស្បតិ៍ ៥ កើតខែពិសាខ ឆ្នាំកុរ
ឧព្វស័ក តាំងលោកគ្រូ គឹម គិត នាមធម្មយោ បទុមត្ថេរ កើតឆ្នាំរ
អាយុ ៦៦ ឆ្នាំ វស្សា ៩ ជាចៅអធិការវត្តកុល ឃុំផុង ស្រុកគងពីស
កំពង់ស្ពឺ ។

(មានត)

សេចក្តីផ្តួចផ្តើម អំពីពុទ្ធសាសនបណ្ណិត្យ

ពុទ្ធសាសនបណ្ណិត្យ ជាមន្ទីរសិក្សាស្រាវជ្រាវការបោះពុម្ពផ្សាយទាំងវិជ្ជាខ្មែរ អានទាំងបាលី-
វិស្តុត ទាំងទាំងផ្នែកគតិលោក ទាំងផ្នែកគតិធម៌ ។

ថ្ងៃបើសព្វថ្ងៃនេះ ការបោះពុម្ពផ្សាយល់បាកពន់លោក ដោយហេតុខ្វះប្រែជាច់ប្រែជា
ម្រាប់រៀងពុម្ព ។ មិនមានបោះពុម្ពរៀងផ្សេងៗ ឲ្យបានស្មើរគ្នាទាន់កាលសម័យ ។
ពុទ្ធសាសនបណ្ណិត្យ ក៏នៅតែខំប្រឹងលើកបោះពុម្ពសៀវភៅថាស់ៗ ខ្លះ ដែលចំណាយ
ស់ហើ នឹងរៀងថ្មីៗ ខ្លះ ក្នុងឆ្នាំ ១៩៤៩ នេះ ។

រឿងថ្មី

ឯកសម្រាយ: មហាវេស្សន្តរជាតក . . . . . ជំពៃ ១ ក្បាល ១៦, ០០

ឯកថាលី: កង្ខាវិតរណី (អដ្ឋកថាជាតិមោក្ខ) (គន្ថមាលា សម្រាប់សាលាថាលី
ជាន់ខ្ពស់ កំពុងបោះពុម្ព)

រឿងដែលបានបោះពុម្ពហើយ

១— សត្តបរិត្ត - ទ្វាទសបរិត្ត . . . . . ជំពៃ ១ ក្បាល ១៤, ០០

២— ឃាមណោវាទ័ឃ . . . . . — ៥, ៥០

៣— អនុមោទនាវិធី . . . . . — ៦, ៥០

៤— នាគាជាតក . . . . . — ១២, ០០

៥— តិហិតបដិបត្តិ . . . . . —

(បំពុងបោះពុម្ពតទៅទៀត)

៦— ពាក្យសូមបត្តម្ត

៧— ធម្មបទភាគ១: ដែល១:ទាក

៨— ភាណវារៈបាលី

៩— សម្ពន្ធមាលា

១— វិន័យបាតិមោក្ខ

១— មង្គលត្ថទីបនី ភាគ១:ដែល១:ទាក

២— វិសុទ្ធិមគ្គ ភាគ១:ដែល១:ទាក

សូមអស់លោកដែលត្រូវការសៀវភៅទាំងប៉ុន្មានមុខទាំងលើនេះ ចូលទៅរកទិញបាន